គ្រួសារនិងប្រពៃណីជាតិ
COMMISSION DES MOEURS & COUTUMES

កាន្តសុទ្ធិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

INSTITUT BOUDDHIQUE

ឆ្នាំទី ២៩ លេខ ៧ ខែកក្កដា ព.ស. ២៥០០ គ.ស. ១៩៥៧





កម្ពុជសុរិយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ
បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មាតិកា	ទំព័រ
– វិរិយភាវ	ឃុនបណ្ណាសុវ័ត្ថ ប៊ុ-ប៊ូ	៦០៣
– អនាមតធម្មិ	ឃុនសុវត្ថិវេទី យូរ-អ៊ុន	៦១២
– និទានសុភាសិត	ព្រះមហា មៅ-ភាន់	៦១៩
ផ្នែកអក្សរសាស្ត្រ		
– សិល្បៈនិងអតីតនៃព្រះពុទ្ធរូបក្នុងប្រទេសខ្មែរ	លោក ភ័ឃ-ប៊ុត. ប្រែ	៦២៣
– រឿងទេវតាទួរបស់អម្រឹតឈ្មួញម៉ឺនក្បាល (តមក)	លោក ញ៉ុក-ថែម ពិនិត្យ	៦៣៧
– រឿងសាមកុក (តមក)	ឯកញ៉ា ន្ហ-កន ប្រែ	៦៤៤
– រឿងហ្សាតិត (តមក)	លោក ភ័ឃ - ប៊ុក ប្រែ	៦៤៩
– រឿងព្រះខាងអាព៉ាបុស្ដា	លោក ផេង-ត្រីវ ប្រែ	៦៥៤
កំណាត់ធម៌ប្រវត្តិសាស្ត្រ		
– សុន្ទរកថានិងសារលិខិត	លោក ភ័ឃ-ប៊ុក	៦៦៣
– បុណ្យឆ្លងវិហារវត្តរៀង ស្រុករៀង (កំពង់ធំ)	ព្រះគ្រូអនុគណ ពោង-តឹម	៦៧៥
– ពិធីបុណ្យ ព.ស. ២៥០០ នៃទៃត្រកំពង់ឆ្នាំង	ព្រះភិក្ខុ ទេព-សារុន	៦៨៩
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះភិក្ខុ ប៊ាង-ខាត់	៦៩២

មួយឆ្នាំមាន ១២ សៀវភៅ–ដំណែលជាវ ៤៣០រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÉRES

PARTIE RELIGIEUSE:

-Viriyakatha . . . . . par *M. BOU-PO.* 603
-Anamatadharma . . . . . par *M. YOU-OUN* 612
-Nidanasubhasit . . . . . par Vén. *MAU-KHANN* 619

PARTIE LITTERAIRE:

-L'art et le passé du Royaume khmer . . traduit par *M. RAY-BUC* . 623
-Histoire de Devanda de *M. MOK*,
revue et corrigée (suite) par *M. NHOC-THEM* 637
-Histoire de Samkok (suite) . . . . . traduit par *M. NOU-KAN* . . 644
-Histoire de Zadig . (suite) . . . . . traduit par *M. RAY-BUC* . . . 648
-Histoire de la princesse *ARAPOSKA*
traduit par *M. PHENG-CHRIV* . 654

NOTES ET CHRONIQUES:

-Discours et messages de *M. RAY-BUC*
lors de la célébration du Bouddha
Jayanti en Inde . . . . . par *M. RAY-BUC* . 663
-Fête de l'Inauguration du temple de Vat Rovieng, srok
de Rovieng (Kg. Thom) . . . par vén. *THONG-KIM*. 675
-Fêtede l'an2.500 de l'Ere Bouddhique
á Kg. Chhnang . . . . . par vén. *TEP-SAROUN*.689
-Dictionnaire Samskrit - Khmer (suite) . . . par vén. *PANG-KHAT* . . . 692

Prix d'abonnement annuel (comprenant 12 numéros): 230$00

អារ័យកថា

ឃុនបណ្ណានុរ័ក្ស ប៊ូ.ប៊ូ រៀបរៀង

ប្រកួតក្នុងពិធីបុណ្យ ព.ស. ២៥០០ ជាប់លេខ ១

ពាក្យផ្តើម

ព្រះសក្យមុនីគោតមសម្មាសម្ពុទ្ធ ជាបវរមគ្គនៃយើង ព្រះអង្គទ្រង់ជា
ជាបញ្ញាធិក ទំព្យាយាមបំពេញបារមី ៣០ ប្រការ ចំនួន៤៨ អសង្ខេយ្យ
ទីឆ្ងាំកន្លៃមួយសែនកប្ប ទើបបានត្រាស់ជាព្រះពុទ្ធ ។ ក្នុងព្រះជាតិដែល
បានត្រាស់នោះ មុនដំបូង ព្រះអង្គលះបង់ពាសម្បត្តិ ស្តេចចេញពីព្រះ
នគរទៅទ្រង់ព្រះផ្នួស គង់នៅក្នុងព្រៃតែមួយព្រះអង្គឯង ទំតាំងព្រះទ័យ
ព្យាយាមធ្វើអំពើជំកម្រើកក្រៃ ដែលគ្មានអ្នកណាត្រាប់បាន (ទុក្ករកិរិយា)
ដើម្បីឲ្យដល់ទីរលត់ទុក្ខ (និព្វាន) ចំនួន ៦ ឆ្នាំ ទើបបានត្រាស់ ហើយ
ទ្រង់ទំព្យាយាមសំដែងធម៌ ប្រោសពុទ្ធបរិសទ្ធឲ្យសត្វជាច់មិនជាច់ជាកបដល់
ថ្ងៃបួលនិព្វានចំនួន ៤៥ ឆ្នាំ ទាល់តែកើតមានពួកពុទ្ធបរិស័ទទាំងព្រះសង្ឃ
ទាំងគ្រហស្ថជាច្រើនពាប់មិនអស់ ដោយសារតែព្រះអង្គព្យាយាម សំដែង
ធម៌វិន័យពន្យល់ឲ្យកើតសទ្ធាជ្រះថ្លា ជឿកម្ម ទីឆ្ងាំជឿលបស់កម្ម ។

កាលព្រះអនុត្តញ្ញាណ បរិនិព្វានទៅហើយ ព្រះធម៌ទីឆ្ងាំព្រះវិន័យ
ជានុកាទនៃព្រះអង្គនោះ មិនរលត់ជាត់បង់ទៅឆាងឡើយ នៅតាំងទ្រង់បិត

ថវចៈកាល ជាប់រហូតមក ចាន ๒๙๐๐ ឆ្នាំហើយនេះ ដោយសារតែពួកពុទ្ធបរិស័ទចាំដ៏ព្រះសង្ឃ ចាំដ៏គ្រហស្ថ មានព្យាយាម ខំប្រឹងប្រតិបត្តិថែរក្សាតៗគ្នាមក ជាច្រើនដំណាបុត្តបុរស ។

គម្ពីរក្នុងច្បាប់ខាងព្រះពុទ្ធសាសនា មានចំនួនច្រើនណាស់ ដែលសំដែងរៀបរាប់សរសើរ អំពីសេចក្តីព្យាយាមថាជាគុណធម៌ដ៏សំខាន់ អាចផ្តល់ឲ្យចានសម្រេចផលប្រយោជន៍ តាមកំឡាំងព្យាយាមរបស់ខ្លួន។ ដូចជាកូនសិស្ស ដែលព្យាយាមរៀនសូត្រខ្លាំងក្លា ក៏ចានចេះដឹងច្រើនច្រះ, អ្នកព្យាយាមធ្វើការច្រើន ក៏ចានទ្រព្យសម្បត្តិបរិបូណ៌, អ្នកព្យាយាមប្រតិបត្តិធម៌យ៉ាងតឹងរ៉ឹង ក៏ចានសម្រេចមគ្គផលដល់ទីបំផុតទុក្ខ សមតាមព្រះពុទ្ធភាសិត ๑ បទ ក្នុងគម្ពីរសុត្តន្តបិដក ខុទ្ទកនិកាយ សុត្តនិបាត ថាៈ

វីរិយេន ទុក្ខមច្ចេតិ មនុស្សត្ថេន ទុតទុក្ខចាន ព្រោះសេចក្តីព្យាយាម ។

អធិប្បាយៈ សេចក្តីលំបាកចិត្ត, ព្រួយចិត្ត, មិនសប្បាយចិត្ត ហៅថា ទុក្ខ ។ ទុក្ខនេះ មានច្រើនចំពូកណាស់ ទើនរៀបរាប់ឲ្យចប់សព្វគ្រប់ក្នុងទីនេះមិនចានទេ ។ សេចក្តីខ្សត់ក្រ, ខ្វះខាតអាហារគោជនទើនខ្វះខាតសំលៀកបំពាក់, ខ្វះខាតគ្រឿងប្រើប្រាស់ផ្សេងៗ ជាដើម ក៏ជាទុក្ខ ๑ យ៉ាង ។ ការដែលទើនធ្វើឲ្យផុត ពីទុក្ខខ្សត់ក្រ, ពីទុក្ខខ្វះខាតនេះចាន ព្រោះតែព្យាយាមប្រឹងប្រែងធ្វើការ, ព្យាយាមស្វះស្វែងរកទ្រព្យសម្បត្តិឲ្យចាន ដោយផ្លូវសុចរិតត្រឹមត្រូវ តាមច្បាប់លោក ច្បាប់ធម៌ ។ នៅពេលកំពុងរៀនសូត្រក្តី កំពុងធ្វើការអ្វី ។ក្តី តែងឮឡើយហត់លំបាក

រូបកាយ, ព្រួយចិត្តគំនិត ដោយទំគិតគូរ ចួនកាលទៅជាបរិភោគបាយ មិនឆ្ងាញ់ អាស្រ័យដំណេកមិនលក់ ខាល់តែឈឺចាប់ក៏មាន នេះជាទុក្ខ ๑ យ៉ាង ។ ការដែលនឹងធ្វើឲ្យផុតពីទុក្ខទៀយហាត់ នឹងព្រួយចិត្តនេះបាន ព្រោះតែព្យាយាមអត់ទ្រាំ ចេះតែរៀនសូត្រហូតទៅ មិនឈប់រៀន កណ្តាលទី ព្យាយាមអត់ទ្រាំធ្វើការខាល់តែរួចស្រេច មិនទំលាក់ចោលខាក់កណ្តាលការ ។ អ្នកដែលត្រូវគេបន្ទោស, ត្មះតិះដៀល, ដេរស្តីកំភើតទុក្ខក្តៅក្រហាយចិត្ត ។ ការដែលនឹងធ្វើឲ្យផុតពីទុក្ខក្តៅក្រហាយចិត្តនេះបាន ព្រោះតែព្យាយាមអត់ធ្មត់ ដោយពិចារណាលោកធម៌ ๘ យ៉ាង គឺមានលាភ ๑ គ្មានលាភ ๑ មានយស ๑ គ្មានយស ๑ និន្ទា ๑ សរសើរ ๑ សុខ ๑ ទុក្ខ ๑ ឲ្យឃើញថា ធម៌ ๘ នេះ តែងប្រែប្រួលផ្លាស់ប្តូរគ្នា ជាធម្មតា មិនខៀងខាត់ទេ ។ ខ្ជិនប្រាណមានជម្ងឺឈឺចាប់ កំភើតទុក្ខព្រួយចិត្ត ។ ការដែលនឹងធ្វើឲ្យផុត ពីទុក្ខព្រួយចិត្តនេះបាន ព្រោះតែព្យាយាមអត់សង្កត់ចិត្ត ដោយពិចារណាព្រះត្រៃលក្ខណ៍ថា រូបមិនខៀង, រូបជាទុក្ខ, រូបមិនមែនខ្ជិនប្រាណ ឬពិចារណាធម៌ ๙ ប្រការថា យើងចាស់ដក ជាធម្មតា គេចមិនផុតពីចាស់ដកទេ ๑ យើងមានជម្ងឺឈឺចាប់ ជាធម្មតា គេចមិនផុតពីជម្ងឺឈឺចាប់ទេ ๑ យើងមានសេចក្តីស្លាប់ ជាធម្មតា គេចមិនផុតពីសេចក្តីស្លាប់ទេ ๑ យើងព្រាត់ប្រាសពីមនុស្សសត្វនឹងវត្ថុជាទីស្រឡាញ់ពេញចិត្ត ជាមិនខាន ๑ យើងមានកម្មជាបៃស់ខ្ជិន ๑ ។ ការកើតនឹងស្លាប់ ក៏ជាទុក្ខ ។ មនុស្សនឹងធ្វើឲ្យផុតពីកើតនឹងស្លាប់បាន ព្រោះតែ ព្យាយាមប្រព្រឹត្តធម៌ ចំរើនអដ្ឋង្គិកមគ្គ ๘ ប្រការ គឺសម្មាទិដ្ឋិ

ប្រាជ្ញាយល់ឃើញត្រូវ ๑ សម្មាសង្កប្បៈ សេចក្តីត្រិះរិះត្រូវ ๑ សម្មាវាចា សំដីត្រូវ ๑ សម្មាកម្មន្តៈ ការងារត្រូវ ๑ សម្មាអាជីវៈ ការចិញ្ចឹមជីវិតត្រូវ ๑ សម្មាវាយាមៈ ព្យាយាមត្រូវ ๑ សម្មាសតិ ការរលឹកត្រូវ ๑ សម្មាសមាធិ ការដំកល់ចិត្តឲ្យនឹងត្រូវ ๑ ។

អដ្ឋង្គមគ្គ ๘ នេះ រួមចូលជាសិក្ខា ๓ គឺសម្មាទិដ្ឋិនឹងសម្មាសង្កប្បៈ ๒ នេះ ជាអធិប្បញ្ញាសិក្ខា; សម្មាវាចា, សម្មាកម្មន្តៈ នឹងសម្មាអាជីវៈ ๓ នេះ ជាអធិសីលសិក្ខា; សម្មាវាយាមៈ, សម្មាសតិ នឹងសម្មាសមាធិ ๓ នេះ ជាអធិចិត្តសិក្ខា ។ ព្រះពុទ្ធវចនៈទាំងអស់ដែលហៅថា ព្រះត្រៃបិដក រួមឲ្យខ្លី នៅតែត្រឹមសិក្ខា ๓ នេះឯង ។ បើអ្នកណាព្យាយាមប្រព្រឹត្តសិក្ខា ๓ នេះចប់ អ្នកនោះទើបផុតពីទុក្ខ ព្រោះកើតនឹងស្លាប់ ។

"ព្យាយាម" ជាភាសាកណ្តាល ព្រោះព្យាយាមធ្វើល្អក៏មានព្យាយាមធ្វើអាក្រក់ក៏មាន ។ ត្រង់ព្រះពុទ្ធភាសិតថា "មនុស្សធ្វើនឹងផុតទុក្ខបាន ព្រោះសេចក្តីព្យាយាម" នោះ សំដៅយកព្យាយាម ក្នុងផ្លូវត្រូវ, ផ្លូវល្អ (សម្មាវាយាមៈ) មិនមែនសំដៅយកព្យាយាម ក្នុងផ្លូវខុស, ផ្លូវអាក្រក់ (មិច្ឆាវាយាមៈ) ទេ ។ អ្នកព្យាយាមលះអាក្រក់ ហើយធ្វើល្អ ឈ្មោះថា ព្យាយាមក្នុងផ្លូវត្រូវ ។ អ្នកព្យាយាមធ្វើអាក្រក់ ដូចជាលួច, ឆក់, កុហកបញ្ឆោតបោកប្រាស់យកទ្រព្យសម្បត្តិគេ ដើម្បីឲ្យផុតពីភ័យទុក្ខទ័លក្រ ឈ្មោះថា ព្យាយាមក្នុងផ្លូវខុស មិនពាប់ថា ព្យាយាមឲ្យផុតទុក្ខទេ ព្រោះអ្នកលួចទ្រព្យគេ រឹតតែថែមទុក្ខទ្វេទ្បាំងឡើងទៀត ដោយហេតុមានទោសតាមច្បាប់សម្រាប់ប្រទេសក្នុងបច្ចុប្បន្នផង មានទោសទៅ

បរិសោក តាមច្បាប់ពុទ្ធសាសនាជាដើម ដូចសុភាសិតខ្មែរបុរាណថា "លួចគេវាគ្រាន់តែគេចាន់ក្រែល" ។

ព្រះបរមសោកនាថ ទ្រង់ត្រាស់ណែនាំពួកសាវក ឲ្យមានសេចក្តីព្យាយាមខាងផ្លូវត្រូវ, ផ្លូវល្អ ដោយន័យច្រើនប្រការ ដូចទ្រង់ច្រាប់ពួកសាវកឲ្យត្រាប់សត្វកណ្តៀរថា ខ្លួនកណ្តៀរគួចសោះទេ ប៉ុន្តែវាអាចធ្វើដ៏ឲ្យកើតទៅជាធំបូកធំសំបើម លើសមាឌវាបាន ព្រោះតែវាព្យាយាមពាំដំបន្តិចម្តងៗ មិនឈប់ ។ អ្នករៀនវិជ្ជាផ្លូវលោក ចូរត្រាប់តកណ្តៀរ ដែលរៀនបានចេះដឹង ព្រោះតែព្យាយាមរៀនរឿយៗ បន្តិចម្តងៗ តាមវេលាមិនអាក់ខាន មិនមែនបានចេះដឹង ព្រោះមានប្រាជ្ញាច្រើនទេ ។ អ្នកកេត្រឲ្យសម្បត្តិ ចូរត្រាប់តកណ្តៀរ ដែលវាកេបានសម្បត្តិច្រើន ព្រោះតែព្យាយាមសន្សំពុកឆាក់ ទឹងព្យាយាមធ្វើការងារ មិនមែនវាកេឲ្យបានច្រើន ព្រោះតែមានដើមទុនច្រើនទេ ដូចសុភាសិតខ្មែរបុរាណថា "ចេះតែរៀន មានតែវាក; តក់ៗ តេញចំពង់ ធុងៗ កន្ទុះគ្រហែត; តួងតាងដេកផ្លូវ សូវៗ ដល់ផ្ទះ" ។ អ្នកប្រតិបត្តិធម៌ ចូរត្រាប់តកណ្តៀរត្រូវព្យាយាមប្រតិបត្តិធម៌ ឲ្យហូរហែតាមលំដាប់គឺ សីល, សមាធិ, បញ្ញា ឬ ទាន, សីល, ភាវនា ជារឿយៗទៅ កុំធ្វើបង្ខំតែ ១ ថ្ងៃ ឲ្យកើតធម៌ពាំងអស់ ។ មនុស្សបុថុជ្ជន ក្លាយទៅជាព្រះអរិយៈច្រើនណាស់ ក៏មិនអស់ទេ ព្រោះតែលោកព្យាយាម កំចាត់បង់អាក្រក់ចេញ ហើយព្យាយាមធ្វើល្អវិញ ។ ឯសេចក្តីព្យាយាម ដែលលំបាកធ្វើជាងគេបំផុត សំដៅយកត្រង់ព្យាយាម ៤ យ៉ាង (សម្មប្បធាន) គឺ

๑- សំវរប្បធាន ព្យាយាមរក៏ងប្រយ័ត្នការពារសេចក្តីអាក្រក់ ដែលមិនទាន់កើត មិនឲ្យកើតមានឡើង ក្នុងកាយក៏ចាចិត្តផង ។

๒- បហានប្បធាន ព្យាយាមកំចាត់បង់សេចក្តីអាក្រក់ (๑) ដែលកើតមាន ក្នុងកាយក៏ចាចិត្តរួចពីមុនមក ហើយឲ្យដាច់ស្រះស្រឡះចេញ ។

๓- ភាវនាបធាន ព្យាយាមធ្វើសេចក្តីល្អ (๒) ដែលមិនទាន់កើតមាន ក្នុងកាយក៏ចាចិត្ត ឲ្យកើតមានឡើង ដែលកើតមានស្រាប់ហើយធ្វើឲ្យរឹតតែចំរើនច្រើនឡើង ។

๔- អនុរក្ខនាបធាន ព្យាយាមរក្សាសេចក្តីល្អដែលធ្លាប់កើតមាន ក្នុងកាយក៏ចាចិត្ត រួចពីមុនមកហើយ មិនឲ្យសេត់សោយ ចាត់បង់ទៅវិញ ។

សេចក្តីព្យាយាមទាំង ๔ យ៉ាងនេះ បំប្រួញឲ្យតិច នៅត្រឹមតែ ๒ យ៉ាង គឺ ព្យាយាមលះអាក្រក់ ๑ ព្យាយាមធ្វើល្អ ๑ ។

លោកដែលចូនសម្រេចមគ្គផល ដល់ព្រះនិព្វានជាទីផុតទុក្ខនោះ ព្រោះតែលោកមានសេចក្តីព្យាយាមទាំង ๔ យ៉ាង ដូចពាក្យខាងដើមពេញលេញ ឥតខ្វះកន្លះ ដូចមានអតីតនិទាន ក្នុងគម្ពីរអដ្ឋកថាធម្មបទថា បុត្រមហាសេដ្ឋីម្នាក់ ចូនស្តាប់ធម្មទេសនា នៃព្រះទសពល កើតចិត្តជ្រះថ្លាក្រៃលែង តក់ស្លុតនឹងរូបកាយ ស្រឡាញ់គេចអ្នកបួសថាជាគេចធ្វើឲ្យផុតទុក្ខ ទើបប្រគល់សម្បត្តិទាំងអស់ ឲ្យប្អូនប្រុសថែរក្សា រួចចូល

๑ ជាប, អកុសល; ទុច្ចរិត ។ ๒ បុណ្យ; កុសល; សុចរិត ។

បួសជាតិក្ខុ កន្លងសំណាក់ព្រះសព្វញ្ញូ ហើយទ្រទ្រង់វិបស្សនាធុរៈ តាំងព្រះ
ទ័យថា កន្លងវស្សា ៣ខែ មិនសឹងនិសោះប្រើតែឥរិយាបថ ៣ គឺឥន្ទ, ឈរ,
ឱនឱមន្តប៉ុណ្ណោះ ។ ព្រះថេរៈព្យាយាមឥតចំរើនសមណធម៌ តាំងថ្ងៃ
តាំងយប់ មិនសឹងតាំងពីខែ១ រហូតដល់ខែ២ កំចាប់ឈឺព្រះនេត្រ ។
គ្រូពេទ្យសូត្បាំប្រេង ប្រគេនទូលឲ្យសឹងឋន្តក់ ។ ព្រះថេរៈមិនព្រមសឹង
បន្តក់សោះ ចេះតែតង់បន្តក់ពាល់លើក ។ ឯថ្នាំប្រេង មិនស្រក់ចូល
ក្នុងព្រះនេត្រឡើយ ថែរជាហូរចូលក្នុងច្រមុះវិញ ។ ពុកជាគ្រូពេទ្យខឹង
អង្វរកា ឲ្យសឹងបន្តក់ថ្នាំដូចម្តេច ក៏ព្រះថេរៈនៅតែតង់បន្តក់ថ្នាំដដែល មិន
ព្រមសឹងបន្តក់សោះ ព្រោះលោកខ្ទាបជាប់អធិដ្ឋានថា មិនសឹង ៣ខែ ។
តមក ព្រះនេត្រតែងឈឺខ្លាំងឡើង មើលអ្វីលែងឃើញ ទឹកព្រះនេត្រ
ហូរសស្រាក់ ដូចទឹកហូរចេញពីត្អមដូច្នេះ ។ ឯគ្រូពេទ្យទាល់គំនិត ក៏ទូល
លាព្រះថេរៈសូមឈប់ លែងរក្សាពេតព្រះនេត្រតទៅ ។ លំដាប់នោះ
ព្រះថេរៈចំព្យាយាម ខ្ជួនខ្ជួនលោក តាមផ្លូវព្រះវិន័យកូណ៍ថា ៖

"នែភាវុសោ ចាលិត! ឥឡូវនេះគ្រូពេទ្យចោះបង់ចោលអ្នកឯង
ហើយ, អ្នកនិយាយទៅមើល, អ្នកស្រឡាញ់ក្អែក ឬស្រឡាញ់ព្រះពុទ្ធ-
សាសនា? ក្អែកអ្នកខ្វាក់ច្រើនជាតិណាស់ហើយ ពាប់មិនអស់ទេ សូម្បី
ព្រះពុទ្ធពាប់សែនព្រះអង្គ ក៏ពាំបានណាតដើមកំណើត របស់អ្នកឯងមិន
ឃើញដែរ, នែចាលិត! បើក្អែកអ្នកខ្វាក់ ក៏ខ្វាក់ទៅចុះ, បើគ្រូពៀក
អ្នកថ្ងន់ ក៏ថ្ងន់ទៅចុះ, រូបកាយអ្នកបែកធ្លាយស្លាប់ ក៏ស្លាប់ទៅចុះ អ្នកកុំ
ស្តាយក្អែក, គ្រូពៀក ឱនរូបកាយឡើយ, អ្នកត្រូវស្តាយតែព្រះពុទ្ធ-

សាសនា, ត្រូវរក្សាតែព្រះពុទ្ធសាសនាមប៉ុន្ណឹង " ។

ព្រះថេរៈព្យាយាមតង់ខ្ជាន់ខ្ជួនលោកយ៉ាងនេះ គាំងពីព្រះនេត្រនៅមិនទាន់បែកខ្ចាក់ រហូតដល់ថ្ងៃ ដែលព្រះនេត្របែកខ្ចាក់ ក៏បានសម្រេចព្រះអរហត្តផល ដំណាលនឹងពេល ដែលព្រះនេត្របែកខ្ចាក់ ដោយហេតុនេះ ទើបមានព្រះនាមថា ព្រះចក្ខុបាលត្ថេរ ។

ការព្យាយាមកំចាត់បង់អំពើអាក្រក់ចេញ ហើយព្យាយាមធ្វើតែអំពើល្អវិញ ជាការក្រណាស់, ជាការតឹងតែងណាស់ ដូចឧបាសកឧបាសិកាអ្នករក្សាសីល ៥, សីល ៨, សីល ១០ ត្រូវតែព្យាយាមតមត្រណម តាមសិក្ខាបទនៃសីលនោះៗ ឲ្យសព្វគ្រប់ ដោយម៉ត់ចត់ ទើបអាចរក្សាសីលជាប់លាប់រហូតទៅបាន ។ ចំណែកភិក្ខុសាមណេរ ត្រូវតែព្យាយាមលះវៀរអំពើអាក្រក់ ដែលតាស់ខុសនឹងពុទ្ធប្បញ្ញត្តិចេញ ហើយព្យាយាមប្រព្រឹត្តអំពើល្អត្រឹមត្រូវ តាមពុទ្ធានុភាព ទើបអាចរក្សាផ្លូវជាប់ជានិច្ចទៅបាន ។ នៅវេលាដែលកំពុងតែព្យាយាម លះអាក្រក់ធ្វើល្អនោះ មិនមែនជាការសុខស្រួល សប្បាយចិត្តទេ សុទ្ធតែជាការតតែនក្នុងព្រួយចិត្តគាំងអស់ ។ ប៉ុន្តែ ទុក្ខនេះមិននៅគ្រាំគ្រែងជាប់រហូតដល់ស្លាប់ទេ បើបានសម្រេចផលប្រយោជន៍ ជាលោកិយៈឬជាលោកុត្តរៈពេលណា ពេលនោះទើបបានសុខសប្បាយ (អកាលិកៈ) ។

សេចក្តីព្យាយាមលះអាក្រក់ ធ្វើល្អ មានគុណសំខាន់ណាស់ គាំងខាងតតិលោក គាំងខាងតតិធម៌ សូមពុទ្ធជនគាំងឮយល់ច្បាប តាមលំអានព្រះពុទ្ធដីកាដូចតទៅនេះ ៖

សេចក្តីព្យាយាមធ្វើការងារ ឬ ប្រតិបត្តិធម៌ មានគុណឲ្យបាន
សម្រេចផលប្រយោជន៍ តាមប្រាថ្នា (វីរិយិទ្ធិបាទ);
- មានគុណធ្វើឲ្យចិត្តក្លាហាន (វេសារជ្ជករណធម្មា);
- មានគុណ ជាកំឡាំង អាចត្រាបសង្កត់សេចក្តីខ្ជិលច្រអូស នូវអកុសល
ពាំងពួងបាន (វីរិយពលំ);
- មានគុណ ជាធំក្នុងការកំចាត់អកុសលពាំងពួងបាន (វីរិយិន្ទ្រិយំ);
- មានគុណ ឲ្យបានដឹងច្បាស់នូវចតុការិយសច្ច (វីរិយសម្ពោជ្ឈង្គោ);
- មានគុណ ឲ្យបានសម្រេចលោកិយផល នូវលោកុត្តរផល (សម្ម-
ាវាយាមោ) ។ល។

សម្តេចព្រះជិនស្រី ទ្រង់ត្រាស់សរសើរគុណ នៃសេចក្តីព្យាយាម
ដោយន័យច្រើនប្រការ ដូចសេចក្តីខាងដើម ប៉ុន្តែ ព្រះអង្គទ្រង់ត្រាស់
បញ្ចប់ ដោយព្រះពុទ្ធដីកា ១ បទថា៖

"វីរិយេន ទុក្ខមច្ចេតិ មនុស្សត្រូវនូវធុតទុក្ខបាន ព្រោះសេចក្តីព្យាយាម"
ដូចមានអត្ថាធិប្បាយមកនេះឯង ។

ជ័យោ ព្រះពុទ្ធសាសនា!

អនាមតធម៌

ឃុនសុវត្ថិវង្ស ប្បូរ-អ៊ុំធ រៀបរៀង

ប្រកួតក្នុងពិធីបុណ្យ ព.ស. ២៥០០ វិស្សា

តែដោយអ្នករៀបរៀងធម៌នេះ ជាសមាជិកនៃគណៈកម្មការត្រួតអត្ថបទប្រកួតដែរ ទើបគណៈកម្មការសម្រេចឲ្យដាក់ចេញ, អត្ថបទនេះក៏មិនបានប្រកួតទៅវិញ

សូមថ្វាយបង្គំចំពោះព្រះរតនត្រ័យ

គឺព្រះពុទ្ធ ព្រះធម៌ និងព្រះសង្ឃ ដោយសេចក្តីគោរព !

យម្ហិ សទ្ធា ន ឱក្កា ច អហិំសា សញ្ញមោ ទមោ
ឯតនវិយា សេវន្តិ ឯតំ លោកេ អនាមតំ ។

សូមថ្វាយបង្គំព្រះគុណាគ្រប់ព្រះអង្គ !

សូមជំពាក់ចអស់លោក-អ្នកតុលាការ !

ថ្ងៃនេះជាថ្ងៃមានឫក្សជោគជ័យ ដល់ព្រះពុទ្ធសាសនា ដោយខ្មែរយើងទាំងប្រទេស បានធ្វើមហាបុណ្យពុទ្ធសករាជ ២៥០០ វិស្សា ដ៏ជាមហោឡារិកអធិកអស្ចារ្យ ។ ឧកាសនេះ ខ្ញុំព្រះករុណា ខ្ញុំប្រចាំ ខ្ញុំបាទ សូមថ្វាយនូវអនាមតធម៌ ប្រគេន ជូន ជាទីសណ្តាប់ ដើម្បីជាផ្លូវប្រតិបត្តិដូចតទៅនេះ ៖

មុនឡើងសំដែងអនាមតធម៌នោះ សូមសំដែងអំពីពុទ្ធកិច្ច (កិច្ចនៃព្រះពុទ្ធ) ដើម្បីជម្រាលសេចក្តីពីខាងដើមទៅបន្តិចសិន ។

ព្រះសម្ពុទ្ធបរមគ្រូរបស់យើង ចាប់តាំងអំពីព្រះអង្គបានត្រាស់ដឹងនូវសព្វញ្ញុតញ្ញាណហើយ ព្រះអង្គតែងទ្រង់ចំពេញនូវពុទ្ធកិច្ច ៥ យ៉ាងរាល់ថ្ងៃ ឥតដែលអាក់ខាន; ពុទ្ធកិច្ច ៥ យ៉ាងនោះគឺ

១ - កុងវេលាព្រឹកត្រហាម ស្តេចយាងទៅប្រោសសត្វ ដោយការទ្រង់ចំណូលចិត្ត ។

២ - កុងវេលាថ្ងៃរសៀល ទ្រង់សំដែងព្រះធម៌ដល់ចតុព្វិធបរិស័ទ ។

៣ - កុងវេលាជិតព្រលប់ ទ្រង់ប្រទានឧវាទដល់ពួកភិក្ខុ ។

៤ - កុងវេលាពាក់កណ្តាលអធ្រាត្រ ទ្រង់ដោះប្រស្នាចំពោះទេវតា ។

៥ - កុងពេលបែកបច្ចូសគឺពេលជិតថ្ងៃរះ ទ្រង់ប្រមើលមើលពុទ្ធនិស្ស័យសត្វដែលគួរប្រោស ១ ។

ចំពោះព្រះធម៌ដែលព្រះអង្គសំដែងមក អស់រយៈវេលា ៤៥ វស្សានោះ សឹងមានកុងគម្ពីរព្រះត្រៃបិដក ។ ព្រះធម៌ទេសនានេះហើយដែលជាព្រះពុទ្ធសាសនា ។ អាយុព្រះពុទ្ធសាសនា កប់ចាប់តាំងអំពីព្រះអង្គបរិនិព្វានទៅ រហូតមកដល់ឆ្នាំនេះ ត្រូវជា ២៥០០ វស្សា ។ ព្រះពុទ្ធសាសនា ដែលមានអាយុយឺនយូរយ៉ាងនេះ តើមកអំពីអ្វី ? មកអំពីកុងដៃព្រះពុទ្ធសាសនា សឹងពេញទៅដោយពាក្យពិត ជាពាក្យសមហេតុសមផល ។ អ្នកប្រាជ្ញជាន់ក្រោយពុទ្ធកាល ច្រើនជាតិច្រើនប្រទេសបានសើរើ ពិនិត្យមើលព្រះពុទ្ធសាសនា ឃើញគ្នាខាស់ខុស បានអនុម័តយល់ព្រមប្រកាសថា ព្រះពុទ្ធសាសនា ជាសាសនាឯកកុងលោក ។

មួយទៀតព្រះសម្ពុទ្ធដែលជាអ្នកតាំងសាសនានេះ ព្រះអង្គមានអនាមតធម៌ក្នុងសន្តាន គឺព្រះអង្គមានធម៌មិនស្ងាប់ក្នុងព្រះទ័យ ទើបសាសនាព្រះអង្គមិនបាត់បង់ទៅ អាចប្រតិស្ឋាននៅក្នុងលោក រហូតមកដល់ថ្ងៃនេះ ។

ពុទ្ធកាសិតដែលខ្ញុំលើកឡើង ជាទំនៃបបទខាងដើមនោះ ក៏ជាសុភាសិតដែលព្រះអង្គសំដែង អំពីអនាមតធម៌នេះឯង ។ ដូច្នេះ ខ្ញុំនឹងសំដែងន័យអនាមតធម៌នោះជូនជាសណ្តាប់ ដូចតទៅនេះ ៖

អនាមតធម៌ ប្រែថា ធម៌ធ្វើមិនឲ្យស្លាប់ គឺមិនឲ្យស្លាប់ក្តីឈ្មោះ ។ តួយ៉ាងដូចព្រះសម្ពុទ្ធជាម្ចាស់នៃយើង កាលព្រះអង្គគង់ព្រះជន្មនៅឡើយ ទ្រង់ប្រាប់បំពេញអនាមតធម៌ក្នុងសន្តាន ទ្រង់ក៏ប្រាប់ជាសាស្តាអស្ចារ្យក្នុងលោក សូម្បីព្រះអង្គបរិនិព្វានបាត់ទៅក៏ពិត តែគុណធម៌ដែលព្រះអង្គប្រព្រឹត្ត ឥតបាត់បង់ទៅជាមួយព្រះអង្គទេ នៅផ្សាយក្តីរុងរឿងគុណរបស់ព្រះអង្គ ស្ទើរតែសត្វប្រទេសក្នុងលោក ហាក់ដូចជាព្រះអង្គមិនទាន់បរិនិព្វាន នៅនឹមន្តទេសន៍ប្រាប់សត្វជាធម្មតា ពាំងនេះក៏មកអំពីព្រះអង្គមានអនាមតធម៌ក្នុងសន្តាន ។

អនាមតធម៌នោះ មានប្រភេទចែកចេញជា ៩ ប្រការ ដោយពុទ្ធភាសិតថា :

យម្ហិ សច្ចញ្ច ធម្មោ ច ។ល។ ឯតំ លោកេ អនាមតំ

ប្រែថា គុណធម៌ ៩ ប្រការ គឺ សច្ចៈ ១ ធម្មៈ ១ អហិំសា ១ សញ្ញមៈ ១ ទមៈ ១ មានក្នុងបុគ្គលណា ព្រះអរិយៈពាំងឡាយ តែងតប់រក

ប្គុគ្គលនោះ, គុណធម៌មានសច្ចៈជាដើមនេះ ឈ្មោះថា អនាមតធម៌ (ធម៌ធ្វើមិនឲ្យស្ងាប់) តែងប្រតិស្ឋាននៅក្នុងលោក ។

ក្នុងចំនេះ ខ្ញុំនឹងអធិប្បាយអំពីគុណធម៌ទាំង៩នេះ ជាន័យជាន់ក្នុងលោ តាមសមគួរដល់កាលវេលា ដើម្បីជាសាធារណៈប្រតិបត្តិនៃសាធុជន ។

១- សច្ចៈ ការប្រព្រឹត្តិកាយវាចា ស្របគ្នានឹងចិត្តពិត ។ ឈ្មោះថា សច្ចៈ គឺថាបើធ្វើអ្វីដោយកាយក្តី ដោយវាចាក្តី កំឲ្យចិត្តព្រមធ្វើផង ទើបឈ្មោះថា សច្ចៈ បើធ្វើតែកាយនឹងវាចា ចំណែកចិត្តមិនព្រមធ្វើ ដូចក្អាយបង្គិសោះតែកុំឲ្យគេថា ពោលវាចាសោះតែមិននិយាយកេ ដូច្នេះឲ្យឈ្មោះថា សច្ចៈ មិនបាន ។ បើពោលដោយសេចក្តីពិត សច្ចៈនោះបានដល់កាពជាអ្នកខ្មៅត្រង់នឹងមិត្តសំឡាញ់, ខ្មៅត្រង់ចំពោះកាលវេលា ដែលជាគេលត្រូវបួលត្រូវចេញ, ខ្មៅត្រង់ចំពោះកិច្ចការដែលជាមុខនាទីខ្លួនត្រូវធ្វើ, ខ្មៅត្រង់នឹងចៅហ្វាយ, មានកតញ្ញូកតវេទីចំពោះអ្នកមានគុណ ទាំងនេះ ហៅថា សច្ចៈ ។

សច្ចៈនេះជាធម៌សំខាន់មួយ ក្នុងកិច្ចការរបស់មនុស្ស មិនថាកិច្ចការនោះជាផ្លូវលោកឬផ្លូវធម៌ទេ ដែលនឹងសម្រេចកើតការ សមតាមសេចក្តីប្រាថ្នាទៅបាន ក៏ដោយសារមានសច្ចៈជួយទំនុកបំរុង ព្រោះធ្វើអ្វីធ្វើពិតតិតអ្វីតិតមែន រៀនអ្វីរៀនមាំ រមែងបានទទួលផលពិតផលមែនដូចគ្នា ។ ប្គុគ្គលអ្នកតាន់សច្ចៈខ្មៅត្រង់ ដូចអង្គព្រះសម្ពុទ្ធ ប្រៀបដូចបានកែវដ៏មានដំឡៃ ព្រោះអាចដឹកនាំប្រជុំជន ឲ្យមានសេចក្តីស្រឡាញ់ គោរព កាន់តាន

មានកេរ្តិ៍ឈ្មោះក្រអូបសព្វទិស សព្វកាលរកខ្ចីបំផុតគ្មាន ។

២. ធម្ម: កុងខ័នេះ សំដៅយក គារវធម៌ គឺសេចក្តីគោរព ។ ចុះអំពើបែបណា ហៅថា សេចក្តីគោរព ? ការក្រាបសំពះនូវបុគ្គលគួរសំពះ, ការក្រោកទទួលនូវបុគ្គលគួរក្រោកទទួល, ការឲ្យទីដេកទីអង្គុយដល់បុគ្គលគួរឲ្យ, ការធ្វើសក្ការៈបូជាដល់បុគ្គលគួរបូជា ហៅថា សេចក្តីគោរព ។

សេចក្តីគោរពនេះ ជាគុណសំខាន់របស់ជនគ្រប់ជាន់ ជាគ្រឿងអប់រំសាមគ្គីឲ្យរឹងប៉ឹង ទាំងជាគុណនាំឲ្យកើតមានសួស្តីជយមង្គល ។ មែនពិតប្រជុំជនដែលរួមគ្នានៅជាពួក ។ គេត្រូវតាំងមនុស្សម្នាក់ ឲ្យជាប្រមុខសម្រាប់មើលសុខទុក្ខ, ជនក្រៅពីនេះ ត្រូវគោរពស្តាប់អ្នកប្រមុខនោះ, ឯជនជាអធិបតី ក៏គប្បីគោរពប្បាប់ គឺគាន់យុត្តិធម៌ មិនលំអៀងដោយអំណាចអគតិ ។ ដូចជាព្រះសម្ពុទ្ធជាម្ចាស់ ព្រះអង្គទ្រង់គោរពព្រះធម៌ដែលព្រះអង្គបានត្រាស់ដឹងហើយ គឺព្រះអង្គកាន់តតឲ្យគាស់ខុសពីគន្ធង់ធម៌ ទើបព្រះអង្គមានកេរ្តិ៍ឈ្មោះពីរោះជាប់រហូតមកដល់សព្វថ្ងៃនេះ ។

៣. អហិំសា ការមិនបៀតបៀនធ្វើទុក្ខធ្វើបាបដល់សត្វទំនងមនុស្សដទៃ ឈ្មោះថា អហិំសា បានដល់ចិត្តមេត្តា ដែលជាព្រហ្មវិហារធម៌ ។ មនុស្សក្នុងសកលលោក បើបានគាន់ធំអហិំសាពាំងអស់គ្នា ក៏គ្មានជនណាដេរាយអ្នកណា គ្មានប្រទេសណាធ្វើចំបាំងទឹងប្រទេសណាទេ ដែលពៅជាមានកាប់សម្លាប់គ្នា មានធ្វើចំបាំងទឹងគ្នា ក៏ព្រោះជនខ្លះ

ប្រទេសនោះមិនបានកាន់អហិសានេះឯង ។ ព្រះសម្ពុទ្ធទ្រង់កាន់អហិសា
ទើបព្រះអង្គបានជាសាស្តាឯកជាទីគោរពនៃពុទ្ធបរិស័ទ ។

๔. សញ្ញមៈ ចាន់ដល់ការសង្រួមរាំងខ្លួនឲ្យប្រពៃពីកាមគុណ
ដោយការសង្រួមឥន្ទ្រិយ គឺសង្រួមភ្នែក ត្រចៀក ច្រមុះ អណ្តាត កាយ
ចិត្ត ដែលហៅថាឥន្ទ្រិយសំវរសីល; ក្នុងពេលដែលជួបអារម្មណ៍ល្អ-មិន
សោមនស្សរីករាយ បើជួបអារម្មណ៍អាក្រក់មិនទោមនស្ស មិនអាក់អន់តូច
ចិត្ត ។ សាធុជនអ្នកប្រាថ្នាមិនឲ្យទោសគរហាន៍ខ្លាំតើតមានដល់ខ្លួន តែង
ទំប្រឹងសង្រួមឥន្ទ្រិយទាំង ៦ ជានិច្ច ។ កាលបើបានសង្រួមហើយ
សេចក្តីអាក្រក់ទំងមិនតើតមានដល់ខ្លួនឡើយ តពីនោះមកនឹងប្រសប់
ផលដែលធ្វើខ្លួនឲ្យជាទីគោរពរាប់អាននៃមនុស្សពួកៗ ។ ព្រះសម្ពុទ្ធ
ជាម្ចាស់ព្រះអង្គមានឥន្ទ្រិយសំវរសីលនេះជាប់ជានិច្ច ទើបព្រះអង្គបាន
ជាទីគោរពនៃពុទ្ធសាសនិកជន មិនមានស្តប់ខ្ពើមព្រះអង្គឡើយ ។

๕-ទមៈ បានដល់ការទប់ឃាត់ចិត្ត, ការហាមប្រាមចិត្តមិនឲ្យ
ចិត្តដើរទៅក្នុងផ្លូវខុស ប្រកបដោយទុក្ខអន្តរាយ ដោយវិធីរក្សាសីល ៥
សីល ៨ សីល ២២៧ ឬដោយវិធីចំរើនកម្មដ្ឋាន ។ ទមៈជមិនេះ ជាគុណ
សំខាន់សម្រាប់ជនគ្រប់ថ្នាក់ ព្រោះថាតាមធម្មតាមនុស្សយើង បើគ្មាន
ទមៈជមិនេះកង់សន្តានទេ ក្នុងពេលដែលត្រូវពាក្យ: ទោស; មោហៈ
ជុះជាលពុះពោរឡើង ក៏ទំនងាំចិត្តឲ្យផុងលង់ចុះទៅក្នុងអំណាចកិលេស
នោះ ។ ជាហេតុឲ្យហ៊ានប្រព្រឹត្តអាក្រក់ ដោយផ្លូវកាយផ្លូវវាចាជាច្រើន

ប្រការរហូតដល់ក្មេង ភូមិ ឋាន ជាតិប្រទេស ក្លាយទៅជាមនុស្សមាន
កំហុស មិនគួរជាទីគោរពរាប់អាននៃប្រជាជន ។ បើមានទម្លាប់ធម៌ក្នុង
សន្តាន ដូចជំរឹមានទម័ក ទំនឹងបានផលផ្លុយពីខាងលើនេះ ដែលជាផល
គួរតែលើកដំកើងគោរពបូជា ។

ពណ៌នាមកក្នុងអនាមតធម៌ទាំង ៥ ប្រការដោយសេចក្តីសង្ខេបត្រឹម
ប៉ុណ្ណេះ ។ គុណធម៌ទាំង ៥ ប្រការនេះ សឹងមានក្នុងសន្តានព្រះសម្ម-
សម្ពុទ្ធគ្រប់ជាតិបូណ៌ ទើបកេរ្តិ៍ឈ្មោះរបស់ព្រះអង្គមិនស្ងាប់ អាចប្រតិស្ឋាន
បានរហូតមកដល់សព្វថ្ងៃ ។ ក្នុងសម័យនេះ សាសនារបស់ព្រះអង្គ
ក៏រីករុងរឿងជាយ៉ាងអស្ចារ្យ ។ ប្រទេសឥណ្ឌា, សេរីលង្កា, កូមា, ថៃ
លាវ នឹងប្រទេសកម្ពុជាយើងនេះ បានធ្វើបុណ្យពុទ្ធសក្ករាជ ២.៥០០
វស្សា ជាបុណ្យដ៏មហោឡារិកអធិកមហិមា ដែលមិនធ្លាប់ធ្វើមុនណា
សោះឡើយ ។

បពិត្រអស់លោក-អ្នកជាពុទ្ធបរិស័ទទាំងឡាយ !

ខ្ញុំព្រះករុណា ខ្ញុំប្រជាខ្ញុំបាទ ដែលលើកយកអនាមតធម៌ មក
ពណ៌នាក្នុងពេលនេះ ដើម្បីលាភត្រជាងប្រកាសគុណនៃព្រះសម្ពុទ្ធ
ជាម្ចាស់ ឲ្យពុទ្ធបរិស័ទគ្រប់ប្រភេទកាន់តែជ្រាបច្បាស់អំពីព្រះពុទ្ធគុណ
ឡើងទៀត ។ ការណ៍នេះពុំកជាកិច្ចគោរពយ៉ាងខ្ពង់ខ្ពស់របស់ខ្ញុំព្រះករុណា
ខ្ញុំប្រជាខ្ញុំបាទ ចំពោះព្រះបរមសារីរិកធាតុនៃព្រះជិនស្រី ដែល
ប្រតិស្ឋានលើបុស្សកនៅចំពោះមុខក្នុងទីកាសនេះ ។

ជយោ ព្រះពុទ្ធសាសនា !

ធិទានសុត្តាសំវត្ត

ការរិលទៅតាមខ្សែមាត់

ព្រះមហាមៅ៉ា·ខាន់

ក្រុមដំនុំប្រែព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ព្រះពុទ្ធសាសនា ប្រដៅឲ្យមានទ្វា (សេចក្តីជឿ) ទុកក្នុងចំណា តែងប្រដៅឲ្យមានបញ្ញាទុកក្នុងចិនោះផង ដើម្បីការពារមិនឲ្យជឿងប់ ច្រាសចាកហេតុផល ។ អ្នកកាន់ព្រះពុទ្ធសាសនា មិនអាចត្រូវគេដឹកនាំ ដោយការកំហែងគម្រាម ឬបង្គាប់ឲ្យចេះតែជឿ ក្នុងរបស់ដែលមិនអាចត្រិះរិះពិចារណាឲ្យឃើញពិត ដោយបញ្ញាបានឡើយ ។ មនុស្សពាល់ប៉ូ មានសិទ្ធិអាចប្រើបញ្ញារបស់ខ្លួន ពិចារណាឲ្យឃើញច្បាស់ជាមុនថា ពាក្យប្រដៅដែលនេះ មានហេតុផលយ៉ាងណា មានលទ្ធផលដល់អ្នកប្រតិបត្តិដូចម្តេចខ្លះ កាលបើឃើញថាត្រូវ ឃើញថាល្អ សមគួរដល់យោនិសោមនសិការៈ គឺការត្រិះរិះពិចារណាហើយ ទើបតាំងចិត្តជឿនឹងប្រតិបត្តិ ដោយធម្មានុធម្មប្បដិបត្តិ គឺប្រតិបត្តិឲ្យសមគួរដល់ធម៌ ដែលបានត្រិះរិះពិចារណាឃើញនោះ ។ សទ្ធា (ជំនឿ) ដែលមានដំណើរយ៉ាងនេះ ចាត់ជាកម្លាំងធំ (ពលធម៌) ជាគ្រឿងញុំាងសេចក្តីភ្លាហានឲ្យកើតឡើងដល់អ្នកជឿ ។ ព្រោះថា កាលបើជឿមានហេតុផល ត្រឹមត្រូវហើយ មិនបាច់ខ្លាចក្រែងអ្នកណា មកប្រដាប់ពោសដាក់កំហុសថាជាមនុស្សវង្វេង កាន់ច្រឡំនឹងមិនចាំបាច់ផ្លាស់ប្តូរសេចក្តីជឿរឿយ ។ តាម

ឱ្យលំមាត់អ្នកដទៃ ដែលបក់មកអំពីទិសផ្សេង ๆ ឡើយ។ សេចក្តីដឿ ប្រៀបដូចបង្គឹតទូក បើតាំងទុកទិស ធ្វើឱ្យទូកបែរក្បាលទុកហើយ ល្មើនៅមុខបានត្រឹមណា ក៏ទុកប្រើនត្រឹមនោះ ។

មនុស្សគ្រប់ប្រភេទតែប្រាថ្នាសេចក្តីសុខគ្រប់មែនហើយ ប៉ុន្តែផ្លូវដែលនឹងឱ្យសម្រេចសេចក្តីសុខនោះ ដោយឡែកទេ នេះជាបញ្ហាសំខាន់ដែលនាំឱ្យគេតែងពាក្យប្រដៅដាស់ប្រើនមែបផ្សេង ๆ គ្នា គោលបំណងក៏គឺថា ធ្វើយ៉ាងណា ទើបបានទទួលសេចក្តីសុខប៉ុណ្ណោះឯង ។ តែមានអ្នកដែលចាំបង្អុលបង្ហាញផ្លូវឱ្យទៅកាន់សេចក្តីសុខ នៅគ្រប់ទិស ដូចសាសនាខ្លះ ប្រដៅឱ្យយកខ្លួនឆ្ពោះក្តើង ឬ ហាលខ្លួនកំពុងថ្ងៃត្តៅ ញាំញីខ្លួនឱ្យបានសេចក្តីលំបាកវេទនា សាសនាខ្លះ ប្រដៅឱ្យបន់ស្រន់អង្វរទេវតា ។ ល ។ ឯព្រះពុទ្ធសាសនា ក៏ប្រដៅទំនងគេដែរ ប៉ុន្តែ ប្រដៅថាទំនងទៅឆ្ពោះខ្លួនធ្វើអ្វី ឆ្ពោះគេលេសតែញ មិនប្រសើរជាងឬ, ចាំទៅបន់ស្រន់អង្វរទេវតាធ្វើអ្វី, ខ្លួនយើងឯង អាចជួយខ្លួនយើងបានល្អជាងទេវតា ព្រោះថា ខណៈដែលយើង អាត់តែបន្តិចពេល ទៅអង្វរគេទេវតា សុំឱ្យត្រើយខ្ទេចគេមករកយើងនោះ មនុស្សម្នាក់ទៀត គេអាស្រ័យកម្លាំងខ្លួនគេ ចំហែលចឹកឆ្ពោះទៅ ទំនងបានដល់ត្រើយយូរណាស់ទៅហើយ មួយទៀត ខណៈដែលយើងបន់នោះ ដឹងជាទេវតាកំពុងលក់ឬ ភ្លាក់ ឬ កំពុងមានធុរៈយ៉ាងណាខ្លះ? អាចជួយយើងបាន ឬ មិនបាន ។

កាលបើពាក្យណែនាំ បង្អុលឱ្យទៅកាន់សេចក្តីសុខមានដោយឡែកពីគ្នា ម្នាក់មួយទិស ម្នាក់មួយទិសដូច្នេះ គង់យើញ្ញាបានថា សេចក្តីដឿនោះ

សំខាន់ត្រឹមណា ។ គ្រោះថា សេចក្តីដឿៅក្នុងផ្លូវខុស ក៏ប្រហែលគ្នានឹង ដើរថយក្រោយ ឬ រៀបកន្លែងៅផ្លូវខាងស្តាំខ្លះ ខាងឆ្វេងខ្លះ នាំឲ្យបង់ពេលនឹងហត់ខឿយខនេះ ។ សេចក្តីដឿ ទើបប្រៀបដូចជាបង្គំតទូក ដែលអាចនាំៅបាន ពាំនឹងខុសពាំនឹងត្រូវ ។ ហេតុនេះ បានជាព្រះពុទ្ធជាម្ចាស់ទ្រង់ប្រដៅឲ្យប្រើបញ្ញាពិចារណា ឲ្យតែឃើញពិតជាមុនហើយសឹមដឿ មិនមែនឲ្យដឿ ដោយអាងតម្រាដោយនឹកស្មាន ឬគ្មានគិតយកជាដើមនោះទេ ។

និទានតៅនេះ សំដែងតួយ៉ាង នៃបុគ្គលអ្នកវិលៅតាមឱ្យល់មាត់ ជាគ្រឿងបំភ្លឺហេតុផល ក្នុងការបណ្តុះជំនឿ ។

យូរលង់ណាស់មកហើយ មានព្រាហ្មណ៍ម្នាក់ ប្រាថ្នាបួងាយញ ទើបៅទិញតែមួយ បានហើយលើកដាក់លើស្មា លើដើរត្រឡប់ៅកាន់លំនៅនៃអាត្មា ។ រយៈដងផ្លូវ តាំងពីទីផ្សារៅដល់ផ្ទះព្រាហ្មណ៍នោះ ប្រហែលជាឆ្ងាយ ហើយជាផ្លូវស្ងាត់ បត់បែន គាត់ព្រៃឈើស្បែះៗច្រើនអន្ទឹង ។ ក្នុងពេលដែលព្រាហ្មណ៍កំពុងលីតែតែ ដើរៅនោះ មានអ្នកលេង ៣ នាក់ឈរនៅក្បែរផ្លូវ ។ ពាំង ៣ នាក់នោះ អត់ឃ្លានមកជាយូរថ្ងៃ ក្រឡេកឃើញព្រាហ្មណ៍លីតែតែដើរមកក៏ប្រឹក្សាគ្នាថា តែមួយនេះ សាច់ច្រើនណាស់ ប្រសិនបើយើងបានមកដោយៗជាយណាមួយ សមពួកយើងនឹងរម្ងាប់សេចក្តីឃ្លានបានក្រែល ។ គិតៅឃើញៗជាយមួយអ្នកលេងពាំងនោះ ក៏ឡើបប្រាប់គ្នា ហើយបំបែកគ្នាៅកាន់ទីផ្សេង ។ តាមសណ្តាត់ផ្លូវ ដើម្បីប្រតិបត្តិការ តាមល្បិចរបស់ខ្លួន ។ ព្រាហ្មណ៍អ្នកលីតែតែ ដើរៅ ។ ក៏ជួបនឹងអ្នកលេងម្នាក់ដើរមកពីមុខ ។ អ្នកលេងនោះស្រដី

ទៅគាន់ព្រាហ្មណ៍ថា យើ! ព្រាហ្មណ៍ធ្វើអ្វីយ៉ាងហ្នឹង, អ្នកទំលែ្ពគម្រក់នេះ យកទៅឯណា? ព្រាហ្មណ៍ក៏ឥតយកចិត្តទុកដាក់ ទទឹងពាក្យរបស់អ្នកលេង នោះឡើយទៅតែទំដើរ ទៅមុខតាមប្រក្រតី ។ លុះដើរទៅបន្តិច ក៏បានជួប នឹងអ្នកលេងទី៦ដើរមកព័ទ្ធាងមុខទៀត គេស្រែកហៅឡើងថា អស្ចារ្យ អ្វីម្ល៉ះ ព្រាហ្មណ៍! ែ្ពនេះមានប្រយោជន៍ដូចម្តេចដល់អ្នក? អ្នកធ្វើអំពើ ដែលគួរតិះដៀលនេះធ្វើអ្វី ព្រាហ្មណ៍បានឮដូច្នោះ ក៏ទំកសង្ស័យក្នុងចិត្ត បន្តិចប៉ុន្តែទៅតែដើរតទៅខាងមុខ ទៅបន្តិចក៏ជួបនឹងអ្នកលេងទី៣ដើរមក ព័ទ្ធាងមុខ ដូចមុនទៀត ។ អ្នកលេងនោះឃើញព្រាហ្មណ៍ហើយក៏ស្រែក ឡើងថា នែព្រាហ្មណ៍! អ្នកទំនាំខ្សែយញ្ចាដែលពាក់លើស្មាធ្វេងសំយុង ចុះមកក្រោមដៃស្តាំ ជាមួយនឹងែ្ពនេះទៅធ្វើអ្វី? អ្នកជាព្រាន មិន មែនជាព្រាហ្មណ៍ទៅហើយឬ ចានជាចេញទៅដេញសត្វ ដោយែ្ពនេះ ដូច្នេះ? ព្រាហ្មណ៍ឮហើយគិតមិនខាន់ ក៏ទំកស្មានក្នុងចិត្តថា សត្វនេះ យកទៅបូជាយញ្ញមិនកើតទេ ក៏ជាែ្ពពិតហើយ ព្រោះមនុស្សខាំងនោះ ច្រើនគ្នា ទំងថាគេយល់ខុសឯណាចាន ។ គិតហើយ ក៏ត្រលែងពពែ ចោលក្នុងព័ទ្ធនោះ ហើយចងតូចទំកដើរបង្ហិសទៅផ្ទះទៅ ។

អ្នកលេងទាំង ៣ នាក់ ក៏ទាំគ្នារើសយកពពែ ទៅសម្លាប់ចំអិនជា អាហារបរិភោគ្តាយាំងសប្បាយ ។

និទានេះ ប្រដៅឲ្យដឹងថា អ្នកឆ្មើងប់ ផ្តាប់មុខមិនពិចារណារក ហេតុផលឲ្យឃើញជាក់ ដោយខ្លួនបាយបញ្ញាជាមុនសិន តែងរិលទៅតាម ខ្សែល់មាត់ ដោយងាយ។ ជាមិនខានឡើយ ។

ចប់

ផ្នែកអក្សរសាស្ត្រ

សិល្បៈនិងអតីតនៃព្រះពន្ធអាណាចក្រខ្មែរ

លោក ហង់រីមារ្សាល អភិរក្សព្រះរាជវាំងអង្គរ រៀបរៀង

លៅកវ៉ាយ-ប៊ុក ប្រែជាភាសាខ្មែរ

ស៊ុវ៉ាវៀតខ្មែរបុរាណ មានតម្លៃស្មើគ្នាទឹងស៊ុវ៉ាវៀតប្រទេសឯទៀត ព្រោះមានអនុស្សាវរីយ៍ជាកិត្តិនាម កន្លងសម័យបច្ចុប្បន្ន គឺប្រាសាទដែលបិតនៅតាមទេពញ កន្លងកម្ពុជរដ្ឋ ។

ប្រាសាទតាំងអស់នោះ មានតែប្រាសាទដែលសាងនៅខាងជើងបឹងទន្លេសាប ដែលគេហៅថា ប្រាសាទអង្គរ មានឈ្មោះល្បីល្បាញជាងគេ ។ ប្រាសាទអង្គរនេះ បណ្តិតខាងបុរាណវត្ថុ ទើបទឹងស្រាវជ្រាវស្គាល់ច្បាស់តាំងពីជាង ៥០ ឆ្នាំប៉ុណ្ណោះ ។

ពីអតីតកាល មានពួកអ្នកអឺរ៉ុប មានជាតិពាណិជ្ជគេស៍ ទឹងអេស្បាញ៉ុល ចូលមកទស្សនាប្រាសាទនេះពីសតវត្សរ៍ ១៦ ទឹង ១៧ តែគ្មានអ្នកណាយកចិត្តទុកដាក់ កន្លងការយើញប្រាសាទតាំងនេះសោះឡើយ ។

មានអ្នកតំណើរជាតិចិនម្នាក់ ឈ្មោះ ស៊ាវ-តា-គួន ចូលមកមើលប្រាសាទអង្គរ កន្លងសតវត្សរ៍ទី ១៣ ចូលថ្លែងរឿងពីព្រះបរមពជកំពង ទឹងជីវិតាភាពនៃប្រជាពលរដ្ឋខ្មែរ កន្លងសម័យនោះដោយច្បាស់លាស់ ។ រឿងនេះ លោកអាបែល - រីមុយសាត់ (Abel-Remusat) ចូលប្រែពីភាសា

ចំនួន មកជាការសាបាកំណត់ ព័ត៌មានលម្អិត ១៩ ។

ការពីគ.ស.១៨៦១, វិញ្ញាជនបារាំងម្នាក់ ឈ្មោះលោកហង់រីមូហូត (Henri Mouhot) បានឃើញប្រាសាទអង្គរនៅក្នុងព្រៃ, កំប្រកាសរៀបរៀងអំពីអច្ឆរិយវត្ថុនៃអតីតខ្មែរ ក្នុងប្រទេសបារាំង ។

តាំងពីនោះមក ការស្រាវជ្រាវរឿងនេះ កាន់តែមានផលល្អខ្លាំងឡើង; កិច្ចខន្ធារបស់ប្រាសាទនេះ ក៏មានញឹកញាប់ ហើយបេសកកម្មក៏ឆ្ពោះធ្វើឡើងជាលំដាប់តមក រហូតដល់មានការស្រាវជ្រាវត្រួតពិនិត្យកិច្ចសិក្សារបស់អតីតប្រវត្តិប្រទេសកម្ពុជា ។

ការដែលមានចំនួនច្រើនរបស់ក្បាច់ចម្លាក់ ប្រកបដោយអច្ឆរិយភាពនៃប្រាសាទ ដែលបិតនៅគ្រប់ទិសមជ្ឈមណ្ឌលប្រទេសខ្មែរ បញ្ជាក់ឲ្យឃើញថា នៅទីនេះ មានប្រជាពលរដ្ឋដ៏ខ្ពស់ឧត្តមមួយ រស់នៅពីអតីតកាល ។

ការប្រែរបស់អក្សរសិលាចារឹក ដែលបានរកឃើញតាមប្រាសាទទាំងនោះអាចឲ្យស្គាល់បានចំពោះប្រវត្តិសាស្ត្រ នៃប្រជាពលរដ្ឋដ៏វិសេសវិសាល ដែលជាអ្នកកសាងប្រាសាទទាំងប៉ុន្មាន ព្រមទាំងស្គាល់ព្រះបរមនាមនៃព្រះមហាក្សត្រ ដែលសោយរាជ្យ ក្នុងសម័យនោះ ។

យើងអាចដឹងបានច្បាស់លាស់ នូវសន្តតិវង្សព្រះហស្តទាំងនោះ, ព្រះពុទ្ធដីកាពន្ធនសង្គ្រាម ដែលកើតមានឡើង ក្នុងសម័យនោះ ។

ខ្ញុំនឹងពណ៌នា ដោយសង្ខេបនូវប្រវត្តិសាស្ត្រប៉ុណ្ណា នៃកម្ពុជវង្ស ដើម្បីឲ្យលោកអ្នកជ្រាប អំពីរឿងព័ត៌មានទាំងនោះ ដែលមានក្នុងសៀវភៅជាច្រើន និងនូវជាពិស្តារអំពីប្រទេសកម្ពុជា ក្នុងអតីតសម័យ ។

តាលតាមតីតសម័យ ព្រះពុទ្ធសាសនាបានចម្រើនដែលរុងរឿងជាងគេ នោះគឺក្នុងសតវត្សរ៍ទី ๖ ទៅដល់សតវត្សរ៍ទី ๑๔ គឺសម័យដែលសៀមចូលទៅលុកលុយ ចំផ្លាញនូវតិតាលនៃប្រទេសកម្ពុជា ជាបរិយោសាន ។

ព្រះពុទ្ធសាសនាបានចម្រើនខ្លាំងណាស់ ក្នុងសម័យបុរាណ មានព្រំដែនរៀងៗខ្លួនយ៉ាងច្បាស់លាស់ ដំណើរទៅមកស្តួចស្តើង ព្រោះគេបានតែឃើញប្រាសាទជាច្រើនដែលនៅប្រទេសសៀម, លាវ និងវៀតណាមខាងត្បូង ។

មុននឹងឡើងទៅកាន់ទត្តមភាគ, មុនសតវត្សរ៍ទី ๖, ប្រទេសកម្ពុជាជាប្រទេសនៅក្នុងព្រះពុទ្ធសាសនាចម្រើនមួយ ហៅថា "ហ្វូណាំ" ប្រកបដោយស៊ីវិលាមាំមួន តែគេមិនសូវដឹងរឿងរ៉ាវប្រទេសនេះ ឥតាលសម័យនោះឡើយ ។ ដំណឹងសំខាន់ ៗ អំពីរឿងនេះ គឺមកពីមានពួកចិនដែលបានធ្វើដំណើរទៅមក ភាគច្រើនទាក់ទងនឹងព្រះមហាក្សត្រ ហ្វូណាំ ។ តែបើតាមការដឹកនាំនូវបុរាណវត្ថុ នៅខេត្តបាសាក់ (ភូមិភាគក្រមួនស, កពយា) បានបញ្ជាក់ឲ្យឃើញថា ប្រទេសហ្វូណាំ មានការគមនាគមន៍នឹងប្រទេសមជ្ឈិមទ្វីប ហើយនឹងព្រះពុទ្ធសាសនាចម្រើនមាំង ។

គេអាចយល់ថា តាំងពីសតវត្សរ៍ទី ๑ នៃគ្រិស្តសករាជមុខជាមានអ្នកដំណើរ ពួកបូជនីយេសក៍ (pèlerins) និងពួកពាណិជ្ជ, ។ល។ ជាច្រើន ចេញចូលទៅមកទន្លេបឹងបឹងចិន ។

ក្នុងសតវត្សរ៍ទី ๖, មានរដ្ឋមួយក្នុងចំណោម នៃរដ្ឋដែលនៅក្រោមអធិបត្យភាពប្រទេសហ្វូណាំ, ព្យាយាមតាំងជាឯករាជ្យចេញពីបាន;

ហើយតាំងពីកាលនោះមក, ប្រទេសកម្ពុជា ក៏ផ្តើមមានគេរឿងឈ្មោះ ក្នុង
ប្រវត្តិសាស្ត្រលោក ។

ក្នុងអាណាខេត្តនៃប្រទេសកម្ពុជា ក៏មានសាងប្រាសាទតាស
ពេញដោមដំបូងមានសភាពធម្មតា មានសើនធ្វើពីឥដ្ឋ, កម្រងធ្វើពីថ្ម
បាយក្រៀម, កំសួលផ្សេងៗពីសិល្បៈឥណ្ឌា ដែលមានស៊ីវិល័យនិង
ពុទ្ធសាសនា, ព្រហ្មញ្ញសាសនាផ្សេងគ្នា ក្នុងបុរាណកាលខ្លាំង ។

ព្រះមហាក្សត្រខ្មែរ ជាបឋមបានស្ថាបនាទូព្រះរាជធានី និងព្រះរាជ-
វង្សតិចាលជាច្រើនតន្លែង មានខ្លះបំផ្លាញទៅធ្លាយពីគ្នា, គេបានស្រាវជ្រាវ
រកឃើញ ដោយមានតំណែលត្រមាំងសិលាចារឹក ដែលមានចាំងកាល-
បរិច្ឆេទត្រឹមត្រូវគួរជឿ ។

ព្រះរាជធានីដំបូងពីបុរាណសម័យ បានទុកគ្រើដំណែលប្រាសាទ
ជាច្រើន គឺព្រះរាជធានីសម្បូរវៃត្រគុក ខាងជើងខេត្តកំពង់ធំដែលព្រះបាទ
ឥសានវរ្ម័ន សាងពីសតវត្សរ៍ទី ៧ ។

ក្រោយមក មានកាលសម័យ ប្រកបដោយការកន្ត្រាក់ជាច្រើន
ដែលមានព្រះរាជអាណាចក្រ បែកទៅជាពីរដ្ឋគឺកម្ពុជាលើ ភាគខាងជើង
កម្ពុជាក្រោមភាគខាងត្បូង ។ ឯកភាពនៃរដ្ឋទាំងពីរបេះតែបានសម្រេចទៅ
ក្នុងរជ្ជកាលព្រះបាទជយវរ្ម័នទី៧ ដែលសិលាចារឹកពោលថា ស្តេចយោង
មកពីប្រទេសជ្វា ។ ព្រះមហាក្សត្រអង្គនេះ សោយរាជ្យបាន ៥២ វស្សាពី
គ.ស.៨០២ ទៅ ៨៥៤ ទ្រង់បានស្ថាបនាព្រះរាជធានី ជាច្រើនតន្លែង ។
គឺព្រះរាជធានី ទី ១ ហៅថា ឥន្ទបុរៈ ប្រហែលជាទៅខាងកើតកំពង់ចាម

រួចតមក ដែតបន្ទាប់ទៅទៀត, ទ្រង់ក៏បានសាងព្រះរាជធានីហៅថា ហរិហរាល័យ នៅស្រុករលួស ដែតមួយទៀតផង ។ ព្រះរាជធានី ទី ៣ ហៅថា អមរិន្ទ្របុរៈ ទ្រង់ក៏បានស្ថាបនា ខាងលិចអង្គរ នៅត្រង់កន្លែងដែលគេប្រទានដីដ៏ស្រះបាយឈូ ខាងលិចតទៅអនាគត ។ ព្រះរាជធានី ជាអាសនៈនៃព្រះបាទជយវរ្ម័នទី៧ តែមហិន្ទ្របិតៈ ប្រាសាទនេះគេបានស្រាវជ្រាវរកឃើញនៅលើកំពូលភ្នំគូលេន ខាងជើងអង្គរ ។ ព្រះមហាក្សត្រអង្គនេះ(១) គេបានសន្មតនាមទ្រង់ជាទេវរាជ ជាព្រះអាទិទេពស្តេច(Dieu-Roi) ដែលគេទុកព្រះមហាក្សត្រសោយរាជ្យ ជាព្រះប្រតិកូនៃព្រះអាទិទេពនៅលើផែនដី ។ ចំពោះសាសនកិច្ចនេះ, បដិមប្រចៃនៃពជសម្បត្តិបានបូលមកប្រតិស្ឋានជានាមសញ្ញា ប្រកបដោយសន្តិភាពហៅលិង្គ (linga) សិលាជាមនោធម៌ ដែលជាព្រះកេតនកណ្ឌនៃព្រះសិវៈ (ព្រះឥស្សរ) អ្នកតំណាងអាទុភាពនៃការបង្កើតនឹងបម្រើនលោក ។

សាសនកិច្ច ឬ ព័ធនេះ មានព្រះសង្ឃបានចាត់រៀបចំ ធ្វើនៅក្នុងព្រះវិហារដែលសាងនៅលើព្រះចេតិយធំមួយ ។

ព្រះមហាក្សត្រជយវរ្ម័នទី៧ ដែលមានកិត្តិនាមសំគាល់ថាជាព្រះមហាក្សត្រប្រកបដោយតេជានុភាព បានរចនាប្រទេសកម្ពុជា ឲ្យសម្បូរដោយភោគទ្រព្យនឹងមានឥទ្ធិពលអស្ចារ្យ , ត្រូវយើងចងចាំកុំភ្លេចថា ព្រះអង្គ ទ្រង់មិនមែនគ្រាន់តែរៀបចំឲ្យបានសន្តិសុខ ក្នុងប្រទេសកម្ពុជាទេ

---

(១) ព្រះអាទិទេព-ស្តេច គឺព្រះមហាក្សត្រ ដែលសោយព្រះវិវង្គតទៅ ព្រលឹងព្រះអង្គក្លាយទៅបិតនៅ ក្នុងរស្មីព្រះអាទិទេព គឺជាតំណាងព្រះអង្គ ជាព្រះអាទិទេពនៅលើពិភពលោក ដើម្បីឲ្យគេថ្វាយបង្គំ (កំណត់អ្នកបកប្រែ) ។

ទ្រង់ចាប់ផ្តើមសាងសង់ប្រាសាទបាយ័ន ដែលជាប្រាសាទធំបំផុតក្នុងក្រុងអង្គរ ។ ប្រាសាទនេះមានរាងដូចជាភ្នំមេរុ ដែលជាទីស្នាក់នៅរបស់ព្រះឥន្ទ្រ ។ ប្រាសាទនេះមានប្រាំជាន់ ហើយមានប្រាសាទតូចៗជាច្រើនតូចនៅជុំវិញ ។ ប្រាសាទនេះមានរូបចម្លាក់ជាច្រើនដែលបង្ហាញពីជីវិតប្រចាំថ្ងៃរបស់ប្រជាជនខ្មែរ ។

ព្រះរាជាណាមួយរបស់ព្រះអង្គ ទ្រង់ព្រះនាមព្រះបាទជ័យវរ្ម័នទី១ ដែលបានសម្លាប់ព្រះបាទសូរ្យវរ្ម័នទី១ ហើយបានឡើងសោយរាជ្យជំនួសវិញ ។ ព្រះបាទជ័យវរ្ម័នទី១ បានសាងសង់ប្រាសាទជាច្រើន ដូចជាប្រាសាទបាយ័ន ប្រាសាទតាព្រហ្ម ប្រាសាទតាកែវ ប្រាសាទតាសោម ប្រាសាទបន្ទាយក្តី ប្រាសាទបន្ទាយស្រី ប្រាសាទបន្ទាយសំរែ ប្រាសាទបន្ទាយឆ្មារ ប្រាសាទបន្ទាយព្រះខ័ន ប្រាសាទបន្ទាយក្តីស្វាយ ប្រាសាទបន្ទាយក្តីធំ ប្រាសាទបន្ទាយក្តីតូច ប្រាសាទបន្ទាយក្តីស្រុក ប្រាសាទបន្ទាយក្តីព្រៃ ប្រាសាទបន្ទាយក្តីជ្រុំ ប្រាសាទបន្ទាយក្តីជ្រុំតូច ប្រាសាទបន្ទាយក្តីជ្រុំធំ ប្រាសាទបន្ទាយក្តីជ្រុំតូចនៅជិតប្រាសាទបន្ទាយក្តីជ្រុំធំ ប្រាសាទបន្ទាយក្តីជ្រុំតូចនៅជិតប្រាសាទបន្ទាយក្តីជ្រុំតូច

ព្រះពុទ្ធអាណាចក្រចេមប៉ា ដែលតាំងព្រះពុទ្ធជាធីនៅមាត់សមុទ្រអាណាម ពួកចាមនេះ ឬប្រជាជនចេមប៉ា ច្រើនបង្កើតគ្រឹះមនឹមហាពុទ្ធប្រទេសកម្ពុជា ជាច្រើនលើកច្រើនជន ។

រដ្ឋកាលក្រោយតមក, មិនសូវមានរឿងរ៉ាវអ្វីជាសំខាន់, តែ គ.ស. ៨២១, ព្រះបាទជយវរ្ម័នទី៤ បានផ្ទាស់ព្រះពុទ្ធជាធី មកតាំងនៅគោកកែ; ចំនួន ៨០ គីឡូម៉ែត្រ, ខាងទិសឦសានអង្គរ នៅជិតស្រះមួយធំ ។

ស្រះធំបាយណ៌, ជលប្រទេស, អណ្តូងទឹក, ព្រែកជីក មានប្រយោជន៍ជាសំខាន់ ចំពោះព្រះពុទ្ធជាធីខ្មែរ ពីសម័យបុពណសម្រាប់ស្រោចប្រកម្ទឹងស្រែចម្ការ ដោយមានប្រជាពុទ្ធស្ត្រជាច្រើន ត្រូវការខាងសៀងអាហារ ។ ការផ្ទាស់ប្តូរទៅព្រះពុទ្ធជាធី ដែលយើងបានយល់ទៅហេតុពិតប្រាកដនោះ មានក្នុងចំរៀលា ២៣ឆ្នាំ ឆ្នាំ៨៤៤, ព្រះមហាក្សត្រពុទ្ធជ័យវរ្ម័នទី៤ ទ្រង់បានលើកព្រះពុទ្ធជាធី មកតាំងនៅអង្គរវិញ; នៅទីនោះ ព្រះអង្គទ្រង់បានសាងប្រាសាទសំខាន់ៗ ជាច្រើន ។

នៅឆ្នាំ៨៦៧ ទ្រង់បានសាងប្រាសាទបន្ទាយស្រី ចម្ងាយ ៤០គីឡូម៉ែត្រពីទិក្រុងសៀមរាប ដែលមានទ្រង់ព្រះយនៅដូចដើម ដោយហេតុគេបានជួសជុលធ្វើជាថ្មី តាមរបៀបសិល្បៈដើម ។ ព្រះរដ្ឋបាលព្រះអង្គបានបន្តព្រះពុទ្ធស្នាព្រះហស្តតមក ហើយជាសម័យនៃប្រវត្តិសាស្ត្រអង្គរ (ពីសតវត្សរ៍ទី៣ ទៅដល់ សតវត្សរ៍ទី១៦) ជាសម័យប្រកបដោយសេចក្តីរុងរឿងទឹងសម្បូណ៌ភាព ។

ព្រះពុទ្ធសិទ្ធិ គឺព្រះពុទ្ធរដ្ឋាភិបាល, ក្នុងពេលនោះបានតាំងនៅមាំមួន

ការសាងប្រាសាទជាន់សាសនា (ព្រះវិហារ) កិច្ចធ្វើសង្គ្រាម បង្ហាញឲ្យ
ឃើញនូវអានុភាពនៃព្រះមហាក្សត្រខ្មែរ ក្នុងសម័យនោះ ដែលមាន
សិលាចារឹកពោលពុំមកស្រាប់ ។

ព្រះមហាក្សត្រ គឺជាព្រះតំណាងនៃព្រះអាទិទេព ក្នុងពិភពលោក,
ទេវតា,ហើយកិត្យានុភាពនៃអារ្យធម៌ប្រទេសកម្ពុជា ដែលឮល្បីល្បាញ
រំពងឆ្ងាយ បានផ្សាយទៅកាន់សមព្ភប្រទេស គឺពួកចាមខាងកើត, ប្រជាជន
ថៃ នៅត្រីកោណទន្លេមេគង្គ ទឹងមេណាម ។

រដ្ឋាភិបាលខ្មែរ ធ្លាក់ទៅលើត្រកូល រាជនដែលក្រុមបដោយអានុភាព
(oligarchie aristoiratique) ត្រមាំងត្រកូលព្រាហ្មណ៍ប្រកបដោយ
ពលភាពជាបង្អែក កាន់តាប ។

សាសនានៃពួកមន្ត្រីធំគឺ ពុទ្ធសាសនាទឹងព្រហ្មញ្ញសាសនា ពិធី
ទាំងពីរប្រើនមានចារឹកពុំកក្នុងអត្ថបទនៃសិលាចារឹក ។

រូបដែលតាំងនៅក្នុងព្រះវិហារ គឺរូបព្រះវិស្ណុ, ព្រះសិវៈ, ព្រះហរិ-
ហរៈ (គឺព្រះសិវៈរួមទឹងវិស្ណុ ជាអាទិទេពតែមួយរូប) រូបនាងលក្ស្មី, ឋិវទ័,
ព្រះពុទ្ធរូបទឹងព្រះរូបព្រះពោធិសត្វ ដែលជាបដិមារូបនៃព្រះមហាក្សត្រ,
ព្រះពជវង្សានុវង្សទឹងមន្ត្រីធំ ។

ព្រះវិហារ (ប្រាសាទ) គឺព្រះមហាក្សត្រទ្រង់តសាងពុំតជាអនុស្សា-
វរីយ៍ចំពោះព្រះមហាក្សត្រឬព្រះអយ្យកោនៃព្រះមហាក្សត្រអង្គនេះ។ឬជួ-
ទីយដ្ឋានៅចំកណ្តាល ដែលមានព្រះបដិមារូប អាទិទេពក្សត្រ (DiU-Roi)
ឋិតនៅ គេបានរចនាឲ្យមានជ្ញាក់ខ្ពស់ជាបដិមារូប (Symbôle) នៃភ្នំ

ព្រះសុមេរុ (ភ្នំពិសិដ្ឋ, (montagne sacrée)) ; គឺនៅលើខ្នងភ្នំនេះឯង ដែលមានទេវតាហិណ្ឌូសាជាច្រើន ។

ការដែលរចនាបូជនីយដ្ឋាននេះ ឲ្យមានសភាពខ្ពស់ ធ្វើឲ្យក្បាច់សិល្បៈខាងសាសនានៃប្រទេសកម្ពុជា មានទំដ្ឋភាពសម្រេចតាមលក្ខណៈនៃសិល្បៈប្រទេសនេះ ។

ចំពោះខាងប្រាសាទ, ស្ថាបៃនៃសិល្បៈខ្មែរគឺមានសំអាងត្រង់ប្រាសាទអង្គរវត្ត ដែលមានលំអអស្ចារ្យ អាចយកទៅប្រៀបធៀបនឹងប្រាសាទដែលគេបានដឹងថា ជាអច្ចរិយភាព ដែលបិតនៅក្នុងពិភពលោក ។ ប្រាសាទនេះ ព្រះបាទសូរ្យវរ្ម័នទី១ ទ្រង់បានកសាងពីពាក់កណ្តាលសតវត្សរ៍ទី១២ ដោយគេបានរកឃើញសិលាចារឹកមានជាក់ព្រះបរមនាមបច្ឆាមរណៈ (Nom posthume) នាមដែលចារឹកក្រោយទិវង្គត) ថាបរមវិស្ណុលោក (Para mavishnuloka) ដែលគេបានឃើញព្រះបរមរូបទ្វាក់នៅក្បាច់ដញ្ជាំងនៃប្រាសាទនេះ ។

អង្គរវត្តនេះពុកជាអច្ចរិយភាព (ភាពគួរឲ្យស្ញប) នៃសិល្បៈខ្មែរដែលបានរចនារិះកន្ធរលំអបន្ថែមមួយ។ រហូតដល់លំអដ៏ខ្ពង់ខ្ពស់បំផុត, បើតាមតំនិតប្រៀបធៀប នឹងប្រាសាទនេះ, ប្រាសាទនាមថាវេថនដ៏ (parthénon) នៅទីក្រុងអាថែន្ស (ប្រទេសក្រែស) ដែលកសាងពីសតវត្សរ៍ទី ៥ មុន គ.ស. គេបានឃើញថា ប្រាសាទថាវេថនដ៏ មិនស្ទើមានសភាពសន្ធោសន្ធៅតែក្រោ ។ ចំណែកឯព្រះវិហារដែលរចនាដោយក្បាច់សិល្បៈបែបគោធិក (gothique) សាងពាសពេញប្រទេសជាពិសេ

(ពីសតវត្សរ៍ទី១៣ ក្រោយ គ.ស.)ខាងលើដូចជាមានសភាពខ្ពស់ហួសប្រមាណ ហើយខាងក្រោម មិនសូវសម្បើមទេ ។

អាទុភាពអស្ចារ្យហើយគួរឲ្យស្បថស្បែងតន់ពេក នៃក្បាច់សិល្បៈប្រទេសអេស៊ីប្ត (សតវត្សរ៍ទី១៥ មុន គ.ស.) បើកាលណាគេចូលទៅក្នុងព្រះសួចរចេតិយនោះ ទើបអាចបញ្ចេញទ្វារអាទុភាពគួរឲ្យស្បថស្បែងបាន ។

សភាពប្រាសាទអង្គរវត្តពិតត្រូវ ដោយរួបរួមតាមគម្ងាយមានទំហំធំសម្បើមអស្ចារ្យ បើកាលណាគេទៅជិតប្រាសាទទាំងនោះ ត្រង់បូជនីយដ្ឋានសំខាន់, មានទិដ្ឋភាព (aspect)(១) ប្លែក ។ គ្នា ។ បើពួកទេសចរ(២) អញ្ជើញមកទស្សនាទូវែកខ្នែងទាំងនោះ ចិត្តលោកតែងមានមនោសញ្ចេតនា(៣) ស្បថស្បែង ប្រកបដោយបីតិ(៤)ទីឥតបានជាមោទ្ទៈ(៥)មិនខាន ។

នៅក្នុងរជ្ជកាលព្រះរជ្ជាយោ(៦) នៃព្រះបាទសូរ្យវរ្ម័នទីពីរ, ប្រទេសកម្ពុជា តែងមានចលាចល ដោយកើតសង្គ្រាម ដែលធ្វើឲ្យបង្ហូរឈាមប្រជាជន ។ លំដាប់តាំពីព្រឹត្តិការណ៍នោះមក, ព្រះបាទជយវរ្ម័នទី ៧ គ.ស. ១១៨១ ទ្រង់ឡើងសោយរាជសម្បត្តិ បានដេញពួកចាមដែលចូលមកលុកលុយព្រះរាជធានី ហើយទ្រង់បានរៀបចំក្នុងព្រះ

១- ទិដ្ឋភាព: ទិដ្ឋិ; ជំណើរយល់ឃើញ. ទិដ្ឋភាព: ភាពទៅតាមជំណើរដែលយល់ឃើញ

២- ទេសចរ: អ្នកដែលត្រាច់មើលប្រទេស ។

៣- មនោសញ្ចេតនា: លំនាំ, ជំណើរបស់មនោ (ចិត្ត) ។

៤- បីតិ ព្រឺរោម ព្រឺស្បែក ។

៥- ជាមោទ្ទៈ: ផ្ទុះភ្លាមនឹងបីតិ តែមានកំឡាំងខ្សោយជាងបីតិ ។

៦- ព្រះរាជាយោ: ព្រះអង្គម្ចាស់ដែលគេបម្រុងនឹងឲ្យសោយរាជ្យ ជាព្រះមហាក្សត្រព្រះរាជវង្ស ។

ពជអាណាចក្រមានសភាពស្រួលបួល ។ ទ្រង់បានកសាងព្រះពជធានីថ្មី ដើម្បីទំនង់ផ្ទាស់ប្តូរទៅព្រះពជធានី ដែលបច្ចាមិត្រធ្វើឲ្យវិនាស ។ ព្រះពជ-ធានីថ្មីនេះ មានកំពែងរឹមាំមួន, មានជីកស្នាមភ្លោះព័ទ្ធជុំវិញ, គឺជារូប គំនូរនៃចក្រវាឡ ក្នុងពហូអាទិទេពនិយមលទ្ធិ (mythologie) មាន ឥណ្ឌៀដែលមានជួរកំពែងជុំវិញ ហើយទំនាសមួយ គឺព្រះពជធានីដែល គេហៅថា អង្គរធំ ។

នៅចំកណ្តាលព្រះពជធានី, ព្រះបាទជយវរ្ម័នទី ៧ ទ្រង់បាន កសាងប្រាសាទបាយ័ន ដែលមានក្បាច់សិល្បៈ ត្រមាំងសើនមានធ្វាក់ មុខព្រហ្ម មើលទៅគួរឲ្យរំភើបក្នុងចិត្តៈ ទៅពេជ, បដិមារូបនៃព្រះពជសិទ្ធិ ដែលគេបានរកឃើញនូវបូជនីយដ្ឋាន កណ្តាលមានធ្វាក់ជាព្រះពុទ្ធរូប សំគាល់ឲ្យឃើញថា ព្រះមហាក្សត្រនេះ ទ្រង់ជាពជូបត្ថម្ភនៃព្រះពុទ្ធ-សាសនា ។

ក្រោយដែលទ្រង់មានជោគជ័យ ក្នុងសង្គ្រាម, ទ្រង់បន្តយព្រំដែន ព្រះពជអាណាចក្រទាន់ដើនទឹងទាន់លិច ។

មានសិលាចារឹកបង់ព្រះបាទជយវរ្ម័នទី ៧ ពីឆ្នាំ ១១៨១ គេបាន រកឃើញនៅប្រទេសលាវ (វិត្រុងសៃហ្គុន) ជាព្រះពជធានីខ្មែរអតីត បិតនៅជិតទីក្រុងវៀងចន្ទន៍ ។

ព្រះមហាក្សត្រអង្គនេះ ទ្រង់មានព្រះឋានភាពក្រមាំងព្រះទ័យ ល្អោកលង់ពន់ប្រមាណ ទ្រង់បានរាជាឲ្យប្រទេសកម្ពុជាសម្បូណ៌ ដោយ កោតក្រែងហើយនឹងពលភាព ។

ប្រាសាទជាច្រើនដែលទ្រង់ស្ថាបនាឡើង សម្រាប់ជាបូជនីយដ្ឋាន
ខាងព្រះពុទ្ធសាសនាមហាយាន ដូចគេបានឃើញមានព្រះរូបព្រះពោធិ-
សត្វជាច្រើន ក្នុងការតាប់តាស់ប្រឹងពីស្រាប់ ។ ការកសាងរបស់ព្រះអង្គ
មានច្រើនអនេកប្បការ, ក្រៅពីបូជនីយដ្ឋានទំនឹងមហាប្រាសាទសំខាន់ៗ
ដែលទ្រង់បានកសាងទៅតាស់ពេញប្រទេសកម្ពុជា ទ្រង់បានស្ថាបនាទូ
មន្ទីរព្យាបាលរោគ ១០២, ត្រាស់បង្គាប់ឲ្យជីកព្រែកទំនឹងអន្ទង់ជាច្រើន ។

ទ្រង់បានបង្គាប់ឲ្យធ្វើផ្លូវថ្នល់គមនាគមន៍ ពីប្រាសាទមួយទៅប្រា-
សាទមួយ ព្រមទាំងស្ពានធ្វើដសិលា, ព្រែក, ទំនប់សាលសំណាក់ សម្រាប់
អ្នកដំណើរតាមផ្លូវថ្នល់នោះ ។

ព្រះរាជឱយាទនៃព្រះបាទជយវរ្ម័ន ទី ៧ ទ្រង់វិលត្រឡប់មកកាន់
ព្រហ្មញ្ញសាសនាវិញ, ទ្រង់បានបំផ្លាញនូវពុទ្ធរូប ឬក្បាច់ចំលាក់
ខាងព្រះពុទ្ធសាសនា ដែលមាននៅក្នុងប្រាសាទទាំងនោះ ។

តែការប្រឹងប្រែងកសាងប្រាសាទ ក្នុងសម័យនោះ, បានធ្វើឲ្យប្រជាជន
ខ្មែរថមថយកម្លាំងជាច្រើន ព្រមទាំងព្រះរាជអាណាចក្រ ក៏ខន់ខ្សោយ
ដោយមានសង្គ្រាមពីប្រទេសជិតខាង ចូលមកលុកលុយថែមទៀត ។

ក្នុងសតវត្សរ៍ ទី ១៣, មានប្រជាជនថ្មីមួយទៀត, ហៅថា ថៃ ដែល
អំណឹះតពីនេះមក ប្រែទៅជាជាតិសៀម, បានចេញពីខាងត្បូងប្រទេស
ចិន, ចូលមកបញ្ចេញសមត្ថភាព ក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា ។

ក្នុងសតវត្សរ៍ ទី ១៤, មានក្បាច់ដញ្ជាំងនៅប្រាសាទអង្គរវត្ត គេ
មានឃើញទ្វាក់ឫគ្គលស្លៀកពាក់ខោអាវថ្មែក, ពាក់មួកថ្មែក ឈរនៅ

ក្នុងដួរកងច័ត្តខ្មែរ, បើតាមសិលាចារឹកថាជាជាតិសៀម, ក្នុងសម័យ
នោះ, ពួកសៀមតឿនៅក្រោមបង្គាប់បញ្ជាព្រះចាន់សុរ្យវរ្ម័នទី៣ ។
តែដែលពួកសៀមមកតាំងច័ក្តន្ទ្រនៅទន្លេមេណាម, ពួកនេះនៅជានៅ
ក្នុងប្រទេសជិតខាងកម្ពុជរដ្ឋហើយត្រឡប់ជាបច្ចាមិត្រ នៃប្រទេសកម្ពុជា
វិញ ។ ពួកសៀមនេះ ក៏ចូលមកលុកលុយប្រទេសកម្ពុជា ជាញឹកញយ
ដែលនាំឲ្យខូចកិត្តិយសខ្មែរ ។

ក្រោយ ដែលខ្មែរទន្ទឹងសៀមចាន់ធ្វើសង្គ្រាម នៅវិញៗមកជាច្រើនលើក
ច្រើនគ្រា ព្រះពុទ្ធជាទីអគ្គ្រ ក៏ត្រូវបោះបង់ចោលនៅគ.ស.១៨៣២ ។

ដើម្បីទន្ទឹងឲ្យយល់ជាក់ច្បាស់ អំពីសារៈសំខាន់របស់ប្រាសាទខ្មែរ
បុពណដែលបញ្ជាក់ឲ្យលំអប្លែកអស្ចារ្យ ផ្សាយចេញពីសិលា, ខ្ញុំមាន
ត្រៃជុះចាក់ឫស ត្រូវយើងយកសញ្ញាណផ្សេង ។ មកពិនិត្យ ។

ប្រាសាទទាំងនេះ មានរូបអាទិទេពបិតនៅ ក្នុងបូជនីយដ្ឋានកណ្តាល
ដែលជាបដិមរូបនៃប្រាសាទទេវតានៅស្ថានសួគ៌ ។

បូជនីយដ្ឋាន (Sanctuaire) ឬតារាស្ថាន (chapelles) គេច្រើន
សាងឲ្យខ្ពស់មានថ្នាក់ជាច្រើន នៅទៅមទ្វីដែលមានរូបអាទិទេព, គេ
តែងស្អាងសើនមួយ ។ ខាងក្រៅសើនេះមានថ្នាក់លើថ្នាក់ក្រោម
មានទំហំកាន់តែតូច ។ ស្រុបទៅលើ ។

មានកំពែង ឬ ជញ្ជាំងព័ទ្ធជុំវិញបូជនីយដ្ឋាន ព្រមទាំងប្រាសាទ
សំខាន់ៗដែលបិតជុំវិញអស្សព្ភមិកដ្ឋាន (Cour) ខាងក្នុង ។ គេអាចទៅ
ពីអស្សព្ភមិកដ្ឋានមួយ ទៅអស្សព្ភមិកដ្ឋានមួយទៀត. តាមសិលាត្រៃះមាន

សើនពីលើកំពូល ដែលហោចថា គោបុរៈ ។

វិថីពាក់ព័ន្ធនឹងមហាប្រាសាទ ដែលមានព្រែកជីកព័ទ្ធជុំវិញ មានគំនូរបម្លាក់ធ្វើឲ្យចំដូគាតនៃលំអក្បាច់សិល្បៈកាន់តែមានសម្រស់ខ្លេឡើងទៀត ។

ដើម្បីកុំឲ្យឆ្ងើងធ្ងល់; កាលណាគេចូលទៅខាងក្នុងប្រាសាទ មានប្រាសាទតាព្រហ្ម, បន្ទាយក្តី ឬព្រះខ័នជាដើម ដែលមានទំហំធំដូចនេះ, គេត្រូវដឹងថា ប្រាសាទទាំងនេះ គឺជាកុសលដ្ឋាន ឬសាលាទាន ឬពុំនោះ សោត ជាវិជ្ជាស្ថាន ខាងសាសនា ឬជាវត្តអារាម ។

មានមនុស្សជាច្រើនណែនណាន់តាន់តាប់ គឺពួកមន្ត្រី, ព្រះភិក្ខុ-សង្ឃ, ភ្នង់បុរស (musicien) នាដក: (danseurs) ខាសាដែលរស់នៅខាងក្នុងកំពែងប្រាសាទទាំងនេះ ។

អ្នកក្រីក្រមានគេឲ្យម្ហូបអាហារបរិភោគ; គេបានបង្ហាត់បង្រៀនពួកបូជនីយេសក៍ ខាងការសិក្សាទូទៅគម្ពីរពិសិដ្ឋជាច្រើន ហើយមានឧបាសក ឧបាសិកា ចូលទៅរួមក្នុងពិធីបុណ្យសាសនានេះ ។

គេអាចពោលបានថា ប្រាសាទអង្គរបានបញ្ចេញទូវកំសួលផ្សេងៗគឺអានុភាពសាសនាពីអតីតនឹងពលភាពព្រះមហាក្សត្រ ដែលមានជីវិតនិម្មិតចេញពីសភាពស្ងាត់កំចាំងសុទ្ធនៃប្រាសាទដែលមានរុក្ខជាតិនឹងឈើព្រៃចូលទៅលុកលុយ ធ្វើឲ្យប្រាសាទទាំងនោះចាក់ឬកវិនាសអស់ ។

ប្រទេសកម្ពុជាអាចអួតខ្លួនឯងបាន ដោយមានកសិកម្មជាមរតកសម្បើមអស្ចារ្យពីអតីតកាល ដែលមានពួកទេសចរបានមកពាល់ឃ្នាំ ពីប្រទេសឆ្ងាយ ដើម្បីនឹងសិក្សានាប្រាសាទទាំងនេះហើយពោលសរសើរគ្រប់ៗគ្នា ។

ពាក្យកាព្យ

លោកអម្ចាត្យត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថៃម ពិនិត្យ

(តមក)

ព្រះកត្តកត់តរ ទុកជាមរណ៍ សោយសោកជ្រាសជ្រាណ ខ្លួតឡឺនឡង់ លើអង្គអស្សយាន សេះសោតមិនហ៊ាន ជោលខ្ចាំនក្រែងធ្លាក់ ។ សេះលួងលោមថា បពិត្រកុមារ ប្រសើរទ្រង់លក្ខណ៍ កុំសែនសោយសោក អមោក្សអន់អាក់ ខ្ញុំក្រែងថ្លៃធ្លាក់ អង្គអន្ធការ ។ មួយខ្ញុំតិតកយ៏ ជ្រួតម្ចាស់សោកវក្រ ទឹងកើតទៅជា កេតបៀតក្រីក្រ ឥតហ្មត់ពេទ្យា អាសូរអនុជា ក្មេងណាស់ម្ចាស់អើយ ។ ស្តេចស្តាប់អស្សពាហ៍ លួងលោមបរាជ័ណើរច្នោះហើយ គ្រាន់ស្រាកគ្រាន់ស្រាល ស្រយាលបានស្បើយ ព្រះអង្គស្ងួនល្មើយ អស់អង្គក្លាត់ក្តៅ ។ សេះយល់ស្តេចស្បើយ ទូលថាម្ចាស់អើយ ខ្ញុំប្រឹងតង់ទៅ ឲ្យជាប់លើខ្ញុំ ទឹងខំជោលទៅ ពាន់កន្លងប៉ុន្ម្រៅ ឲ្យធ្លាយនគរ ។ ថាៈស្រេចសេះប្រឹង ជោលអស់ទំហឹង ហើយពាអស្សតរ ឲ្យគាស់អស់ស្បៀង រៀងៗ ចេញ លុះស្ងាត់ទិនករ សាមសិបយោជន៍ណា ។ សេះឈប់ឲ្យសោយ ទៅទៀតដើរដោយ ដែនជង្ឃាគា សេះពុំហានខ្ជាំង រក៏ងកុមារ បទស្តេចសោកា ពុំបានស្រោកស្រាន្ត ។ សាមសិបយោជន៍ឃប់ សេះឈប់នៅម្តុំ ឈើធំមួយមាន ស្រះស្រន់ទូលាយ

សប្បាយក្សេមក្សាន្ត កំពង់ទីជាន ពាបរលើងស្រួល ។ ឈូកឈរពេណីច្រាំ
ស្ទឹកស្ងោមដញ្ជាំ ពោះទាំងទីខួល ទីពាបរក្តា ផ្ទៃផ្កាមួល មែកមើលដង្ហួល
ជង្គឹស្រោងស្រឹង ។ រលើងក្រោមធេង មុខគួរដើរលេង រំវែកវារើង មុខគួរ
ឈរឈប់ ក្រោមម្ជប់ត្រឈឹង ត្រឈៃតើង រំពៃព្រឹក្សា ។ កុមារបុះ
ស្រង់ ជម្រះអស់អង្គ បំផាត់ចរិយាហ៍ ស្តេចឡើងមកឈប់ ក្រោមម្ជប់
រុក្ខា សេតសោយកោជនា ច្រាស់ផ្ទំលំហើយ ។ សេះធីក្រវែល ក្រវើន
មិនដែល ឲ្យហ្វាតន្ទាយឡើយ កុមារសោតផ្ទំ ក្រៀមក្រំពុំស្បើយ
គ្រាស់ថាប្អូនអើយ ថ្មើរណោះមាគា ។ តែឯឃល់យើងដល់ ខែនទី
មណ្ឌល សេតសោយកោជនា ទម្ងន់សមនឹងខន្ធឹងមាគា អង្គអាចអត់អា-ហារ
ហើយចាំយើង ។ ព្រលឹងបងអើយ ពុំយើញាយើងឡើយ សមត្តៅដូច
ក្តៅឆ្អែ ឆេះខ្លាតែ ខំរត់រកយើង រត់ចុះរត់ឡើង រកក្នុងមន្ទីរ ។ ពុំឃល់
សមស្ងែង រកដោយទីល្បែង កេងកាជតាដី សមសែនសោយសោក
អមោក្សសែនខ្លី ណាយខ្លួរកោជនីយ៍ សោយតែទឹកភ្នែក ។ សមនឹងចោក
ច្រាស់ អង្គកាយតរព្រះ ពាក្យចុះបែក ប្រមាត់ថ្លើមផ្ងាក់ ដូចអ្នកហួរហែក
រយះរំយែក ក្នុងព្រះអង្គឯង ។ បពិត្រខេត្តា សូមអ្នកមេត្តា ខឿនខូលថ្លា
ថ្លែង ច្រាប់ព្រះមាគា ជាតំជាតម្តែង កុំឲ្យចម្ងែង សែនសោយសោកសៅ

(និទានសាសព្ទ សាសនតិច្ចកាព្យ តិច្ចកល់ដោយខ្លួវ ដំណើរ
តោធ-សត្វរំសេសរៅ បញ្ចប់កាព្យខ្លួវ ហៅខ្សែ ១ ហោង(១) ។

១- ប្រាប់ដើមចប់ខ្សែ ១ ត្រឹមប៉ុណ្ណោះ តទៅជាសេចក្តីខ្សែ ២ តាមច្បាប់សាស្ត្រស្ទឹកតែ
វត្តសញ្ជឹ ស្រុកស្អាង ខែត្រកណ្តាល ។

នេះនៅតំណ ជំណើរថ្ងៃដ៏ត ថ្ងៃដ៏តាមទំនង ជំណើរកិច្ចការ
រៀងរាបខាក់ខាង ខាក់តាមគន្ធង គន្ធបការ ។ ហៅថាខ្សោ កាលព្រះ
ពន្ធ្យោ-ធិន្ធវ៍ប្អូនក្ស ដេកជាក់អាស្រ័យ នៅព្រៃព្រឹក្ស តាមដោយអគ្គ-
ធិប្បាយជ្រះថ្លា ។ ខ្មៀនខ្ញុញខ្លល់ខ្ពុក្ខ លើសលែងលុះលក់ ចាត់ខ្មៀន
ខ្ញុញទៅ លុះព្រឹកព្រាងព្រះ សូរ្យរះឆ្ពិនឆ្ពោ ស្រស់ស្រង់សោយខ្ទូ អាហារ-
គោជនា ។ ខ្សើងលើអស្សតរ កដនាំចេញចរ ទៅសព្វទិព ពុំដែលប្រទះ
ឥសិសីលា ខនរគាមា តាមៈដង ។ យល់តែអស់ម្រឹគ នៅក្នុងព្រៃ
ព្រឹក្ស តិងពាក់ប្រស្រ័យ ចាំងគោចខ្មៀយំ ច្រឡំច្រឡៃ ចាត់ចាន់រៃរៃ
ក្ងុកក្ងោក ។ ក្រៀលចាតចាប មៀមមាន់ព្រៃព្រាប តារៅចាប់ល
គោក សកត្រយង កេងកងបិតសោក ត្រាចដើមខ្ពស់ខ្ពក ទីខុយ
អាស្រ័យ ។ ក្តាន់ក្មៀងញីញង ដើរដោយជ្រលង ដងដែនព្រឹកព្រៃ
ពុំភ្លឹកពុំក្លើន រំពើនរំពៃ ខ្លាខ្លាំងមានមៃ. ត្រើត្រេកគាន់គ្នា ។ កេសរកេស-
សីហ៍ គោត្រគោក្រមើ កែះទន្ដគជសារ តជសីហ៍សត្វសិង្ហ រិលរឹងរេក
ជាញដែនជល់គ្នា ប្រឡែងលេងលង ។ ខនេរ្យាងខនេរ្យាយ ប្រើសព្រៃ
ឈ្មួសត្រាយ គាំងលៀងគាជង ចោលបណ្ដើរគ្នា លីលាត្រសង រេករួស
រង ដោយកនត្ថក់ ។ ហេតុដោយបរមត្ថ ជារមិមហាកប្ប ត្រូជពន្ធ្យពុទ្ធ
ម្រិគាម្រិគីបក្សីបក្សា មែនមានមេត្តា ទៅរកទៅមក ។ ស្តេចយល់សត្វជង
កៀងគូត្រសង ជួបជុំរួសរេក ស្ទៅបរិភោគ្គា កុមារសោយសោ . កាគន់តិត-
ក្ខក ដល់ព្រះមាតា ។ ឧសភ្ញាងឡាយ ជួបជុំគូកាយ មិនមានឃ្លាតឃ្លា
កម្មអ្វីអគ្គីអញ ឲ្យមេញ្ញមហិមា ព្រាត់ព្រះមាតា ខ្ទូព្រះជនក ។ សត្វ

សត្វសម្លាយ សោតសឹងសប្បាយ ឥតខោសឥតទុក្ខ តែអញនេះម៉ិញ
អម្ចេញពុំសុខ មិនបានឃើញមុខ មាតាបិតា ។ ម្ល៉ះសមអ្នកម្តាយ
សែនសោកស្តេចស្តាយ បទបុត្រឃ្លាតឃ្យា ដើរគ្រាត់ច្រាសមួយ សែន
មួយៗនៅ គ្រាន់ព្រះមាតា ស្រោកស្រាន្តទុក្ខធង់ ។ ឥឡូវឃ្លាតឃ្យា
ទាំងពីរអង្គា សមអ្នកវែងវង ទុក្ខខោមនស្សមខោ ទុះនេះម្តង ហេតុ
កម្មចាំបង អង្គឲ្យឃ្លាតឃ្យា ។ ហាក់កូនទុំដិន ធ្វើឲ្យព្រះគុណ សែន
សោយសោក ខ្មៀងលស់តែទុក្ខ ពុំសុខសាន្តសា- ប៉ាយបទបុត្រា
បុត្រីឃ្លាឃ្លាត ។ កូនមិនដូច្នោះ នេះឯងពីព្រោះ កម្មកាយអង្គភាត្
វែនយើងទាំងពីរ ពិតពីបុព្វជាតិ ខាំមកបងឃ្លាត ឲ្យឃ្លាយឃ្លៀងឃ្យ ។
ទុះហេតុសម្ភារ បុណ្យចាម៉ែតា អញខ្ញុំក្រាស់ក្រៃ សាងពីបឋមា ជាអស-
ន្ធើយ្យ សូមខេតកពក្រៃ ច្រើសច្រន់ចំពូញាណ ។ សូមលោកវក្ខ
សម្តេចមាតា ឲ្យបានសុខសាន្ត កុំឲ្យជាទុក្ខ ជាទុកក្នុងច្រាណ ឲ្យស្រន់
ឲ្យស្រាន្ត ឲ្យស្រាលទុក្ខា ។ ខំពំខ្ញុំបាន ត្រឡប់វិលឋាន រដ្ឋភជសីមា
ខួញក្លាងសោយសោក វិយោគផ្សប់ផ្សា ញាប់ញ៉ែវអង្គា លើខ្នងមខោ-
ម័យ ។ កុមារវិលក្តណ៌ សែនសោកអួលអាក់ អួលអន់អាល័យ អាខ្លោះ
ព្រះមេ ឥតល្អែព្រះច័យ សែនសោកសត្វថ្ងៃ ស្តួមទាំងកាយា ។ សេះ
យល់សោកណាស់ លួងលោមខួលថាស់ មិនឲ្យសោក គ្រាន់ស្រោក
សោកសោយ តែមួយវេលា ខឹកឡើងកាលណា តែងខួញខ្មៀតខ្យៅ ។
តាំងតែជាទុក្ខ មិនមានសាន្តសុខ ខឹកដល់រឹងក្តៅ តំណើរន័យនេះ ឈប់
ស្ទុះទិត្យខ្យៅ ខឹងថ្ងាថ្ងៃងងៅមន្ទីរមណ្ឌល ។

អស់អ្នកចាស់ខុំ មេនំខ្ញុំស្នំ ពីព្រឹកពុំយល់ ស្មានស្តេចទៅព្រៃ
យប់ក្រៃពុំដល់ ពុំដឹងសឹងធ្លល់ សឹងឈ្លោកកេសព្ធ ។ ខ្លះគង់កេលើ
ប្រាសាទប្រសើរ ដោយកៀនចន្ទប់ ពិតពុំយឺងយល់ រៀលថ្លៃថប់ តិត
ភ័យចាំងយប់ កកើតគោលា ។ រកដោយពេងសេះ សព្ធពេងរទេះ
ពោសស្ទួគ្នា ពុំយល់ចរចួល ទៅខ្លួលយក្សា ខ្ញុំនាងវិមលា បពិត្រក្សត្រ
ក្សត្រិន្ត ។ ជ្បាតបុត្រខ្ញុំហា ចាត់ពន់រៀលា ចាំងពាជអស្សយាន
ថ្មើរណេះតែងដល់ មណ្ឌលចិត្តហាន ស្តេចពុំដែលមាន ឲ្យខុសរៀលា ។
បពិត្រថ្ងៃនេះ ចាត់ដល់យប់ម្ល៉ិះ ប្លែកនឹងសព្ធគ្រា សព្ធថ្ងៃចមទៅ
ស្តេចទៅព្រឹក្សា តែងតែចរចា ច្រាប់អស់ចាស់ខុំ ។ យប់មិញស្តេចទៅ
ចាត់ពីយប់ជ្រៅ ពុំច្រាប់យើងខ្ញុំ ខ្ញុំស្នំស្នេហា មកពោរតូចធំ ចំឡែក
តេកពុំ ជួបជើមសព្ធគ្រា ។ យើងខ្ញុំរកកេ ដោយជ្រងដោយច្រក
ទីល្បែងកុមារ ខ្ញុំទៅដល់ពេង ដែលចងអស្សតាហ៍ ពេងពាជរដ្ឋ
សោតសាយសព្ធសុះ ។

នាងនាថវិមលា ចានជ្រួតជ្រាបថា បុត្រចាត់ជូរញ្ជះ ខ្លះតប់ទុក
សោកាតាខ្លោះ ជាលដល់ដួលចុះ សន្ធប់សុបសៅ ។ យក្ខកំយក្សីត
កន្ត្រែ ដោយទឹកទើបភ្ញាក់ កាយគន់ទិត្យនៅ ឈឺឆៀបផ្សប់ផ្សង ទុក
ក្តួលក្តៅ សៃនសោយសោកសៅ ពុំចេញចរចា ។ យក្ខលោម
លំហើយ ព្រលឹងបងអើយ ចាំឲ្យសេនា រកសិនកុំស្ងួន ខ្ញុំមខ្ញុនពំងា
កុំសោកពេកណា គង់តែឃើញទេ ។ ត្រាស់ស្រែចយក្ខប្រើ សេនា
ឲ្យដើរ រកសព្ធមគ្គ មាគ៌ាសុះសព្ធ ពុំមានចំនេរ សព្ធស្រុកទេសគេ

ទំសាំងជ្រាំបី ។ ខ្លះតខ្លះវែ ខ្លះទៅជានតែ បួនជ្រាំពត្រឹ សឹង
រកពុំឃល់ ខ្លះដល់ខែបី សួរសតួបូរី ជិតឆ្ងាយនានា ។ ខ្លះទៅជ្រាំ
វែ ស៊ើបសួរសឹងតែ ពុំឃល់កុមារ រិលរើចរចូល ខឿនខូលយកថា
យើងខ្ញុំត្រប់គ្នា ស្វែងរកបុត្រនោះ ។ ស៊ើបសួរសព្វសឹង ពុំឮដំណឹង
ដំណើរសួខ្សោះ យកក្បស្តាប់តិតថា ជាក់ជាសេះនោះ ច្រាច់ហេតុ
ចំនោះ ចេះចរយោគ្រា ។ ទាន់ឮបុត្រជាត់ ញ័រថ្ងើមប្រមាត់ សោយ
សោកខ្លាំងថា ឧមាសមិត្រទៅ ជាត់ទៅឋានណា ចោលម្តាយឲ្យផ្សា
ច្រូងច្រូតក្រំក្រៃ ។ ឬគោសិង្ហសិង្ហ៍ ខ្វាឆ្ងាក្របី ដោយដៃនជនវៃ
ប្រហារដំរីតែ មាសមិត្រក្សីណាក្ស័យ ក្ស័យឬមាសថ្ងៃ រិលរៀរវែងឆ ។
ទុក្ខខន្តុម ចោលអស់ស្រីស្នំ ចោលអស់ទីល្បែង ចោលម្តាយឲ្យម្តាយ
ខៅតាយឯកឯង ឯកអង្គខឿនតែឆ ខល់ទុក្ខសោកា ។ ឧបើម្តាយ
ដឹង ទៅតីព្រៃលឹង ទិត្យខៅឋានណា ម្តាយមិនទិត្យខៅ ទឹងទៅតាម
ចា តាមបុណ្យបុក បួកណាម្តាយហោង ។ ឬម្តាយបម្រាត់ បម្រាស់
កូនសត្វ ឲ្យឃ្លាតគូគ្រង ខើបម្តាយច្រាស់កូន ខ្ញុំមខ្ញុនស្នេហ៍ស្នង ពុំ
មូលមួយផង ដូចគាលសព្វថ្ងៃ ។ ខ្ញុនម្តាយមានអ្នក ថ្ងៃស្នេហាហាក់
ដូចជួនហ្ចាំយ ប្រសើរឥតមោះ ពុំខោះដូចនំយន៍ កែវនេត្រាថ្ងៃ តាំងពីរ
ទិត្យខៅ ។ ឧខ្ញុលក់ខ្ញុល ទីទំព្ងំណែល ជំណេកតាលៅ ជំ
ណេកជំណែល កន្ទេលខ្ចីយនៅ ជាត់តែឥត្តៅ ឋានណាពុំឃល់ ។
សត្វថ្ងៃគ្នានទុក្ខ ដ្បិតជាខំយល់មុខ មិត្រមាសថ្លើងថ្កល់ ដូចព្រះបន្ទូ
ចែងចាំងមណ្ឌល ស្រឡះទិមិល ឥតពាកចាំង ។ ព្រលឹងស្នូនអើយ

ខ្ញុំនម្ពាយចាស់ហើយ មិនបានចាំ ដូចឈើខ្ពង់ខ្ពស់ ដើមដុះខៀវច្រាំង
សង្ឃឹមអ្នកចាំង - ពីរលើកខ្នោចម្ពាយ ។ ទុមាសនិមិល បើម្ពាយពុំ
យល់ សមម្ពាយលោយ រំលោងបង្ហាក្នុង ជីពជន្មអន្ធកាយ ចរកចោល
អង្គកាយ ពិតពុំលែងឡើយ ។ នាងខ្ញុញសព្វ ។ ញាប់ញ័រចំប្រប់
តុំមានល្អែល្អើយ ឈឺខៀវកាយោ គក់ពកហើយ សោយសោកពុំ
សើយ សន្ធប់សុបសៅ ។ មេនំសាស្រែ មាត្សមុខមន្ត្រី ពស្ត្រវង្គកង
ក្រៅ សោតសង្ឃឹតពុំសុខ ជាខុក្ខសោកសៅ រលឹកខ្លួនៅ កុមារទាំងពីរ ។
ព្រហោអឌ្ឍកង ព្រហឹងរំពង ខ្លួចាំងជាន ឃក្ខភ័យភ្ញាំងភ្ញាត់ ឃកទឹកភ្នែ
ក្បឿតកន្ត្រែទើ ហើយលួងលោមថា ។ ទៃហែកែវកល្យាណ ចូរកែវ
កំសាន្ត កុំសោយសោកា ចូរប្អូនវាល័ក្ខណ៍ នៅក្នែរដ្ឋ បងនឹងលីលា
តែឯងអង្គនៅ ។ រកឲ្យឃង់ឃល់ ថារស្រេចចុះដល់ មន្ទីរហាន្ត្រៅ
មន្ត្រីសេនា យោងហៅនៅ ឃក្ខយាត់ឲ្យនោ ហើយបន្ទូលថា ។
អស់អ្នកសឹងសុខ្ខ រកពុំឃល់បុត្រ អញចាំងត្រីត្រា[1] អង្គអញឯងជាត់
តែសត្តទិក[2] ទឹងរកបុត្រភ្លា ចាំងពីឲ្យឃល់ ។ ចូរអ្នកពាល់គ្នា
ខិត្យនៅរក្សា នាងនាថនិមិល នៅព្រះនគរ បវរមេណ្ឌល ក្រែងកើត
អំពល់ បទអញពុំនៅ ។

---

១. តំបុត្រីបុត្រា ។ ២ ប្រែថាតែឯថ្ងៃទេ ។

រឿងសាមកុក

កំណែទី ២៨

ឧកញ៉ាវិបុលរាជសេនា ស៊ូ-ភីង ប្រែរៀបរៀង

តមក

> រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> ធំងបេះទុបាយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

ហាន់តីកំភ្លែងញុះញង់ថា ខៀនហាន់ដែលត្រូវពោសក្នន់គុកនោះ ឮដំណឹងថា លោកចាញ់ខ័ងចូវ រត់មកកំពះដៃស៊ីចហ៊ីយថា ព្រោះតែលោកមិនស្តាប់ពាក្យ ហ៊ីយឡើយកខៀនហាន់ទៅជាក់គុក ឥឡូវក៏ឃើញសមដូចពាក្យខៀនហាន់និយាយនោះមែន ។ អ្នកនៅវាំងបានស្តាប់ដូច្នោះក៏ទឹងណាស់និយាយថា “ម៉េលម៉ៅ ខៀនហាន់ជាហ៊ានចំអកឲ្យកឲ្យឃ្លះដៃឲ្យអញ ដូច្នោះ អញនឹងទុកជីវិតវាតទៅម្តេចបាន” ទើបយកក្រប៉ិចប្រគល់ឲ្យពាហានម្នាក់ហ៊ីយបង្គាប់ថា ឯងចូរស្រួតទៅឲ្យដល់ស្រុកមុនអញ យកខ្លួនខៀនហាន់មកសម្លាប់ចោលចេញ ។ ពាហានក៏ទទួលយកក្រប៉ិហ៊ីយលាចេញទៅ ។

ឯនាយកូយុំដែលនៅចាំរក្សាខៀនហាន់ ឮយាយនឹងខៀនហាន់ថា ខ្លួនខ្ញុំជាអ្នកតូចតាច តទៅមុខ ខ្ញុំសូមទីពឹងបុណ្យលោកផង ។ ខៀន

ហាន៍ស្ងួរនាយភូយុំថា ខ្ញុំនេះយើន៍ជាមនុស្សមានទោស ហេតុម្តេចបាន
ជាអ្នកមកនិយាយដូច្នេះវិញ ។ នាយភូយុំតបថា ពីមុននោះលោកបាន
ឃាត់ហាមអ្ននសៀវថា កុំគាល់លើកទ័ពទៅ បើចង្អុំលើកទៅនឹងបរាជ័យ
ចាញ់ចួនួ អ្ននសៀវមិនត្រមស្តាប់ពាក្យលោក បង្អុំលើកទៅធ្វើ
ការសឹកសង្គ្រាមគាល់តែបែកទ័ពត់មក ខ្ញុំយល់ឃើញថា សមដូចពាក្យ
លោកហាមឃាត់មែន អ្ននសៀវគន់នឹងដោះលែន៍លោក ហើយកប់
អាន៍ដើម្បីស្តាប់ពាក្យលោកវិញ នឹន៍ទុកបំរុង់លោកឲ្យធ្វើធំឡើន៍ទៅ
ខាងក្រៅ ហេតុនេះបានជាខ្ញុំសូមផ្តើខ្ញុំនប្រាណានឹន៍លោក ។ ខាងហាន
បានស្តាប់ដូច្នោះ ក៏អស់សំណើចហើយតបថា ដែលអ្នកនឹន៍ផ្តើខ្ញុំនប្រាណ
លើខ្ញុំ ។ ក៏អរណាស់ហើយ តែបើអ្ននសៀវត្រឡប់មកដល់កាលណា
ខ្ញុំនឹន៍ត្រូវស្លាប់កាលណោះ ។ នាយភូយុំឆ្លើយថា មនុស្សទាំន៍តួន
និយាយគ្នាថាលោកឃាត់ហាមយ៉ាន៍ម្តេច ក៏ត្រូវនឹន៍ពាក្យលោកទាំន៍អស់
មុខជាអ្ននសៀវនឹន៍ចំនុកបំរុង់លោកជាន៍ពីជើមឡើន៍ខាងក្រៅ ហេតុម្តេចបាន
ជាលោកនិយាយថា លោកនឹន៍ស្លាប់ដូច្នេះវិញ ។ ខាងហាន៍តបថា បើ
អ្ននសៀវមានជ័យជំនះលើសមកវិញ មុខជានឹន៍ចុកជីវិតខ្ញុំឲ្យនៅរស់ ត្រានេះ
អ្ននសៀវបែកទ័ពមកត្រូវដូចពាក្យខ្ញុំថាមែន យើញថានឹន៍មានសេចក្តី
អាប់យសអៀនខ្មាសដល់យើន៍ នឹន៍ឲ្យសម្ងាប់យើន៍ចេញជាប្រាកដ ដោយ
ហេតុចិត្តអ្ននសៀវនោះគាន់ចិដ្ឋមានះថា ខ្ញុំនជាធំមិនបានយកតំនិតអ្នក
ឯណា ធ្វើអាការបើជួបជាខ្ញុំននោះខ្លាំន៍ពូកែ មានតម្រិះប្រាជ្ញាជ្រៅ
ខ្ញុំលាយណាស់នឹន៍រកនរណាស្មើគ្នាន ។ នាយភូយុំបានស្តាប់ដូច្នោះក៏នៅ

មានសេចក្តីសង្ស័យ ខ្លួនមានតាហានអ្នកនៅម្នាក់ គាត់ក្រមុំចូលមកប្រាប់នាយភូឃុំថា អ្នកនៅប្រើខ្ញុំឲ្យមកសម្លាប់ខ្មែងហង៍ចេញ អ្នកបួរប្រញាប់នាំខ្លួនចេញមក ខ្ញុំនឹងសម្លាប់ចេញ តាមបង្គាប់អ្នកនៅ ។

ខ្មែងហង៍ឮស្តាប់ដូច្នោះ ក៏ប្រាប់នាយភូឃុំថា ខ្ញុំដឹងចិត្តអ្នកនៅស្រាកជណាស់ ឮជាខ្ញុំប្រាប់ដំណើរខ្លួនឲ្យស្តាប់ អ្នកក៏មិនចូលចិត្តផ្សឹ តឡូវឃើញមែនឬទេ? ។ នាយភូឃុំស្តាប់ហើយក៏អង្គុយយំដំនក។ ខ្មែងហង៍ថា "អ្នកកុំសោកសៅធ្វើអ្វីនាំឲ្យព្រួយ មានពាក្យបូកណាពោលពុកមកថា ធម្មតាកើតមកជាប្រុស បើនឹងកន្ទាយចៅហ្វាយ ក៏ផ្សាត់គ្រោះមើលឲ្យស្គាល់ចិត្តថ្លើមជាល្អ ឬអាក្រក់ជាមុន សិមចូលទៅនៅជង តឡូវខ្លួនខ្ញុំចោលពាក្យចាស់ចូរណា មិនឮនពិចារណាមើលចិត្តអ្នកនៅ ឲ្យប្រាកដជាល្អ ឬអាក្រក់ ឃើញតែយសបណ្តាសិក្តិ ក៏ចូលមកនៅនឹងអ្នកនៅ។ ជាមនុស្សល្ងង់លើតាប់តគ្រាជ្រា ឮជាខ្ញុំត្រូវខ្លួលពុក្ខពោសដល់ខ្លួនេះ ព្រោះកម្មរបស់ខ្ញុំ" ហើយខ្មែងហង៍ក៏សូមក្រមុំពីនាយភូឃុំមកអារកខ្លួនឯង ស្តាប់នៅពីនោះ ។ បណ្តាមហាជនលុះដឹងថា ខ្មែងហង៍ស្តាប់ ក៏នាំគ្នាសោកស្រណោះអាណិតអនាថ ខ្លួញយំតែគ្រប់ៗគ្នា ដោយគិតឃើញថា ខ្មែងហង៍ជាមនុស្ស មានចិត្តស័ត្យខ្មែនត្រង់ ។

ឯអ្នកនៅលុះលើកទ័ពទៅដល់ស្រុកគីដីវ៉ កំមានសេចក្តីពុក្ខពោមនស្សជាខ្លាំង តាំងតែរង្វើនេនជោងស្មារតីដោយចាញ់ទ័ពគេមក ក៏មិនបានចេញនិយាយពាក្យជាដូរថ្លៃ អ្នកចាំកំលាចិតាទៅនៅរក្សាស្រុកសៀនជីវ៉ាជាស្រុកចាស់ដូចដើមវិញ ។ ឯនាងខ្លាដឹងការយោយឃើញអ្នក

សៀវមិនសប្បាយ វង្វេងស្មារតីដូច្នោះ ទាំងខានចេញស្តីការពាដការ ជាយូរថ្ងៃទៀត ទើបចូលទៅសួរអ្នួនសៀវថា ខ្លួនលោកមិនមានសេចក្តី សប្បាយដូច្នេះ ធឹងតិតដូចម្តេច? ព្រោះពាដការផែនដីតើតចលាចលផ្សេង។ ឯបុត្រយើងទាំង ៣ នាក់ គឺអ្នួនចាំជាបងធឹងទៅឈរស្រុកសៀងជាវ, អ្នួន ហ៊ីទៅឈរស្រុកអ៊ីវជាវ, នៅតែអ្នួនស៊ុនជាប្អូន គឺជាកូនរបស់ខ្ញុំ អ្នកចូរ ពីគ្រោះមើល តើបុត្រណាមានសតិប្បញ្ញា ចូរចាត់ឲ្យទៅស្តីការពាដការ រក្សាស្រុកតីជាវនេះជាប្រញាប់ទៅ ទំរាំតែលោកធឹងមានសេចក្តីសប្បាយ ឡើងវិញ ។

អ្នួនសៀវឮខានស្តាប់ដូច្នោះ ក៏ឆ្លើយថា "នាងតិតដូច្នេះជាការត្រូវល្អ ហើយ" ទើបឲ្យហៅសឹមផោយ, ហងតឺ, ស៊ុនបេង, គួតៅ មកប្រឹក្សា ការតាមពាក្យនាងឡៅជី។ ទីប្រឹក្សាទាំង ៤ នាក់ក៏ប្រឹក្សាយល់ផ្សេងៗពីគ្នា ព្រោះសឹមផោយធឹងហិងតឺនោះ មានចិត្តស្រឡាញ់អ្នួនស៊ុង ចង់ឲ្យស្តីការ ពាដការក្នុងស្រុក ឯគួតៅធឹងស៊ុនបេងនោះចង់ឲ្យអ្នួនចាំធ្វើជាធំ ។ អ្នួន សៀវនិយាយថា អ្នកទាំង ៤ នាក់ ប្រឹក្សាការមិនត្រូវត្រឿងគ្នាសោះ គ្រា នេះ សឹកសង្គ្រាមសត្រូវតែក្រៅកំជាប់ជាចំណងធឹងគ្នា មិនខាន់ជាប្រក្រតី នៅឡើយ ខ្លួនយើងក៏មិនសប្បាយ ឯក្នុងស្រុកសោត យើងក៏តិតទាំង ឲ្យបុត្រម្នាក់ឈរក្សាទ្វារត្រ ដើម្បីជាចាកបង្គោលនៃផ្លូវពាដការ ធឹងបាន ការតាអន្តរាយជួយរក្សាសេចក្តីសុខ នៃអាណាប្រជាពស្ត្រទាំងឡាយ តាន់ការតេទៅ ដូចជាបុត្រាយើងទាំង ៣ នាក់នេះ យើងក៏សំគាល់ឃើញថា

រឿងហ្សាដ៊ីក

លោកវ៉ុលតែរ ឌីពទ

លោក រ៉ាយប៊ុក ប្រៃរៀបរៀង

តមក

វគ្គទី ៤

អ្នកលោភ

លោកហ្សាដ៊ីគ មានបំណងចង់បំភ្លេចរឿងកាល ដែលធ្វើឲ្យលោកមានសេចក្តីទុក្ខលំបាកជាច្រើន, ដោយការសិក្សាទូទៅស្តីពីវិជ្ជា ឌីឆ៍ការស្វែងរកមិត្តភាព ។ នៅភូមិក្រៅក្រុងប៉ារីសខ្លាន, លោកហ្សាដ៊ីគមានគេហដ្ឋានមួយដែលបានតុបតែងរចនាដ៏ល្អវិចិត្រ; ហើយលោកបានប្រមូលសិល្បៈ ឌីឆ៍វត្ថុនាំឲ្យសប្បាយយកមកជាក់ក្នុងគេហដ្ឋាននោះ ។ ក្នុងវេលាព្រឹកព្រហាម លោកបានបើកទ្វារបណ្ណាល័យ ខ្ចួលខ្លួនពួកបណ្ឌិត; ក្នុងវេលាថ្ងៃរសៀល លោកបានអញ្ជើញសុទ្ធតែពួកសប្បុរស ឌីឆ៍អ្នកប្រាជ្ញឲ្យពិសាក្រយាហារ ។ លោកបានជប់លៀង ហើយថែមទាំងមានភ្លេងតូរ្យតន្ត្រី ឌីឆ៍ការសន្ទនាគ្នាទៅវិញទៅមកផង ។ ក្នុងកិច្ចសន្ទនានេះ, លោកមិនបានប្រញាប់ប្រញាល់ បង្ហាញប្រាជ្ញាភ្លាម ។ ឡើយ ។

នៅជិតគេហដ្ឋានលោក, មានបុគ្គលម្នាក់ ឈ្មោះអារីម៉ាំសេ, ជាបុគ្គលពាលទុច្ចរិត, មានចិត្តលោភលន់ពន់ប្រមាណ ហើយបើគេស្រាន់តែក្រឡេកឃើញទឹកមុខ គេអាចយល់បានថា ជាអ្នកអសប្បុរស ។ អារីម៉ាំសេនេះ ប្រកបដោយចិត្តអាក្រក់ មានអាកប្បកិរិយាក្រអឺតក្រទម

ហើយថែមទាំងជាអ្នកបង្កើត ឲ្យគេអង្គុយ . . . ។ តាំយ៉ាបែបនេះ ធ្វើឲ្យឈ្មោះនេះមិនបានសម្រេចប្រយោជន៍អ្វីក្នុងលោក, ឈ្មោះនេះគឺគាំងចិត្តគំនុំគុំគួនអ្នកដទៃ ព្រមទាំងប្រើពាក្យផ្ទុសភ្ជាថែមទៀត ។

លោកហ្សាំង ពិតមែនតែលោកជាអ្នកមានទ្រព្យ សូម្បីតែអ្នកបង្ហោះក៏លោកអាចប្រមូលមក លេងតំណន្តសប្បាយបាន ។ ស្ថានេះដែលចូលទៅក្នុងគេហដ្ឋានលោកហ្សាំង ធ្វើឲ្យលោកអាម៉ាំសេអង្គុយត្រចៀកជាខ្លាំង សំឡេងដែលគេសរសើរលោកហ្សាំង ធ្វើឲ្យលោកអាម៉ាំសេស្តាប់ក្រហាយចិត្តជាខ្លាំង ។

លោកអាម៉ាំសេ បានអញ្ជើញទៅតំណន្តសប្បាយនៅគេហដ្ឋានលោកហ្សាំង, ម្ចាស់មួយកាល, ហើយក៏ចូលទៅអង្គុយនៅជិតតុមួយ ដោយគ្មានអ្នកណាអញ្ជើញឡើយ ។ បុរសនេះ ជាអ្នកធ្វើឲ្យកកស្អក់ខ្លាំងសេចក្តីសប្បាយនៃសង្គម ។ មានមួយថ្ងៃ, បុរសនេះ កំពុងសន្ទនាការជាមួយលោកហ្សាំង ស្រាប់តែមានជម្លោះម្នាក់ មកអញ្ជើញលោកហ្សាំងតែម្នាក់ឯង ទៅពិសារក្រយាហារជាកិត្តិយស, មិនបានអញ្ជើញលោកអាម៉ាំសេផងឡើយ ។

លោកអាម៉ាំសេ ជាអ្នកលោភនៅទីក្រុងថាប៉ាន មានធនុះយ៉ាងមាំចង់ចំផ្ទាញ់លោកហ្សាំងឲ្យនាសសាបសូន្យ ព្រោះឃើញលោកជាអ្នកមានតំណាងធំ ។ បណ្ឌិតហ្សូអែស្ត្រ បានពោលថា «កាលដែលនឹងធ្វើបាបអកុសលនោះ មានមួយរយដងក្នុងមួយថ្ងៃ, ហើយពេលវេលានឹងធ្វើបុណ្យកុសល មានតែមួយដងទេ ក្នុងមួយឆ្នាំ ។

អ្នកលោកនោះ ចាន់ទៅគាន់គេហដ្ឋានលោកហ្សាឌិត, ចាន់ឃើញលោកកំពុងដើរលេងកំសាន្ត នៅក្នុង១ខ្សាច ជាមួយនឹងមិត្តពីរនាក់ ខឹងនារីម្នាក់ ជជែកគ្នាអំពីសង្គ្រាម ដែលមហាក្សត្រចាន់បង្ហើយដោយជោគជ័យ ចំពោះព្រះអង្គម្ចាស់ហាវកាន៍សាមន្តភាជ ។ លោហ្សាឌិតក៏ចាន់លោលន្លូវសេចក្តីក្លាហាន ក្នុងសង្គ្រាមដ៏ខ្លាំងនោះ ដោយសរសើរព្រះអង្គន្លូវសេចក្តីក្លាហានជាអនេកប្បការ តែលោកមិនចាន់កូចនារីស្រស់ប្រឹមប្រិយនោះទេ ។ ក្នុងមួយរំពេច លោកហ្សាឌិតក៏ចាន់យកបន្ទះក្រដាសក្រាស់ហើយសរសេរជាពាក្យកាត់ប្លន់ឃ្លា ហើយដូនទៅនារីនោះអាន ។ តែក្នុងពេលនោះ ពួកមិត្តរបស់លោកទាំងពីរនាក់ សុំឲ្យលោកបង្ហាញពាក្យកាត់នេះ ដើម្បីយកមកអាន ។ លោកហ្សាឌិត មិនអាចបំពេញកិច្ចនោះប្រាប់ចំពោះមិត្តទាំងពីរនាក់នោះចាន់ទេ លោកក៏វាយចំបែកបន្ទះក្រដាសក្រាស់ជាពីរចំណែក ហើយចោះចោលទៅក្នុងគុម្ពោតផ្កាកូឡាប ។ មានមនុស្សទៅស្វែងរកបន្ទះក្រដាសនោះជាច្រើនលើក តែមិនឃើញ ។ បន្តិចទៀត, ខ្លួលមានភ្លៀង, អ្នកទាំងអស់ក៏លែងត្រឡប់ចូលទៅក្នុងគេហដ្ឋាន។

អ្នកលោកដែលនៅក្នុង១ខ្សាច, ក៏ចាន់ព្យាយាមរកបន្ទះក្រដាសក្រាស់នោះ ចាល់តែឃើញ ១ ចំណែក ។ នៅលើក្រដាសនោះ គេចាន់ឃើញពាក្យកាត់ន័យមួយ ។ ជារឹតមានន័យផ្សេងគ្នា ឬ ទៅជាពាក្យកាត់មានឃ្លាតូច ។ ទៅវិញ ។ តែដោយចៃដន្យប្លែកពីធម្មតា, ពាក្យកាត់តូច ។ មួយកំណាត់ ។ ដែលអ្នកឃើញប្រមូលមកនោះ ទៅជាពាក្យអាស្រូវកាស

ប្រទុស្តកយប្រមាថមើលងាយដល់ព្រះចេស្តា ជាយ៉ាងសំបើមអស្ចារ្យ
ព្រោះគេអានថា:

ដោយការប្រព្រឹត្តដ៏លាមកជាំ
នៅលើពជបល្ហង្គដ៏ប្រសើរ
កងសន្និភាពជាសាធារណៈ:
នេះតិបច្ចាមិត្តតែមួយ ។

អ្នកលោកក៏មានចិត្តត្រេកអរជាខ្លាំង ព្រោះខ្លួនមានកស្តុតាងនៅទីដៃ អាចធ្វើមនុស្ស ដែលមានគុណធម៌ឲ្យអន្តរាយបាន ។ អំនួតពេញទៅដោយការសប្បាយ ក៏យកបន្ទះក្រដាសដែលយើញៈនោះទៅគ្រាបបង្ហិនូលព្រះមហាក្សត្រ ។ ព្រះអង្គទ្រង់គ្រាស់បង្គាប់ឲ្យយកលោកហ្សុនិតព្រមទាំងមិត្តពីរនាក់ទីនាំម្នាក់ទៅជាក់គុក ។ រឿងនេះគេក៏បានសម្រេច ដោយស្ងាត់កំបាំង ។ ដល់លោកហ្សុនិតទៅគាន់សាលាដំបូងវិញ, អ្នកលោក ទៅស្ងាក់ចាំផ្លូវហើយស្រែកចំអក ដោយសំឡេងខ្លាំងថា ពាក្យការពារអ្នកឯង មិនមានតម្លៃសោះឡើយ ។

លោកហ្សុនិត មិនបានអួតថា ខ្លួនជាមេចិត្តការ៉ៃយ៉ាងចំណានទេ, តែលោកព្រួយបារម្ភខ្លាំងពេក ដោយលោកត្រូវគេឆ្គួលច្រាស អំពីបទថាក្បត់ព្រះមហាក្សត្រ ព្រមទាំងគេយកនារីស្នេហ៍ម្នាក់ ខ្ទឹងមិត្តរបស់លោកទាំងពីរនាក់មកជាក់គុក អំពីបទទ្រឹដ្ឋ ដែលអ្នកទាំងអស់មិនបានប្រព្រឹត្ត។ គេហាមប្រាមមិនឲ្យលោកនិយាយអ្វីសោះឡើយ ព្រោះថា បន្ទះក្រដាសក្រាំងនោះដាក់ស្តុតាងគ្រប់គ្រាន់ អាចពោលជួសខ្លួនលោកបានពិត

ប្រាកដ ។ នេះហើយជាបទបញ្ញត្តិច្បាប់ នៅទីក្រុងចាប៉ាឡាន ។ គេ
បានបណ្តើរលោកហ្សាឌិត ទៅចំកណ្តាលពួកប្រជាករ ដែលគ្មានអ្នកណា
មួយអាណិតអាសូរ ដល់លោកសោះឡើយ ។ ពួកទាំងអស់នេះ ក៏ស្ទុះ
ទៅមើលមុខលោក ដោយការចង់ដឹង តើលោកនឹងខ្លួលមរណភាព
ដោយសេចក្តីក្លាហានឬ .....? គេឃើញតែមាតាបិតាលោកមានចិត្ត
ព្រួយបារម្ភជាខ្លាំង ..... ។

កន្លងពេល ដែលលោកប្រុងប្រៀបនឹងខ្លួលខ្លួរមណៈ, ស្រាប់តែ
សេកព្រះមហាក្សត្រ ហើរមកពីលើវិមានព្រះបាទ ចុះទៅកាន់ទ្បាន
លោកហ្សាឌិត ត្រង់គុម្ពតង្កាកុឡាបមួយ ។ មានផ្លែប៉ែស្សមួយ
ដែលវាយោចបាកបក់ពីរុក្ខជាតិមួយដើម ធ្លាក់មកលើបន្ទះក្រដាសក្រាស់
មួយកំណាត់ទៀតនោះ ហើយក៏បែកឆ្ងាតជាប់ស្អិត ។ បក្សានោះ
បានយកទាំងផ្លែប៉ែស្ស ទាំងបន្ទះក្រដាសក្រាស់ ហើយក៏ហើរទៅទំលើ
ព្រះដំនូព្រះមហាក្សត្រ ។ ទ្រង់ក៏បានទតទៅឃើញលំពាក្យកាត្បាតែក
នៅលើបន្ទះក្រដាសក្រាស់ ទ្រង់បានអាន តែមិនយល់សេចក្តីថាយ៉ាងណា
ណា ចំពោះតែពាក្យកាត្បាងាងបុង ។ ទ្រង់សព្វព្រះពេជ្ញាទ័យនឹងកវីនិពន្ធ,
ហើយរឿងសេកនេះ ធ្វើឲ្យព្រះអង្គមានព្រះពេជ្ញាទ័យអណ្តែតអណ្តូងជា
ខ្លាំង ..... ព្រះអគ្គមហេសី ទ្រង់ត្រាស់បង្គាប់ឲ្យយកបន្ទះក្រដាស
ក្រាស់ ដែលគេបានប្រកាន់លើលោកហ្សាឌិត មកប្រៀបធៀបមើល ។
ទ្រង់ក៏បានអានពាក្យកាត្បា ដែលលោកហ្សាឌិតបានទិពន្ធ ។
ព្រះមហាក្សត្រទ្រង់ត្រាស់បង្គាប់ហៅក្រុមក្រុងលោកហ្សាឌិត ហើយនាំលោក

យកមកថ្វាយចំពោះព្រះកន្ត្រៃព្រះអង្គ ព្រមទាំងឲ្យដោះលែងចេញពីឃុំ ឃាំងនូវមិត្តទាំងពីរនាក់ នឹងនារីម្នាក់ ។ លោកហ្សាំគ កំសុះទៅ ថ្វាយបង្គំព្រះបមកគ មុខសំយុងចុះទៅកាន់ព្រះធរណី , ខឿបព្រះបាទ ព្រះមហាក្សត្រនឹងព្រះអគ្គមហេសី ។ លោកក៏បានសូមឲ្យព្រះអង្គ ព្រះពាន្ធុញ្ញាតទោស ដោយលោកបានធ្វើពាក្យកាត្សាអាក្រក់ ។ លោកក៏បានបញ្ចេញនូវវោហារ ក្នុងពេលនោះដោយសម្រស់ , ច្រើនជា ទីណាំចារណាញាណ ពាល់តែព្រះមហាក្សត្រ នឹងព្រះអគ្គមហេសី ទ្រង់ ត្រាស់បង្គាប់ ឲ្យចូលមកគាល់ថ្ងៃក្រោយទៀត ។ លោកក៏បានអញ្ជើញទៅ មកញឹកញាយ ក្នុងព្រះបរមរាជវាំង ពាល់តែមហាពរទ្រង់សព្វព្រះរាជហ្ឫទ័យ ពន់ពេក ។ គេបានប្រមូលសម្បត្តិទ្រព្យ អ្នកលោក ដែលចោទលោក ដោយពោលបង្កាច់ជាពាក្យមិនពិតនោះយកមកប្រគល់ជូនលោកទាំងអស់, តែលោកមិនព្រមយក , លោកបានប្រគល់សម្បត្តិទ្រព្យនោះ ទៅអ្នក លោកវិញ ។ អ្នកលោកនោះ មានចិត្តសប្បាយតែត្រង់ មិនខ្ចប់ខ្ចាតទ្រព្យ សម្បត្តិប៉ុណ្ណោះ ។

ព្រះមហាក្សត្រទ្រង់សព្វព្រះរាជហ្ឫទ័យ ទើលោកហ្សាំគ រៀន ពាល់ថ្ងៃ ។ ទ្រង់ត្រាស់បង្គាប់ឲ្យលោកចូលទៅជិតស្និទ្ធស្នាល ទើព្រះអង្គ ហើយព្រះអង្គ ទ្រង់ប្រឹក្សាការទាំងអស់ជាមួយទើលោក ។

លោកហ្សាំគ យល់ថា សេចក្តីសុខមិនជាលំបាកណាស់ទេ,តែ លោកអ្នកអាន ទើឃើញនូវព្រឹត្តិការណ៍ ខាងក្រោយថា មិនមែនដូច្នោះ ទេរ្បើយ ។ (មានត)

លោក ផើង-ជ្រើរ នៅក្រសួងប៉ោសនាការជាតិ

ប្រែចាកសៀវភៅ កុងត៍អេឡេសង់ដ៍ ដំ រ៉ោម៉ានី

(Contes et Légendes de Roumanie.)

រឿងព្រះនាង អាព៉ាបុស្កា

កុងកាលដ៏កន្លងទៅហើយ មានព្រះចៅពាជាធិពាជមួយព្រះអង្គ មានវិគ្គានុភាពជាពន់ពេក គឺថា បើត្រង់ទីណា ទ្រង់ស្តេចយោងចេញទៅធ្វើសង្គ្រាមហើយ សត្រូវត្រង់ទីនោះ ទៀនវិតងាក់បបខ្ទប់ខ្ទាចព្រះបេស្តាជាមិនខាន ។ ព្រះពាជរដ្ឋានៅជិតខាងរាំងប៉ុន្មាន លុះកុងអំណាចរបស់ព្រះអង្គគ្មានសល់ ។ ព្រះពាជាមានព្រះពាជបុត្រាបីព្រះអង្គ ប្រកបដោយរូបឆោមលោមពណិល្អ ។ ជួបគ្នា ហើយសេចក្តីគ្រហានក៏មានប៉ុន្មាន ។ លុះកាលណា ទ្រង់ជ្រាបថា សេចក្តីស្លាប់ដ៏តមកដល់ហើយ ព្រោះទ្រង់ព្រះជពណាស់ព្រះចៅមានព្រះពាជទន្ទឹងប្រាប់ដល់ព្រះពាជបុត្រ ឲ្យចេះតែបន្តការធ្វើសង្គ្រាមទៅទៀត ដើម្បីពង្រីកទូព្រះពាជអាណាចក្រ ខាងក្រោយការទើង្គីតនៃព្រះអង្គ ។ ប៉ុន្តែ ជួរកូនកុំទៅធ្វើសង្គ្រាមតន់ទឹងព្រះពាជរដ្ឋានៃព្រះនាង . អាព៉ាបុស្កា ដែលជាដែនមួយតាំងនៅកុងទិសបូពិជាប់ទឹងព្រះពាជរដ្ឋារបស់យើងឡើយ ដ្បិតថាបើអ្នកទៅធ្វើចម្បាំងតន់ទឹងព្រះនាងនោះ អ្នកមុខជាទឹងចោលឆ្អឹងនៅទីនោះជាមិនខាន ។ ពីព្រោះមិនដែលមានអ្នកណាចូលកុងនគរនោះ ហើយត្រឡប់មកវិញបានឡើយ ។

មិនយូរពេលប៉ុន្មាន មកពាជក៏យកជួនវិញាណរបស់ព្រះចៅទាំងចេញ

ចាកព្រះកាយទៅ ។ ព្រះកជបុត្រតាំងបីព្រះអង្គទៀនសោយភជ្ឈ
ជំនួសព្រះវរពជបិតាត្រមុត្តា ព្រោះទ្រង់ស្រឡាញ់គ្នាណាស់ ហើយមិន
ចង់បែកចេញពីគ្នាសោះ ។ លុះត្រង់ភជសម្បត្តិហើយភ្លាម ព្រះចៅ
តាំងបីព្រះអង្គ ទ្រង់ប្រឹក្សាគ្នាសម្រេចនឹងចូលទៅជួយនគរនៃព្រះនាង
អាភ័ប្ភស្ការ ដោយដំនុំគ្នាថា ព្រះវរបិតាយើង មិនគួរបើនឹងខ្វាច ដោយ
ឥតពិចារណាសោះ ព្រោះនៅក្នុងព្រះពជរដ្ឋាភិសបូពិ តែមិនឃើញមានអ្វី
ក្រៅពីទីពំលដាច់កន្ទុយកែក រកក្រួន រកភូមិ រកមនុស្សម្នាក់គ្មាន ។
ម្ល៉ោះហើយ ព្រះយុវរាជាតាំងបីព្រះអង្គ ទ្រង់សម្រេចឲ្យសម្តេចព្រះរៀម
ស្តេចយាន់ទៅមុន ជាមួយនឹងពលយោធាមួយកង៍យ៉ាន់ក្បាហាន ។
ប្រសិនបើមានគ្រោះថ្នាក់ដល់សម្តេចព្រះរៀម ហើយពេលដំណាច់ឆ្នាំ
មិនឃើញទ្រង់ស្តេចយាន់ត្រឡប់មកវិញទេ សម្តេចព្រះរៀមទី២ ត្រូវលើក
កង៍យោធាចេញទៅតាម ។ ជាទីបំផុត បើដល់ដំណាច់ឆ្នាំមួយចៅទៀត
ហើយមិនឃើញសម្តេចព្រះរៀមទី ២ ទ្រង់ស្តេចយាន់មកវិញទេ នោះ
ព្រះកជបុត្រទៅទីនឹងលើកកង៍ទ័ពចេញទៅដោយព្រះអង្គឯងតែម្តង ។

តិតក្លាមធ្វើក្លាម ។ លុះបានកេណ្ឌកង៍យោធាប្រើនល្មមត្រប់ត្រាន់
ហើយ សម្តេចព្រះរៀមឫទ្ធ ទាំកង៍ទ័ពចូលបន្តិចម្តង ។ សន្ធឹម ។ ទៅ
កន្លែដែនទៃព្រះនាង អាភ័ប្ភស្ការ ។

ពួកកង៍ទ័ពចេះតែត្រាច់ទៅ ។ អស់តាលដ៏ឃ្លេ ឥតបានឃើញអ្វីសោះ
ឃើញតែមេឃ ទីដីពំលក្រៀមក្រោះ ហើយពួកគាហានមានសេចក្តី
លំបាកវេទនា ដោយកេទឹកមួយដំណក់ផឹកគ្មាន ។ ប៉ុន្តែថ្ងៃមួយ នៅ

តេលមោង ១៤ ត្រង់ គេបានប្រទះឃ្លាសាខមួយភ្លឺចិញ្ចាចដូចថ្ម ។ ព្រះ
ចៅទ្រង់ចាត់ឲ្យរៀបកងទ័ពតាមស្នូនចម្បាំងមួយរំពេច ហើយទ្រង់ព្រះរាជ-
បញ្ជាឲ្យតំឡើងនោះ ។ ប៉ុន្តែនៅទីនោះ គេមិនឃើញមានមនុស្សម្នាក់
សោះ សូម្បីតែស្នាមជើងមនុស្សក៏គ្មាន មានតែតួឃ្លាសាខយ៉ាងល្អ
អស្ចារ្យ;ឥដ្ឋកំពស់យ៉ាងរលោង ឋខ្ទប់ទូលាយមានតន្ទឹកប់រយពាន់ មាន
រស្មីចាំងផ្លេក ។ ល្អជាងតន្ទឹព្រះមាតិត្យ ទ្វារទំនប់ធ្វើពីឈើខាងមួន
ប្រកបដោយក្បាច់ចំឡាក់ផ្សែង ។ ក្រោងទ្វារដំឡូងអាដោយត្បូងពេជ្រ
មានរស្មីចាំងចិញ្ចែង ។ មិនតែប៉ុណ្ណោះ គេឃើញតុះមួយយ៉ាងធំសម្បើម
ហើយនៅលើនោះ មានម្ហូបអាហារគោសពេញគ្រប់បែបយ៉ាងឆ្ងាញ់ពិសា
មួយណាដូចមួយណា ។ ហើយមានទេវតាមួយយ៉ាងវែង ដើរបំរើថ្វាយមិនដាច
ដាក់ពេញសុទ្ធតែធុងស្រាទំពាំងបាយជូរដាក់ពេញចិត្តដល់អ្នកធំក ដែល
គាន់តែវាំលេងយ៉ាងសប្បាយ ។

លុះបានឃើញកន្លែងនោះគាល ពួកតាហានតត់ដាក់ទេម្ចាស់
ភ្លាម ទាំងអស់គ្នាដកស៊ីផ្ទៀងពាំ តាមអំពីចិត្ត ទាល់ស្កឹកត្រចៀកឡើងក្រហម
រៀងខ្លួន តាំងពីកូនតាហានដល់នាយតាហានធំ។ ត្រមាំងព្រះចៅភជ-
ធិកដ. ហើយទាំងអស់គ្នាដេកវង្វេងវិលល ឥតដឹងខ្លួនច្បាស់ ។

លោកត្រី មានស្ត្រីក្រមុំម្នាក់ រូបល្អអស្ចារ្យ បើអ្នកណាឃើញសឹង
ភ្លឺកជាត់ស្មារតី ហោះមកកែ្ត ។ នាងពញាក់ពួកតាហានដោយសូរ
សន្ធឹក ប៉ុន្តែនាងរវៃតែមួយខ្លាប់ ទូរមនុស្សពាំងឮយ ដោយគាំបិតបន្ទោះ
ដែលនាងកាន់នៅដៃស្តាំ ហើយចាក់ធ្លុះមួយម្តង។ ភ្លាមនក្រៅប្រាសាទ

លើតំនរសាកសពទាំងឡាយដទៃ ។ រួចនាងលាងឈាមដែលប្រឡាក់ពាសពេញ ចិត្តធុនស្រាដែលហូរហៀរចេញចោល រៀបចំម្ហូបចំណីជាថ្មី បរិភោគដោយខ្ជួនខ្ជាង ហើយព្រឹកឡើងគេលស្រាងកំហោះទៅវិញថ្លាត់ ។ ម្ចាស់ហើយប្រាសាទនោះស្អាតឆង្គ គ្មានប្រឡាក់ដិតជាមដោយស្នាមរឿង ដែលកន្ធងទៅហើយនោះឡើយ ។

ព្រះអនុជទាំងពីរ មិនទ្រង់ឃើញព្រះរៀមស្តេចយាងត្រឡប់មកវិញ កំខោរធ្វើចាំអស់គេលមួយឆ្នាំ ។ លុះដល់គេលដំណាច់ឆ្នាំ ត្រូវនែព្រះរៀមទី ២ ជាអ្នកចេញទៅមុន ជាមួយទ័ពមាហានទាំងឡាយ ដែលប្រមូលបានមក បានទៅដល់ប្រាសាទដដែល ហើយត្រូវខ្លួលគ្រោះកាចដូចជាព្រះរៀមបង្ហើរដែរ ។ លុះដល់ដំណាច់ឆ្នាំមួយទៀត ព្រះរាជបុត្រទៅចាប់ធ្វើដំណើរចេញទៅ ។ ព្រះរាជបុត្រអង្គនេះគឺជាអ្នកកាន់រាត្តកន្ធទុកជាយកល ជាន់ក្នុងបណ្តាព្រះរាជបុត្រទាំងបី ។

ដូច្នេះ កាលព្រះអង្គទ្រង់ស្តេចយាងទៅដល់ប្រាសាទនោះ ពួកមាហានទាំងប៉ុន្មាន បានប្រព្រឹត្តអំពើដូចមាហានមុនៗទាំងឡាយ ។ ចំណែកឯព្រះអង្គមិនទ្រង់សោយសុកឡើយ បែរជាទ្រង់ស្តេចតាំងចេញទៅពួនទៅក្បែរប្រាសាទ លើមែកឈើមួយដើមយ៉ាងស៊ុបទ្រុប គ្មានអ្នកណាអាចមើលឃើញ ។

ព្រះអង្គទ្រង់ប្រថាប់ក្នុងទីនោះអស់ទិវាសកាល ។ ដល់គេលពេលត្រី ព្រះអង្គព្រះសណ្តាប់ឮសូរដូចជាខ្យល់ព្យុះបក់មកយ៉ាងខ្លាំង ហើយទ្រង់ស្តេចឧតយើញព្រះនាងសាក៏បុស្តាមកដល់ភ្លែត ឃើញចូលក្នុងប្រាសាទ

ឃើញចាក់ដុះឡើងពីហានរបស់ព្រះអង្គចុះចាល ។ ព្រះអង្គទ្រង់ពុះពោរក្នុងព្រះរាជហឫទ័យដោយព្រះពិរោធ ទំនងដោយព្រះទ័យមេត្តា តែទ្រង់មិនអាចទំនងធ្វើដូចម្តេចកើត ។

លុះព្រឹកឡើង ព្រះមហាស្វ៊ែត្រ ទ្រង់ទតឃើញនាងនោះហោះទៅវិញគាំបិតបន្ទះនៅដៃ ។ ប៉ុន្តែ ដោយទ្រង់ទតឃើញរូបនាងល្អប្រកបដោយសម្ផស្សយ៉ាងក្រៃពេក ព្រះកាងកទ្រង់ឈប់ទឹកគិតដល់សេចក្តីអន្តរាយ ទើបទ្រង់យាងចុះពីដើមឈើទ្រង់លោតតង់លើព្រះទីនាំងអស្សតរ ដែលទុកជាពាហានមួយរបស់ទ្រង់ ហើយបំផ្លាយដេញតាមនាងពីក្រោយ ។ ហេតុតែកុសលរបស់ទ្រង់ ជាន់ជាព្រះនាងអាភ័ព្វស្ការមិនឃាតក្រោយ ព្រោះអ្វី ប្រសិនបើនាងឯងឃើញ នោះសមព្រះទៅទំនងដុតព្រះដន្ធត្រឹមហ្នឹងស្រេច ។

ព្រះទៅចេះតែទ្រង់ស្តេចយាងតាម! ទ្រង់បរបំផ្លាយព្រះទីនាំងអស្សពាហន៍ទូងគាត់ក្តុំ កាត់ទ័ពល កាត់ព្រៃព្រឹក្សា! ជាទីបំផុត សេះហត់អស់ដើរ ព្រះអង្គក៏ហត់ ទើបជាន់ដល់នគរបស់សត្វចាបគឺជាព្រៃមួយកន្លែងនៅលើកំពូលភ្នំ ។ ត្រង់ទីនេះ ព្រះកាងជាន់ជាន់ព្រះនាងអាភ័ព្វស្ការ មិនដឹងជាទៅខាងណា ។ បើដូច្នេះ តើធ្វើដូចម្តេច ? ទ្រង់ដណ្តឹងសួរចាបថា: តើចាបទាំងនោះស្គាល់ទីលំនៅរបស់ព្រះនាងឬទេ ? ចាបទាំងអស់ធ្វើយព្រមគ្នាឡើងថា:

-សូមទ្រង់ព្រះមេត្តាជ្រាស! យើងខ្ញុំកល់គ្នាមិនស្គាល់ទេ ។

ប៉ុន្តែ បើទ្រង់ត្រូវការ យើងអាចបង្ហាញផ្លូវថ្វាយបាន ព្រោះព្រះ

នាងអាក៉ាបុស្សាទៅមកជានិច្ចតាមហ្នឹង ពិតមែនតែព្រះនាងមិនដែលឈប់។
ហេតុដូច្នេះ ចាប់ចិត្តស្ងួតត្រង់ ហើរនាំផ្លូវទ្រង់ដល់ព្រំប្រទល់ដែនខេត្តរបស់ខ្លួន ហើយក៏សូមលាព្រះអង្គមកវិញ ទុកឲ្យព្រះចៅស្តេចយាងតែមួយព្រះអង្គ ក្នុងការថែរក្សានៃព្រះអាទិទេពជាម្ចាស់។ ឯកោ អនាថា ព្រះកជាទ្រង់ធ្វើព្រះកជដំណើរតទៅទៀត ហើយទ្រង់ជាន់ឧត្តសត្វក្អែក ឧត្តសត្វអក ឧត្តសត្វតាជក់ សត្វទាំងនេះនាំសេចក្តីក្រាបបង្គំទូលដូចជាចាប់ដែរ តឹគ្មានដឹងអ្វីច្រើនទៅទៀត មិនដឹងជាព្រះនាងអាក៉ាបុស្សាតន៏ទៅទីត្រង់ណា គ្រាន់តែឃើញព្រះនាងកោះទៅហោះមកដូច្នេះ។

ព្រះចៅមិនទ្រង់បង្អន់ ក៏ស្តេចយាងក្បួយទៅទៀត រួចទ្រង់ជាន់ឧត្តសត្វត្រដេវវែង ឧត្តសត្វល្មាចេក ឧត្តសត្វត្រលីងត្រលោង ហើយបក្សីទាំងនោះជាន់ប្រជុំអស់ប្រជារាស្ត្រ ដើម្បីសាកសួរថា តើក្រែងមានឈ្មោះណា ធ្លាប់ជាន់ស្គាល់ទីលំនៅនៃព្រះនាងអាក៉ាបុស្សាដែរ? ប៉ុន្តែមិនមានសត្វណាមួយអាចឆ្លើយក្រាបបង្គំទូលជាន់សោះ។

ជាទីបំផុត គេជាន់ឃើញសត្វត្រដេវវែងពិការជើងម្ខាង ដើរប៉ាក់ពៀចមកដល់ ហើយក្រាបបង្គំទូលថា:

-បពិត្រព្រះករុណាជាអម្ចាស់ ខ្ញុំព្រះបង្គំស្គាល់ព្រះរង្គនៃព្រះនាងអាក៉ាបុស្សា។ -តើឯងស្គាល់ពិតមែនឬ? -សូមទ្រង់ព្រះមេត្តាជ្រាបសេចក្តីពិការនៃខ្ញុំព្រះបង្គំនេះ មកតែពីខ្ញុំព្រះបង្គំចង់ដឹងនូវនោះឯងជាហេតុ។ -ចុះព្រះនាងអាក៉ាបុស្សានៅឯណាអ្វី? -បពិត្រព្រះករុណាថ្វៃ-

វិសេស អាក៏បុស្តាជាស្ត្រីក្រមុំម្នាក់ មានតាំងតបន្ទោរជាកំឡាំង ។

បើគ្មានតាំងតបន្ទោរនោះទេ គឺជាស្ត្រីធម្មតាដូចជាអស់ស្ត្រីតាំងផ្តាស ។

ប៉ុន្តែ បើតាំងតបន្ទោរទៅគង់ដៃហើយ ព្រះនាងអាចបំផ្លាញមនុស្សក្នុងសាកលលោកតាំងមូលបាន ប្រសិនបើព្រះនាងចង់ ។

ព្រះចៅតំណេរទ្រង់សួរថា:

–ដូច្នេះ បើឯងដូនយើងឲ្យដល់ទៅទឹកដែនរបស់នាងផងតើបានឬទេ? –សូមទ្រង់ព្រះមេត្តាក្រោសបាន ប៉ុន្តែតិចបាក ។ –តិចបាកដូចម្តេចកំដោយ ។–ដូច្នេះ សូមព្រះអាទិទេពជាម្ចាស់ជួយគាំពារទ្រង់ផង ដើម្បីផ្តាញ់មារសត្រូវ!

ហើយយកចុងស្បាបទៅញុលព្រះគ័ត្រព្រះចៅ សត្វត្រដេវរៀបសូមឲ្យព្រះចៅដាំទីងបីដង ។

លុះព្រះចៅធ្វើតាម ស្រាប់តែរូបព្រះអង្គក្លាយទៅជាសត្វយុយមួយ គឺជាយុយធម្មតា ប៉ុន្តែ ចេះនិយាយទំនងចេះយល់ការណ៍សត្វត្រដេវ ។

ត្រដេវរៀបក្រាបបង្គំទូលថា: "ឥឡូវ សូមព្រះអង្គទំលើខ្នងទូលព្រះបង្គំមក ។

លុះព្រះចៅតំណេរ បានថ្វាយសេចក្តីអរគុណ ចំពោះសកុណាតាំងឡាយនោះហើយ ត្រដេវរៀបសុះហើរកែតបានជាប់ខ្សែលើរួចក៏ហើរបន្ទាបបន្តិចម្តង ។ ចុះមកដី ។

ព្រះចៅទំទៅគោងខ្នងសត្វត្រដេវរៀបស្ទើរតែមិនជាប់ កំយុខ្លាចក្រែងធ្លាក់ ហើយស្រែកសរសើរថា: "អ្នកឯងហើរលឿនមែន" ។

ត្រដែវរៀបក្រាបបង្គំទ្រូយតបថា: " បើប្រសិនជាដើរតាមធម្មតាបីឆ្នាំទើបដល់ ,, ។ ហេតុដូច្នេះ ឆានជាទូលព្រះបង្គំនិមិត្តព្រះអង្គឲ្យក្លាយទៅជារុយ ។

រួចទទេះស្ងាបតែបីប្តូនជង់ទៀត ជនតាំងពីកើតមានទៅដល់ ។ គ្រានោះ សត្វត្រដែវរៀប ក្រាបបង្គំទូលព្រះចៅកំឡោះ សូមឲ្យទ្រង់លោតដាំទីនបីដងជាថ្មី ហើយព្រះអង្គកំត្រូវយាងមកជាមនុស្សវិញ ។ តមកទៀតបក្សីចង្កឹលច្រាប់ច្រាសាទនៃព្រះនាងអាព៉ាបុស្ការ ដែលតាំងនៅលើកំពូលភ្នំតួចមួយ ។ ក៏ក្រាបបង្គំទូលថា:

-សូមព្រះអង្គស្តេចយាងព័ទ្ធប្រាសាទ ព្រះអង្គនឹងទ្រង់ប្រទះទ្វារមួយជាវិការៈនៃមាស បើយាងទៅតាមទ្វារនោះ ទ្រង់នឹងបានដល់បន្ទប់ដែលព្រះនាងអាព៉ាបុស្ការ តែងផ្ទំសម្រាកកាយ ក្រោយពេលត្រឡប់មកពីធ្វើដំណើរនេះវិញ ។ សូមព្រះអង្គឈប់ចាំឲ្យព្រះនាងផ្ទំលក់សិន រួចទំចូលយ៉ាងដូចម្តេច កុំឲ្យព្រះនាងដឹង រួចលួចយកកាំបិតបន្ទោះទៅលាក់កន្លែណាកុំឲ្យព្រះនាងរកឃើញ ។ ទូលព្រះបង្គំសូមទូលថា បើព្រះអង្គយាងបូលដល់ហើយ ទ្រង់ចង់ត្រូវការនឹងរូបព្រះនាងយ៉ាងណា ទ្រង់ចេះតែធ្វើបាន តាមព្រះកដបំណង ឥតមានរឿងហេតុអ្វីឡើយ ។

ព្រះចៅកំឡោះ សូមថ្វៃងអំណរគុណដល់សត្វត្រដែវរៀបច្រើនជាអនេក ប៉ុន្តែ បក្សីចិត្តស្មូតត្រង់ មិនត្រូវការនឹងសេចក្តីសួរសុមច្រើនពេកក៏ស្ទុះហើរត្រឡប់វិលវិញ ដោយថ្វាយពរសត្វសាធុការ សូមឲ្យព្រះចៅទ្រង់បានសម្រេច ដូចព្រះហឫទ័យប៉ុនប៉ង រួចក៏ហើរបាត់ទៅកន្លែអាកាស។

ព្រះចៅកំឡោះទ្រង់ធ្វើតាមបណ្តាំរបស់ត្រកូវរៀច ព្រះអង្គសម្រេច
លួចយកថ្នាំតាបិតបខ្មោះ ហើយលាក់ទុកយ៉ាងស្រួលបួល ។ រួចទ្រង់
វិលមកតង់ជិតព្រះនាងអាភ័ព្វស្លាប់ប៉ុន្តែ ទ្រង់មិនតាចនឹងដួចម្តេច ឲ្យព្រះនាង
តើនឡើងបាន ទើបព្រះចៅចាប់តុបព្រះនាងវិតមួង ។

លុះព្រះនាងអាភ័ព្វស្លាប់ទ្រង់ក្តាក់ឡើង ក្នុងព្រះហស្តនៃក្រុះចៅកំឡោះ
ព្រះនាងបងចិញ្ចឹម ចោលទេត្រូវកតាំបិតបខ្មោះ ហើយសុះគ្រាក
ចេញយក។ ប៉ុន្តែ លុះកតុំយើញ ព្រះនាងយល់ច្បាស់ថា ព្រះនាងពិតជា
លុះក្នុងកណ្តាប់ព្រះហស្ត នៃព្រះចៅកំឡោះដែលតង់នៅក្បែរនេះហើយ
វេលាដែលព្រះចៅសុះមកតុបមួងទៀត ព្រះនាងក៏ត្រឡប់តុបព្រះអង្គវិញ។

ព្រះនាងអាភ័ព្វស្លាប់ ខំលួងលោម សូមឲ្យព្រះ ចៅប្រាប់កន្លែងលាក់តាំបិត
បខ្មោះ ប៉ុន្តែព្រះចៅមិនព្រមប្រាប់ ខ្លាចក្រែងមានរឿងដូចលើកមុនទៀត។

ខាងក្រោយដែលបានតុបចើបគ្នាចេញមក ព្រមបបោសអង្អែល
អស់ចិត្តស្រេចហើយ ព្រះចៅទ្រង់នាំខាងវិលត្រឡប់មកព្រះនគរវិញ ។

ព្រះចៅនឹងព្រះពជជាយាយាងតម្រង់ព្រះពជរដ្ឋា ។ ប៉ុន្តែ ម្ចងនេះ
ខុសពីលើកមុនគឺសុទ្ធតែចំក្រែងមានផ្លុះល្អ ។ មានមនុស្សយ៉ាងច្រើនអឺក-
ធឺក ។ មនុស្សទាំងនេះ គឺជាព្រះនាងអាភ័ព្វស្លាប់ ដែលជាអ្នកសត្រូវនឹង
មនុស្សជាតិ បានបំផ្លាញបាត់អស់ ដោយប្រើអាវុធគឺតាំបិតបខ្មោះនេះ។

ឥឡូវតាំបិតខ្មោះបាត់ហើយ វត្តភាំងប៉ុន្មានព្រមទាំងមនុស្សត្រឡប់
មានជីវិតឡើងវិញទាំងអស់ ដោយទាំងព្រះរៀមទាំងពីរព្រះអង្គរបស់ព្រះ
ចៅ ហើយនឹងកងពលយោធាទាំងអស់ផង ។

ឆ្លាតនឹងប្រវត្តិសាស្ត្រ

សុន្ទរកថាដ៏ឆ្លាតលើសលុប

ដែលលោកព្រឹទ្ធបុរីបានថ្លែងក្នុងពិធីបុណ្យ

ពុទ្ធជយន្តី ព.ស. ២៥០០ នៅប្រទេសឥណ្ឌា ។

សុន្ទរកថាថ្លែងចំពោះមុខឧបាសិកាឆេហ៍ភូដ្ឋមន្ត្រីធិ ១
ប្រទេស ៥ណ្ឌៀ ក្នុងឱកាសបុណ្យពុទ្ធជយន្តីប្រទេស
៥ណ្ឌៀ កាលពីថ្ងៃសុក្រទី ៣០.១១.៥៦ នៅភ្នំពេញ ។

លោកនាយករដ្ឋមន្ត្រី ប្រទេស៥ណ្ឌៀ !

លោកអ្នកជាបណ្ឌិតា នៃសាពេតិមានភាន់ឡាយ !

ថ្ងៃនេះជាថ្ងៃទទួលបុប្ផាជ័យមង្គលសិរីសួស្តី ដោយខ្ញុំបានមកជួបជុំនឹង
លោកនាយករដ្ឋមន្ត្រីប្រទេស៥ណ្ឌៀ នឹងអស់លោកដែលជាបណ្ឌិតា
សាពេតិមានភាន់ឡាយ ។ អតិលទ្ធិតសម័យ តពិធីបុណ្យគាត់កណ្តាល
សាមនា ដែលលោកនាយកបានផ្តើមធ្វើជំនឡាវែកនេះ ហើយបានមកញ៉ែញ
ខ្ញុំដាផ្លូវការមកកាន់ទីនេះ ខ្ញុំសូមថាវែកទុកក្នុងឋានយាត្តិ ប្រៀបដូច
សិលាចារឹកដ៏ប្រសើរ ដែលខ្ញុំចាំទុកឥតមានភ្លេចសោះឡើយ ហើយថែម
ទាំងគួរកំណត់ទុកក្នុងប្រវត្តិសាស្ត្រប្រទេសកម្ពុជា នឹងប្រវត្តិនៃពុទ្ធសា.
សនាខ្មែរ ឬសមាគមមិត្តភ្ញុំកវិទ្យាល័យ ។ ម្យ៉ាងទៀតខ្ញុំមាន

អំណរជាយ៉ាងក្រៃលែង ហើយសូមថ្លែងនូវគតញ្ញូតវេទិតុណ អំពី
ការទទួលគ្រប់ពីរខ្នែង ដោយកិត្តិយសដ៏ប្រសើរ តាំងពីការបរិភោគម្ហូប
អាហារ, ការស្នាក់អាស្រ័យជាដើម ។

ប្រទេសឥណ្ឌា ជាប្រទេសមួយ ប្រកបដោយអារ្យធម៌ដ៏ខ្ពង់ខ្ពស់
តាំងពីបុរាណសម័យ ។ ជនជាតិដែលមកតាំងទៅដំបូងនៃប្រទេសឥណ្ឌា
ជាពួកអរិយៈដែលបានផ្សាយអាទិភាពទៅក្នុងប្រទេសអឺរ៉ុប ដូចលោក
ហិរ៉ែតូតជាតិតនាយករដ្ឋសាស្ត្រមាំញ បានប្រកាសថា: " ពូជសែរម៉ាំងជាពូជ
អរិយៈ " ។

លំដាប់តមក, ប្រទេសឥណ្ឌាមានបច្ចាមិត្តចូលមកលុកលុយជា
ច្រើនលើកច្រើនសារ ដំបូង ស្តេចអាឡិកសន្ត្រីឡឺក្រង់ មហាក្សត្រ
ម៉ាសេដ្ឋាន បានលើកកងទ័ពមកដល់ទ្វារម្រទេសឥណ្ឌា កំពង់ពីវត្តក
ក្នុងពេលនោះទៅ ។ លំដាប់មក, ស្តេចសង់ស៊ីសវ័ន ឬគូប៉ីឡៃវ័ន,
មហាក្សត្រមង់គោល ទង់លោកតាមៃឡង់មេទ័ពបានលើកកងទ័ពចូល
មកវាយប្រទេសឥណ្ឌា ។ តមក, មានពួកស្តេចអាវ៉ាប់តាំងពីព្រះបាទ
ជាថ្មា, អ័តថារ, សីហង់សីរបានលើកកងទ័ពមកតយុទ្ធទឹងប្រទេសឥណ្ឌា
បានជោគជ័យតាំងពដ្ឋានទីទៅអគ្រ: ។ រួចមានការតេស្ងូតួតមហាម័តទឹង
ព្រហ្មញ្ញសាសនា ឬព្រហ្មញ្ញសាសនាទឹងពុទ្ធសាសនាជាដើម ។

សម័យក្រោយមក, ព្រះអគ្គមហាសេនាបតីឧត្តមទឹងឡាប៊ុរបុណ្ណស បាន
ចូលទៅវាយប្រទេសឥណ្ឌា ហើយយកបានតំបន់ជាច្រើនកន្លែង ហើយ
ព្រះបាទស្តីទី ១៥ ប្រទេសថាកំងបានតែងតាំងជាសួរ៉ែរណ៉ីរសេរណ៉ាល់

នៃក្រុមហ៊ុនឥណ្ឌូ ១៧៤២ ។

ក្រោយមក, អង់គ្លេសបានរើយដណ្តើមប្រទេសឥណ្ឌូយកបានពីបារាំង ។ រួចលោកមហាត្មៈគន្ធី ដោយនិយមយកធម៌អហឹង្សៈទឹងសច្ចៈគ្រហៈមកជាផ្លូវប្រតិបត្តិ ទឹងលោកបណ្ឌិតនេហ៊ូ ក៏បានលើកជាដំបូងនូវទង់ជ័យជាតិ ដើម្បីតាមទាវឯកពភ្ជប្រទេសជាតិមាតុភូមិ ។ ក្រោយដែលមានមហាត្មៈគន្ធី បានអត់អហារជាច្រើនលើក, ប្រទេសឥណ្ឌូក៏បានបែងចែកជាពីរដ្ឋតឺ រដ្ឋឥណ្ឌូស្តង់ ទឹងប៉ាគីស្តង់ ។ ក្រោយដែលមានពួកឥស្សរកុច្ចិតេ ធ្វើឃាតកម្ម ១៩៤៨, ឯកពភ្ជប្រទេសឥណ្ឌូក៏បានបញ្ចេញរូបភាពច្បាស់លាស់ ហើយបណ្ឌិតនេហ៊ូ ដែលមហាត្មៈគន្ធីបានតែងតាំងលោកជារដ្ឋមន្ត្រីទី១ ប្រទេសឥណ្ឌូ ១៩៤៧ ក៏បានបន្តនយោបាយលោកមកលុះសម័យបច្ចុប្បន្ន ។

ចំពោះការគាក់ទងប្រទេសកម្ពុជានឹងប្រទេសឥណ្ឌូ ព្រះបាទគោ.ណ្ឌញៈព្រះមហាក្សត្រីសម័យហ្នឹងជាតំបូង មានសញ្ជាតិជាឥណ្ឌូ ។ អក្សរសាស្ត្រខ្មែរ, វប្បធម៌ខ្មែរ, ទំនៀមទម្លាប់ខ្មែរ តើតឡើងដោយមានការសិក្សាឥត, ជាលើជាមូលដ្ឋាន, ទំនៀមទម្លាប់ព្រាហ្មណ៍បានរក្សាទុកនៅក្នុងពិធីបុណ្យព្រះបរមពជកំង ដូចមានជាគូ បរោហិតស្រាប់ ។

ខាងសាសនា, ជំបូងប្រទេសកម្ពុជា បានទិយមគាន់ព្រហ្មញ្ញសាសនាហ៊ីនយាន ។ គេបានតំណាលរឿងថា :

ព្រះពុទ្ធសាសនាមានតិក្ខុបានទាំយកមកតាមផ្លូវគោក, ទឹកប្រតិស្ថានទៅកោះស៊ីឡង់ ហើយមានតិក្ខុយកទៅផ្សាយឯឧបទ្វីបឥណ្ឌូចិន ។ ១ផ្នែក

ទៀត ជាន់ទៅពីក្រសួងខ្មែរគង្គាទឹងព្រហ្មបុត្រ (ចង្កឹលខាងកើត) ទៅ
កាន់ជ្រោះស្ទឹងសុរម៉ា ទឹងជាកន់ទៅដល់ខ្មែរអ៊ីវ៉ាដ្ឋីទឹងសាលូអែនរហូត
ទៅប្រទេសភូមា, ស៊ីយ៉ាម, កម្ពុជា ។ តាំងពីព្រះពុទ្ធសាសនាហីន-
យាន ចូលទៅប្រតិស្ឋានទៅប្រទេសកម្ពុជា, ព្រះពុទ្ធសាសនាហីនយាន
ក៏មានអានុភាពបន្តិចម្តងៗ រហូតដល់ធ្លើពុទ្ធសាសនាមហាយានទឹង
ព្រះហ្ន័ញសាសនា ត្រូវរលត់រលាយសូន្យឈឹងលុះសព្វថ្ងៃ ។

លំដាប់ក្រោយមក, ១៩៥២, ដោយសេចក្តីសុំនៃសម្តេចព្រះមហា-
សុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ជួន-ណាត ដោតញ្ញាណោ
ប្រទេសកម្ពុជា ជាន់ឧបសម្បទាព្រះបរមសារីរិកធាតុព្រះបរមសម្មាសម្ពុទ្ធ
ទឹងអគ្គសាវកទាំងពីរទៅកាន់ជាន់ទីក្នុងពេញ។ ព្រះករុណាជាអម្ចាស់ជីវិត
លើក្បាល ឥឡូវទ្រង់ជាសម្តេចព្រះនរបយុវរាជ ក៏ជាន់ឲ្យរៀបចំពិធី
ឧបសម្បទាកិច្ច ហើយជាន់ទៅប្រតិស្ឋាន ទៅវត្តព្រះកែវមរកត ធ្វើ
បុណ្យជាច្រើនថ្ងៃ, ក្រោយមក ពី គ.ស. ១៩៥៥, សម្តេចព្រះនរបយុវរាជ
ទ្រង់ស្តេចយាងទៅកាន់ប្រទេសវៀតណាម, ក៏ទ្រង់ជាន់តំណាងមេត្រីភាព
រវាងប្រទេសទាំងពីរ ក៏កាន់តែមាំមួនឡើង ហើយជាន់ប្រកាសថា ប្រទេស
កម្ពុជាគាន់អព្យាក្រឹតភាព ដូចប្រទេសវៀតណាមដែរ ហើយជាន់ប្រកាស
លំនួនគោលទាំង ៥ ជាតាគានយោជាយដែលត្រូវប្រព្រឹត្តប្រតិបត្តិតាមគឺ

១- ត្រូវឧបត្ថម្ភលើកទូរអធិបតេយ្យ, ឯកភាពភាព ទឹងបូណិ-
ភាព នៃប្រទេសទៅវិញទៅមក,

២- មិនត្រូវលើតើនគ្នាទៅវិញទៅមក,

๓- ត្រូវរក្សាឲ្យមានសមភាព ទំនាក់ទំនងគ្នាទៅវិញ ទៅមក,

๔- មិនត្រូវជ្រៀតជ្រែក ទំនាក់ទំនងក្នុងប្រទេសទៅវិញ ទៅមក ។

๕- ត្រូវរក្សាឋានៈ ទំនួលខុសត្រូវ ដើម្បីតំរង់ទិសការសង់ទៅជាមួយគ្នា ដោយសន្តិសុខក្នុងសាកលលោកតទៅ ។

ចុងខែវិច្ឆិកា ๑๙๙๖ សម្តេចព្រះនរោត្តម សម-សារី ជានាយកគណៈប្រតិភូខ្មែរ ប្រទេសកម្ពុជា បានស្តេចយាងទំនិញមកកាន់ប្រទេសនេះ ក្នុងពិធីបុណ្យពុទ្ធជយន្តីប្រទេសនេះ ដើម្បីទំនាក់ទំនងតមនាគមន៍ ឲ្យកាន់តែជិតស្និទ្ធឡើង ។

ប្រទេសកម្ពុជា ទំនាប់ប្រទេសឥណ្ឌា បានកាន់អត្សាក្រិតភាពជួបគ្នា មានមាគ៌ានយោបាយជួបគ្នា, សូមកាន់ដៃគ្នាទៅវិញទៅមក ដោយសម្ពន្ធមិត្តជិតស្និទ្ធ ព្រមទាំងរក្សាអត្សាក្រិតភាពនេះ ឲ្យតែបំផុតទៅអនាគត ដើម្បីទំនាក់ទំនងរបស់ប្រជាជនកាត , សេរីភាព , ភាតរភាព, សម្ព័ណ្ឌភាព ជាហេតុឲ្យលោកបានសន្តិភាព អស់កាលដ៏យូរអង្វែងទៅ ។

សារលិខិតថ្វាយទៅមហាវិទ្យាសញ្ជ័ (រដ្ឋកោចាល) ប្រទេសឥណ្ឌា តាសព័ត៌ថ្ងៃអង្គារទី ๔-๑๒-๙๖ ក្នុងនាមសព័ន្ធបុណ្យពុទ្ធជយន្តី ប្រទេសឥណ្ឌា ។

លោកជុកវ័រ បត្តាត-ស័តរៈមយៈ នាយករដ្ឋមន្ត្រីប្រទេស ខែត្រកោចាល!

ព្រះតេជព្រះគុណ លោកអ្នក លោកស្រី គណៈប្រតិភូទាំងឡាយ !

ពួកពុទ្ធសាសនិកជនទៅសញ្ជីទាំងឡាយ !

ខ្ញុំខ្ញុំជាតំណាងពួកពុទ្ធសាសនិកជនប្រទេសកម្ពុជា សូមថ្លែងនូវ
កតញ្ញូកតវេទិតុណ ចំពោះមហាពាធិសមាគមសញ្ជឹ ដែលបានរៀបចំពិធី
បុណ្យនេះ ទទួលគណៈប្រតិភូនានាប្រទេស ដែលបានមករួមប្រជុំនៅ
បុណ្យព្រះពុទ្ធសាសនាប្រទេសឥណ្ឌា ។ ខ្ញុំសូមថ្លែងនូវចិត្តសោម-
នស្សជាយ៉ាងក្រៃលែង ចំពោះរដ្ឋាភិបាលឥណ្ឌា ដែលបានរៀបចំទទួល
គណៈប្រតិភូដោយទទ្រឹងកិត ។

ពិធីបុណ្យនេះ ខ្ញុំទទឹងក្រែងក្នុងជួងហាងឃវត្តទុកជាអនុស្សាវរីយ៍ដ៏
ប្រសើរ ប្រៀបដូចជាបុប្ផាផ្សាយក្លិនក្រអូបទៅសព្វទិសាទុទិស ។ ពិធី
បុណ្យនេះ, ជាស្ពានទូន្មឲ្យពួកពុទ្ធសាសនិកជនតាំងឡាយឮច្បាស់ ហើយ
ស្រាកពីនិទ្រាឈរឡើង ដើម្បីត្រួតដៃគ្នាតស៊ូនូវអយុត្តិធម៌គ្រប់យ៉ាង
ការបង្ក្រិះឈ្មោលឥតប្រ ឯជន ព្រមទាំងរក្សាសន្តិភាពលោក ក្នុងកាលជា
អនាគត ។

អាសាខ, ពួកពុទ្ធសាសនិកជនប្រទេសកម្ពុជា សូមព្រះត្រ័យរតន:
ថ្នូរសំដែងរដ៏ឃមន្តិលសិរីសួស្តីគ្រប់ដំណូក ចំពោះពួកពុទ្ធសាសនិកជន
សព្វថ្ងៃ, ប្រទេសឥណ្ឌា, នានាប្រទេស សូមរក្សានូវសាមគ្គីភាពដែលជា
កំពូលមួយ ដើម្បីនឹងការពារកុំឲ្យក្មួលក្លៀង នៃមហាសង្គ្រាមសាកលលោក
ផ្ទុះឡើងបាន ។

សូមបត្តិទានឥស្សរជនសេចក្តីបវរមេសុខ ។

×

× ×

សារលិខិតថ្ងៃដ៏ផៅពុទ្ធជម្ម ក្នុងសកាព ពុទ្ធិកសមាគមបង្គ្លល កម្ពុលកត្តា ប្រទេសឥណ្ឌា ថ្ងៃពុធទី ១២.
១២.៥៦

សូមនមស្ការចំពោះព្រះសង្ឃគាំងឡាយ !

សូមជំរាបលោកប្រធានពុទ្ធិកសមាគមនៅបង្គ្លល !

សូមជំរាបពួកពុទ្ធសាសនិកជននៅបង្គ្លល !

ថ្ងៃនេះជាថ្ងៃបឋមដែលខ្ញុំមានកិច្ចសំណាងបានមកកាប្រសព្វនឹងពួកពុទ្ធសាសនិកជនបង្គ្លល, ជាអតិលក្ខិតសម័យដ៏មានផាតជ័យមង្គ្លលសួស្តី។ ពួកពុទ្ធសាសនិកជន ប្រទេសកម្ពុជាបានមកតែចំណាងកាតកោតចំពោះពួកពុទ្ធសាសនិកជនបង្គ្លល ប្រទេសឥណ្ឌា នឹងនានាប្រទេស ដែលមកជួបជុំនៅទីនេះ ដោយយល់ថា យើងគាំងអស់គ្នាជាអ្នកកាន់ព្រះពុទ្ធសាសនាដូចគ្នា, គោរពព្រះបរមសម្មាសម្ពុទ្ធតែមួយព្រះអង្គ, ប្រព្រឹត្តប្រតិបត្តិតាមពុទ្ធោវាទដូចគ្នាគាំងអស់, យើងគាំងអស់គ្នា សូមសំដែងកតវិទេសនេះទូទឹកចិត្តដ៏ស្មោះស្ម័ត្រព្រតដែគ្នា កសាងព្រះពុទ្ធសាសនាឲ្យមានវឌ្ឍនភាពតទៅ ។ ពុទ្ធិកសមាគមពិភពលោក ជានស្ថាបនាឯនានាប្រទេសសាកលលោកនូវសាខាគ្រប់កន្លែង ។

ព្រោះហេតុនេះ យើងគាំងអស់គ្នា សូមជួយឧបត្ថម្ភសាខាគាំងនោះធ្វើសកម្មភាពឲ្យបានមាំមួន ផ្សាយព្រះពុទ្ធសាសនាគ្រប់ម៉ត់បន់ ដើម្បី

ជាឧសថទិព្វ សម្រាប់ការពារមហាសង្គ្រាមសាកលលោកទីបំផុតនៅអនាគត។

សូមព្រះពុទ្ធសាសនាឱ្យបានចម្រើន !

សូមពុទ្ធសាសនិកជនឱ្យបានសុខ !

×

× ×

សេចក្តីថ្លែងឯកឧត្តមសម-សារ៉ាំ

សមាជិក ឧត្តមប្រឹក្សា ឯកជន អមព្រះរាជា ប្រធានខែធម្មានុប្រតិបត្តិប្រទេសកម្ពុជា ក្នុងឱកាសពិធីបុណ្យពុទ្ធជយន្តីប្រទេសតណ្ឌៀ កាលពីថ្ងៃចន្ទ ទី ៤៦ ខែឧសភា ១៩៥៦ ពេលម៉ោង ១៥;៣០ នាទី នៅវិញ្ញាណវិន; (មន្ទីរសន្និសីទក្រុង) ញូវដែលស៊ី ។

អានុភាពព្រះពុទ្ធសាសនាបំពោះសិល្បៈ

ព្រះពុទ្ធសាសនាមានអានុភាពអស្ចារ្យចំពោះប្រទេសជាច្រើនត្រមតាំងប្រជាពស្ត្រខ្មែរ ។ គឺក្នុងព្រះពុទ្ធសាសនានេះឯង ដែលប្រជាពស្ត្រជានយកពាខ្លះ មកធ្វើជាបរិតនិស្ស័យរបស់ខ្លួន ដូចជាខន្តី សុចរិតសេចក្តីបរិសុទ្ធិ ចំនៀមខម្ងាប់, សេចក្តីខ្ពស់ពាក់ចំពោះគ្រឿង ដែលមកពីនាក់អាស្រ័យជាដើម ។ អានុភាពនៃព្រះពុទ្ធសាសនា អាចមានរហូតដល់ដីវភាពជាសាធារណៈ, ចំពោះសិទ្ធិភាពឯកឃ, ថែមទាំងក្នុងដែន ដែលមិនសមថានឹងផ្សាយដល់ គឺវិជ្ជាសិល្បៈ ។ អានុភាពព្រះពុទ្ធសាសនាទៅគាន់សិល្បៈ ។ បើប្រៀបធៀបទឹកដោយស្មានទៅថាមានសភាពតិចតួចណាស់ ។ មានប្រវត្តិសាស្ត្រជាច្រើនបានបញ្ជាក់ថា:, ព្រះពុទ្ធសាសនាជាហេតុឱ្យសិល្បៈខ្មែរដុះអន់ថយនូវលភាព ។

បើតាមគោលការណ៍ ព្រះពុទ្ធសាសនាជាអ្នកញុំាង ហើយជ្រោមជ្រែង
សិល្បៈខ្មែរឲ្យកើតមានបម្រើនឡើង ។

១- ហេតុម្តេច ព្រះពុទ្ធសាសនា បើតាមស្មានជ្រួបជាធ្វើឲ្យ សិល្បៈខ្មែរផ្លាក់ប្តូរ ក្នុងទុព្វលភាព ?

តាំងពីសតវត្សរ៍ទី ៨ ទៅដល់សតវត្សរ៍ទី ១០, ប្រទេសកម្ពុជាបាន ជួបប្រទះនឹងសម្បូណ៌ភាព, ព្រមទាំងសភាពថ្កុំថ្កើងរុងរឿង ។ គឺក្នុងពេល នោះឯង ដែលមានសាងសង់មហាប្រាសាទ ដែលក្រុមភាពយន្តក្នុងបណ្តា ពិភពលោកសម័យបច្ចុប្បន្ន គេទុកជាអច្ឆរិយៈភាពទី ៧ ។ គឺក្នុងពេល នោះឯងដែលកម្ពុជរដ្ឋមានអធិប្រទេសមួយយ៉ាងលំបូលាយ ប្រកបដោយ ព្រំដែន: ខាងជើងលាន់នឹងភូមិភាគប្រទេសភូមាសម័យបច្ចុប្បន្ន ខាង ត្បូងលាន់នឹងកោះទាំងឡាយនៃប្រទេសឥណ្ឌូណេស៊ី ។ គោលដៅតិត ប្រាកដគឺថាក្នុងសម័យនោះ ព្រះមហាក្សត្រនឹងប្រជាពលរដ្ឋខ្មែរ និយម កាន់ព្រះពុទ្ធសាសនា សាសនាដែលយើងបានទៅទទួលយកមកពី ប្រទេសរបស់អ្នកដែលកាន់ព្រហ្មញ្ញសាសនា ។

ព្រះពុទ្ធសាសនា ជាសាសនាពេញចិត្តគោរពខាងលទ្ធិពលភាពនឹង ឫទ្ធានុភាព ។ ប្រជាពលរដ្ឋខាងព្រហ្មញ្ញសាសនា ជាប្រជាពលរដ្ឋពេញចិត្ត ខាងសង្គ្រាម ។

ប៉ុន្តែ, បន្ទិច ។, តាំងពីសតវត្សរ៍ទី ១៣, ព្រះពុទ្ធសាសនា, បាន ផ្សាយទូលទ្ធិសប្បុរសធម៌, សន្តិភាព, សមភាព, ក៏បានធ្វើឲ្យប្រជា-ពលរដ្ឋខ្មែរពេញចិត្តជាយ៉ាងក្រៃលែង ។ តាំងពីសម័យនោះមក ប្រទេស

កម្ពុជាឈប់សាងគ្រាសាងធំៗ ហើយលះបង់ខ្លួនវិសេចក្តីណែក កំត្រឡប់ប្រែក្លាយជាប្រទេសដូចដែលអ្នកបានស្គាល់កន្លងសម័យបច្ចុប្បន្នស្រាប់ គឺជាប្រទេសប្រកបដោយសន្តិភាពនឹងមេត្រីភាព ។

២- អានុភាពពិតប្រាកដ នៃព្រះពុទ្ធសាសនា បំពោះសិល្បៈ ។

បើតាមសេចក្តីពណ៌នាដ៏សង្ខេបដូចខាងលើនេះ អាចឲ្យយើងយល់ថា ព្រះពុទ្ធសាសនាមិនសូវមានអានុភាពទៅលើសិល្បៈខ្មែរប៉ុន្មានទេ ។ តែមិនមែនដូច្នោះទេ, បើយើងពិនិត្យ, តាមគោលការណ៍នៃលទ្ធិពុទ្ធសាសនាព្រមទាំងហេតុដែលធ្វើឲ្យសិល្បៈនោះបម្រើនដោយអនុភាពនៃលទ្ធិនេះ ។

ក) លទ្ធិ.,

ព្រះសម្មាសម្ពុទ្ធទ្រង់ទេសនា, មិនត្រឹមតែឲ្យយើងប្រព្រឹត្តធម៌ ដើម្បីទៅកាន់បរលោកនោះទេ, ថែមទាំងឲ្យយើងប្រតិបត្តិតាមព្រះធម្ម ដើម្បីរបានខ្លួនយើង ក្នុងលោកសម័យបច្ចុប្បន្ន ឲ្យចំរុងរឿង ចំពោះធម្ម ព្រះអង្គជាច្រើន ចំពោះបណ្តាទុក្ខ ជាបណ្តាសំខាន់នៃព្រះពុទ្ធសាសនា, យើងត្រូវចាំតែបណ្តាមួយ ដែលមានប្រយោជន៍ជាងគេ, គឺ ព្រះអនាវរ.ណញ្ញាណទ្រង់ទូន្មានមនុស្សឲ្យលះបង់នូវការខ្ជិលច្រអូស ។ ចំពោះការខ្ជិលច្រអូសនេះ, គេមិនអាចរកគោតទ្រព្យ ឬក្តីរឹឈ្នោះបាន ។ ព្រះដ៏មានព្រះភាគ ព្រះអង្គទ្រង់ទូន្មានឲ្យយើងខំព្យាយាមធ្វើការ, តាមតែទម្រង់យ៉ាងណាក៏ដោយ, ហើយជាកិច្ចពិសេស, ចំពោះការសិល្បៈ ការស្ថាបនានូវសិលាគ្រឹះ, ចម្ងាក់, សាបតាក្រម, វិចិត្រកម្ម, តំនូរ ព្រមទាំង

នាជាកម្មនីយជម្រៀង ។ បើតាមព្រហ្មញ្ញសាសនា, គេអាចសុំពរពីព្រះអាទិទេពផ្សេងៗ; តាមពាក្យ, ដោយតាំងចិត្ត ឬបួងសួងចំណែកឯព្រះពុទ្ធសាសនា យើងនឹងអាចប្រកបកាត់បានចំពោះតែភូតដែលយើងបានសាបព្រោះ ។ យើងក្នុងសម័យបច្ចុប្បន្នជាផលនៃយើងដែលប្រព្រឹត្តពីអតីតកាល ជាបអកុសលអាចឲ្យផលអាក្រក់ក្នុងបច្ចុប្បន្ន ឬ ក្នុងជាតិអនាគត ។

๑) ការប្រព្រឹត្តិ,-

ដោយកិច្ចធ្វើការជាសំខាំ, បានជាជនជាតិខ្មែរមិនបានចោះបង់ចោលខ្លួការសិល្បៈ, វត្ថុសិល្បៈនៃប្រទេសកម្ពុជា ដែលបានយកគំនាំងនៃវិចណីទ័ក្រុងញ្ជាវយ៉ក ត្រមាំងវត្ថុសិល្បៈ ដែលមកពីប្រទេសឯទៀតនៃអាស៊ីផ្នែកអគ្នេយ៍, មានតែគេសរសើរជាយ៉ាងក្រពេក ។ ម្យ៉ាងវិញទៀត យើងមិនត្រូវភ្លេចថា: បញ្ហាប្រាសាទដែលបឹតនៅក្នុងសម័យបច្ចុប្បន្ន, មានប្រាសាទខ្លះ មិនមែនថាមានសភាពមិនល្អទេ, ជាប្រាសាទសាងសង់ដើម្បីពុទ្ធបូជា ។ ក្នុងពេលឥឡូវនេះ, មានជនជាតិខ្មែរសាងសង់ ហើយស្ថាបនាជាច្នៃតៗគ្នា ខ្លួព្រះវិហារសម្រាប់បូជាព្រះរបស់ម្ចាស់ពុទ្ធ ។ ជញ្ជាំងនៃព្រះវិហារនោះ មានគូរគំនូរដ៏វិចិត្រ អំពីរឿងពុទ្ធប្រវត្តិ ។ សព្វថ្ងៃ,មានវត្តចំនួន ២.៨០០ ប្រែកបដោយព្រះវិហារ មានព្រះស្តូបដែលមានរចនាក្បាច់ដ៏វិចិត្រ ។ មានបទបញ្ញត្តិច្បាប់មួយទើបនឹងប្រកាសឲ្យប្រើពោលថា: ការដែលអនុញ្ញាតឲ្យសាងវត្តអាចមានបាន លុះត្រាតែអ្នកដែលសុំកសាងនោះ មានការតភ្ជាប់ សាងក្នុងរយៈពេលប្រាំឆ្នាំ. ខ្លួព្រះវិហារ, កុដិសាលាធម៌ាន, សាសារៀនដែលតាមប្រពៃណី, ត្រូវបញ្ចូលការ

សិក្សាវិជ្ជាសិល្បៈទៅជាមួយផង ។

ការដែលមិនប្រតិបត្តិតាមបទបញ្ញត្តិខាងលើនេះ អាចធ្វើឲ្យកាជការមិនអូសយកគុំក្ណ ព្រមទាំងរំលាយចោល នូវពុទ្ធបូជនីយដ្ឋានទោះ ។ វត្តអោកមជាមជ្ឈដ្ឋានខាងសាសនា, ឥឡូវប្រែទៅជាមជ្ឈដ្ឋានខាងការអប់រំ ព្រមទាំងមជ្ឈដ្ឋានខាងសិល្បៈវិជ្ជា ។

អវសានបទ.

បើព្រះពុទ្ធសាសនាមិនមែនផ្សាយសកម្មភាពជាយ៉ាងម៉ឺងម៉ាត់ ខាងសិល្បៈវិជ្ជាព្រោះថាពុទ្ធសាសនិកជន មិនបានប្រតិបត្តិតាមដោយតឹងរឹងនូវគុណនៃសាសនានេះ ។ ពីរបីបុណ្យរំលឹក ២.៥០០ ព្រះវស្សា នៃព្រះពុទ្ធបរិនិព្វាន ដាតេសតុកាសដ៏ល្អ ចំពោះពួកពុទ្ធបរិស័ទទាំងឡាយ ដើម្បីនឹងជជែក, ប្រៀបធៀបការសិក្សាបស់ខ្លួនខាងព្រះពុទ្ធសាសនា ដើម្បីនឹងភ្ជាំងវិធីប្រតិបត្តិព្រះពុទ្ធសាសនានេះ ឲ្យបានប្រែកែទៅតាមវិសុទ្ធិភាពដែលមានមកតាំបវមកាល ព្រមទាំងរចនាសាសនានេះឲ្យទៅជាសាសនានៃសិល្បៈនឹងសន្តិភាពជាអវសាន ។

ញូវដែលថ្ងៃនៅថ្ងៃទី ២៦ វិច្ឆិកា ១៩៥៦ ។

បុណ្យឆ្លងព្រះវិហារ
និងអភិសេកព្រះជីវិតអង្គធំ

នៅវត្តរៀង(១) ឃុំចាក់ក្តោង ស្រុករៀង ខេត្តកំពង់ធំ
ព្រះគ្រូសោភណប្បញ្ញា ថោង-គឹម អនុគណ រៀបរៀង ។

នៅតាមជនវិថីព័ក្រុងកំពង់ធំនៅ សាលាស្រុកនៃប-ជាំខ្លាន បម្លាយពីក្រុងកំពង់ធំទៅ ប្រមាណ ៩០ គីឡូម៉ែត្រប៉ុណ្ណោះ មានវត្តមួយឈ្មោះ "វត្តរៀង" ប្រតិស្ថាននៅក្នុងឃុំចាក់ក្តោង ស្រុករៀង (កំពង់ធំ) ។ សម័យបច្ចុប្បន្ន វត្តនេះកុះករដោយពុទ្ធបរិស័ទជាសម្មាទិដ្ឋិ ជាវត្តប្រកបដោយសេចក្តីសប្បាយ ៤ យ៉ាង :

១-សប្បាយដោយសេនាសនៈ,

២-សប្បាយដោយធម៌នឹងវិន័យ,

៣-សប្បាយដោយបុគ្គលមានសាមគ្គីធម៌,

៤-សប្បាយដោយអាហារគោជន ។

វត្តនេះ មានសាលាបាលីវគ្គ(ពុទ្ធិកបឋមសិក្សា)នឹងសាលាធម្មវិន័យ ទាំងបីថ្នាក់,ជាវត្តបរិបូណ៌ដោយវិជ្ជាផ្លូវលោកផ្លូវធម៌ នឹងហៅថា វត្តដង្រ្កែកនៃស័លធម៌អារ្យធម៌ នឹងវឌ្ឍនធម៌ផ្លូវចិត្តវិញក៏បាន គឺជាជួងកែវនៃដីតែអក្សរសោភ្ស្រ ក្នុងខ័ណ្ឌបន់ស្រុកនោះឯង ។

នៅទីវត្តនោះ មានទេសភាពល្អ មានដើមឈូកជាតិដុះចម្រុះគ្នាជាគ្រឿងលំអវត្ត គួរជាទីជាប់អារម្មណ៍ដល់គ្រហស្ថបព្វជិត ដែលបានទស្សនា ។

---

១ ខេត្តកុម្រែ ជា ល្អៀង ។

នៅថ្ងៃ៨-៩ខែធ្នូ ១០កើត ខែផល្គុនឆ្នាំវក អដ្ឋស័ក ព.ស. ២៤៩៩ ត្រូវនឹងថ្ងៃ ៨-៩ខែធ្នូ ១០មីនា គ.ស.១៩៥៧, ពុទ្ធបរិស័ទបានដង្ហែបុណ្យសម្ពោធក្នុងព្រះវិហារ (ពេលទទួលទាន) ដែលសង់ដោយគ្រឿងឈើប្រក់ក្បឿង ជញ្ជាំងឥដ្ឋកម្រាលស៊ីម៉ង់ត៍ ជុំវិញមានរបងកសាងពីសំណាងថ្មសុទ្ធ ហើយនឹងអភិសេកព្រះពីរអង្គឆ្នាំធង ។

បុណ្យនេះមានរបៀប ដូចខាងក្រោម ៖

ពួកទាយកទាយិកាដើរវត្តពាំងពីរឃុំគឺ ឃុំថ្កាត់ស្ពោង ឧដុងឃុំស្រែធំ ចែកជាវេន ១៤ ក្រុម គឺឃុំមួយៗ មានពីរក្រុម ។ ។

ក្នុងក្រុមនីមួយៗ មានគណៈកម្មការវត្ត ឧដុងនីប្រឹក្សាវត្តឧដុងអាចារ្យវត្ត ។ ក្នុងឧកាសធ្វើបុណ្យនេះ គេធ្វើពេនធំៗ ១៤ខ្នង សម្រាប់ទទួលព្រះសង្ឃឧដុងត្រហស្តមានរបៀបដូចខ្នុះ ៖

- ក្រុមឃុំថ្កាត់ស្ពោង ធ្វើពេន ៧ ខ្នង ដួរខាងលើនព្រះវិហារ ។
- ក្រុមឃុំស្រែធំ ធ្វើពេន ៧ ខ្នងដែរ តាមដួរពីខាងក្បូនព្រះវិហារ ។

ពេនទាំង ១៤-នោះ សុទ្ធតែរចនាដោយស្មឹកក្នុងជាតិ ខង់ជាតិ ខង់សាសនា បងាចារកែពុទ្ធកាសិតនឹងខេមរសុភាសិត បិទជុំវិញពេន ។ ពេលព្រលប់ មានអុជប្រទីបភ្លាលា ដែលរចនាពីក្រដាសព័ណ៌ផ្សេង ។ គួរជាទីរីករាយនឹងដ្រះថ្លាពន់ពេក ។

ជុំវិញព្រះវិហារ មានតាំងព្រះពុទ្ធរូបនឹងព្រះធម៌យ៉ាលក្ខ័ណ៍ព្រះករុណាជាម្ចាស់ជីវិត គ្រប់ជ្រុងព្រះវិហារទាំង ៤ គេត្រៀកទៅឃើញរូបសម្តេចព្រះសង្ឃនាយក ឧដុងសម្តេចព្រះឧបយុវរាជនៅទីនោះ

ផង បីដូចជាព្រះអគ្គិបានយាងទៅកន្លែងនោះដែរ ។

កេងដទៃទៀត គឺកេងសម្រាប់ទទួលទេយ្យវត្ថុជាច្រើនកន្លែង។

មានកេងធំជាងគេពីរទៀត គឺនៅខាងទិសអាគ្នេយ៍ ខាងទិសឦសាន ១ នៃកុដិព្រះគ្រូអនុគណ ។ កេងនេះមានតាក់តែងតុ តៅអី ដើងផ្កា ឋជា ធំធំស្វឹកវុក្ខជាតិផ្សេង ។ ជាគ្រឿងលំអ ។

កេងខាងទិសអាគ្នេយ៍ សម្រាប់ទទួលព្រះសង្ឃគ្រប់ហាន:, កេងខាងទិសឦសាន សម្រាប់ទុកជាទីស្នាក់នៃព្រះគ្រូអនុគណ ដើម្បីប្រជុំព្រះសង្ឃ កិច្ចសាមណេរ ធំធំជាបដិសណ្ឋារដ្ឋាន ចំពោះពុទ្ធបរិស័ទពាំងគ្រហស្ថបព្វជិត ដែលមកពីទីជិតឆ្ងាយគ្រប់ទិសទាំង ៤ ។

នៅចំមុខកុដិព្រះគ្រូអនុគណ គេធ្វើកន្លែងមួយទៀត ឲ្យឈ្មោះថា មង្គីរចាត់ការ មានប្រជានម្នាក់ធំធំសមាជិកច្រើនគ្នា ជាព្រះមន្ត្រីខ្លះ ឧបាសកខ្លះ សម្រាប់ប្រជុំចាត់ការបុណ្យ ។

នៅចំមុខព្រះវិហារគេសង់បុស្បកមួយខ្នង កំពូលស្រួចជាធម្មាសន: សម្រាប់ទេសនា ធំធំជាវេទិកា សម្រាប់ថ្វែងការផ្សេង ។ ។

គ្រប់កេងទាំងតូច-ធំ ធំធំបុស្បក សុទ្ធតែមានបដាច្រើនផ្ទាំងចារឹកពុទ្ធគាថាធំធំរមេសុភាសិតជាដម្បូន្មានផ្សេង ។ ដែលរចនាតាក្រងជាសពណ៌គ្រប់បែប ។ បរិយាកាសបុណ្យនេះភ្ញៀវយ៉ាងដូចថ្ងៃទាំង ៣ យប់ ដោយអំណាចកុសលអគ្គិសនី ។

បុណ្យនេះ គេធ្វើ ៣ ថ្ងៃ ៣ យប់ គេនិមន្តព្រះសង្ឃតាវត្តនានា ក្នុងចំណោមអនុគណខ្លះក្រៅខ្លះទាំងអស់ ៤៩ វត្ត មកជាបដិគ្គាហក: ។

ថ្ងៃទី ១ គឺថ្ងៃ ៨កើត ខែផល្គុនឆ្នាំកកដស័ក ព.ស. ២៤៩៩ ពេលព្រឹកប្រគេនចង្ហាន់ព្រះសង្ឃ ពេលយប់ចម្រើនបរិត្ត ៧, ព្រះគ្រូនិវេយប្រឹក្សា (ឃុន-ឃួន) វត្តលង្កា ក្រុងភ្នំពេញសំដែងធម៌ទេសនា, លុះចប់ធម៌ទេសនាហើយ អុជគាំជ្រួចរន្ធូបូជាចំពោះព្រះគេន. ត្រង់ ប្រគំភ្លេងពិណពាទ្យ(ភ្លេងសៀម)តាមសមគួរដល់ពេលវេលា ។

ថ្ងៃទី ២ គឺថ្ងៃ ៩ កើត ខែឆ្នាំជវដែល (៩-៣-៥៧) ពេលព្រឹកកម្មវិធីដូចថ្ងៃទី ១ លុះដល់ម៉ោង ៦ រសៀល ចាត់ពិធីដង្ហែព្រះពុទ្ធរូបដំណាន់អង្គព្រះជីវ័ធំ ដែលបិតនៅក្នុងព្រះវិហារ ។ ម៉ោង ៧ ចម្រើនព្រះសង្ឃស្រែង់ទឹក; ម៉ោង ៩ ប្រគេនកេសជ្ជៈ, ម៉ោង ៧ យប់ចំរើនបរិត្ត, រួចហើយអតិសេកព្រះពុទ្ធរូប; ទើបខ្ញុំ (ថៅង-គឹម) សូត្រសុន្ទរកថា ថ្លែងអំពីប្រវត្តិនៃវត្តទំនឹងពិធីបុណ្យ (ឯសុន្ទរកថានោះទំនឹងរៀបរៀងនៅខាងមុខ) ចប់ហើយ អាចារ្យវេរព្រះវិហារថ្វាយព្រះសង្ឃ ម៉ោង ៨ ព្រះខេមមុនី (ហ្រាជ-ប៊ុល)វត្តទ ណ្ណាលោមសំដែងធម្មទេសនា ចប់ហើយអុជគាំជ្រួចរន្ធូប្រគំភ្លេងពិណពាទ្យ បន្ទាប់ពីនោះ មានបញ្ចាំងភាពយន្ត (កុន) ក្រសួងយោសនាការជូនប្រជាជនមើលកំសាន្ត ។

ថ្ងៃទី ៣ គឺថ្ងៃ ១០កើត (១០-៣-៥៧) ពេលព្រឹកកម្មវិធីដូចថ្ងៃមុន, ម៉ោង ៣ រសៀលរៀបពិធីដង្ហែខ្ញុំ (ថៅង គឹម)ដំ ទ្យវាកែ ដើម្បីប្រគេនហានន្តរ៍ជាព្រះគ្រូសោភណប្បញ្ញាអនុគណ ក្នុងស្រុករវៀងនេះ ដោយមានលោកដំណាង៉កស្រុក កង-ជា លោកចៅហ្វាយស្រុក រស់-កុំ លោកចាង៉ហ្វាង៉សាលាស្រុករវៀង លោកយោគ្យវត្រ ព្រមទាំងអ្នកពាក់ព័ន

ឯទៀតជាច្រើន បានអញ្ជើញទៅជាកិត្តិយស ក្នុងពិធីស្រោចទឹកនេះ ។ គេក្រឡេកទៅឃើញក្បួនហែប្រទក្សិណព្រះវិហារពាំជុំ សុទ្ធតែសិស្ស-ទុសិស្សវាំងបព្វជិតគ្រហស្ថ នាំមុខនឹងពន្លឺ តម្រៀបតម្រង់ជួរ គួរជាទីជ្រះថ្លាពន់ពេកណាស់ ។ លុះចប់ក្បួនហែកាលណា ពួកសិស្សាទុសិស្សបានទទួលព្រះមហាថេរជាច្រើនអង្គស្រោចទឹកខ្ញុំ ។ ព្រះសង្ឃដែលបានទទួលទៅពីទីធ្វើយវាំងប៉ុន្មានទាំងគ្នាសូត្រដួយខ្ពើ.៣ ចប់ ។ បន្ទាប់ពីនោះទៅ លោកអតីតចៅហ្វាយស្រុកវៀង បានថ្វាយសុទ្ធរកថាមួយ ហើយប្រគេនសញ្ញាប័ត្រ, តពីសុទ្ធរកថាលោកចៅហ្វាយស្រុកមក លោកជំណាងពន្លឺ ឡើងថ្លែងសន្ទិសីពន្លឺទៅទៀត ។ ម៉ោង៧ សូត្រមន្ត, ម៉ោង ៨ ទទួលលោកគ្រូអាចារ្យ កែវ-អ៊ីវ ចៅអធិការវត្តស្ពឺត្បូង ស្រុកស្នោង សំដែងធម៌ទេសនា ចប់ហើយ មានការបញ្ចាំងភាពយន្ត (កុន) សមគួរដល់កាលវេលាទៀត ។

ព្រឹកឡើងថ្ងៃ ១១ កើត (១១.៣.៥៧) រៀបពិធីធ្វើបុណ្យសម្រេចថ្ងៃនោះ ។

សុន្ទរកថា

ព្រះគ្រូអនុគណ ប៉ោង-គឹម វត្តរវៀង

ថ្វែងក្នុងឱកាសបុណ្យច្រងព្រះវិហារ

ព្រះថេរានុត្ថេរៈ ! ទីដ៏នវកិក្ខុសាមណេរ គ្រប់ព្រះអង្គ ! អស់លោក-អ្នកសប្បុរសគាំងឡាយ !

ឧកាសនេះ ខ្ញុំព្រះករុណាអគ្គាភាព សូមថ្លែងប្រវត្តិនៃវត្តនេះ ទីដ៏បុព្វហេតុនៃពិធីបុណ្យប្រគេនជូនជាសណ្តាប់ដូចតទៅ ៖

វត្តរវៀងនេះ ជាវត្តបរមបូរាណយូរយារណាស់មកហើយ ផ្តើមកសាងឡើងប្រមាណជាង ២៩៦ ឆ្នាំហើយ, នាមដែលគ្រាពុកកន្លងផ្លូវការថា "វត្តរវៀង" ប្រែថា "វត្តមានដើមរវៀង" ដោយគេសន្មតតាមទីវត្ត ដែលសង់កន្លងព្រៃរវៀង, តែអ្នកស្រុកខ្លះហៅថា "វត្តល្វៀង" ដូច្នេះវិញ ។

កាលពីដើម វត្តរវៀងនេះ តាំងនៅ ។ ក្បែរៗលពីរ គេហៅថាវត្តកំលពីរ , លោកគ្រូសម្តេច (មិនចាំព្រះនាម គេហៅតែ លោកគ្រូសម្តេច ។) ធ្វើជាមេវត្តបានប្រមាណ ៣០ ឆ្នាំ លោកក៏សុគតទៅ ក្រោយធ្វើបុណ្យបូជាសពលោកគ្រូសម្តេច គេនាំគ្នាលើកវត្តកំលពីរនោះមកកសាងនៅ "យ៉ាំពៃ" គេហៅថា "វត្តយ៉ាំពៃ" លោកគ្រូព្រះនាម "សាំង" ជាចៅអធិការ ។ កន្ទងមកប្រមាណ ១០ ឆ្នាំ លោកគ្រូសាំងនិងពួកជើងវត្តនាំគ្នាលើកវត្តយ៉ាំពៃ មកកសាងនៅទីវត្តរវៀងសព្វថ្ងៃនេះ កាលកសាងរួចហើយ ក៏បញ្ចុះឈ្មោះសីមា ។ លោក

គ្រូអគ្គនេះធ្វើជាចៅអធិការបាន ៤០ ឆ្នាំ ទើបសុគតទៅ ។

តមក , គេតាំងលោកគ្រូតាមាសឲ្យធ្វើជាចៅអធិការ គេហៅថា "លោកគ្រូតាមាសប៉ប្អូរ" ព្រោះលោកនិមន្តមកពីវត្តប្រប៉ប្អូណា ។ លោកគ្រូតាមាសធ្វើជាចៅអធិការ បាន ៤០ ឆ្នាំតត់ ទើបលាចាកសិក្ខាបទទៅ ។

គេក៏តាំងលោកគ្រូសុត្រព្រះនាម "ដួង" ជាចៅអធិការ ។ លោកគ្រូអគ្គនេះ ធ្វើជាចៅអធិការបាន ៤០ ឆ្នាំ ក៏អនិច្ចធម្មទៅ ។

គេតាំងលោកគ្រូព្រះនាម "នន" ជាចៅអធិការតមកទៀត ។ លោកគ្រូអគ្គនេះធ្វើចៅអធិការបាន ៥០ ឆ្នាំ ទើបលោកសឹកទៅ ។

គេតាំងលោកគ្រូសុត្រព្រះនាម "លន" ជាចៅអធិការឡើង លោកគ្រូអគ្គនេះធ្វើជាចៅអធិការបានរៀង ២០ ឆ្នាំ ទើបលោកលាចាកសិក្ខាបទទៅវិញ ។

គេទាំងតាំងលោកគ្រូព្រះនាម "សៅ" ជាចៅអធិការទៀត ។ លោកគ្រូអគ្គនេះធ្វើបានតែ ១០ ឆ្នាំ ក៏សឹកចេញទៅទៀត ។

កាលនោះ, គេតាំងលោកគ្រូព្រះនាម "ត្រាំ" ជាចៅអធិការបានចំនួន ១០ ឆ្នាំ ក៏សឹកចេញទៅ ។

កាលណាបើលោកគ្រូព្រះនាមត្រាំសឹកចេញទៅហើយ គេតាំងលោកគ្រូព្រះនាម "ស្រេម-ស្រី" ជាចៅអធិការទៀត, លោកគ្រូអគ្គនេះទៅមានគោរមរៀងរាល់ "ព្រះគ្រូកន្លាមុនី" ឯព្រះគ្រូអាញ្ញាមុនីនេះ

ធ្វើជាចៅអធិការទីឆ្នាំព្រះខេមរៈបានចំនួន ៥២ឆ្នាំ លោកក៏ខួលអនិច្ចធម្មៈ ។

កាលលោកគ្រូអញ្ជើញមុន៏សុគតទៅហើយ ចំហៅវត្តខេត តតមានចៅអធិការទៀ ។ ប៉ុន្តែ ឃ្លានខ្ញុំព្រះករុណាអគ្គាភាពថៅធ-គឹមហ្នឹងឯងធ្វើការជំនួសចៅអធិការបាន៦ឆ្នាំ ទើបគេតាំងលោកគ្រូព្រះនាម សូរ-ពុតជាចៅអធិការទៀង ; ឯរូបខ្ញុំព្រះករុណាអគ្គាភាព គេតាំងជាគ្រូសូត្រស្តាំ ។ លោកគ្រូចៅអធិការព្រះនាម "សូរ-ពុត" នេះធ្វើជាចៅអធិការព្រមតាំងស្តីទីជាអនុគណផង បានត្រឹមតែ៣ឆ្នាំ លោកក៏សុគតទៅនៅថ្ងៃ ៧ ៧ ១ ឆ្នាំថោះត្រីស័ក ព.ស. ២៤៨៤ គឺថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ១៩៤១ ។

លុះលោកគ្រូអង្គនេះ សុគតទៅចំហៅវត្តខេទៀតចំនួន ៥ ឆ្នាំតិចឆ្នាំយ៉ោះនោះ មកខ្ញុំគ្មានទីឆ្នាំកនេះ ពុំបានមានរូបចៅអធិការនឹងរូបអនុគណនៅឡើយ តែថា ឃ្លានរូបខ្ញុំព្រះករុណាអគ្គាភាព ធ្វើការជំនួសចៅអធិការនឹងអនុគណទៀត ៥ ឆ្នាំគត់ ។

លុះមកដល់ ព.ស.២៤៩៩ គ.ស.១៩៥៦ ពួកការបានតាំងរូបខ្ញុំព្រះករុណាអគ្គាភាពជាចៅអធិការ សញ្ញាប័ត្រលេខ១២០១៤ចុះថ្ងៃ ៥ ៧ ៣ ឆ្នាំមមែសប្តស័ក ទីឆ្នាំជាអនុគណ សញ្ញាប័ត្រលេខ១២០១៦ ចុះថ្ងៃ ៥ ៧ ៤ ឆ្នាំមមែសប្តស័ក បាន១ឆ្នាំគត់ ។

សូមត្រឡប់ទៅរៀបរាយអំពីការស្នាបនា (កសាង) ពងចេតិយសុវណ្ណគីរីវិហារតទៅ ៖

កេងទោសថដែលមានទម្រង់សមគួរនោះ គឺឲលើកនឹងបច្ចុប្បន្ន
នេះឯង ។

កេងទោសថទី១ កសាងបន្ទាប់ពីនឹងការកសាងវត្តនេះសសរធំ។
ប្រាំបីដ្រុង គ្រឿងឈើចាំងអស់ ប្រក់ស្បូវ ; កេងទោសថនេះបិតថេរ
ចិរកាលជាយូរអង្វែងឆ្នាំ ពីព្រោះគ្រឿងទ្រូសម្ភារៈមាំ។ រហូតមកដល់
ព្រះគ្រូអរញ្ញមុនី សោម-ស្រី ទើបគ្រាំគ្រាបាក់បែក ។

លុះដល់ឆ្នាំកុរត្រីស័ក ព.ស. ២៤៨៤ គ.ស. ១៩១១ ក្នុងកាល
ព្រះគ្រូអរញ្ញមុនីសោម-ស្រីនោះឯង លោកបានរុះរើកសាងឡើងជាថ្មី
ទៀត ទូវកេងទោសថទី២ ។ ឯកេងទោសថទី២នេះ កសាង
ដោយគ្រឿងឈើ តែប្រក់ក្បឿងធំជាងទី១ ថាវៈឡាប់ទួនបានចំ-
នួន៣០ឆ្នាំ គឺឥឡូវកុរត្រីស័កដល់ឆ្នាំមមាញ់ត្រីស័ក (ព.ស. ២៤៨៤
គ.ស.១៩៤១) ។ កេងទោសថនោះក៏គ្រាំគ្រាបាក់បែកធ្លុះធ្លាយ,
លុះដល់ឆ្នាំមមែបញ្ចស័ក ព.ស.២៤៨៦ គ.ស.១៩៤៣ ព្រះគ្រូអរញ្ញមុនី
សោម-ស្រី សុគតទៅនៅថ្ងៃ ១ ២ ៨ ឆ្នាំមមែបញ្ចស័កនោះឯង (ព.ស.
២៤៨៦ គ.ស.១៩៤៣) ។

ខ្ញុំព្រះករុណាអគ្គាគាព បានទទួលការៈជាចៅអធិការដំទួសហើយ
ទើបានផ្តើមកសាងឡើង ទូវកេងទោសថទី៣ គឺកេងទោសថបច្ចុប្បន្ន
ដែលកំពុងធ្វើបុណ្យគ្នានេះឯង ។ ពីត្រឹមឆ្នាំមមែបញ្ចស័កនោះរហូតមក
ដល់ឆ្នាំវកអដ្ឋស័កនេះ គិតទៅបាន១៣ឆ្នាំគត់ទើបបានសម្រេច ។

ក្នុងរវាង១៣ឆ្នាំនោះ បើគិតទៅជាចៅហ្វាយស្រុកដែលបាន

មកនៅក្នុងស្រុករវៀងនេះ មាន ៧ ឃុំហ្វាយស្រុក គឺលោក ទឹម.ជួន ទី១, លោក ស្រ៊ី-ណាល់ ទី២, លោក ទឹម-ប៊ុន ទី៣, លោក យ៉ី-តាម ទី៤, លោក ម៉ម.ធួក ទី៥, លោកវស់-កុំ ទី៦, ទីឆ្នាំលោក ហ៊ុន-ខាន់ ទី៧ (បច្ចុប្បន្ន) ។ លោកឃុំហ្វាយស្រុកទាំង ៧ នេះ សុទ្ធតែលោកបានដឹកនាំ ទីឆ្នាំបុគ្គលិកបំរុង ក្នុងការកសាងពោធិ៍បាសថនេះគ្រប់រូប គឺលោកខ្លះបានជួយដោយកំឡាំងកាយ, ខ្លះដោយទ្រព្យ ខ្លះទាំងកាយទាំងទ្រព្យ ។ ឧទាហរណ៍ដូចលោក ទឹម.ជួន ជួយដៃរណែងជាដើម, លោកស្រ៊ី-ណាល់ ជួយក្តារជាដើម, លោក ទឹម-ប៊ុន ព្រមទាំងលោកស្រ៊ី ជួយចំណាយចតុប្បច្ច័យ មានធ្វើបុណ្យផ្កា ទីឆ្នាំកបិនជាដើម, ហើយថែមទាំងលោកបានផ្តើមធ្វើឡដុតឥដ្ឋ-ក្បឿង ឲ្យគេតាមស្រុករវៀងបានឥដ្ឋទីឆ្នាំធ្វើដញ្ជាំងទីឆ្នាំប្រក់ព្រះវិហារនេះ, លោកយ៉ី-តាម ព្រមទាំងលោកស្រ៊ី បានជួយចាត់ការធ្វើដញ្ជាំងបន្តពីលោកទឹម ប៊ុន, ឃ៉ាងម៉ឺងម៉ាត់ ទាំងកំឡាំងកាយ-ទ្រព្យ គឺធ្វើបុណ្យកបិន-បុណ្យផ្កាទីឆ្នាំដញ្ជាំងដ៏ក្រាស់ជាងគេ ឥតប្រកាន់ខ្លួនឡើយ ព្រមទាំងគ្រួសារលោកទាំងអស់, លោកម៉ម ធួកក៏ជួយចតុប្បច្ច័យដូច្នោះដែរ, លោក វស់-កុំ បានជួយក្នុងការធ្វើនេះ ៣ ទីឆ្នាំកិច្ចដទៃទៀតជាច្រើន, លោក ហ៊ុន-ខាន់ (បច្ចុប្បន្ន) ក៏លោ បានជួយខ្លះវិទីឆ្នាំព្រមទាំងឲ្យយោបល់ទីឆ្នាំកុបំរុងក្នុងការបុណ្យសម្ពោធ (ឆ្លង) នេះឯង ។ លោកឃុំហ្វាយស្រុក ដែលមាននាមនៅក្នុងស្រុក. រវៀងទាំងអស់នេះ សុទ្ធតែជាសម្ពាធិដ្ឋ យល់ក្រៃទាំងអស់ លោកខ្លះបានទាំងសមាគមសីល ៥ សីល ៨ក៏មាន ។

ចំណែកលោកយោកក្សាត់វិញ មាន ៤ រូប គឺលោកខក-ខេស, លោកកាទិល, លោកអ្វឺ-ស្ងួន, លោកអ៊ុំ. សារិន (បច្ចុប្បន្ន) ។ លោកយោកក្សាត់ទាំងអស់នេះ កំសុទ្ធតែជួយដោយកម្លាំងកាយខ្លះ ទ្រព្យខ្លះ ទាំងកាយខ្លះទាំងទ្រព្យខ្លះ ជួច ។ គ្នា ។

ចំណែកលោកគ្រូគេឲ្យ ចាប់តាំងពីលោកគ្រូគេឲ្យយោគ-រ៉ែត ជាដើមរហូតដល់លោកគ្រូគេឲ្យបច្ចុប្បន្ននេះ កំសុទ្ធតែបានជួយខ្លះខ្លែងជួច ។ គ្នាដែរ ។ លោក យោគ.រ៉ែត ព្រមទាំងភរិយា បានជួយដោយកម្លាំងកាយ មានអូសឈើជញ្ជួនដាក់ព្រះវិហារ ជាដើម, កម្លាំងទ្រព្យគឺលោកបានធ្វើបុណ្យផ្កា-កប៉ិន ជាដើមផង ។

ចំណែកលោកគ្រូបង្រៀនគ្រប់រូប ក៏លោកជួយខ្លះខ្លែងដោយបច្ច័យនឹងកម្លាំងកាយ មានទាំកូនសិស្សឲ្យជញ្ជួនដីជាដើម ដោយមានលោកគ្រូចាន់ហ្វាន សាលាជាប្រមុខ ។

ផ្នែកលោកមេឃុំទាំងពីរឃុំ គឺឃុំ ចាក់ក្តោងនឹងឃុំស្រែធំ លោកក៏ប្រឹងជួយឧបត្ថម្ភព្រះវិហារនេះឥតបន្ទរបន្ទុយ ។

ឃុំចាក់ក្តោងគឺមេឃុំស្រី ឌី, ហឹម - ជុំ, ព្រំ . តឹម,ស្រ៊ី-ព្រំនឹងមេឃុំសោម-ស៊ុំ (បច្ចុប្បន្ន) ។ ឃុំស្រែធំគឺលោកមេឃុំម្យឹង. ចៅង,រស់-ន្ងូមេឃុំ ស្តីទីម្យឹង-ស៊ុន (បច្ចុប្បន្ន) ។

ចំណែកអាចារ្យវត្តទី ១. សោម.ព្រំ, ទី២.យូ- ញ៉ែម (បច្ចុប្បន្ន) ។ អាចារ្យវត្តទាំងនេះ មានសមត្ថភាព ខាងការដឹកនាំពុទ្ធិសិស្ស ឲ្យចេះខាងការធ្វើបុណ្យ ឲ្យមានសាមគ្គីធម៌ ។ វត្តនេះ, អ្នកស្រុក-ភូមិ មិនមែន

ជាអ្នកស្តុកស្តម្ភប៉ុន្មានទេ ប៉ុន្តែចំណែកខាងបុណ្យទានមានធ្វើមិនដាច់ គឺធ្វើការកសាងវត្តអ.កមនឹងធ្វើបង្ហាន់វេនគ្រប់ថ្ងៃ ពាល់ខែ-ឆ្នាំ ។ ក្នុងមួយថ្ងៃត្រូវភូមិមួយ ឬ ពីរភូមិរួមគ្នា ធ្វើបង្ហាន់ ។

ក្នុងពេន្ធទោសថ្ងៃទី ១ ទី ២ គេកសាងអាសនៈព្រះពុទ្ធរូបតែនឹងគ្រឿងឈើ ហើយមានថ្នាក់មានជាន់ ។ លុះមកដល់ពេន្ធទោសថ្ងៃនេះ លោកគ្រូចាន់ហ្វាន សាលាបឋមសិក្សាបំពេញវិជ្ជា ស្រុកវៀងនាម សូរ.សៀងព្រមទាំងអ្នកស្រី កេត-ភួងជាកវិយា នឹងបុត្តធីតារបស់លោក មានសទ្ធាជ្រះថ្លា ឃានដំនុំព្រមគ្នានឹងពុទ្ធបរិស័ទចំណុះដើងត្នកសាងព្រះជីវអង្គធំ ព្រមទាំងបល្ល័ង្ក ដោយគ្រឿងបេតុងការម៉ាសស្មើក់ចំនួន ១៨៦៩ការ៧០ ដើងវត្តខ្លួល ១០.០០០រ០០ ។ លោកគ្រូចាន់ហ្វានចំណាយ ៨.៦៩ការ៧០ ដែលរួមធ្វើបុណ្យអកិសេកជាមួយនឹងធ្វើបុណ្យឆ្លងពេន្ធទោសនេះ ។

ឯការកសាងពេន្ធទោសនេះ រួបរួមចំណូលមកគ្រប់មុខឃើញថ្លាន ស្មើក់ចំនួន ២៤៤.៩០៨រ០០ ។

លោកគ្រូចាន់ហ្វានាម សូរ.សៀងនេះ លោកមិនគ្រាន់តែដឹកនាំក្នុងការកសាងព្រះជីវធំនឹងបល្ល័ង្កប៉ុណ្ណោះទេ គឺលោកដឹកនាំពុទ្ធបរិស័ទគួរគំនួរដញ្ជាំងខាងលិច ខាងកើតថែមទៀតគឺ គួរខាងលិច រឿនខាងសុជាតា ថ្វាយមធុបាយាស, ខាងកើត គួរវៀងព្រះអង្គយាងចូលកាន់បរិនិព្វាន ដូចជាអស់លោក-អ្នកបានឃើញស្រាប់ហើយ ។

ចំណាយក្នុងការកសាងពេន្ធទោសព្រមទាំងគំនួរនេះអស់ស្មើក់

ចំនួន ៤៣៦.១៦៣រ៣០ នៅសល់ប្រាក់ ៨.៧៤៤រ៧៤ ។

ប្រាក់ដែលសល់នោះ យកចំណាយក្នុងការរៀបចំធ្វើពិធីបុណ្យនេះគឺ

១- ថាយបង្គើយកុដិលោកគ្រូវត្តស្រះចក ៣.៩០០រ ។

២- ថាយធ្វើនោមឫស្សី ៩០០រ ។

៣-ប្រគេនលោកគ្រូអាចារ្យ បង្រៀនធម្មវិន័យ ឲ្យទិមន្តទៅ
កំពេញ ១០០០រ ។

៤- ធ្វើទូដាក់គម្ពីរ ២.៨០០រ. ។

៥- ទុបត្តម្ភព្រះសង្ឃ ធ្វើកិច្ចការបុណ្យអស់បច្ច័យ ៩០០រ. ។

រួមទាំងអស់ត្រូវជា ៨.៧០០រ ។

ប្រាក់នៅសល់ទាំងអស់តែ ៤៤រ៧៤រៀត សម្រាប់ប្រើប្រាស់
ខាងក្រៅ ដូចទិញលួស. ក្រដាស. ថ្នាំ ទឹងដែកគោលអស់ទៅហើយ
(នៅសល់ ៧៤ សេនប៉ុណ្ណោះក្នុងហិបនោះ) ។

ឯប្រាក់ចំណូលក្តី ចំណាយក្តី ខ្ញុំព្រះករុណាអាត្មាភាពបានកត់ក្នុង
បញ្ជីសព្វគ្រប់ដែរហើយ បើទឹងយកមកសូត្រ ក្នុងទីនេះក៏បានដែរ ប៉ុន្តែ
ក្រែងយូរពេលវេលាទឹងសំដែងធម៌ទេសនា ។ ក្នុងឧកាសនេះ ខ្ញុំព្រះ
ករុណាអាត្មាភាពបុំសូមតិព្រះតេជព្រះគុណគ្រប់ព្រះអង្គ ទឹងអស់លោក
.អ្នក តើលួមលៃពេលសូត្រឥឡូវនេះបានទេឬ ? (ពុំបាច់សូត្រទេ) ។

បុណ្យនេះ ដោយសារព្រះករុណាគ្រប់ព្រះអង្គគឺ ភិក្ខុ សាមណេរ
ទាំងឡាយ ព្រមទាំងអស់លោក-អ្នកសប្បុរសពុទ្ធបរិស័ទនៅស្រុកជិត-
ឆាយ ដែលបានទិមន្តទឹងអញ្ជើញមកជាអធិបតី មកជួយទុបត្តម្ភចំនុកបំរុង

ផង កំបានទៅជាបុណ្យដ៏ទុល្លភៃក្រៃពេក ។

ក្នុងនាមទាសក-សិកាពុទ្ធបរិស័ទដើមវគ្គ ខ្ញុំព្រះករុណា អាត្មាភាព សូមថ្វាយពរសព្វសាធុការចំពោះព្រះករុណា ជាម្ចាស់ជីវិត ទឹងសម្តេចព្រះមហាក្សត្រិយានី ព្រមទាំងសម្តេចព្រះទេពយុវរាជ ជាព្រះបិតាឯករាជ្យជាតិ សូមឱ្យព្រះអង្គសោយសេចក្តីសុខ ក្នុងសិរីរាជសម្បត្តិ អស់កាលជាអង្វែងតទៅ ។

ម្យ៉ាងទៀត ខ្ញុំព្រះករុណា អាត្មាភាព សូមប្រគេនផ្ញើនសព្វសាធុការនេះ ចំពោះព្រះករុណាគ្រប់ព្រះអង្គ ទឹងអស់លោក-អ្នកសប្បុរសទាំងឡាយ ឱ្យបានប្រកបដោយពរ ៤ ប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ ទឹងសិរីសួស្តីជយមង្គល គ្រប់ប្រការសព្វគ្រប់ពាក្រើ កុំបីមានចន្លោះឡើយ ។

លំដាប់តទៅនេះ យើងខ្ញុំសូមចែករំលែកនូវបុញ្ញកុសលដែលកើតអំពីបុញ្ញកម្មនេះ ចែកប្រគេនជូនព្រះករុណាគ្រប់ព្រះអង្គ អស់លោក-អ្នកសប្បុរសទាំងឡាយ សូមឱ្យបានទូវគាគផលកុសលទឹងបុញ្ញកុសលនេះស្មើៗគាគគ្នា ហើយទឹងសូមឱ្យពុទ្ធសាសនាបានរុងរឿងចំរើនគ្រប់កំណាត់ ៥០០០ព្រះវស្សាទឹងផ្សាយទូទៅពេញពិភពលោក, សូមឱ្យពិភពលោកទាំងសាកល ដល់នូវសន្តិភាពរៀងរាបតទៅ, កាលបើអស់លោក-អ្នកបានទទួលយកនូវកុសលកុសលនេះគ្រប់ៗគ្នាហើយ កំសូមឱ្យបញ្ជូនូវសទួសញ្ញាបន្ទូលថា សាធុ ។ ឱ្យត្រមគ្នាទៅហោង ។

ពិធីបុណ្យ ព.ស.២៥០០ ខែត្រកំពង់ឆ្នាំង

ភិក្ខុធម្មធរោ ទេព សារុន វត្តឧណ្ណាលោម

ជាអ្នកនិពន្ធ

កាលពីថ្ងៃអាទិត្យ៨កើតខែចេត្រ ឆ្នាំវក អដ្ឋស័ក ព.ស.២៤៨៨ គឺថ្ងៃទី ៧ ខែមេសា គ.ស.១៩៤៧ នៅវត្តទេពធីតាពម មានធ្វើពិធីបុណ្យរំលឹកពុទ្ធសាសនាយុកាល គំរប់២៥០០វស្សា ទំនឹងបុណ្យធ្វើបបរពីតំបូងចាំង ៥ កន្ទែង ដែលបានមកអំពីប្រទេសឥណ្ឌៀ ព្រមទាំងដង្កៀព្រះបរមសារីរិកធាតុនៃព្រះសក្យមុនីសម្មាសម្ពុទ្ធគោតម ក្រោមអធិបតីភាពនៃលោកអ្នកឧកញ៉ាស្រែនាធិបតីចៅហ្វាយខែត្រនាម កេត-ជួន ទំនឹងព្រះធម្មវិន័យ-ធិបតីមេគណព្រះនាម ខុម-អ៊ុម ។

ឯបុណ្យនេះ ពួកពុទ្ធបរិស័ទចាំងអស់ ក្នុងខែត្រកំពង់ឆ្នាំងគឺ ផ្នែកបព្វជិតមានព្រះតេជព្រះគុណមេគណ, លោកគ្រូអនុគណទំនឹងលោកគ្រូចៅអធិការគ្រប់វត្តជាដើម, ផ្នែកអ្នកពជការមានលោកចៅហ្វាយខែត្រ លោកចៅហ្វាយស្រុកចាំង ៥ ស្រុក ទំនឹងលោកមេឃុំគ្រប់ឃុំជាដើម ផ្នែកពិជ័យសង្គ្រាមទំនឹងពជគ្រួត មានលោកអនុសេនីឯក នាមអ៊ុម - សង់អ៊ីម លោកសេ - ភូម្ពាកន នាយតម្រួតភាជាន, លោកអ័ន - តាំ ចាងហ្វាងសាលាក្រុងច័ណ្ឌ, ទំនឹងលោកអ៊ីម - ហូ ជាដើម ជាន់ត្រមត្រៀងគ្នា

១– បបរពីតំបូង(ដើមប្រសើរ) ៥ កន្ទែងគឺ ដំត្រង់សុម្ពីនំ ជាកន្ទែងព្រះអង្គប្រសូត ១, ដំត្រង់ពុទ្ធគយា ជាកន្ទែងព្រះអង្គជាន់ត្រាស់ ១, ដំត្រង់កុសិនារ ជាកន្ទែងដែលព្រះអង្គបរិនិព្វាន ១, ដំត្រង់ឥសិបតនមិគទាយវ័ន ជាកន្ទែងដែលព្រះអង្គសំដែងធម្មចក្កប្បវត្តនសូត្រ ១, ដំត្រង់មកុដពន្ធនចេតិយ ជាកន្ទែងប្លងជាព្រះបរមសពនៃព្រះសក្យមុនីសម្ពុទ្ធ ១ ។

ជាឯកច្ឆន្ទ ប្រារព្ធធ្វើបុណ្យនេះឡើង ។

នៅពេលដែលជាង្វែព្រះបរមសារីរិកធាតុព័ទ្ធទីក្រុងនោះ មានពួកពុទ្ធបរិស័ទចាំដឹងបព្វជិតនិងគ្រហស្ថចាំដឹងអស់ ប្រហែលពីរម៉ឺនប្រាំពាន់នាក់គឺពួកខ្មែរ, យួន, ចិន, ខ្មែរឥស្លាម ព្រមចាំកងវរសេនាតូច ៣ហាន ប្រដេញលេខ ១៨, កងអាវុធតិរេសនិងកងកាំភ្លើងធំ ប្រាំរយនាក់ផង តាមហែហមព្រះបរមសារីរិកធាតុ ។ ឯក្បួនហែបានតម្រៀបគ្នាចម្ងាយ ๓ គីឡូម៉ែត្រ ហើយក៏បានដើរដំណើរចេញពីវត្តទេពធីតាភនៅម៉ោង ๑๔, ๕๐ នាទី តាមមហាវិថីព្រះបាទមុនីវង្ស៍ វិធីដ៏វែងល, លុះរថយន្តបានមកដល់វិថីខេមរភូមិន្ទ នៅមុខសណ្ឋាគារលោកចៅហ្វាយខែត្រ ព្រះសង្ឃចំនួនប្រាំរយអង្គ ក៏បានស្វាធ្យាយជយន្តាជូនពរជ័យចំពោះលោកប្រមុខខែត្រ ព្រមចាំងបុត្រកវិយោរបស់លោក ។ លុះព្រះសង្ឃស្វាធ្យាយជយន្តា ជូនពរជ័យចប់ស្រេចហើយ លោកចៅហ្វាយខែត្រ ក៏បានលើកយកព្រះពុទ្ធរូបមាសមួយព្រះអង្គ ព្រមចាំងគ្រឿងសក្ការៈជាច្រើន មកដំកល់លើរថយន្ត ថ្វាយចំពោះបរមសារីរិកធាតុបន្ទាប់ពីនោះមក រថយន្តក៏បានចេញដំណើរ តាមវិថីមីលីសាំងឡាច,វិថីនារីក្សាហានទីនិងវិថីព្រះសីហនុ ក៏បានបត់មកតាមមហាវិថីព្រះបាទមុនីវង្សវិញ ឆ្ពោះទៅកាន់ផ្សារក្រោម អស់ចម្ងាយវិថី๑๐ គីឡូម៉ែត្រ ។ លុះដល់ម៉ោង ๑๗,๕๐ នាទី ទើបចប់វិធីហែនោះ ។

នៅពេលកំពុងហែ យើងបានសង្កេតឃើញមានបដាជាច្រើនសរសេរជាភាសាស្វាគមន៍

១-បុណ្យហៅព្រះបរមសារីរិកធាតុ នឹងបបរីពិសិដ្ឋបូជនីយដ្ឋាន,

២-សូមនមស្ការ ដោយគោរព ចំពោះព្រះបរមសារីរិកធាតុ នៃព្រះសក្យមុនីគោតម,

៣-ដោយតេជះនៃព្រះសក្យមុនី សូមសន្និកាពកើតមានដល់ពុទ្ធបរិស័ទ កន្លងកម្ពុជរដ្ឋ.

៤-សូមលើកថ្វាយព្រះពរជ័យសិលដ៏ទុត្តមនេះ ចំពោះព្រះប្រិយ-មហាក្សត្រទាំងពីរព្រះអង្គ ព្រមទាំងសម្តេចព្រះទេបយុវរាជ ជាបិតាឯក-ភាជ្យនៃប្រទេសកម្ពុជា ។

នៅត្រង់មុខគេហដ្ឋានទាំងអស់កន្លងទៅក្រុង សុទ្ធតែមានរៀបចំគ្រឿង សក្ការបូជា ចំពោះព្រះបរមសារីរិកធាតុ ដែលបានហៅទៅកន្លងថ្ងៃនោះ ។

នៅម៉ោង១៧,៥០នាទី សម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ កំពុងនិមន្តទៅដល់ ហើយមានព្រះពុទ្ធដីកា បដិ-សណ្ឋារៈ ចំពោះពួកតាហានព្រមទាំងបព្វជិត នឹងបណ្តាពស្ត្រ ដែល តាមហៅហមព្រះបរមសារីរិកធាតុ មកដំកល់លើបុស្បកមុខព្រះវិហារ ដោយសេចក្តីពិស្តារ ។ បន្ទាប់ពីនោះមក ទើបអុជតាំជ្រួចក្តីខឿនថ្វាយ ព្រះបរមសារីរិកធាតុហើយ ទើបនិមន្តសម្តេចប្រធានធម្មទេសនា ។ បុណ្យ នេះកំណត់ធ្វើ៣ថ្ងៃ មានអុជតាំជ្រួចថ្វាយព្រះបរមសារីរិកធាតុព្រមទាំង មានធម្មចក្កសំដែងធម្មទេសនាពាល់ពាក្រ ។

(តមក)

-ទីប្តិ ស្ត្រី. ការិយារលាយអាហារដោយភ្លើង ។ -ទូត គុ. ដែលមានភ្លើងជាទូត, អគ្គិទូត ។ -ធានុ នបុ. ភាជន៍សម្រាប់ទ្រភ្លើង (ក្នុងពិធីបូជាព្រះអគ្គិ) ។ -នាភ ស្ត្រី. ល្មោះពិធីស្រោចស្រង់ព្រះអគ្គិ ។ -នយន នបុ. ពិធីនាំព្រះអគ្គិយេញទៅ ។ -បក្ក គុ. ដែលឆ្អិនដោយភ្លើង ។ បរិក្រិយា ស្ត្រី. ការិយារក្សាព្រះអគ្គិ, យាននៃព្រះអគ្គិ ។ -បរិច្ឆទ បុ ត្រឿងប្រដាប់សម្រាប់បូជាព្រះអគ្គិ ។ -បរិណាន នបុ. ការិយាបិទបាំងនូវព្រះអគ្គិ ។ -បវិត្ត បុ. ភ្នំភ្លើង, អគ្គិបពិត ។ -បិណ្ឌ គុ. (ដង្កាប់) ដែលមានបុងក្រហមដោយភ្លើង ។ -បុរេគម គុ. ដែលមានភ្លើងប្រព្រឹត្តទៅក្នុងខាងមុខ, ដែលមានភ្លើងជាអ្នកនាំ ។ -ប្រតិស្ឋ ស្ត្រី. ការិយាប្រតិស្ឋនូវភ្លើង (បំពោះភ្លើងមង្គលការបុត្រធីតា) ។ -ប្រទាន នបុ. អគ្គិប្រទាន, -ការិយាឲ្យដល់ភ្លើង ។ ប្រភា ស្ត្រី. ពន្លឺនៃភ្លើង, សត្វល្អិតពុល ។ -ប្រវេស បុ. -ប្រវេសន នបុ. ការិយាចូលទៅកាន់ដើងភ្លើង ។ -ប្រស្ករ បុ. ឬភ្លើង (ឬដែលមានជាតិភ្លើង) ។ -ភាហ បុ. មានដៃជាភ្លើង, ស្បែង, នាមបុត្រទីមួយនៃព្រះមនុ (តម្លឹងហរិវង្ស), នាមបុត្រនៃព្រះប្រិយព្រតនិងកាម្យា ។ -ភីជ នបុ. ពូជនៃភ្លើង, មាស; តាមអក្សរ «រ» ។ -ភ នបុ, មានពន្លឺឆួចភ្លើង មាស ។ -ភយ នបុ. អគ្គិភ័យ, ភ័យអំពីភ្លើង ។ -ភុ នបុ. ដែលកើតពីភ្លើង ទឹក ។ -ភូ បុ. ស្ពន្ធ ។ -ភូតិ បុ. នាមជនម្នាក់នៃគណធរទាំង១២នាក់នៃតិថិការ ។ -ភ្រាជស គុ. ដែលមានពន្លឺនៃភ្លើង ។ -មណិ បុ. កែវស្ទួរភ្លើង ។ -មន្ថ បុ.ភ្លើងគឺកាម,កាម។

ភ្នំពេញ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ៨ ខែសីហា ព.ស. ២៥០០ គ.ស. ១៩៥៦



ភ័ន្តសនីយា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បណ្ឌិតរៀន	ទំព័រ
– អំពីឥទ្ធិពលនៃព្រះពុទ្ធសាសនាលើសិល្បៈខ្មែរ	លោកឡៀង ណែ-ឈន ប្រែ	៦៩៥
– ប្រយោជន៍ ២ យ៉ាង	ស្រី-អ៊ូ រៀបរៀង	៧០៤
– ការស្រោចស្រង្រោះពន្លង	អ៊ុក-ឆិង រៀបរៀង	៧០៨
ផ្នែកអក្សរសាស្ត្រ		
– តំរូកតញ្ញូ-មិត្តភាពរវាងតាវរឿង ព្រះធម្មបុត្ត	អ្នកស្រីអ៊ុច-សុខ ប្រែ	៧១៧
– រឿងខេត្តរបស់អង្គ្រីតឈ្រើម៉ាក (តមក)-	លោកឡាំក-ថែមពិតត្បូ	៧២៣
– រឿងសាវកុក (តមក)	ឯកឃ្លាំ ន្ហ-កន ប្រែ	៧៣៣
– រឿងហ្សាឆិត (តមក)	លោក រ័ត្ន - ប៊ុក ប្រែ	៧៤៣
– រឿងអណ្តើកមាស	ឈឹងមករង្គ ប្រែរៀបរៀង លោកប៊ូ-ប៊ី ពិនិត្យ	៧៤៧
ផ្នែកកំណត់ទំនឹងប្រវត្តិសាស្ត្រ		
– ដំណើរទស្សនាការសិក្សារបស់មន្ត្រីសាលាមេរីកនៃព្រះពុទ្ធសាសនាលើកទី		៧៦៩
– ដំណើរមកកាន់ពុទ្ធសាសនបណ្ឌិត្យ នៃឯកឧត្តមឧត្តមសេនីយ៍ឯក ត្រឹង ស្សាន អនុប្រធានាធិបតី នៃសភាតំណាងរដ្ឋ(ប្រទេសវៀតណាម)	លោក រ័ត្ន-ប៊ុក រៀបរៀង	៧៨១
– ឥតិបណ្តុំទទួលអដ្ឋិធាតុ នៃព្រះគ្រូហ៊ិន-សាង ជាតិចិន នៅនាលន្ទា (ប្រទេសឥណ្ឌា)	លោក រ័ត្ន-ប៊ុក រៀបរៀង	៧៨៥
– វចនានុក្រមសំស្ក្រឹត-ខ្មែរ(តមក)	ព្រះមហាជាង-ខាត់ រៀបរៀង	៧៨៧

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

-L'influence du Buddhisme sur l'art Khmèr. traduit par *M. TIANG-TAY-CHHUN* 695
-Les 2 bienfaits du Buddhisme par *M. SREY-OU* 704
-La rechèrche du bonheur par *M. OUK-FHANG* 708

PARTIE LITTERAIRE:

-Reconnaissance (Conte japonnais) traduit par *Mme. UCH-SONN* . . 717
-Histoire de Devanda de *M. MOK*, revue et corrigée (suite) par *M. NHOC-THEM* 723
-Histoire de Samkok (suite) traduit par *M. NOU-KAN* 733
-Histoire de Zadig (suite) traduit par *M. RAY-BUC* 743
-Histoire de la tortue d'or traduit par *M. LY-THIEM-TENG* . . 747

NOTES ET CHRONIQUES :

-Voyage du Vénérable HUOT-TAT aux U. S. A. par *M. CHEA-TONN* 769

-Visite de S. E. Dr. Sarvepalli Radhakrishnan à l'Institut Buddhique par *M. RAY-BUC* 781
-Fête de réception des reliques vénérable *HOUN-SANG* à Nalanda par *M. RAY-BUC* 785
-Dictionnaire Sanskrit-khmer par Vén. *PANG-KHATH* 787

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

អំពីឥទ្ធិពលនៃព្រះពុទ្ធសាសនា
ទៅលើសិល្បៈខ្មែរ

នាងកញ្ញា ម៉ាន់ឌីឃួនសុភ័ក្ត្រ ជាឧបាសិកាជាភាសាបារាំង
លោកទៀង-តាយ-ឈុន ក្រមការជើមខ្សែលេខ ១
ប្រែជាភាសាខ្មែរ

ព្រះពុទ្ធសាសនាបានជ្រាបចូលមកប្រទេសកម្ពុជា ព្រមគាំងវត្តធាតុ នៃអារ្យធម៌ដណ្តៀ ។ ព្រះពុទ្ធសាសនាបានស្គាល់នូវសម័យដ៏រុងរឿងច្រើន សតវត្សមកហើយ, ប៉ុន្តែក្នុងសម័យខ្លះ ព្រះពុទ្ធសាសនាធ្លាក់ចុះអាប់ទន ។ ក្រោយដែលបានខូច សេចក្តីអនុគ្រោះខ្លះ ក្នុងសម័យអង្គរ, ព្រះពុទ្ធសាសនាកំធ្លាក់ចុងជាបត់ត្រិស្តសតវត្សទី ៨ ទៅសតវត្សទី ១០ ។ តាំងពីនោះមក ព្រះពុទ្ធសាសនាខាងលទ្ធិមហាយាន ក៏ចាប់ផ្តើមចំរើនរុងរឿងឡើងជាថ្មី បានជាសាសនារបស់រដ្ឋ ក្នុងទីបំផុតសតវត្សទី ១១ ក្នុងរជ្ជកាលព្រះជាធិបតីជ័យវរ្ម័នទី ៧ ។ ក្នុងវគ្គទី ២ នៃពាក់កណ្តាលត្រិស្តសតវត្សទី ១៣, ព្រះពុទ្ធសាសនាបានតុរភាវនូវទៃបសគ្គដែលកើតមានឡើង អំពីការមិនអត់ឱនរបស់សាសនាព្រាហ្មណ៍ លទ្ធិព្រះឥស្សរក្នុងគោលដៅខ្លី, ប៉ុន្តែមិនយូរប៉ុន្មាន, ព្រះពុទ្ធសាសនាលទ្ធិថេរវាទជាការសាហាវឈ្លានជ័យជំនះ បានៈវាជាសាសនាប្រទេសកម្ពុជាក្នុងកាលបច្ចុប្បន្ន ។ ពិតមែនតែក្នុងសម័យបច្ចុប្បន្ន, ព្រះពុទ្ធសាសនាមិនសូវមានការរេចនា ជា

ធំជុំខេ, ប៉ុន្តែអាចតាញអ្នកសិល្បករខ្មែរឲ្យបានទៅជាអ្នកស្នាដៃឯក
ខោះខាងស្ថាបត្យកម្ម ខាងសិល្បកម្ម ។ យើងនឹងចាប់ផ្តើម
និយាយអំពីឥទ្ធិពលនៃព្រះពុទ្ធសាសនាទៅលើសិល្បៈខ្មែរ ដោយសង្ខេប
ដូចតទៅនេះ ៖

នៅសម័យកន្លះ លោកពីយែរ-ឌុយ-ប៉ុង (Pierre Dupont) បាន
សង្កេតឃើញថា "ព្រះពុទ្ធសាសនាមាន ដំណើរលិចអណ្តែត" ។
នៅខាងចុងគ្រិស្តសតវត្សរ៍ទី ៥, ព្រះពុទ្ធសាសនាមានសារៈច្រើនក្នុងព្រះ
រាជអាណាចក្រហ្វូ-ណន, ជាពិសេសដែលតាំងនៅលើកំលងំនាបខន្ទុមេ
កុង ទឹងឆ្ពោះឈូងសមុទ្រសៀម ។ តែកាលណោះ ជាព្រះពុទ្ធសាស-
នាថេរវាទជាភាសាសំស្ក្រឹត ។ មួយសតវត្សរ៍ក្រោយមក ទើបមាន
ព្រះពុទ្ធសាសនាមហាយានកើតមឡើង ហើយតាំងនៅជាប់ក្នុងចុងបុព្វភាគ
នៃគ្រិស្តសតវត្សរ៍ទី ៨ ។ ព្រះពុទ្ធសាសនាមហាយាន ដែលកើតមាន
ឡើងថ្មីនេះ ដោយពិត មិនមែនជាចំរើនរុងរឿងនំដុំណាស់ណាទេ តែ
ខោះជាយ៉ាងណាក៏ដោយ លទ្ធិនាំងពីរនេះ តែចំរើនរុងរឿងក្នុងរជ្ជកាលនៃ
មហាពលវាន់ក្រោយទាំងឡាយនៃប្រទេសហ្វូ-ណន គឺព្រះបាទគោណ្ឌញ-
ជយវរ្ម័នទី២ ព្រះបាទរុទ្រវរ្ម័ន ។ ព្រះពុទ្ធសាសនាទាំងពីរលទ្ធិនេះ កើត
ចំរើនឡើងពិតប្រាកដដរាបដល់សម័យចិនឡើងមុតរលត់ ; តែដល់មក
ខាងចុងគ្រិស្តសតវត្សរ៍ទី ៨, ព្រះពុទ្ធសាសនាធ្លាក់ចុះគប់គុន ហើយយើង
មិនសូវបានឮនិយាយពីសាសនាទាំងពីរនេះជាច្រើនសតវត្សរ៍ ។

ទម្រង់ព្រះពុទ្ធរូបដែលគេកសាងឡើង ក្នុងសម័យកន្លងហើយ មាន

ច្រើនគួរសមដែរ ដូចជាការពេនាព្រះពុទ្ធរូបបែបបទនិព្វាន ឬ ផ្តត់ព្រះវត្ថុន
ខាត់សមាធិ ឬ តដ៏សំយុំដ៏ព្រះបាទ ពុំនោះទ្រង់តដ៏សណ្តិតឈរពេព្រះ
ហស្ត, ព្រះពុទ្ធរូបចំនួនោះ សុទ្ធសឹងសំដែងអាការស្រួតត់ស្រួតំរម្យទំពាំង
អស់, ព្រះពុទ្ធរូបដែលល្អជាងគេបំផុតនោះ គឺប្លាកដជាព្រះពុទ្ធរូបសណ្តិត
ឈរនៅវត្តំរំលោក ។ ព្រះពុទ្ធរូបអង្គខ្លះ មានទ្រង់ទ្រាយស័ក្តិសម ហើយ
សុភាព អង្គខ្លះទៀត (រូបថតទី១) មិនមែនជាមានភាពរៀពៃតទេ ហើយ
ទ្រង់ឈរខេន់ពោះទៅមាន់មុខចន្ទិច មើលទៅឃើញដូចជាទ្រង់មានព្រះរ័យ
ប្រកបដោយភក្តីណា ។

រូបពោធិសត្វអវលោកិតេស្វរៈ ដែលមាននៅខេត្តក្រមួនស
(Rachgia) នាំឲ្យយើងស្គាល់ការពេនា នៃព្រះពុទ្ធសាសនាមហាយាន ។
រូបពោធិសត្វនេះមានលក្ខណៈនឹងសម្ងាមត្រូ មុខគួរឲ្យគោតស្ងើច ប្រតិស្ឋ
ជាតួអង្គពេជកុមារពេតប្លាកដ ហើយញញឹម ត្រមាំងនៅជាលក្ខណៈ
ការពេនាឥណ្ឌៀ សុទ្ធសាធ ។

ក្នុងសម័យ ៦ ឬ ៧ ដែលបែងចែកគ្នាជាពីរនៅត្រីស្តសតវត្សរ៍ទី ៥ ឬ ដ
ក្នុងសម័យស្តាបនាប្រទេសខ្មែរឥឡូវនេះ ទៅត្រីស្តសតវត្សរ៍ទី ៨, សិល្ប-
កាពនៃការពេនាព្រះពុទ្ធសាសនា កាន់តែកម្រៃឡើង ។ ប៉ុន្តែការគោរពព្រះ
ពុទ្ធសាសនា មិនមែនសាបសូន្យទៅទេ ហើយដរាបមកទាន់ចុងត្រីស្ត
សតវត្សរ៍ទី ៨ ក្នុងរជ្ជកាលនៃព្រះបាទយសោវរ្ម័ន ទើបមានៈសេចក្តីសម្រេច
របស់ព្រះអង្គជាតស្តុតាង ឲ្យយើងឃើញច្បាស់, ព្រោះដប្រកាស ៣ ច្បាប់
ត្រាស់បង្គាប់ឲ្យតសាងទេពាល័យ ៣ កន្លែង មួយសម្រាប់ជនៈគោរពព្រះ

ឥសូរ, មួយសម្រាប់ជនគោរពព្រះវិស្ណុ, មួយទៀតសម្រាប់ពុទ្ធសាសនិ-
កជន ។ អត្ថបទទាំង ៣នេះដូច ១ គ្នា តែមានសេចក្តីផ្សេងគ្នាខ្លះ ទៅ
តាមលទ្ធិសាសនាទាំង ៣ ហើយតម្រូវទៅតាមអង្គការណ៍ខាងសម្ភារៈ
នៃក្រុមអ្នកបួសនីមួយៗ ។ ដូច្នេះ សក្តិភាពបណ្ឌិតរឹតបូកណា
នេះ ជាកស្តុតាងតែមួយ ដែលទាំឲ្យដឹងថា មានព្រះពុទ្ធសាសនា, ប៉ុន្តែ
យើងមិនទាន់ដឹងថា មានការរចនាណាមួយមកបញ្ជាក់លើកស្តុតាងនេះ
នៅឡើយ ។ លុះត្រាតែដល់ពាក់កណ្តាលគ្រិស្តសតវត្សរ៍ទី ១០
ទើបមានទេវរូបខាងព្រះពុទ្ធសាសនា ដូចជាបែបរចនានៅគោះកែ មាន
ពុទ្ធរូបនៅចន្លោះមួយអង្គ មានទម្រង់បែបរឹងបន្តិច, តែបែបរចនានៅ
បន្ទាយស្រី មានរូបពោធិសត្វអវលោកិតេស្វរៈ នៅខ្លួលជីវេតមិនសូវ
មានក្បាច់រចនា, តែស័ក្តិសម ។

នៅវដ្តកាលនៃព្រះបាទសុរិយវរ្ម័នទី ១ ដែលទ្រង់បាននោយពជ-
សម្បត្តិនៅសម័យអង្គរ ពុកជាក់ថា ព្រះអង្គជាពុទ្ធសាសនូបត្ថម្ភក៍ជា
ដំបូង ។ ការរចនាព្រះពុទ្ធសាសនាបានខ្លួលក្តីប្រោសប្រាណជាច្រើនទៀត
ដែលសំដែងឲ្យឃើញប្រាកដនៅកណ្តាលគ្រិស្តសតវត្សរ៍ទី ១១
គឺកន្លងកាលនោះហើយ ដែលកើតមានព្រះពុទ្ធរូបប្រភេទនាគ ដែលពុកថាជា
សម្បត្តិប្រទេសកម្ពុជាមកឃ្លាតឆ្ងាយហើយ ។ ព្រះពុទ្ធរូបភាំងឡាយនោះ
មានលក្ខណៈជាបែបរចនាសម័យប្រាសាទបាពួន គឺសម្បាលក្ខណៈ
ប្រកបដោយកុណ្ឌគុណ, ដើងចម្ងាស់ម៉ត់ចត់យ៉ាងវិសេស, ការរចនា
ជាគ្រឿងលំអនាគប្រណីតបញ្ចង់ ។

ពុទ្ធបូជនីយដ្ឋាននៃព្រះចុលិលិយ ប៉ិតខៅខាងទិសឧត្តរនៃព្រះកំពង់ផែ
សាងតាមបែបអគ្គិវត្ត ។ ហោជាងនឹងផ្តែនៃពុទ្ធបូជនីយដ្ឋានថែរក់ខនេះ
(រូបថតទី ៤) ថ្ងៃនត្រង់ក័ណ្ឌដែលមុខគួរឲ្យរំកើបចិត្ត នឹងមុខគួរឲ្យមាន
តម្លៃថ្លៃថ្នូរនៃដីប្រវត្តិព្រះពុទ្ធ តីត្រង់មានរលើកកងច័តមកប្បាំងជណ្តើម
ពុទ្ធបល្ល័ង្ក ត្រង់សំដែងធម្មចក្កប្បវត្តនសូត្រ, ត្រង់ទ្រង់មានករុណាទទួល
សាកែថ្វ ។ ពុទ្ធបូខាងដើមគ្រិស្តសតវត្សរ៍ទី ១២ បានវិវឌ្ឍន៍តាំងតែអំ
ព៉ាបែបវេចនាជាច្រើន; លក្ខណៈបូខៅល្អឥតខ្ចោះ សម្ផស្សមានទម្រង់
ល្អត្រកាល, ការលំអកិរិយាតែតែរិសេសសាលជាងខេនៅខៀត; ក្បាំង
ទឹងមកុដនៃព្រះពុទ្ធបូទ្រង់គ្រឿង ព្រមទាំងលំអនាគសុទ្ធសឹងប្រណីត
បញ្ចប់ទឹងធ្វើតធាយ គួរឲ្យពិតពិលរមិលមើល, ប៉ុន្តែគួរកត់សំគាល់ថា
កងការប្រតិស្ឋ មានទិន្នាការខៅខាងអាការក្រៀមក្រំបន្តិច ។
លក្ខណៈទាំងខេនេះ មានជាតិរសេសបំពោះអគ្គិព្រះពុទ្ធបូប្រកំនាគ ខៅក្នុង
តំបន់ស៊ីសូផុន ដែលគេបានយកមកជំគល់ទុក ខៅកងជិតិងកណ្តាលដ្ឋាន
ខៅក្រុងភ្នំពេញ (រូបថតទី ៣) ។

កងរវាងតាតទី ២ នៃពាក់កណ្តាលគ្រិស្តសតវត្សរ៍ទី ១២, ការវេចនា
ព្រះពុទ្ធសាសនាខ្មែរ បំរែនរុងរឿងខ្ពស់បំផុត គេទុកថាជាសម័យយុគ.
មាស ។ ជ័យជំនះព្រះចាទជយវ៉ារ្មនទី ៧ បណ្តាលឲ្យព្រះពុទ្ធសាសនា
លទ្ធិមហាយានមានជ័យជំនះដែរ ។ ទ្រង់បានតសាងប្រាសាទ "ចាយ័ន"
ទុកជាមហាតិរិយារនៃព្រះពុទ្ធសាសនា, ជាមជ្ឈមណ្ឌលព្រះរាជអាណា.
ចក្រលទ្ធិមហាយាន, មិនតែប៉ុណ្ណោះទេ, ទ្រង់បានតសាងពាជវិហារធំ ។

ដូចជាប្រាសាទព្រះខាន់, តាព្រហ្ម, បន្ទាយក្តី ព្រមទាំងវិហារនៅខែត្រ
ដូចជាបន្ទាយ "ឆ្មារ", វត្តនគរធំឯតាព្រហ្ម នៅជាដើម ។

អំពីពុទ្ធរូប, គេសង្កេតឃើញមានពុទ្ធរូបពីរបែប មួយបែប
ទ្រង់ឈរកាន់ព្រះហស្ត ឬអតយមុទ្រ:, មួយបែបទៀត ទ្រង់គង់ទាត់សមាធិ
ប្តូរតែមុទ្រ: មានន័យប្លែក ។ អំពីរូបពោធិសត្វ, កាលពីអតីតសម័យ
មិនសូវមានច្រើន; ឥឡូវឃើញមានច្រើន ។ ទេវរូបមហាយាន ដែលសិល្បៈ
តែកសាងច្រើន តើអង្គពោធិសត្វអវលោកិតេស្វរ: ឬធិព្រះនាងប្រាជ្ញា
បារមិតា ? ។ លើនប្រាសាទ "បាយ័ន" មានផ្ទាក់ព្រះពុទ្ធរូប ដែល
ប្រកបដោយមេត្តាចិត្ត ។ ទេវរូបទាំងអស់នោះ ជាខាងសាសនាព្រាហ្មណ៍
ឬ ខាងព្រះពុទ្ធសាសនា ពុំកជាអង្គព្រះពាយ, លុះទ្រង់ទិវង្គត ទៅកើត
ជានៅជាទេវរូបតិតប្រាកដ, ដូច្នេះ ទេវរូបទាំងឡាយនៅប្រាសាទ
"បាយ័ន" ពុំកជារូបភាពមុខគួរឱ្យមានសេចក្តីរំភើបចិត្តយ៉ាងក្រៃលែង ។
សម្មាសម្ពោធិញ្ញាណ បញ្ចេញរស្មី មកលើព្រះតក្ត្រនោះទាំងអស់ ។
ញាញីមដែលចេញមកពីខាងក្នុង ហៅថា "ញាញីមបាយ័ន" ល្បីល្បាញ
ឮកន់ដូចជាគំនូរគួរតែសមានអាការ ដែលគេចាប់យកមិនបាន គឺជាសម្ម-
សម្ពោធិ, រឹមតែញាណដែលផុតចេញពីព្រះវិត្រលគុណ៍ មិនតែប៉ុណ្ណោះ
ទេ, មានមហាករុណាចំពោះពួកជនដែលមានសេចក្តីទុក្ខថែមទៀតផង ។
បើដូច្នេះ ម្តេចឡើយកំទំធ៌មិនទាំងឱ្យមានកម្ម្យាការជាតម្លើរភាព (រំភើប
ចិត្តយ៉ាងមហិមា) ចំពោះព្រះតក្ត្រដែលប្រកបដោយមនុស្សធម៌ដ៏ខ្ពង់ខ្ពស់
ដែលបញ្ចេញរស្មីមកអំពីកំពូលសម្មាសម្ពោធិញ្ញាណ _ ឧទ្ធមហាករុណា.

ចំគុណនៃព្រះសម្មាសម្ពុទ្ធទៅបាន?

ទៅពេលនេះ យើងមិនអាចរៀបរាប់អំពីទេវរូបដ៏ល្អ ។ ទាំងនោះក្នុងសម័យ ដែលរុងរឿងបំផុតនោះបានឡើយ ។ យើងសូមតែពឹងឲ្យបានដឹងថា ព្រះពុទ្ធរូបទៅស្ថាសាទព្រះខាន់ មានសភាពស្ងប់ស្ងៀមក្សត្តិ, តោដ-សត្វអរិលោកតែស្ងាត់ ទៅទ្វារខ្ទោចអន្លង់ធំ ប្រកបដោយមេត្តាចិត្ត (រូបថត ទី ៤), អង្គនាងស្រាជ្ញាបារមីតាពដកុមារ ទៅមន្ទីរពិពិធកណ្ឌក្រុងកុំពេញ មានអាការញញឹម ហាក់ដូចជាក្រៀមក្រំបន្តិច (ញញឹមស្ងួត) (រូបថត ទី ៥) ។ ព្រះបាទជយវរ្ម័នទី ៧ ដែលមានមហាគុណាធិគុណរបស់ព្រះពុទ្ធបានជ្រាបចូលទៅក្នុងព្រះអង្គ ធ្វើឲ្យរូបកាពព្រះអង្គប្រកបដោយមនុស្សធម៌ ខឹងឥន្ទានុភាពដ៏ក្រៃលែង នាំឲ្យយើងនឹកដល់ព្រះពុទ្ធបន្ទូលដែលទ្រង់ត្រាស់ទុកថា "ទ្រង់មានព្រះទ័យខ្ជាប់ផ្សាំចំពោះជម្ងឺប្រជាជន ខ្លាំងជាងព្រះអាពាធព្រះអង្គ ព្រោះថា សេចក្តីទុក្ខនៃប្រជាជន ជាសេចក្តីទុក្ខនៃព្រះពុទ្ធទាំងឡាយ តុំមែនចំពោះទុក្ខផ្ទាល់ព្រះអង្គឡើយ" ។

ព្រះពុទ្ធសាសនាលទ្ធិមហាយានរុងរឿងបានតែត្រឹមតែ ៤-៥ សតវត្សរ៍ (២០ ឬ ៣០ ឆ្នាំ) ក្នុងកាលជាខាងក្រោយ ដែលព្រះបាទជយវរ្ម័នទី ៧ ទ្រង់ទិវង្គតហើយ ។ បើទុកជាដូច្នេះ ព្រះពុទ្ធសាសនានៅប្រទេសកម្ពុជាមិនមែនអន់ថយប៉ុនទេ ។ ក្នុងរវាងពីរបីទាំងមានអ្នកអធិម្មត្តន្ត្រៀតរកឧបាយបំផ្លេចបំផ្លាញរូបបដិមាករ ព្រះពុទ្ធសាសនានៅក្នុងប្រទេសនេះ ដែលជាប្រទេសកាន់ខន្តីធម៌ខ្លាំងខ្លាយ តាំងតែពីប្រាំនសតវត្សរ៍មកហើយ ។ សម័យវិបត្តិនេះ ធ្វើឲ្យមានការកាន់ប្រៃ; ព្រះពុទ្ធសាសនាលទ្ធិមហាយាន

ខ្ញុំដល់សេចក្តីសោមនស្សខ្លាំង ហើយព្រះពុទ្ធសាសនាលំដាប់ពីនេះ
ប្លែកពីគ្នាឡើងវិញ ។ ចំណែកព្រះពុទ្ធសាសនាចាប់ពីនេះ
ព្រះចាប់ផ្តើមវគ្គទី ៧ ទ្រង់សព្វព្រះពជហឫទ័យរួចមកហើយ ប្លែក
ទ្រង់បញ្ជូនព្រះពជបុត្រមួយព្រះអង្គ ឲ្យទៅសិក្សាទស្សនវិជ្ជាព្រះពុទ្ធ-
សាសនាចាប់ពី ឯកោះសិរីលង្កា ។

ក្នុងគ្រិស្តសតវត្សទី ៨, សិល្បៈបានទុកឲ្យយើងឃើញស្នាដៃឯករហូត
មកដល់បច្ចុប្បន្នកាល, ដោយពិសេស ក្នុងខាងដើមនៃសិល្បៈមុខតស៊ាង
ប្រាសាទបាយ័ន ។

ពិពិធកណ្ឌដ្ឋានទៅក្រុងកំពេញមានរូបចំឡាក់មួយ ដែលល្អក្រៃលែង
ក្នុងសម័យនោះ; គឺជាព្រះពុទ្ធរូបប្រកាន់នាគគង់ខាត់សមាធិ ព្រះនត្រូចិ
ពាក់កណ្តាល តាមលក្ខណៈពិសេសរបស់បែបការបច្ចា ។ អាកប្បកិរិយា
នៃព្រះពុទ្ធរូបប្រកបដោយអតិដនភាព, ព្រះភក្ត្រប្រកបដោយតន្ទីរស្ងៀ
ព្រមទាំងអាការៈសួបរម្យក្សត្ត ទំនងមេត្តាចិត្តដែលគើតអំពីសម្មាសម្ពោ-
ធិញ្ញាណដ៏ផ្សាលផ្សៃ (រូបថតទី ៧) ។

ជាទៃអំពីសិល្បៈសាសនាព្រាហ្មណ៍, សិល្បៈព្រះពុទ្ធសាសនាចំរើន
រុងរឿងយូរអង្វែងណាស់មកហើយដែរ, យ៉ាងហោចណាស់ ក៏មាន
ការកសាងព្រះពុទ្ធរូបឡើង ឯសិល្បៈព្រះពុទ្ធសាសនា ក៏មានលក្ខណៈ
ដោយឡែកពិសេស ។ សេចក្តីពិសេសនៃព្រៃចីវរឬគ្រឿងប្រកបផ្សេង ។
មានផលប្រយោជន៍ សម្រាប់អ្នកបូកណាវត្តច្រើនណាស់, ប៉ុន្តែយើងត្រូវតែ
គាំងចិត្តសិក្សាទៅសិល្បៈពិសេស ដែលយើងគួរចង់ដឹងចំពោះបដិមាករ

ខាងត្រែភុទ្ធសាសនានេះ ។ ព្រះភុទ្ធបូបនៅវត្តរំលោក ជាបដិមាករ
មានអាការខន់ទៅរកសាកែព្រះអង្គ ។ ព្រះកន្ត្រៃព្រះភុទ្ធបូបនាគប្រក់
ជាបដិមាកមានអាការពេញត្រៀបដោយសមាធិចិត្តដ៏ជ្រាលជ្រៅ ។
ដ័យជំនះ នៃសម្ចាសម្ពោធិញ្ញាណតាមបែបការពិនានៅប្រាសាទជ្ញាយ័ន
នាំឲ្យយើងយល់ថា ព្រះពុទ្ធសាសនាថ្កុំថ្កើងរុងរឿងណាស់ ។

ត្រប់តែព្រះកន្ត្រៃព្រះភុទ្ធបូបក្តី បូបពោធិសត្វអរិលោកិតេស្វរៈក្តី បូបព្រះ
នាងប្រាជ្ញាបារមីតាក្តី ជាបដិមាកមានអាការបង្ហាញស្មើឲ្យយើញថាមាន
ព្រះមហាករុណាគុណឥតរំបិទ ។

ការបញ្ចូលព្រះពុទ្ធសាសនាទៅជាបុគ្គលគួរដល់តារាកាត ដោយបាន
ប្តូរប្រែភាពនៃព្រះមហាកជា ទេពព្រះមហាកដ៏ទេ ទៅជាពុទ្ធកដៈ ។ ការ
រំលឹកបញ្ជាក់ដ៏អស់នេះ ប្រាន់តែតិតែជំរឿន ចេញអំពីការញ៉ឹមនៃសើន
សិល្បៈជ្ញាយ័ន ដែលគេរៀបចំតួនាទីក្រឡេកមើល ពុកជួចជាលំនាំដ៏
បរិសុទ្ធរៃត្រែលង នៃទេពកោសល្យខ្មែរ ។

ប្រយោជន៍ ២ យ៉ាង

ស្រីអ៊ូ បណ្ឌិតនៅពុទ្ធសាសនបណ្ឌិត្យ ភ្នំពេញ

រៀបរៀង

មានសេចក្តីដំណាលថា ព្រះបរមគ្រូទ្រង់គង់នៅវត្តជេតពន ដឹងក្រុងសាវត្ថី ព្រះអង្គសំដែងអំពីប្រយោជន៍ ២ យ៉ាង ប្រារព្ធចំពោះព្រះភ្លុកបសេនទិកោសលថា

ទិដ្ឋេ ធម្មេ ច យោ អត្ថោ យោ ច សម្បរាយិកោ
អត្ថាភិសមយា ធីរោ បណ្ឌិតោតិ បវុច្ចតិ ។

ប្រែថា ធីរជនដែលសោកហៅថា បណ្ឌិត ព្រោះស្រង់យកនូវប្រយោជន៍ ២ យ៉ាងបាន គឺប្រយោជន៍ខាងក្នែកឃើញ ១ ប្រយោជន៍តាមជួនទៅក្នុងបរលោក ១ ។

សេចក្តីអធិប្បាយ:

ពាក្យថា ប្រយោជន៍ ជាវត្ថុបំណងរបស់ប្រជាជនទូទៅ ។ ប្រយោជន៍ដែលកំណត់ប្រើជាភាសាខ្មែរសព្វថ្ងៃនេះ មកពីពាក្យសំស្រ្កឹតថា ប្រយោជិន: ភាសាចាលីថា បយោជិន: ប្រែថា ដំណើរដែលគួរប្រកប, របស់ដែលគេត្រូវការ ផលដែលសម្រេចមកអំពីការប្រកប ។ ប្រយោជន៍ចេញមកពីពាក្យថា អត្ថ: ប្រែថា "សេចក្តីត្រូវការ, សេចក្តីចំរើន" អត្ថ: បើមកជាគូនឹង ធម្ម: ។ ប្រែថា"ហេតុ" អត្ថ: ប្រែថា "ផល" ។

ពាក្យថា ប្រយោជន៍ ក្នុងន័យនេះ សំដៅយកផល ដែលសម្រេចមកអំពីការប្រកបការងារតូចធំ តាមប្រើនតាមសមត្ថភាព ដែលបុគ្គលអាចធ្វើបាន ។ ដូចយ៉ាងគ្រឿងសម្ភត្តិគាំទ្រជីវិត គឺមាសប្រាក់ស្រែអង្កាផ្ទះសម្បែងក្របីគោសេះដំរី គោចក្រយានរថយន្តជាដើម ដែលបុគ្គលរកបានមក ហៅថា " ប្រយោជន៍ " ព្រោះជាផល ដែលសម្រេចមកអំពីការស្វះស្វែងរក ។ អម្រស់អម្រែដែលរកបានមក សម្រាប់ចិញ្ចឹមរក្សាខ្លួន ហៅថា ប្រយោជន៍ចំពោះខ្លួន ។ អម្រស់អម្រែដែលរកបានមក ហើយចិញ្ចឹមមាតាបិតាបុត្រភរិយាទាសកម្មករ ឲ្យបានសេចក្តីសុខ បំបាត់សេចក្តីអន្តរាយផ្សេង ។ សង្គ្រោះញាតិសន្តានមិត្រសំឡាញ់ ខ្ចប់ល្អៀរបង់ពន្ធដារអោកាសទូសារពើ បរិច្ចាគទានចំពោះសមណព្រាហ្មណ៍ មានសាលារៀន កុដិ វិហារ ស្ពានថ្នល់ជាដើម ហៅថា ប្រយោជន៍ចំពោះខ្លួនផង ចំពោះអ្នកដទៃផង ។

ឯប្រយោជន៍ខាងក្នុងយើញ គឺផលដែលខ្លួនបានខ្ចប់ប្រើប្រាស់ក្នុងពេលកំពុងរស់នៅ ដូចយ៉ាងគ្រឿងសម្ភត្តិ មាសប្រាក់ ផ្ទះសំបែងក្របី គោ ឥន្ធនក្តីរឈ្មោះយសស័ក្តិជាដើម ដែលបានខ្ចប់ប្រើប្រាស់ក្នុងពេលដែលខ្លួនកំពុងរស់នៅ ។

ម្យ៉ាងទៀត ប្រយោជន៍ខាងក្នុងយើញ បាត់ចូលក្នុងសម្ប៉ា ៤ គឺ

១ - ឧដ្ឋានសម្ប៉ទា បរិបូណ៌ដោយការព្រាងឡើង ដើម្បីធ្វើការងារ;

២ - អារក្ខសម្ប៉ទា បរិបូណ៌ដោយការថែរក្សា,

๓- กัลยาณมิตตตา ภาวะជាអ្នកមានមិត្តល្អ,

๔- សមជីវិតា ភាវៈជាអ្នកចំណេញដំរិតស្មើល្មមនឹងធនធាន ។

ឯប្រយោជន៍តាមដូនក្នុងលោកខាងមុខមាន ៤ ដែរគឺ

๑- សទ្ធាសម្បទា បរិបូណ៌ដោយជំនឿ ។ ជំនឿដែលប្រកបជាប់ក្នុងខ្លួន ដូចដឹកនាំឲ្យប្រព្រឹត្តល្អ ឲ្យបរិច្ចាគទានតាមតែឈ្នះសេចក្តីគំណាញ់ ។ មនុស្សខាងឯណាដែលនឹងបានល្អ ព្រោះដឿកាន់យកតាមសេចក្តីណែនាំរបស់អ្នកចេះដឹងមុន ដែលគេបានពិសោធរួចមកហើយ ។ ដូចបុត្រធីតានឹងបានល្អ ក៏ព្រោះដឿកាន់យកតាមដំបូន្មានរបស់មាតាបិតា, សិស្សនឹងបានចេះដឹងច្រើន ក៏ព្រោះដឿកាន់យកតាមទង្វើរបស់គ្រូ, បរិស័ទអ្នកកាន់ព្រះពុទ្ធសាសនា ដែលនឹងទទួលផលដ៏ប្រសើរ ព្រោះដឿតាមការគ្រាស់ដឹងរបស់ព្រះសម្មាសម្ពុទ្ធបរមគ្រូ ។

๒- សីលសម្បទា បរិបូណ៌ដោយការប្រព្រឹត្តកាយវាចារៀបរយមានសណ្តាប់ធ្នាប់ល្អ ។ បុគ្គលដែលនឹងប្រព្រឹត្តល្អ មិនធ្វើអំពើអាក្រក់ដោយកាយវាចា មិនបៀតបៀនអ្នកដទៃដោយការពិចារណា ដោយវិចារណញ្ញាណថា:

-សត្វទាំងអស់ត្រូវការសេចក្តីសុខសប្បាយ ត្រូវការសេរីភាព សិទ្ធិភាព អធិបតេយ្យ ត្រូវការរស់នៅយឺនយូរ ត្រូវការជួបជុំស្វាមីភរិយា បុត្រធីតា មិនត្រូវការសេចក្តីព្រាត់ប្រាស ។ល។ ដូច្នេះមនុស្សដែលមានសេចក្តីត្រូវការជួបគ្នា មិនត្រូវបៀតបៀនទ្រូវគ្នានឹងគ្នាឡើយ ។

-សត្វទាំងអស់ត្រូវការទ្រព្យសម្បត្តិ ស្រឡាញ់ទ្រព្យសម្បត្តិមិនមាន

ទំបំផុតក្នុងការចង់បានចង់មាន; ដើម្បីយុត្តិធម៌ក្នុងទ្រព្យសម្បត្តិដែលជាកម្មសិទ្ធិរបស់គេ ដែលគេថែរក្សាទុកនោះ ជនអ្នកមានសេចក្តីត្រូវការជួបគ្នា មិនត្រូវលួចទ្រព្យសម្បត្តិគេឡើយ ។

—សត្វទាំងអស់ តែងបរិភោគតាមរកងបុរសស្ត្រី តាមប្រពៃណី ដោយសេចក្តីស្នេហា ដែលកើតអំពីធម្មជាតិ ជនអ្នកមានសេចក្តីស្នេហាជួបគ្នា មិនត្រូវប្រព្រឹត្តល្មើសសិទ្ធិស្នេហា ក្នុងគូគ្រងរបស់អ្នកជាខៃឡើយ ។

—មនុស្សទាំងឡាយរមែងត្រូវការសេចក្តីពិតត្រង់ ត្រូវការទំនុកចុកចិត្តរកងគ្នានឹងគ្នា ដើម្បីរួមភួក រួមសង្គម ។ បុគ្គលអ្នកមានបំណងត្រូវគ្នា មិនគួរគោលពាក្យកុហកឡើយ ។

— មនុស្សទាំងឡាយតែងត្រូវការសេចក្តីថ្លៃថ្នូរ ត្រូវការស្មោះត្រង់ដើម្បីច្រើស្រែយគ្នាឱ្យបានស្រួល ។ ដូច្នេះ បុគ្គលអ្នកមានសេចក្តីត្រូវការជួបគ្នាមិនគួរសេពសុកឡើយ ។

៣ ចាគសម្បទា បរិបូណ៌ដោយការចែកចាន គឺចេះចែករំលែកជនជាន ដែលខ្វះខាន ដល់សមណព្រាហ្មណ៍ ឃាតក អ្នកកំសត់ទុគ្គតអនាថាគាថសម្តួ ឈ្មោះថា ចែករំលែកសេចក្តីសុខដល់អ្នកជាខៃ ។

៤—ឧជ្ជាសម្បទា បរិបូណ៌ដោយត្រង់ គឺមានការយល់ ប្រកបដោយសម្មាទិដ្ឋិថា ធ្វើបុណ្យបានបុណ្យ ធ្វើបាបបានបាបជាដើម ។

បុគ្គលជាអ្នកត្រង់ តែងត្រេះឃើញនូវប្រយោជន៍ទាំង ៤ យ៉ាងគឺ ប្រយោជន៍ខាងក្នុងឃើញ ខាងក្រៅ ប្រយោជន៍តាមក្រុង តាមលោកខាងមុខ ដូចពោលមក ដោយសង្ខេបនេះ លោកឱ្យឈ្មោះថា "បណ្ឌិត" ។

បញ្ចប់សេចក្តីអធិប្បាយត្រឹមប៉ុណ្ណេះ ។

ការស្រាវជ្រាវរកមង្គល

អ៊ុក.៨ដ

ក្រុមាបញ្ជីសាលាខ្មែរណ៍

រៀបរៀង

មង្គលនោះ គឺអ្វី?

មង្គលគឺសេចក្តីសុខ, សេចក្តីចំរើន, ហេតុដែលនាំឲ្យបានសេចក្តីសុខ-ចំរើន ឬថា សិរីសួស្តី ។ ពាក្យថា មង្គលនេះហើយ ដែលជាព្រះផ្ទាល់នាំឲ្យមនុស្សខ្មែរ ទឹងព្រហ្មទាំងឡាយនាំគ្នាសាកសួរគ្នា អស់រយៈកាល ១២ ឆ្នាំ គ្មាននរណាមួយអាចសន្និដ្ឋានបានថា នេះជាមង្គលឬនោះជាមង្គលឡើយ គឺគេតែងតាំងជាបញ្ហាមួយ ដ៏ស្មុគស្មាញក្រៃលែងវិនិច្ឆ័យពុំជាច់ស្រេចសោះ ។

មានសេចក្តីដំណាលថា មហាជនទៅជម្ពូទ្វីបទាំងមូល បានប្រជុំគ្នាក្នុងទីតាំងឡាយ មានទីក្សត្រាព្រះនគរ, សណ្ឋាគារ ទឹងសភា ជាដើម បានជួលគ្នាដោយច្រើនមាស ឲ្យនិយាយរឿងតាំងវាស្ទង ។ មានរឿងនាងសិតាជាដើម គឺរឿងទីមួយៗដល់ ៤រឿ តើចជាច់ស្រេច ។ ការប្រជុំគ្នាច្រើននេះ ក៏បណ្តាលឲ្យគេតែងតាំងជាពាក្យដដែគ្នាគេមង្គលថា:

កិន្តុខោ មង្គលំ កឹ និដ្ឋំ មង្គលំ សុតំ មង្គលំ មុតំ មង្គលំ ឝោ មង្គលំ ជាតាតិ អ្វីហ្នឹងជាមង្គល រូបារម្មណ៍ដែលភ្នែកបានឃើញ ជាមង្គលឬ? សទ្ទារម្មណ៍ដែលត្រចៀកបានឮ

ជាមង្គលឬ? តន្ទាម្នាណ, រសោម្នាណ ទឹងជាដួញម្នាណ ដែលប្រមុះ
អណ្តាត ទឹងកាយ ប៉ះពាល់ ជាមង្គលឬ? នរណាបានដឹងនូវមង្គល? ។

គ្រានោះ ស្រាប់តែបុរសអ្នកប្រកាន់យកបែបដែលមើលឃើញ
ជាមង្គល ក៏និយាយឡើងថា អហំ មង្គលំ ជាឆាមិ និដ្ឋំ
សោតេ មង្គលំ រូបំ ខ្ញុំដឹងវត្ថុជាមង្គល គឺរូបដែលក្អែកបានឃើញ
រាប់ថា ជាមង្គលក្នុងលោក ព្រោះថា បុគ្គលណាមួយក្នុងលោកនេះ
ក្រោកពីព្រលឹមស្រាង។ ហើយ បានមើលឃើញរបស់ពណ៌ខ្មៅមានសត្វ
ត្រចៀកសាំ ទំពាំងឬស្សី ស្តើមានតតិ ក្អែងដែលមានត្រឹងប្រជាប់តាក់
តែង ក្អមពេញដោយទឹក ត្រឹត្តិនស្រស់ សេះអាជានេយ្យ រថអាជានេយ្យ
គោឈ្មោល គោញី សត្វស្វាជាដើម ឬថា ឃើញនូវវត្ថុណាមួយក្រៅ
ពីនេះ អ្នកដែលឃើញវត្ថុមានសភាពដូច្នេះ រាប់ថាជាមង្គល, រួចម្នាណ
ដែលក្អែកមើលឃើញដូច្នេះ លោកហៅថា "ទិដ្ឋមង្គល" ។

លំដាប់មក មានបុរសម្នាក់ទៀតជាអ្នកប្រកាន់យកការស្តាប់ឮ ជាមង្គល
គេលេងឡើងភ្លាមថា ម្នាលអ្នកដ៏ចំរើនវ័យ ការដែលក្អែកបានមើល
ឃើញនូវរួចម្នាណ ហើយរាប់ថាជាមង្គលនោះ ពុំគាន់បាននៅឡើយទេ
ពីព្រោះធម្មតាក្អែកមែនមើលឃើញនូវរូបស្អាតខ្លះ រូបមិនស្អាតខ្លះ រូបល្អខ្លះ
រូបមិនល្អខ្លះ រូបជាទីគាប់ចិត្តខ្លះ រូបមិនជាទីគាប់ចិត្តខ្លះ ហេតុនោះ រួច-
រម្នាណដែលគេបានមើលឃើញដោយក្អែកនោះ ពុំគួរពោលថាជាមង្គលទេ
បើតាមយោបល់ខ្ញុំ ខ្ញុំយល់ថា សំឡេងដែលគេបានឮដោយត្រចៀកទើប
ឈ្មោះថា ជាមង្គល ព្រោះថា បុគ្គលខ្លះក្នុងលោកនេះ ពើក្រោកឡើងពី

ត្រលឹមស្រាង ។ ហើយបានស្តាប់ឮសំឡេងគុំថា ចំរើន ថាកំពុងចំរើន ថាបរិបូណ៌ ថាជនមានសម្បុណ៌ស ថាជនមានចិត្តល្អ ថាសិរី ថាថ្ងៃនេះជាទិវាដ៏ប្រសើរល្អយ៉ាមល្អ ជាសុភមង្គល ។ ការដែលត្រចៀកស្តាប់ឮសំឡេងមានសភាពដូច្នេះ ទើបលោកសន្មតថា សុភមង្គល ។

លំដាប់នោះ មានបុរសម្នាក់ ជាអ្នកប្រកាន់យកការប៉ះពាល់ជាមង្គល និយាយឡើងថា នែអ្នកទាំងឡាយដ៏ចំរើន ការដែលស្តាប់ឮដោយត្រចៀកបែបនេះ ពុំបានពាក់ព័ន្ធថាជាមង្គលទៅឡើយទេ ព្រោះត្រចៀករមែងស្តាប់ឮនូវសំឡេងពីរោះកំមាន សំឡេងមិនពីរោះកំមាន សំឡេងជាទីគាប់ចិត្តកំមាន សំឡេងមិនជាទីគាប់ចិត្តកំមាន ហេតុនោះសំឡេងដែលគេស្តាប់ឮដោយត្រចៀក ពុំគួរពាក់ព័ន្ធថាជាមង្គលទេ បើតាមយោបល់ខ្ញុំ ខ្ញុំយល់ថា ភ្នែក, រស, ផោដ្ឋព្វៈ (ការនាំឲ្យកើតរសចក្តីដឹង) ដែលប៉ះពាល់ ដោយប្រមុះ, អណ្តាត នឹង កាយ ទើបសន្មតថាជាមង្គលបាន ព្រោះថា បុគ្គលពួកខ្លះក្នុងលោកនេះ បើស្រាកឡើងពីត្រលឹមស្រាង ។ បានធុំក្លិនផ្កាមានផ្កាឈូកជាដើម បានទំពាស៊ីនូវឈើស្ងួនមានព័ណ៌ស បានសម្លាប់នូវផែនដី បានប៉ះពាល់សំឡូនមានព័ណ៌ខៀវ អាចម៍គោស្រស់ បានចាប់កាន់រនេះពេញដោយលូ ស្លាឈើ ផ្លែឈើ លាបនូវមេឃពណ៌ស បានស្ទៀកសំពត់រលើប បានដួតក្បាលដោយសំពត់រលើប ការប៉ះពាល់នូវវត្ថុ មានសភាពដូចពោលមកនេះ ទើបសន្មតថា មុតមង្គល ។

បុរសទាំង ៣ រូប ដែលប្រកាន់តាមមតិរៀងខ្លួននោះ ពុំអាចញុំាងគ្នានឹងគ្នាឲ្យយល់ច្បាស់នូវគោលការណ៍រៀងខ្លួនបានឡើយ ។ បណ្តាមនុស្ស

ពាំនឹងឮយ៉ាងក្រៅពីបុរសពាំនឹង ៣ នាក់នោះ មនុស្សពួកខ្លះក៏ជឿតាមពាក្យ ទិដ្ឋមង្គលិកបុរស ខ្លះក៏ជឿតាមពាក្យសុតមង្គលិកបុរស ខ្លះក៏ជឿតាមពាក្យមុតមង្គលិកបុរស ហើយក៏ប្រកែកគ្នាដែរគ្នា ដោយប្រការនេះតាមបក្សពួកតែរៀងខ្លួន មនុស្សជឿតាមពាក្យ ទិដ្ឋមង្គលិកបុរស ក៏ចូលចិត្តជឿនូវទិដ្ឋមង្គល ។ មនុស្ស ជឿតាមពាក្យសុតមង្គលិកបុរស ក៏ចូលចិត្តជឿនូវសុតមង្គល ។ មនុស្សជឿតាមពាក្យមុតមង្គលិកបុរស ក៏ចូលចិត្តជឿនូវមុតមង្គល ។ ពាក្យសួរកមង្គលដូចរៀបរាប់មកនេះក៏លេចឡុះសាយឡើង ក្នុងសកលជម្ពូទ្វីប ។

. អថ សកលជម្ពូទីបេ មនុស្សា ភុម្មភុម្មា បាតុភវិត្ថ ខោ មង្គលត្តិ ចិត្តយឹសុ គ្រានោះ មនុស្សពាំនឹងឮយ៉ាង ក្នុងសកលជម្ពូទ្វីប ក៏ពួតគ្នាភៀងជាពួក ៗ គិតរកមង្គលថា "តើយ៉ាងណាជាមង្គល"? ។

ក្នុងពេលនោះ សូម្បីតែក្តេវេតាពាំនឹងឮយ៉ាង កាលបានឮនូវមង្គលកថានោះ ក៏ដឹងសំណាក់នៃមនុស្សពាំនឹងឮយ៉ាង ហើយក៏គិតរកនូវមង្គលពាំនឹងឮយ៉ាងដូចពួកមនុស្សដែរ ។

ដោយហេតុថា មនុស្សជាមិត្រនឹងតាក្តេវេតា តាក្តេវេតា ជាមិត្រនឹងភូមិទេវតា ភូមិទេវតា ជាមិត្រនឹងអាកាសដ្ឋកទេវតា អាកាសដ្ឋកទេវតា ជាមិត្រនឹងចាតុម្មហារាជិកាទេវតា ។ ល ។ សុទស្សីទេវតា ជាមិត្រនឹងអកនិដ្ឋទេវតា ។

. ទេវតានឹងព្រហ្មពាំនឹងឮយ៉ាង ក្រោយដែលបានស្តាប់នូវមង្គលកថា តៗគ្នាភៀង ក៏ថែកគ្នាជាពួក ។ លើយគិតរកមង្គល ដូចពោលមកនេះ ។

ការស្រាវជ្រាវរកមគ្គ័លដូចពោលមកខាងលើនេះ តើគេមានឡើងត្រង់តែទីឋានគាំងឈ្មោះក្នុងមួយចក្រវាឬ ? ការស្រាវជ្រាវរកមគ្គ័លនោះ អស់រយៈកាល ១២ ឆ្នាំ មិនមាននរណាអាចនិយ័យបាននោះ ។

គ្រានោះ មនុស្ស, ទេវតា ទើបព្រហ្មគាំងឈ្មោះ លើកវិលជាតែព្រះអរិយសាវកចេញ កំបែកខ្វែកគ្នាជា ៣ ពួក តាមមតិនៃទិដ្ឋមគ្គ័លិកបុរស សុតមគ្គ័លិកបុរស ឥន្ទ្រិយមគ្គ័លិកបុរស សូមឲ្យតែងនម្មាក់ទើងចូលចិត្ត ដោយជាក់ច្បាស់ថា នេះជាមគ្គ័ប ឬ នោះជាមគ្គ័លក៏គ្មានដែរ ។

លំជាប់នោះ ស្រាប់តែបណ្តាលហេតុឡើង គឺទេវតានៅកន្លែងជាន់សុទ្ធាវាស បានដឹងការចិត្តនៃមនុស្សគាំងឈ្មោះ ហើយក៏ត្រាច់ចរៅមកក្នុងមនុស្សបថ (កន្លែងដែលមានមនុស្សនៅ) ហើយប្រាប់ថា "កន្លែងតំនេះនៅរាង ១២ ឆ្នាំទៀត ព្រះសម្មាសម្ពុទ្ធនឹងឧប្បត្តិឡើងក្នុងលោក ហើយទ្រង់នឹងសំដែងនូវមគ្គ័លនោះ" ។ កាលកន្លងតំនាយមក ១២ ឆ្នាំ ទេវតាគាំងឈ្មោះក្នុងឋានតាវត្តិង្ស ក៏តាំងប្រជុំគ្នា រួចចូលទៅគាល់ទូលសួរព្រះឥន្ទ្រថា "បពិត្រលោកមិរទ្ធ មគ្គ័លបញ្ហា ដែលកើតមានឡើងនោះ ទេវតាទើងមនុស្ស ១ ពួក ប្រកាន់នូវទិដ្ឋមគ្គ័ល ១ ពួកទៀត ប្រកាន់នូវសុតមគ្គ័ល ១ ពួកទៀត ប្រកាន់នូវមុតមគ្គ័ល, បណ្តាទេវតាទើងមនុស្សគាំងឈ្មោះនោះ យើងខ្ញុំព្រះអង្គក្តី ទេវតាទើងមនុស្សដទៃក្តី ក៏តាំងនៅក្នុងការសួរគាំស្ទើរគាំងអស់គ្នា យើងខ្ញុំសូមអង្វរ សូមព្រះអង្គព្យាករប្រាប់យើងខ្ញុំ តាមសេចក្តីពិតឲ្យបាន" ។

" មគ្គ័លកថានេះ តើគេមានឡើងជាដំបូង នៅក្នុងឋានណា" សូត្រ

ទេវរាជទ្រង់ត្រាស់សួរ ។

"នៅកន្លែងហានមនុស្សលោក" ទេវតាតាំងឡាយក្រាបបង្គំទូល ។

"ព្រះកតវន្តមុនី គង់នៅកន្លែងហានណា" សក្កទេវរាជត្រាស់សួរ ។

"នៅកន្លែងហានមនុស្សលោក" ទេវតាតាំងឡាយក្រាបបង្គំទូល ។

សក្កទេវរាជទ្រង់ព្រះសណ្តាប់ហើយ ទ្រង់ត្រាស់ថា "ម្នាលអ្នកនិរទុក្ខតាំងឡាយ បើដូច្នេះ ចូរអ្នកតាំងអស់គ្នាមក, យើងនឹងនាំចូលទៅក្រាបបង្គំទូលចំពោះព្រះកតវន្តមុនី អំពីមង្គលសញ្ញានោះ" ហើយត្រាស់បង្គាប់ទៅទេវបុត្រមួយរូបថា "ចូរអ្នកចាំក្រាបបង្គំទូលព្រះកតវន្តមុនីចំពោះមង្គលបញ្ហា" ហើយក៏នាំតម្កងទេវតាតាំងឡាយ ចូលទៅកាន់វត្តជេតពនក្នុងវេលាព្រឹកជាំស្ងាត់ ។

លំដាប់នោះ ទេវបុត្រដែលទទួលបង្គាប់ពីព្រះឥន្ទ្រ ឲ្យក្រាបទូលសួរមង្គលបញ្ហានោះ ក៏ចូលទៅក្រាបបង្គំព្រះកតវន្តមុនី ហើយឈរនៅក្នុងកន្លែងសមគួរ រួចទូលសួរតាមបញ្ហា ចំពោះព្រះកតវន្តមុនី ។

ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងដោះស្រាយ មង្គលបញ្ហានោះ ប្រាប់ទេវបុត្រថា មង្គលមាន ៣៨ ប្រការដូចតទៅនេះ៖

១-ពាលានសេវនា	ការមិនគប់រកមនុស្សពាល,
២-បណ្ឌិតសេវនា	ការគប់រកមនុស្សជាបណ្ឌិត,
៣-បូជនីយបូជា	ការបូជាដល់មនុស្សដែលគួរបូជា,
៤-បដិរូបទេសវាសោ	ការនៅក្នុងប្រទេសដ៏សមគួរ,
៥-បុព្វេ កតបុញ្ញតា	ភាពជាអ្នកបានធ្វើបុណ្យទុកពីមុនមក,

៦-អត្តសម្មាបណិធិ ការដំកល់ខ្លួនដោយប្រពៃ,

៧-ពាហុសច្ចៈ ភាពជាបុគ្គលអ្នកបានរៀន ចេះស្តាប់ច្រើន,

៨-សិប្បៈ សិល្បសាស្ត្រគឺសេចក្តីឆ្លៀវឆ្លាសក្នុងការហត្ថកម្ម;

៩-សុសិក្ខិតវិនយៈ ការសិក្សា ឬការកាន់វិន័យដោយម៉ត់ចត់,

១០-សុភាសិតា ភាចា វាចាដែលបុគ្គលពោលត្រឹមត្រូវ,

១១-មាតុឧបដ្ឋានៈ ការបំរើមាតា,

១២-បិតុឧបដ្ឋានៈ ការបំរើបិតា,

១៣-បុត្តទារសង្គហៈ ការសង្គ្រោះកូន ខ្ចីដ៏ប្រពន្ធ,

១៤-អនាកុលកម្មន្តៈ ការងារមិនច្របូកច្របល់,

១៥-ទានៈ ការបរិច្ចាគទាន,

១៦-ធម្មចរិយា ការប្រព្រឹត្តធម៌,

១៧-ញាតកសង្គហៈ ការសង្គ្រោះញាតិ,

១៨-អនវជ្ជកម្មៈ ការងារមិនមានទោស,

១៩-ចាចាអារតីវិរតី ការមិនត្រេកអរបំពោះជាប ខ្ចីនការ
វៀរចាកជាប,

២០-មជ្ជបានសញ្ញមៈ សេចក្តីសង្រួមចាកការផឹកទឹកស្រវឹង,

២១-ធម្មាប្បមាទៈ ការមិនប្រមាទក្នុងធម៌,

២២-គារវៈ ការគោរពចំពោះបុគ្គល ដែលគួរគោរព,

២៣-និវាតៈ ការប្រព្រឹត្តិបន្ទាបខ្លួន,

២៤-សន្តុដ្ឋិ ការត្រេកអរ ចំពោះរបស់ដែលមាន,

๒๕- กตญฺญุตา ភាពនៃបុគ្គលជាអ្នកដឹងនូវគុណ ដែលអ្នកដទៃបានធ្វើដល់ខ្លួន,

๒๖- กาเลน ธมฺมสฺสวนะ: ការស្តាប់នូវធម៌ តាមកាល,

๒๗- ขนฺติ សេចក្តីអត់ធន់,

๒๘- โสวจสฺสตา ភាពជាបុគ្គលដែលគេប្រដៅងាយ,

๒๙- สมณานญฺจ ทสฺสนะ: ការបានជួបប្រទះនូវសមណៈ,

๓๐- กาเลน ธมฺมสากจฺฉา ការសន្ទនានូវធម៌ តាមកាល,

๓๑- ตป: ការព្យាយាមដុតបំផ្លាញបាប,

๓๒- พฺรหฺมจริย: ការប្រព្រឹត្តនូវធម៌ដ៏ប្រសើរ,

๓๓- อริยสจฺจาน ทสฺสนะ: ការឃើញនូវអរិយសច្ចធម៌,

๓๔- นิพฺพาน สจฺฉิกิริยา ការធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន,

๓๕- ผุฏฺฐสฺส โลกธมฺเมหิ จิตฺตํ ยสฺส น กมฺปติ, จิตฺตเยสฺส បុគ្គល ដែលលោកធម៌ប៉ះពាល់ត្រូវហើយ មិនញាប់ញ័រ,

๓๖- อเสาก: ចិត្តមិនមានសេចក្តីសោក,

๓๗- วิรช: ចិត្តមានធូលី គឺកិលេសរម្ងាប់ហើយ,

๓๘- เขม: ចិត្តក្សេមក្សាន្ត ។

លុះចប់ហើយ ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់បន្ថែមថា" ទេវតា ខ្ញុំធ្លាប់មនុស្សភាំងឡាយ កាលបើបានធ្វើនូវមង្គលភាំងឡាយប្រាកដដូច្នេះហើយ ខ្ញុំធ្លាប់ជាអ្នកមានជ័យជំនះ មិនបរាជ័យ គ្រប់ទីភាំងពួង រមែងបានដល់នូវសិរីសួស្តី គ្រប់ទីភាំងពួង" ហើយទ្រង់ចាប់បន្ថែមជាអនុសាសនៈទៀតថា "ម្នាល

ទេវតា ចូរអ្នកប្រកាន់ដឿ៉ងថា មង្គលទាំង ៣៨ ប្រការ មានការមិនគប់រកបុគ្គលពាលជាដើម ជាមង្គលដ៏ឧត្តម" ។

ចំណែកទេវតានោះ លុះបានស្តាប់មង្គលទាំង ៣៨ ប្រការនោះហើយ ក៏មានចិត្តរីករាយ ហើយក្រាបថ្វាយបង្គំលាព្រះគតវន្តមុនី ក៏ជាត់អំពីទីនោះទៅ ។

លុះដល់ថ្ងៃជាគំរប់ពីរ ព្រះគតវន្តមុនី ទ្រង់ត្រាស់ហៅអានន្តរមក ហើយទ្រង់សំដែងប្រាប់ព្រះអានន្ទ ទូរមង្គលទាំង ៣៨ ប្រការ ដែលព្រះអង្គបានសំដែងប្រាប់ទេវតារួចហើយ ដើម្បីឱ្យព្រះអានន្ទរត្តរៀនឱ្យបានចេះចាំ ហើយយកទៅសំដែងប្រាប់ពួកពុទ្ធបរិស័ទ គឺភិក្ខុ ភិក្ខុនី ឧបាសក ឧបាសិកា សិក្ខាតទៅទៀត ។

ចំណែកព្រះអានន្ទរត្តរ៍ ក៏បានទទួលព្រះបរមពុទ្ធាដំកល់លើសិរសា ។ ចាប់តាំងពីពេលនោះមក មនុស្ស ទេវតា ទឹង ព្រហ្មទាំងឡាយ ក៏បានយល់ជាក់ច្បាស់ លែងសង្ស័យចំពោះមង្គលទាំងឡាយ លែងឈាស់ខែនខ្វែងគំនិតគ្នា ដោយសារមង្គលកថា ដែលព្រះគតវន្តមុនី ទ្រង់បានសំដែងមក ដោយប្រការដូច្នេះឯង ។

ខ្លែកអគារប្រសាស្ត្រ

កំប្លែកតាមរឿងមិត្តភាពរវាងមាតាបិតា

ជារឿងព្រេងជប៉ុន

អ្នកស្រី អ៊ុប-សុន ប្រែពីសៀវភៅរឿងព្រេងជប៉ុន

មានបុរសម្នាក់ឈ្មោះ កុម៉ាត់ស៊ុ-សុំដិ (KomatzuSeitchi) តែងថ្នាក់ថ្នមគោរពប្រណិប័តន៍ចំពោះមាតាបិតាជាប់ជានិច្ច តាំងពីកុមារភាពមក ។

បុរសនោះប្រុងប្រយ័ត្ន មិនធ្វើការឲ្យមាតាបិតាកើតទុក្ខបន្តិចសោះ ។ មាតាបិតាបង្គាប់បញ្ជាអ្វី គាត់តែងទទួលធ្វើតាមបង្គាប់គ្មានប្រកែក, ទំធ្វើបំពេញបំណងមាតាបិតា ជួយធ្វើការសេពសារពើនៅក្នុងគ្រួសារជួយធ្វើម្ហូបអាហារម្តាយ ទំនងជួយធ្វើតិចផ្សេងៗ នៅក្នុងផ្ទះ ដោយប្រើចរិយាសូតបូត ។

គេឃើញកុម៉ាត់ស៊ុ-សុំដិនៅទិញត្រី, ទិញទំតាំងសំពាប់ធ្វើម្ហូបក្នុងគ្រួសារឃើញផ្ទុំភ្នើងចន្ត្រោនដែលកំដៅមន្ទប់, ឃើញដុតញើសឲ្យឥតុកនៅក្នុងមន្ទប់ទឹក ដូចគាលគេឃើញគាត់ស្តាបៃប្អូនប្រុស ឬប្អូនស្រីនៅទ្នងតាមទំនៀមស្រុក ខាំយកនៅដើរលេង ។

កុម៉ាត់ស៊ុ-សុំដិ លុះបំរើនៅយ៉ាងធំឡើងបាន៖ឃើញបញ្ជាស់ខ្លួនកិច្ចដែលមាតាបិតាបានទំនុកបំរុងគាត់ តាំងតាំងក្មេងមក ឲ្យតាំនៅក្នុងដីវភាពដ៏ប្រពៃ ។ តែគាត់ភ្លៅដោះម្តាយរហូតអាយុ ៣ ខ្ចាំ ។ ឥតុកគាត់តិតមែនតែមានធនធានតិចតួចក៏តាំងចិត្តបម្រើដែលជាស្នូនកូនគ្រប់ គ្រាន់តាមបំណងដូចជាទៃ្វន, ឈើភ្លៀវ, មុខ ទំនងបន្តែងមួយ ផ្ញើតំក្រងាសក្រាស់ដែលគាត់រក្សាទុកដូចកំណប់មួយយ៉ាងវិសេស តាំងពីយូរណាស់មកហើយ ។

ចំពោះទុបការគុណមាតាបិតាបែបនោះ កុមារ៉ាត់ស៊ុ-សុជិ កំណត់ពុកកន្ទឹងចិត្តថា ដូចជាបំណុលដែលគាត់មិនអាចសងវិញបាន ។

កុមារ៉ាត់ស៊ុ.សុជិ កាលនៅកន្ទឹងតុណាយ គាត់ជាប់ចិត្តខ្លាំងដោយការអានសៀវភៅដំបូន្មានចិន ដែលគេយកមកបង្រៀននៅដំបន់ខ្លះ ។ ក្នុងប្រទេសជប៉ុន ។ អ្នកនិពន្ធសៀវភៅនោះបានពោលការណ៍ អំពីចរិយាទឹងកាយវិការផ្សេង ។ ដែលបុត្រគាំនឹងត្រូវតែប្រតិបត្តិចំពោះមាតាបិតា ។

គេនិយាយថា:

"ធម្មតាកូនមិនត្រូវស្ដោះទឹកមាត់, ស្ទាប, ក្អក, កណ្ដាសនៅទឹងមុខឪពុកម្ដាយទេ ត្រូវមើលមុខឪពុកម្ដាយ តែកុំសម្លឹងជាប់ បើគាត់រមាស់ត្រង់ណា ។ ត្រូវអេះជូនគាត់ ហើយត្រូវពេញចិត្តនឹងបរិភោគម្ហូបចំណីដែលសល់អំពីមាតាបិតា" ។

ចំណែកកុមារ៉ាត់ស៊ុ-សុជិ ក៏ចូលចិត្តតែនឹងគំរូនៃកតញ្ញូធម៌នេះដែលជាជ័យដោគសម្រាប់បណ្ដាជន នៅបូព៌ាប្រទេស ។

គេពោលថា:

"មានឃ្មុំដងម្នាក់ ក្នុងសាច់នៅខ្វិលក់ ស៊ូប្លុងទេខ្លួលពានដំណេកគ្មានមុនីនៅពេលយប់ ដើម្បីឱ្យម្ចាស់គាំងអស់នៅកន្ទឹងផ្ទះមកពេមដញ្ជក់ឈាមខ្លួន ឱ្យតែឪពុកម្ដាយខ្លួនសុខគ្មានជាសុខ" ។

មានបុរសម្នាក់ទៀត មានឈ្មោះកុតស្ងោតពិសាត្រី ។ គាប់ជួនដល់រដូវត្រជាក់ ទឹកបឹងប្លឹគាំនឹងឡាយ កកខៅជាទឹកកកអស់ មច្ឆានានាក៏មិនបញ្ចេញខ្លួន ឱ្យអ្នកនេសាទចាប់យកខៅបរិភោគបានទេ ។ ម្ដាយក្មេកបុរសនោះ ក៏គ្មានត្រីពីសាដូចអ្នកផងគាំងពួង បុរសនោះដោះ

សំលៀកបំពាក់ ចេញទៅដេកសន្ធឹងនៅលើផែនទឹកកក, ចំហាយត្តៅ ចេញពីខ្លួនបុរសនោះ ធ្វើឲ្យរលាយទឹកកកតើតទៅជាទឹកវិញ ។ណៈនោះ មច្ចានាគក៏មកដកដង្ហើមនៅទឹងទឹក ជិតបុរសនោះ ឯបុរសនោះក៏ចាប់បានត្រីយកទៅជូនម្ចាយក្មេកពីសា ។

កុមារតស៊ុសុំដ ចូលចិត្តជាខ្លាំងបំផុតនូវរឿងព្រេងចិនម្នាក់ដែលដំណាលអំពីយុវតីម្នាក់ ។ យុវតីនោះ ជាបុត្រីរបស់នាហ៊ីនម្នាក់ឈ្មោះ តួអេន-យឺ ។ ព្រះចៅអធិរាជប្រទេសចិន បានទ្រង់ចាត់ឲ្យនាហ៊ីនោះបង្គាប់ ឲ្យជាងធ្វើជង្ហឹមួយ ឲ្យមានសម្ងួតឮសូរទៅឆ្ងាយបាន ។ ឯកញ្ញាដែលជាបុត្រីនៃនាហ៊ីនោះ តំបង្គាប់ឲ្យជាងចំណាន ។ ជាប្រើនមកធ្វើជង្ហឹ, ជាងទាំងឡាយលាយមាសជាមួយស្ពាន់ ដើម្បីឲ្យជង្ហឹមានសំណូរជូន ហើយឲ្យលាយប្រាក់ផង ដើម្បីឲ្យឮសូរឆាំ ប៉ុន្តែនៅតែគ្មានបានលទ្ធផលឡើយ គឺជង្ហឹមិនបានឮសំណូរ ដូចព្រះពន្ធបំណងព្រះចៅអធិរាជ ប្រទេសចិនសោះ ។ ក៏ឯនាហ៊ីនជាឪពុកនាងកញ្ញានោះ បានទទួលព្រះពន្ធបញ្ជាពីព្រះចៅផែនដីម្ដងទៀតថា បើលើកទី ៣ នេះ នៅតែមិនបានលទ្ធផលអំពីការសិតជង្ហឹនោះទេ នាម៉ឺននោះ ទឹងត្រូវគេដាក់ទណ្ឌកម្មដល់ទៅគេកាប់ក្បាលចោល ។ កញ្ញាដែលគួរឲ្យគោរពនេះ កាលបានដំណឹងដូច្នោះ ក៏លួចលាក់គ្រឿងអាភរណៈរបស់នាង ដើម្បីទិងយកប្រាក់ទៅកត្រូហោ. ពាសាស្ត្រាយអំពីការសិតជង្ហឹ ។ ឯត្រូហោពាសាស្ត្រ ក៏ទាញក្បួនឡាតមកទាយតាមឫក្ស ជាតាកស៊ី ហើយក៏ទ្លើយប្រាប់នាងកញ្ញានោះថា "ម្នាលនាង! មាស, ប្រាក់, ស្ពាន់ ទឹងមិនរលាយបូលគ្នាទេ បើគ្មាន

សាច់របស់ស្រីក្មេងរលោយចូលទៅខ្លួនជាវ ជាមួយរលោហធាតុនោះ ឬបើគ្មានលោហិត របស់ស្ត្រីព្រហ្មចារី ហូរចូលលោយទៅខ្លួនលោហធាតុដែលរលោយទៅហើយនោះ" ។

ហេតុនេះ នៅវគ្គទី ៣ នាងកញ្ញានោះ ឮនិយាយដូច្នេះថា នាងចង់ទៅទស្សនាការបិតដួងផ្កាលើភ្នែកនាងម្ខាង, ឪពុកក៏ព្រមឲ្យនាងទៅ។ នៅពេលដែលគេកំពុងរលាយលោហធាតុ នាងក៏លោតចូលទៅក្នុងខ្លួនជាវដែលគេរលាយ ហើយបន្ទឺសម្ងួនថា "លោកឪពុក! នេះជាសេចក្តីស្នេហានៃខ្ញុំចំពោះលោកឪពុក!" ។ លើកនេះ ដួងក៏ឮឮបបួរឆ្ងាយពេក ទ្រង់ទ្រាយកំសត សម្បុរក៏ល្អ សំលេងឮបបួរល្អដួងដែរ ប៉ុន្តែដួងកាលគេឮបបួរសម្ងួន ដំបូង, ថ្ងូរ, យំអណ្តឹតអណ្តកម្ងន់។ ។

កុម៉ាត់ស៊ុ-សុជិ ពេញចិត្តនឹងរឿងត្រង់ចំនោះណាស់ គាត់ចង់តាំងខ្លួនជាវីរបុរសខុតតែដួចជាដនតាំងនោះណាស់ដែរ ។ គាត់សប្បាយយ៉ាងណាទៅ បើគាត់អាចតាំងខ្លួនធ្វើជាតំរូតញ្ញាធម៌បាន ? ប៉ុន្តែអាយុគាត់កាន់តែលឿនទៅមុខ ដោយគ្មានឱកាសឲ្យគាត់តាំងខ្លួនជាវីរបុរសដូចគេបាននោះ . . . ។

មកដល់អាយុ ៧៥ ឆ្នាំហើយ កុម៉ាត់ស៊ុ-សុជិនៅតែមិនពន់បានបំពេញការណ៍ដាពន្ធឺ ដែលលើកគាត់ដំកល់ក្នុងចំណោមវីរបុរសនានា ដែលជាទីគោតសរសើរបស់គាត់ ប៉ុន្តែគាត់សប្បាយចិត្តខ្លាំង ដោយឪពុកម្តាយគាត់ដែលមានអាយុប្រហែលជាង ១០០ ឆ្នាំ នៅមានជីវិតរស់នៅឡើយ ។

សោតឯយាយចាស់តាចាស់នោះ ពេលបើ កុម៉ាត់ស៊ុ-សុជិថ្លាត់ថ្នមបំរើ

យ៉ាងណាក៏ដោយ ក៏នៅតែព្រួយចិត្តទងដកវេរបស់គាត់ពុំបេះដាច់ ។

ពេលណាគាត់ទឹកដល់គាលដែលកន្ទុងមក គាត់បេះតែរសាយចិត្តនៅពេលនោះ, ពងវៀតគាត់អូនថយចុះទៅ, ទម្ងន់អន់ខ្លាយដកបេ, ឯកម្លាំងក៏រំខាសសូន្យឈឹង, ក្អែកមើលមិនច្បាស់, ត្រចៀកស្តាប់មិនសូវឮ ។ គាត់មិនហ៊ានធ្វេះកញ្ចក់មើលមុខគាត់ទេ ព្រោះមុខគាត់ត្រូបដណ្តប់ទៅដោយសែ្បកស្ងួតជ្រីវជ្រួញ ទងសម្បុរពណិពក្រក់ ។

គាត់មិនអាចអនុម័តការអ្វីម្យ៉ាង ។ ឬក៏បងគំនិតរបស់គាត់ទាំងពីរនាក់ ឬក៏រញ្ជួញភ្លាវា ចំណែចំអន់លេងសោះ, គាត់យល់ច្បាស់ថាគាត់បានមកដល់ច្រាំងនៃវិលចរិតហើយ .... ។

ឯកុមារ៉ាត់ស៊ុ.សុជិ កងច ជាតែគាត់ៗ គិតតែធ្វើយ៉ាងណាឲ្យមាតាបិតាបានរសាយខ្វល់ចេញ សូម្បីជាខ្វល់បន្តិចបន្តួចក៏ដោយ ប៉ុន្តែមិនដឹងជាធ្វើយ៉ាងដូចម្តេចទើបបំបាត់ខ្វល់ជារខោះ អំពីឪពុកម្តាយគាត់បាន ។ គាត់ទំរកឧបាយកលដែលបំបាត់ខ្វល់នោះ លុះដល់ថ្ងៃមួយគាត់ក៏រកឃើញឧបាយមួយ អ្នកភាំងពួងដឿថា គាត់រកឃើញឧបាយកលនោះមែន ។

គេឃើញគាត់ចូលទៅក្នុងហាងទំនិញ ដែលលក់សុទ្ធតែសែ្បងកូនក្មេង គាត់ទាទិញស្ករមួយ ទិញសឺមួយនឹងរូបខន្ធ្រយធ្វើពីក្រដាសក្រាស់មួយ ហើយទិញតឺមូណូមួយភាណាស៊ីដូម តឺមូណូជាអាវែងមួយដៃធំ ។ ដែលពួកបុរសស្ត្រីដប៉ុន ពាក់ខ្លួនជាអាវជាតិ តាមធម្មតាអាវតឺមូណូប្រើនមានភាណាស្រគត់ស្រគំ ប៉ុន្តែប្រើនតែពួកក្មេង ។ ដែលពាក់ពណិធើត ។

កុមារ៉ាត់ស៊ុ.សុជិ ដោតឫស្សី ១ ដើមវែងនៅមុខផ្ទះ គាត់យកបំប៉ត្រី ១

ធ្វើអំពីក្រដាសភ្លឺផ្សេងៗ យកមកបង់នៅពុងប្រុស្ស៊ី ឲ្យបក់ចោយតាមខ្យល់ ។ ព្រោះនៅប្រទេសជប៉ុន ក្នុងថ្ងៃបុណ្យដែលគេហៅថា "បុណ្យក្មេងប្រុស" ឪពុកម្តាយតាំងខ្សាយតែងយកបូតក្រឹមកបង់នៅពុងប្រុស្ស៊ី តិចឬច្រើនតាមចំនួនកូនប្រុសរបស់គេ ដែលមានអាយុតិចជាង ៧ ឆ្នាំ ។

តាមសញ្ញានេះ គេសន្មត់ទុកជាពរជ័យសាធុការ ១ យ៉ាង ដែលគេផ្សាយដល់កូនក្មេង ដែលទើងអាចចំរើនវ័យទៅមុខបាន ទោះបីមានទុបសគ្គយ៉ាងណា ។ ប្រៀបដូចជាត្រីដែលអាចបួលទៅក្នុងស្ទឹងបាន ទោះបីមានទឹកហូរយ៉ាងណាក៏ដោយ ។

មាតាបិតាកុមារ៉ាត់សុសិដ កាលបើបានឃើញដើមប្រុស្ស៊ី ដោតនៅខាងមុខផ្ទះ ហើយមានបង់រូបត្រីនៅខាងពុងផង ក៏ទឹកចិត្តល់ខ្លាំងណាស់ ។ ហើយគាត់ស្រឡាំងកាំងរីករាយខ្លាំងទៅទៀត កាលបើបានឃើញកូនប្រុសគាត់(ទោះបីអាយុ ៧៨ ឆ្នាំហើយ) ពាក់អាវតីម្ហូតណាស៊ីដម្ពូជាអាវដែលគេសម្រាប់ពាក់ឲ្យកូនក្មេង ហើយវារនៅទីធំដ ដូចជាពាក់ទើបទឹងចេះវារហាមាត់ធ្វើបបិតបបុក លេងជាមួយទីធំស្អាមួយហើយទីធំរូបខ្លាយធ្វើពីក្រដាសមួយ ។

កុមារ៉ាត់សុ-សុិដ បង្កើតសែ្នងដូច្នេះ ដើម្បីធ្វើឲ្យឪពុកម្តាយដឹងថាគាត់មិនមានចាស់ណាស់ទេ ដោយគាត់មានកូននៅក្មេងនៅឡើយ ។

តួកកម្មបុិនប៉ាវនេះ ទុកកុមារ៉ាត់សុ-សុិដ ស្មើដូចជាវីរបុរសដែលជាគំរូនៃកតញ្ញូធម្មមួយដែរ ។

ចប់

ពាក្យភាព្យ

លោកអម្ចូតក្សត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះចាវសម្តេចព្រះនរោត្តម

លោក ញ៉ុក-ថៃម ពិធីត្យ

(តមក)

មន្ត្រីតូចធំ ក្រាបថ្វាយបង្គំ លាវិលវែងទៅ យកួយានឯងអង្គុ ចូលកន្លែងត្រៃត្រៀ ដល់ត្រៃលំទៅ យកដំបងបាន ។ រំពឹងគិតថា រីកដ-អស្សពាហ៍ កំឡាំងហាវហាន មួយរយៈយោជន៍យល់ ទៅដល់ម្ល៉ៃបាន ឥឡូវប្រមាណ បានប្រាំរៃគត់ ។ គួរនិម្មិតខ្លួន ឲ្យខ្ពស់មែនមួន លើសនឹងកំណាត់ ទើបនឹងឈោងឈាន បាច់បានប្រាកដ អញធីឲ្យ ហ្មាត់ កុំឲ្យរួចរស់ ។ ស្រេចហោះទៅឆ្ងាយ និម្មិតប្រែកាយ ជាធំខ្ពង់ ខ្ពស់ កាលយកទុជិន ប្រែមុខបង្គស់ ប្រមាណកំពស់ ៧ ជួរត្នោតលៃ។ ចាំងនឹងឈើផង ហើយយកួយង់ឃ្លង ទៅនិម្មិតដៃ ទំយោងជួន ដល់ជួនត្នោតលៃ មើលមិនឃើញនៃ ព្រះពន្ធកុមារ ។ ហើយយកួនិម្មិត ប្រាំពីរដងពិត ខ្ពស់ក្រៃមហិមា ត្រដែតមើលទៅ ត្រូវនៃពហុត្តា-ឡីសខ្សែនយក្ស មើលមិនឃើញស្មោះ ។ ស្ងាញស្ទុះទៅឈរ ឈានឈប់លើប - ពិតមួយឯងនោះ កំពស់គណនា ឯការយោជន៍ស្មោះ មើលឃើញកួហោះ តាមទៅដោយរំខ្ញែ ។ ដោយតេជក្រុងយក្ខ ពារ កំឡាយភ្លាត់ ភ្លាត់ឡាយណ្តាលដ្ឋិត ដូចខ្សែលំយុគ — ខ្លាតខ្លាំងត្តិត

ឈើព្រៃខៀចដិត ខោខន់ញ៉ែរញែក ។ ម្រឹគសង្ហ្គសីហ៍ ខ្លោងខ្លាដំរី រមាសស្រៀវស្រែក តិតកំយរន្ធត់ រួតរត់ចោលចែក គូកនជ្រៀតជ្រែក ជ្រែកដោយព្រឹក្សព្រៃ ។

សេះឆ្មស័ព្ទយក្ខ បៀនចែវមើលជាក់ ឃាល់ដិតពេកព្រៃ ខះខំ ប្រឹងស្រូត រួតរត់មួយថ្ងៃ ខោះទៅឆ្ងាយព្រៃ ច្រាំយោជន៍(១)មហិមា ។ កុមារតិតកំយ ឃាល់យក្ខដិតព្រៃ ច្រាយច្រាប់សេះថា យក្ខមកពន់ហើយ សេះឆ្លើយវិលថា ម្ចាស់អើយខ្ញុំហា អស់កំឡាំងព្រៃ ។ បួរម្ចាស់ទៅពួន ពឹងភាក់លាក់ខ្លួន នៅក្នុងព្រឹក្សព្រៃ សម្ងាត់សម្ងំ សូវខ្ញុំក្សិណក្សយ ឲ្យអម្ចាស់ថ្ងៃ វស់រួចជន្មា ។ កុមារថ្លាថ្ងៃ ចុះចោតមនោ ម័យ ចាប់ហត្ថអនុជា ចូលពួនអាស្រ័យ នៅព្រៃព្រឹក្សា សេះរត់ម្ដងម្កា ហើយ អធិដ្ឋាន ។ នូវហេតុសម្ភារ សូមអស់ទេវតា សោឡសតិមាន ទេព ពាំងកពព្រៃ ប្រណីជ្រោសជ្រាណ ឲ្យម្ចាស់ខ្ញុំជាន តង់ព្រះជន្មា ។ ហេតុពាក្យពោលពិត ហើយទេពនិម្មិត រន្ធនៅរុក្ខា ឲ្យពោធិវរ្ឆ ខ្ទម អង្គុតនុជា ចូលស្រែចខេត្តា និម្មិតច្បាំនិមិ្ត ។ ពុកវន្ទមួយតូច ឲ្យលំ ចេញចូលរួច ហើយទើចនិម្មិត ជាពីរពាន់ពាស ព័ទ្ធដោយរន្ធដិត មៀនមើលយល់ឥត មានមនុស្សនិត្យនៅ ។

យក្ខហោះតាមសេះ សេះរត់បង្វែះ បង្វិលរងោះទៅ ឲ្យឆ្លុះយពីទី ក្សិត្រពីរួនទៅ យក្ខយន់យោរយៅ តាមពាន់អស្សពាហ៍ ។

១-ធ្លាងាប្រាំរយយោជន៍មហិមា ។ តែលើសពាក្យច្រូន ដាសេចក្ដីប្រែរអាមទំនួរព្រោះតាមធម្មតា បរសេះ ១ ថ្ងៃ១០០យោជន៍ បើមានភ័យ ត្រូវបង្កើនល្បឿនលើសឯណា សេះអាចរត់បាន ដល់៥០០យោជន៍ ។

ស្ទុះលោតទៅចាប់ សេះគេចក្រឡាប់ ក្រឡាស់យកកួយ ដំបងទៅ
ពុំត្រូវអាជ - នេយ្យនោះយកក្លា គ្រាចពន់ប្រមាណ ។ ស្ទុះ
លោតទៅចាប់ ជាន់កន្ទុយខ្លាប់ គាន់ក្បាលអស្សយាន ឆ្លើយផ្តន្ទា
ថាអាជ្ញាប់មាន ពុតតួតអាចហ៊ាន រួតរត់យាត្រា ។ អញឆើក្បាលទៅ
ទុកខ្នងអាទៅ អសោចអសារ ក្នុងព្រៃសាន្តគ្រោះ សូន្យសោះអសារ
ចំណីអាហារ ស្ងាតស្អែកដោយព្រៃ ។ ស៊ីស្រេចយកកូមក ឈ្លោកវេរកេ
កុមារតែម្តង សព្វគ្រោមមណ្ឌល គៀនគល់ព្រៃវែង ទីបំពួនទៃ រត្ន-
ពជកុមារ ។ វៃវេរវេរិល ពុំឃល់ហើយខ្លិល យកកូស្រដីថា អញឆើ
សេះក្រែង ប្រលែយដន្ទា ក៏ទឹងទៅណា មានតែក្បាណក្បែយ ។

គិតស្រេចហោះទៅ ដល់ទីលំទៅ ចាប់សត្វដោយព្រៃ ចរិកោត
ស្អប់ស្អប់ ត្រង់ប្រាំពីរថ្ងៃ ក្រឡាប់វិលវៃ ចូលកាន់សីមា ។ បក្ខោត
មន្ត្រី មេទំសាវស្រី នូវនានីមលា បុត្រយើងពីរពាស់ ចិត្តចង់ប្រា-
ថ្នា រឿនសិលាស្រស់ស្អាត គាចឲ្យចេះស្ងាត់ ។ អង្វរតែទៅទៅ សូមសំណាក់
ទៅ ឥសីស៊ីវសុទ្ធ ជាន់ជាមិនណា គិតថាក្រែងឃាត់ រឿនរួចស្រេច
ថ្ងាត់ មកកាន់ឋានបិត ។ ខានឆ្ងាច្បោះហើយ គ្រាន់ស្រាកគ្រាន់ស្បើយ
មិនប្លែកនៃនិត ពេកតន់ដន្ត្រី សេនីត្រាហ្មណ៍ព្រឹទ្ធ ស្រេះនៃស្មានពិត
សឹងពុំសង្ស័យ ។

ទំនៃនេះ យើងលើកខុតស្ទុះ ថ្លែងឆ្ងាទេព្តា រឹងរឹទ្ធិសិទ្ធិសក្តិ
ដែលណាក់ក្នុងវេរ គ្រោយក្រុងយក្ស ត្រឡប់វិលវៃ ។ អស់ពាំង

ខេត្តា បើកពាជកុមារ ឲ្យស្តេចចរចេញ និម្មិតកោជនា អាហារពោរ
ពេញ គាំងភាជន៍មាសមិញ ថ្វាត់ថ្វាយកុមារ ។ តុំឲ្យយល់អង្គ កុមារ
សោតទ្រង់ សោយអស់អាហារ ព្រះកក្តស្រស់ស្រិល ដោយរសទុជា
ពិសេសពិសា ពីសួគ៌ពីសុទ្ធ ។ ស្តេចសោយស្កប់ស្កល់ រកសេះតុំយល់
ពន្ធកពង្សពុទ្ធ គន់គិតអស្សពាហ៍ កាយាខ្ញុត់ ទុបង៌រូតរត់ ទៅទី
ហានណា ។ ឃើញវិលទៅហើយ បង៌អើយម្តេចឡើយ តុំវិលយាត្រា
ត្រឡប់វិលមក រួសរកអ្នកភ្លា ថ្មមួយយក្ខរ៉ា សម្ងាប់បង៌ក្រឡេ ។ តោធិ-
សម្ភារ នាំព្រះអនុជា ចេញចាកដើមព្រៃ លីលាទៅតាម ស្នាមដើង
នោះនៃ កន្ទេង៌មនោម័យ ដរង្ហើយហាហៅ ។ ទុបង៌មានគុណ គុណ
តាម់មហាធន់ ធ្ងន់ហើយជ្រាលជ្រៅ នាំយើង៌ទាំង៌ពីរ ចេញពីលំនៅ
ដើរដោយព្រៃជ្រៅ តែបីអង្គា ។ បង៌អើយសត្វថ្លៃ តែង៌បានអាស្រ័យ
ពឹង៌ភាក់ផាតិជា តំណាក់តំនឹង តិតកឹង៌កាល់ត្រា ប្រសើរថ្លៃថ្លា ជាតិជា
ដើង៌បង ។ បើបង៌ក្សិណក្សយ ជីវិតប្រល័យ កង៌ព្រឹក្សាតរ ដូចជាអ្នកកាត់
ចាខហត្ថមែនមរណ៍ កង៌ព្រឹក្សាតរ អង្គឥតដើង៌ដើរ សត្វថ្លៃយើង៌មាន
ខ្លួរពង៌រូបច្រាណ អង្គឥតអំពើ ឬជន្មជីវិត ពីរពិតបើង៌ផ្ទៃ ផ្តួកផ្តាក់
ខុកលើ នៃរូបពង៌បង ។ រិះរត់យាត្រា ចោលព្រះមាតា មេនំស្នំផង
ចោលច្រុង៌ច្រាសាទ ស្ថាង៌ស្ថាតឥតហ្មង ឥតហេតុមកវង៌ ខុកខ្ញុំទោ-
មនស្សា ។ ព្រោះហេតុគំនិត បំណាច់បង៌តិត នាំយើង៌យាត្រា ឥឡូវ
នេះបង ម្តេចម្តង៌ហ្មាតហ្មា ចោលយើង៌ខ្ញុំកា-សារសោះសូន្យនៅ ។
ឬបង៌ស្ងួះស្ងែង រូតរត់រង្គែង កណ្តាលព្រៃជ្រៅ ថ្មមួយយក្ខរ៉ា មោហា

យោរយៅ ចិត្តចោរកម្ចៅ សម្ងាប់បងធំ ។ សែនស្តាយសោកដោយ
ព្រៃព្រឹក្សជង្រោយ ហៅពាជការជី ស្រយោកស្រយុត រន្ធត់ឥន្ទ្រិយ អ័ព្ទអន់
ធ្មឺ ដោយទ្រង់ត្រូវក្តៅ ។ ឈប់ដោយមួយឈើ ពុំសូវខំដើរ ព្រោះ
ព្រះចមរចៅ អាសូរព្រះអង្គ ស្រីស្នងការលៅ ដ្បិតក្មេងណាស់នៅ
រោមជាង ។ លន្ទធំលន្ទោច ស្រេងស្រេងស្រោច ស្រង្គតកន្ត្រាក ខ្លួញ
ទៅនគរ ព្រះវរមាតា ឱកូនឃ្លាតឃ្លា ព្រះមេថ្លាថ្លៃ ។ សង្ឃឹមអស្ស-
ពាហ៍ ស្មើព្រះមាតា ជាជើងសត្វថ្លៃ ឥរ្យាវប្រក្រាស ឱពាសមនោ-
ម័យ ទៅដី ។ ថៃ ពុំមួលមួយគ្នា ។ បើបានសេះទៅ នោះយើងបាន
ទៅ យន់យល់កន្ត្រាក ព្រះមេថ្លាថ្លៃ ដូចគ្តីច្រាថ្នា បរិបូណ៌ច្រោស
ច្រា កដពុំឃ្លៃឆ្ងាត ។

ឱព្រះមាតា ប្រសិនអស្សពាហ៍ ស្បែណាស្រយជន្មជាត ពិតពីរយើង
ខ្ញុំ ស្មើកំបុតបាន ខឹងអស់ជន្មជាត ជីវិតនេះនៅ ។ ចោលពងរួបកាយ
នៅក្នុងព្រៃអាយ អសោចអសៅ អសារមិនខាន មិនបានវិលទៅ
តាន់រឹលំនៅ យល់ព្រះកន្ត្រាក ។ ទុកម្នាក់ម្ល៉ោះ ទ្រង់អើយស្មើរប្រែះ
តិចាកវនា ឱ្យតែគ្រាន់ក្រោក ចោលចាកមាតា កម្មអ្វីបងឃ្លា បង-
ឃ្លាតនេះផង ។ ឥរ្យាវខឹងចរ លិលវិនគរ ប្តូរនាយហោង ពុំដឹង
ទីឋាន ដើមដានគន្ធង ទុកគ្នាអញ្ជាម្តង ណោះរង់វនា ។
ឱអ្នកប្រសើរ អ្នកពុំដែលដើរ ដោយដងអង្គ ដើងជាន់ក្រួសក្តៅ សម
ទៅរកា រកាមជាតា ឧត្តមជាជាំ ។ ត្រាលឹងបងអើយ ម្តងណោះ
ឯងហើយ ហៅវរកម្ម ចិត្តអង្គឯង ពីត្រង់ចងចាំ បងជាប់នានាំ

ឲ្យរងវេទនា ។ ឥឡូវពុទ្ធប្រសើរ សោយសោកបណ្តើរ ព្រះប្អូនស្នេហា
ទៅតាមដោយដាន អស្សយានយាត្រា ខន់ ។ សូរ្យា រសៀលល្ងាចថ្ងៃ ។
ស្តេចយាងទៅដល់ មៀនមើលឃង់យល់ រត្នាដមនោម័យ កំបុត្រក្បាល
ទៅ ដេកនៅក្បែរណាក្រយ៉ែ ស្មើគ្នាក់ថ្នែមថ្ងៃ ដីតជន្មមណា ។ ស្តេចតបសេះសោក សែនសោយអនោមក្ស តាំងពីអង្គា ដាលដល់សន្ធប់
សូន្យសតូសរោ បងីបាត់ព្រះស្មារ - តីដោយសោកសល់ ។

ហេតុបុណ្យពន្យោ- ជីសត្វពោធិ វិសេសថ្លៃនឹកល់ បណ្តាលតើតក្តៅ ក្តួចទៅដួចដល់ មណ្ឌលកម្ពុល អាសនាឥន្ទ្រា ។ ស្តេចបើកសហស្ស-ន័យន៍នេត្រយល់ប្បាស់ ចុះមកម៉្លេះ យកទឹកពិតុលុប សាយសតូមង្គា ព្រះពាជកុមារ តាំងពីរបួរត្ន ។ ភ្ញាក្ញាក់ស្មោះស្មារ - តីដឹងតាយាក្រួញក្រាមប្រណិប័ត្ន ខៀបជាខតន្ត្តីឥន្ទ្រ ខេរិន្ទ្រចក្រវត្តិ ព្រះសូរមហាសតូ
បើកបន្ទូលថា ។ ម៉ៃអ្នកពីរភ្ញាណ អ្នកមកអ្នកមាន បើទៅឋានណា
ព្រោះប្រការកិច្ច ជួចប្តេចឋានដា អ្នកចរយោត្រា ត្រាត់ថ្ងៃសាន៍ ។
កុមារស្តែងស្តាប់ ពូលថ្ងែនថ្ងៃ ឱប្រាប់ តាមពាក្យពាដ ដើមដានសុះសតូ
ក្រាន់គ្រប់តិតតី រឿងយក្សាស៊ី ស.ម្តេចបិតា ។ ហេតុនោះសោតសេះ
នានាំបង្វែះ បង្វែនយាត្រា ចោលព្រះនគរ ចោលវិមាត ទៅនឹងយក្ស
សាមាន្យពុនិន ។ អស្សានាំ មកដល់ខែប្រាំ យកតួមកតាមពាន់ ខ្ញុំនឹង
ប្អូនស្នេ លាក់ខ្លួនកន្លែន ព្រៃដ្ឋានវស់ដន្ធ ដោយទេពករុណា ។ សេះរត់
មកបាត់ យកតួតាមមកកាត់ យកតែសរសោ ស៊ីប្តូមិនដឹង ខ្ញុំនឹងអនុជា
បើតតអស្សា សមស្ងាប់នោះនេះ ។ ព្រះឥន្ទ្រធ្លាស់ឆ្លើយ ថាហៃចៅអើយ

កុំចៅតិតរិះ តិតព័យក្រែងខ្លាច តាអាចប្រសប់សេះ ប្រសើរជំនិះ ជាចំ
ណាប់ឱ្យ ។ ចូរកុំសោយសោក ចៅដើរចៅវក សិរសោសេះដោយ ព្រៃ
ព្រឹក្សឈូឆគ ត្រោះក្រែកក្រែងត្រាយ យល់យកមកឱ្យ អញស្លាប់ឱ្យថ្លា ។
កុមារទ្វាស់ឆ្លើយ ថាបពិតអើយ រឹស្សាលអស្សពាហ៍ យកមួយនឹងយោ-
ធៅ យកទៅកោតា ខ្ញុំក្មេងណា ក៏ខ្លាចបាន ។ ព្រះឥន្ទ្រឆ្លើយថា
បើឮយ៉ាងចូរបា្ត ទៅចុះក្រែងមាន សត្វណាទើបក្រើយ កុំបីបាច់បាន សិរសោ
អស្សយាន សិនចាន់ដួចគ្នា ។

កុមារអែតខ្លែ ព្រាកកាន់ខ្លែន ចេះចេះយោគ្រា ដោយព្រៃ
ហោមវង្គ ហេតុបុណ្យសម្ភារ យល់ពរស័ព្ទ ឈ្មោលមួយទើមស្ទាប់ ។
គាត់កគាន់យក ក្បាលលៃរើមក ដល់ដួចបង្គាប់ ព្រះឥន្ទ្រស្តេចស្រួល
ខ្លួលមកភ្លាប់ ខ្លីឆ៍សេះប្រែចស្រាប់ ស្រែចស្រាចរឹកទៅ ។ សេះមាន
ជីវិត ប្រែប្រួកកវរខ្លី ហើយប្រែកមខ្លួ ពាណាគំ ខ្លោះខ្លាំងក្លាហៅ
ហានហើយខឹងទៅ ដោយកកាសបាន ។ (កែវភាដី រុនរឿនរិទ្ធ
អនឹកេចក្សាកាន ខ្លួនដារលួតាប៉ា សិរសោប្រគាន ជាសីហ៍សឹងមាន(១)
ខ្លួរត្រឿនត្នែកាយ ។ រីក្រោតតេត្រ ប្រឹង្គវែកដាច់ ស្លឹតស្លោចខ្លាត់ខ្លួយ
កុមារបវរ ក្រែកអរពេកឃ ខ្លួនអង្គាត់ប្លែយ បង្គំឥន្ទ្រ ។ សម្តេចស.
ហស្សន័យន ទ្រង់ត្រាស់ថាចៅ ចូរអ្នកថ្លាថ្លា ដួចម្តេចចូរចៅ ថាទៅអញ

១-ក្នុងរឿងព្រះកាឝាភារៈថ្មី ដាច្រើនភារៈដាតំណាងនូវ តិណាសម្ផស្សភាពខ្លួន
ធ្វើបុះ សត្វរបស់ខ្លួនម្នា ស្មោះបឹងស្លុះស្លាប់ ខ្លួនដាអស្សពាហ៍សឹងសោ
សឹងហ៊ាប់ ដាសីហ៍ប្រាណាប់ ខ្លួរត្រឿងត្នែកាយ ។

ជាវ.នានិងឲ្យថា ឲ្យបានដូចចិត្ត ។ កុមារបង្គិ ខ្ញុលថាអញ្ជុំ សូមពរ
បពិត្រ បួនឲ្យព្រះអង្គ ស្តេចទ្រង់ប្រសិទ្ធិ ប្រសាទដូចចិត្ត ដូចជាបំណង ។

ពរមួយសូមមាន តេជតេជៈបាន ឈ្នះយក្ខទ្រើសឃ្នង ច្រាស-
ចង្រៃកេត ទុក្ខសោកតិយផង សុខដូចបំណង បំណាច់ច្រាថ្ម ។ មួយសូម
មានរិទ្ធ ឈ្នះបច្ចាមិត្រ តាំងទសទិសា មួយសូមសុខសម ដួចដុំមគា
បានសោយរាជា គ្រប់គ្រងបូរី ។ មួយសូមច្រាថ្ម ពោះបីមនុស្សណា សត្វ
សត្វផងក្តី ខឿនខើបទនិងជាប់ ខើបស្ងាប់ថ្ម ។ ខ្ញុំប្រសូមរ្យ ឲ្យបានរួចសេ ។

ព្រះតន្ត្រីធិទ្ធិ ស្តេងស្តេចប្រសិទ្ធិ ព្រះពរតាំងអស់ ដោយ
តេជអំណាច ឯងអាចរំសេ រំកេពុទ្ធស្ស ពុទ្ធឆ្ងាកេ ។ ស្រេចព្រះអង្គតន្ត្រ
ទីព្វខេតចក្តន្ត្រិយ៍ បរមសេដ្ឋោ ទ្រើសទ្រង់តុបះ លាព្រះពង្សគោ-
ធីសត្វទត្តមោ កាន់ត្រៃត្រឹង្ស ។

ខើបក្សត្រៃពង្ស លើលាឡើងតង់ លើអង្គអស្សពាហ៍
ហៀរហោះត្រដែត ឯលើស្មោអា រុងរឿងហាក់ដា សម្តេចគោសិយ៍ ។
លឿនត្រដែតដោយ អាកាសគន់តយ អស់អង្គថ្លាថ្លៃ អនុជស្នេហ៍ស្និទ្ធ
នៃបទិត្យចក្រី ឆព្វណ្ណរង្សី ភ្លឺផ្លេកត្រកាល ។ ទីអ្នកជួមជល់ វិសេស
ឃង់ឃល់ រុងរឿងវិសាល ទុក្ខសោកប៉ុន្មាន ត្រាន់បានជួរស្រាល
ស្រាកស្រន់ប្រយោល ពុំសូវសោកសៅ ។ វែងរំពឹងថា ទុព្រះមាតា
ស្តេងស្តេចទិត្យទៅ នៃបទិងក្រុងយក្ខ អបល័ក្ខណ៍រយារយៅ យោរទិង
ក្រៃក្រៅ ឃុត្តិធម្ម ។ ញ៉ាំងវាតិយោជ ព្រះមេព្រះមា.តាជលំមរណា ឯអ្នក
ប្រណិប័ត្តិ ត្រូវចិត្តយេក្ស យក្ខសោតមេត្តា តនិ៍ជន្មានៅ ។ ទុយក្ខវ-

គេច រិលទៅធ្លើម្តេច ជីនអើយប្អូនទៅ ពាលោមព្រះមេ ឲ្យស្លេសោកសៅ
ឋមួយពាក់ទៅ គំហែនដេរថា ។ ឧ:ទ្ធគ្គតិត អាបូរអាណិត ព្រះវរមាតា
មិនជ្រាបសូគាត បើជ្រាបយល់ជា ខ្ញីងមកមួយគ្នា ពុំបានខិត្យទៅ ។
ស្តេចតែងសោក តិតព្រះមាតា ទ្រូងត្រួតក្រំក្តៅ សេះហោះលុះយប់
ចូរឈប់ខិត្យទៅ ព្រឹកឡើងទៀតទៅ សព្វ ។ ចំព ។ យូរតិចទៅដល់
ឯកវដ្ឋមណ្ឌល មួយនោះនាមា ហែមន្ធនគរ បវរដ្ឋា គំពែងសីមា
ព័ទ្ធប្រាំពីរទ័ណ្ឌ ។ រចនាមណ្ឌប់ ប្រសើរសុះសព្វ គ្រប់ទ្វារដោយជាន់
មានប្រាន្តប្រាសាទ ស្អាងស្អាតសោភ័ន សុទ្ធសឹងសុវណ្ណ ខ្ទមណីតែផ្តៅ
។ ផ្ទះពស្ត្រមន្ត្រី ក្នុងពជបូរី សោតសឹងមានទៅ ដេរដោសសឹង
តន់ តាំងក្នងតាំងក្រៅ ពុំមានមនុស្សទៅ ដល់អន្ធឯកា ។ ក័ណ្ឌក្រក្ខន្ធ
ថ្កើងថ្កល់ តន់តិតឡាយធួល់ ក្នងព្រះចិន្តា ហើយស្តេចដណ្តើង ទៅខ្ញីង
សេះថា បងអើយខតរ នេះស្ងាត់អ្វីម្ល៉ះ ។ ធ្លើម្តេចខ្ញីងជីង
ខ្ញងឯដំណើង ដំណើរហេតុនេះ មនុស្សទៅឯណា ចានជាជួរច្នះច្នេះចូរបង
សេះ ខន្ធាបចុះទៅ ។ សេះខន្ធាបដល់ ប្រាសាទមណ្ឌល ប្រសើរឆ្លងផ្តៅ
កុមារពាំងខ្ញី ចុះពីសេះទៅ ចូលក្នងលំទៅ តន់ប្រាន្តប្រាសាទ ។
ស្លែងស្លីងធំធេង ក្អីផ្ទេកចិញ្ចៀង ចិញ្ចៀចស្អាងស្អាត កញ្ចក់កញ្ចាំង
តៀងតាំងព្រោងព្រាត ល្អស្អុះសុទ្ធសាត ទីទិព្វសកល ។ តែវកងក្រចក់
មាស សឹងទៅតេញតាស ខ្ពស់ពាំងមណ្ឌល ព្រំព្រុយព្រៃព្រម ចៀមចំ
ឡើយខ្ពស់ ប្រើនអនេកសល់ អនន្តមានទៅ ។ កុមារខតសព្វ ដោយ
កៀនបន្តប់ តាំងក្នងតាំងក្រៅ ពិតពុំយឺយល់ មនុស្សដល់ម្នាក់ទៅ

ហើយទ្រង់ត្រាស់ទៅ ទីឥតពាដីថា ។ បងអើយឆ្ងប់ពេក ឆ្ងល់ឃល់ ហៅថ្មក ក្នុងហទ័យា មាសថ្លែកន្ទូរអស់ ព្រះពាតស្ត្រា ខ្ទូរគ្រឿង ប្រដា ប្រដាប់មានក្រែល ។ មនុស្សតើទៅណា សត្វសត្វនានា មិនមានយើញដែរ តន់ៗ ជាក់ ។ ដំណាក់ដំណែល ដំណែងប្រហែល ជាស្តេចប្រដី ។ ឬក្រែងមានឃុត្ត ដូរជាតិអប្បល័ក្ខណ៍ ភមតចាប់ធី វែស្តេងស្តេចក្រែងខ្លាច អំណាចរិទ្ធី រត់ចោលជានី ដូចយើងដែរដឹង ។ សេះក្រាបខ្ញុលធ្វើយ បពិត្រម្ចាស់អើយ ថាបើម្ចាស់ទីង ចង់ជ្រាបសភាព តន់ជ្រាបដំណឹង តែយើងទៅទីង កុំទៅឋានណា ។ ស្តេចស្តាប់សេះខ្ញុល ដូច្នោះហើយចូល ក្នុងព្រះចិត្តា តូជតង្ស្រោងធី រៀបទីក្រឡា បន្ទំរចនា ម្ខេងដុំទៅក្រៅ ស្តេចធ្ងុំសឹងលុះ ព្រឹកព្រាងឹកាល ណោះ សេះខ្ញុលតឿនទៅ បពិត្រសូត្រក្សត្តិ យើងបានមកទៅ សុខគួរ ចមទៅ ទ្រង់ព្រះចិត្តា ។ ទុកអង្គុដទៅ នេះយើងនិងទៅ រុករកផលា យកមកថ្វាយសោយ កុំឲ្យអង្គុជា នឿយព្រួយកាយា ហត់ហើយ ហាលថ្ងៃ ។ ស្តេចស្តាប់អស្សរាហ៍ ត្រេកត្រអែចិត្តា បន្ទូលថាហៃ ឫទ្ធិស្ងួនស្នេហា បងលាទៅព្រៃ ចូរមាសមិត្រថ្លៃ អ្នកនៅនេះណា ។ រួមរក្សាកាយ ក្រែងកើតអន្តរាយ ម្តេចៗស្ងួនភ្ងា បិតុរាធ្លាដាច កុំភិតភយា រសៀលសូរ្យា បងមកវិញាទេ ។

(មានត)

រឿងសាមកុក

ភ័ណ្ឌទី ២៨

ទាញយកពីវិបុលភាជនសេទា ឆ្ងូ-ភឿង ប្រែរៀបរៀង

តមក

> រឿងសាមកុកទុកជាឃុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> នឹងបេះខុបាយកលចំណាន
> ទាំងមានសន្តានស្នេហាជាតិ ។

អ្នកថាំនោះខ្លួនក៏ច្រើនប្រព្រឹត្តអាក្រក់រមែងតាប់សម្លាប់មនុស្សតាមអំពើចិត្ត ឯអ្នកហ៊ីនោះសោត ជាមនុស្សចិត្តទន់ខ្ចីឃើញជាការប្រញាប់មិនបាន តែអ្នកស៊ីនដែលជាកូនកើតពីនាងឡៅដីនោះ មានសតិប្រញាក់ឈ្លាសវាងវៃ ចាំងចិត្តថ្លៃមកំណត់សុភាពរៀបរយ ដោយមេត្រីធឹងសេនាខាហាន នូវអស់អាណាប្រជាជនជារាប្រាំន គួរយើងលើកតំកើងអ្នកស៊ីន ឲ្យធ្វើធំកន្ត្រកតីដីវានេះ ជាប្រយោជន៍រឹងជួយខំទុកបំរុង រក្សាអាណាប្រជាពស្ត្រតៗ ។ គួរតែវាធ្វើយ៉ាងថា អ្នកថាំជាបុត្រឫធឹងធំជាន់តែវាំងអស់ លោកឲ្យទៅឈរ រក្សាស្រុកសៀនដីវ៉ា ដែលត្រូវទៅធឹងស្តាប់បង្គាប់ស្រុកតីដីវានេះ ឥឡូវលោកឲ្យអ្នកស៊ីន ជាអ្នកធ្វើជាធំកន្ត្រកតីដីវ៉ា បង្គាប់បញ្ជាការអ្នកថាំជាបងនោះ មិនតាំងឲ្យបងមកចំណុះប្អូនទេឬ ? ដែលលោកធ្វើដូច្នេះឃើញថា

ខុសនឹងចំនៀមចម្ងាប់ប្រវេណី ពីបុពណរៀងមក ម្យ៉ាងទៀត ខាងអ្នកចាំ
ក៏តង់មានចិត្តពាស់អញ្ជាស្រ័យ ខមួយទៀត ការសឹកសង្គ្រាមក៏កំពុងជាប់
ដៃជាំងគ្នា បើដូច្នេះ តួរតែលោកគិតការសង្គ្រាមឲ្យសម្រេចជាមុនទើប
បាន ដែលលោកមកកន្ទុលជាប្រញាប់ទឹងតាំងតែងបុត្រឲ្យធ្វើធំធ្វើតួច ខុស
របៀបគ្នាដូច្នេះ ខ្ញុំយល់ឃើញថាដូចជានាំឲ្យបុត្រលោក ចងអាឃាត
ញាក់ចុងគ្នា ទៅវិញទៅមក សុំឲ្យលោកបង្អន់ឈប់សិន ជាការស្រួល
ជាង ត្រូវតែគិតស្រុតរូតចាត់ចែងការហាន លើកទៅធ្វើសង្គ្រាមនឹងចូលឲ្យ
សម្រេចមុនទើបគួរ ។

អ្នក.ស៊ីវ៉ៃទៅស្ងៀម មិនតបដូចម្តេចឡើយ ខណៈលមានការហាន
ចូលមកប្តឹងថា ឥឡូវ អ្នកចាំលើកការហាន ៥០.០០០, អ្នកហ៊ុំលើក
ការហាន៦០.០០០.មកនឹងជួយសង់សឹកចូលួ តាំងគោកន់ជាកុយដែលធ្វើ
ជាទៅហ្វាយស្រុកនៅម៉ង់ដីវ៉ៃនោះ ក៏លើកការហាន ៥០.០០០ មកជួយធ្វើ
សង្គ្រាម ច្បាំងនឹងចូលួដែរ ។ អ្នកសៀវ ភ្ញាហើយក៏មានអំណាចស់
តាំងចាត់ចែងឲ្យប្រមូលសេនាការហានបាន១០ម៉ឺនភ្លាយ ហើយនាំអ្នកចាំ
អ្នកហ៊ុំ,អ្នកស៊ុង,ទឹងគោកន់ លើកកងទ័ពចេញទៅដល់ដំបន់ស៊ីងតេង ក៏
ឲ្យបញ្ជាការហាន ចោះកងទ័ពនៅទីនោះ ។

ឯចូលួកាលលើកទ័ពធ្លងខន្ទូហង៉ហោ តាមអ្នកសៀវទៅ លុះមិនការ
ហើយ ក៏លើកត្រឡប់មកឈប់ នៅក្បែរមាត់ខន្ទូហង៉ហោនោះ ពួក
អ្នកស្រុកក្រៅនាំង៉ប៉ុន្មាន ក៏នាំគ្នាយកបស់ទ្រព្យសម្ភារពីចំណីត្រី
សាច់ទៅជូនចូលួជាច្រើន ។ ចូលួក៏មានចិត្តសោមនស្សក្រែកអរ ពេលនោះ

ឃើញមនុស្សប្រុសចាប់ដាក់ ៤នាក់ យកវេសមកឲ្យ ក៏ហៅខ្លួនឡើងសួរ
អង្គុយលើទីសមគួរហើយសួរថា អ្នកទាំង៤នាក់នេះអាយុប៉ុន្មានឆ្នាំហើយ ?
តាចាស់ទាំង៤នាក់ទោះដឹងថា អាយុខ្ញុំបាទទាំង ៤ នាក់នេះ ជាង៩០
ឆ្នាំហើយ ។ ប៉ុន្តែថា យើងដែលលើកតង់ទ័ពមកតទល់ ឥឡូវនេះ
ព្រោះជាការចាំបាច់ តែចិត្តទឹកអាណិតអ្នកទាំងអស់គ្នា ជាពស្តេអ្នកស្រុក
ក្រៅ ដែលឥឡូវមានសេចក្តីលំបាក ព្រោះតាហានបេសយើងសែនឆ្ងាយ
សុំដោយគំពាមកំហែងដណ្តើមយកស្រូវអង្ករសម្បៀងអាហារ មកការពារ
ចិញ្ចឹមជីវិត ។ តាចាស់ទាំង ៤ នាក់ឆ្លើយថា ការណ៍នោះមិនអ្វីទេ ការ
ព្រះចៅហួនតេ ជាទេសាយភស្តុតាងនោះ មានតាចាស់ម្នាក់ ឈ្មោះ
អ៊ីគុយ នៅស្រុកសៀតាំងមកសូមអាស្រ័យនៅជួនខ្ញុំបាទ លុះរំលង
កណ្តាលយប់ឃើញផ្កាយរះឡើង ខាងទិសឯណើងមួយដួងធំមានរស្មីលឿង
អ៊ីគុយនោះចេះតម្រាមើលផ្កាយរើបទំនាយទុកថា នៅ៥០ ឆ្នាំទៀតនឹង
មានអ្នកមានបុណ្យមកប្រាប់ប្រាមសត្រូវ នៅដំបន់ទន្លេហាននេះ ខ្ញុំ
បាទកាប់ខ្នាញ់អ៊ីគុយទំនាយមកដល់ថ្ងៃនេះ ឃើញត្រប់ ៥០ ឆ្នាំហើយ ឯអ៊ីន
សៀវនោះលួចគ្មានបញ្ហាអ្វីសោះ ប៉ើនឹងធ្វើការអ្វីក៏មានតែធ្វើតាមអំពើចិត្ត
អាក្រក់ដូចយ៉ាងការលែងលើកតង់ទ័ព មកចាំឆ្នាំនឹងលោកនៅដំបន់
តួតវានោះ តាហានអ៊ូនសៀវមានច្រើនជាងលោកដល់ ៧ ភាគ ១០ ភាគ
បះណ្តាយឲ្យលោកវាយបំបែកបាន ខ្ញុំបាទឃើញថា លោកជាអ្នកមាន
បុណ្យដូចអ៊ីគុយទំនាយទុក ឯការប្រជាពស្តេរាំងឆ្ងាយ កុងឧបទ្វីប
ស៊ីមាការណាវែងត្រាំងនេះ គង់ទឹងបាននៅជាសុខរក្សាមក្សត្ត ព្រោះ

បុណ្យរបស់លោកតវៅ ។

ចូរឆ្ងល់ស្តាប់ដូច្នោះ ក៏អស់សំណើច ហើយក្រែងចង្អុលប្រាប់ថា "លោកតានឹងមកសំគាល់ថា យើងនេះ ជាមនុស្សមានបុណ្យក់សនានោះ មិនមែនទេ" ថាហើយ ចូរក៏ឲ្យយកមាសប្រាក់នឹងគ្រឿងសម្លៀកបំពាក់យ៉ាងល្អ មកចែកឲ្យតាចាស់ចាំង ៤ នាក់ ជាបំណាច់ភ្នំនាន់មាត់ ហើយបង្គាប់តាហានចាំងអស់ថា កុំឲ្យនរណាទៅធ្វើដណ្តើមយកបរស់ទ្រព្យអ្នកស្រុកចាំងពួងឡើយ បើនរណាហ៊ានមិនស្តាប់ពាក្យយើង ។ ទីនឹងចុះទោសប្រហារជីវិត ។ តាចាស់ចាំង៤ នាក់ក៏លាចូរឆ្ងលវៅ ។ ខណៈនោះ ឯណាប្រជាកស្តូចាំងឡាយបានដឹងថា ចូរឆ្ងលបានឆ្លាស់ពលសេនាតាហានដូច្នោះ ហើយក៏រីករាយសប្បាយចិត្តចាំងអស់គ្នា មានចិត្តស្នេហាស្រឡាញ់ចូរឆ្ងលថាអនេកប្បការ ។ ចូរឆ្ងលដឹងតិត្តិសព្ទថា ពស្តូចាំងឡាយនោះសប្បាយរីករាយស្រឡាញ់ខ្លួនក៏មានអំណរពន់ប្រមាណ ។ ខ្លួលមានបំរើសេះម្នាក់មកជំរាបចូរឆ្ងលថា ឥឡូវ អ្នកនឿសៀវ លើកកងទ័ពមកចាំង ៤ ខែត្រ មានតាហានប្រហែល ៣០ ម៉ឺន មកបោះទ័ពនៅជិតទន់ស៊ីនគេន ។

ចូរឆ្ងលដឹងដូច្នោះ ក៏ប្រមូលពលតាហានលើកទៅតាំងបន្ទាយភ្លាមគ្នានឹងបន្ទាយអ្នកនឿសៀវ ។ ឃើញចូរឆ្ងលមកបោះទ័ពភ្លាមគ្នាដូច្នោះ ក៏នាំបុត្រចាំង ៣ នាក់នឹងកូយម្នាក់ទៀតអស់សេនាតាហានចាំងពួង ចេញមកបញ្ជរសេះនៅមុខបន្ទាយ ។ ចូរឆ្ងលឃើញហើយ ក៏បរពលចេញទៅក្រៅបន្ទាយ ទើបឡើងបរសេះបំពារតាហានទៅបញ្ជរពីមុខតាហាន ហើយស្រែកហៅអ្នកនឿសៀវថា ខ្លួនបពន័យចាញ់យើងម្តងទៅហើយ ហេតុម្តេច ក៏មិន

មកចំណុះបុះចាញ់យើងតែម្តងទៅ ? ខ្ញុំនចង់ឲ្យគាត់ដល់ក ទើបដឹងខ្លួនឬ ? ។ អ្នកនសៀវភៅជូរថ្នោះខឹងណាស់ ទើបសួរគាហានគាំងតួងថា នរណានឹងនឲ្យសាសាបេញ្ញាទៅបង្ហាំងនឹងបួងបួងបាន ។

អ្នកស៊ុងជាបុត្រ ក៏សួមនឲ្យសាសាបរសេះកំក្រប៉ី ចួលទៅបង្ហាំងនឹងបួង ។ ឃើញជូរថ្នោះ ក៏សួរគាហានគាំងតួងថា គាហានអ្នកនសៀវភៅម្នាក់នេះយើងឃើញមែកមុខ នរណានឹងស្គាល់ ? គាហានបួង ឆ្លើយថា ឈ្មោះអ្នកស៊ុងជាបុត្រអ្នកនសៀវ ។ ខណៈគាលគាហានប្រាប់បួងមិនទាន់ចុងពាក្យ ស្រាប់តែនដែលជាគាហានឆើស៊ីហ្គុង បរសេះកំពួនចួលទៅបង្ហាំងតឹងអ្នកស៊ុងបាន ៣ ភ្លែង អ្នកស៊ុងធ្វើជាថយសេះត់ទៅក្រោយស្រាប់តែម៉ងដឹងកលខុចាយ ក៏បរសេះដេញតាមទៅ អ្នកស៊ុងឃើញបានចំណាប់ ក៏ចាប់ខ្លួនឡើងបាញ់ព្រួញលឿនញាំញីទៅត្រូវកែកស្រាប់តែដួលទាក់តែសេះស្រាប់ ។ អ្នកនសៀវឃើញអ្នកស៊ុងមានជ័យជំនះគាហានបួងដួលថ្នោះ ក៏មានចិត្តកំរើកដេញគាហានចួលតតាំងនឹងបង្ហាំង នឹងគាហានបួងបានពីរគ្នា ។

ឯគាហានបួងក៏ចល់ចប់ខុបាន កងទ័ពគាំងសងខាងស្រាប់តែបួសតិការអស់ជាច្រើន ។ លុះវេលាល្ងាច បួងនឹងអ្នកនសៀវបានថយទ័ពចួលបន្ទាយរៀងខ្លួន ។ ដល់ពេលកណ្តាលអធ្រាត្រ បួងប្រឹក្សានឹងគាហានគាំងតួងថា នឹងធ្វើម្តេចឲ្យបានជ័យជំនះតែអ្នកនសៀវ ។ រៀយក៏ឆ្លើយថា សូមឲ្យលោកបាត់គាលគាហានបែងចែងជា ១១ កង ឲ្យបង្កប់ពាយគ្នាភាគខាងឆ្វេង ១០ កង, មួយកងទៀតនោះ ឲ្យបញ្ជាតថយមក បើបានចំណាប់ហើយក៏ឲ្យអុជផ្លាកែងសញ្ញាឡើង ហើយកងបញ្ជាតនោះ តចល់ចង្កាំងនៅទីនោះ

បើកនំពីរនឹងសៀវភៅយកបៃតខ្មៅ ឲ្យកនំពីរដែលបង្គប់សងខាងផ្លូវចាំង ១០ កន ខោះចេញមកចាំង ១០ កន ពីសងខាងផ្លូវ ព្រួតគ្នាលើកក្រលុកវាយកាត់យកទំពីរនឹងសៀវ មុខជាបានជ័យជំនះដោយងាយ ។ ចូរឆ្លុយល់ឃើញត្រូវផង ទើបបាត់ចៃដន្យបែនរំលែកពលពាហនខាងស្តាំ ៥ កងតឺ ឲ្យ ចោហន, ខៀវខាប់, ស៊ីហ្គុន, អ័តម នឹងកោឡាំជានាយទំព; ខាងឆ្វេង ៥ កងឲ្យហៃហ្គីខុន, ខៀវលៀវ, លីខៀន, ង៉ាក់ដិន នឹងហៃហ្គីអឿន ជានាយទំព លើកប្រសព្វពាហានទៅបង្គប់តាំងសងខាងផ្លូវ ហើយបង្គាប់ថា បើឃើញកល់ការ បានចំណាប់ហើយ ឲ្យលើកគ្នាចេញតតាំងច្បាំងកាត់យកកនំទំពីរនឹងសៀវ តាមផ្លូវរៀងទៅ ។ នាយពាហានចាំង ១០ កន កំលើកពាហានទៅតួនបង្គប់ កនពេលយប់នោះ តាមពាក្យបង្គូបង្គាប់ ។ លុះដល់ពេលកណ្តាលអធ្រាត្រប្រហែលយាម ៣ ម៉ោយ បង្ហូរទ្រីទៅឆ្ងៃ លើកទំពាទៅធ្វើជាវាយបន្ទាយអ្នឧនសៀវហើយថា «មើឃើញកនទំព អ្នឧនសៀវលើកចេញមកតវៃ អ្នកចូរនាំពាហានថយមក យើងតឹថយចេញពីបន្ទាយឲ្យអស់" ទៅឆ្ងកំលើកកនពាហានទៅរៀបតាមបង្គាប់បង្ហូរ ។

ខណៈនោះ អ្នឧនសៀវបានឮពាហាន វៃស្រែកហោចូលមកឡោមព័ទ្ធបន្ទាយដូច្នោះ កំប្រមូលពាហានចេញចាំង ៤ កន មកតតាំងច្បាំងគ្នាជាគោលាហល ។ ទៅឆ្ងកំបពលចូលហើយធ្វើជាថយក្រោយវិញ ចូរឆ្ងកំដេញពាហានឲ្យចូលតាមប្រសព្វគ្នាខឹងកនទំពទៅចុ ។ អ្នឧនសៀវឃើញដូច្នោះ កំបន្ទុំដេញពាហាន តាមទៅដល់មាត់ទន្លេហនហោ ខ្លួលភ្លឺស្វាងខ្លាំង ចូរឆ្ងកំអុជជាវាសញ្ញាហើយស្រែកប្រកាសដល់ពាហានចាំងពួងថា

ហេតុម្តេចទើបមិនឈប់ហើយចាំផ្ទះនៅតែនេះ នឹងថយទៅដល់ណាទៀត; នឹងទៅឲ្យគាល់តែលង់ទឹកស្លាប់ឬ ; គាហានគាំងពួន ចាន់ចូលឆ្លៀតស្រែក ដូច្នោះ កំភ្លាចស្លាប់ដោយលង់ទឹក ទើបបបួលគ្នា ត្រឡប់មុខមក ឈរចាំគាំងតល់ជាតទឹក ។ ទៅជួបរេសកំពួនបួលដេញចាក់គាប់ សម្លាប់គាហាន ស្លាប់អស់ជាច្រើន ហើយរុកកាន់ទន្រានដេញចូលទៅ សម្លាប់គាហានឯកអ្នកនៅសៀវអស់ ប្រហែល ១១-១២ នាក់ថែមទៀត ។ គាហានម្នាក់នៅសៀតតល់ពុំឈ្នះ ក៏បែកខ្លែកទៅវិញ អ្នកនៅសៀវឃើញដូច្នោះ ក៏នាំបុត្រចាំង ៣នាក់ នឹងក្មួយ ១ ហើយនឹងគាហានចាំងពួនរត់ចំលាយ ខ្លាចេញទៅ ។ ចួនឃើញបានចំណាប់តិបតលបួលដេញពីក្រោយ ។

ឯណោះកាលអ្នកនៅសៀវបែកខ្លាចរត់ទៅនោះ ខ្លួលឮសូរសំឡែងឃ្នុះ តង់ស្គរអើងកងជុំវិញខ្លួន ក្រឡេកមើលទៅខាងស្តាំផ្លូវ ឃើញកោះគ្នាំ លើកគាហានដាច្រើនចូលមកកេមតំខ្លួនជុំវិញ, មើលទៅខាងឆ្វេងផ្លូវឃើញ ហែហ្មដូរគ្នៅលើកគាហានចាមកេមចូលមកទៀត អ្នកនៅសៀវ កំយល់ខ្លាំង ណាស់មិនបានគិតនឹងដឹងតាំងប្លាំងឡើយ ប្រើងតែនាំបុត្រនឹងក្មួយខ្លួនៅអស់ គាហានចាំងពួនរត់ចេញទៅ បានចង្ហាយផ្លូវប្រហែល ១០០ សិន (៤គ.) ខ្លួលប្រទះនឹងគាហានទ័ពអ៊ុតម លើកតំខ្លួនពីខាងស្តាំមក ឃើញ កងទ័ពដាក់ដំនេរចេញពីខាងឆ្វេងផ្លូវ ក៏ឃប្រសព្វខ្លួនបំភ្លាមមកទៀត អ្នកនៅសៀវ ក៏នាំគ្នារត់ទៅបានចម្ងាយផ្លូវប្រហែល ៣០ សិន (១២០ម.) ឃើញស៊ុ. ហ្វុងលើកគាហានចេញពីខាងស្តាំមកចំស្លាក់ពីមុខ ឃើញលើកឆ្លៀនលើក គាហានចេញពីខាងឆ្វេងក៏ឃប្រសព្វខ្លួនបំពីក្រោយមក អ្នកនៅសៀវ ក៏នាំ

បុត្រទីឆ្នាំក្រយនូវអស់ពលសេនាគាហាន រត់តាមគាត់តទីតេញទៅ
លុះទៅដល់បន្ទាយ ក៏ចូលទៅឈប់ដាំភ្នាយអាស្រ័យ ចាយរៀបតែទីឆ្នាំន
ខ្លួលខ្លៅខាប់ទីនឹងខ្លៅសៀវ លើកគាហានហែកបន្ទាយចូលទៅចាំន
អ្នកសៀមិនតាន់ស៊ីចាយ ភ័យខ្លាំងណាស់ ក៏នាំបុត្រទីឆ្នាំនពលគាហាន
តាំងពួន រត់ខំលាយបន្ទាយទៅ កំឡាំងក៏អស់ ខំប្រឹងរត់ទៅដល់ដើនក្តុ
មួយអន្លើ ខ្លួលដួលទីឆ្នាំនតាន់ខោហាន, រៀបហ៊ុំខ្លួន លើកពលរយខ្លាប់
ថែមមកខ្លៅត អ្នកសៀ ក៏ស្រែកហៅគាហានតាំងពួនថា បើនរណា
មួយ មិនតាំគ្នាឲ្យឆ្ងាំនាទេ មុខជាគាហានបួនសម្លាប់អស់ហើយ ។ គាហាន
តាំងពួន ឮនក្តីអ្នកសៀស្រែកដូច្នោះ ក៏នាំគ្នាមកតទល់ ឲ្យឆ្ងាំន
ការពារនាំអ្នកសៀរៀបត្រួតទៅឃាន ។ ឯនាយគាហានបួនតាំង ១០
កងនោះ ឃានជាក់គាប់សម្លាប់គាហានអ្នកសៀ ស្លាប់ដោយលំដាប់
រៀងមកជាប្រៃណាស់ អ្នកសៀ កាលរត់ទៅដុតហើយ ឃើញអ្នកហ៊ុ
ជាបុត្រទីឆ្នាំនតេតាន់ជាមេទាន់នោះ ប្រាប់ព្រួញទីឆ្នាំនអាវធជារឿនមកខ្លៅ អ្នក
សៀ ឲ្យបុត្រទីឆ្នាំនញ៉ាំងព្រួញយិ៍ ពាល់តែសន្ធប់ឃាត់ស្មារតីទៅ៏ទាន់ទៅ ។
គាហានតាំងអស់ ឃើញដូច្នោះក៏ពិតភ័យ នាំគ្នាតែនទីឆ្នាំនស្មារតីឡើង
វិញ ។ ក្នុងទីនោះ អ្នកសៀ មានសេចក្តីត្រេកអរក្តីចិត្តជាខ្លាំងណាស់
ពាល់តែគុណយាមបេះព្រួញមក លុះដឹងស្មារតីបើយ ក៏ជម្រាបថ្លើមធំហើយ
ថា “តាំងពីយើងកើតមក មិនដែលមានសេចក្តីទុក្ខបំពាក ខ្ញុំសេចក្តី
ក្តៅក្រហាយចិត្ត ដូចគ្រានេះសោះឡើយ ដ៏តែយើងគ្រានេះ ឃើញថា
ទីឆ្នាំនមិនរួចពីសេចក្តីស្លាប់ បុត្រទីឆ្នាំក្រយ នូវអស់សេនាគាហានតាំងពួនឆ្នាំ

ចូរនាំគ្នា វិលទៅស្រុកវិញចុះ ហើយចូរនិយាយតបទៅគេថា ឲ្យគេបានឲ្យអស់សេចក្តីកំហឹង របស់យើង" ហើយអ្នកនៅស្រុក ក៏គិតថា ស្រុកស្រែឯណីវានោះ ជាផ្លូវឆ្ងាយជាច់ស្រយាលណាស់ ខ្លាចបួនទ័ពទៅកាយយកកំទេចថែមទ្រាំមិនបាន, គួរតែ ទើសុំនបង ឲ្យទៅនៅរក្សាស្រុកស្រែឯណី ឲ្យអ្នកហ៊ីត្រឡប់ទៅស្រុកអ៊ីជីវ ឲ្យកោកត្រឡប់ទៅស្រុកបេងជីវ ឲ្យកេណ្ឌពាហានទាំង ៣ ស្រុក ទុកឲ្យត្រមស្រេច បើយើងត្រូវការឲ្យប្រមូលវិលមក ទើបបានលើកមកភ្លាមឲ្យទាន់ការ អ្នកទាំងនោះក៏ទាំងអ្នកស៊ីនទើបពាហាន ដែលនៅសល់នោះត្រឡប់ទៅស្រុកគីជីវិញ ។ ក្រោយនោះមក អ្នកទាំងនោះ ក៏ចាប់មានជម្លឿជាខ្មាន់ ទើបចាត់អ្នកស៊ីន ឲ្យចេញទៅស្តីការពាក្យការជំនួសខ្លួន ឲ្យសឹមផង, ហើយតែជាជំនួយពាក្យការនេះមិនផង ។

ឯបួនគ្រាលបើពាន្យៃយ៉ាងនេះអ្នកទាំងនោះ ជាតំរង់ ៤ គ្រានៅ ទើបឲ្យប្រមូលសេនាពាហានរបស់ខ្លួនទាំងនោះ ដែលបែកខ្ចែកក្រាត់ទៅនៅក្នុងព្រៃនោះមកជុំបូលជារឿន លើយលើកទ័ព ចូលទៅតាន់បន្ទាយនោះដែរ ដ្បិតសិនតែនឹងវិញ ទើបចាត់ចែងឲ្យបំណាច់ខ្មាន់សេនាពាហានធំតូច ជាមាសក្រាក់ទឹនត្រឿងសម្លៀកបំពាក់តាមសមគួរ ហើយបួនក៏ចាត់ពាហានឲ្យចូលទៅស៊ើបស្តាប់ការ ក្នុងស្រុកគីជីវនោះ ឲ្យដឹងថា អ្នកទាំងនោះនៅមានរិះគិតប្រការម្តេចទៅទៀត ពាហាននោះ ក៏បន្ធឹងចូលទៅជាច្រើនថ្ងៃ ហើយចេញមកជំរាបបួនថា ឥឡូវ អ្នកទាំងនោះឈឺឲ្យអ្នកស៊ីនស្តីពាក្យការជួស ឯអ្នកស៊ីននោះ គិតខ្លាចក្រែងយើង លើកទ័ពទៅកាយយកស្រុកគីជីវ ទើប

កេណ្ឌគាហានឡើងទៅនៅរក្សាសើនបន្ទាយជាមាំមួន, ឯអ្នងចាំ, អ្នងហ្ន៎, គោកន្ទនោះ រំលែទៅរក្សាស្រុកវៀងខ្ងុនហើយ ។

ចូរួចបានស្តាប់ក៏នៅស្ងៀម មិនបានថាប្រការអ្វីច ប្រឹក្សាទាំងសេនាគាហានទាំងពួងជំរាបថា ឥឡូវ អ្ងុនសៀវ ឈឺដែលឲ្យអ្ងុនស៊ុងស្តីកដការជំនួសនោះ យើញថាតំនិតនឹងថ្លៃដែអ្ងុនស៊ុង ទំនឹងការពាររក្សាស្រុកមិនបានទេ សូមឲ្យលោកស្រួតលើកទ័ពទៅកាយយកស្រុកគន្លីវ៉ែ កុងវែលានេះ មុខដានទឹងបានដោយងាយ ។ ចូរួតបបថា ស្រុកគន្លីវ៉ែនោះស្បៀងអាហារបរិបូណ៌ណាស់ ទាំងសឹមដោយកំមានដំរែះក្រោជាច្រើន, ដែលយើងទំនឹងលើកទ័ពទៅកាច់យកដោយងាយនោះ យើញថាមិនបានទេ ព្រោះខេសៈកាលៈជារដូវ ធ្លើស្រែស្រូវគោជសាលីកំពុងខុំ អាណាប្រជាទុកស្តុកក៏ទំនឹងបានសេចក្តីក្តៅក្រហាយ យើងត្រូវតែតាំងបន្ទាយនៅឡាប់រក្សាស្រុកសិនទំពាកស្តុកធ្លើស្រែរួច សឹមលើកទៅកាត់យកស្រុកនោះទំនឹងបានដោយងាយ ។

ក្នុងខណៈនោះ មានបំរើសេះម្នាក់ កាន់សំបុត្រស៊ុនរុតមកឲ្យចូរួច ចូរួចយកសំបុត្រមកមើលឃើញសេចក្តីថា "ឥឡូវ ខ្ញុំពីរនៅស្រុកយីឡាំ បញ្ជាបញ្ជាលសេនាគាហាន ប្រមូលបានប្រមាណ ៥ ម៉ឺនប្លុង ដឹងថា បហាទបពជលើកកងទ័ពមកធ្វើសង្គ្រាមនឹងអ្ងុនសៀវ ខ្ញុំពីរគិតត់ទ្រូវបេកឲ្យនៅរក្សាស្រុកយីឡាំ ខ្ងុនខ្ញុំពីរ លែងកងទ័ពត្រូវប់ត្រាយមកវាយយកស្រុកហ្ន៎តោ សូមឲ្យមហាទបពជប្រញាប់លើកទ័ពត្រូវប់មកការពារស្រុក ឲ្យមានគារ" ចូរួយើញសំបុត្រដូច្នោះ ក៏រ័យខ្លាំងណាស់ លើកកងទ័ពត្រូវប់មកដល់ទ្វេហាង ហក ជាន់ឲ្យគោហានតាំងបន្ទាយកំនទ័ពនោះទើ នោះ ហើយចូរួចក៏លើកកងត្រូវមកស្រុកខ្ញុំពីរ ។ (មានវ)

ហោកវុលតែរ ធីពង្ស

លោក វ៉ាយ-ប៊ុក ប្រែរៀបរៀង

(តមក)

វគ្គទី ៥

អ្នកសប្បុរស

នៅទីក្រុងចាប៉ីខ្លោនគេធ្លាប់ធ្វើពិធីបុណ្យដ៏ធំឡើងក្នុងរៀងរាំឆ្នាំម្តងៗ ពិធីបុណ្យនោះគឺជាប្រពៃណីនៅទីក្រុងចាប៉ីខ្លោន, ដែលជាពិធីប្រកាសដ៏ធំឡើង, នូវនាមពលរដ្ឋណា ដែលបានប្រព្រឹត្តសកម្មភាពដ៏ប្រសើរ ដែលគេទុកជាមហាសប្បុរស ។ បណ្តាពួកមន្ត្រីធំៗ ទន់ពួកមន្ត្រីសង្ឃ ជាចៅក្រមសម្រាប់និច្ឆ័យរឿងនេះ មន្ត្រីធំម្នាក់ដែលត្រួតត្រាទីក្រុង ក៏បានប្រកាសតំកល់ពាង អំពីសកម្មភាព ដ៏វិសេសវិសាលដែលខ្លួនបានធ្វើចំពោះប្រទេស ។ គេប្រុងប្រៀបទន់សម្រេច ហើយព្រះមហាក្សត្រទ្រង់មានព្រះពាដហប្តូរ ២ បម្រុងទន់សម្រេចជាអវសាន ។ គេអាចមកកាត់ពិធីបុណ្យនេះ តាំងពីប្រទេសដែលបិតនៅចុងដែនដី ពួកជ័យបុរស ទទួលអំពីព្រះហស្តព្រះមហាក្សត្រ នូវព្រះតានមាស ពេញទៅដោយត្បូងពិភ្យ ហើយព្រះអង្គទ្រង់មានព្រះពាដឧទ្ធារថា " ចូរអ្នកទទួលភ្លាមនេះ ហើយសូមឲ្យព្រះអាទិទេព ទ្រង់ព្រះពាដានទូវពលរដ្ឋណាមកខ្ញុំ មានសភាពឲ្យដូចអ្នក " ។

ក្នុងពេលថ្ងៃនោះ , ព្រះមហាក្សត្រទ្រង់គង់នៅក្រោមព្រះ

ស្ងួតប្លុក្រ មានមន្ត្រីធំៗ ចាំតាល់ហ្អា, មន្ត្រីសង្ឃតំណាងពស្ដេចនៃប្រជាជាតិទាំងឡាយអមជាព្រះពជបរិវារ អញ្ជើញមកប្រជុំរួមក្នុងពិធីបុណ្យនេះ។ កិត្តិគុណត្រូវបានមិនមែនមកពីសេះលឿនរត់ឈ្នះគេ ឬកំឡាំងកាយមានអានុភាពជាងគេនោះទេគឺមកពីគុណធម៌តែម្យ៉ាង។ មន្ត្រីធំម្នាក់បានប្រកាសនូវសកម្មភាព ហើយពន្យល់ថា រង្វាន់នេះនឹងអាចទទួលបាន ចំពោះតែមន្ត្រីធំណា មានគុណសម្បត្តិដ៏ពេញលេញ។ មន្ត្រីធំនោះ មិនបានពោលអំពីមហាសប្បុរសធម៌ នៃលោកហ្ស៊ាងឌិត ដែលបានប្រគល់សម្បត្តិទ្រព្យឲ្យអ្នកលោភកវិញទាំងអស់នោះទេ ព្រោះមិនមែនជាសកម្មភាព ដែលត្រូវប្រឡងប្រជែង ក្នុងពិធីបុណ្យនេះ .....។

មន្ត្រីធំនោះបានពិណាអំពីរឿងចៅក្រមម្នាក់ ដែលធ្វើឲ្យអ្នកក្តីចាញ់គេ សម្លឹមអស្ចារ្យ ដោយសេចក្តីភ្ញាក់ផ្អើល ដែលខ្លួនមិនអាចទទួលខុសត្រូវបាន, ហើយបានយកទ្រព្យសម្បត្តិរបស់ខ្លួន សងគ្រប់ចំនួន, ឲ្យត្រូវតាមចំនួនទ្រព្យសម្បត្តិ ដែលអ្នកក្តីនោះបានខូចខាត។

រួចមន្ត្រីធំនោះ បានពណ៌នាអំពីប្រុសកំឡោះម្នាក់ មានចិត្តប្រតិព័ទ្ធនឹងនារីតញ៉ាម្នាក់ ដែលខ្លួនប្រឹងនឹងធ្វើវិវាហមង្គលការ ហើយលះបង់នាងនេះទៅមិត្តភក្តីម្នាក់ ដែលមានចិត្តស្និទ្ធស្នេហាជាយ៉ាងក្រៃពេក ស្ទើរស្ល៉ាយជីវិត ដោយចេញប្រាក់ចំណងដៃប្រគល់ឲ្យថែមទៀត។

លំដាប់តមក, មន្ត្រីធំនោះ ពោលអំពីតាហានម្នាក់, កាលពីសង្គ្រាមហ៊ីរកានី, បានបញ្ចេញឲ្យឃើញថា ខ្លួនជាមហាសប្បុរសពិតប្រាកដដោយមានបច្ចាមិត្តម្នាក់ បានវាយដណ្តើមយកតួសង្ឃ, តាហាននោះ ក៏ខំ

ព្យាយាមការពារជាយ៉ាងម៉ឺងម៉ាត់, ស្រាប់តែមានគេមកប្រាប់ថា មានពួកហិរ៉ាទីឯទៀត កំពុងវាយដណ្តើមយកម្ចាយខ្លួន ។ កិលេបង់ស្ត្រីនោះ ដោយយំសោកជាខ្លាំង រត់ស្ទុះទៅជួយមាតា រួចលើកត្រឡប់មកកាន់តូសង្ឃរាវនោះ ដែលដិតខ្លួនមរណភាព ។ គាហានោះគិតនឹងពិឃាដខ្លួនឯង, តែមាតាខ្លួន បានបង្ហាញឲ្យឃើញជាក់ស្តែងថា អញមានតែឯងនេះជាទីពឹង ហើយគាហានោះ កិលេបង់ក៏អំតើទៅ ។

លៅក្រមតាំងឡាយយល់ថា គាហាននេះឯងត្រូវបានរង្វាន់ ។ ហើយព្រះតូមិន្ទ្រឆ័កមានត្រាដូចខ្លួលថា:

"សកម្មភាពនៃគាហាននេះ, ទឹងអ្នកឯទៀតល្អហើយ តាំងមិនឲ្យខ្ញុំឆ្ងឹងឆ្ងល់សង្ស័យអ្វីសោះឡើយ ។ ពីម្យ៉ាងទៀត, លោកហ្សាឌិតបានធ្វើអ្វីមួយ គួឲ្យខ្ញុំឆ្ងល់សង្ស័យជាខ្លាំង គឺ ខ្ញុំបានដញ្ជាក្តីមន្ត្រីសំណប់នាមកូរបង្ហាចេញពីតំណែង ។ ខ្ញុំបានប្តឹងនឿសមន្ត្រីនោះជាខ្លាំង, ហើយពួកព្រះពជកចុះត្រាតាំងប៉ុន្មានបញ្ជាក់ថា ខ្ញុំស្មូតណាស់; ខ្ញុំក៏សួរទៅលោកហ្សាឌិត តើលោកយល់យ៉ាងណា ចំពោះរឿងនេះ លោកហ្សាឌិតហ៊ានិយាយសរសើរពីរាជមន្ត្រីខ្ញុំមកវិញ . . . ។ ខ្ញុំយល់ត្រមហើយខ្ញុំបានឃើញក្នុងប្រវត្តិសាស្ត្រយើង, ទុកជាណា ដូចមានមនុស្សលេបង់ទ្រព្យសម្បត្តិរបស់ខ្លួន ដោយការភ្លើងឆាត់; ឬលេបង់តូសង្ឃរា; ឬពេញចិត្តជួយទប្បត្តិមាតាដ៏ស្រីរបស់ខ្លួន ។ តែខ្ញុំមិនដែលឮ ឬបានអានសៀវភៅថា មានសេវកាមាគ្យណាមួយ ហ៊ានិយាយល្អអំពីរាជមន្ត្រី ដែលព្រះរាជា បានដកហូតងារចេញពីតំណែង ហើយដែលទ្រង់ព្រះក្រោធ

ជាខ្លាំង រួចទ្រង់ក៏ថ្វាយព្រះពរជាន់មាស ចំនួនពីរហ្មឺន កហាបណៈ ចំពោះម្នាក់ ។ ដែលមន្ត្រីធំថ្វាយសរសើរខ្លួមហាសប្បុរិសធម៌ តែខ្ញុំជូនព្រះពានសុវណ្ណចរណៃនេះទៅលោកហ្ស៊ិត ។

លោកហ្ស៊ិតក៏ក្រាបបង្គំទូលថា ប្លូតិត្រព្រះសមតិទេព, មានតែព្រះអង្គទេ ដែលត្រូវថ្វាយព្រះពានសុវណ្ណចរណៃ, ព្រោះព្រះអង្គទ្រង់ថ្វាយប្រព្រឹត្តព្រះពរជសកម្មភាពដ៏ប្រសើរ ក្នុងព្រះពរជហ្នាន្តរៈជាមហាពរជ, ទ្រង់មិនថ្វាយព្រះក្រោធ ទីងតាសាព្រះអង្គដែលចំពាស់ទីងព្រះពរជហ្ស៊ីយ ប្លូសោះឡើយ ។

គេថ្វាយសរសើរមហាពរជទីងលោកហ្ស៊ិត ។ លៅក្រមដែលថ្វាយបូជាទ្រព្យសម្បត្តិដោយប្រពៃ, បុរសដែលរៀបរាប់ហមង្គល ស្ត្រីជាគូសង្សារទីងមិត្តភ័ក្តិ, តាហានដែលតេភ្ញាចិត្តដួងស្រោចស្រង់មាតាជាងគូសង្សារ កំថ្វាយខ្លួនខ្លួវសារត្រែ ពីព្រះហស្តព្រះមហាក័ត្រគ្រប់ៗគ្នាពួកនេះថ្វាយ ឃើញគេយកនាមខ្លួនទៅចារឹក នៅលើសៀវភៅមហាសប្បុរិស។លោកហ្ស៊ិតថ្វាយព្រះពានសុវណ្ណចរណៃ, ហើយព្រះមហាក័ត្រទ្រង់ថ្វាយទៅព្រះពរជកិត្តិនាម ថាជាមហាពរជ ប្រកបដោយទសពិធពរជធម៌ ។

ថ្ងៃនោះ កំជាថ្ងៃដែលគេធ្វើពិធីបុណ្យទេះ យ៉ាងវែង—យូរលើសថ្ងៃសព្វដង, ហើយជាអនុស្សាវរីយ៍មួយ ដែលគេថ្វាយក្បាលទុកនៅក្នុងទ្វីបអាស៊ី ។

លោកហ្ស៊ិតពោលថា ខ្ញុំម្ចាស់នេះ ខ្ញុំមានចិត្តស្រួលសុខសប្បាយជាយ៉ាងក្រៃលែង តែក្នុងពេលនោះ, លោកហ្ស៊ិតក៏នៅតែគាន់ច្រឡំខ្លួតៈ . . . . . ។

(មានត)

រឿងអាល្ហ័កមាស

រឿងព្រេងនៅប្រទេសយៀក-ណាម កណ្តាល

លី-ជាមតែង

ប្រែទំនៀងរៀបរៀង

ប៊ូ-ប៊ូ ពិនិត្យ

មានព្រះពុទ្ធរូបមួយព្រះអង្គព្រះនាម "អាន់-យឿង" ទ្រង់ចាន់ជ្រើសរើសកកន្ទែងល្អមួយ ដើម្បីសាងព្រះពុទ្ធរូបសំពាប់ព្រះអង្គ ។

គ្រានោះ មានគ្រួអាស្រែយ៉ាងក្លាតែម្នាក់ ដែលនៅស្រែរនោះ ទឹកតួចចិត្តទឹងព្រះពុទ្ធរូប ព្រោះទ្រង់តុំភ្លេចពីគ្រោះរឿងនេះ ជាមួយទឹងទួនសោះ ហើយក៏ម្តេចក្នុងចិត្តថា ទឹងធ្វើឲ្យព្រះពុទ្ធរូបអង្គនេះ ទើនទុក្ខវេទនាយ៉ាងសាទួន ទឹងបំផ្លាញឲ្យខ្ចាត់ខ្ចាយពីព្រះពុទ្ធរូបទៅវិញ ។ គិតដូច្នោះ គ្រួអាស្រែចាប់ផ្តើមធ្វើអំពើអាក្រក់ដល់ស្តេច តែយកថ្នាំបំពុលទៅបាច ក្នុងទឹកត្រប់កន្ទែង ។ សម័យនោះ ទាំងក្រុង-មន្ត្រី ក្មេង-ចាស់ មានជម្ងឺយ៉ាងធ្ងន់មកគ្រប់សង្កត់ ឥតដឹងដើមហេតុអ្វីឡើយ ។ តែរាល់ព្រះបាទអាន់-យឿង ជាស្តេចទ្រង់ទសពិធរាជធម៌ ទ្រង់ចំបន់ស្រន់ដល់ព្រះពុទ្ធរូបដោយមានសន់ទៅស្នាន់ជាប្រើនសំពាប់រៀបគ្រឿងសក្ការបូជា បួងសួងសុំឲ្យបានសុខសាន្ត ក្នុងនគរ ដើម្បីទឹងចាត់ការសាងព្រះពុទ្ធរូបទៅវិញ ។

តមក ព្រះអង្គទ្រង់គ្រាស់បញ្ជាឲ្យពួកជាងចាត់ចែងរៀបចំជាកំពែងទឹងប្រាសាទឡើងភ្លាម ។ នៅគ្រាដែលដញ្ជាំងប្រាសាទបានឡើងជាកងហើយ គ្រួអាស្រែប្រើឲ្យឡស់ព្យុះសង្ឃរាមកបោកលើងប្រាសាទទាំង

នោះអស់ ។ ដើមឈើទាំងឡាយរលើងទាំងស្រស់ ។ ប៉ុន្មានលឿន
ដូចជាមែកឈើតូច ។ ។

ស្តេចមានរាជដំណើរទៅដល់ទន្លេសន្ទុះ ។ ក៏រលំធ្លាក់ចុះមកដែរ ចំពោះទាំង
បណ្តាជនស្ងាប់អស់ជាច្រើនទៀតផង ។ ក្រោយមក ព្រះអគ្គមន្ត្រីឈ្មោះ
យល់ថា ទុបសគ្គនេះជាអំពើអាក្រក់របស់មេអាវក្ស ។ ដើម្បីទំនុកបម្រុងទោសវា
ទ្រង់ត្រាស់ឱ្យបំរើម្នាក់ ទៅចាប់វាមកកាត់ក្បាលទុក ។

អ្នកបំរើទៅដល់លំនៅមេអាវក្ស ហើយរកមើលសព្វគ្រប់ទៅ មិន
ឃើញមនុស្សម្នាក់សោះ ព្រោះអាវក្សតូចតែនេះ បំបាំងខ្លួនបាត់ទៅហើយ ។
អ្នកបំរើក៏ត្រឡប់មកទូលព្រះពជាតាមដំណើរនោះ ។

ទៅពេលដែលគេកំពុងតែកម្ចាត់ទាំងឡាយ ដែលស្ងាប់ស្ទើរតែ
តុំបានទៅក្នុងទីក្រុង ព្រះពជាទ្រង់គង់នៅក្នុងព្រះពជវាំង រវាងបីថ្ងៃ មិន
ឱ្យមហេសីណាមួយ ទៅជិតព្រះអង្គឡើយ ។ ស្តេចបិតនៅតែឯកអង្គ តម
មិនសោយសាច់នឹងសុរាសោះ ទ្រង់ព្យាយាមតាំនោងធម៌ រៀបគ្រឿងសក្ការៈ
បូជា ថ្វាយដល់ព្រះម្ចាស់សួគ៌ សុំឱ្យបានសេចក្តីសុខ ស្រួលមកវិញ ទឹង
ឱ្យដណ្តើងក្រុងសាខក្នុងក្រុងថ្មីនេះ តើតឡើងវិញបានដោយងាយ ។
ជាងទាំងឡាយ ចាប់ធ្វើការសារជាថ្មីម្តងទៀត ប៉ុន្តែក្នុងរយៈមួយខែ
ដណ្តើងក្រុងសាខដែលតើតបានជាថ្មីហើយ តំរិលអស់ទៅវិញ តេមិនដឹង
ជាមេអាវក្ស ប្រើមធ្យោបាយយ៉ាងណាទេ ។ ព្រះមហាក្សត្រទ្រង់តូចព្រះ
ពជហ្ឫទ័យខ្លាំងណាស់ មិនដឹងធ្វើម្តេច ទ្រង់គិតតែពីរៀបចំគ្រឿងសក្ការៈ
បូជាថ្វាយដល់ព្រះម្ចាស់សួគ៌ជាដរាប ដើម្បីអង្វរករសូមឱ្យលោកជួយការ

តាវគ្រន់ ។ រួចព្រះអង្គ៌គ្រាស់ឲ្យពួកជាងចាប់ផ្តើមធ្វើជញ្ជាំងកំពែងជាថ្មី ។ កាលណាជញ្ជាំងបានហើយស្រេច ស្តេចបាត់ឲ្យមនុស្សជាច្រើននាក់ដើរយាមល្បាតជុំវិញកំពែង មើលកុំឲ្យមនុស្សណាមួយ ចូលមកជិតបាន ។ ពួកអ្នកយាមនាំគ្នាប្រតិបត្តិការ ចាប់តាំងពីពេលព្រលប់រហូតដល់ភ្លឺ ។ នៅពេលដែលអ្នកទាំងនេះរំពៃមើល ស្រាប់តែមានគ្រាប់អង្គរជ្រុះមកពាសពេញនៅចំពោះមុខរៀងខ្លួន ។

ព្រះច័ន្ទដែលរះឡើងតែមួយដួងកំពាប់លិចបាត់ទៅវិញ បណ្តាលឲ្យមហាមេឃងងឹតសូន្យសុង គួរឲ្យអស្ចារ្យណាស់ ។ ពួកអ្នកយាមល្បាតទាំងឡាយទៅចាំប្រុងឃ្លាំមើលសត្រូវដែលមកពីក្រៅ តុំហានសំពះកឡើយ ប៉ុន្តែ តាំងពីពេលនោះរហូតដល់ភាត់កណ្តាលអធ្រាត្រ គេគ្មានឃើញហេតុអ្វីផ្សេងខៀតសោះ ។ បន្តិចមក ទើបអ្នកទាំងនោះឃើញមេអាកែ្សដើរចូលមក ដៃកាន់ថាវមួយដែលមានគ្រាប់សណ្តែកពេញ ។ ពួកអ្នកយាម ហៀបតែនឹងស្ទុះទៅជះល្អីមយកថាវពីក់ ស្រាប់តែទៅតុំរួបហាក់ដូចជាជាប់ចំណងយ៉ាងម៉ាំ ដោយសារមន្តអាគមរបស់មេអាកែ្ស ។ អ្នកទាំងនោះ គ្រាន់តែអង្គុយទឹកឆ្ងល់គ្មានធ្វើអ្វីក៏បានឡើយ ។ ឯចន្លុះដែលពួកនេះកាន់ នៅតែឆះដង្កើលដដែល អាកែ្សចិត្តអាក្រក់ លូកយកគ្រាប់សណ្តែកមួយក្តាប់ពីកន្ធបាមក សាបទៅលើដីជិតជញ្ជាំងច្រាសាខ ។ គ្រាប់សណ្តែកទាំងនោះភ្លាក់ដល់ដីភ្លាម ក៏ក្លាយទៅជាហ្វូងមនុស្សតូច ។ មួយរំពេច មនុស្សនេះធំឡើងបន្តិចម្តងៗ ។ ក្លាយបានទៅជាទាហានមួយកង មានកាន់ចបត្រែសេះនឹងចបកាប់ជាគ្រឿងអាវុធ ហើយប្រជ្រៀតគ្នា

ឈរវៀបជួរតាមសណ្តាប់ ។ ពួកនេះដើរតម្រង់ទៅដល់ញាំងកំពែងប្រាសាទ
គ្មានឲ្យពួកសូរអ្វីសោះ តាមដោយសញ្ញាបស់គ្រូអាវ៉ែក្ស ។ ដល់ហើយ
ក៏តាំងគាប់គាស់រំលើងដញ្ជាំងឲ្យរលើងរលំគ្មានសល់ ។ អ្នកយាមល្បាត
ដែលមានសេចក្តីវន្ទត់ជាខ្លាំង ពុំអាចរត់បេញ ឬ ស្ទុះទៅទាំងខា ឬក៏ស្រែក
ដើម្បីឲ្យដំណឹងដល់អ្នកដទៃបានឮឡើយ ។ ពួកអ្នកយាមមិនបានដឹងថា
ពួកខាហានរបស់អាវ៉ែក្សធ្វើការយ៉ាងម្តេចខ្លះទេ ព្រោះមានសេចក្តីកិតក័យ
វន្ទត់ខ្លាំងពេក ។ ពួកខាហានគាន់បបកំរើកចុះឡើង ឥតឲ្យឮសូរបប
មួយក្រឹកឬមាត់មួយម៉ាត់ឡើយ បាក់ដូចមនុស្សគ្រេកាប់ទៅលើសំឡី ។ លុះ
គាស់រំលើងប្រាសាទ បានស្រេចហើយ អាវ៉ែក្សទាំងខាហានប្រមូលគ្នា
ដើរបេញទៅដោយឥតនិយាយនឹងឮគ្នាសោះ ដូចជាមានន័យខឿន
ពាត់ណាស់ ។ លុះគ្រាតែវាទៅដល់មាត់ព្រៃហើយ ទើបពួកអ្នកយាម
កំរើកខ្លួនរួច ហើយស្រែកឲ្យដំណឹងគេ ។

លុះដំណឹងអកុសល បានជ្រាបទៅដល់ព្រះកាល ។ កំទ្រង់អស់
សង្ឃឹមត្រឹមនេះ ។ ទ្រង់ព្រះចិន្តាទីឆ៍ះបង់ចីកន្ទែងនេះចោល ដើម្បី
ទៅរកកន្ទែងថ្មីទៀត ដោយប្រថ្នាថារកសន្តិសុខឲ្យបានពេញចិ ។

– សូមទ្រង់ព្រះមេត្តាប្រោស ព្រះករុណាទ្រង់ព្រះដំរែយ៉ាងនេះ
មិនត្រូវទេ (ក្រុមប្រឹក្សារបស់ព្រះអង្គក្រាបបង្គំទូល) ព្រោះអស់លោក
អ្នកតាបានចំទុកបំរុងចីនេះ ទុកឲ្យយើងតាំងពីត្រង់នាយមក ។ ត្រូវ
តែព្រះអង្គទំពួច ឲ្យតាល់តែសត្រូវចុះបាញ់ព្រះអង្គទៅវិញ ។

ព្រះកាលទ្រង់ព្រះដំរែថា ប្រហែលជាពាក្យបន់ស្រន់របស់ទ្រង់ ពុំ

ខាន់ចាន់ល្អហ្នាត់ចត់ទៅឡើយទេ ទើបទ្រង់យល់ព្រម ធ្វើតាមក្រុមប្រឹក្សា នេះ ចាប់ផ្តើមសាងប្រាសាទជាថ្មីម្តងទៀត ហើយមិនឈប់រៀបគ្រឿងសម្ភារៈបូជាដល់ខ្ពស់ជាមុនឡើយ ។ ទ្រង់តង់កាន្តាធម៌ ពេញរយៈបីថ្ងៃ សោយតែផ្លែឈើ, បន្លែស្រស់ ហើយតមមិនខុតមហាសីនីដ៏មិត្តភ័ក្តិសោះ ។

ល្ងាចថ្ងៃទី ៣ នៅវេលាព្រះអាទិត្យជ្រៀតហើយ ព្រះពជាចេញទៅគង់ត្រង់កើយព្រះដំណាក់តែមួយព្រះអង្គឯង ហើយទ្រង់បែរព្រះភ័ក្ត្រទ្លោះទៅខាងលិច តិនិត្យពណ៌មេឃដែលក្តឹត្រចះ ស្តេចបន់ស្រន់ព្រះពុទ្ធនីដ៏អស់រូបកាត ដែលធ្លាប់ធ្វើគុណដល់មនុស្សលោក ជាលើកក្រោយបំផុត ។ កន្លះពេលមួយរំពេចនោះ ស្រាប់តែទ្រង់ទតឃើញចំហាយមានពណ៌មាសនុះពីដីឡើងបន្តិចម្តង ។ ទៅលើមេឃ រួចក៏ក្លាយទៅជារាងមនុស្សមើលឃើញច្បាស់ ។ ឃ្លាបន្តិចមកទើបបង្ហាញឲ្យឃើញច្បាស់ជារូបតាចាស់ម្នាក់មានពុកមាត់សវែង ឈរលើពពក ចីដូចរូបចំឡាក់ឈរលើក្តារ ។ តាចាស់នោះ មានសំលៀកបំពាក់ពណ៌ក្រហម ដូចរនើកភ្លើង ។ ស្តេចទ្រង់ធ្វើលក្ខន៍ព្រះពជាយ៉ាងខ្ជាប់ខ្ជួន ទើបតាចម្លែកនេះ ។

– បពិត្រក័ត្រាធិពជ ភាគ្យបុណ្យសួគ៌ចេស្តាទ្រង់បានរាសាត់ទៅដល់ព្រះម្ចាស់សួគ៌ហើយ (តាចាស់ទូលស្តេច) ឥឡូវលោកប្រើឲ្យខ្ញុំមកការពារព្រះអង្គ ។ ខ្ញុំនេះឈ្មោះ"អណ្តើកមាស" ជាអ្នកតាចាំក្បែរមនុស្សស្លុតតែ ។

– តុលោកអ្នកតាដ៏មានបុណ្យ ! (ស្តេចមានព្រះពជទន្លាវ) ខ្ញុំមិន

ក្តៅគុណលោកខេ ខ្ញុំអរគុណលោកម្ចាស់ជាខ្លាំង ហើយចង់ឲ្យលោកម្ចាស់ចុះមកជួលទីជិតខ្លួនខ្ញុំនេះ ។

– ខ្ញុំដែលខ្លួលបន្តុកជាបំរើព្រះម្ចាស់សួគ៌នេះ មានចិត្តសប្បាយណាស់ (គាថាស់ជាអ្នកតាន់ឃាយ) ព្រោះខ្ញុំពេញចិត្តនឹងភាពរបស់ខ្លួន។

– ខ្ញុំពុំមានយល់ជាក់ ខ្លួរសេចក្តីសប្បុរសរបស់លោកម្ចាស់ យ៉ាងដូចម្តេចឡើយ សូមលោកមេត្តាធ្វើឲ្យខ្ញុំយើញជាក់នឹងភ្នែកខ្ញុំមើលសិនតើលោកអាចប្រាប់ខ្ញុំផងបានឬទេ ហេតុអ្វីបានជាជញ្ជាំងប្រាសាទដែលខ្ញុំសង់រួចហើយស្រេច បែរទៅជារលាយបាត់អស់ទៅវិញ?

– នេះគឺជាពួកបីសាច ដែលជាប់ប្រព្រឹត្តកម្មអាក្រក់ រាំបំផ្លាញកុំឲ្យព្រះអង្គគិតការនេះកើត ។ ប៉ុន្តែវាមុខតែនឹងទៅជាអ្នកខ្សាយឆ្ងល់ ហើយមានទុក្ខវេទនាទៅវិញ ។ សិល្បៈរបស់វាមិនអាចប្រគាំងនឹងព្រះចេស្តារបស់ព្រះអង្គបានឡើយ ។ សូមខ្លួនជាប់ផ្តើមធ្វើការនេះជាថ្មីទៀតទៅចុះកុំបីញាប់ញ័រតក់ឡើយសោះ ។ ដើម្បីនឹងបញ្ចាំចិត្ត ហើយដើម្បីជាសញ្ញាដល់មិត្តភាពរបស់ខ្ញុំ។ សូមថ្វាយក្រចកមាសនេះ ដែលអាចយកទៅធ្វើកែងបាន ។ របស់ប៉ោនីប្រសើរនេះ នឹងធ្វើឲ្យអាវុធរបស់ខ្លួនទៅជាពូកែស័ក្តិសិទ្ធិ ព្រួញមួយ។ អាចសម្លាប់សត្រូវមួយហ្វូងបាន ។ កាលបើវត្ថុនេះជាប់ទៅជាមួយនឹងក្រមព្រះអង្គហើយ ព្រះអង្គមុខតែបានល្បីព្រះនាមពុំលែងឡើយ ។

ពេលនោះ ក្រចកមាសក៏ផ្លាស់មកស្ថិតព្រះបាទព្រះអង្គភ្លាម ។ ព្រះរាជាខនរើសរបស់នេះយកមកពុក ។ កាលណាស្តេចនើបឡើងវិញ

អ្នកតានឹងពពក ក៏លោយថាត់បង់ទៅ ។ នៅខាងលិចផ្លូវមេយវែលមាន
ពណ៌ភ្លឺចែងចាំង ស្រាប់តែត្រឡប់ជាខៀវឡើងស្រទំ គ្មានអ័ព្ទ គ្មានចំហាយ
ស្តើងទៀត ។ ព្រះអង្គទ្រង់ទឹកស្នានថា យល់សប្តិ ឬមមើមមាយ
ឃើញរបស់ចំលែកនេះ ប៉ុន្តែទ្រង់ឈប់ស្នានទៀត ដោយថាឃើញ
ក្រចកអណ្តើក ដែលអ្នកតាថ្វាយនោះនៅជាប់នឹងព្រះហស្តព្រះអង្គយ៉ាង
ស្អែង ។ គ្មានលោយទៅណាទេ ទ្រង់មានអំណរនឹងដឹងគុណដល់ព្រះ
ម្ចាស់សួគ៌ ហើយទ្រង់លុតព្រះជង្ឃ ប្រណមក្រត់ទៅទិសដែលអណ្តើក
មាសបាត់នៅពីពេលមុននេះបន្តិច ។

– តុលោកអ្នកតាអើយ(ស្តេចមានបន្ទូលថា) ខ្ញុំសូមអរគុណដល់
លោក ជាបំរើនៃព្រះម្ចាស់សួគ៌ដ៏មានឫទ្ធិ ។ ស្អែកឡើង ព្រះពជាតាំង
រៀបចំធ្វើបុណ្យមួយយ៉ាងធំ ជាទីលឹក នឹងជាអំណរគុណ ដល់អ្នកតា
អណ្តើកមាស ។

ស្តេចបង្គាប់ឲ្យបណ្តាជននឹងពួកជាងសង់ប្រាសាទនៅទីក្រុងនេះ
ជាថ្មីម្តងទៀត គ្មានញ៉ាញ៉ីតអ្វីឡើយ ។ កិច្ចការទាំងឡាយធ្វើទៅបាន
ដោយស្រួល ឥតមានភ័យកជំពាស់ឡើយ ដោយសារអំណាចក្រចកអណ្តើក
មាសនោះ ។ គេបានទាំងសង់កំពែងបីជាន់ ដើម្បីខ័ណ្ឌប្រាសាទផង ។
ប្រាសាទនេះមានកងជួបជាសំបកគ្រំយ៉ាងធំ ហើយសន្ធឹងយ៉ាងវែងដោយ
ហេតុនេះបានជាគេឲ្យឈ្មោះ ថា "ប្រាសាទសំបកគ្រំ" ។

កន្ទងពីនោះមក បានរកងមួយឆ្នាំ ទីក្រុងនេះគេបានធ្វើហើយជា
ស្រេចសព្វគ្រប់ជួបប្រជុំ ។ មានមនុស្សម្នាមហាជនកុះករបិតនៅក្នុង

សេចក្តីសុខក្សេមក្សាន្ត គ្មានឧបស័គ្គអ្វី មកបៀតបៀនខ្វែតឡើយ ។ ស្រូវអង្កររឹងមឺងផលដំណាំផ្សែង ។ សម្បូរហិរញ្ញវត្ថុ ។ ដូច្នេះ ព្រះបាទអាន់យ៉ឿង បានសោយរាជ្យសម្បត្តិ ដោយសុខសម្រាន្តតាមស័ព្ទសាធុការពររបស់ព្រះម្ចាស់សួគ៌ ។ ក៏ប៉ុន្តែ មិនមែនបានសុខហូតតរៀងតមានហេតុអ្វីសោះនោះទេ គឺតែមានស្តេចមួយព្រះអង្គព្រះនាម "ខ្វៃយ៉ា" សោយរាជ្យនៅប្រទេសចិន គិតបង្កើតទំនាស់មួយដំ មកវាយនាព្រះបាទ "អាន់យ៉ឿង" ដែលធ្លាប់បានសេចក្តីសុខជាជាន់ខ្លួន ។ អំពើអាក្រក់នេះ តើមកពីសេចក្តីញុះញង់របស់មេអាក្សែ ។

ខណៈព្រះបាទអាន់យ៉ឿង មានព្រះទ័យចង់ធ្វើចម្បាំងជាយូរមកស្រាប់ហើយ ព្រោះចង់សាកល្បងរបស់ទ្រង់មើល លុះឃើញស្តេចចិនណាត់ពេលឲ្យទ្រង់យាងទៅធ្វើចំបាំង, តទល់នឹងទំនាស់ដូច្នេះ ព្រះអង្គគ្មានគំនុំគុតព្រះទ័យចន្ទិចសោះ ត្រឡប់ជាត្រេកអរទៅវិញ ។

ព្រះបាទ "ខ្វៃ-យ៉ា" បានរៀបចំគ្រឿងចំបាំងយ៉ាងសម្បើមអស្ចារ្យ ដោយលាក់លៀមពុំឲ្យអ្នកប្រទេសជិតខាង ជ្រាបដឹងឡើយ ។ ចំណែកឯព្រះបាទ អាន់-យ៉ឿង វិញ គាំងតែពាក្យបានក្រចកមាសមកតាលណា ស្តេចមិនដែលបានរៀបចំ ប្រមូលទាហានឲ្យមកហាត់ការចំបាំងសោះ ដោយអាងថាជាអំណាចរបស់ព្រះម្ចាស់សួគ៌ ។ ពួកទាយទាហានរបស់ព្រះអង្គ គាល់ដឹងថាចំបាំងមកដល់ហើយ ក៏មានសេចក្តីញាប់ញ័រខ្លាតែពាល់ខ្លួន ព្រោះស្តេចពុំបានប្រកាសជ្រាបដល់អ្នកទាំងនោះថា ទ្រង់ទុកព្រះទ័យលើរបស់អ្វីឡើយ គ្រាន់តែជ្រាប់ថា ពួកយើងមុខតែ

ឈ្នះសត្រូវជាពុំខាន ។ ពួកនាយទាហានប្រមូលគ្នាចេញពីបន្ទប់ ហើយស្រែកហៅគ្នាឲ្យរៀបគ្រឿងសស្ត្រាវុធ ចេញទៅធ្វើសង្គ្រាម ។ អ្នកទាំងនេះ រត់ប្រជ្រៀតគ្នាចេញតាមមាត់ទ្វារ ដោយមានចិត្តមុខបែបភ័យខ្លាំង ។ ព្រះពជបុត្រីឮដំបៅរបស់ព្រះអង្គឃើញដូច្នោះ ក៏រត់ទៅទូលព្រះវរបិតា ពាំនាំមានព្រះអស្សរួដលហូរហាមផង ។ ព្រះពជធីតានេះ មានព្រះជន្ម ១៦ ឆ្នាំ ឫកពាសមមៀ ព្រះកត្តិនីព្រះកាយល្អឥតខ្ចាស់ មានព្រះទាមថា " ម៉ី.ចូ " ដែលប្រែមកថា ពេជ្រល្អកពុំបាន ឬថាពេជ្រស្អូតត្រង់ ។ ព្រះពជបិតាទ្រង់សព្វព្រះពជហឫទ័យទីនព្រះនាងជាខ្លាំង លុះខេតឃើញព្រះនាងបង្ហាញភ័ក្ត្រដែបភ័យខ្លាំង ក៏ទ្រង់ញញឹមទៅរកព្រះនាង ដើម្បីឲ្យព្រះនាងឈប់ភ័យ រួចទ្រង់បន្ថែបការស្ងាត់កំបាំងរបស់ព្រះអង្គឲ្យព្រះនាងជ្រាប ថែមទាំងយកក្រចកអណ្តើកមាស មកបង្ហាញទៀត ហើយមានព្រះបន្ទូលថា " យើងមុខជាមានជ័យជំនះ ដោយសារវេបនេះមិនខាន ចូរកូនកុំភ័យថាអ្វីឲ្យសោះ " ។

ភ័ក្ត្រព្រះនាង ដែលមានចិត្តព្រះនេត្រហូរហាម ក៏ត្រឡប់ទៅជាញញឹមពន្លាយទៅវិញ ។ ព្រះនាងយកទ្រាមព្រះហស្តទៅកាន់អង្គែលក្រចកមាសនោះ ហាក់ដូចជាក្មេងតូចដែលគេបើកអំណាចឲ្យកាន់ អង្គែលលេងរបស់ដ៏មានជម្លៃដែរ ។

ព្រះនាងសើចលេងសប្បាយឥតឧបមា ។ ស្តេចមិនខុសបេះនេះ ឲ្យបុត្រីលេងជាយូរពេលខ្លះ ទ្រង់យកក្រចកមាសពីព្រះពជបុត្រីវិញ ព្រោះខ្លាចបែកការនេះ ខ្លួនឯងដល់អ្នកដទៃ ។ ព្រះអង្គទ្រង់ហាមប្រាមព្រះនាងថា:

-បួរនាងកុំនិយាយការនេះប្រាប់អ្នកណាទៀតឲ្យសោះ ពោះជាមាតា នាងក៏មិនត្រូវឲ្យដឹងដែរ ។

ព្រះពជបុត្រីប្រគល់ព្រះត័ក្រគ្រាម ហើយទូលតបថា:

-ខ្ញុំម្ចាស់មិនថាញ្ចេញរឿងហេតុនេះ ដល់អ្នកណាសោះឡើយ បើព្រះវរបិតាពុំដឿឹកូនទេ កូនហ៊ានសច្ចថា: សូមឲ្យលោកអ្នកតាទឹងអស់លោកឯណា ដែលមានបុទ្ធិដ្ឋយចាំពាក្យខ្ញុំម្ចាស់នេះចុះ ។ បើកាលណាខ្ញុំម្ចាស់បញ្ចេញការនេះឲ្យគេដឹង សូមឲ្យលោកអ្នកមានបុទ្ធិទាំងនោះ ផ្តាច់ជីវិតខ្ញុំម្ចាស់ ដោយព្រះខ័នពជ្ឈរបស់ព្រះបិតាចុះ ។

គ្រានោះ ស្តេចយាងចេញនាំកងទ័ពឆ្ពោះទៅទីសមរភូមិ ។ ព្រះនាងធ្វើទឹកព្រះភ័ក្រញញឹមទៅរកព្រះបិតា ដោយព្រះនាងមានសង្ឃឹមច្រើនថា ព្រះបិតាព្រះនាងមុខជាទឹងជ័យជំនះពុំខាន ។

មិនខុសទេ ក្នុងចំបាំងលើកនេះ ថ្វីបើខាងទ័ពស្តេចចិនមានគ្រឿងប្រដាប់យ៉ាងចំណាន ទ័ពនេះក៏ទៅតែចាញ់ទ័ពព្រះបាទ"អាន់ យឿង" ជាដរាប ។

រឿងជ័យជំនះនេះ មកតែពីអំណាចនៃឆ្នូសព្រះម្ចាស់សួគ៌ ។

ព្រះបាទ"ទៀវ-យ៉ាំ" ជ្រាបថា ទប់ទល់ទឹងគេពុំឈ្នះក៏ដកទ័ពថយ ហើយទ្រង់ព្រះតម្រិះថា ថ្ងៃណាមួយទឹងសង្ឃឹកសិត្រូវវិញពុំលែងឡើយ។ ព្រះពជតម្រិះនេះឥតអំពើសោះ ព្រោះព្រះបាទ"ទៀវ.យ៉ាំ" រកមធ្យោបាយទឹងទៅផ្តន្ទាព្រះបាទអាន់-យឿងភ្លាមពុំបាន ។

តមក ព្រះពជាទាំងពីរគង្គ កំស្រុះស្រួលគ្នាលែងធ្វើចម្បាំង ហើយ

សុំគ្នាធ្វើជាមិត្ត ។ ថ្ងៃមួយព្រះបាទ "ខៀវ-យ៉ាំ" បញ្ជូនព្រះពជបុត្រាមួយព្រះអង្គព្រះនាម "ព្រុន-គុយ" ឲ្យទៅនគរស្តេចសម្ព័ន្ធមិត្ត ដើម្បីថ្លែងមិត្តភាពឲ្យបានជាក់ស្តែងឡើង ។ មុនទីឯបញ្ជូនព្រះពជបុត្រឲ្យចេញពីនគរ ព្រះអង្គមានព្រះទន្ទ្រាវផ្តែផ្តាំថា:

ចូរបាស្សាថចំពោះព្រះអស្សាគា-អយ្យិកាយើងថា ទីឯសឯសឹកសត្រូវយើងវិញជាដរាប ។ ត្រូវអ្នកនិះកេ។ បាយបៃបណា ដើម្បីកេឲ្យឃើញរបស់យ៉ាំងចំឡែក ដែលនាំឲ្យព្រះបាទ "អាន់-យឿង" មានជ័យជំនះនោះ ព្រោះរបស់នេះគេលាក់លៀម ដោយស្ងាត់កំបាំងណាស់ ។ ព្រះបាទ "ខៀវ-យ៉ាំ" ឈប់បន្តិច ទឹកមុខដល់តាវដែលកើតមានឡើង ក្នុងពេលចំបាំង ។ ក្នុងព្រះទ័យក្តៅឈួលមួយរំពេច ហាក់ដូចជាគេយកដែកដុតក្រហមឆ្នូនមកសៀតសឹកក្នុងព្រះឧកព្រះអង្គ ។ ព្រះនេត្រពាំងគួ បញ្ចេញឲ្យឃើញថាមានព្រះក្រោធខ្លាំងណាស់ ។ ព្រះពជបុត្រនៅតង់ស្ងៀមចាំស្តាប់បន្ទូលព្រះបិតា ដែលមានព្រះទន្ទ្រាវតទៅទៀត :

- ការដែលបិតាបញ្ជូនកូនឯងឲ្យទៅនេះ គឺដោយសារចង់ឲ្យកូនឯងរៀបចំទុនប្រុងទីឯសឯសឹកសត្រូវយើង ហេតុដូច្នេះ ចូរអ្នកស្តាប់ឲ្យបិតាម្តងទៀត ។

- ខូលបង្គំទីឯប្រតិបត្តិតាមព្រះទន្ទ្រាវរបស់ព្រះបិតា ដើម្បីតតាំងទីឯសត្រូវ ឲ្យបានជ័យជំនះដូចប្រាថ្នា (ព្រះពជបុត្រតប) ។

- បើឯងក្មេងពាក្យស្តាប់នេះ ឯងទីឯទៅជាមនុស្សក្បត់ជាតិទីឯស្តាប់បិតាផង ។

-សូមព្រះវរបិតាពុកព្រះចិត្តាលើកូនចុះ ក្រាបខ្លួលតែប៉ុណ្ណោះ តំ
ក្រាបថ្វាយបង្គំណាព្រះបិតា ចេញសំដៅទៅនគរព្រះពជសម្ពន្ធមិត្រ
លុះដល់ហើយ ព្រះបាទ អាន់-ហ្សឺង ទទួលព្រះពជកុមារដែលជាព្រះពជ-
បុត្រ សត្រួចាស់ហើយផ្ទាស់ប្រែជាមិត្តនោះដោយពាក់ពាក់ ទ្រង់សព្វព្រះ
ទ័យនឹងព្រះអង្គម្ចាស់នេះណាស់ ទ្រង់ឃាត់ឲ្យនៅក្រសាលក្នុងនគរព្រះអង្គ
ជាយូរថ្ងៃ ។

ព្រះអង្គម្ចាស់ (ទ្រុង-ធុយ) តាំងពីមកដល់ប្រទេសនេះគាលណា
ចេះតែលួចគយគន់មើលព្រះនាង "ម៉ី-ចូវ" ជារឿយ ។ ប៉ុន្តែមិនដឹង
ធ្វើម្តេច ឲ្យបានជួបនឹងព្រះនាងក្នុងពេលស្ងាត់ ។ ឯព្រះនាង ម៉ី-ចូវ ក៏ចេះ
តែរំពៃចិត្តក្នុងព្រះទ័យ ព្រោះយល់នេត្រវបស់ព្រះអង្គម្ចាស់ ដែលចោល
មកលើរូបនាងជាញឹកញាយ, ហើយដោយសារឃើញព្រះអង្គម្ចាស់
ទ្រុង ធុយ មានព្រះរូបឆោមស្អាតបាត ឫកពាសមរម្យ ពាក្យជាបុត្រ-
ក្សត្រ ។ ចំណែកព្រះពជាវិញ ក៏មានព្រះទ័យចង់លើកព្រះពជបុត្រី
ឲ្យធ្វើជាអគ្គមហេសីព្រះអង្គម្ចាស់នេះដែរ ។

ថ្ងៃមួយកិច្ចអភិសេកសមរស[1]រវាងព្រះនាង ម៉ី-ចូវ នឹងព្រះអង្គ
ម្ចាស់ ទ្រុង-ធុយ ក៏កើតមានឡើងយ៉ាងអ៊ឹកធឹក ។ ព្រះវរបិតារីក
ចម្រើនជាខ្លាំង ដោយឃើញគូ បុត្រា-បុត្រីថ្មី នេះសមគ្នាឥតខ្ចោះ ។

ព្រះនាងម៉ី-ចូវ សព្វព្រះទ័យនឹងព្រះស្វាមីរបស់ព្រះនាងណាស់ ។
កិច្ចការនានាព្រះនាងមិនសូវលាក់នឹងព្រះអង្គម្ចាស់នេះទេ ព្រោះព្រះនាង

---

១ អភិសេកសមរស គំរៀបចំដង្ហែលការស្តេច មានពិធីប្លែកអំពីការអភិសេកសោយរាជ្យ ។

ពុកព្រះស្វាមី ដូចជាថ្វើមប្រមាត់នៃព្រះនាង ។

ល្ងាចមួយ ព្រះអង្គម្ចាស់ទ្រង់ទតឃើញឆ្នូសរនៅជិតព្រះនែនរបស់ព្រះពជសសុរ:(១)ទ្រង់សួរព្រះមហេសី ពីរឿងកំណែនៃឆ្នូសរនេះ ។ គាលនោះ ព្រះនាងដែលធ្លាប់តែពុកព្រះឆ្អែងលើព្រះស្វាមី ក៏ឆ្លើយទូលរឿងកំណែឆ្នូសរនោះ តាមការណ៍ដែលព្រះនាងបានជ្រាប ។ ព្រះនាងក្មេចគិតដល់ពាក្យសច្ចា ដែលបានធ្វើនៅចំពោះព្រះភ័ក្ត្រព្រះបិតារបស់ព្រះនាង ។ បន្តិចមក ទើបព្រះនាងនឹកភ័យជាក្រោយ តែព្រះនាងគិតថា រូបស្វាមីក៏ដូចជារូបព្រះនាងដែរ; ព្រោះពេលនេះ ព្រះអង្គម្ចាស់បានមករួមសុខទុក្ខជាមួយគ្នាហើយ គ្មានហេតុអ្វីមកធ្វើឲ្យព្រះវរបិតាខាំងពីរមានរឿងខាស់សាហេតុនឹងគ្នាទៀតទេ ព្រះស្វាមីមិនមែនហ៊ានកេរឿងច្បាំងនឹងព្រះបិតាឡើយ ។

ក្រោយមក ស្រាប់តែមានបំរើពីនគរស្ដេច ខៀវយ៉ាំ មកទូលព្រះអង្គម្ចាស់ទ្រង់-ធុយថា: បិតារបស់ទ្រង់ មានព្រះពេគជាខ្លាំនសូមឲ្យទ្រង់យាងទៅជាប្រញាប់ ។

ព្រះអង្គម្ចាស់ទ្រង់ ធុយ បានឮដំណឹងថ្មីនេះភ្លាម ទ្រង់គាំងរៀបចំព្រះអង្គដើម្បីទទឹងចាកចេញពីទីក្រុងនេះ ។

ព្រះនាងដែលមានព្រះដន្ដតិចនៅឡើយ ព្រះភ័ក្ត្រគ្រៀមក្រម ទឹកភ្នែកហូរហាម ចង់ទៅតាមព្រះស្វាមីដែរ ។ ប៉ុន្តែព្រះអង្គម្ចាស់ពុំចង់ឲ្យព្រះនាងទៅតាមឡើយ ទ្រង់លួងលោមព្រះនាងថា:

---

១ អានថា ស័ក-សុ-រ័ក ព្រះបិតាក្មេក ។

- នាងមិនអាចធ្វើដំណើរទៅដោយគ្រែស្នែងបានទេ ហើយបើសិនជាបងឲ្យនាងទៅផង ដំណើរបងនឹងរឹតតែយឺតយូរទៅទៀត ។ ចូរនាងដឹងថា ព្រះបិតាបងប្រឈួនខ្លាំងណាស់ ហើយត្រូវបងទៅដោយរួសរាន់ឲ្យទាន់ពេល ។

- ដើម្បីកុំឲ្យបែកឪម្ចាស់បង (នាងតប) ខ្ញុំម្ចាស់ត្រូវតែដឹះសេះតាមទៅដែរ ។

ព្រះអគ្គម្ចាស់គ្រវីព្រះកេសបែបគ្រាមព្រះទ័យ ។

- ម្ចុនអើយ នៅគេលដែលយើងនឹងបែកគ្នានេះ រឿមមានពុក្តជាខមួន់ណាស់ នៃព្រលឹងបងអើយ ចូរនាងដឹងថា បងស្រឡាញ់នាងហ៊ានប្តូរជីវិត មិនយូរទេ បងនឹងមករកវិញ ក្នុងពេលតាប់ ។ នេះព្រះអគ្គម្ចាស់នៅស្ងៀមបន្តិច ទើបមានព្រះបន្ទូលតទៅទៀតថា ;

- ព្រៃនាសនាវបស់ប្រទេស ចានសុខសាន្តត្រាណ ឬ មានបម្លាំងក៏មកតែពីទំនើងព្រះទ័យរបស់ព្រះម្ចាស់សួគ៌ មិនមែនតាមតែចិត្តមនុស្សលោកទេ ។ យើងគង់តែនឹងចានជួបគ្នាវិញមិនខាន ឲ្យតែព្រះម្ចាស់សួគ៌ជួយគ្រប់គ្រងចុះ យើងមិនមែនជួចវិសាងដើងនឹងខាងស្លួង ដែលនៅឃ្លាតឆ្ងាយពីគ្នាជាមិនខ្លះទេឡើយ ។ វិសាងដើងនឹងខាងស្លួងឃ្លាតឆ្ងាយពីគ្នាដូច្នេះ តើនាងអាចពន្យល់បងថា មកពីហេតុអ្វី ចានដែរឬទេ ។

ហេតុនេះគឺមកតែពីទំនើងចិត្តព្រះទ័យព្រះម្ចាស់សួគ៌ (នាងឆ្លើយ) ។

-អើបើដូច្នេះ យើងមិនត្រូវព្រួយពេកទេ យើងគង់តែចានជួបគ្នាវិញជាជាច់ខាត ។ ណ្ហើយចុះ បើម្ចុនមិនស្អប់ខ្ពើមបងទេ បងសូមផ្តាំថា បើ

សិនជាប្អូនត្រូវចាកចេញពីក្រុងទៅ ដោយប្រការយ៉ាងណា សូមប្អូនកត់
របស់អ្វីដែលអាចធ្វើឲ្យបងចំណាំផ្លូវទៅតាមប្អូនបានផង ។

-ទូលបង្គំមិនចេញពីក្រុងនេះ ៧ មុនពេលម្ចាស់បងត្រឡប់មកវិញទេ
តែបើម្ចាស់បងចង់ឲ្យទូលបង្គំធ្វើដូច្នេះ គឺពុំអ្វីដែរ ព្រោះខ្ញុំម្ចាស់មានអាវ
ស្វាបក្លាន១មួយ ប្អូនសូមសន្យាថា បើប្អូនចាកចេញទៅ ប្អូននឹង
ដកស្វាបក្លាននេះ ឥតអាវជាក់ទៅត្រង់កន្ទេងផ្លូវបែក ដើម្បីជាសញ្ញាសម្រាប់
បង្ហាញជានរបស់ប្អូន ។

-ចំណែកបងវិញ សូមសន្យាទីនប្អូនថា កន្ទងជាតិនេះ បើបងមិនបាន
ជួបនឹងប្អូនវិញទេ បងមិនសុខចិត្តរស់នៅតទៅទៀតឡើយ ។

ព្រះអង្គម្ចាស់ ទ្រង់-ទុយ លុះបានត្រាស់យ៉ាងនេះហើយ ស្រាប់តែទឹក
ឃើញដល់ពាក្យសម្បថចំពោះព្រះអយ្យកោ-អយ្យិកា ទីនព្រះបិតាខ្លួន
ទើបទ្រង់រលាស់ព្រះហស្ត ឥតាត្តព្រះនាង « ម៉ី.ជូ » ហើយយាងចេញទៅជាប្រញាប់ ។ ព្រះអង្គម្ចាស់លួចយកបានភាំងក្រចកមាសឪព្រះបិតាក្មេកទៅធ្វើកែងមរបស់ខ្លួនផង ហើយធ្វើកែងមួយថ្មីឲ្យមានតាពដូច របស់ព្រះបិតាក្មេកទុកនៅកន្ទេងដដែលវិញ ។ ទៅពេលខោះ គេឮសូរសេះផាយអបខំហឺន ។ មិនយូរប៉ុន្មាន ព្រះអង្គម្ចាស់ក៏បានយាងទៅដល់ទីនគរព្រះវរបិតា, ឯព្រះបាទ ខៀវ យ៉ា គង់ជាសុខស្រួលតាមធម្មតា ឥតព្រះកេតអ្វី បៀតបៀនព្រះអង្គឡើយ ។

ទូលព្រះបង្គំបានតាន់សំដីទៀងតាត់ទាំងពោះព្រះវរបិតាទីនព្រះអយ្យកោ-អយ្យិកាហើយ (ព្រះអង្គម្ចាស់ ទ្រង់ ជុយ ទូល) យើងមុខ

ជាមានជ័យជំនះមិនខាន ។

- បិតាគេញញែកគ្នាណាស់ ហើយដោយបានឃើញថាមកដល់ថែមទាំងយកបានរបស់ដែលមានឫទ្ធិមកផង ។

- ខ្ញុំលព្រះបង្គំធ្វើតាមបង្គាប់ព្រះបិតានេះ ដោយមានទុក្ខវេទនាជាខ្លាំងបំផុត ។ ខ្ញុំលព្រះបង្គំសូមអង្វរព្រះបិតាថា កុំឲ្យយករបស់នេះទៅប្រើក្នុងការសង្គ្រាមសត្រូវយើងធ្វើអ្វី ។ ព្រះបាទ អាន់-យ៉ឿង មិនមែនជាសត្រូវនឹងព្រះបិតាទេ, ស្តេចសព្វព្រះរ័យលើកខ្ញុំលព្រះបង្គំដូចព្រះរាជបុត្របង្កើតរបស់ព្រះអង្គដែរ ។ នៅវេលានេះ ខ្ញុំលព្រះបង្គំបានធ្វើរំលោភលើព្រះអង្គ ដោយសារតែធ្វើតាមព្រះរាជបញ្ជារបស់ព្រះបិតា ។ ម្យ៉ាងទៀត ខ្ញុំលព្រះបង្គំ មានសេចក្តីស្នេហាលើរូបព្រះរាជមុត្រីព្រះបាទ អាន់-យ៉ឿង នេះជាខ្លាំង ។ ខ្ញុំលព្រះបង្គំបានផ្តាច់សេចក្តីស្នេហាដោយសារតែលាក់ការស្ងាត់កំហាំងរបស់ព្រះបិតា ទើបស្តាប់បង្គាប់ព្រះបិតា; ប៉ុន្តែខ្ញុំលព្រះបង្គំ មុខតែត្រឡប់ទៅជួបនឹងមហេសីរបស់ខ្ញុំលព្រះបង្គំវិញពុំបានឡើយ ។

ព្រះបាទ ខៀវ-យ៉ាំ គង់នៅស្ងៀមទុកឲ្យព្រះរាជបុត្រព័ន្ធភ័ជាំដំណើរហេតុឲ្យដឹង ។ ព្រោះតែលោះ សេចក្តីក្រេវក្រោធមកបំពេញក្តីត្រេកត្រអាលនឹងសេចក្តីក្រោធ ។

- បើគុណបុណ្យព្រះអយ្យកោ-អយ្យិកាបើនឹងជួយយើងឈ្នះ ខ្ញុំនឹងអ្នកមុខតែនឹងបានត្រេកត្រអាលនៅឯណាពុំខាន ហើយនឹងបានជួបមហេសីវិញដែរ បិតាមិនមែនបំបែកបំបាក់កូនឯងទេ ចូរកូនយល់ថា ព្រះបាទ

អាន-យឿង ដែលធ្លាប់ធ្វើអំពើអាក្រក់ដល់បិតា ថ្ងៃណាមួយគង់តែនឹងធ្វើអំពើអាក្រក់នោះដល់អ្នកឯទៀតជាមិនខាន មានកូនឯងដែរ, កូនឯងមិនត្រូវអាណិតដល់ស្តេចនោះទៀតទេ, ឯមហេសីអ្នកក៏គង់តែស្តាប់បង្គាប់បិតាគេ ហើយធ្វើបាបអ្នកដូចជាអ្នកស្តាប់បង្គាប់បិតា ហើយធ្វើបាបនាងផ្កូវច្នេះដែរ, ចូរអ្នកកុំស្រែណោះមហេសីពេក, ។ មិនយូរប៉ុន្មានព្រះបាទខៀវ-យ៉ា ក៏ឲ្យដំណឹងទៅស្តេច អាន-យឿង ថា ឲ្យលើកទ័ពមកច្បាំងគ្នា។ កាលបើដំណឹងនេះបានទៅដល់ព្រះបាទ អាន-យឿង ។ ទ្រង់មានព្រះវិតក្កយ៉ាងខ្លាំង ។

- យ៉ា! យ៉ា! ខៀវ-យ៉ា (ស្តេច អាន-យឿង ភ្ញាក់មាត់) ម្តេចក៏ក្មេចគិតដល់ធ្នូសរយ៉ាងខ្លាំងពូកែរបស់យើងហើយហ្ន៎! ។ ល្អើយចុះ អញគិតធ្វើវា ម្តងនេះ ឲ្យទូបខ្ចាចលែងហ៊ានកេរឿនទំនងអញតទៅទៀត ។

កាលនោះព្រះនាង ម៉ី-ជូ សោកសង្រេកជាខ្លាំង ព្រោះព្រះនាងគិតថា ស្វាមីមុខតែលែងបានដួចទឹងព្រះនាងវិញហើយ ។ លុះព្រះនាងទឹកឃើញធ្នូសរដ៏មានឫទ្ធិរបស់ព្រះបិតានាង។ ក៏អន់ព្រួយបន្តិចទៅវិញ ។ ព្រះនាងគ្មានសង្ស័យថា ព្រះស្វាមីលួចក្រចកមាសរបស់ព្រះបិតានាងទៀយ ។ ឯស្តេចជាព្រះវរបិតាក៏តុំស្មានថា ព្រះពជ្រត្រីឆ្លាយគំនិតប្រាប់សេចក្តីស្វាត់កំបាំងដល់ព្រះពជ្រសុណិសានោះដែរ ។ ព្រះមហាក្សត្រទឹងព្រះពជ្រជីតាខាំងពីរអង្គ ចេះតែមានសង្ឃឹមទៅលើធ្នូសរមួយមុខប៉ុណ្ណោះដូចគ្នា ។

ព្រះបៅ អាន-យឿង ស្តេចចេញទៅធ្វើជាប្រមុខនៃកងទ័ព ដើម្បី

ទឹងធ្វើសឹកសង្គ្រាម ដែលទ្រង់សង្ឃឹមជាទីបំផុត ទឹងមានជ័យ ។ សេចក្តីសង្ឃឹមនេះខុសស្រឡះ ព្រោះកងទ័ពខាងព្រះបាទអាន់-យ៉ឿង ចេះតែចេញប្តូរបន្តិចម្តងៗ ។ មិនយូរប៉ុន្មាន ស្តេចត្រាំទឹងសត្រូវពុំបានតំកៀសព្រះអង្គឲយត្រាយត្បែ ។ ពេលនោះ សត្រូវគាន់តែដេញរុកចូលទៅជិតដល់ព្រះរាជកំនល់របស់ព្រះអង្គ ។

ឯព្រះអគ្គមហេសី, ព្រះរាជបុត្រី, ព្រមទាំងពពួកស្រីស្នំរត់ចេញពីប្រាសាទ ដើម្បីទៅគាំទ្រព្រះរាជជំណាក់មួយទៀត នៅឯទិសខាងតើក ព្រោះដឹងថា សត្រូវចូលមកជិតដល់ហើយ ។

ពួកកងទ័ពខាងស្តេច ខ្លៅ-យ៉ោ គិតថា បើស្តេចនគរនេះកៀសខ្លួនបាត់ទៅ យើងអាចយកទ័ព្រទ្រង់ចាន់ដោយងាយ ហើយចម្បាំងក៏ទឹងអស់តែត្រឹមគ្រានេះ ។

ពេលនោះ គេឃើញស្រី ១ រត់ប្រញាប់ប្រញាល់ អ្នកខ្លះបានត្រឿងចំឡាក់ដាំពេជ្រ ទឹងត្រឿងមាសយកទៅតម់លាក់កងដី ព្រោះមិនហ៊ានយកទៅជាមួយនឹងខ្លួន ខ្លាចសត្រូវកេរយដណ្តើមយក ។

ហេតុនេះ ទ័ព្រទ្រង់មានមនុស្សរត់ប្រជ្រៀតគ្នាចុះឡើង ប៉ះដួចស្រមោចកវរចេញពីវត្ត ។ រីឯម្ចាស់ក្បួត្រ "ម៉ី-ចូវ" តុំព្រមរត់ចេញទៅណាសោះ ស៊ូតែនៅចាំព្រះរាជកំនល់មួយអង្គឯង ។

ស្រែកឡើង ព្រះចាវ អាន់-យ៉ឿង បាត់ជ័យហើយ តំយាងដោយព្រះទីនាំងភាដ៏ តាត់ទ័ព្រទ្រង់ដែលស្ងាត់សូន្យឈឹង ។ ក្រុងទៅដល់មុខព្រះរាជកំនល់ហើយ ស្តេចចោលព្រះនេត្រទៅ ស្រាប់តែឃើញព្រះរាជ-

បុត្រីដែលតនឹងទៅស្ងៀម ហាក់រងំចាំព្រះអង្គ ។

ព្រះនាង ម៉ី-ចូ សុះត្រង់ទៅរកព្រះអង្គភ្លាម ។ ព្រះបាទ អាន់-យឿង ទតឃើញហើយក៏បញ្ឈប់ពាជី លើកព្រះកដម្រុត្រីជាក់លើកែបពីក្រោយ ព្រះអង្គ ហើយបំផាយអស្សពាជីយ៉ាងលឿនត្រង់ទៅមុខ ។ កាលនោះ ម្ចាស់ក្សត្រីបានយកអាវស្បែកក្លែនទៅជាមួយដែរ ។ ព្រះនាងបោចស្បែកមួយម្ដង ។ ចំណាត់ហែតាមផ្លូវ ដើម្បីជាសញ្ញាប្រាប់ព្រះស្វាមីឲ្យតាមរកនាង ។ ព្រះនាងមិនបានខឹកឃើញថា អំពើនេះជាកិច្ចក្សត់ខឹងព្រះបិតានាងជាលើកទីពីរទេ ។ ព្រះបាទ-អាន់ យឿង បំផាយសេះឥតឈប់ រហូតទៅដល់មាត់សមុទ្រ ។

ខណៈវេលាព្រះអាទិត្យខេទន់ភាបទៅទិសបស្ចឹមហើយ មានស្មៅបៃតងចាំង គ្របដណ្ដប់លើផ្ទៃទឹកសមុទ្រធំធេង ។ ពាជីព្រះទីនាំងឈរឈប់ស្ងៀម ដោយរាងអស់កំឡាំងក្រៃពេក ។

- ព្រះម្ចាស់សួគ៌ប្រហែលជាព្រះអង្គលះបង់ខ្ញុំចោលទៅពេលនេះហើយ (ស្ដេចមានព្រះពាក្យទន្ទឹងត្អូញត្អែ) ឧលោកអ្នកបំរើព្រះម្ចាស់សួគ៌ដ៏មានបុណ្យអើយ សូមលោកមេត្តាមកជួយដោះខ្ញុំក្នុងទុក្ខដ៏ធង តម្រិតសត្រូវតាមមកជិតគាន់ហើយ ។

ពេលនោះ ទឹកសមុទ្រផ្ទួលឡើងហាក់ដូចជាបេះធ្លើយតបនឹងព្រះអង្គ ។ មួយរំពេច ស្រាប់តែមានអណ្ដើកធំមួយ ផុះចេញមកលើផ្ទៃទឹក ។ សូកអណ្ដើកនេះមានពណ៌ដូចមាសភ្លឺផ្លេក។ ដោយខ្នងវិថ្ម ។ ស្ដេចគ្មានតក់ស្លុតរន្ធត់ខឹងអណ្ដើកមាសនេះសោះ ត្រឡប់ជាមានព្រះពាក្យតិច ។ ថា:

-ទ្រង់ព្រះសណ្ដាប់ដូច្នេះហើយ ស្ដេចកំរៃព្រះភ័ក្ត្រទៅខាងក្រោយភ្លាម ឥតឃើញមនុស្សណាម្នាក់សោះ គាំងតាក្រោយសោះហុតទៅដល់ដើងមេឃ ដែលខ្លាចសន្ធឹម, យល់តែព្រះពជបុត្រី ដែលជាទីសព្វព្រះទ័យរបស់ព្រះអង្គ ស្ដេចទ្រង់ឈ្លេងយល់ការណ៍ភ្លាម កំហូតព្រះខាន់ពស្ប ដើម្បីសម្ងាប់ព្រះខាង ម៉ៈ-ចូវ៉ា ចោល ។ ព្រះពជបុត្រីយល់អាការបំណងព្រះបិតាដូច្នេះហើយ ក៏តាំងសច្ចាថា:

- បើប្រសិនជាចិត្តខ្ញុំស្មោះត្រង់ចំពោះព្រះបិតាខ្ញុំពិតមែន សូមឲ្យឈាមខ្ញុំក្លាយទៅជាគ្រាប់ពេជ្រដ៏មានជម្ងៃ ក្រោយពេលដែលជីវិតខ្ញុំក្ស័យទៅហើយ ។

ព្រះខាងស្ងប់ដូច្នេះចប់ ព្រះខ័នពស្បកំភ្លាក់ទៅត្រូវព្រះខាងភ្លាម ។ ខ្លួនព្រះខាងដួលដេកស្លុកស្ដឹង លើដីឡប់ថ្ម្យរន្ធរសមុទ្រ ។

ព្រះចាខ អាន់-ហេង៉ ទឹកស្ងាយព្រះពជបុត្រីណាស់ក៏ចុះតាមទ្វារសេះហើយលោតចុះទៅកន្លងទឹកសមុទ្រភ្លាម ដើម្បីទឹងសម្ងាប់ព្រះអង្គ ។ ដោយតាមសំណាងជំរៃសើរបស់ស្ដេច អាណ្ដើកមាសក៏នាំយកព្រះអង្គទៅដល់

ប្រាសាទបេស់ខ្លួនដែលៈទាំងបាតសម្តុំគ្រាយូរអង្វែងទៅ ។

ឯព្រះសពនាង មី-ចូវ នៅស្ងឹតស្ងាំងស្តឹងស្តូកលើផែនដី ដូចផ្កាយ៉ាងធំមួយ ដែលគេកាប់ចំក្រញ៉ាំចោល ។ ឈាមព្រះនាងហូរតាមក្រវែងថ្មរហូតទៅដល់ទឹកសមុទ្រ ។ ឈាមមួយដំណក់ៗក្លាយទៅជាត្រីមួយគ្រាប់ៗ ។ មានសត្វគ្រឹនឹងសត្វចំពុះទាសមុទ្រជាច្រើន បានមកពាំនាំយកត្រីនោះទៅហើយលេបធ្លាក់អាហារ ហេតុនេះហើយបានជាគេភ្ជាប់ឃើញមានត្រីទៅកន្លែងនោះគ្រប់ ។

ចំណែកព្រះអង្គម្ចាស់ទ្រង់-ធុយ កាលដែលយាងមកដល់ក្រុងព្រះបាទអាន់-ឃ្យឹង ហើយទ្រង់យាងចូលទៅកព្រះអគ្គមហេសី បេញ-ប៊ាបទ្វប់មួយចូលទៅបន្ទប់មួយ ហើយបេះតែស្រែកហៅព្រះនាងផង តែគ្មានឮសូរសម្លេងឆ្លើយតបមកវិញសោះ ។ លុះកព្រះនាងពុំឃើញ ទ្រង់ក៏នឹកដល់ពាក្យសន្យាគ្នាពីថ្ងៃមុន ។ ព្រះអង្គម្ចាស់ចាប់សេះដ៏រហ័សជាយទៅកព្រះនាង តាមដានដែលនាងបានប្រាប់ថា មានស្ទាបក្វានជាចំណាំ ។ ឃើញបន្តិចព្រះអង្គម្ចាស់នេះបានទៅដល់ទីកន្លែង ដែលព្រះនាង មី-ចូវ សុគត ទ្រង់ឃើញសពព្រះនាងស្តឹងស្តូកនៅមាត់សមុទ្រ ក្រោមម្លប់ឈើត្រឃឹងត្រឈៃមួយដើម ។ ព្រះអង្គម្ចាស់ទ្រង់-ធុយ ទឹកភ្នែកបង្ហូរព្រះទ័យលោតចុះពីលើខ្នងសាជានេយ្យភ្លាម ទ្រង់ស្ទុះទៅត្រកងព្រះនាងឡើង ហើយស្រែកហៅបេញ-ប៊ាមព្រះនាងតាមធម្មតា ហាក់ដូចតែស្រែកហៅមនុស្សនៅមានជីវិតលុះបានជ្រាបថា ព្រះនាងផុតព្រះជន្មហើយ ទ្រង់ក៏លើកសពព្រះនាងដាក់លើខ្នងសេះ ហើយចំបំបោលឆ្ពោះដំរើទៅទីក្រុង ។ ដល់ខណៈហើយ

ខ្ញុំបង្គាប់អស់សេនាមាត្យ ឲ្យរៀបចំធ្វើបុណ្យជូនសពព្រះទេព៌ យ៉ាងអ៊ឹកធឹក ។

តាំងពីពេលនោះមក ព្រះអង្គម្ចាស់ខ្ទេង-ធុយ ព្រួយព្រះទ័យគេកធ្វើជាគំពុះចេះស្តី ។ គោះព្រះបិតាខ្ញុំព្រះពុទ្ធវង្សាទ្រង់ស្ងួរយ៉ាងណាក៏ដោយ ព្រះអង្គម្ចាស់ក៏នៅតែស្ងៀម មិនត្រមៃធ្វើឆកបន្លើយ ។ នៅពេលដែលស្តេច ខ្មៅ-យ៉ា ខ្ញុំព្រះពុទ្ធវង្សាទ្រង់ប៉ិតនៅក្នុងច្រាសាទបស់ព្រះចៅអាន-យ៉ែង ជាសុខសាន្តនោះ ព្រះអង្គម្ចាស់ ខ្ទេង-ធុយ ទ្រង់តែងទឹកមុខមើមមាយ ក្នុងព្រះចិត្តរកព្រះមហេសីរបស់ព្រះអង្គជានិច្ច ។

ល្ងាចមួយអាកាសភ្លឺស្អាតល្អណាស់ ព្រះចន្ទចាំងរស្មីនៅលើសួនដ៏មានផ្កាបញ្ចេញក្លិនក្រអូប សាយសព្វគេញ្ញាំងសួនច្បារ, ព្រះអង្គម្ចាស់ខ្ទេង-ធុយ យាងតម្រង់ទៅអណ្តូងដែលនៅក្រោយកំផែង ដល់ហើយស្តេចលោតទៅក្នុងអណ្តូង សម្លាប់ព្រះអង្គតាមព្រះមហេសី ។

តាំងពីថ្ងៃនោះមក បើអ្នកស្រុកណារើសបានគេជ្រៀតក្នុងគោះគ្រឹប្ប ជំពុះពា ដែលនៅក្នុងបាតសមុទ្រ ពាល់តែយកគេជ្រៀនោះទៅលាងទឹងទឹកអណ្តូងនេះសិន ទើបមានរស្មីភ្លឺល្អ ដោយសារព្រះបារមីសេចក្តីស្នេហារបស់ព្រះអង្គម្ចាស់ ខ្ទេង-ធុយ ទឹងព្រះនាង ម៉ី-ចូវ នេះឯង ។

ចប់

ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត-តាត បាងហ្វាង

ពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រឹត ក្រុងភ្នំពេញ, កម្ពុជា

រៀបរៀងដោយ ជា-ធន់

សាស្ត្រាចារ្យទទួលការៈខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត

សូមក្រាបថ្វាយបង្គំព្រះមហាថេរានុត្តរៈ, តិក្ខុសាមណេរគ្រប់អង្គ
សូមក្រាបប្រណិប័តន៍អស់លោក-អ្នកជាទីស្រឡាញ់គាំនឹងឱ្យ
តាមឋានៈបញ្ញា នៃព្រះតេជព្រះគុណព្រះពោធិវង្ស បាងហ្វាង
ពុទ្ធិកវិទ្យាល័យ ខ្ញុំមានសេចក្តីរីករាយដ៏ធំក្នុងថ្ងៃប្រគេន-ជំរាបព្រះគុណ
គ្រប់អង្គ, អស់លោកអ្នកជាទីស្រឡាញ់គាំនឹងឱ្យ អំពីដំណើរទស្សនា
សហរដ្ឋអាមេរិក របស់ព្រះតេជព្រះគុណ ដូចសេចក្តីតទៅនេះ:

ដូចព្រះគុណគ្រប់អង្គ ទំនងអស់លោកអ្នកគាំនឹងឱ្យជ្រាបខ្លះ
មកហើយ, ព្រះតេជព្រះគុណព្រះពោធិវង្ស ព្រះនាម ហួត-តាត ជា
បាងហ្វាងនៃពុទ្ធិកវិទ្យាល័យ ទំនងជាអគ្គាធិការនៃពុទ្ធិកសិក្សា ក្នុងព្រះ
រាជអាណាចក្រ ឬានត្រួមទិមន្តទៅតាន់សហរដ្ឋអាមេរិក ចំនួនបីវៃ តាម
សេចក្តីទិមន្តន៍នៃរដ្ឋាភិបាលសហរដ្ឋ ដែលមានអគ្គទូតជាអគ្គៈជំណាង ។

នៅថ្ងៃសៅរ៍ ១ កើត ខែកត្តិក គឺថ្ងៃទី ៣ វិច្ឆិកា ២៤៩៩-១៩៥៦
វេលាម៉ោង ២ ទំនឹង ៣០ នាទី រសៀល, ដំណើរចេញទៅសហរដ្ឋ

អាមេរិក នៃព្រះតេជព្រះគុណ ចាន់ធ្លើឡើង ដោយមានពុទ្ធបរិស័ទជា
ច្រើន ផ្នែកខាងព្រះសង្ឃមានសម្តេចព្រះសង្ឃនាយកវត្តទុណ្ណាលោម ជា
ប្រធាន, ខាងគ្រហស្ថ មានលោកសំ-ញាណ ប្រធានពុទ្ធិកសមាគម
ជាប្រធាន ចានហែហមជូនដំណើរទៅចំណតអាកាសយានពោធិចិនគុន។
ឯមន្ត្រីខាងស្ថានទូតសហរដ្ឋ មានលោកហ្គាត់លីជាអគ្គទូតវិញ ជាដើម
ចានជូនដំណើរទៅ យ៉ាងគគ្រឹកគគ្រែង សំដែងសេចក្តីគ្រេកអរ ខឹងប្រ.
សិទ្ធិពរស័ព្ទសាធុការប្រគេនតាមទំនៀម ។

ក្រោយដែលចានក្រាបថ្វាយបង្គំលា សម្តេចព្រះសង្ឃនាយកធីវិញព្រះ
មហាថេរភិនឡាយ ព្រមទាំងចំរើនពរលាពុទ្ធបរិស័ទរួចហើយ, ព្រះតេជ
ព្រះគុណព្រះពោធិវង្ស មានលោក ជា ខន់ សាស្ត្រាចារ្យអង់គ្លេសនៅ
ពុទ្ធិកវិទ្យាល័យព្រះសុពម្រឹត ជាសហាយវិកតាមទៅជាមួយផង ចាន
និមន្តឡើងលើអាកាសយានយៃ ហោះតាមទាល័យប្រទេស ឆ្ពោះទៅ
កាន់ទ្វីបអាមេរិកខាងជើង តាមផ្លូវចានឆកក, ហុងកុង, តូក្យូ, ហូណូ-
លូលូ ។ ម៉ោង ៦ ទីធ ៣០ នាទីល្ងាច, ត្រលប់យប់មើលគ្នាលែងឃើញ
ច្បាស់ហើយ, អាកាសយានសម្ងួចស្ងាបបង្គំធំលឿនចុះចតនៅចំណតជន
មឿង នៃក្រុងចានឆកក ។ នៅវាលកចាំស់ហោះ, នៅតេលនោះ, មានពុទ្ធ-
បរិស័ទព្រះសង្ឃទីធីគ្រហស្ថ ជាច្រើនចានធ្វើចាំទទួលធ្វើបដិសណ្ឋារកិច្ច,
ខាងស្ថានទូតសហរដ្ឋ មានមន្ត្រី ១ រូប, ខាងស្ថានទូតកម្ពុជា លោកឧត-
ទូតធីនសហការីរបស់លោក ចានធ្វើចាំទទួលធ្វើអគិនទូនាការយ៉ាងស្ងួ-
ស្ងាល ។

នៅថ្ងៃ ៣ កើតខែកត្តិក (ខែ៩វិច្ឆិកា) ២៤៩៩ វេលាម៉ោង ៦ ទឹង ៣០ នាទីព្រឹក, អាកាសយានអាមេរិកាន់មួយឈ្មោះ Pan American World Airways បាននាំអ្នកដំណើរតាំង៦៣យ៉ាង រួមតាំងព្រះតេជព្រះគុណទឹងសិស្សផង ហោះទ្វឹងកាត់ប្រទេសតួចជំនាន ទឹងមហាសមុទ្រចិន សំដៅទៅហុងកុង អាណានិគម នៃចក្រភពអង់គ្លេស, អាកាសយាន បានចុះចតនៅចំណតប្រហែល ៣០ នាទី ទើបផ្តើមហោះទៅខ្មែតដកចដល់ម៉ោង ៨ យប់ (ម៉ោងនៅតូក្យូ) ទើបបានទៅដល់ចំណតអាកាសយាន នៃក្រុងតូក្យូ ប្រទេសជប៉ុន ។ ឈប់នៅក្រុងតូកយូប្រហែលមួយម៉ោង ទើបហោះតទៅខ្មែត ។ ម្តងនេះ អាកាសយានកង្ហារ ៤ ជុនធំ មានជាន់ពីរចំណុះ ៨០ នាក់ បានហោះនាំអ្នកដំណើរទ្វឹងកាត់មហាសមុទ្រប៉ាស៊ីហ្វិកដ៏ធំធេង អស់ ១យប់ គឺតាំងពីម៉ោង ៩ យប់ ដល់ម៉ោង ៩ ព្រឹក ទើបបានទៅដល់កោះមួយហៅថាកោះវ៉ែក ឬ Wake Island ជាកោះនៅក្នុងការយុំត្រួងក្បែនៃសហរដ្ឋ, អាកាសយានឈប់នៅទីនោះចំនួន ១ ម៉ោង អ្នកដំណើរស្រស់ស្រូបអាហារព្រឹកនៅកោជនាគារ របស់សមាគមយន្តហោះនៅទី នោះ ។ រួចហើយទើបចាប់ផ្តើមហោះត.ទៅខ្មែតហោះតាមអាកាសវិថី អស់ ១ថ្ងៃខ្មែត គឺតាំងពីម៉ោង ១០ ព្រឹក ដល់ម៉ោង ៨ កន្លះយប់ បានដល់ទៅក្រុងហូណូលូលូ នៃកោះហាវ៉ៃ របស់សហរដ្ឋអាមេរិក ។ មិនដឹងថាពេលម៉ោង ខុសផ្សេងគ្នាយ៉ាងដូចម្តេចទេ រវាងតូក្យូ ទឹងហូណូលូលូ ស្រាប់តែទៅដល់ហូណូលូលូ នៅតែថ្ងៃទី៥ វិច្ឆិកា ម៉ោង ៨ កន្លះយប់ដដែល ។ ក្រុងហូណូលូលូ នៃកោះហាវ៉ៃ ជាខ្ងោង

ទ្វារចូលទៅកាន់សហរដ្ឋអាមេរិក ។ នៅចំណតអាកាសយានហូណូលូលូ, ទាន់មន្ត្រីជាតំណាងក្រសួងការបរទេសស.រ.អា. ដែលមកទទួលគ្រឿង ១ រូប ទីឯកទូតកម្ពុជា ១ រូប ជាតិកំណើតជប៉ុន ជួលសញ្ជាតិអាមេរិកាន់ឈ្មោះ ឥសប្ប៊ី អ៊ីរៈ ជានាយំចាំទទួលធ្វើជាសក្ខីភាពកិច្ចយោងស្នងស្នាលហើយជានាំទៅសំណាក់នៅគេហដ្ឋានទទួលភ្ញៀវ ដែលគេបានបំរុងទុកស្រេច ។ លោកឥសប្ប៊ីអ៊ីរៈ ជាអ្នកមានសទ្ធានចិត្តសប្បុរសស្មោះសរចំពោះមិត្ត ឬ ភ្ញៀវរបស់លោក បានរៀបចំសេនាសនៈឲ្យសំណាក់អាស្រ័យ ទីឯកំទុកបំរុងអាហារគោជនសព្វគ្រប់ គ្នីពេលដែលបិតនៅទីនោះចំនួនពីរថ្ងៃ ។ សូម្បីតែរយៈវេលាខ្លីដូច្នេះ ក៏ប៉ុន្តែស្ទើរតែគ្មានសល់បន្ទោះកន្លែងឯណាទេ ដែលព្រះតេជព្រះគុណបានទិមន្តទៅទស្សនាដោយឥសប្ប៊ីអ៊ីរៈពុទ្ធិកជននេះ បានបញ្ជុះបញ្ជូលឡើង ដោយរថយន្តផ្ទាល់ខ្លួន ទាំមើលសព្វទីតាំងអស់ គោះជិតក្តី ឆ្ងាយក្តី ។ ក្រៅពីបូជនីយដ្ឋាន, អនុស្សរណីយដ្ឋាន, វត្តព្រះសង្ឃរួមហាយានជាច្រើន ដែលព្រះតេជព្រះគុណបានទស្សនា ទីឯពុទ្ធសាសនិកជននានា ដែលព្រះតេជព្រះគុណបានជួបសន្ទនាប្រស្រ័យ ក្នុងឋានៈជាពុទ្ធមាមកជនដូចគ្នា ព្រះតេជព្រះគុណបានទិមន្តទៅធ្វើធម្មទេសនាមួយ អំពីកម្ពុជាជន ទីនៃព្រះពុទ្ធសាសនា ព្រមទាំងវត្តបំណងរបស់លោកទៅកាន់សហរដ្ឋក្នុងពេលនេះ នៅមហាវិទ្យាល័យហាវ៉ៃ" University of Hawaii ។

ថ្ងៃ ៥ កើតខែកត្តិក (៧ វិច្ឆិកា ១៩៥៦) វេលាម៉ោង ៧ ទឹង ៣០ នាទីយប់ (ម៉ោងនៅហូណូលូលូ) ព្រះតេជព្រះគុណព្រះពោធិវង្ស ចាន

ចេញពីក្រុងហូណូលូលូ បន្តដំណើរទៅកាន់ក្រុង សាន-ហ្វ្រាន-ស៊ីស-កូ រដ្ឋសាល៉ហ្វ៊ឺនញ៉ា San Francisco, California ។ អាកាសយាន តាអេអេ PAA ហោះអស់រយៈវេលាប្រហែលជាប់ពីរម៉ោង ទើបបានទៅដល់ក្រុង សាន-ហ្វ្រាន-ស៊ីស-កូ ទៅដល់ទីនោះ នៅម៉ោង ៨ ទឹង ៣០ នាទីព្រឹក (ម៉ោង នៅសាន-ហ្វ្រាន-ស៊ីស-កូ) ។ លោកវ៉ូតវ៉ាដ Woodward តំណាងក្រសួង ការបរទេសស.រ.អា. ដែលទទួលភ្ញៀវបានធ្វើចាំធ្វើបដិសណ្ឋារកិច្ចនៅទីចំណតអាកាសយាន ហើយបាននាំទៅឲ្យសំណាក់នៅមហាសណ្ឋាគារមួយ ដែលគេបំរុងទុកស្រេច ។ ក្រោយដែលព្រះតេជព្រះគុណ បានទទួលទៅដល់កន្លែងសំណាក់ហើយ, ក្នុងពេលបន្ទាប់គ្នា មិនជាយូរប៉ុន្មាន, ព្រះតេជព្រះគុណបានទទួលទូរអក្សរនាគារ អំពីឥស្សរជនអាមេរិកាន់ ១ រូបឈ្មោះ ស្កាបរ៉ូ Scarborough ជាអ្នកតំណាងខាងមូលនិធិអាស៊ី The Asia Foundation ។ លោកស្កាបរ៉ូនេះឯង ជាអ្នកចាត់ចែងរៀបចំកម្មវិធី ប្រគេនព្រះតេជព្រះគុណ ក្នុងវេលាបួនថ្ងៃ ដែលប៉ិតនៅក្រុងសាន-ហ្វ្រាកស៊ីស-កូ ។ ដោយកម្មវិធីនោះ, ព្រះតេជព្រះគុណបានទទួលទស្សនាទូរទស្សន៍យដ្ឋានទាំងនា ដូចជាវិហារព្រះសង្ឃមហាយានពុទ្ធសាបនិក មហាវិទ្យាល័យសាលីហ្វ៊ឺនញ៉ា University of California, បណ្ណាល័យសាធារណៈ ជាដើម, ជាន់ជួបប្រស្រ័យការជាមួយសាស្ត្រាចារ្យជាច្រើនរូប ។

ក្រៅពីការទស្សនាចំណេះដឹងផ្សេងៗខាងលើនេះ, តាមសេចក្តីទិមន្តន៍នៃប្រជាជនអាមេរិកាន់ ព្រះតេជព្រះគុណបានទទួលទៅផ្ទះអាមេរិកជន

ជាច្រើនរូប ។ ជនជាតិអាមេរិកាន់ចាំនឹងឡាយ ចូលចិត្តបង្ហាញទំលាំងៅ
របស់ខ្លួនដល់ភ្ញៀវបរទេសណាស់ ។ នៅផ្ទះនីមួយ ។, គេបង្ហាញគ្រឿង
ប្រដាប់ប្រើប្រាស់សព្វគ្រប់ចំពោះភ្ញៀវ ដូចជាបន្ទប់ទទួលភ្ញៀវ, បន្ទប់
ដេក, បន្ទប់ទឹក, បន្ទប់ចរិកោត, មាំសុំនចោកគត់ខោអាវសំលៀកបំពាក់,
មាំសុំនលាងចាន ជាដើម ។

នៅថ្ងៃ ៨ កើតខែកត្តិក (១១ វិច្ឆិកា) វេលាម៉ោង ១:៣០ ព្រឹក,
ព្រះតេជព្រះគុណព្រះពោធិវង្ស ចានចេញចាកក្រុងស៊ីនក្រាំស៊ីសស្កូ បន្ត
ដំណើរទៅកាន់ក្រុងវ៉ាស៊ុងតុនឌីស៊ី ជារដ្ឋធានីនៃសហរដ្ឋអាមេរិក តាម
អាកាសយានឈ្មោះ យូណាយធិត អែរឡាយន៍ United Airlines;
ម៉ោង ១:០០ រសៀលនៃថ្ងៃទី ១២ វិច្ឆិកា ចានទៅដល់ក្រុងវ៉ាស៊ុងតុនឌីស៊ី
ដែលនៅទីចំណតអាកាសយាន មានលោកហាក់-អេង, ឧ.កុសល៍: ទំង
លោក ថាច់.ភៀម នៃស្ថានទូតកម្ពុជា ប្រចាំក្រុងវ៉ាស៊ុងតុន ចានរង់ចាំ
ទទួល ហើយចានទាំទៅទ្បែតង់នៅគេហដ្ឋានមួយ លេខ ៤៩០០ ផ្លូវ
លេខ១៦ N.W. របស់ស្ថានទូតមិនឆ្ងាយពីគេហដ្ឋានលោកពាដ្ឋតប៉ុន្មាន។
នៅក្រុងវ៉ាស៊ុងតុន, លោកស្រី នង-តិមនី ព្រមទាំងអស់លោកអ្នកធ្វើការ
នៅស្ថានទូតទាំងឡាយ ចានទំនុកបំរុង ដោយចង្ហាន់សព្វគ្រប់ ។ ដោយ
សហរដ្ឋអាមេរិក ជាប្រទេសធំត្រជាក់ណាស់ នៅរដូវហេមៈ, អ្នកស្រុក
ទំងអ្នកដំណើរនោនា ត្រូវមានសំលៀកបំពាក់ សំពាប់ការពារធាត្រជាក់គ្នា,
ព្រោះហេតុនោះ សម្តេចព្រះទេបយុវពង ន.ស៊ីហនុ ចានមានព្រះពាដបញ្ជា
បង្គាប់លោកនង-តិមនី ឲ្យចាត់ការដោះគ្រឿងបំពាក់សំពាប់ការពារធា

ប្រគេនព្រះតេជព្រះគុណ ដោយព្រះពាជទ្រព្យផ្ទាល់ព្រះហត្ថ ក្នុងពេលណា
ដែលព្រះតេជព្រះគុណទិមន្តទៅដល់ក្រុងវ៉ាស៊ីនតុន ។ តាំងពីចូលទៅ
ដល់ក្រុងវ៉ាស៊ីនតុនភ្លាម, ព្រះតេជព្រះគុណចាត់ហ្វាង បានអនុវត្តតាម
កម្មវិធីទស្សនា ស.រ.អ ដែលសភាអាមេរិកាន់ ខាងសិក្សា បានចាត់
ការរៀបចំឡើង ក្រោមបញ្ជាការនៃក្រសួងការបរទេសសហរដ្ឋ ។
ឯមូលដ្ឋាន ដែលជាតែចំណាត់ក្នុងជំរំណើរទស្សនាសហរដ្ឋ នៃព្រះតេជព្រះ
គុណចាត់ហ្វាង គឺចំពោះការសិក្សា ទីដ៏វប្បធម៌ ព្រោះហេតុនោះ,
កម្មវិធីទស្សនា បានរំលែកពេលជាច្រើន ចំពោះការសិក្សា, ព្រះ
តេជព្រះគុណ បានទិមន្តទៅកាន់ក្រុងទីផ្សារ, និគម, ប៉ុំ, កូមិ ជាច្រើន
ដូចរៀបរាប់ខាងក្រោមនេះ:

ក្រុងវ៉ាស៊ីនតុន ឌី ស៊ី ជារដ្ឋធានីសហរដ្ឋ, Washington D.C. Nations Capital.

ក្រុងញូ ហាវ៉ិន រដ្ឋខ្នង.ណិក.ធី.ខ័ត New Ver Haven, Connecticut.

ក្រុងប៉ុស.ស្តុន រដ្ឋម៉ាស់ សាស់.ឈើស៊ីត, Boston Massachusetts

ក្រុងញូយ៉ក, រដ្ឋញូយ៉ក New Ver York, N.Y.

និគមវ៉ែនថ៍ រដ្ឋអូហៃយ៉ូ, Kent, Ohio

និគម Oberlin, Ohio. អូបឺលិន, អូហៃយ៉ូ

ក្រុងឌីត្រយ, រដ្ឋមិស.ឈី.គាន់ Detroit Michigan.

ប៉ុំបេរ៉ា, រដ្ឋខែន ថើក.ឃី. Berea, Kentucky.

កូមិវែនឡិន រដ្ឋខារ៉ូឡៃណា ខាងជើង Penland, North Carolina

ក្រុងនូអ៊ែ-ឡេន, រដ្ឋលូស៊ីយ៉ាណា, Newr Orleans, Louisiana

ក្រុងឡុស-អ័ន-ដើ-លិស រដ្ឋខាលីហ្វ័រនីញ៉ា Los Angeles, California

ក្រុងសាន-ហ្វ្រាន់ស៊ីស-កូ រដ្ឋខាលីហ្វ័រនីញ៉ា San Francisco California

ក្រុងហូណូលូលូ គ្រូមិកាតហាវ៉ៃ Honolulu Territory of Hawaii

នៅទីតែនេះខាងលើនេះ ព្រះតេជព្រះគុណបានឱមន្តខសូត្រនាំ,

๑-ផ្នែកខាងសិក្សា

ក-សាលាបឋមសិក្សា ឯកជន ទីណ សាធារណៈ,

ខ-សាលាមធ្យមសិក្សា " " "

គ-វិទ្យាល័យ " " "

ឃ មហាវិទ្យាល័យ " " "

ង-បណ្ណាល័យ " " "

ច-សារមន្ទីរ,

ឆ-ការបង្រៀន ទីណរបៀបបង្រៀន,

ជ-បានជួបសន្ទនាជាមួយមន្ត្រីខាងការសិក្សាៈ ចាងហ្វាង, សាស្ត្រាចារ្យ គ្រូបង្រៀន, ប្រធានវិទ្យាល័យ ទីណមហាវិទ្យាល័យជាច្រើន ។

๒-ផ្នែកខាងសាសនា

ក.)វិហារជាំបំនៅនៃពុទ្ធសាសនិកជនមហាយាន;

ខ.)វិហារខាងគ្រីស្តសាសនា;

គ.)សមាគមមិត្តពុទ្ធសាសនិកនៅក៏សុងគុន ។

៣_ផ្នែកខាងប្រជាជន

ក.)ជីវភាពនៃប្រជាជន:

ខ.)អាមេរិកជនទំនឹងសាសនា;

គ.)សិទ្ធិនឹងសេរីភាពនៃប្រជាជន.

ឃ.)ច្បាប់សំរាប់ប្រជាជន,

ង.)សកម្មភាពរបស់ប្រជាជន ។

៤_ផ្នែកខាងរបៀបរៀបចំប្រទេស

ក.)ផ្លូវគមនាគមន៍, ផ្លូវថ្នល់, ស្ពាន, ដំណើរតាមរថយន្ត, តាមទូក តាមរទេះភ្លើង, តាមកប៉ាល់ហោះ;

ខ.)ការបកបរ កុងទ័ក្រុង ទំនឹងកងទ័តមជនបទនានា;

គ.)សេចក្តីរៀបរយនៃទ័ក្រុង,

ឃ.)ទេសភាពនៃប្រទេសនឹងទ័ក្រុង ។

បពិត្រព្រះករុណាគ្រប់ព្រះអង្គ, ខ្ញុំអស់លោក អ្នកចាំងឡាយ, តាមចំណុចសំខាន់ ។ ដែលខ្ញុំព្រះករុណា, ខ្ញុំបានបង្ហើលខាងលើនេះ ឃើញថា ព្រះតេជព្រះគុណចាងហ្វាង ក្នុងដំណើរទស្សនាចរនេះ ចាន់តែឃើញស្ទើរតែគ្មានសល់បន្ទាត់ត្រង់ណាទេ, ខ្ញុំព្រះករុណា, ខ្ញុំនឹងធ្វើអត្ថាធិប្បាយតាមដំណើរគោរណ៍ ប្រគេន ជូនជាសណ្តាប់ ដើម្បីឲ្យចានជ្រាបច្បាស់ ដូចជាចានទំមន្ត, អញ្ជើញទៅឃើញជាមួយគ្នា ។ ខ្ញុំព្រះករុណា, ខ្ញុំសូមអភ័យទោសទុកជាមុនថា ខ្ញុំព្រះករុណា, ខ្ញុំទំនឹងថ្លែងតាមការណ៍ពិត, ការណ៍មែន, ការណ៍ដែលចានឃើញ ចានដឹងច្បាស់

ប្រគេន-ដូច មិនមែនថ្លៃដប់ទុំ អ្នតសរសេរតែពីស្រុកគេ ដើម្បី ញ៉ាំនព្រះកុណាគ្រប់អង្គ ទើនអស់លោកអ្នកតាំឡាយ ឲ្យស្រឡាញ់ រាប់អានអាមេរិកាំនេ ។ តែប៉ុន្តែ ខ្ញុំព្រះកុណា ខ្ញុំបាទសង្ឃឹមយ៉ាង ខ្លាំនថា ដោយការសំដែនអំពីដំណើរទេស្យនាសហរដ្ឋនេះ, ព្រះកុណាគ្រប់ អង្គ ទើនអស់លោក មុខជាទើនបានជឹនដូរឿនថ្មែក ។ ដែលអាចយក ទៅបំបែក ជាមេគំនិតគំតែកសាន់ប្រទេសយើន ឲ្យបានថ្កុំថ្កើនរុនរឿន ទៅអនាគត ។

តទៅវិនេះ ខ្ញុំព្រះកុណា, ខ្ញុំសូមផ្តើម:

ផ្នែកខាងសិក្សា.. អំពីសាលារៀន

សាលារៀនគាំនឡាយ នៅសហរដ្ឋអាមេរិក សុទ្ធសឹនតែថ្មែក។ ពីសាលារៀននៅប្រទេសយើន ដោយរូបភាពសាលា ។ សាលារៀន គាំនឡាយចែកតាមលំដាប់ថ្នាក់ -ដាន់ខ្ពស់ទើនតាមដូច្នេះគឺ

១. សាលាបឋមសិក្សា ហៅថា Elementary School ឬ Primary School

កូនអាមេរិកាន់គាំនឡាយ គាំនប្រុសគាំនស្រី ដែលមានវ័យ. ក្មេងតាការ ចំរើនឡើនគ្រប់ ៦ ឆ្នាំហើយ ឪពុកម្តាយច្រើននាំទៅប្រគល់ ឲ្យសាលារៀន ។

នៅសាលារៀនផ្នែកដំបូន សំរាប់កុមារកុមារីដែលមានអាយុ ៤ ឆ្នាំ គេ ឲ្យរៀននៅក្នុនថ្នាក់តិសេម ដែលគេហៅថា Nursery School ។

សំរាប់កុមារកុមារីដែលមានអាយុ ៥ ឆ្នាំ គេឲ្យរៀននៅក្នុនថ្នាក់តិសេស ផ្សេនទៀត ហៅថា Kindergarten (F.Ecole maternelle)

លុះកុមារកុមារីគាំនរនោះ មានអាយុគ្រប់ក្រាំមួយឆ្នាំបរិបូណ៌ហើយ ទើបគេឲ្យរៀនក្នុងថ្នាក់រៀន ដែលគេកាប់រៀងតាមលំដាប់ឆ្នាំដូច្នេះ:

ថ្នាក់ឆ្នាំដំបូងហៅថា First grade, រៀបបារាំងថា Cours Enfantin

ថ្នាក់ឆ្នាំទី ២ " Second " Préparatoire

ថ្នាក់ឆ្នាំទី ៣ " Third " Elémentaire

ថ្នាក់ឆ្នាំទី ៤ " Fourth " Moyen 1èreannée

ថ្នាក់ឆ្នាំទី ៥ " Fifth " 2ème Année

ថ្នាក់ឆ្នាំទី ៦ " Sixth " Supérieur

សាលាបឋមសិក្សាខាងលើនេះ, ច្រើនតែសង់អាគារតែមួយយ៉ាងធំល្អណាស់ ប្រដាប់ដោយជាន់តាំរ ប្តូបី ហើយចែកចេញជាថ្នាក់រៀនជាច្រើន មានតាំ ១៧ ថ្នាក់រៀ ៣០ ថ្នាក់ ។ នៅក្នុងអាគារជាមួយគ្នានោះ ក្រៅពីថ្នាក់រៀនគាំនរនេះ មាន:

មណ្ឌលកីឡា,

សាលប្រជុំ,

កន្លែងលេងទឹក,

ការិយាល័យ, ទីបាត់ការ,

បន្ទប់ទឹងបង្គន់សំរាប់កុមារ-កុមារី,

កន្លែងសំរាប់ដាក់ខោអាវ, ប្រដាប់ប្រដាសិស្ស,

ម៉ាស៊ុនទឹក,
បណ្ណាល័យ ។

កាលបើចូលទៅខាងក្នុងសាលាមួយៗ ឃើញមានទំហំធំល្វឹងល្វើយ គួរតែកាយសប្បាយនឹងការរៀនសូត្រណាស់ ។ នៅក្នុងថ្នាក់រៀនគ្រប់ថ្នាក់ ចាប់តាំងពី Nursery *រហូតថ្នាក់ទី ៦ យើងសង្កេតឃើញមាន:*

កូនតុតូចៗ ពាប សំពាប់ក្មេងប្រុស.ស្រី តាមវ័យ;

ក្តារខៀនបញ្ឈរលើជញ្ជាំង (តាប្លូ) ជុំវិញថ្នាក់រៀន;

ឥយ៉ាំណូ សម្រាប់គ្រូបង្ហាត់ច្រៀង;

តុគ្រូបង្រៀន ដែលមានសៀវភៅតារាច្រើន, ។

តាប្លូ គេច្រើនលាបពណ៌ស្វឹតឈើ ប្រើដីសព័ណ៌លឿង តុគ្រូបង្រៀន មិនមានកំណល់កល់ទេតែខ្ពស់ជាងតុសិស្សទេ គេជាក់ស្តែគាំងអស់ ។

កុមារ កុមារី ដែលរៀននៅសាលាបឋមសិក្សា មានតាំងពីអាយុ ៤ ឆ្នាំខ្ទះ, ៥ ឆ្នាំខ្ទះ ៦ ឆ្នាំខ្ទះ រហូតដល់អាយុ ១២ ឆ្នាំ ។

គ្រូបង្រៀន ច្រើនតែជាកេទស្ត្រី ហើយច្រើនតែមានចំណាស់គួរសម ប្រហែលពី ២៥ ទៅ ៣០ ឆ្នាំ ហើយច្រើនតែមានគ្រូពីរនាក់គ្រប់ថ្នាក់ ។ បានដឹងថា គ្រូបង្រៀនប្រចាំថ្នាក់ មានតែម្នាក់ៗទេ ឯស្ត្រីដទៃម្នាក់ទៀតនោះ ជាអនាគតគ្រូ គេឲ្យមកអប់រំខាងការបង្ហាត់បង្រៀនចំនួន ១ ធមាសម្នាក់ ហេតុនេះបានជាឃើញមានគ្រូពីរនាក់ជានិច្ច ។

(នៅមានត)

ដំណើរមកកាន់តុទ្ធសាសនបណ្ឌិត្យ

នៃឯកឧត្តម បណ្ឌិត រាជក្រិស្ណាន

អនុប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូ

លោក រ៉ាយ-ប៊ុក រៀបរៀង

ឯកឧត្តម បណ្ឌិតរាជក្រិស្ណាន អនុប្រធានាធិបតីសាធារណរដ្ឋឥណ្ឌូ ជាប្រធានគណៈប្រតិភូឥណ្ឌូ បានអញ្ជើញមកទស្សនាជាផ្លូវការ នៅប្រទេសកម្ពុជាអស់បីរវេលា ៤ ថ្ងៃ គឺពីថ្ងៃទី ៩ ដល់ថ្ងៃទី ១២ កញ្ញា ១៩៥៧ ទើបត្រឡប់ទៅវិញ ។ នៅថ្ងៃទី ១១ កញ្ញា បានអញ្ជើញមកកាន់មន្ទីរតុទ្ធសាសនបណ្ឌិត្យ ។

លុះអញ្ជើញមកដល់, ឯកឧត្តមបានទស្សនាខ្លះៗអំពីបវេទសៀវភៅសាស្ត្រទំនិតម្ដីរស្ងឹកវិត, រួចបានលិត្រឡប់ទៅកាន់កន្លែងសន្និបាត, នៅកណ្ដាលបណ្ណាល័យតុទ្ធសាសនបណ្ឌិត្យ ។ ផ្នែកខាងគ្រហស្ថ មានឯកឧត្តម រាជក្រិស្ណាន ឯកឧត្តម ក៏-គាមិល ឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសឥណ្ឌូ, ឯកឧត្តមកេដាំល-សិង្ហ ឯកអគ្គរាជទូតប្រទេសឥណ្ឌូ ប្រចាំប្រទេសកម្ពុជា លោកជាំល់.ជួន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទំនើងធម្មការ, លោកមាស-យ៉ង អនុរដ្ឋលេខាធិការក្រសួងធម្មការ, លោកលៀង-ចឹម អគ្គលេខាធិការក្រុមតុទ្ធសាសនបណ្ឌិត្យទំនើងបុគ្គលិកក្រសួងធម្មការទំនើងក្រុមតុទ្ធសាសនបណ្ឌិត្យ ឈរទាំងជើង ។

ផ្នែកខាងបព្វជិត, មានសម្ដេចសង្ឃនាយកទាំងពីរគណៈ ព្រះពោធិវង្ស ហ៊ុត-តាត ចាងហ្វាងតុទ្ធិកវិទ្យាល័យព្រះសីហនុពុទ្ធរាជ្យ ពាជ-

គណៈ, ហានាទុក្រម តធ៌នៅលើកៅអីខាងស្តាំ ។

ក្រោយដែលព្រះសង្ឃសូត្រជយន្តោ ជូនពរស័ព្ទសាធុការ ចំពោះឯកទត្តម ។ កំបានថ្វែងទូវសង្កថាមួយ ជាភាសាអង់គ្លេស, ព្រះគ្រូសង្ឃសន្តា ប៉ុណ្យសុម្ភាជ ធម្មាភរោ ជាអ្នកប្រែមកជាភាសាខ្មែរថា:

ខ្ញុំមានចិត្តសោមនស្សជាយ៉ាងក្រៃលែង ដោយខ្ញុំបានទទួលកិត្តិយសមកកាន់ប្រទេសកម្ពុជា ដែលជាប្រទេស និយមកាន់ព្រះពុទ្ធសាសនា ដែលជាសាសនា អាចដឹកនាំពិភពលោកៈឲ្យកាន់សន្តិភាព ។

ប្រទេសកម្ពុជា មានការសិក្សា ខាងព្រះពុទ្ធសាសនាជាយ៉ាងមាំមួន, មានពុទ្ធិកវិទ្យាល័យព្រះសុពម្រឹត មហាពុទ្ធិកវិទ្យាល័យព្រះសីហនុរាជ្យ, សាលាបាលីវិន, សាលាធម្មវិន័យ; មិនតែប៉ុណ្ណោះ ថែមទាំងមានពុទ្ធសាសនបណ្ឌិត្យ ជាអ្នករក្សាពុទ្ធវចនៈគម្ពីរព្រះត្រៃបិដក, ផ្សាយនូវព្រះពុទ្ធសាសនា ដោយចេះពុម្ពនូវសៀវភៅផ្សេងៗ ។

ព្រះពុទ្ធសាសនា មិនមែនអស់ហើយត្រឹមតម្លៃបាលីសាស្ត្រា, សៀវភៅ,ក្បួនបញ្ជាប់ទង្វើធម្មទេសនានោះទេ ដែលពិតនោះ គឺនៅត្រង់បញ្ញាត្តិរិះ រកហេតុផលទង្វើៈសេចក្តីប្រតិបត្តិ ដើម្បីឲ្យកើតប្រយោជ្យក្នុងស្ថានវុឌ្ឍរឿងខ្លីៗ,លោកបានបញ្ចប់នូវសង្កថាថា :

ព្រះពុទ្ធសាសនា ជាសាសនាដែលមានសម្ភាទិដ្ឋិកប្បញ្ញាជាមូល. ដ្ឋាន មិនមែនសាសនាដែលប្រើអំណាចមកសង្កត់សង្កិន បង្ខំឲ្យគេជឿជា

ជាច់ខាតនោះទេ ហើយជាសាសនា ដែលត្រូវយកព្រះធម៌មកពិចារណា ត្រិះរិះឲ្យយល់ហេតុផលសព្វគ្រប់ សឹមប្រតិបត្តិ ។

លំដាប់តមក ព្រះពោធិវង្ស ហួត-តាត ចាត់ហ្វាងពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ចានថ្លែងចំពោះមុខ ឯកឧត្តមពាធក្រិស្ណាន ថា គាត្មាភាព មានចិត្តសោមនស្សជាយ៉ាងក្រៃលែង ដោយរដ្ឋាភិបាលឥណ្ឌា ចាត់សាស្ត្រាចារ្យម្នាក់ មកបង្រៀនភាសាសំស្ក្រឹតនៅសាលានេះ ។

គួរឲ្យស្តាយពន់ពេក ព្រោះពេលនោះ មហាមេឃបង្អោរភ្លៀងធំជួនស័ព្ទសាធុការពារ ចំពោះឯកឧត្តម ។ ឯកឧត្តមមិនអាចអញ្ជើញទៅឧស្សាគ្រប់ដុំទុំទៀមទម្ងន់ ក្រុមនៃការផ្សាយ, ក្រុមដំទុំព្រះត្រៃបិដក ។ល។

រួចទើបមានពិធីប្រគល់សៀវភៅជាអំណោយនៃពុទ្ធសាសនបណ្ឌិត្យ ចំពោះឯកឧត្តមពាធក្រិស្ណាន ដូចខាងក្រោម :

១ -សៀវភៅ ពុទ្ធសាសនា ភាសាខ្មែរមួយក្បាល,

២ -សៀវភៅ ពុទ្ធសាសនា ភាសាចាក់ឆ ម្ភក្បាល

៣ -សៀវភៅ វចីវិទ្យា ភាសាចាក់ឆ មួយក្បាល,

៤- សាស្ត្រាស្តីពីតឹត រឿងសិរីវិបុលកិត្តិជាតក១ខ្សែ ។

លំដាប់តមក, ឯកឧត្តមពាធក្រិស្ណានបានធ្វើអំណោយសៀវភៅចំពោះមហាពុទ្ធិកវិទ្យាល័យព្រះសីហនុពង្ស ដូចខាងក្រោម :

១ - សៀវភៅភគវតឹត គីតាមួយក្បាល,

២-សៀវភៅ ឃោមលាំចំពោះដើរកាតហ៊ីណ្ឌូ មួយក្បាល,
៣-សៀវភៅពាធក្រិស្ណាខ, ទស្សនាវដ្តីគាត ១ មួយក្បាល,
៤ សៀវភៅពាធក្រិស្ណាខ, ទស្សនាវដ្តីគាតទី ២ មួយក្បាល,
៥-សៀវភៅសាសនាបូរាប្រទេសទឹងចិន្តាមជ្ឈឹមប្រទេសមួយក្បាល,
៦-សៀវភៅទស្សនាវដ្តីនៃសំរេចល្អ-ពាធក្រិស្ណាខមួយក្បាល ។

ពិធីទស្សនាការឯកទត្តមនេះ បានបញ្ចប់នៅវេលាម៉ោង ៤,៣០ នាទីរសៀល ។

ពិធីបុណ្យទទួលអដ្ឋិធាតុ

នៃព្រះគ្រូហ៊ុន-សាង ជាតំបន់នៅនាលន្ទា

(ប្រទេសឥណ្ឌា) លោករ៉ាយ-ប៊ុករៀបរៀង ។

កាលពីថ្ងៃទី ១២ មករា ១៩៥៧, មានពិធីបុណ្យទទួលអដ្ឋិធាតុ នៃព្រះគ្រូហ៊ុន-សាងជាតិចិននៅនាលន្ទា (ប្រទេសឥណ្ឌា) ។ អដ្ឋិធាតុនេះ, ឯកអគ្គរាជទូតប្រទេសចិនប្រចាំប្រទេសឥណ្ឌា បានទាំមកប្រគល់ជូនរដ្ឋាភិបាលប្រទេសឥណ្ឌា ។

ពិធីបុណ្យនេះធ្វើឡើង នៅក្រោមអធិបតីភាព នៃសម្តេចជាវៃឡាមា ទឹងសម្តេចបញ្ចិនឡាមាប្រទេសទីបេត ។ អដ្ឋិធាតុនេះ, លោកឯកអគ្គរាជទូតចិន បានជូនចំពោះលោកបណ្ឌិតនេហ៊ូ រដ្ឋមន្ត្រីទី ១ ប្រទេសឥណ្ឌា ។ អដ្ឋិធាតុ បានតម្កល់ក្នុងកោដ្ឋមាសកំពស់ ០ម.៦៤៦ ។

ពេលមាន ៤ រសៀល, មានពុទ្ធសាសនិកជនទាំងបុរស-ស្ត្រី, ទាំងបព្វជិត ជាឯកទ្វេលានាក់ បានមកទស្សនាពិធីបុណ្យនេះ តឹកតឹងរំពងសាសពេញវាលនាលន្ទា, ជុំវិញវេទិកាកិត្តិយស, ដែលសម្តេចជាវៃឡាមា ទឹងបញ្ចិនឡាមា ទ្រង់គង់ព្រមទាំងបុគ្គលិកជាន់ខ្ពស់ប្រទេសឥណ្ឌាទឹងប្រទេសចិន ។

មានទេសានសំភូ ផ្សាយសំឡេងពេញគ្រប់ទិសានុទិស ។

ក្រោយពិធីបុណ្យ, ប្រតិភូប្រទេសចិន បានជូនចំពោះបណ្ឌិត

នេហ៍វុ ខ្ញុំវិញទីនៃសិលាគ្រឹះមួយ ដែលរចនាតាមក្បាច់សិល្បៈចិន ដែលនឹងត្រូវសាងជាតម្រាវិទ្យាល័យនាលន្ទា ព្រមទាំងប្រាក់កន្ទុះលាន រូពីសម្រាប់សង់ ។ សិលាគ្រឹះនេះជាថូបដ្ឋានសម្រាប់តម្កល់អដ្ឋិធាតុព្រះគ្រូហ៊ុន-សាង ហើយអាចធ្វើជាកុដិសម្រាប់ព្រះភិក្ខុសង្ឃ, ពួកសាស្ត្រាចារ្យ, ពួកសមណនិស្សិត ។

តាំងពីបុណ្យនេះ ខុកជាព្រឹត្តិការណ៍មួយដ៏សំខាន់ ចំពោះពុទ្ធសាសនប្រវត្តិ នឹងការប្រាស្រ័យទាក់ទងវប្បធម៌ រវាងប្រទេសឥណ្ឌា នឹងប្រទេសចិន ហើយត្រូវនឹងជំណើរដែលព្រះភិក្ខុ ជគទិស-កស្សប និមន្តទៅស្ថេរដ្ឋាភិបាលចិនាំង នឹងលស្សា អំពីការស្ថាបនាមហាវិទ្យាល័យនាលន្ទា នៅទីក្រុងតាំងពីរ ។

អាសាន, បណ្ឌិតនេហ៍វុលោកបានជូនសម្តេចជាវៀ-ឡាម៉ា នឹងបញ្ចិន-ឡាម៉ាទៅកាន់ភ្នំគិជ្ឈកូដ ឯពុគ្រឹះ ព្រមទាំងទស្សនាខ្ញុំថ្មល់វែង ដែលព្រះបាទពិម្ពិសារបានសាង, គឺនៅវត្តដែលសាងទាំងលើកំពូលភ្នំគិជ្ឈកូដ ដែលព្រះគ្រូហ៊ុន-សាង បានគង់នៅសិក្សាព្រះពុទ្ធសាសនា ព្រមទាំងធ្វើសមាធិចិត្តអស់រយៈវេលាប្រាំឆ្នាំ ។

–មន្ត គុ. ដែលពួតដើម្បីភ្លើង ។ –មន្ថន នបុ. ការយោពួតដើម្បីភ្លើង ។ –មាឡ្យ នបុ. ការយោយឺតនៃភ្លើង (សំលេយអាហារ) ។ –មារុត បុ. តាមនៃអគស្ត្យ: ។ –មិត្រ បុ. តាមស្តេចនៃភាគវង្សសុគ្គ:ជាបុត្រព្រះបាទមុម្ហមិត្រ: ។ –មុខ: គុ. ដែលមានមាត់ភ្លៅឆ្ងួចភ្លើងអគ្គិមុខ ។ បុ. ឈ្មោះសង្កើចអគ្គិមុខ ។–មូឍ គុ. ដែលភាន់ភាំងដោយភ្លើង។ –យោជន នបុ. ការយប្រកបនូវតិធីអគ្គិ ។ –រក្សណ នបុ. ការរក្សានូវភ្លើង ។ រជ្ជ រជស៑ បុ. សត្វល្អិតពណ៌ក្រហមឆ្អៅ ។ –រហស្យ នបុ. “ រហស្យកម្មនៃអគ្គិ” តាមគម្ពីរសេតបថ-ព្រាហ្មណ: ។ –ភជន្ត គុ. ពហុ. “ មានអគ្គិជាស្តេច” , តាមនៃវសុស៑ ។ –ភស្ម បុ. ផំនរនៃភ្លើង ។ –រុហា ស្ត្រី. ដើមមាឡ្យរោហិណី ។ រូប គុ. ដែលមានអគ្គិជារូប, នបុ. អគ្គិរូប ។ –រេតស គុ. ដែលកើតពីពួជនៃភ្លើង ។ –រោហិណី ស្ត្រី. ការ-យោហើមចោងក្រហមត្រង់ភ្លៀក ។ –លោក បុ អគ្គិលោក ។ –វចិស៑ បុ. តាមអាចារ្យនៃគម្ពីរបុរាណ: ។ –វណ៌ គុ “ដែលមានពណ៌ឆ្ងួចភ្លើង” ក្តៅ; បុ. បុត្រព្រះបាទសុទាស៑ ។ –វដ្ឋិន គុ. ដែលតាំងឡសំលេយអាហារ ។ –វល្លភ បុ. ឈ្មោះដើមឈើ។ វ៌ណ បុ.សរតំភ្លើង ។ –វ៌ត្តិ គុ. ដែលប្រព្រឹត្តទៅដោយភ្លើង, ដែលរស់នៅដោយភ្លើង ។ –វ៌ស៑ស៑ គុ. ដែលស្មៀកពាក់ដោយសំលៀកបំពាក់ក្រហម ។ –វ៌ហ បុ.ការយោតាំទៅនូវភ្លើង, អគ្គិភាវ; ផ្សែង ។ – វិរមាបន នបុ. ការយោបន្ថយនូវភ្លើងតិធិ(ដោយយកភ្លើងចេញខ្លះ) ។ – វិសជ៌ បុ. ការយោពង្រីកនូវភ្លើង ។

-វិហារណ ន.បុ. ការយោគាំទៅនូវរភ្លើង (ពីអាគ្គីន្រះទៅ សទ្ទសិ ខណ្ឌ) ។ -វីយិ ន.បុ. មាស ។ -វ្ឫទ្ធិ ស្ត្រី. ការយាចម្រើនដោយភ្លើង (ដំណើរអាហារ) ។ -វេលា ស្ត្រី. អគ្គិវេលា, (វេលាដុតភ្លើង) រសៀល ។ -វេគ បុ. តាមបុរសផ្សេងៗ, តាមអាចារ្យ របស់ព្រាហ្មណ: ។ -វេគ្គិន បុ. ថ្ងៃទី១៤នៃកក្តិ-មាស ។ -វេទ្យ បុ. តាមនៃ អាចារ្យក្នុងរឿងការព: ។ សវណ ឬ -សាល ន.បុ - សាលា ស្ត្រី. "សាលា សម្រាប់ទុកភ្លើងពិធី" អគ្គិសាលា ។ -សិខ ពុ. ដែលមានចុងក្តៅដូចភ្លើង; បុ. សរ; ចង្កៀង; តាមបិតានៃវរុចិ, កថាស; តាមនៃវេតាល, កថាស; ន.បុ. រមៀត, មាស ។ -សិខា ស្ត្រី. អណ្តាតនៃភ្លើង ។ -សុស្រូសា ស្ត្រី. ការយាប្រយ័ត្នរក្សានូវភ្លើងពិធី ។ -សេតុណិ ស្ត្រី ដើងក្រាខភ្លើងពិធី ។ -ស្តុត បុ. "អ្នកស្តុតភ្លើងពិធី", បឋម-វិរៈនៃអគ្គិឆោមពិធី, ថ្ងៃមួយនៃសត្រ បញ្ចទក្ខព្រះ ។ -ស្តោម បុ. ពិធីអគ្គិស្តោម: (ស្មូត្រមួងសួងព្រះអគ្គិ) ។ -ស្ត ពុ. ដែលបិតនៅក្នុង ឬ លើ ឬ ជិតភ្លើង; បុ. ខ្ទះ, យាន សម្រាប់តាំព្រះអគ្គិ ។ -ស្ថិកា ស្ត្រី. ខ្ទះ ។ -ស្វត្ត ឬ ស្វត្ត បុ.ពហុ. តាមព្រាហ្មណ៍ ។ -សំស្ការ បុ. ពិធីបួងព្រះអគ្គិ, ពិធីរំលាយសព ។ -ស ១ បុ. "សំឡាញ់នៃ ភ្លើង" ១ឈ្មោះ ។ -សំភាគ ពុ. ដែលភ្ជាប់នឹងភ្លើង ។ -សំចយ បុ. ការយារបួចចំ សម្រាប់បួងព្រះអគ្គិ ។ -សំភវ ពុ. ដែលកើតពីភ្លើង, បុ. រមៀតព្រៃ ។ -សរស ន.បុ. តាមតិថិ: ។ -សហាយ បុ. "សម្ភាញ់នៃភ្លើង" ១ឈ្មោះ, សត្វក្រាបព្រៃ

(មានត)

ភាសាសង្សកឹត

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ៩ ខែកញ្ញា ព.ស. ២៥០០ គ.ស. ១៩៥៦

ស. ស. ៩៤ ស្ត-១១-ច



ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បន្លែរឿង	ទំព័រ
– ទ្វារនៃប្រយោជន៍ ៦ យ៉ាង	ស្រី-ទ្រី រៀបរៀង	៧៤១
– អធិប្បាយពុទ្ធភាសិត	លំ-ឆម-ពេង រៀបរៀង	៧៤៦
– តើព្រះពុទ្ធសាសនាវិវត្តអភិវឌ្ឍត្រឹមណា ?	លោក ភ័យ-ប៊ុក ប្រែពីភាសាបារាំង	៨០១
ផ្នែកអក្សរសាស្ត្រ		
– អានុភាពនៃខ្មែរអតីត	លោក ភ័យ-ប៊ុក រៀបរៀង	៧០៦
– រឿងទេវីខ្មែរបស់អង្គឌួងក្សត្រីម៉ុក (តទៅ)	លោក ញឹក-ថៃម ពិនិត្យ	៧១៥
– រឿងសាមកុក (តទៅ)	ឧកញ៉ា ភូ-កាន ប្រែ	៨២៧
– រឿងហ្សាឆិត (តទៅ)	លោក ភ័យ - ប៊ុក ប្រែ	៨៤០
– អំពីបងប្អូនពីរនាក់ដែលមានដំណក់	លោកឡៀង-ឆៃ-ឃេង ប្រែរៀបរៀង	៨៤៥
ផ្នែកកំណត់ធម្មប្រវត្តិការណ៍		
– ដំណើរទស្សនាការរបស់ឯកឧត្តមអគ្គរដ្ឋទូតអាមេរិកនៃព្រះរាជាណាចក្រកម្ពុជា	(តទៅ) លោកជា-ទន់ រៀបរៀង	៨៥៧
– សន្ធិសីទនៃបណ្ឌិតវិស្សាទអេក្លិត ធ្វើនៅតុទ្ធិកវិទ្យាល័យព្រះសុភទ្រឹត លោក ភ័យ-ប៊ុក រៀបរៀង		៨៦៣
– ជីវប្រវត្តិសង្ខេបនៃឯកឧត្តមឧកញ៉ាឥន្ទ្រសុន អនុប្រធានទី៣នៃសភាធម្មនុញ្ញ	លោក ភ័យ-ប៊ុក រៀបរៀង	៨៦៩
– វចនានុក្រមសំស្ក្រឹត-ខ្មែរ (តទៅ)	ព្រះមហាយ៉ឹង-ទាត់ រៀបរៀង	៧៣៦

មួយឆ្នាំមាន ១២ លេខ តម្លៃលក់ ២៣០រៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

-Les six bienfaits du Buddhisme par *M. SREY-OU* 791
-Adhippaya Bouddhabhasita par *M. LY-THIEM-TENG* 796
-Où en est le Bouddhisme ? traduit par *M. RAY-BUC* 801

PARTIE LITTERAIRE:

-Le passaé glorieux Khmer par *M. RAY-BUC* 806
-Histoire de Devanda de *M. MOK*, (suite)
revue et corrigée par *M. NHOC-THEM* 815
-Histoire de Samkok (suite) traduit par *M. NOU-KAN* 828
-Histoire de Zadig (suite) traduit par *M. RAY-BUC* 840
-La légende de deux frères et du coq de
combat traduit par *M. TIANG-TAY-CHHUN* . . . 845

NOTES ET CHRONIQUES :

-Voyage du Vénérable HUOT-TAT aux
U. S. A. (suite) par *M. CHEA-TONN* 857
-Conférence du Dr. RICHARD A. GARD au Lycée
Buddhique Préah Suramarit par *M. RAY-BUC* . . . 863
-Biographie du Dr. RADHAKRISNAN par *M. RAY-BUC* . . 869
-Dictionnaire Sanskrit-khmer par Vén. *PANG-KHATH* 876

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

ទ្វារនៃប្រយោជន៍ ៦ យ៉ាង

ឃុនសិរីមេធី ស្រី-អ៊ូ

ក្រុមដំនុំព្រះត្រៃបិដក នៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

ប្រទ្បងប្រជែងបានទទួលរង្វាន់ ក្នុងឱកាសបុណ្យ

ព.ស. ២៥៦០

ធម្មទេសនាដែលព្រះដ៏មានព្រះភាគ សំដែងប្រោសសត្វអស់រយៈកាលជាយូរមកហើយ ដែលចងក្រងជាគាថានោះ ច្រើនពាន់ពេក ក្នុងទីនេះ ខ្ញុំសូមដកស្រង់គាថាមួយនៅក្នុងគម្ពីរ ជាតកដ្ឋកថា ទុតិយភាគ ដែលព្រះដ៏មានព្រះភាគទ្រង់សំដែងប្រារព្ធចំពោះកុលបុត្តម្នាក់ នៅវត្តព្រះជេតពន ជិតក្រុងសាវត្ថី, គាថានោះ សំដែងអំពីទ្វារនៃប្រយោជន៍ ៦ យ៉ាង ដូចតទៅ៖

អាភេត្យមិច្ចេ	បរមញ្ច លាភំ
សិលញ្ច តុដ្ឋានុមតំ	សុតញ្ច
ឆម្ហានុវត្តិំ ច	អលីនតា ច
អត្ថស្ស ទ្វារា	បមុខា ឆឥច្ចតេ ។

ប្រែថា៖ បុគ្គលគប្បីប្រាថ្នាទ្វារមិនរាប់ភាគ ជាលាភ-ក្រៃលែង ១,

ការប្រព្រឹត្តវៀរវេរ ១, សេចក្តីយល់តាមនុភាព នៃអ្នកប្រាជ្ញ ១ ការស្តាប់, ការរៀនសូត្រចេះដឹងច្រើន ១, ការប្រព្រឹត្តតាមសុចរិតធម៌ ១, សេចក្តីមិនជំអក់ខំរន់ ១, ធម៌ទាំង ៦ នេះ ពុកជាទ្វារ ពុកជាប្រមុខនៃប្រយោជន៍ ។

សេចក្តីអធិប្បាយ:

ខ្ញុំសូមដកស្រង់ធម៌ទាំង ៦ ដែលជាទ្វារនៃប្រយោជន៍ ក្នុងគម្ពីរ-សិតនេះ មកដំរៀបជាមាតិកា ហើយអធិប្បាយមួយម្តងមួយ ។ ឲ្យល្មមស្តាប់បានដូចតទៅ៖

១-អារោគ្យៈ ការមិនមានរោគ គឺ

ក) រោគញាណគឺជម្ងឺតម្កាត់ទាំងអស់ មានសរីរកាយជាប្រក្រតី (ជាដែនកើត) ព្រោះថា រាងកាយរបស់សត្វទូទៅ សុទ្ធសឹងលាបស្រឡាបដោយសាច់ឈាម, គ្រវេដណ្តប់ដោយស្បែក, ប្រឡាក់ប្រឡែងដោយសរសៃ, បញ្ចុះជ្រុំដោយក្រពះធំធ្ងន់ពោះវៀនតូច-ធំ-សួត-ថ្លើម, មានធ្មេញជាសសរធំធ្ងន់ ចន្ទល់ អាការៈទាំងនេះពុកជាលំនៅនៃរោគ ។ រោគកិបណ្តាលឡើងឲ្យឈឺចាប់ស្គមរាងវៃ ចុកសៀត រួយស្រពន់ ក្នុងរាងកាយជាដើម ហៅថា កាយិករោគ (រោគក្នុងរាងកាយ) ។ បុរសស្ត្រីណាមួយ កាលបើកើតរោគាញាធផ្សេង ។ ហើយ មិនអាចនឹងរកប្រយោជន៍បានឡើយ សូម្បីកោតទ្រព្យដែលមានស្រាប់ហើយ ក៏មិរកោតប្រើប្រាស់មិនបាន ។ ភាពនៃបុគ្គលមានរោគនេះ ជាទោសមួយនាំឲ្យខាតប្រយោជន៍ត្រង់ប៉ាង ។

១) តំលេសទាំង៦ឯណោះ មានលោភៈទោសៈមោហៈជាដើម ចាត់ជាកេតចាក់ជោតចិត្ត ធ្វើចិត្តឲ្យសៅហ្មង ឲ្យកកស្អុកជាដើម ហៅថា ចេតសិកកេត (កេតប្រព្រឹត្តទៅក្នុងចិត្ត) ។ បុរសស្ត្រីកាលបើចិត្តប្រកបដោយតំលេសកេតហើយ មិនអាចធ្វើកុសលផ្សេង។ បានទេ សូម្បីកុសលខ្លះដែលបានធ្វើហើយ ក៏ទំនងនាំសបាត់ទៅវិញ ។ ហេតុនោះ ការមិនមានកេត ទើបឈ្មោះថា ជាលាភដ៏ក្រៃលែង ជាទ្វារបើកឲ្យប្រយោជន៍ហូរចូលមក ។

២- សីលៈ ការប្រព្រឹត្តរៀបរយល្អ គឺការប្រព្រឹត្តិល្អ ដោយកាយវាចា មិនឲ្យកាយវាចាប្រព្រឹត្តល្មើសឈ្មោះខាន បំពាល់សិទ្ធិសេរីភាពនៃបុគ្គលដទៃ, ការមិនទំយោយកុហក មិនដឹកសុរា; មិនប្រព្រឹត្តអបាយមុខទាំង ៤ ណាមួយ នេះហៅថា "សីល" ។ បុគ្គលមានសីលបរិសុទ្ធហើយ រមែងឃើញផលានិសង្សជាក់ប្លាស់ទំនឹងក្នុង តាំងអំពីជាតិនេះរហូតដល់បរលោក ឈ្មោះថា បើកទ្វារឲ្យប្រយោជន៍ហូរចូលមក ។

៣-ភាវនាមយ ការយល់តាមនូវបរមត្ថរបស់អ្នកប្រាជ្ញ ។ ព្រះអរិយៈទាំង៦ឯណោះមានព្រះភ្នែកជាដើម តែងសំដែងធម៌បញ្ញត្តិទំនៃ ដើម្បីទូន្មានប្រៀនប្រដៅដឹកនាំសត្វលោក ឲ្យប្រព្រឹត្តល្អ ចៀសវាងទោសទៃ។ កាលបើ សត្វលោកព្រមស្តាប់ចិត្តទទួលនូវនោះហើយ ប្រតិបត្តិតាមត្រឹមត្រូវយ៉ាងហ្មត់ចត់ ប្រាកដជាទំនងបានប្រយោជន៍ដ៏ធំធេងណាស់ ឃើញជាក់ប្លាស់ទំនឹងក្នុងភ្លាមៗខាន ។

៤-សុតៈ ការស្តាប់, ការរៀនសូត្រ,ចេះដឹងច្រើន គឺការសិក្សាវិជ្ជា

ផ្សេង ។ ជានចេះដឹងច្រើន ទុកដូចជាមានកូនសោសម្រាប់ចាក់បើកភ្ជាប់ឆ្ងល់ប្រយោជន៍ឱ្យចូលមក ទាំងកងចិត្តប្បន្ន ឧដ្ឋបរលោក ។

៥-ធម្មាត្តុរិត្តិ ការប្រព្រឹត្តិតាមសុចរិតធម៌ ។ សុចរិតធម៌មាន ៣ ប្រការ គឺកាយសុចរិត, វចីសុចរិត, មនោសុចរិត ។ សុចរិតធម៌ទាំង ៣ ប្រការនេះ ចាត់ជាធម៌សម្រាប់មនុស្ស ជាធម៌ទ្រទ្រង់មនុស្ស, ឱ្យមានហានៈខ្ពង់ខ្ពស់ មិនឱ្យធ្លាក់ចុះ ក្នុងរណ្តៅថោកទាប ជាធម៌ត្រួបដណ្តប់បិទបាំងបាប មិនឱ្យបាបចូលមកបាន ដូចជាឆ័ត្របិទបាំង មិនឱ្យត្រាប់ភ្លៀងធ្លាក់ត្រូវ ។ បុរសស្ត្រីត្រូវមានសុចរិតធម៌ ៣ ប្រការ ទើបជាទីពុកចិត្តនៃមនុស្សជនគ្នា ស្ទុះស្ទួនរកប្រយោជន៍ទាំងពួង ឧដ្ឋបានសម្រេចដូចបំណង ។ ការប្រព្រឹត្តិតាមសុចរិតធម៌ ឈ្មោះថា បើកភ្ជាឱ្យប្រយោជន៍ហូរចូលមក ។

៦- អ្លីឆត្តា ការមិនដំអក់ខំរន់, សេចក្តីមិនខ្ជិលច្រអូស ។ ការមិនដំអក់ខំរន់នេះ ជាឈ្មោះនៃសេចក្តីព្យាយាម ក្នុងករណីយកិច្ចទាំងពួង ។ បុគ្គលត្រូវព្យាយាមតស៊ូនឹងទុច្ចរិត្ត គឺកោសជ្ជៈ (សេចក្តីខ្ជិលច្រអូស) ព្រោះកោសជ្ជៈជាមេកន្ត្រាញយ៉ាងធំ មកជំទាស់ មិនឱ្យធ្វើអ្វីបានទាំងអស់ ។ បុគ្គលដែលបណ្តោយឱ្យសេចក្តីខ្ជិលជិះជាន់បាន ច្រើនដំអក់ខំរន់ថា ព្រឹកពេក, ត្រជាក់ពេក, ថ្ងៃពេក, ក្តៅពេក, ឃ្លានពេក, ស្រេកពេកជាដើម ពុំអាចនឹងប្រកបការងារទាំងពួងបាន ធ្លាក់ខ្វិនទៅជាមនុស្សថោកទាប ដើមមុខមិនរួច ។ បុគ្គលត្រូវមានព្យាយាមមិនរួញរា ត្រូវមានចិត្តក្លាហាន

តស៊ូចំពោះការងារដែលត្រូវធ្វើ មិនគិតអំពីត្រជាក់ក្តៅជាដើម ទើប
សម្រេចប្រយោជន៍ដូចបំណង ។ បុគ្គលប្រាថ្នាធំធ្វើការងារណាមួយ
ឬប្រាថ្នាធំរៀនវិជ្ជាណាមួយ ត្រូវបោះធន្លុះទៅថ្ពក់ជាប់ធំធំគោលបំណង
ហើយបញ្ជះរីរាយៈ ឲ្យតែសព្វសារសិណាម តស៊ូគាល់តែបានសម្រេច
ដូចបំណង ដូចព្រះសក្យមុនី កាលទៅជាពោធិសត្វ បានធ្វើដំណើរដោយ
ឆាក់ចក្ខុលសមុទ្រ កំបែកសំពៅទៅកណ្តាលសមុទ្រ ទ្រង់ឡើងទៅលើ
ជង្គង់ក្តោងសំឡឹងមើលគោះក្រៃយ ដើម្បីនឹងហែលសំដៅទៅរក កំឃើញផ្ទៃ
សមុទ្រធំធេង ល្វាលាំ មិនដឹងត្រើយនៅត្រឹមណា ទ្រង់តាំងព្រះទ័យថា
ផ្ទៃសមុទ្រថ្លើបើធំសំបើមដល់ម្ល៉ះ បងធំធំលើសនេះទៅទៀត កំអាត្មាអញ
មិនញាក់ដែរ ហើយក៏បន្តឹងតទ្រូងហែលលើផ្ទៃសមុទ្រ បែរសំដៅទៅរក
ត្រើយ, ដោយរឹងប៉ាមាំនោះ កំមានទេវតាមកជួយអង្គ្រងាំទៅជាក់ដល់
ត្រើយ ជាទីបញ្ចប់តអំពីសេចក្តីអន្តរាយ ។ រឿងនេះបញ្ជាក់ឲ្យឃើញថា
សេចក្តីមិនរួលប្រមូស ជាហេតុនាំឲ្យបានសម្រេចប្រយោជន៍ ដូចបំណង
មែន ខុសជាគ្មានបើកឲ្យប្រយោជន៍ហូរចូលមក ។

អធិប្បាយអំពីចម្ងាយគ្មានប្រយោជន៍ ៦ យ៉ាង

ចប់ ត្រឹមប៉ុណ្ណេះ។

អធិប្បាយពុទ្ធភាសិត

អត្ថបទទួលទង្វាន់ក្នុងការប្រឡងប្រជែង ក្នុងពិធីបុណ្យ

ព.ស.២៥០០

លឹ-ជាមតេង

សមាជិកក្រុមអភិបាលសមាគមអ្នកនិពន្ធខ្មែរ

រៀបរៀង

ព្រះសម្មាសម្ពុទ្ធជាបរមគ្រូនៃយើងកល់គ្នា ព្រះអង្គបានចងទុកនូវពុទ្ធភាសិតជាច្រើន សំរាប់ធ្វើជាទីរាប់ដល់ជនានុជន ពត់កាយវាចាចិត្តឲ្យស្របទៅតាមសុគតិធម៌; ដូចជាពុទ្ធភាសិតមួយបទយ៉ាងខ្លីពោលថា:

"អព្យាបជ្ឈំ សុខំ លោកេ

ប្រែថា: "ការមិនព្យាបាទ ជាសេចក្តីសុខក្នុងលោក" ។

ភាសិតនេះខ្លីមែន តែមានន័យយ៉ាងជ្រៅជ្រះ គប្បីយើងរើសយកមកត្រិះរិះពិចារណាកេហេតុផល របស់ពុទ្ធទីន្ទាន់ខ្នោះ ។ ពាក្យថា "ការមិនព្យាបាទ ជាសេចក្តីសុខក្នុងលោក" គឺជាពាក្យរស់រវើកមានអាយុតាំងពីពុទ្ធសម័យ រហូតមកដល់បច្ចុប្បន្នសម័យនេះ នៅតែគង់វង្សជាខ្លឹមសារឥតសាបរលាបឡើយ ។

"ការមិនព្យាបាទ ជាសេចក្តីសុខក្នុងលោក" បានសេចក្តីថា ក្នុងលោកយើងនេះ បើគ្មានការព្យាបាទដល់គ្នាទីឆ្ងាយគ្នាទេ សេចក្តីសុខនឹងកើតមានដល់ជនគ្រប់រូបជាប្រាកដ ។ ន័យមួយទៀតថា បើប្រសិនជាជនគ្រប់គ្នាឥតមានការព្យាបាទទៅវិញទៅមកឬ ព្យាបាទចំពោះជនម្នាក់ៗទេ

សេចក្តីសុខទើតកើតមានជាមិនខាន ទៅក្នុងលោកយើងនេះ ។ ឯការព្យាបាទនេះ អាចចែកជាវគ្គផ្សេងពីគ្នាបានដូចតទៅ៖

ក- ការព្យាបាទរវាងបុគ្គលទៅនឹងបុគ្គលគឺថា បើបុគ្គលមួយមិនមានការព្យាបាទ ឬ បៀតបៀនបុគ្គលមួយទេ, បុគ្គលដទៃនោះឯង ក៏តង់ប៉ិតនៅក្នុងសេចក្តីសុខរៀបរយដូចប្រក្រតី គ្មានរង្គើសសៅហ្មងអ្វីឡើយ ។ បើប្រសិនជាមានគេបៀតបៀនខ្លួនហើយ បុគ្គលនោះមិនមានចិត្តបង្អាក់ការព្យាបាទទៅអ្នកប្រព្រឹត្តមុនវិញទេ នោះទុក្ខសោកដែលមានមកដល់ខ្លួន ក៏មិនរំលងទៅដល់ជនប្រព្រឹត្តហើយនោះដែរ ។ ដូច្នេះ សេចក្តីស្ងប់ទើតកើតមានឡើងមួយរំពេច តែចប់ផុតរលត់សេចក្តីទុក្ខទៅតែត្រឹមនេះដោយសារបុគ្គលគ្មានបន្តដំណើរព្យាបាទឲ្យវែងឆ្ងាយទៅទៀតឡើយ ។

ខ- ការព្យាបាទរវាងគ្រួសារទើងគ្រួសារ, ចំពោះការព្យាបាទរវាងគ្រួសារទើងគ្រួសារនេះ បានសេចក្តីថា តែគ្រួសារមួយ មិនបៀតបៀនគ្រួសារមួយទៀតទេ,គ្រួសារនោះទើងបានសេចក្តីសុខកាយសប្បាយចិត្ត ឥតត្រូវបារម្ភអ្វីបន្តិចបន្តួចឡើយ ។ គេរស់នៅជាមួយក្រុមញាតិវង្សត្រកូលគេ យ៉ាងសុខសាន្តជាមិនខាន ។

គ- ការព្យាបាទរវាងជាតិទើងជាតិ ឬ ប្រទេសទើងប្រទេស ព្យាបាទរបៀបវគ្គនេះ មានទំហំយ៉ាងធំលើសការព្យាបាទមុន ។ តើអាចបំផ្លាញបានខ្លះសេចក្តីសុខយ៉ាងធំរបស់មនុស្សគ្មានទើងព្រំកំណត់ ។ ដូច្នេះ សង្គមទូទៅក្នុងលោក មិនគប្បីចំអាយព្យាបាទយ៉ាងនេះទេ ត្រូវតែជួយសាងភាពនៃសង្គមជាតិមួយ ។ គ្មានការព្យាបាទ ឬ ការបៀតបៀនគ្នាទេ សេចក្តី

ស្ងប់រៀបរយ ពោលគឺសន្តិភាព ទើរតើតមានដល់ប្រទេសនោះជាមិនខាន ។ រីឯអ្នកគ្រប់គ្រង ឬអ្នកដឹកនាំប្រទេសនោះវិញ ក៏ជានិយមនឹងចាត់ចែងការដែនដីគ្រប់ជ្រុងគ្រប់ជ្រោយ បង្កើតជាសេចក្តីសុខសាន្ត. គ្រាណា សំពាប់មនុស្សគ្រប់រូប ដែលរស់នៅក្នុងប្រទេសនោះ ។ ចុះបើពលរដ្ឋក្នុងប្រទេស មានការព្យាបាទដល់គ្នាវិញ នោះសេចក្តីសុខដូចពោលខាងលើនេះនឹងផុតរលត់ជាមិនខាន ។ យើងគង់យើញដាក់ស្តែងស្រាប់ហើយ ពិតណាសម័យមុននេះបន្តិច ឬ ក្នុងសម័យបច្ចុប្បន្ននេះ ដែលកំពុងជួបពេលទៅដោយភ្លើងកិលេស គឺ លោភៈ ទោសៈ មោហៈ បង្កើតជានការព្យាបាទរវាងជាតិមួយនឹងជាតិមួយ បណ្តាលឲ្យមនុស្សជាតិច្រាសចាកសេចក្តីសុខសាន្ត គ្រប់ប្រការ ហៃរជារឿងទុក្ខវេទនា ដូចជាការបង្កិនចំផ្លាញដ៏តែមនុស្ស ធ្វើឲ្យហិនហោចខ្ទេចខ្ទីជាតិផ្សេង ។ ដែលមនុស្សត្រូវការពើនប្រមាណជាដើម ។ យ៉ាងនេះឯងជាការព្យាបាទពេលណា បង្កិនលោក ដូចជាមានពុទ្ធភាសិតមួយទៀតពោលថា: "អវតិ លោកនាសតា ប្រែថា "សេចក្តីប្លន់ជាហេតុញ៉ាំងលោកឲ្យវិនាស" ។

បើពោលតាមន័យប្រៀបធៀបវិញ ពុទ្ធភាសិតនេះ ស្របដូចរឿងមួយក្នុង"បញ្ញាសជាតក"ត្រង់ជាតកទី ៤ ដែលលោកយកញ៉ាំ កោសាធិបតីកៅ ជាកវីឯក ជានបកប្រែរៀបរៀង ជាភាសាគម្ពីរភាសាខ្មែរឲ្យឈ្មោះថា "ក្រឹងសុភមិត្រ" ។ រឿងនោះមានសេចក្តីដូចតទៅ ៖

កាលនោះ ព្រះបរមពោធិសត្វ ជានយោនយកកំណើតកើតជាព្រះ

មហាកស្សបត្ថេរមួយអង្គ ស្មោះយកជ្រៅចំបង្អាកប្លែ ព្រះនាមព្រះបាទ"ក្រុងសុភមិត្រ" ។ ព្រះអង្គមានអគ្គជាយា ប្រកបដោយគុណលក្ខណ៍ត្រមាំងព្រះពជបុត្រាតីព្រះអង្គ សឹងនៅតួបនៅឡើយ ។ ថ្ងៃមួយ ព្រះទបកជនាម"អសុភមិត្រ" ដែលត្រូវជាព្រះអនុជបង្កើតរបស់ព្រះអង្គ បង្គំទូលថ្វាយមកខ្លាមថាបំព្រះពជា ដណ្តើមយកពជសម្បត្តិរបស់ខ្លួនឯង ។ ប៉ុន្តែជាបុណ្យសម្ភារបស់ព្រះអង្គ ព្រះបាទក្រុងសុភមិត្រទ្រង់ជ្រាបការនេះជាមុនហើយ ព្រះអង្គទ្រង់ត្រិះរិះថា ប្រសិនណាជាទ្រង់លើកទំពាសៅតទល់នឹងអំពើលោភរបស់អនុជចិត្តភ្លាំងនេះ នឹងនាំឲ្យអន្តរាយដល់ជីវិតកងរបាជានឹងរបស់ទ្រព្យអ្នករស់នៅក្នុងស្រុក,កងនគររបស់ទ្រង់ជាមិនខាន ។ កាលទ្រង់ឈ្វេងយល់ដូចនេះហើយ, គឺទាំងអគ្គមហេសីនឹងបុត្រាទាំងគួ លួចគៀបព្រះអង្គចេញពីក្នុងពជកិច្ច ទាំងក្នុងពត្រីសូម្បីសោត ឥតមានជនណាជឿជាន់ឡើយ ។ លុះព្រឹកឡើង គ្រាដែលត្រូវអនុជលើកទំពាមកតំខ្លួនមិនបានឃើញអង្គព្រះពជាទេ គឺប្រកាសតាំងខ្លួនឯងជាស្តេចគ្រងពជ្យឡើង ។ ចំណែកព្រះរៀមជាស្តេចទ្រង់ធម៌វិញ ព្រះអង្គយាងគ្រាច់ដោយព្រៃព្រឹក្សាសាវល្លិ ចំរើនធម៌មេត្តាភាវនាតាមដូរ ឥតមានខាននៅពេលណាឡើយ ។ លុះដល់ទីបំផុតនៃពជជីវិតណើរ និពសដោយព្រៃ នឹងក្រោយពេលគ្រាត់ច្រៀបព្រះខ្លាំ នឹងប្តូរាមក, ព្រះអង្គក៏ត្រៀបស្មានផ្សឹងតដៃខ្លួនទៅនតតក្តៅសិលា មកយាងព្រះអង្គឲ្យឡើងគ្រងពជសម្បត្តិ ទៅកាន់ប្រាសាទនោះ ។ ទ្រង់ក៏បានជួបជុំពជាយានឹងបុត្រាទាំងគួ ស្មោះយកសម្បត្តិ ដ៏សុខសាន្តគ្រាណាយូរលង់ ។

សង្ខេបសេចក្តី៧ ពុទ្ធភាសិតនេះ ដាក់ប្រទីបត្រោលបំភ្លឺយើងឲ្យស្គាល់មគ្គ ដែលត្រាច់ឆ្ពោះទៅកាន់សេចក្តីសុខសេចក្តីចំរើន ហើយពុទ្ធភាសិតនេះ អាចបដិបត្តិបានគ្រប់ប្រមូលទុស្ស ក្នុងលោក មិនថាអ្នកកាន់ពុទ្ធសាសនា ឬ កាន់សាសនាដទៃនោះទេ ដើម្បីដៀសវាងពីការបង្កបង្កើតសឹកសង្គ្រាម ដែលតែងធ្វើឲ្យវិនាសធម៌ នាំឲ្យសត្វលោកវេទនាឥតប្រៀបផ្ទឹមបាន ។

ចប់ ។

សេចក្តីរួបរួម

រីព្រះបរមភពម្លប់ត្រៃលោក
ទ្រង់មានជ័យជោគបានទេសនា
ប្រដៅសព្វសត្វមនុស្សទេព្រឹ
ដោយពុទ្ធដីកាប្បាស់ស័ក្តិសិទ្ធិ ។
ថា «ការមិនបៀតបៀនគ្នាវិគ្នា
ជាសុខមហិមាក្នុងលោកពិត»
បើជនគ្រប់ជាតិបានប្រព្រឹត្ត
កាន់តាមភាសិតនេះសុខហោង ។

ប្រ.ធ.

តើព្រះពុទ្ធសាសនារីតែមកដល់ត្រឹមណា ?

សន្តិសីទលោក ភ.ភ. ភាហុល ថ្នែងនៅវិទ្យាល័យ ឥទ្ធិអាទិទេពនិយម
(Collége Idéologique) ដទីក្រុងជាំសៃ កាលពីថ្ងៃទី ១០ ធ្នូ ១៩៤៦

លោកវ៉ាយ-ប៊ុក ប្រែពីភាសាចិនមកជាភាសាខ្មែរ

ព្រះពុទ្ធសាសនា ឬ ឧត្តមព្រះសម្ពុទ្ធជារបៀបដ៏វិសាល ដែលត្រូវតែពិសោធប្រព្រឹត្តប្រតិបត្តិអនុវត្តតាម ចំពោះដំណាក់កាលថ្មី, ដ៏វិសាលសង្គមនីមួយៗ ក្នុងសម័យបច្ចុប្បន្ន ។

ពុទ្ធសាសនាជារបៀបមួយដ៏ធំ ហើយពេញលក្ខណៈនៃការសិក្សាសីល-ធម៌, ទស្សនវិជ្ជានឹងចិត្តវិជ្ជា ដែលបានព្រែកវែកពិតប្រាកដ ប្រកបដោយវិទ្យាសាស្ត្រដ៏ប្រសើរ របៀបដែលចូលទៅជ្រួតជ្រាបចំពោះទិដ្ឋភាពគ្រប់យ៉ាង នៃជីវិតមនុស្សលោក ។ គឺជាផ្លូវមួយដែលនាំមនុស្សទៅតាមថ្នាក់-ជាន់ដោយច្រើន ជាមៈធ្យាបាយគឺវិន័យ ប្រកបដោយសីលធម៌, លោកិយប្បញ្ញា, លោកុត្តរប្បញ្ញា ឲ្យបានចម្រើន ទូលំទូលាយដ៏ទត្តម, គឺបត្តុកាយសច្ចនឹងព្រះនិព្វាន ។

ខ្ញុំមិនមានបំណងចង់រោលពីលទ្ធិដ៏ជ្រាលជ្រៅ ប្រកបដោយទស្សនវិជ្ជា, ចរមត្តវិជ្ជា នឹងចិត្តវិជ្ជា ព្រមទាំងពុទ្ធសាសនប្រវត្តិទេ ។ តែបើតាមអត្ថបទ ដែលបានដំរាបមកនេះ, ខ្ញុំយល់ថា គួរតែបញ្ជាក់អំពីស្ថានភាពព្រះពុទ្ធសាសនា ក្នុងសម័យសព្វថ្ងៃ នឹងអនុភាពព្រះពុទ្ធ-សាសនា ចំពោះដំណាក់កាលសង្គម, នយោបាយនៅលើទ្វីបអាស៊ី ដែលជាតំបន់ដែលសម្រាប់យកទៅសាងមនុស្សជាតិ ក្នុងកាលជាអនាគត ។

ហេតុនេះ, យើងចាប់ផ្តើមពី គ.ស. ១៩៤៨, ក្នុងពេលដែលប្រទេសឥណ្ឌា, ប្រទេសប៉ាគីស្តង់, ប្រទេសភូមា, ប្រទេសស៊ីលង់ក្លាបានឯករាជ្យ ដោយសម្បូណិភាព ។ ព្រឹត្តិការណ៍នេះគេទុកជាបឋមសម័យថ្មីដែលធ្វើឲ្យទ្វីបអាស៊ីប្រែប្រួតម្តងទៀតជាថ្មី ។ ប្រជាជាតិនៃទ្វីបអាស៊ីគាំងមួល បានដឹងខ្លួនដោយខ្លួនឯងថា ខ្លួនបានរក្សាវប្បធម៌ និងប្រាជ្ញាដ៏ប្រសើរ តាំងពីយូរណាស់មកហើយ ។

នៅទីនេះ យើងត្រូវនឹកថា ព្រះពុទ្ធសាសនាជាកត្តាមួយ ដែលជាតិមានសភាពសំខាន់ ហើយមានអានុភាពជាងគេ ។

ពិតមែនតែព្រះពុទ្ធសាសនា បានបដិសន្ធិចំរើនរុងរឿងនៅប្រទេសឥណ្ឌា, ប្រទេសនេះ សម័យបច្ចុប្បន្ន មានពុទ្ធសាសនិកជនមានចំនួនតិចណាស់; ព្រះពុទ្ធសាសនាបានលេចសាជាសូន្យ ក៏ប្រទេសនេះ តាំងពីសតវត្សរ៍ ទី ១១ ។

គេបានឃើញព្រះពុទ្ធសាសនា បិតនៅនានាប្រទេស នៃទ្វីបអាស៊ី ដូចជាប្រទេសលង្កាទ្វីប, ប្រទេសភូមា, ប្រទេសថៃឡង់, ប្រទេសកម្ពុជា, ប្រទេសលាវ, ប្រទេសយៀតណាម, ប្រទេសជប៉ុន, ប្រទេសចិនទឹងប្រទេសទីបេត ។ មានក្រុមពុទ្ធមាមកជននៅប្រទេសនេប៉ាល់, ប្រទេសប៉ាគីស្តង់, ប្រទេសអិនដូណេស៊ី, ប្រទេសម៉ាឡេស៊ី ។ ចំណែកឯប្រទេសឥណ្ឌា បានកាន់សាសនាហិណ្ឌូដោយភាគច្រើន ហើយសមាជិករដ្ឋាភិបាល សុទ្ធតែគ្រហស្ថគាំងអស់ ។

តែអ្នកណែនាំឥណ្ឌា លោកជ្រាបថា វប្បធម៌ ទឹងអារ្យធម៌ឥណ្ឌា

ជាទីវិត្តសៅដល់ថ្នាក់ខ្ពស់ជាងគេ នៅរជ្ជកាលព្រះបាទអសោកនិងសម័យ
សន្តតិវង្សតទៅ, លោកបានទទួលស្គាល់ថា ព្រះសម្មាសម្ពុទ្ធបរមគ្រូ
ជាមហាបុត្រនៃប្រទេសឥណ្ឌា; វត្តតែមួយគឺព្រះពុទ្ធសាសនាដែល
ប្រទេសឥណ្ឌា ជាទីរួចំពោះប្រជាជាតិភាគច្រើនអស់ហើយ ប្រជាជាតិ
ភាគច្រើននេះ បានទទួលដោយសេចក្តីសោមនស្ស ។ លទ្ធិហិណ្ឌូមានព្រំ
ដែនត្រឹមតែប្រទេសឥណ្ឌាតែមួយប៉ុណ្ណោះ មិនមែនជាសាសនារាល
ជាតិនោះឡើយ ។ មានប្រទេសឯទៀតជាច្រើន ក្នុងទ្វីបអាស៊ីគោរព
ប្រទេសឥណ្ឌា ព្រោះថា ប្រទេសនេះ បានធ្វើអំណោយព្រះពុទ្ធ-
សាសនាចំពោះពិភពលោក ។ ពពួកហិណ្ឌូភាគច្រើនអស់ ដែលមាន
ប្រាជ្ញាចេះដឹងត្រៀវត្រែះ បានសំដែងសេចក្តីគោរពជាខ្លាំង ព្រមទាំង
សេចក្តីពេញចិត្តពន់ពេក ចំពោះព្រះពុទ្ធសាសនា ។

ព្រោះហេតុដូច្នេះ, ពួកអ្នកណែនាំប្រទេសឥណ្ឌា បានយកធម្មចក្រ
ជាព្រះសិង្ហាព្រះអាទិត្យអសោក ដែលជាទិម្មិតរូបនៃពុទ្ធសាសនា យកមក
ជាក់នៅលើទង់ជាតិនៃប្រទេសឥណ្ឌាឯកភាជ្ជ ។ ម្យ៉ាងវិញទៀត, ទិម្មិត
រូបនៃ "សិង្ហាព្រះបាទអសោក" គេយកមកជាក់លើត្រារបស់រដ្ឋ ។ ប្រ-
ធានរដ្ឋសភា ប្រទេសឥណ្ឌាឯកភាជ្ជ បានបិតនៅជិតត្រៃពុទ្ធរូបធ្វើពីប្ដ
សំដែងនូវសេចក្តីសៃធម៌ ដែលគេយកតម្លៃកន្លងទិសន្ទិជាត ។

លុះប្រទេសឥណ្ឌា បានប្រកាសសាធារណរដ្ឋមួយ, គេបានបោះពុម្ព
សៀវភៅមួយក្បាយថា តតិសាធារណរដ្ឋ មិនមែនជាតតិប្បទេសនិងកើត
មានឡើងទេ, ព្រោះថា សាធារណរដ្ឋទី ១ គឺព្រះសង្ឃក្នុងព្រះពុទ្ធសាសនា

ដែលព្រះសម្ពុទ្ធខ្រេង់បានស្ថាបនាឡើង តាំងពីសតវត្សរ៍ទី ៦ មុនគ.ស. ។

មានការចលនាជាធំ ដើម្បីនឹងឲ្យព្រះពុទ្ធសាសនារស់នៅជាថ្មីឡើងវិញ នៅប្រទេសឥណ្ឌា ព្រោះអ្នកទាំងអស់ជ្រាបស្រាប់ហើយថា ព្រះពុទ្ធសាសនាជាសាសនាមួយ ដែលបញ្ញត្តឲ្យមានសេរីភាពនឹងសមភាពចំពោះមនុស្សជាតិ ជាសាសនាមួយ ដែលពន្យល់អំពីវឌ្ឍនភាព នៃសង្គមវប្បធម៌ នឹងសេដ្ឋកិច្ច ។ ក្នុងចំណោមលោកអ្នក មានបុគ្គលខ្លះប្រហែលជាបានស្គាល់លោកដុកទ័រ អ័មបេដការ, អតីតរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ នៃរដ្ឋាភិបាលឥណ្ឌា ហើយជាប្រធានគណៈកម្មាធិការ ដែលបានស្ថាបនានូវរដ្ឋធម្មនុញ្ញ ប្រទេសឥណ្ឌាសម័យបច្ចុប្បន្ន ។ លោកដុកទ័រអ័មបេដការ មានវណ្ណៈជាពួកសូទ្រៈ, ជាវណ្ណៈប្រកបដោយមហិទ្ធានុភាពជាងគេ ។ លោកអ្នកក៏បានជ្រាបថា សង្គមហិណ្ឌូបានបែងចែកជាវណ្ណៈ។ ព្រះពុទ្ធសាសនាបានតស៊ូ ទាំងរបៀបវណ្ណៈ ហើយ ប្រកាសជាទង្វើរកនូវសមភាព នៃមនុស្សលោកទាំងអស់ ។ លោកដុកទ័រអ័មបេដការ ត្រឡប់ទៅជាពុទ្ធមាមកជន ហើយលោកបានទូន្មាន ឲ្យពួកសូទ្រៈទាំងអស់ ចូលក្នុងព្រះពុទ្ធសាសនា ។ លោកដុកទ័រនេះ ក៏បានណែនាំពន្យល់បំភ្លឺពួកសូទ្រៈ ឲ្យចូលមកកាន់ព្រះពុទ្ធសាសនា មានចំនួនជាង ២០០.០០០ នាក់ ។ លោកអ្នកប្រហែលជាបានជ្រាបថា ក្រុមវណ្ណៈមិនមែនជាក្រុម មានសារៈសំខាន់ទេ ព្រោះថា ក្រុមនេះ មានចំនួនសមាជិកច្រើនជាងចំនួនពលរដ្ឋ ប្រទេសថ្មីៗទាំងមូល ។

នៅគ.ស. ១៩៥០, ពុទ្ធិកសមាគមពិភពលោក បានស្ថាបនានៅ

គោះស៊ីរីលង្កា ។ គឺជាអង្គការពុទ្ធសាសនាពិភពលោក ដែលទើបទំនងបង្កើតជាលើកដំបូង, ហើយអង្គការនេះ បានប្រមូលប្រទេសដែលកាន់ព្រះពុទ្ធសាសនានៅទ្វីបអាស៊ីត្រមាំងក្រុមជាច្រើនមកពីទ្វីបអឺរ៉ុបនិងអាមេរិក ។

ម្ភៃប្រាំបួន ភូមិភាគ នៃប្រទេសពិភពលោក បានបញ្ជូនអ្នកតំណាងមកកាន់សន្និសីទពុទ្ធសាសនាសាកលនៅសិរីលង្កា ។ នានាប្រទេសដែលកាន់លទ្ធិថេរវាទ នឹងមហាយានក៏អញ្ជើញមកប្រជុំដែរ ។

ចូរយើងពិចារណាថា លោកអ្នកច្រើនពោលពាក្យថា ហីនយាន នឹងមហាយាន យានតូចនិងយានធំ ។ ចំពោះសន្និសីទនៃសិរីលង្កា, គេបានសម្រេចឯកច្ឆន្ទថា មិនត្រូវប្រើពាក្យ "ហីនយាន" (យានតូច) ត្រូវប្រើពាក្យថា "ថេរវាទ" វិញ គឺជាពាក្យសំរំ ដែលគេធ្លាប់ប្រើក្នុងគម្ពីរបុរាណ តាមប្រពៃណីមក ។ ពាក្យថា "មហាយាន" (យានធំ) ត្រូវប្រើឲ្យតិចទៅៗ ។ ចំណែកឯពាក្យថា "ហីនយាន" ត្រូវយកទៅឧទ្ទិសដល់ប្រទេសតាំងពីរ ដូចប្រទេសសិរីលង្កា, ប្រទេសភូមា, ប្រទេសថៃឡង់, ប្រទេសកម្ពុជា ។ល។ នេះគឺមកពីប្រទេសនេះមានវិស្ថាន៍ព្រះពុទ្ធសាសនា តិចតួចស្ទួចស្ទើរណាស់ ។

តាមសាតាតូទៅ, គេគិតទៅវិញទៅមកថា ពាក្យថេរវាទនឹងមហាយានជាសាសនាពីរផ្សេងគ្នា ដោយមានឈ្មោះជាសម្ងួតនាមថា ព្រះពុទ្ធសាសនា ។ នេះជាយោបល់មិនពិត ។

(មានត)

ផ្នែកអក្សរសាស្ត្រ

អានុភាពនៃខ្មែរអតីត

លោក រ៉ាយ-ប៊ុក រៀបរៀង

ខ្មែរតាំងសម័យបុរាណ មានអានុភាពអស្ចារ្យ ជាងខ្មែរសម័យបច្ចុប្បន្ន មានប្រាសាទបុរាណ បិតនៅពាសពេញប្រទេស ព្រមទាំងសិលាចារឹកជាច្រើនកន្លែង ដែលលោកជាសមាជិកខាងវិទ្យាស្ថានបារាំងបូព៌ាប្រទេស និងលោកជាបណ្ឌិត នៃបុរាណវត្ថុ ខាងបស្ចិមប្រទេស ជាន់ស្រាវជ្រាវរកឃើញជាច្រើនកន្លែង ។

អច្ឆរិយភាពទាំងនេះ ជាភស្តុតាងមួយសារៈសំខាន់ បញ្ជាក់ឲ្យឃើញថា ខ្មែរក្នុងសម័យបុរាណ ជាខ្មែរមានអារ្យធម៌ ដ៏ឧត្តុង្គឧត្តម ក្នុងមហាប្រទេសសុវណ្ណភូមិ ។

ចង់ប្លូនរួមជាតិទាំងឡាយ មុននឹងពណ៌នាអំពីអានុភាពនៃខ្មែរអតីត ខ្ញុំសូមពណ៌នា អំពីស្ថានភាព ឬ ភូមិសាស្ត្រនៃប្រទេសកម្ពុជា ពីសម័យបុរាណសិន ។

នៅសតវត្សរ៍ទី ១ នៃគ្រិស្តសករាជ, នៅទ្វីបអាស៊ីក្នុងមហាប្រទេសសុវណ្ណភូមិ មានព្រះរាជអាណាចក្រពីរ, ប្រកបដោយស៊ីវិលៃឆ្ពណ្ឌៃតីប្រទេសមហូរាណ ទឹងប្រទេសចិនឡា ។ ប្រទេសហូរាណ មានសិលាសាកាព រួបរួមទាំងប្រទេសកម្ពុជាខាងត្បូង ទឹងប្រទេសកូសាំងស៊ីន

សម័យបច្ចុប្បន្ន; ប្រទេសនេះ ជាន់តតម្ចិតភាព រហូតដល់ប្រទេសវៀតណាមខាងត្បូង ទឹងប្រទេសសៀម ដោយភូមិភាគច្រើនព្រមទាំងជ្រោយម៉ាឡាយូ ។ បើតាមសន្ធិសញ្ញាទំនោកមល្អីរ៉ែ ជាងហ្វាងនៃរដ្ឋាស្ថាន ចុងចូលប្រទេស ជាន់ថ្ងៃពីថ្ងៃទី ៤៨ ខែសភា ១៨៥១ នូវរឿងស៊ីវិល្ហ អ្នក អៅថា ប្រទេសហ្វូណាន មានទីក្រុងមួយ ឬ ព្រះរាជធានីនាម អ្នក_អៅ បិតនៅរាងទន្លេជ្រាសាក់ ទឹងឈូងសមុទ្រសៀម ចម្ងាយប្រហែល ៣៥ គីឡូម៉ែត្រ ពីមាត់ឈូង មុនសតវត្សរ៍ទី ៦។ ដោយជាន់តែឃើញនូវវត្ថុផ្សេងៗ បញ្ជាក់ថា ប្រទេសនេះ មានផ្លូវគមនាគមន៍ទឹងបស្ចិមប្រទេស ព្រមទាំងប្រទេសរូមាំង..... ។ ក្រៅពីនេះ ប្រទេសហ្វូណាន ជាន់តុកក្តើដំណែលទឹងសិលាចារឹកផ្សេងៗ ព្រមទាំងឯកសារចិន មានសៀវតៅអ្នកដំណើរចិនជាតាគួនជាដើម ព្រោះប្រទេសចិនទឹងប្រទេសហ្វូណាន មានការគមនាគមន៍ទៅវិញទៅមក ដោយការទូត ឬ ដោយពាណិជ្ជកម្ម ក្នុងសម័យនោះ ។

ប្រទេសចិនឡើង រួបរួមទាំងប្រទេសកម្ពុជាខាងជើង ទឹងប្រទេសលាវខាងត្បូង ។ នៅទីនោះមានរដ្ឋមួយនាមថា កម្ពុជ: ដែលផ្លូវនាមមកជាកម្ពុជាតីប្រទេសកម្ពុជាយើងសព្វថ្ងៃ ។

លុះមកដល់គ.ស.៤៤០, ប្រទេសហ្វូណានជាន់ភ្លាក់ទៅក្នុងអធិរាជ្យភាពប្រទេសចិនឡើង ប្រទេសទាំងនោះ ក៏ដូចចូលមកនៅក្រោមអធិបតេយ្យតែមួយដែលហៅថាប្រទេសកម្ពុជាមុនសម័យអង្គរ, ក្នុងសតវត្សរ៍ទី ៦.៧។

ប្រទេសចិនខ្លា កំបែងបែកជាពីរដួង គឺរដ្ឋចិនខ្លាគោកខាងជើង រដ្ឋចិនខ្លា-ទឹកខាងត្បូង ។

លំដាប់តមក ខ្ញុំនឹងពណ៌នាអំពីអនុភាព នៃវិទ្យុសម័យបុរាណ ដែលគេបានស្គាល់:

១-តាមសិលាចារឹក,

២-វិជ្ជាសិល្បកម្ម,

៣-សាសនា, ប្រពៃណី, ទំនៀមទម្លាប់ ។

១-សិលាចារឹក: អ្នកប្រាជ្ញខាងបុរាណវត្តបានស្រាវជ្រាវនូវរឿងរ៉ាវឃើញមានចារឹកអក្សរសំស្ក្រឹត ទំនងអក្សរខ្មែរបុរាណជាភាសាឲ្យពរស័ព្ទ-សាធុការខ្លះ ជាអនុស្សាវរីយ៍ខ្លះ ក្នុងសម័យបច្ចុប្បន្ន គេបានរកឃើញសិលាចារឹកជាច្រើនម៉ឺន ។ ព្រោះហេតុនេះបានជា យើងមានវត្ថុ-ធាតុដ៏គ្រប់គ្រាន់ល្មមទំនងកំណត់ ដោយច្បាស់លាស់ នូវប្រវត្តិការណ៍នៃកម្ពុជរដ្ឋសម័យបុរាណ, សន្ធតិវង្សព្រះមហាក្សត្រ, ការលះបង់ប្ជុះ ទំនងទីនៃទ្រព្យសាទដ៏សំខាន់ ដែលមានតាសតេញប្រទេស ។ បើពិនិត្យតាមសិលាចារឹក ទំនងឯកសារចិន, សៀម, សៀវភៅខាងបច្ចេកទេសវិជ្ជាស្ថានចុងបូព៌ាប្រទេស ទំនងបច្ចេកខាងបុរាណវត្ថុ គេអាចស្គាល់ច្បាស់លាស់នូវសាសនា, ជីវភាពនៃប្រជាជន, ស្ថានភាពខាងសង្គម, ទំនៀមទម្លាប់ប្រពៃណី, វប្បធម៌ជាដើម ។

២-វិជ្ជាសិល្បកម្ម: វិទ្យុសម័យហ៊ូណន, មុនអង្គរទំនងអង្គរបាន

កសាងព្រះពុទ្ធរូបជាទី ព្រមទាំងប្រាសាទ មានក្បាច់សិល្បៈរចនាដ៏រាប់ត្រ
បិតនៅពាសពេញកម្ពុជរដ្ឋ មានប្រាសាទអង្គរជាដើម ដែលភ្ញៀវទេស-
ចរបរទេសជាតិ មានជាតិអាមេរិកជាដើម បានចូលមកទស្សនាពល់ ។ ឆ្នាំ
ខុទជាអប្បរិយវាគ្គទី ៨ លំដាប់មកពីអប្បរិយវាគ្គ ពិតជាលោកទាំង ៧ ។

ព្រះបាទឥសានវរ្ម័ន ព្រះមហាក្សត្រសម័យបុពណ (មុនអង្គរ)
បានកសាងព្រះពុទ្ធរូបជាទី នៅសម្បូណវិត្រគុក, ខាងជើងកំពង់ធំ
ពីសតវត្សរ៍ទី ៧ ។ តមក ព្រះបាទជយវរ្ម័នទីពីរ បានសាងព្រះពុទ្ធរូបជាទី
នាមថា: ឥន្ទ្របុរៈ ១, ហរិហរាល័យបុរៈ ១, អមរេន្ទ្របុរៈ ១, មហេន្ទ្រ-
បរ្វតៈ ១, ។

ព្រះមហាក្សត្រសម័យអង្គរ មានព្រះបាទយៈសាវរ្ម័ន បានសាងព្រះ
ពុទ្ធរូបនាមថា យៈសោធរបុរៈ មានប្រាសាទភ្នំបាខែង នៅបំពាក់កណ្តាល
ព្រះពុទ្ធរូបទី ទីនព្រះបាទជយវរ្ម័នទី ៧ នៅអង្គរ មានប្រាសាទបាយ័ន
បិតនៅកណ្តាលទីក្រុង ព្រមទាំងព្រះមហាក្សត្រ ក្នុងសន្តតិវង្សវរ្ម័ន បាន
កសាងព្រះពុទ្ធរូបអាណាចក្រធំទូលាយព្រមទាំងកសាងប្រាសាទមានក្បាច់សិល្បៈ
គួរឱ្យស្ញប់ស្ញែងពន់ពេក ។ អង្គវត្តជាចំណាត់ព្រះសពព្រះបាទសុរិយវរ្ម័ន
ទីពីរ ។ ព្រះបាទជយវរ្ម័នទី ៧ ព្រះអង្គទ្រង់សាងប្រាសាទជាច្រើន
កន្លែង មានប្រាសាទបាយ័ន, បន្ទាយក្តី, តាព្រហ្ម, ព្រះខាន់ជាដើម;
ព្រះមហាក្សត្រអង្គឯទៀត ក៏បានសាងប្រាសាទឯទៀត ជាច្រើនកន្លែង
មានបន្ទាយឆ្មារ, ប្រាសាទភ្នំជីស្វរ, ប្រាសាទនាងខ្មៅជាដើម ។ ប្រាសាទ
ទាំងនេះ យើញមានរចនាក្បាច់សិល្បៈ គួរឱ្យមានមនោសញ្ចេតនាត្រឹកេម

ព្រឹស្សក តើតបីតិបាមោជ្ជៈ ស្ទាប់ជញ្ជាំងគំនូរផ្សេងៗ លាបពណ៌ (រចនាគ្រ-
សិល្បៈ), រួបពន្លឺគ្រឿងប្រាសាទតាំងនោះ សម្បើមអស្ចារ្យ នាំឲ្យពួក
ទេសចរនឹកដល់អាទុកាពខ្មែរសម័យបុរាណ, អារ្យធម៌, សន្តិភ ។
បើខ្មែរសម័យអតីត មានឥទ្ធិពលយ៉ាងដូច្នេះ, តើក្នុងពេលនេះវិញ
ឥទ្ធិពលនោះ នៅឯណាទៅ? តាមការពិតិត្យមើលប្រាសាទតាំងនោះ ទឹង
ប្រជាជនដែលនៅជុំវិញប្រាសាទសព្វថ្ងៃ តាមភូមិឃុំ ឃើញពុំមានមេឃ
ទឹងដី ។ តើខ្មែរក្នុងសម័យនោះ នៅឯណាពេល? សិល្បៈតាមតន្ត្រីលោក
បាត់ ឬជាមានជាតិដាំ នាំយកទៅជាឈ្មួញសឹក ឬតំបូតាក្នុងពេលនោះ
គ្មានច្បាប់រាងប្រជាជាតិ, ជាតិដែលចាញ់ក្នុងសង្គ្រាម ត្រូវទៅក្នុងអណ្តាប់
ដៃជាតិដែលឈ្នះ តាប់សម្ងាប់ចូនតាមចិត្តគឺថា "តំណាន់ពីរលើច្បាប់" ។
មិនដូចការបាត់ជ័យជាតិដប៉ុន ទឹងអស្ចារ្យទេ ។ ព្រោះជាតិនេះ អាច
តវ៉ាតាមផ្លូវច្បាប់ខ្លះ មានការប្តឹងពួកឈ្មួញសឹកជាដើម ។ ព្រោះហេតុ
នេះ យើងមិនត្រូវធ្លាប់ថា ខ្មែរសម័យបុរាណ ដែលបានឥទ្ធិពល
ដូចមានប្រាសាទស្រស់ស្រាង ជាកន្លែងលំណាលស្រាប់ ម្តេចក៏ចុះមកខ្ទង់
ខាងអន់ខ្លាយ ក្នុងសម័យបច្ចុប្បន្ននេះទៅវិញ ។

៣-សាសនា ប្រពៃណី, ទំនៀមទម្លាប់ទឹងវិជ្ជាផ្សេងៗ: ខ្មែរ
ក្នុងសម័យនោះ គាំពារព្រះពុទ្ធសាសនាមហាយាន មានរូបព្រះពុទ្ធ;
ព្រះពោធិសត្វ, ព្រះមេត្រីយៈ, ព្រះអវលោកិតេស្វរៈ, ព្រះអមិតាភៈ, ព្រះឥ-
ន្ទិពុទ្ធ ជាដើម ដែលយើងឃើញបិតនៅ តាមតេភ្ញាប្រាសាទទាំង
ប៉ុន្មាន ។

ឯព្រះមហាក្សត្រខ្មែរដ៏ជាសាសនូបត្ថម្ភក៍, ជាអតីតក្សត្រខ្មែរប្រៃពណ៌សាសនា ព្រមទាំងព្រះស្តេចចេតិយ ដែលពួកជនកដនបូជាចំពោះព្រះអង្គ ខ្មែរត្រូវធ្វើព្រះរាជពលិកម្មនឹងពិធីផ្សេង ។ តាមទំនៀមទម្លាប់ជាដើម ។ ខ្មែរប្រតិស្ឋានព្រះប្រែសម្ងួត នាមថា "ព្រះអាទិទេព មហាក្សត្រ" ដើម្បីនឹងឲ្យប្រជារាស្ត្រគោរពខ្មែរ ដូចព្រះអាទិទេព ។

បន្ទាប់អ្នកមួយជាតិភាំងឡាយ, ខ្ញុំពុំបានពណ៌នាពិស្តារទេ ព្រោះពេលវេលាតិចពេក ខ្ញុំនឹងពណ៌នាតែគោលសង្ខេប អំពីប្រជាជនសម័យនោះមានចំនួនច្រើន, ប្រហែលជា ៣០ លាននាក់ មាន ៩០ ភាគរយ ជាអ្នកមិនចេះអក្សរ តាមសេចក្តីពោល ក្នុងសិលាចារឹកខ្លះ, មានដីកស្រែចម្ការយ៉ាងណាក៏ត្រូវគណនា ជាប្រើនកន្លែង សម្រាប់ស្រោចស្រែចម្ការត្រូវមានបានយើញក្បឿង ឥដ្ឋ នៅកន្លែងជាច្រើន, បង្ហាញឲ្យស្គាល់ថា មានគេជាច្រើន ទើបប្រជារាស្ត្រកុះករ ប្លែកប្លួជាសង្គមធំ ។ ជាអនេកប្បការ ។

សង្គមនោះ មានចាស់ព្រឹទ្ធាចារ្យទើបពួកមន្ត្រីយ៉ាំ ជាអ្នកត្រួតត្រាដែលមានអធិប្បាយ នៅតាមសិលាចារឹក ដើម្បីទើបញ្ជាក់ឲ្យប្រជាពហុតុនៃកម្មសិទ្ធិដីភូមិ ព្រមទាំងបោះគោលព្រំប្រទល់ ។ ចំពោះដីកាតនៃពួកក្សត្រកម ទើបពលរដ្ឋកន្លែងភូមិ, គេបានដឹងរឿងពីរបៀបបន្តិចបន្តួច មានពោលថា ពួកភាំងនេះ ច្រើនមានពួកក្រុមជាន់ខ្ពស់ គេបានឲ្យ ៧ ភ្លើងតាសកម នៅកន្លែងបូជនីយដ្ឋាន, ព្រះវិហារឬ ក៏ប្រាសាទ ដោយហេតុថាពួកទក្ខក្រុមនេះ ច្រើនមានបសាទសទ្ធា ចំពោះសាសនាផ្សេង ។ ។

ក្រៅពីនេះ មានទំនៀមទម្លាប់ ខាងការសម្ពោធប្រាសាទភាំងនោះគឺបានអង្គការនៃព្រះវិហារ ឬសមាសភាពនៃបុគ្គលិក ក្នុងព្រះវិហារនោះ

មាននាយក, សាស្ត្រាចារ្យ, បព្វជិត, អ្នកកាន់ទិន: (គ្រូធំមហាស្រុកតូរ្យតន្ត្រី), អ្នកប្រឹក្សា, នាងនាដកា (របាំ), នាយគ្រូរបាស, នាយពាសេស, (ចំណីអាហារ), នាយក្រុងបុជ្ជា ឧដ្ឋាកបរិវារផ្សេងៗ, ពួកមាសកម្មករ បុរសស្ត្រីជាច្រើន ដែលដួលទៅធ្វើរបរស្រែ ដែលជាកេរ្តិ៍មតិក របស់វត្តនេះ ។ យើតាមលោកស៊ីដែស ដែលបានកេរ៉ើញសិលាចារឹកមួយពោលថា គោគ្រឿងនៃប្រាសាទឬវត្តនោះ មានច្រើនឥតគណនាឯបដិមរូបមួយ ធ្វើពីសិលាដំកល់ទុកនៅក្នុងវត្តចំពោះទៀត្រនីមួយៗ មានគ្រឿងអលង្ការពេញបរិបូណ៌ គឺមានគ្រឿងមាស ឧដ្ឋាក់មកពីដកជ្រកឆក, ខ្សែខ្ចូន, កាវពាក់ត្រចៀក, ចិញ្ចៀន, ខ្សែដៃឧដ្ឋាកឆដើង, ឃ្លាំងនៃវត្តឬប្រាសាទនោះ មាកុណ្ឌសម្រាប់ធ្វើពិធី ឧដ្ឋាគ្រឿងប្រដាប់ឯទៀតជាច្រើន រចនាដោយមាស, ប្រាក់, ស្ពាន់ឬលង្ហិន ។ ដល់មកនាងពុទ្ធសតវត្សរ៍ទី ១៦ ប្រាសាទដែលជាស្ថូបសម្រាប់ដំកល់អដ្ឋិធាតុមានគោគ្រឿង សម្បើមអស្ចារ្យ ដែលគេបានធ្វើបញ្ជី ចុះនាមរបស់ដោយពិស្តារ ។ នៅប្រាសាទតាព្រហ្ម ដែលជាប្រាសាទកសាងចំពោះព្រះជនន៍នាថ សិទ្ធិត្រួតត្រាលើភូមិ ៣.១៤០ កដបរិវារ ៧៩.៣៦៥ នាក់ ក្នុងចំនួនបរិវារនេះ មាន១២.៦៤០នាក់ ដែលនៅប្រចាំ ក្នុងកំពែងប្រាសាទ ។ ក្រៅពីនេះមានលោកសង្ឃ សម្រាប់ស្សត្រពិធី ២.៧៤០ អង្គ អ្នកប្រជាសង្គ្រោះ ២.២០២ នាក់, នាងនាដកា ៦១៥ នាក់ ។ ប្រាសាទនេះ មានឃ្លាំងមួយមានសុណ្ណភាជន:មួយទម្ងន់ ៥០០០ គីឡូ, មានភាជន:ប្រាក់ជាច្រើន, មានស្លឹងពេជ្រ ៣៥ គ្រាប់, មានសុវណ្ណកន្ទីរមួយធំ

ព្រមទាំងមុនវិស្សប្រទេសចិន ៨៦៧, ត្រែសំពត់ព្រៃ ៥១២, ធ្នូក្រហម ៥៦៣.....។

សេចក្តីពណ៌នាប៉ុណ្ណេះ សឲ្យយើញថា ស៊ីវិលៃខ្មែរបុរាណ មានអាទុភាពអស្ចារ្យមែនពិត, ឯប្រាសាទឯទៀត ក៏មានភោគទ្រព្យ, សាសនាធ្លាប្រពៃណីដូចៗគ្នា មានរៀបនការត្រង់ប្រាសាទ, ក្រុមព្រះនគរបាល, កិច្ចអនុញ្ញាត, កិច្ចហាមប្រាម ពិធីផ្សេងៗ.....។

នៅកន្លែងសម័យនោះ ព្រះមហាក្សត្រជាច្រើនអង្គ ទ្រង់បានសាងមន្ទីរព្យាបាលរោគ ធ្លាសាលាសំណាក់ ធ្លាសាលារៀនជាច្រើន ។ តាលវដ្តតាលព្រះបាទជយវរ្ម័នទី ៧, មានសិលាចារឹកពោលថា ទ្រង់បានសាងមន្ទីរព្យាបាលរោគ ១០៤ ដែលបំពាក់នៅតាស់ពេញ ក្នុងព្រះពរជអាណាចក្រ ។ ពេលព្យាបាលទាំងនេះ ប្រាស់ជាកសាងដោយឈើធ្លាតដ្ឋ មានមនុស្សជាច្រើន នៅបីបាច់ថែរក្សាអ្នកជម្ងឺ ហើយមានបញ្ជីចំណាយចំណូល មានចំណាយស្រូវ ១១.១៧២ គោន, លុ ២.១២៤ គីឡូក្រាម, ក្រព័ញ ១០៥ គីឡូក្រាម, គ្រាប់កែឡាក់ ៣.៤០២ គ្រាប់, ថ្នាំគ្រុន ៤.៨០០ គ្រាប់, ថ្នាំសម្រាប់បិទបូសជូនបាន ១.៨៦០ ប្រអប់ ហើយវត្ថុឯទៀតជាច្រើន.....។

ម្យ៉ាងទៀត, នៅកន្លែងវដ្តតាលទ្រង់ៗ មានអគ្គមហេសីទីពីរ ទ្រង់ព្រះនាមព្រះនាងឥន្ទ្រទេវី មានចំណេះវិជ្ជាខាងវិទ្យាសាស្ត្រ ធ្លាប់បរមេត្តៈ; ព្រះនាងជាគ្រូបង្រៀនពួកស្រី ។ នៅសាលារៀនខ្មែរថា នរេន្ទ្រាស្រម... ព្រះនាងគេបានចារឹកព្រះនាមទុកនៅផែនសិលាចំពាមានអាកាស ព្រមទាំង

ភាព្យាទិភាពពីរោះអស្ចារ្យ សរសើរតើតេជានុភាព នៃព្រះបាទជ័យវរ្ម័នទី៧, ក្នុងសម័យនោះ មានអ្នកប្រាជ្ញខាងអក្សរសាស្ត្រសំស្ក្រឹត, ខ្មែរជាច្រើន ។

បងប្អូនរួមជាតិភាំងឡាយ ! តាមដែលខ្ញុំតណានាជាសេចក្តីខ្លី ។ មកខាងលើនេះ លោកអ្នកតួរជ្រាបថា អារ្យធម៌នៃខ្មែរបុរាណ បានមកពីអារ្យធម៌ឥណ្ឌូលាយឡំគ្នា ទើងអារ្យធម៌នៃពលរដ្ឋឥណ្ឌូចិន; ហ្វូណន មុនអង្គរ ទើងអង្គរពីពាក់កណ្តាលសតវត្សរ៍ទី៦ មកដល់ទើងសតវត្សរ៍ទី១៥, ប្រទេសកម្ពុជាបានរីកចំរើនដោយភាពថ្កុំថ្កើងបំផុត ហើយមានកិត្តិនាមល្បីល្បាញក្នុងទ្វីបអាស៊ី មានការគោរពរាប់អាន ចំពោះប្រទេសចិន, ឥណ្ឌា, ក្រិក, រោម, សម្បូរណ៌ដោយកោតខ្លាច ជាអនេកប្បការ, មានវិជ្ជាខាងអក្សរសាស្ត្រ តែងតែញុំគេម, ជនបទ, ភូមិភាគ, មានពលរដ្ឋច្រើន, មានវិធានការគ្រប់យ៉ាង, មានមហាជ ក្នុងសន្តតិវង្សរ៉ៃនប្រកបដោយតេជានុភាពពន់ពេក, បានជាប្រទេសជាតិមាតុភូមិ ខ្សើងខ្ពស់កាន់មហាអំណាច ក្នុងអធិបទេសសុវណ្ណភូមិ ។

ចប់ ។

ការសិក្សា

លោកអម្ចាស់ក្បត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក.ថៃម ពិនិត្យ

(តទៅ)

ផ្តាំស្រែចម្ការតន់ លើអង្គអស្សពន្ធ្យ ហោះត្តោះទៅឯ ព្រះព្រៃហោម-ពាន្ត សឹងមានផ្តាំថ្លែ សុភ្ន ។ សឹងតែ បេះបរិកោគ្គា ។

ហោមហន្ធ្យនាំ មយូរតន្ត្រីយ៍ នរមិត៌សាកៀ ពជសីហ៌តជសីហ៌ ដំរីខ្លាឃ្លា កែះគោតលៀងកា តំលេនសត្វសិង្ហ ។ ខោតទិដ្ឋជុំពា ជាញដែងជល់គ្នា ពុំប្រាស់ប្រុងប្រឹង សម្រក់ទឹកមាត់ ជាបហាត់សម្ងឹង សំឡក់ក្រញឹង ក្រញ៉ូវៅមក ។ កុមារក្រសាល សាន្តសុខត្រអាល ព្រៃព្រឹក្សឈូឆគ សេះខន្ធបះស្មាះ ស្តេចចុះបេះយក ជលជងសេះក សៅមរិកាគ្គា ។ លុះថ្ងៃតបខន់ ស្តេចស្រន់ស្រប់ប- ខ្មោអស់ទណ្ហា តន់សេះលៃតេច ដល់ស្រែចម្ការ ប្រទានផលា ឲ្យអន្ទុដសោយ ។ តែព្រឹកកាលណា តែងសៅព្រឹក្ស តែឯកអគ្គិទ្យ អន្ទុដនិត្យសៅ លុះសៅខ្មៅក្រាយ ខោះខាងហោតុងាយ អង្គុតឯកឯង ។ មួយថ្ងៃសៅគាន់ ក្រោសាខមួយដាន់ មៀងមើលត្រប់ល្ហែង តែបងសៅព្រៃ សព្វថ្ងៃសោតតែង ខ្លើងលេងឥតក្រែង ដោយស្ងិទ្ធាប់សៅ ។ ល្ងាចចុះមកតន់ សៅរីព្រះអង្គ ព្រះរៀមស្តេចសៅ លុះព្រឹកព្រាងស្រែច សម្តេចចមសៅ

ស្តែងស្តេចហោះទៅ កាន់ព្រៃខួបគ្រឹម ។ នាងឡើងទៅគាន់ ប្រាសាទ
សត្វជាន់ ឃល់ស្លាមួយធំ ត្រចុំលព្រឹងឆ្ងាយ រលើងរលំ នាងយកដៃដំ
អង្អែលស្នាមលេង ។ ឃល់ស្នាមពុំស្ងួត ជាហេតុឲ្យរបួស ដើកបានឥតព្រែង
ឃល់កុមារជាក់ តិតភ្ញាក់អង្គិងឆង ពុំគាចថ្លាថ្លែង ពាក្យតេចន៍ចរោ ។

កុមារឃល់ជាក់ ព្រឺព្រួចហើយហក្ត់ អណ្តែតកាយ តើតក្តួច
គន់គិត ចាប់ចិត្តស្នេហា ឆញ្ជឹងគិតថា នាងនេះល្អម្ល៉ះ ។ ជាស្រីនាគ
ឬស្រីទេវតា ឬមួយនាងនេះ ជាស្រីកំនុត ទើបល្អដល់ម្ល៉ះ ឬ
មួយនាងនេះ ជាយក្ខិនី ។ គិតព្រែងសួរថា ហៃនាងធីតា នាង-
នេះជាស្រី មនុស្សឬទេវតា នាគកំនុត ឬរក្ខិនី នាងមកពីណា ។
នាងនៅបូរី ស្រុកទេសឈ្មោះអ្វី ហេតុម្តេចបានដា - តែឯងអង្គប្រាណ
ឬមានឧរណា មកផងនាមា នាមេឈ្មោះអ្វី ។ នាងប្រាយប្រាប់ស្មោះ
ចាំអញ្ជឹងឈ្មោះ ចន្ទាជាស្រី មនុស្សលោកប្រាកដ ឬត្រកូត្រកងបតី
នៅពាពណសី មហានគរ ។ ព្រះនាមកាសិក ធ្លាប់ដងម្ចិក មាតាទ្រង់តរ
សម្តេចរមណា ដេដ្ឋាបវរ ទ្រើសទ្រង់ឆ្នាំនាមករ ទៅនគ្រាថ្ងៃ ។ ទៀនតើមទៅ
ប្រាប់អស់អំពី ប្រាសព្រះបូរី ប្រាប់ស្រេចដណ្តឹង ទៅរឹងរឿងខ្ញី
នាមអ្នកឈ្មោះអ្វី ចូរប្រាយប្រាប់មក ។ មាតាប៉ិតា ស្តែងស្តេចទៅណា
អស់អ្នកគេរ សឹងបាត់រាំងអស់ គ្មានសោះមួយមក អ្នកនៅនេះកំ
ម្ងាក់ឯងទេឬ ។ មានអ្នកឯណា នៅផងជាគ្នា មួយមានជម្ងឺ ខ្វៃខ្វិនឬជាគ
កុមារសុះឮ សូរសៀងត្រួចត្រឹ ចាប់ចិត្តចង់ឆ្លុះ ។ បន្តុលប្រាប់ថា ឆ្លុះអើយ
បងជា បុត្រកូត្រមួយមាន ឃុសឃល់ថ្លើងថ្លែង ឯកឯងក្សេមក្សាន្ត

មន្ត្រីពស្ត្រមាន អនេកអនន្ត ។ ឯព្រះនាមា សម្តេចបិតា ព្រះនាមហោម៍ន្ត
នតរនោះឈ្មោះ ដូច្នោះសុខពន់ សុខពេកអនន្ត អនេកវិស្ស ។
កាលបន្តសម្រាល បិតាតូចាល ប្រកបនាមា ចំរើនតាជ័យ អតិយកុមារ
ស្តេចស្តេចស្នេហា ដូចដួងជីវិត ។ មានកាលមួយឆ្នាំ នោះហតុកាលកម្ម
មានសត្វឥន្ទ្រីយ៍ សាហាវយោរយៅ តាំងឈ្មោលតាំងញី ពីរពិតមកពី
ព្រៃហោមពាន្ត ។ ចូលចិកធ្វើមនុស្ស ខ្លះស៊ីក៏យប្រុះ ដួរតន់ចោលហាន
ទៅទៅអាស្រ័យ កន្លងព្រៃស្មសាន តាំងពួនចាត់ចាន រស់ប្លែចន្ទជាតិ
បិតាអម្ចាស់ អាសូរបងណាស់ ជាក់ក្នុងស្តុរស្នាត បំបិទបំបាំង
ទៅកន្លងប្រាសាទ ស្វាត់ល្អស្អាងស្អាត រក្សាអាត្មា ។ តាំងរសោច្រាំ
ព្រៃគ្រដណ្តាំ ចាយបរិភោគ្គា ហើយសត្វឥន្ទ្រីយ៍ មកស៊ីមនុស្សម្នា
សម្តេចបិតា ក្រាញក្រុងបួរ ។ សត្វមកស៊ីមនុស្ស អស់រាងស្រីប្រុស
ហើយស៊ីក្របី គោសេះឆ្កែឆ្មា មាន់ទាជាតិ សព្វសត្វអ្វី ។ សឹងឆ័ម.
ណា ។ ហេតុដើមដូច្នេះ បានជាស្រុកនេះ ស្ងាត់ឥតមនុស្សម្នា បន្តិចឯង
ព្រលឹង សោតសឹងកំព្រា ព្រាត់ប្រាសដូចគ្នា ខេរគឺតម្នងឯង ។ បាន
ជាប្អូនស្រី ប្រាសប៉ាបួរី រលែរលែងវង្វេង មកជល់អាយស្រាប់ តីតំពូតាត្រង
ចូរចៅមកសេង ទីដីបន្តមកនាដ ។ ក្សត្រីរលែកូណា ស្តែងស្តាប់
ដៀងជាក់ ពាក្យតេចន៍រៃអង្គ បាប់ចិត្តកួចកាន់ ដៀងគន់អាងខ្លាង
ប្រែប្រាស់យ៉ាសយាង បន្តិចចុះទៅ ។ កុមារបរិ ចេញចុះចាកស្តូរ
បែរប្រាយហាហៅ ដៃតែកាបតាយ មកតាយសិខរៅ អាលអ្វីតែទៅ
ទៅតើទៅណា ។ ព្រះករដេស្តជ័យ បាប់ចុងជាយស្ទៅ នាងជាត់ដៃថា

នែអ្នកខ្លួនខ្ញុំ ក្រមុំព្រហ្មចា- រ៉ូបអ្នកជា កំឡោះក្មេងខៅ ។
ពុំគួរដឹងគ្នា តែពីរមគ្គា លែងខ្ញុំទឹងខៅ ថាហើយដឹតា ខ្ញុំទ្វារក្រេវខៅ
កុមារចមខៅ អត់ឥតរុញក ។ ខៅតាញ្ញាវមិន តន់ខានិតដឹត
ត្រាស់ថាប្អូនក្លា នេះគឺសំណាង ជាន់សាន់ជន្លា ជាតួប្អូក ប្អូកណា
ព្រេងព្រិច្ច ។ បងទឹងផ្ញើខ្លួន ខុកលើប្អូនស្លួន តាល់អស់ដឹតិត
ខ្លួនបងទឹងមេ សឹងតែឯកឥត ខៅជន្លួតិត ឲ្យមួលមួយគ្នា ។
គ្រាន់បានជាពីរ រក្សាមន្ទីរ ជាតួស្នេហា ប្អូនមាសស្អប់បង . តើខ្លួនត្រង់ណា
ប្អូរខៅថែថា ឲ្យដៀនឲ្យជាក់ ។ នាងឆ្លើយឆើសួន បពិត្រកុខបង
ខ្លួនខ្ញុំមិនម្នាក់ មានបងធំបតី ស៊ើបតាជាក់ បើចិត្តស្មោះស្មើត្រង់
តួរកុំប្រញាប់ ។ អ្នកខៅចុំយក ដល់ស្តេចវិលមក ឲ្យស្រួតាមល្បាប់
បើព្រមក្រោសផ្សំ ខ្លួនខ្ញុំទឹងស្រាប់ ខៅក្នុងកណ្តាប់ កណ្តាលដៃហើយ ។
កុមារឆ្លើយថា ម៉ៃប្អូនស្ងៀមហា កុំថាខ្មោះឡើយ បើបងស្មាលស្មេហ៍
ទឹងមេស្រេចហើយ ព្រលឹងបងអើយ បើព្រះអៀមខៅ ។ ជឹងហើយសមអរ
សមឲ្យព្រះពរ បពិបងជាន់ខៅ ខៅមួលមួយគ្នា . ជាតិជាញាតិផៅ
គួរគាត់ចិត្តខៅ ម្តេចមិនមេត្តា ។ ណាៗម៉្លេះហើយ ព្រលឹងបងអើយ
ផ្តាច់ប្អូរដន្ទា ផ្ញើខ្មោចផ្ញើខ្លួន លើស្លួនស្នេហា រស់រួបតំរា កើតកន្លែអម្រិយ ។
ក្សត្រីត្រែងស្តាប់ ដឿចូលចិត្តចាប់ ក្លួចកើតបេតី ខំឆ្លើយដោះសា
ការក្លែងក្លាំប្រើ បពិត្រកុំបី លួងលោមបងៅ ។ ខ្ញុំពុំព្រមដោយ ប្អូរ
ស្តេចបើកឲ្យ ខ្ញុំចរយាត្រា កុំយាត់កុំខាំង ពាក់ងាស់ខ្លួរ ជាតួឯងឥតា
យាងខៅតួរមាង ។ អភ័យកុមារ យាងខៅពាស់ខ្លួរ អរគុបគន្លួនាង

ព្រឹត្រួចស្នេហ៍ស្និទ្ធ ដួញជិតសារគាត្ត លើកតយាសយាង ចូលកន្ទុស
ស្តុរមាស ទាន់ដាត់នាងប្រាន ប៉ុន្មាន ។ តុំមានលាកលះ រួបរឹតអស់
អន្ត ប្រតិយត្តិមត្រមាស ព្រឹត្រមរួមក. ស្នាស្និទ្ធស្នេហា ។ ចរចា
ទៅមក ពេះពេយស្រេក គោជនគោត្តា លុះថ្ងៃតាបទេ ទៅឯបច្ចិមា
ក្សត្រីលាថា បតិត្រូបមទៅ ។ ថ្ងៃទន្ទាបសល់ ក្រែងបងខ្ញុំដល់
ខ្ញុំសូមលាទៅ តុមារអួលអាត់ ថ្នមជាត់លើក្បៅ ត្រាស់ថាបៃតាទៅ
តាសត្រេញស្នេហា ។ បច្ចូសសម័យ បងនាងទៅព្រៃ ចូរទៅម្ដីម្នា
បតិវិញ្ញូឃ្លាវ អាសូរវៀមក៏ រៀមវែងក្រំជ្ឈា ទ្រូងទន្ទឹងតន់
ហាសបរស្រេ. ឱ្យាញ់ទាសមិត្រប្រ- សើរសេមតមេ- ន្ទិលខើសថាស់ចិត្ត
ទាសបិរបងតន់ បងតិតដួចជន្ម ដួចជីវិតបង ។ បើទៅពន្ធក
ស្រេ ត្រេមក សោរសេមរៀមរង ទុក្ខបទមិនបាន ឃាល់ប្រាណស្ងួនត្រង
ក្នុលស្នេហ៍ស្នេហ៍ស្និទ្ធ ស្រេរៀមក៏ ។ រៀមវែងក្រំក្រៀម ក្រំក្រៃស្ងាត់ស្ងៀម
ស្រេជ់ស្រេតត្រូវ ឯកឯងនិត្យទៅ មើលផ្លូវស្ងួនភ្ងា មរមែមមា
មមាសម៉ាទៅ ។ ក្សត្រីទុក្ខម ស្តាប់ហ៊ោយក្រៀមក្រំ កត្ត្រាហ្មន៍សៅ
ស្រេជ់ដំណើរ យាត្រាចេញទៅ តន្ទីចំបមទៅ នៅព្រះគេវតា ។
ឮសោយស្ងេរសៀលត្រៀលត្រេ តាបទៅបច្ចិមា ពោធិសត្វថ្ងៃ
ជ្រៃតែទុក្ខសា រំលឹងលិសា មកដល់មណ្ឌល ។ នាងធ្វើស្រស់ស្រួល
អរខេនខ្ញុល សេតះសោយកំសុផល ពីតេង្វាសម ជ្ជិមជ្ឈំសកល់
តតហ្នាំលុះដល់ ស្តាធ្រាសូរយ៉ែ ។ ទុកនាងឲ្យទៅ ស្តេច
ទៅនាងទៅ ភ្លាំងត្រាស្ងាមី មានតាសមួយថ្ងៃ តិតតំយស្រេជ បតិត្រូ

អគ្គិ- សូរលើសិរសា ។ យើងគាំងពីរនេះ ធ្វេសធ្វើសុនម្ល៉ះ ហេតុ
នេះមិនដា ដឹងដល់បងខ្ញុំ ហើយសមមរណា គាំងខ្ញុំគាំងស្លា- មិត្តុ
លែងឡើយ ។ អ្នកទឹងគិតកិច្ច គិតកល់ដូចឆ្កួច ឲ្យរស់ម្ចាស់អើយ
កុមារធ្វើយថា ពំងាបងអើយ កុំគិតភ័យឡើយ ងាយណាស់ទេតៅ ។
ដ្បិតហេមភាន្ត ឯលិចមែនមាន សុទ្ធសឹងអំពៅ ប៉ុនដើមដូងស្លា មាន
ស្លាចាំនៅ ប្រើនណាស់គិតទៅ ប្រាំមួយហ្នឹងថ្ងាយ ។ ធំធាត់ដៃជើង
ប្រប៉ុនមនុស្សយើង មនុស្សសត្វគាំងឡាយ ឯណាដើរដល់ ស្លាយស់
ឥឡូយ រត់មកប្រញាឃ ហែកស៊ីស្លាប់តៅ ។ ចូរនាងធ្វើជា យល់សប្តិ
ឃើញថា បងស៊ីអំពៅ ធ្វើជាប្រើលង ម៉ើបងនាងតៅ សមស្លាប់យើងនៅ
បានសុខក្សេមក្សាន្ត ។ រីហេតុពោធិ ព្រាត់ប្រាសឆាន ឥតកម្មបុព្វណ
តែងតាមមកផ្គួន មួយបួនបុណ្យបាន សព្វសត្វតិរច្ឆាន មកជាបរិវារ ។
មួយឥតសំណាង សំណូមនៃនាង ទឹងអគ្គកុមារ អនេកជាតិយូរ ជាគូសង្សារ
កិត្តិដើយកពការ តែងមានដូច្នេះ ។ រីហេសខ្ញុំគុណ កម្មនឹងបាបបុណ្យ
ពុំដែលរបេះ របូតចាកឡើយ តែងមានដូច្នេះ គួរសង្វេគរវៃ ឲ្យរបូតបង់។
គួរកុំប្រមាទ ខះខំសង្វាត ធ្វើបុណ្យជ្រុតផ្តង់ ចិត្តអកុសល អំពល់គួរប្រុង
ចិត្តបង់បួលកង ឧគារនិញាន រីតាមពាគា កិលេសតណ្ហា ក្រមនុស្សកាន់បាន
រាតែងផ្ទេចផ្តង់ ឲ្យអន្ទរធាន ក្ខេបសីលក្ខេបទាន ក្ខេបខ្លួនមរណា ។

ធីតាហេតុនៅ ក្មេងណាស់ឆោតនៅ ដោយតាមតណ្ហា ធ្វើឲ្យរវៃង្វន
ពុំក្រែងវៃរ ក្ខេបគុណផង្គា ទបត្តម្ភគាំទ្រ ។ ស្រេចចរចុះទៅ តង់
តយនិត្យនៅ សីហបញ្ជរ ឯពោធិវង្ស ស្តេចតង់អស្សតរ នាំផលាការ

ឲ្យអនុជា ។ ស្រេចផ្ទំលក់ភ្លៅ លុះយាមយប់ជ្រៅ ធ្វើជាសោក
ស្តេចក្រាក់ថ្នាក់ថ្នម ប៉ាមសួរថា ម្ចៃប្អូនស្នេហា អ្នកយំម្លេកថ្ងូ ។ សត្វទាំ-
មាសឬ មាសមានដម្ងី ឬមួយប្អូនស្រី រលឹកព្រះម នៅឯប៉ារ
ឬចង់ប៉ុន្តូ ប្រាប់បងចុះកើ ។ នាងទូលមុសា បពិត្រជង្ហា ខ្ញុំដេកលក់ភ្លៅ
យល់សប្តិឃ្លាន-ខ្លួលខានអំពៅ មានរសម្ចៃក្រៃនៅ ម្ចៃព្រះហេមពាន្ត ។
ហេតុនោះទឹកចង់ សូមក្សត្រាទ្រង់ មេត្តាជ្រាបប្រាណ ហិចហោះភ្លៅ
រក ភ្លៅយកម្ចៃឆ្ងាន មែនមកឲ្យខាន ខ្ញុំបរិភោគ្លា ។ កុមារស្តាប់
ហើយ ត្រាស់ថាប្អូនអើយ ចាំភ្លឺសិនណា បងភ្លៅរកឲ្យ កុំសោយសោក
ស្តេចលាមអនុជា ស្រេចផ្ទំនិត្យនៅ ។

លុះព្រឹកក្សត្រា ច្រាប់សេះដូចជា ចំណាន់ប្អូនភ្លៅ ឡើងគន់សេះហោះ
ស្មោះគ្នាសំដៅ ប្តូរមួយមាន ៣ បច្ឆិមនគរ ស្តេចហោះដល់ស្រែច
បុរាភកាច់កាច់ ឃើសរកតើមល្អ ឃានស្រែចស្តេចសោយ ហុចឲ្យកសត្រូវ
សេរសោតសឹងសរ- សើរសំណេះថា ។ នេះផ្លែមប្រសើរ តុមារថាអើ
ផ្លែមហើយតិសា ដូចប្អូនដេកយប់ យល់សប្តិកោគ្លា មានរសយល់ជា ខឹង
មែនរសត្រូវ ។ សោយស្រែចស្តេចកាច់ ចង់ចុះចុះស្រែច ឯរស់ឃានរ
ភ្លាមកាយសាំ ខឹងទាំឲ្យមរណ៍ កាលណោះមសត្រូវ ស្រែរីស្រែកឲ្ងី ។
ស្ងាស្តេចឃានរ នោះសោតសឹងមរ- ណាស្ងាប់នោដី ពោធិ៍ត្រង់សឹក្តី
យល់ជាក់ប្រាណី ព្រះទុស្តប្រឹមប្រើយ ត្រាស់ខឹងសេះថា ។ ស្ងាជង
ទាំងនោះ ស្ងាប់តិតព័ត្រោះ យើងតិរអង្គ្លា តិតតួរប្រាសប្រស់ ឲ្យសេដ្ឋា
ក្រែងមានវេរ ភ្លៅអនាគត ។ តិតស្រែចលីលា ឡើងគន់សព្វាយ៍

នានាពណ្ណពុទ្ធ ដល់ស្រះមួយធំ ស្អាតស្អំបរិសុទ្ធ មានគំនរមុត្តា ច្រាំពណិសិនផ្កា ។ ស្តេចចរចុះស្រង់ ដំរះព្រះអង្គ កាច់ស្វឹកបទុមា ខ្ចប់ទឹកឡើងគន់ លើអង្គអស្សា មកប្រស់អស់ស្វា ពានរចរេស ។ ពួកពានរបង្គំទូលថា យើងខ្ញុំទាំងអស់ ថ្វាត់ថ្វាយគំនរបណ្ណា ជាតិជារបស់ព្រះមហាបុរស យើងខ្ញុំគំនរឡាយ ។ ជាខ្ញុំក្សត្រថ្ងៃ ដល់ច្រាំពីរថ្ងៃ ទើនគាំទៅថ្វាយ ម្ពត់ៗជាសួយ សោះត្រួយព្រះកាយ ស្តេចស្តេចដល់អាយ សឹមយើងខ្ញុំទៅ ។ ស្តេចស្តាប់ស្រាកស្រួល ត្រមព្រះខទួល ហើយយកអំពៅ គន់សេះសន្ធាត ត្រឡប់រិលទៅ អន្ទះនោះនៅ យង់យល់ស្តេចមក ។ ពិតពុំក្សត្រិណក្សីយ រិនគិតគិតភ័យ ធ្លើសពាយកេតក្តែងនិស្រស់ស្រួល ខទួលចាប់យក អស់អំពៅមក កាត់កាប់គោក្តា ។ ពន្យាពាធិញ្ញាណ ច្រាយច្រាប់ពីបាន ស្វាជាតាសា សំណេះច្រាប់ត្រប់ លុះយប់និទ្រា ខៀតតើបព្រមេហា- បុរសទៅត្រៃ ។

នានយកអំពៅ អំពីសល់នៅ ទៅថ្វាយអភ័យ ច្រាប់ថាឥឡូវ ស្តេចទៅពុំក្សីយ ច្រាប់ថាស្វាត្រៃ សុំជាសេនា ។ សត្តទិន(១)នឹងយក អស់អំពៅមក ថ្វាត់ថ្វាយក្សត្រា ច្នេះទឹងតិតម្តេច ឲ្យស្តេចមរណា កុមារធ្លើយថា កុំភ័យមាសបង ។ ម្យ៉ាតហេមពាន្ត ឯដើនទៅមាន សុទ្ធសឹងឃ្មុំផង វែនមានខ្លាឃ្មុំ ចាំដុំគ្រប់គ្រង ធំៗកន្ទុង ប៉ុនៗដំរី ។ បួនហ៊ឺនតត់កាច គ្មានមនុស្សដឹកច ទៅឡើយចូរស្រី យល់សប្តិស៊ុយ៉ុំ យំសុំសំបី ចាន់ចង់ប្រណី ប្អូនស្នេហ៍ស្នេហា ។ តែទៅដល់ព្រៃ នោះនឹងក្សីណក្សីយ ទៅតាំងអស្សា

---

១ សត្តទិន: ប្រែថា ៧ ថ្ងៃ ។

ស្រេចថ្នមផ្តេកផ្តិត ស្មាលស្ទុំខ្លួបជា រសៀលសុរិយោ នាងលាចុះទៅ ។
តោធីវង្កែល លីលាចរួចលែ ខែនទីលំនៅ នាងប្រុងប្រណីប័ត្ន ធ្វើវត្តចម្ងល់
តតឲ្យហ៊ាន់សៅ ដូចគាលប្រក្រតី ។ លន់លុះដាស់ខុំ នាងធ្វើជាយំ តាម
ពាក្យស្វាមី តោធីជ្រួតជ្រាប សួរស្ងាបចិដ្ឋ(១) ប្តូនអើយហេតុអ្វី ក៏ប្តូនសោក
នាងក្លែតថាខ្ញុំ យល់សប្តិស៊ីឃ្មុំ មានរសនុជា សូមព្រះមាសមិត្រ អាណិត
មេត្តា រកឲ្យកោត្តា ជ្បិតខ្ញុំម្ចាស់ចន់ ។ ខ្លោះកុំសោយសោក ព្រឹក
ព្រាងបងរក ឲ្យតាមចំណង់ ពីថ្ងៃនេះទៅ បើចៅតិតចន់ អ្វីចូរប្រាប់ត្រង់
កុំសោយសោក ។ បិទភ្ញាំងតិតភ័យ ត្រែងមាសថ្នើមថ្ងៃ ឈឺថ្ពាត់ពុំជា
ស្តេចលួងលោមនាង លុះស្វាងសុរិយោ ច្រាយប្រាប់អស្រ្តាហ៍ ហើយ
តង់ហោះទៅ ។ លុះស្តែងស្តេចដល់ ខ្ញុំយ៉ាងយល់ ខេរខ្ចីយោរ-
យៅ សួរមកនឹងយ៉ុន្ត នឹងពុន្តទៅ សេះសោតស្រែកទូរ៉ សព្ទសីហៈហើយ
សុន្ទសឹងសន្ធប់ ពិតពុំខ្លាចខ្លាប់ នឹងសព្ទសេះឡើយ តោធីហេតុគិត
អាណិតណាស់ហើយ ក្បាត្រកក្បូនត្រាណាត្រើយ យកទឹកទៅប្រស់ ។
ខ្ញុំយ៉ាងតិចខ្លួន ដោយបុណ្យមែរចាន រួចស៊ប់ភាំងអស់ ក្រឡាក្រាបវន្ទា ព្រះ
មហាបុរស សុខសាន្តសោតនេះ មនោស្មោះស្មាន ។ ព្រះគុណអម្ចាស់
ធ្ងន់តេតក្រៃក្រាស់ រកអ្វីធ្ងឹមភ្នាន យើនខ្ញុំសឹងសុំ ជាខ្ញុំក្បត្រក្បាន្ត ភាំង
ទីហេមពាន្ត ជាតិជាពាជន្ត្រ ។ មិនឲ្យស្តេចត្រួយ ទឹងនាំជាសួយ
ទៅថ្វាយដល់ស្ងាប់ តោធីវាវង្ស ស្តេចទ្រង់ស្តែងស្តាប់ ត្រមែប្រាប្រាយ
ច្រាប់ រីលវែងវិញថា ។ អង្គអញ្ជាតតទៅ សេះសំណាក់នោ ហេមវន្ត-

---

១ បិដ្ឋិ ប្លែថា ខ្នង ។

សីមា ឥតអង្គមន្ត្រី សេនីសេនា ចូរអ្នករក្សា អង្គអញនេះផង ។ ប្រាំពីរថ្ងៃទៅ (ជ្ញានទីលំនៅ(១) ឯអាយឲ្យផង គ្រាអញទូលិល) ត្រាន់យល់ម្ត្រង ។ សោះស្ងាត់យើងចង ចិត្តចូលជាសាច់ ។ ស្តេចទ្វាយុំព្រម ឡើងបេះយុំថ្នម ចរចូលថ្វាយស្តេច ទទួលសេតសោយ បេះឲ្យសេះស្រេចឡើងតង់សេះគេច រៀមមកប្រាសាទ ។ ដល់ហើយហុចឲ្យ អនុជសោតសោយ ផ្អែមល្ហែមមានជាតិ រិះរើនក័យក្តាត់ក្រែងក្ស័ត្រកូនាថ ជ្រាបហើយតិយោជ ពុំខុកជន្មា ។ ប្រុងប្រឹងប្រណិប័ត្ត ធ្វើវត្តមហាក្ស័ត្រ ស្តេចច្រាប់អនុជា ពីចានទ្វាយុំ ជាខ្ញុំចាត សត្តទិនទីន៍នា ទីន៍នាំយុំមក ។

លុះព្រឹកព្រាងថ្ងៃ តែងតើនទៅព្រៃ នាងឡើងទៅរក ស្វាមីទើ ច្រាប់ពីស្តេចយក យុំចានមែនមក មិនមរណានៅ ។ បែរចានទ្វាយុំ មកទៅជាខ្ញុំ គិតម្តេចទៀតទៅ អស័យកុខារ ធ្វើយថាហៃទៅ តម្រែបងនៅ កុំព្រួយចិត្តា ។ ក្នុងហេមពាន្ត ឯបូពានោះមាន ស្រះមួយឈានថ្ងា មានបញ្ចបទុម ធំ ។ ផ្អែម្ល៉ា ប៉ុនកន្ទំរថា រីរស់ពិសី ។ ក្រចាប់សោតមាន មើមធំប្រមាណ ប៉ុនក្បាលក្រប៉ី មានកុម្ភណ្ឌយក្ស ប្អូនខាត់តី្ន នៅឆ្នេរស្រះស្រី រក្សាការពារ ។ តែងជនចំកស្រះ នោះទៅថ្វាយព្រះ វេស្សវ័ណរាជ ផ្ទាស់វេនគ្នានោះ ម៉ោមនុស្សសត្វណា ទៅហើយយក្ស ចាប់ធ្វើណាក្ស័យ ។ ចូរប្អូនឱមិលជាយល់សច្ចិយល់ (ស្រះស្រេចថ្ងាថ្ងៃ ទ្បើបងនាងទៅ តង់តែនងឹកក្ស័យ

---

(១) សេចក្តីក្នុងវង់ក្រចកនេះកែថ្មី ឯសេចក្តីចាស់នូវេះ : ការ់ជ្ញានទៅ អាយឲ្យប្អូនផង ឆ្ងៀតអញទូលិល ។

ជីវិតដន្ទប្រល័យ ដោយដៃយក្ស[1] ។ នាងនាថកន្យាត្រី ព្រមតាមស្វាមី
ក្នុងគុណដេដ្ឋា គឺកម្មពីព្រេង ឲ្យរៃអង្គាស្វាមី ។
មកចាំទេសពល ស្តែងស្តេចលែងលះ ហើយទ្រេចក្រៃ ប្រទានផលា
អាហារចំណី ទៅព្រះបួនស្រី សោយស្រេចនិត្រា ។

លុះព្រឹកនាងខ្លួល តន្ត្រីពុទ្ធឆ្លើយ តទូកសាស្តា នាយប់ស្តប់ស្តល់
ខ្ញុំយល់សប្តិថា ចាន់ចបរិភោគ្គា ផ្លែឈូករហមពាន្ត ។ ខំហ៊ុំប្រាកដ ប៉ុន្តែកន់
កដវថ ក្រែចាប់ប្រមាណ ប៉ុន្តែស្តាលមកដាក់ស្តេច ដែលមកហាក់ជាន្ទង្គិតទួលទាន
តាំងទឹកស្រែផង ។ សូមទ្រង់ក្រាសប្រាណ ទៅកន្ទុយទាន ពោធីបញ្ជាប់
ប្បាង បន្ទូលត្រាស់ថា សូនក្លាស្នេហ៍ស្នង កុំព្រួយសិមបង ទៅកន្ទុយ ។
ត្រាស់ស្រេចព្រះអង្គ ប្រាប់សេដ្ឋីតន្តី ទៅរកាហិចហោះទៅ រកសត្វនិសា
ព្រុត្តជ្រោះជ្រាវ តុំមានបមាទៅ ទៅទិសឋានិ ។ យល់ស្រះមួយធំ ព្រុតជាតិ
ត្រែសុំ ត្រសាយសាខា ឈរយន្តស្រះប្រែង ព្រាពន្ធ្យពុទ្ធា ចុះស្រេចតគ្គា
លាធីតាំងអស្សពន្ធ្យ ។ ដូចជាតុក្កត្រាស់ បេះផ្លែឈូករទៅ ខ្ចប់ទឹកថ្នាយដំ
លើលាស្បើធីដំរ សេះចង្កើត ចាយព្រះស្រះប្រែង ត្រាមដៃសាខា ។ សេត
សោយកំសួផល អាហារស្តេចស្តាប់ តិះសេសតិសា ព្រះពាយផ្សាយគន្ធ
ប្បុប្ផវនាទា ដោះរដាយរាតា តម្រេតបទ្ធំ ។ សូរសព្ទបក្សី ដូចតូរ្យតន្ត្រី
ត្រែបង្គ្រប់គ្រឹង សម្តេចក្រឹត្រកន្ត្រ ប្រែប្រាណត្រាស់ថ្លែង ត្រាមត្រាដៃធំ
លំលៅគាយោ ។ គាលត្រេតាត្រាតា ធីសត្វដែរ តទូកពុទ្ធា ស្តែងស្តេចដ្ឋិត

---

[1] ខេះកែថ្មី ឯសេចក្តីថាសុំ ... ឲ្យបងនាងទៅ តែទៅនឹងស្ងួយ
កុំភ័យប្តូនទៅ យក្សនោះយោរយៅ ក្លាទប៉ិនខ្លួន ។

ព្រះថ្លៃសាខា រសៀលសុរិយោ ខន់ ។ ល្ងាចថ្ងៃ ។ ស្តេចតើនស្រេចស្រែង
ជម្រះព្រះអង្គ ប្រសើរថ្ងាថ្ងៃ រួចរៀបព្រះអង្គ ទឹងគង់មនោមយ ត្រឡប់វិលវៃ
ទៅកាន់ហេមវន្ត ។ កាលពីព្រឹកព្រាង សូរ្យសែងរះស្វាង ទាំងបួនកុម្ភណ្ឌ
ដែលនៅចាំស្រះ រួសរះទៅកាន់ ព្រៃព្រឹក្សរួសកន់ រួសរកគោគ្គា ។
កាលអង្គសម្តេច ពន្ធកសារពេជ្រ ស្តេចទឹងយាត្រា កុម្ភណ្ឌមកដល់
យង់យល់ព្រះមហា . ក្សត្រាថ្ងាថ្ងៃ ទូវសេះសសម ។ រួតរត់ប្រឹងប្រ-
ដែងចង់ចាប់ចរិ- គោគព្រះបរម- ពោធិព្រឹង្ខ ដោយចិត្តលោភលំ- ឥត
អង្គជាចំ- ណាំនៃអាត្មា ។ មហាក្សត្រទត្តម យង់យល់តាយកុ. ម្ភណ្ឌពិត
ហើយហា- ទ័យទ្រង់និនឹក ភ្ញាំងភ្ញឹកព្រឺហ្ម រម្ភរំរួញរាយ រត់រលាំងស្ងោត។
រួសីហ៍និរភ្ញឹក ឃើញអស់អម្រឹត ពាលពុំគិតគោត កុម្ភណ្ឌទាំងបួន កង្ខ្ន
ក្រែវក្រោធ ឃល់ព្រះពង្សពោធិ ពុំព្រញ្ញរញ្ញោក ។ ពុំហានពារតេះ ចូល
ចាប់ប្រាណព្រះ កុម្ភណ្ឌមួយថា អ្នកបេះឈូកកង្ខ ស្រែះស្រែងរំងថ្ងា អ្នក
ឯងត្រូវជា' ចំណីអស់យើង ។ ម្នាក់ថាកុំអាល អ្នកនេះត្រកាល ត្រកូល
ថ្កុំថ្កើង គន់នោមធាយោ ឫកពាចើងម៉ើង ធ្វើតាមទំនើង គ្មានគិតគោតក្រែង
នេះម្តងប្រហែ ប្រប្រឹមឥតភ័យ ឥតគិតឥតស្មែង ឥតគិតទឹកស្ទើប រំភើប
អញឯង ឃល់ដៀងដាក់ស្តែង អញគិតហើយភ័យ ។ រួបពង់អង្គឯក
ស្អួលចំឡែក លើសលោកជាទៃ ក្រែងតាត់ចេះចែង សំដែងធម៌ថ្ងៃ
គួរយើងប្រាស្រ័យ សួរព្រះធម្ម ។ កុម្ភណ្ឌមួយនាក់ ស្តែងស្តាប់ដៀងជាក់
សាកសួរទៅថា ហែមហាបុរស ស្រៀបស្រស់សោភា អាថិធម៌ធម្ម
រំពៃរ ។ អង្គិធម៌ទឹង ធម៌តើអ្នកជឹង អ្នកបេះប្តូរទេ មួយថាបើអ្នក ដៀង

ជាតំបេះប្រៃ ចូរថ្វែងច្រាប់គេ ចុះចៅកុំភ័យ ។ អញអាណិតចៅ រួម
ភនស្លេញស្លៅ ក្រែងចៅក្សិណក្សយ បើចៅឯងអាច មានច្រាប់ដាវ
បេះថ្វែងធម៌ថ្លៃ ឲ្យយើងស្តាប់ហើយ ។ យើងនឹងលែងចៅ ឲ្យរៀនវិន័យ
កុំចៅភ័យខ្លាយ ព្រះពោធិសត្វ បុរសគ្រាណាត្រើយ ស្តែងស្តេចស្តាប់
ហើយ បន្ទូលវិញថា ។ យក្ខអើយអញឯង ពុំខ្វាចពុំក្រែង ដល់ប៉ុន
កេសា មួយរឹតធម៌នេះ អញបេះខេសនា តែព្រះធម្មា ប្រសើរថ្លៃថ្លាន ។
ជាធម៌ព្រះពុទ្ធ ប្រពៃវិសុទ្ធ វិសេសសញ្ញាណ ខេសន៍ខ្ញុំខ្ញានជន អរ-
ហន្តគ្រប់ថ្នាណ បរិបូណ៌មែនមាន បទថាលីថា ។ ខត្តិអាសនំ
អាសនយុត្តំ បើគ្មានអាសនា សមគួរជាអាសន៍ ធម្មាសន៍ថ្លៃថ្លា នោះ
សោតសោកថា ពុំគួរសំដែង ។

កុម្ភណ្ឌសួរថា ជូបម្តេចអាសនា ពុំគួរទឹងថ្វែង បទយើងខ្ញុំនៅ
ចូរចៅចាយចែង យើងនឹងតាក់តែង អាសន៍ឲ្យគួរគាប់ ។

តោដ៏ស្តាប់ហើយ ត្រាស់ថាយក្ខអើយ ចូរចៅប្រជាប់ គ្រឿង
ក្រែធម្មាសន៍ តាសស្រេចស្រាប់ សម្រេចសម្រាប់ ជាគ្រឿងបូជា ។
ហើយមានទៀនធូប ទូវគ្រឿងក្រអូប គ្រឿងគន្ធមាលា មានគ្រឿងអម្ពរ
សឹងសសោភា ឲ្យអង្គអាត្ម អញឯងស្មើកពាក់ ។ គួរខ្ញុំដម្ចា ទើប
ហៅអាសនា អង្គអញជាអ្នក សំដែងព្រះធម៌ ស្មើកសសោភ័ក្តគួ
ទើបគួរដៀងជាក់ ជាតិជាអាចារ្យ ។

(មានត)

ភាគទី ២៨

ទោ ប៊ុលរាជសេនា ជួ - ញ៉ិន ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាស បើបានអាន
ទំនងបេះខុបាយកលបំណាន
ទាំងមានសព្វានស្នេហាជាតិ ។

ឯខ្លៅតី គួនអ៊ូ ខៀវហ៊ុយ ទាំង ភូឡុង គំរើតតាហានប្រហែល ៩ ម៉ឺនចាយ ដម្រាំមកវាយយកស្រុកហ៊ូគោ លុះមកដល់ដំបន់កំពង់សំនដំនឹងថា កងទ័ពចូនលើកមក ខ្លៅតីកំឡាឈប់ទ័ព តាំងបន្ទាយទុកជា ៣ អន្លើ បន្ទាយកណ្តាល ខ្លៅតីនឹង ភូឡុងនៅកណ្តាល បន្ទាយខាងកើតគួនអ៊ូនៅកណ្តាល បន្ទាយខាងលិច ខៀវហ៊ុយនៅកណ្តាល ។

ចូចូ កាលមកដល់កំពង់សំនដំនឹងថា ខ្លៅតីតាំងបន្ទាយនៅទីនោះ កំដុះសេះបរទៅដិតបន្ទាយខ្លៅតី ហើយឲ្យតាហាន ស្រែកហៅខ្លៅតីចេញមកនិយាយគ្នា ។ ខ្លៅតីឮដូច្នេះ កំដុះសេះនាំតាហាន ចេញមកឋានៅមុខបន្ទាយ ។ ចូចូឃើញខ្លៅតីចេញមកតំយកសែសេះចង្អុលមុខខ្លៅតីហើយស្រែកថា ខ្ញុំឯងញាមានគុណ ជាន់ទំនុកបំរុងឯងដល់ខ្នាតហេតុម្តេច ឯងមកឧយសព្រួសក្បត់អញ ដាច់ច្រនគ្រាដូច្នេះ ។ ខ្លៅតី

ឆ្លើយតបថា ដែលឯងបានខំខ្មុកបំរុងចំញ៉ីមអញនោះ ក៏ព្រោះតែព្រះចៅ
ហៀនតែប្រាសមេត្តាអញទេ សព្វថ្ងៃនេះ ឯងជាមហាទុកជាតែឈ្នះទេ
ឯចិត្តនឹងខ្លួនឯងនោះ ចេញខ្លុស្តប់ គិតដណ្តើមយកពាជសម្បត្តិជាដរាប
ខ្លួនអញជាពូជព្រះពាជវង្សតាំងចិត្តកតញ្ញូ ទន់ព្រះមហាក្សត្រ ដែលអញ
គិតប្រទូសក៉ាយទឹងឯងនោះ ព្រោះព្រះចៅហៀនតេ បានៈសចក្តីក្តៅក្រ
ហាយក្នុងព្រះទ័យ ទើបទ្រង់ចុះឡាយព្រះហស្តលេខា ដោយព្រះរោហិត
មកឲ្យកំចាត់ឯងចេញ បានជាអញគិតប្រទូសក៉ាយឯងដោយហេតុនេះ ។

ចូរឆ្លុតដូច្នោះក៏ទឹងណាស់ ទើបប្រើទៅជូ បវរសេះចេញទៅ
ចាប់ខ្លួនឡៅពី. ជូឡុងក្រឡេកឃើញក៏បវរសេះ កំពុងចេញមកតយុទ្ធនឹង
ទៅជូបានញ៉ាំភ្លេង ទៅមិនទាន់ចាញ់ឈ្នះ ខ្លួលទៅជូឮសំឡេងស្រែក
ហ៊ោអឺងកង ក្រឡេកទៅឃើញទាងទំសឯកើតនោះ គួនអ៊ូលើកទាហានខំ
លាយកូលមក ឃើញខៀវហ៊ុយលើកទាហានចូលមក ព័ទ្ធសងលិច
ទៅជូយល់ថា ទឹងចប់ខ្លាំណ្តុះ ក៏ទាញសេះប្រាសរត់ថយក្រោយ ។
គួនអ៊ូ ខៀវហ៊ុយ ជូឡុងយល់បានចំណាប់ ក៏ដេញកងទ័ពប្រកិត តាម
ចាក់កាប់សម្លាប់ទាហានចូលស្លាប់ជាច្រើន ចូរឆ្លុតក៏ប្រមូលទាហានបានជួប
ជុំគ្នា ក៏តាំងជន្លាយនៅទីនោះ ។

ជួនជាពេលត្រលប់ឡៅពី គួនអ៊ូ ខៀវហ៊ុយ ជូឡុង ក៏ទាំងគ្នាត្រឡប់
ចូលបន្លាយ លុះព្រឹកឡើងឡៅពី ក៏ប្រើជូឡុងលើកទាហានទៅស្រែក
ដេរចូរឆ្លុតដល់មុខបន្លាយ គ្រប់ ៣ ថ្ងៃ ។ ចូរឆ្លុតក៏មិនបានចេញតតាំងឡៅពី
ឲ្យខៀវហ៊ុយលើកទាហានទៅដេរ តិះដៀលចូរឆ្លុតថែមខៀត ជាច្រើនថ្ងៃ

ចូរឆ្កែនៅសម្លឹងបន្ទាយ ខ្លៅតិចមានសេចក្តីសង្ស័យ គិតក្រែងចូរឆ្កែនឹងប្រើឲ្យកាយកល់សឹកប្រការម្តេច ខ្លួលមានបំរើសេះមកប្រាប់ខ្លៅតិចថាឥឡូវកងទ័ពទៅនាំស្បៀង ទើបឯកមកឡែកឯទ័ពលោក មកដល់កណ្តាលផ្លូវ ឥាហានចូរឆ្កែនឹងចោមរុំកុំព្រៃ ។ ខ្លៅតិចបានស្តាប់ ក៏តិយថាអ្នកណាស់ គិតថា "ចូរឆ្កែធ្វើកល់សឹកដូច្នេះ បានជាសម្លឹងនៅស្ងៀមមិនចេញច្បាំង" ទើបឲ្យខ្ញៀវហ៊ុយលើកឥាហានទៅជួយកុនគោ; ខ្ញៀវហ៊ុយខ្លួលពាក្យខ្លៅតិចហើយ ក៏លើកទ័ពចេញទៅ ។

ខ្លួលមានបំរើសេះប្លែកមកប្រាប់ខ្លៅតិចថា ឥឡូវហហួខុនលើកទ័ពទៅវាយយកស្រុកយីហ្វាំ បានតតាំងប្លុកនាជាពន្ធឹក ។ ខ្លៅតិចបានឮដូច្នេះ ក៏តិយស្មុតចិត្តគិតថា "ស្រុកយីហ្វាំខ្លះហើយ ត្រូវរបស់យើងក៏ទឹងអន្តរាយ" ហើយប្រើតួនអ៊ូឲ្យលើកឥាហានទៅជួយខ្លៅផែកឯស្រុកយីហ្វាំ តួនអ៊ូក៏ប្រញាប់លើកទ័ពចេញទៅ ។

កន្ទុងតិចនោះមក ២ ថ្ងៃ បំរើសេះមកប្រាប់ខ្លៅតិចថា ហៃហួខុនវាយយកបានស្រុកយីហ្វាំហើយ ខ្លៅផែករត់ចេញតិស្រុកចូរទៅតួនអ៊ូដែលលោកឲ្យលើកទៅជួយនោះ កងទ័ពហហួខុនខ្លាមតិខ្លួនឯងខ្ញៀវហ៊ុយ ដែលលើកទៅជួយការពារស្បៀងនោះ កំចូលទៅទៅកងវាងទ័ពចូរ ។

ខ្លៅតិចបានស្តាប់តតិមានដូច្នេះ ក៏រំតែព្រួយចិត្តជាខម្ងន់ណាស់ទៅទៀត គិតទឹងថយទ័ពត្រឡប់ទៅវិញ ខ្លាចក្រែងចូរឆ្កែលើកទ័ពជាប់តាមខ្លួលឥាហានមកប្រាប់ថា ឥឡូវខ្ញៀវលើកឥាហានមកដេរប្រមាថទៅ

មុខបន្ទាយ ។ ខ្ញុំឥតភ្លេចហើយក៏មិនអាចនឹងចេញតប្លាំង បញ្ជាតួតាហានឲ្យប្រុងត្រៀមត្រាតក្បាបន្ទាយជាមាំមួន លុះដល់កណ្តាលអធ្រាត្រស្ងាត់ ប្រហែលយាម ៤ ជុាយ ខ្ញុំឥតក៏ឲ្យប្រុងប្រៀបសេនាតាហានព្រមគ្នា ឲ្យតាហានថ្មើរដើរលើកចេញទៅគ្រាយបន្ទាយជាមុន ហើយខ្ញុំឥតក៏នាំតាហានសេះតាំងប៉ុន្មាន រត់ចេញពីបន្ទាបេទៅចម្ងាយផ្លូវប្រហែល ៥០ សិន (៤០០ម.) ក្រឡេកទៅឃើញតាហាន ១ កង អុជគប់ភ្លើង ស្ងាក់ពីមុខពេញផ្លូវ ហើយឮសំឡេងស្រែកតំណាប់គ្នាថា កុំឲ្យខ្ញុំឥតរត់រួចទៅបានមហាឧបាជមកចាំនៅជាច្រើនថ្ងៃហើយ ។ ខ្ញុំឥតយល់ព្រលឹង មិនដឹងនឹងគិតវែរត់ទៅខាងណា ។

ដូច្នឹងជំកបថា លោកកុំភ័យបារម្ភ ខុតជាខ្ញុំនឹងត បំប្រាសចេញទៅ ត្រូវឲ្យលោកបរសេះនាំតាហានចេញទៅតីក្រាយខ្ញុំចុះ ខ្ញុំនឹងនាំលោកចេញទៅឲ្យបាន ។ ខ្ញុំលុះឃើញតាហានលើកតាហានតាមពីក្រាយមកទៀត ដូច្នឹងក៏ឆ្ងាកសេះកំនឹងតារ តាំងមុខតាំងក្រាយ នាំខ្ញុំឥតនឹងតាហានចេញទៅបាន ។ ខ្ញុំលុះប្រទះនឹងអ៊ីគឹម លីខៀន លើកតាហានពីយខ្លួបមកទៀតជាច្រើបលាន ខ្ញុំឥតឃើញថាតាលីប្រកតេកណាស់ ក៏លះដោះខ្លួនចោលដូច្នឹង នឹងតាហានតាំងតួច បើយបរសេះតេចវែះចេញរួចទៅតែម្នាក់ឯង ទុំស្រួតរត់ទៅដល់ប្រកដុំ ១ ខ្ញុំលុះក្តីស្រាង ។ ឃើញតាហាន ១ កង លើកមក ប្រហែល ៣០០ ជុាយ ខ្ញុំឥតភ័យណាស់ញាក់សេះចូលទៅតែបតាង៉ដើងភ្នំ លុះតាហានតោះមកដិត ខ្ញុំឥតក្រឡេកឃើញខ្ញុំឥតផ្តេក ស៊ុនខៀនបីកុតបីហាង ក៏ឧយ៉ាងនាំគ្រួសារនឹងតាហានតាំង

តួនមកដល់ ខ្ញុំពីក៏ជួរស្រាលក្នុងចិត្ត ។ ខ្ញុំផែកក៏ដំណរខ្ញុំពីថា
ហែហួខុន មានថ្ងៃដែលាំងតូកែណាស់ លើកទ័ពទៅខ្មាមព័ទ្ធស្រុកជាច្រើន
ខ្ញុំបានតល់ពុំឈ្នះ ទើបនាំគ្រួសារលោករត់រួចមក ហែហួខុន ក៏លើក
ទ័ពជាប់តាមមកដល់ពាក់កណ្តាលផ្លូវ ប្រទះនឹងតួនអ៊ូ បានជួយច្បាំងតគ្នា
ខ្ញុំបានក៏រត់រួចមកបាន ។ ខ្ញុំពីដឹងច្បាស់ដូច្នោះ ក៏សួរថា ឥឡូវតួនអ៊ូទៅ
ឯណា បានជាមិនមកជាមួយគ្នា? ខ្ញុំផែកឆ្លើយថា លោកកុំព្រួយចិត្តក
ឡើយ តួនអ៊ូ មិនមានអន្តរាយទេ នៅការៈរាតាមក្រោយ លោកចូល
រត់ទៅឲ្យផុតភ័យអន្តរាយចុះ ។

ខ្ញុំពីក៏នាំគ្រួសារទឹងតាហានទាំងតួនរត់គេចទៅខាងទិសទក្សិណ
បម្ងាយផ្លូវប្រហែល ៩០ សិន(៤០០ ម.) ប្រទះនឹងខ្ញុំវាប់លើកទ័ពមក
ស្ទាក់ពីមុខ ។ ខ្ញុំវាប់ ក៏ស្រែកគំរាមខ្ញុំពីថា ឲ្យចុះពីលើសេះមក ឲ្យ
យើងចងដោយស្រួល ទើបខ្ញុំនឹងសន្សំរួចជីវិត ។ ខ្ញុំពីភ័យស្លុតស្មារតីថយ
មកក្រោយ ក្រឡេកទៅឃើញកោលាំ លើកទ័ពតាមពីក្រោយមកខ្ញុំត
ខ្ទប់គ្នាពីមុខនឹងពីក្រោយជុំវិញ គិតជាប់ចិត្តនឹងកំយោបុត្រ ក៏ដកដង្ហើមធំ
ហើយដើរមុខទៅលើអាកាសស្រែកថា "ទេវតាឲ្យយើងកើតមកជា
មនុស្ស ម្តេចឡើយមិនជួយទប្បត្តិទុកបំរុងឲ្យបានសុខ ឲ្យតែបើងបាន
រងទុក្ខលំបាកដល់ពីនេះ បើនឹងរស់នៅរក្សាជីវិតក៏វតអំពើ" ថារៀយ
ក៏ហូតក្រចឹងចេញប្រុងនឹងអារកសម្លាប់ខ្លួនឯង ។

នាយតាហានទាំងតួនឃើញដូច្នោះ ក៏ភ័យស្លុតជិត្តទាំងអស់គ្នា នាំ
គ្នារត់ចូលទៅជល់ណើមយកក្របីបាន ។ ខ្ញុំផែកក៏និយាយនឹងខ្ញុំពីថា

"លោកទំនងមកបង្ខិំសម្លាប់ដីវិតចេញ ព្រោះសត្រូវតាមមកបៀតបៀនធ្ងន់អន្តរាយប៉ុណ្ណោះមិនគួរទេ ខ្ញុំបាទនឹងសូមយកអាសា ចេញទៅបង្ខាំងទ្បៃបែកគ្រាតែបាន ហើយនឹងនាំលោកចេញទ្បៃរួចព័ន្ធ ក្នុងគ្រានេះ" លុះឃើញគោលំាបរសេះចូលមកជិត ខ្ញៀផេកកំបរសេះកំពួនចូលទៅបង្ខាំងនឹងគោលាំ ៗ យកខ្លួនចាក់ត្រូវ ខ្ញៀផេកធ្លាក់ពីសេះស្លាប់ ។ ខ្ញៀពីឃើញដូច្នោះកំមានសេចក្តីមានះគិតចេញទៅតស៊ូនឹងគោលាំ ខ្លួលឮសំឡេងគាហានស្រែកពីក្រោយគោលាំឡើង ។ ខ្ញៀពីក្រឡេកទៅឃើញដូឡុនដេញចាក់គាប់សម្លាប់គាហានគោលាំចូលមក ហើយយកខ្លួនចាក់ត្រូវគោលាំធ្លាក់ពីលើសេះស្លាប់ ខ្ញៀពីកំធូរស្រាលក្នុងចិត្ត ដូឡុងកំចូលមកគំនាប់ខ្ញៀពីហើយ កំបរសេះតាវំលាយចេញទៅបង្ខាំងនឹងខ្ទៀវគាប់ ចាន ៣០ ក្បែង ហើយដេញគាប់សម្លាប់គាហានស្លាប់ជាច្រើន ខ្ទៀវគាប់កំនាំគាហានថយទៅក្រោយ តាំងស្ពាត់ទៅច្រកផ្លូវស្បែកភ្នំ ខ្ញៀពីឃើញដូច្នោះ មិនដឹងបើនឹងនាំគាហានចេញទៅខាងណា ។

ឯគួនអ៊ូ ជីវិធ នឹងគួនចេងមកតាមផ្លូវច្រកភ្នំ ឃើញខ្ទៀវគាប់ទៅស្ទាក់ផ្លូវពីមុខ កំបរពលគាហានចូលវាយប្លន់គាហានខ្ទៀវគាប់ ចូលមក ។ ខ្ទៀវគាប់តទល់នឹងថ្ងៃដៃគួនអ៊ូមិនបាន កំនាំគាហានវេះចេញពីផ្លូវរត់ទៅ ។ គួនអ៊ូក្រឡេកឃើញខ្ញៀពី កំចូលទៅពណិនាប្រាប់សេចក្តីដែលបានតតាំងបង្ខាំងនោះគ្រប់ប្រការ ។ ខ្ញៀពីកំទ្បៃបញ្ជាប់ទ័ពទៅស្បែរដើងភ្នំនោះ ហើយប្រគួនអ៊ូទ្បៃទៅស៊ើបសួរពីខ្ទៀវហ៊ុយ ។

ឯខ្ទៀវហ៊ុយពាលទៅជួបគាពារស្បៀងនោះ កំទៅមិនបានដំណែហួងអឿន

វាយយកសម្បៀង ហើយសម្ងាប់កូនគៅ ស្លាប់ជាមុន លុះខៀវហ៊ុយគៅ
ដល់ ឃានតតាំងទំនឹងហែហួរអៀនជាពន្លឹក ។ ហែហួរអៀនគ្រាំទំនឹងថ្លើដៃខៀវ-
ហ៊ុយមិនឃាន ក៏នាំភាហានរត់គៅ ខៀវហ៊ុយក៏ដេញជិតឆ្ងាំងគ្នំគៅជាច្រើន
ជំពន់ ។ ហែហួរអៀនដែលរត់គៅនោះ ជួបប្រទះនឹងដីកជិន លើកភាហាន
មកជាច្រើន ក៏នាំដីកជិន វិលត្រឡប់មកគ្រាយ ប្រទះនឹងខៀវហ៊ុយឃានត
តាំងចម្បាំងគ្នា ជាពន្លឹកទៀត ។ ហែហួរអៀនទំងដីកជិន លើកភាហាន
ខ្មោមពន្លៃខៀវហ៊ុយទុកជាច្រើនជាន់ មានភាហានខៀវហ៊ុយវត់រួច មកប្រ-
ទះនឹងគួនអ៊ូ ក៏ប្រាប់រឿងក៏ាវ្យៃគួនអ៊ូស្តាប់គ្រប់ប្រការ ។ គួនអ៊ូឃានស្តាប់
ហើយក៏ក័យស្មុតចិត្ត ឲ្យភាហានតាំងនោះ នាំគ្នាវៃគៅដល់ទីខ្មោមខៀវហ៊ុយ
គួនអ៊ូក៏បរសេះកំជាវៃចូល គៅដេញកាប់សម្ងាប់ភាហានចូឆួ ស្លាប់អស់ជា
ច្រើន ។ ហែហួរអៀនទំងដីកជិន គ្រាំទំនឹងថ្លើដៃគួនអ៊ូ ខៀវហ៊ុយមិនឃាន ក៏
នាំភាហានដែលទៅសល់នោះរត់គៅ ។ គួនអ៊ូក៏នាំខៀវហ៊ុយទំងភាហាន
តាំងតួងមកវាកឡៅពី ហើយអធិប្បាយក៏ាយរឿងដែលកុងគៅស្លាប់ព្រោះ
ហែហួរអៀនសម្ងាប់ ទំនឹងរឿងដែលឃានចម្បាំងតាំងប៉ុន្មានឲ្យ ឡៅពីស្តាប់ គ្រប់
ប្រការ ខ្លួលមានភាហានម្នាក់មកក្រាប់ឡៅពីថា ចូឆួ លើកភាហាន
តាមមកច្រើនណាស់ ឡៅពីជំងឃ្លាស់ដូច្នោះ កំឲ្យស៊ុនវៀនឃុំនាំគ្រួសារ
គៅមុខ ឡៅពី, គួនអ៊ូ, ខៀវហ៊ុយ ទំងផ្តួងនាំភាហានដែលសល់នោះ
ប្រហែល ១ ពាន់ការគារព៌ក្រោយ ។ ឯចូឆួក៏តាមមកដល់ជម្រុំឡៅពីឈប់
លុះមិនឃើញឡៅពីហើយ ក៏នាំភាហានវិលត្រឡប់គៅបន្ទាយវិញ ។

កុង ១ ណ:ដែលឡៅពីវត់គៅនោះ មិនឃានដឹងផ្លូវព្រៃទំងគៅទីដំបន់ណា

ឧស្សាហ៍ស្រុតកាត់ស្មែរកជ្រៅ លុះទៅដល់ខន្ធមួយ ក៏សាកសួរអ្នកស្រុក
ថា ខន្ធនេះឈ្មោះអ្វី? អ្នកស្រុកថ្លែងប្រាប់ថា ឈ្មោះខន្ធហ៊ានតំង មានផ្លូវហួត
ទៅដល់ស្រុកកេងដែរ។ ឡៅតីក៏ឲ្យគ្រួសារនឹងសេនាគាហានឈប់សម្រាក
នៅទីជិតមាត់ខន្ធនោះ ។ អ្នកស្រុកតាំងពួង ក៏មានសេចក្តីអាណិតព្រោះ
ឡៅតីអត់ជាប់ស្បៀងអាហារមក ក៏នាំគ្នាយកអង្ករត្រីសាច់ទឹងជ្រូកមានច្រើន
ឲ្យទៅឡៅតីជាច្រើន។ ឡៅតីក៏មានអំណរណាស់ ទើបនាំយកវបស់តាំង
អស់នោះ ទៅចែកឲ្យគាហានអាស្រ័យបរិភោគគ្រប់គ្នា ។

ឡៅតីកើតទុក្ខរៀខនាក៏អង្គុយដកដង្ហើមធំ ហើយនិយាយប្រាប់តាម
គាហានតាំងឡាយថា អ្នកតាំងអស់គ្នាសុទ្ធតែមានដម្រេះប្រាជ្ញា ទឹងថ្លៃដែ
ហេតុអ្វី មកស៊ូតាមយើង ដោយព្រួយលំបាកប្រកាយដូច្នេះ ខ្ញុំនយើងនេះដា
មនុស្សអត់តួអាប់កាស៊ី គ្មានបុណ្យកុសលអ្វីទឹងដួយខំនុកបំរុង ឲ្យបានបុ
មានតែសេចក្តីទុក្ខព្រួយលំបាកពន់ពេក អ្នកពាល់គ្នាមកពីងផ្អែក យកប្រ
យោជន៍អ្វី? ដែលអ្នកពាល់គ្នាបានដួយដោះទុក្ខយើង នាំឲ្យរួចពីកយន្តកយ
មកដល់ទីនេះហើយដូចនាំ យើងធ្លុងត្រើយសមុទ្រហើយបានទំពឹងអាស្រ័យ
យើងក៏អរគុណពន់ប្រមាណគួរអ្នកពាល់គ្នាទឹងរិលប្រាន់ទៅកេនាយទៀហ្នាយ
ដែលមានបុណ្យកុសលច្រើន ជាទីពឹងពុះ ប្រយោជន៍ទឹងបានសេចក្តីសុខ
ក្សេមក្សាន្តតទៅ ។ ពេលគាហានតាំងអម្បាលនោះ លុះបានឮសំដីឡៅតី
និយាយដូច្នោះ ក៏មានសេចក្តីអាណិតស្រុកទឹកស្រែក ឃំយែកតាំងអស់គ្នា។

គួនអ៊ូនិយាយទឹងឡៅតីថា កាលព្រះចៅហ៊ានសោយ ធ្វើសឹកសង្គ្រាម
ទឹងព្រះចៅឈាប៉ាអង្គ កំបាត់ជ័យបាញ់ទឹងព្រះចៅឈាប៉ាអង្គ ជាច្រើនគ្រា

លុះអំណឹះតមក ព្រះចៅហ៊ានគោចោធ្វើសង្គ្រាមទឹងព្រះចៅឈប៉ាអង ទៅ
កុំតវិលស័ន ព្រះចៅហ៊ានគោចោ កំមានជ័យជំនះ ហើយបានឡើងសោយ
រាជសម្បត្តិ ។ រង្វែព្រះបាទហ៊ានគោចោសោយរាជ្យតៗមកបាន ៤០០ ឆ្នាំ
រហូតមកដល់ព្រះចៅហៀនភ សព្វថ្ងៃនេះ គ្រានេះ លោកមកជ័យទឹង
ចូលត្រែ២-៣ គ្រាទេ ទឹងមកបង្កើយចិត្ត មិនតិតការតទៅនោះមិនគួរសោះ ។

ស៊ុនទៀនបានស្តាប់តួនអ៊ូនិយាយដូច្នោះ កំយល់ឃើញត្រូវផង ទើប
និយាយទឹងឡៅព័ថា ធម្មតាជាតិភាពានទឹងធ្វើការសង្គ្រាមនោះ រមែង
ឈ្នះទឹងចាញ់ដែលយើងធ្វើសង្គ្រាមគ្រានេះ ផ្លូវកំដិតទឹងដល់ស្រុកកេង-
ជីវហើយ ឯខ្លួនលោកទឹងឡៅប៉ៃកំសែជាមួយគ្នាខ្លួនឡៅប៉ៃវិលហ្វាយ
ស្រុកកេងជីវនោះ មានខែត្រឡើងដល់ទៅ ៨ មណ្ឌល បើលោកទឹងទៅសុំ
ទៅតាស្រ័យទឹងឡៅប៉ៃកំមុខជាទឹងបានបើតាំងខ្លួនជាប្រក្រតីហើយ
តង់ទឹងបានតិតការតទៅ ។ ឡៅព័តបថា យើងត្រែងតែឡៅប៉ៃវិ មិន
ត្រមខ្លួល ។ ស៊ុនទៀនឆ្លើយថា ដែលលោកគិតត្រែងដូច្នោះ ខ្ញុំទឹង
សុំតាសាទៅនិយាយសម្រួលឡៅប៉ៃវិជាមុន មុខជាឡៅប៉ៃទឹងមិនលះ
បង់មេត្រីភាព ។ ឡៅព័បានស្តាប់ដូច្នោះ កំជូរចិត្តទើបថា បើអ្នកទឹងទៅកំ
ទៅចុះ ។ ស៊ុនទៀនកំលាឡៅព័ៈទៅដល់ស្រុកកេងជីវ ហើយចូលទៅតំ
នាប់ឡៅប៉ៃវិ ។

ចំណែកឡៅប៉ៃវិ លុះក្រឡេកឃើញស៊ុនទៀនទៅដល់ កំសួរថា
ខ្លួនអ្នកទឹងឡៅព័មានខុកធុរៈអ្វី បានជាមករកយើង ។ ស៊ុនទៀនជំរាបថា
ឡៅព័នោះកំពូជព្រះរាជវង្ស តាំងមានតម្រេះប្រាជ្ញា កាន់ពាក្យស័ត្យទៀង

ត្រង់ ហើយមានចិត្តសុចរិតតែងតែធ្វើការទំនុកបំរុងដែនដីឲ្យបានសេចក្តីសុខ
ឯខ្លាផេកនឹងកុនតៅដែលបានទៅនៅស្រុកយើហ្វាំកំពុលអាសារខ្លាពី
ពាល់តែស្លាប់ខ្លួន ឥឡូវខ្លាពីធ្វើសឹកសង្គ្រាមចាញ់ចូធូរត់មកនៅខេត្តហ័ន
ក័ន តាំងចិត្តនឹងចូលឈ្លបសមុទ្រទៅអស្រ័យនៅ នឹងស៊ុនគួនថៅហ្វាយ
ស្រុកក័ងក័ង ខ្ញុំបានកំយាត់ហាមខ្លាពីថា ស៊ុនគួននោះជាមនុស្សសាប់
ក្រៅ ដែលនឹងទៅសុំសំណាក់អស្រ័យនោះមិនគួរ ខ្ញុំបានកំនាំមកប្តឹងឯ
លោក ដែលជាសែជាមួយគ្នាវិញ ខ្លាពីកំយល់ព្រមផង បានជាឲ្យខ្ញុំបាន
មកដំកប់លោកជាមុនឲ្យជ្រាម ជាលោកនឹងយល់ឃើញដូចម្តេច ។

ខ្លាបើរំបានស្តាប់ក៏មានអំណរសោទនិយាយថា ខ្លាពីជាបងប្អូន
របស់យើងពិត តែខ្លួនប្រាណយើងក៏មិនដែលស្គាល់ បានឮតែឈ្មោះគេ
និយាយថា មានតម្រេះប្រាថ្នាកាន់ពាក្យស័ក្សខៀនត្រង់ គ្រានេះខ្លាពីមាន
សេចក្តីទុក្ខ បែរមុខមកប្តឹងនៅនឹងយើង ។ កំនឹងបានឃើញមុខគ្នាជាក់
ច្បាស់តទៅ។ ឈ្មេមប្អូនគប់យោខ្លា.ប៉ាវ៉ែធ្វើយថា ឯខ្លាពីនោះពីដើមនៅនឹង
លីប៉ោ ហើយរត់ទៅនៅនឹងចូធូ។ ក៏បានទំនុកបំរុងចិញ្ចឹមដល់ខ្លាត ខ្លា.
ពីតតប្រជុំសក៏យកចូធូ ពាល់តែបានធ្វើសឹកសង្គ្រាមនឹងគ្នា ហើយបែកពីចូធូ
មកប្តឹងនៅនឹងអ៊ួនសៀវ ។ ក៏ចិញ្ចឹមរក្សា ដោយស្មោះត្រង់ ខ្លាពីប្រែ
ចិត្តចេញពីអ៊ួនសៀវ ហើយរើតាំងខ្លួនឡើង ធ្វើសឹកសង្គ្រាមនឹងចូធូទៀត
ពាល់តែបែកខ្ចាត់ខ្ចាយមកនេះ ដែលខ្លាពីមកប្តឹងពាក់ព័ន្ធនាក់អាស្រ័យ
នៅនឹងលោក សូមឲ្យលោកវិនិតិ្តតំពីងពាយណាមើលឲ្យត្រូវ តាមពាក្យ
បុរាណ ប្រសិនបើលោកនឹងខ្លួលខ្លាពីទុកជាវរកប់អាន ចូធូក៏តង់ខឹង

លើកមកវាយយកស្រុកយើង អាណាប្រជារាស្ត្រទឹងជានសេចក្តីក្តៅក្រហាយ បើលោកទឹងចង់ជាសុខតទៅ ត្រូវតែកាត់ក្បាលស៊ុនខៀនបញ្ជូនទៅឲ្យចុងភ្នួ យកសេចក្តីគាប់ប្រសើរណ្ហង ។

ស៊ុនខៀនបានឮដូច្នោះ ក៏មិនញញើតខ្លាច ធ្វើឃតបថា ខ្លួនខ្ញុំទឹងជានខ្លាចសេចក្តីស្លាប់ក៏ទេ ព្រោះហេតុតាំងចិត្តយកអាសាឡៅពីដែលជាមនុស្សស័ត្យខៀងត្រង់ទឹងផែនដី ហើយឡៅពីនោះកើជាភូជព្រះពជវង្សផងតិតតែចំនុកបំរុងព្រះមហាក្សត្រឲ្យសោយពជសម្បត្តិនៅជាសុខដែលឡៅពីជានៅនៅទឹងលីហៅ, កួន, អ៊ួនសៀវ សុទ្ធតែជាមនុស្សមានចិត្តអក្រក់ជូរជាតិខោះ ព្រោះសេចក្តីភាល់ ឥឡូវឡៅប៉ៅជាសែជាមួយគ្នាតាំងមានចិត្តសុចរិតខៀងត្រង់នៅវិញទៅមក ជានជាឡៅពីប្រមុខមកទឹតឹងតាក់ ហេតុម្តេចជានជាអ្នកមកតិះដៀលចូលខាងមនុស្សអាក្រក់និយាយញុះញង់ដូច្នេះ ។ ឡៅប៉ៅជានស្តាប់ ក៏ទឹងទឹងឈួមហើយថា ខ្លួនចិត្តមិនល្អ កុំមកឃាត់ហាមយើងឡើយ តាំងថ្ងៃនេះទៅ កុំមកនិយាយទឹងយើងទៀត ។ ឈួមជានសេចក្តីគាប់ឃសន្ធាសអៀនតន់ពេកណាស់ ក៏ថយទៅកាន់ទីលំនៅវិញ ។ ឡៅប៉ៅបង្គាប់ស៊ុនខៀន ឲ្យត្រឡប់ទៅខួលឡៅពីហើយឡៅប៉ៅក៏នាំតាហានចេញទៅ ចម្ងាយផ្លូវប្រហែល ៣០ សិន (១២ គ.) ទ្រាថ្នាទឹងទៅចាំខួលឡៅពី ។ កាលស៊ុនខៀនទៅដល់ឡៅពីហើយ ក៏អធិប្បាយឃសេចក្តីទាំងពួង ឲ្យឡៅពីស្តាប់គ្រប់ប្រការ ឡៅពីក៏មានអំណរពន់ប្រមាណណាស់ រើបនាំគ្រួសារទឹងសេនាតាហានទាំងពួង ទៅដល់កណ្តាលផ្លូវ ស៊ុនខៀនក៏នាំឡៅពី, គួនអ៊ូ,

ខ្មែរហ៊ុយ, ចូលទៅតំនាប់ឡៅប៉ៅ ។ ឯឡៅប៉ៅកំនាំឡៅពី គួនអ៊ូ ខ្មែរ-ហ៊ុយ, ដូឡុងទីន្រ្តេសោរចូលទៅក្នុងស្រុក ឲ្យរៀបចំតុះលៀងតោជនាហារ ហើយកំចាត់ចែងទីគេហដ្ឋាន ឲ្យឡៅពី គួនអ៊ូ ទីនខ្មែរហ៊ុយ នៅតាម សមគួរ ។

ឯចូនួតាលបើដឹងថា ឡៅពីចូលទៅនៅក្នុងស្រុកកេងជីវដូច្នោះ ក៏ប្រមូល ពលយោធាទីនលើកទ័ពទៅកាយឡៅប៉ៅ ឯស្រុកកេងជីវ ។ ឆៀហ៊ុក កំ ទំយាយឃាត់ហាមថា កាសង្គ្រាមទាងអ៊ូនសៀ នៅមិនទាន់សម្រេចដូច ម្តេចនៅឡើយ ដែលលោកទីនបែរគេចលើកទ័ព ទៅកាយឡៅប៉ៅ យក ស្រុកកេងជីវខ្មែរនោះ មិនបានខ្មែរតែអ៊ូនសៀវិនហើយ គង់ទីនលើកទ័ព ត្រឡប់ទៅកាយយកស្រុកហ៊ូគោ មិនខាន សូមឲ្យលោកប្រមូលសេនា ពាហនៈលើកត្រឡប់ ចូល ៣ក្រុង ដើម្បីទីនទំនុកបំរុងកំឡាំងរហ័ពល ឲ្យ ស្រួលបួលសិន ដល់ចូលឆ្នាំថ្មី ជាវេលាវេសកាលគឺមួនវេលា សឹមលើកកង ទ័ពទៅកាយយកស្រុកកេងជីវ គង់ទីនបានដោយងាយ ឯឡៅពីដែលទៅ គាស្រ័យខ្មៅទីនឡៅប៉ៅនោះ ក៏ទីនមិនរួចផុតពីកណ្តាប់ដៃ របស់លោក ទេឡើយ ។ ចូនួកិយល់ត្រូវធង ទើបលើកកងទ័ព ត្រឡប់ទៅស្រុកក្រុង ហើយប្រទីនប្រៀបសេនាពាហនដាយរួចខ្លះ ។

(មានត)

រឿងហ្សកឌិត

លោកវ៉ុលតែរនិតន្ទ

លោក រ៉ាយ-ប៊ុក រៀបរៀង

(តមក)

វគ្គទី ៦ រដ្ឋមន្ត្រី

ព្រះមហាក្សត្រទ្រង់បានហួតដារចេញពីតំណែង ខ្លួនវរដ្ឋមន្ត្រីទី ១ ។ ទ្រង់បានជ្រើសរើសយកលោកហ្សាឌិតចំនួស ។ ពួកនារីល្អស្រស់ប្រម-ប្រែយនៅទីក្រុងប៉ារីសបាន ឃានទៃអបអរសាទរថា មហាពរជ្រើសរើសលោកនេះឱ្យបំពេញមុខដារតំណែងជាន់ខ្ពស់នេះ ពេញជាត្រូវ ព្រោះថាតាំងពីការស្តាបនាអធិប្រទេសនេះ គេមិនដែលឃើញរដ្ឋមន្ត្រីក្មេង ដូច្នេះទេ ។ ពួកសេវាគាមាត្យអន់ចិត្តជាខ្លាំង ; អ្នកលោកនេះទៀតជាខាកស្តោះមកសុទ្ធតែឈាម ហើយច្រមុះគាត់ទៀតហើមប៉ោងហួសប្រមាណ ។

លោកហ្សាឌិត បានថ្លែងនូវព្រះពរដ៏អំណរគុណ ចំពោះព្រះមហាក្សត្រនិងព្រះពរជនី ហើយបានទៅសំដែងគារវកាព ចំពោះសេកព្រះបមកពថា " ឧបកូដ៏ល្អ " បក្សីឯងបានជួយស្រោចស្រង់ជីវិតខ្ញុំហើយបានបចនាជោគវាសនាខ្ញុំ ឱ្យបានមកកាន់រដ្ឋមន្ត្រីនេះ ។ រឿងសុនខញីនិងពរជនាជីព្រះភូមិន្ទ បាននាំមកនូវទុក្ខភាសភ័យ ជាអនេកប្បការមកឱ្យខ្ញុំ តែអ្នកបាននាំសេចក្តីសុខដ៏ប្រសើរមកឱ្យខ្ញុំ នេះហើយជាជោគវាសនា របស់មនុស្សគាំងឡាយ ។ ប្តូរលោកហ្សាឌិតបានបន្តែមសេចក្តីថា

សុភមង្គលដ៏ថ្លៃភគស្តារឲ្យដូច្នេះ ប្រហែលជាទំនិញសាត់បង់ ក្នុងកាលជាអនាគតមិនខាន ។

សេកកំបានតបមកកាន់លោកហ្សុិតថា " បាទ " ។ ពាក្យធ្វើយនេះ ធ្វើឲ្យលោកហ្សុិត មានមនោសញ្ចេតនាយ៉ាងក៏ស្មុគជាខ្លាំងតែលោកចំប្រុងធ្វើសេចក្តីក្លាហាន ឲ្យមានក្នុងសន្តានចិត្តឡើង ដោយលោកមិនបានដឹងជាក់ថា សេកអាចនាយទូវ៉ាជាគក់សនា របស់លោកបាន ។ លោកក៏ធ្វើព្រងើយកន្តើយ ហើយចំណាយមាមបំពេញមុខការរបស់លោកតាមការគួរ ។

១_លោកហ្សុិតជារដ្ឋមន្ត្រីល្អម្នាក់យ៉ាងប្រសើរ

លោកហ្សុិត ចំណាយមាមឲ្យពេលដ្ឋាំងអស់យល់ជាក់ច្បាស់ នូវអំណាចពិសិដ្ឋនៃបទបញ្ញត្តិច្បាប់ភាំងឡាយ, ហើយលោកហាមប្រាមខ្លួនលោកកុំឲ្យប្រើនូវសេចក្តីថ្លៃថ្នូររបស់លោក ឲ្យធ្លុះទៅកាន់ប្រជាពលរដ្ឋឲ្យសោះ ។ លោកមិនបានជំទាស់ចំពោះក្រុមប្រឹក្សា ស្តេចស៊ីលតង់ទេ ហើយរដ្ឋមន្ត្រីនៃព្រះអង្គម្ចាស់ម្នាក់យ៉ាងប្រសើរ ។ អាចឲ្យយោបល់បានដោយសេរី ។ បើកាលណាលោកសម្រេចរឿងអ្វីមួយ គឺមិនមែនលោកទេ ដែលថាទៅក្រមតឹច្បាប់ជាទៅក្រម តែបើកាលណាច្បាប់នោះ ជាក់ខ្លាតម្តងម្កាលប្រមាណ លោកតែងបន្ធូរបន្ថយទោសនោះខ្លះ ។ បើមានអ្នកណាមិនប្រតិបត្តិតាមបទបញ្ញត្តិច្បាប់ទេ លោកយកសេចក្តីយុត្តិធម៌របស់លោក មកពន្យល់បំភ្លឺពាក្យតែអ្នកនោះឮថាលោកដូចជាមហាបណ្ឌិតហ្សូស្តាស្ត្រដូច្នោះដែរ ។

តែដោយសារលោកចេះលៃលកជួយសង្គ្រោះអ្នកមានទោស មិនត្រូវ

ប្រញាប់ប្រញាល់ដាក់ខណ្ឌកម្មអកសុចរិតតិតត្រង់ទេ ។ ជាន់ជាប្រជាជាតិ
តាំងពីយូរយារ ជាន់យកគោលការណ៍នេះ ជាមូលដ្ឋាន។ លោកយល់ថា ច្បាប់
ធ្វើឡើង ដើម្បីស្រោចស្រង់ពួកពលរដ្ឋ ឥឡូវធ្វើឲ្យពួកពលរដ្ឋនេះខ្វះការ
ជួយប្រសប់ចេស់លោកដ៏សំខាន់ តើត្រូវនិយាយសេចក្តីពិតដែលមនុស្សទាំង
អស់ធ្វើ ខំព្យាយាមធ្វើសេចក្តីពិតនោះឲ្យនឹងនឹតអ័ព្វរស្មើភាវិញ ។

២-អំពីរឿងក្បែរមត៌ក

ថ្ងៃដាច់បរមដែលលោកទៅកាន់តាប់ដង្ហាតិចាល លោកបានយក
សេចក្តីជួយប្រសប់នោះមកអនុវត្ត មានន័យពាណិជ្ជម្នាក់នៅទីក្រុងជា
ដំបូងនេះ បានឧបត្ថម្ភដល់ប្រទេសផ្សេងៗ នាយពាណិជ្ជនោះបាន
បែងចែកក្តីមត៌កមកឲ្យបុត្រទាំងពីរនាក់ ដោយភាគស្មើគ្នា ។ ក្រោយ
ដែលរៀបរាប់ហេតុផលការ ប្អូនស្រីនៃបុត្រទាំងនោះ, គាត់ក៏បានឧបត្ថម្ភ
៣០.០០០ កហាបណៈ ហើយបានប្រកាសចំពោះបុត្រទាំងពីរនាក់ថា
មាសនេះ ខ្ញុំនឹងប្រគល់ឲ្យបុត្រណា ដែលស្រឡាញ់ខ្ញុំជាងគេ ។

បុត្រច្បងបានស្នើឲ្យបង្ហាញមួយផ្នែកគាត់, បុត្រប្អូនបានយកក្តីមត៌ក
មួយចំណែក ឲ្យទៅប្អូនស្រី ដើម្បីបង្ហាញចំនួនប្រាក់ជាដែលប្អូនស្រីនេះ
មានគេគោលថា "បុត្រច្បងនេះឯង ជាអ្នកស្រឡាញ់បិតាជាងគេបុត្រប្អូន
ស្រឡាញ់ប្អូនស្រីជាងបិតា; ព្រោះហេតុដូច្នេះ, បានជាមាស ៣០.០០០
កហាបណៈ ត្រូវបានទៅបុត្រច្បង" ។

លោកហ្សាឌិត ក៏បានហៅបុត្រទាំងពីរនាក់ ហើយលោកមាន
ប្រសាសន៍ទៅកាន់បុត្រច្បងថា "បិតារបស់អ្នក មិនមែនឧបត្ថម្ភលោះ

ភាពទេ តាត់ថ្មានជាសះស្បើយចាកពេតហើយ, តាត់នឹងរំលែកគ្រឿងម៉ាមកតាន់ទីប្រុងប្រៀងជាមួយខ្លាទៀត ក្នុងពេលខាងមុខ" ។ បុត្រច្បងក៏ពោលតបទៅលោកហ្វូងិតទៀតថា "ឧត្តមគាងពេលោកជួយខ្ញុំ; ថ្លូបង្ហូនដែលសងំនេះ; ខ្ញុំបានចំណាយប្រាក់អស់ច្រើន"។ លោកហ្វូងិតបានសួរទៅបុត្រប្អូនដោយពាក្យដដែល, បុត្រប្អូនតបទៅវិញថា "ឧត្តមគាងពេលដ៏ប្រសើរ, ខ្ញុំសប្បាយចិត្តណាស់, តែខ្ញុំសូមទុកប្រាក់ដែលខ្ញុំប្រគល់ឲ្យប្អូនស្រីខ្ញុំ ឲ្យបានខែដូចដែល" ។ លោកហ្វូងិតបានឆ្លើយមកវិញថា "អ្នកមិនបាច់យកប្រាក់ នោះទៅប្រគល់ឲ្យប្អូនស្រីអ្នកទេ ហើយអ្នកត្រូវខ្ជូលមាស ៣០.០០០ កហាបណៈ ថែមទៀត, គឺអ្នកឯងនេះហើយដែលជាអ្នកស្នេហាបិតាជាងគេ"។

៣.សេចក្តីជំនុំជំរះបែបមហារាជ សាឡ្ហមុង(១)

មានទាន់តញ្ញាម្នាក់បានបុះកិច្ចសន្យាថា រៀបរៀបមន្ត្រីលគារ ចំពោះមហាឧបាសកតាំនាក់ ។

ស្រាយដែលបានរួមសង្វាសនឹងគ្នា, នាងទៅជាមានគភ៌ ។ តែមហាឧបាសកតាំងតាំនាក់ មានចិត្តបំណងចង់បានទាន់ជាកូរយោ ។ នាងគិតថា "ខ្ញុំយកបុរសណាដែលផ្តើឲ្យខ្ញុំមានឥលរដ្ឋមួយ សម្រាប់អធិប្បាយសាឋសំយើង" ។

---

(១)- សាឡ្ហមុងជាមហាប្តីត្រៃ នៃពួកដង្ហតីស្រោអេលីត ព្រះពជិប្តត្រនឹងព្រះរាជ្ញាយោ នៃព្រះបាទដាវីដ ។ ត្រង់បានតាំងព្រះពជិប្តម៉ែយខ្លាចំខ្លួន ទៅខាងផ្នែកបាលនឹងការលំអនៃវត្តរបស់ព្រះអង្គ ។ ត្រង់បានសង់ព្រះវិហារសេរ៉ូយសាឡឹម; គតិបណ្តិតរបស់លោកបានផ្សាយសព្វទិសានុទិស ពេញមួយព្រះទេស (៩៣២ មុន គ.ស.)

មហាទុជាសកមួយថា ខ្ញុំនេះឯងធ្វើឲ្យនាងមានគតិ; មួយ
ទៀតក៏ថា ខ្ញុំនៅដែរ ។

នាងក៏ធ្វើយថា "ខ្ញុំនឹងសំគាល់ខ្លួនថាជាតែនៃបុត្រនេះ, កុងឋបណ្ដាអ្នកចាំង
ពីនោក់, អ្នកណាមួយ ដែលនឹងអាចអប់រំកូនេះឲ្យបានល្អទៅអនាគត ។
មិនបានប៉ុន្មានទៀ នាងនោះ ក៏សម្រាលបុត្រមួយ ។ មហាទជ-
សកចាំងពីនោក់ ដណ្ដើមកូនយកទៅចិញ្ចឹម ប៉ាច់ថែរក្សា ។ រឿង
នោះអ្នកណា ក៏មិនអាចសម្រេចបាន ត្រូវបញ្ជូនទៅដល់លោកហ្សាឌិត។
ក៏ហៅមហាទុជាសកចាំងពីនោក់មក, សួរទៅមហាទុជាសកទី ១ ថា
"តើអ្នកឯងឋបង្ហាត់បង្រៀនបុត្រនោះបែបណាខ្លះ"?

មហាទុជាសកទី ១ តបថា"ខ្ញុំនឹងឋបង្ហាត់បង្រៀន នូវវេទសិល្ប:
ចាំង៨ យ៉ាង វិចារណញ្ញាណនិយមវិជ្ជា (dialechique) ហៅថាសាស្ត្រ,
វិជ្ជា ដែលធ្វើឲ្យមនុស្សមានទម្លាប់ស្អែកដូចគាស័្ស (démonomanie)
រូបធាតុនឹងសភាពប្រែប្រួលដ៏វែងឆ្ងាយ, អរូបីនឹងរូបី, ធម្មធាតុនឹងវិជ្ជាដែល
ឃើញថា ព្រះអាទិទេពជាមូលដ្ឋាន ក្នុងឋចុំយកតំណែងវេងនរូប នឹងចិត្ត
(harmoné préétablie)....."។

មហាទុជាសកទី ២ ក្រាបទូលថា "ខ្ញុំនឹងធ្វើឲ្យបុត្រនោះប្រព្រឹត្តប្រតិបត្តិ
ដោយយុត្តិធម៌ព្រមទាំងណែនាំបុត្រនោះឲ្យមានកល្យាណមិត្រឲ្យច្រើន"។

រួចលោកហ្សាឌិតក៏សម្រេចសេចក្តីថា "បើខ្លួកជាអ្នកឯងជា ឪពុក
ឬ មិនមែនឪពុកនៃបុត្រនោះក៏ដោយ អ្នកឯងនេះហើយ នឹងត្រូវ
រៀបរៀបហមង្គលការ នឹងមាតាបុត្រនេះជាពិតប្រាកដ"។ (មានត)

អំពីរបៀបប្តូរតាក់

និង

មាន់ដង្កាក់

លោកទៀង-តែឈុន ប្រៃរៀបរៀង

សេចក្តីដំណាលថា កន្លងសម័យពីព្រេងនាយ មានជនពីរនាក់តឺប្តូនធឺ ប្រពន្ធ មានកូនប្រុសតែមួយនាក់ ។ ជនទាំងពីរនាក់នេះ ក្រីក្រលំបាកគាក ហើកជាភ្ញាំធឺ រកខួលទាន កន្លងមួយថ្ងៃ ។ បានគ្រាន់តែចិញ្ចឹមជីវិតពល់តែខ្នាំ ។

មានមួយល្ងាចនោះ, ជនកំសត់ទាំងលើនេះ ចូលទៅកន្លងដំណេក ហើយបានពិភាក្សាគ្នាដូចតទៅនេះ ៖

យើងមានតែពីរនាក់ទេ ដែលនឹងរកចិញ្ចឹមជីវិតខ្លួនយើង ដោយលំបាកវេទនា, កូនយើងទាំងពីរនាក់ គ្មានបានជួយកំឡាំងសោះ ព្រោះតែតស៊ូលេងប៉ុណ្ណោះ ។ យើងត្រូវបណ្តេញវាចេញពីផ្ទះទៅ ព្រោះយើងមិនអាចរកចិញ្ចឹមវាបានទៀតទេ ។

ដល់ព្រឹកស្អែក, ជនកំសត់នោះ ហៅកូនទាំងពីរនាក់មកជិត, កូននោះស្មានតែឪពុកម្តាយហៅឱ្យចំណី ក៏រត់មកប្រញាប់ប្រញាល់ ។

លុះកូនចូលមកជិតហើយ មាតាបិតាក៏និយាយថា "កូនសំឡាញ់អើយ! ឥឡូវ កូនធំហើយ ។ បេះដឹងត្រប់សព្វផង, ត្រូវកូនចេញពីផ្ទះ ដើម្បីទៅរកចិញ្ចឹមជីវិតខ្លួនឯងចុះ ព្រោះឪពុកម្តាយនឹងរកចិញ្ចឹម

ក្លួនឯងនៅទៀតមិនកើតទេ ប៉ុន្តែ ឪពុកម្តាយមានចិត្តអាណិតអាសូរឯង ទាំងពីរនាក់ណាស់, ហេតុនេះហើយបានជា ឪពុកម្តាយឲ្យប្រាក់ឯង មួយ ថាឌ (Pâd) " ។

កុមារទាំងពីរនាក់នោះ បានទទួលយកប្រាក់មួយថាឌ ពីឪពុកម្តាយ ហើយ ក៏ចាកចេញពីផ្ទះទៅ ។ លុះដើរទៅតាមផ្លូវបន្តិច ទើបកុមារប្អូន និយាយទៅបងថា "ឧបងអើយ ! ខ្ញុំឃ្លានថ្លើយណាស់" ។

បងធ្វើយតបទៅប្អូនវិញថា "ចាំដល់ស្ងាចសិនប្អូន កាលបើយើងដើរទៅប្រទះនឹងអ្នកស្រុក សឹមយើងសុំបាយគេស៊ី" ។

ប្អូនឮហើយនៅស្ងៀម, កុមារទាំងពីរនាក់នាំគ្នាដើរទៅមុខទៀត ។ លុះដើរបន្តិចទៅ, កុមារទាំងពីរនាក់បានឃើញផ្ទះមួយ ក៏ចូលទៅតឹងផ្ទះនោះហើយបន្ទន់ក្បាលជង្គង់ នៅចំពោះមុខអ្នកម្ចាស់ផ្ទះ ហើយពោលថា " សូមលោកមេត្តាអាណិត ឲ្យបាយយើងខ្ញុំទាំងពីរនាក់ ទទួលទានផង ! ប្រសិនលោកមានទៅសល់បាយកក បាយត្កាំនៃដែរឬ" ។

អ្នកម្ចាស់ផ្ទះ កាលបើបានឮកុមារទាំងពីរនេះសុំបាយបរិភោគដូច្នេះ ក៏មានចិត្តអាណិតខ្លាំងពេក ហើយសួរថា "នែកុមារសំឡាញ់! អ្នកមកពីណា? អ្នកមានឪពុកម្តាយដែរឬ?" ។ កុមារនោះធ្វើយតបទៅវិញថា "កាលដែលយើងខ្ញុំនៅផ្ទះ នាំតែគ្មានត់លេង ដោយហេតុបណ្តាលឲ្យមាតាបិតាខឹងខ្លាំង ហើយបណ្តេញឲ្យយើងខ្ញុំចេញពីផ្ទះថា ឯងទាំងពីរនាក់កេចញ្ចឹមជីវិតខ្លួនឯងចុះ អញគ្មានអ្វីចិញ្ចឹមឯងទាំងពីរនាក់ទៀតទេ រួចមាតាបិតាឲ្យប្រាក់មួយថាតមកយើងខ្ញុំ ដើម្បីឲ្យចេញចំណីអហារបរិភោគ "

ចន្លាប់ពីនោះមក, យើងខ្ញុំនាំគ្នាចេញពីផ្ទះដើរមក" ។ អ្នកម្ចាស់ផ្ទះ កាលបើបានឮកុមារនោះ និយាយដូច្នោះហើយ ក៏មានចិត្តអាណិតយ៉ាងខ្លាំងហើយឲ្យថ្លាយ, អំបិល, ទឹក ហើយគោត ។ លុះហើយគោតរួចស្រេចហើយ កុមារទាំងពីរនាក់ក៏សំដែងសេចក្តីអរគុណដល់អ្នកម្ចាស់ផ្ទះ ហើយលាចេញធ្វើដំណើរតទៅមុខទៀត កាលដើរដល់ភូមិនីមួយ ។ កុមារនោះ ចូលសុំថ្លាយគេហើយគោតជានិច្ច រួចបន្តដំណើរទៅមុខទៀត ។ ការចូលសុំថ្លាយហើយគោត គ្រប់តែភូមិនេះហើយ ទើបកុមារនោះ ទៅដួបប្រទះនឹងផ្ទះមួយដែលគេកំពុងពិការក្សាគ្នា អំពីរឿងការមានកូនក្រៃ ។ ឮហើយ កុមារនោះក៏ចូលទៅសួរថា "លោកតូចានលក់មាន់ ដែលលោកតូចានបង្ហាត់ សម្រាប់ធ្វើថ្នាក់ដែរឬ" ? ។ អ្នកទាំងអស់ ដែលនៅក្នុងផ្ទះ ឆ្លើយតបវិញថា "គ្មានមាន់លក់ទេ នាងឯងទៅទិញពីជនជាតិក្លា ដែលមើលទៅឃើញផ្ទះនៅត្រង់នោះ, ក្លានោះទើបមានមាន់បង្ហាត់ សម្រាប់ធ្វើថ្នាក់, ដូច្នេះចូរនាងឯងទៅផ្ទះក្លានោះចុះ" ។

កុមារទាំងពីរនាក់ កាលបើបានដំណឹងនេះហើយ ក៏ទៅផ្ទះក្លានោះ តាមគេបង្ហាញមក ។ លុះទៅដល់ផ្ទះក្លាហើយ ក៏និយាយថា "លោកឪពុក, យើងខ្ញុំបានដំណឹងថា លោកឪពុកមានមាន់លក់ជាច្រើនមែនឬ" ? ឮហើយ, ក្លានោះឆ្លើយវិញថា "ខ្ញុំមានដូច្នោះមែននាង, តែខ្ញុំលក់ថ្លៃណាស់, ខ្ញុំខ្លាចក្រែងនាងឯងមិនហ៊ានទិញ" ។ "លក់ថ្លៃប៉ុន្មានលោកឪពុក"? កុមារសួរទៅក្លា ។ ក្លាឆ្លើយវិញថា "មាន់មួយសម្រាប់

ធ្វើដំណាក់ លក់តាមធម្មតាថ្លៃមួយយប់ៗ, ប៉ុន្តែ មានខ្ញុំៗ លក់ថ្លៃមួយរៀល (១) ។

-ខ្ញុំ! ខ្ញុំមានតែមួយយប់ៗ ហើយថ្ងៃក្រោកនេះ ខ្ញុំត្រូវចុកចិញ្ចាំអាហារឲ្យ ឪពុកខ្ញុំបរិភោគផង ។

-បើឯងមានតែប្រាក់ប៉ុណ្ណោះទេ, ចូរឲ្យប្រាក់នោះមក ហើយឯងយកមានខ្ញុំទៅចុះ ហើយខ្ញុំឲ្យបាយស៊ុនឯងអង្គរចុកដណ្តាំថែមទៀត ។

-សូមលោកឥតពុកឲ្យមានខ្ញុំមើលសិន ។

ជ្លាទៅចាប់មានយកមកឲ្យកុមារតាំងពីរមើល ។ លុះឃើញមានហើយ កុមារតាំងពីរនោះ ក៏សួរថា "លោកឥតពុក ដែលឆ្លាប់យកមានេះទៅធ្វើដំណាក់ពាក់ហើយ ឬនៅ" ?

-អើនាង! មានេះឆ្លាប់ចុះស្មាមួបហើយ ។

-បើមានេះ ឆ្លាប់ធ្វើដំណាក់ដូច្នោះមែន, យើងខ្ញុំសុខចិត្តទិញហើយ សូមលោកឥតពុកឲ្យយើងខ្ញុំសំណាក់មួយយប់ផង ។

បន្ទាប់មក, កុមារតាំងពីរនាក់ ប្រគល់ប្រាក់ថ្លៃមាន់ ឲ្យទៅជ្លាចំនួនមួយយ៉ាត, រួចក៏ដេកទៅ ។

ព្រឹកឡើងពេលថ្ងៃរះ, ជ្លាដាំបាយឲ្យកុមារតាំងពីរបរិភោគ ហើយវេចបាយទំនិត្រមួយកញ្ចប់ ឲុកឲ្យកុមារនោះ ស៊ីតាមផ្លូវថែមទៀត ។ នៅទីបំផុត ជ្លាស្រាយមាន់ ប្រគល់ឲ្យទៅកុមារ។ ឯកុមារតាំងពីរនាក់ កាលបើបានទទួលយកមាន់ពីជ្លាហើយ ក៏លាចេញពីផ្ទះ ដើម្បីបន្តដំណើរទៅខាងមុខទៀត ។

---

(១) តំបាថ្លៃជាងមួយយ៉ាត: មួយយ៉ាតមានតម្លៃតែ១ ភាគ ៤ នៃប្រាក់រៀល ។

លុះទៅបានមួយស្របក់, កុមារគាំងពីរនាក់ចូលទៅក្នុងព្រៃ ហើយ
ចេញពីព្រៃតាត់ឥល ដើរតាត់ឥលចូលព្រៃ លុះត្រាតែអស់កម្លាំង កំឈប់
សម្រាកត្រោមម្លប់ឈើមួយដើម ដើម្បីបរិភោគជាយកញ្ចប់ ហើយក៏ដេក
ទៅក្បែរគល់ឈើនោះ ។

ក្នុងថ្ងៃនោះ អាសនាទៃព្រះឥន្ទ្រ កំរត្តំដួល, ព្រះឥន្ទ្រក៏ពិចារណា
ថា "មានហេតុអ្វី កំអាសនាអញក្តៅម្ទេះ"? ហើយបើកព្រះនេត្រប្រ-
មើលមើល ក្នុងមនុស្សលោក ក៏ឃើញកុមារពីរនាក់ ដែលអស់កម្លាំង
គោកហ៊ោកយ៉ាងខ្លាំង កំពុងដេកលក់ត្រោមដើមឈើ ឃើញដូច្នោះហើយ
ក៏ពិចារណាថា "ត្រូវអញជួយកុមារគាំងពីរនេះ! ព្រោះពាមានបុណ្យ
ណាស់"។ ពិចារណាដូច្នោះហើយ, ក៏ប្រញាប់ប្រញាល់ចុះមកក្នុងមនុស្ស
លោកយ៉ាងលឿន ដូចផ្កែកបន្ទោរ ហើយឃើញកុមារគាំងពីរនាក់ កំពុង
ដេកលក់ ត្រោមដើមឈើ ។ ព្រះឥន្ទ្រក៏និម្មិតអណ្តូងពីរ ជិតក្បែរនោះ, រួច
សរសេរអក្សរលើខឿនអណ្តូង ដូចតទៅនេះ៖

ទៅលើខឿនអណ្តូងទី ១, គេអានថា "បើឯងចុះទៅ ក្នុងអណ្តូង
នេះ; ខ្លួនឯង លិចរលាយបាត់ទៅ" ។

ទៅលើខឿនអណ្តូងទី ២ គេអានថា "បើអ្នកណាលិចរលាយខ្លួន
បាត់ទៅ ក្នុងអណ្តូងទី ១, ត្រូវយកទឹកតាក្នុងអណ្តូងនេះ ទៅបាក់ក្នុង
អណ្តូងទី ១, មនុស្សទាំងអស់ឡើងវិញភ្លាម" ។

លុះព្រះឥន្ទ្របានចារឹកលើខឿនអណ្តូងទាំងពីរ រួចស្រេចហើយ,

កំហោះត្រឡប់យ៉ាងលឿន ទៅតាមទិសនជ្ជានវិញ ។

លុះក្រោកពីដេកឡើង, កុមារនោះឃើញអណ្តូង ដែលព្រះអង្គទ្រង់ម្ចិត, ក្រោកឡើងដើរតម្រង់ទៅ ជុំវិញទីជង្គង់ឯកយកមកលាងខ្លួន, ស្រាប់តែឃើញប្រាសាទដ៏ធំពីរ ដែលនៅលើមាត់អណ្តូង ហើយបានឆ្លុះស្រមោលទើបកុមារបង្គន់យាយថា អញចង់ចុះមាន់យើង ទៅក្នុងអណ្តូងសាកមើល ។

កុមារប្អូនឆ្លើយវិញថា "បងឯងធ្វើតាមគិតឃើញទៅ, ចំណែកខ្ញុំគិតដូច្នោះដែរ" ។

បន្ទាប់ពីការពិភាក្សាគ្នាមក កុមារបង្គន់ចុះមាន់ទៅក្នុងអណ្តូងទី ១, មាន់នោះ កាលបើប៉ះទឹកហើយ ក៏លិចរលាយបាត់ទៅ ។ កុមារទាំងពីរនាក់លុះឃើញមាន់លិចរលាយបាត់ ទៅក្នុងអណ្តូងហើយ ក៏រត់ទៅជង្គង់ទឹក ក្នុងអណ្តូងទី ២ យកទៅចាក់ក្នុងអណ្តូងទី១, វិលានោះ មាន់រស់ឡើងវិញភ្លាម ។

កាលបើឃើញមាន់រស់ឡើងវិញ ហើយល្អជាងមុន, កុមារនោះពិភាក្សាគ្នា ដើម្បីចង់ដឹងអ្នកណា ត្រូវចុះទៅក្នុងអណ្តូងមុន ។ កុមារបង្គន់យាយថា "ត្រូវប្អូនឯងចុះទៅមុន សឹមបងចុះក្រោយ" ។

កុមារប្អូនឆ្លើយវិញថា"តាមធម្មតា មិនត្រូវប្អូនចុះមុនបងទេ,បងចុះមុនទៅ, ខ្ញុំនឹងចុះក្រោយ" ។ កុមារបង្គន់ឆ្លើយថា "បើប្អូនឯងចង់ឲ្យបងចុះ ត្រូវប្អូនឯងទៅជង្គង់ទឹកពីអណ្តូងមួយទៀត ឲ្យស្រែចមក ដើម្បីកុកស្រោចទៅលើបង ។ -"សូមបងលោតភ្លាមទៅកុំខ្លាច,ខ្ញុំនឹងស្រោចទឹកអណ្តូងទៅលើបង " ។

ដោយទុកចិត្តជាក់ច្បាស់លើប្អូនហើយ កុមារបង កំទម្លាក់ខ្លួនទៅ
ក្នុងអណ្តូងទី ១ ។ កាលចេញទាត់ទៅ ប៉ះទឹកហើយ, កុមារនោះ លិច
រលាយបាត់ទៅ ។

កាលណា កុមារប្អូនមើលទៅក្នុងអណ្តូង មិនឃើញបងទេ, ក៏រត់ទៅ
ជង្វិលទឹក ពីក្នុងអណ្តូងទី ២ ហើយចាក់ភ្លាម ទៅក្នុងអណ្តូង ដែលកុមារបង
លិចរលាយបាត់ ។ ស្រាប់តែឃើញកុមារបងឡើងពីក្នុងអណ្តូងមកវិញ ។
មិនតែប៉ុណ្ណោះ កុមារបងនេះ ប្រែក្លាយទៅជាមានរូបរាងអស្ចារ្យ គួរឲ្យពិត
ពិសរមិលមើល ។ ឃើញដូច្នោះហើយ កុមារប្អូនស្រែកថា "បងឯង
ចាំ ស្រាបទឹកលើខ្ញុំដូចម្តេចផង ! ខ្ញុំចុះទៅក្នុងអណ្តូងដែរ" ។

និយាយហើយ,កុមារប្អូនចុះទៅ ក្នុងអណ្តូងភ្លាម ឥតបង្អង់ចាំបានបន្តិច
ក៏លិចរលាយបាត់ទៅ ។ កុមារបងកាលបើឃើញប្អូនលិចរលាយទៅ ក្នុង
អណ្តូងនោះហើយ, គិតតែស្រែកគ្រហោយយំស្ទានថា ប្អូនខ្លួនស្លាប់ស្រេច ។
លុះយំបានមួយស្របក់ កុមារបងក្រាក់ស្មារតីឡើងវិញ ហើយនិយាយ
ក្នុងចិត្តថា ហេតុម្តេចបានជាអញយំ? ដ្បិតមានបណ្តាំមកថា ឲ្យយកទឹក
ពីអណ្តូងមួយទៀត មកជាក់ក្នុងអណ្តូងនេះ ទើបគួរដែលលិចរលាយបាត់
នោះរស់ឡើងវិញ ។ គិតឃើញហើយ ក៏រត់ទៅដង្វិលទឹកពីអណ្តូងមួយ
មកចាក់ក្នុងអណ្តូង ដែលប្អូនលិចរលាយបាត់ ។ លុះស្រាបទឹកហើយ
ស្រាប់តែ កុមារប្អូនងើបឡើងវិញភ្លាម ប្រកបដោយរូបល្អអស្ចារ្យ មាន
ពណ៌សម្បុរភ្លឺផ្លេក គួរឲ្យពិតពិសរមិលមើល ។ នៅទីបំផុត កុមារបង
និយាយថា " ប្អូនអើយ ! យើងមកទៅកន្លែងនេះ ល្មមសមគួរហើយ" ។

ក្មេងកំឡោះតាំងពីនាក់ក៏នាំគ្នា ធ្វើដំណើរទៅមុខទៀត ។

លុះធ្វើដំណើរបានច្រើនថ្ងៃហើយ, កុមារបងបានអាយុ២០ឆ្នាំ ។ កុមារប្អូនបានអាយុ ១៥ ឆ្នាំ ប៉ុន្តែ កុមារប្អូននេះ មានប្រាជ្ញាឈ្លាសច្រើនទីណាមានការប្រឹងប្រយ័ត្នជានិច្ចជាកាល ។

មានមួយថ្ងៃ កុមារតាំងពីនិយាយគ្នាថា "យើងគួរទៅរកមាន់ដើម្បីតបសោធមាន់យើងមើល" ។ គិតគ្នាហើយ ក៏នាំគ្នាដើរទៅរកកន្លែងមួយយ៉ាងស្ងាត់ឆ្ងាយពីផ្លូវអ្នកស្រុក ។ នៅទីនោះ កុមារតាំងពីរវៀបចំជាក់អន្ទាក់ ហើយបងមានទឹងស្មឹងមួយ ។ រួចនាំគ្នាទៅតួនចាំមើល ។ មាន់ទះស្លាបបីជង ហើយរោទ៍ផង ។

កាលបើពួកមាន់រោទ៍យ៉ាងពីរោះដូច្នោះហើយ, កូនស្រីរបស់ចៅហ្វាយខែត្រ ដែលនៅក្នុងផ្ទះ មានចិត្តក្រហល់ក្រហាយ អង្គុយនៅមួយកន្លែងមិនបាន ។ មាន់ទះស្លាប ហើយរោទ៍វិញទៀត ។ សំឡេងមាន់រោទ៍ម្តងនេះ បណ្តាលឲ្យនាងកញ្ញា នៅផ្ទះពុំបាននោះ ហើយក៏យកក្អមមួយ កណ្តៀតដើរតម្រង់ទៅត្រង់កន្លែង ដែលពួកមាន់រោទ៍វា ។ លុះដើរដល់ព្រៃតាំងមួយ, មាន់រោទ៍ម្តងទៀត ។ នាងកញ្ញាក៏ឈប់, ផ្ទៀងត្រចៀកស្តាប់, ហើយដើរសំដៅទៅរកមាន់, ទៅជាន់ត្រូវជាប់ក្នុងអន្ទាក់ ដែលកុមារតាំងពីរបានដាក់ ។

កុមារតាំងពីរចាប់នាងកញ្ញា ដែលមកជាប់អន្ទាក់ ហើយបងដៃតាំងពីនឹងវល្លិ៍ បណ្តើរទៅ កន្លងភូមិ, ពីផ្ទះមួយទៅផ្ទះមួយ ថែមតាំងស្រែកថា "អ្នកណាបងន់ខិញនាងកញ្ញានេះដែលមកជាប់អន្ទាក់យើង" ។

បុរសម្ចាស់ភ្លុដូច្នោះ ក៏ចេញពីគេហដ្ឋានមកមើល ហើយនឹកឆ្ងល់យ៉ាងខ្លាំងថា "យីអើ! កូនស្រីលោកចៅហ្វាយខែត្រ ទេឬ? ហេតុម្តេចបានជាក្មេងនេះ នាំយកមកលក់ដូច្នេះ? ត្រូវអញប្រាប់ក្មេងនេះ ឲ្យនាំទៅជូនលោកចៅហ្វាយខែត្រ ដើម្បីឲ្យដឹងរឿងឲ្យស្រាស់ល្អាស់" ។

ពិចារណាហើយ, បុរសនោះនិយាយទៅកុមារទាំងពីរវិញថា "ខ្ញុំមិនទិញទេ ប៉ុន្តែ នាងឯងនាំទៅលក់ ឯផ្ទះលោកចៅហ្វាយខែត្រទៅ ព្រោះលោក អ្នកមានទ្រព្យសម្បត្តិច្រើនណាស់" ។

កុមារបាននាំនាងកញ្ញា ទៅដល់ផ្ទះលោកចៅហ្វាយខែត្រ។ ក៏បានសួរមកកុមារថា "ហេតុម្តេចបានជា ឯងចាប់កូនស្រីអញចងដៃដូច្នេះ"? កុមារទាំងពីរឆ្លើយវិញថា "នាងកញ្ញានេះ ដោយឰមានខ្ញុំប្រចាទរឿងពីកេះ ក៏ដើរមកជាប់អន្ទាក់របស់ខ្ញុំប្រចាទតែម្តង ហេតុនេះហើយបានជាខ្ញុំប្រចាទចាប់ចងដៃទាំងពីរ នាំយកមកលក់" ។

លោកចៅហ្វាយខែត្រ សួរទៅកុមារទាំងពីរទៀតថា "ចុះនាងឯងចង់លក់ថ្លៃប៉ុន្មាន"? កុមារទាំងពីរឆ្លើយវិញថា "កាលណាខ្ញុំប្រចាទនៅមានជីវិត, ខ្ញុំប្រចាទលក់តម្លៃថ្ងៃ ១០០ ឬ ១២០ កាស, ប៉ុន្តែ ឥឡូវនេះ ខ្ញុំប្រចាទនៅបានមនុស្ស, ខ្ញុំប្រចាទត្រូវលក់យ៉ាងថោកតឹ ៣ រៀល" ។

លោកចៅហ្វាយខែត្រ បានប្រគល់ប្រាក់ ៣ រៀល ឲ្យទៅកុមារទាំងពីរ ហើយយកកូនស្រីលោកមកវិញ ។

លុះខ្លួលទ្រាក់រួចហើយ, កុមារតាំងពីរនាក់មានចិត្តរីករាយសប្បាយយ៉ាងក្រៃលែង ហើយសូមលាលោកចៅហ្វាយខែត្រ ដើម្បីទៅរកទិញចំណីអាហារបរិភោគ ។

កាលណោះ, មានពាណិជបុរសម្នាក់ ឮនូវដំណឹងរឿងនេះ ហើយរត់ទៅទូលព្រះករុណាជាម្ចាស់ដីវិតលើស្តួចថា "សូមទ្រង់មេត្តាទ្រាស មានកុមារពីរនាក់ មានមានទ្លាក់មួយ ពាក់ឮនកូនស្រីលោកចៅហ្វាយខែត្រ, លោកចៅហ្វាយខែត្រ ឮនយកទ្រាក់ ៣ ណែនទៅលោះ ទើបកុមារតាំងពីរ ព្រមប្រគល់កូនស្រីនោះ ឲ្យមកវិញ"។

ព្រះមហាក្សត្រទ្រង់ជ្រាបសេចក្តីនេះហើយ មានព្រះពាណីរាជឱង្ការបង្គាប់ឲ្យពាណិជបុរសនោះ ទៅនាំកុមារតាំងពីរ មកថ្វាយព្រះករុណា ។ ទ្រង់ត្រាស់សួរទៅកុមារតាំងពីរថា "កុមារឯងតាំងពីរនាក់ មានមានទ្លាក់មួយ ចេះពាក់ឮនមនុស្សលោក ពិតមែនឬ" ?

-សូមទ្រង់ព្រះមេត្តាទ្រាស ខ្ញុំព្រះបង្គំជាខ្ញុំ ពាក់ឮនពិតមែន។

-បើមានំកុមារឯង ចេះពាក់ឮនអគ្គមហេសីទី ១ របស់អញ ។ ប្រគល់ព្រះពាណិជាណាចក្រតាំងមូល ឲ្យឯងតាំងពីរនាក់ ។

-សូមទ្រង់មេត្តាទ្រាស សូមព្រះអង្គព្រះករុណាប្រទានសាក្សី ឲ្យខ្ញុំព្រះបង្គំជាខ្ញុំ ដើម្បីឲ្យជួយដឹងឮផង ។

បន្ទាប់មក កុមារតាំងពីរក្រាបបង្គំលាព្រះមហាក្សត្រ ។ កុមារបងបីមាន កុមារប្អូនកាន់អង្ករាក់ ដើរជ្រើសរើស រកកន្លែងជិតកំផ ហើយរៀបដាក់អង្ករាក់ នឹងចោះស្នឹងមួយ ដើម្បីបងមាន ។ លុះរៀបចំការ

នេះរួចស្រេចហើយ កុមារគាំងពីរ ទៅតួនចាំមើលលទ្ធផល ។

មាន់ទះស្លាបបីដង ហើយរងាវដង ស្រាប់តែកំដែងកំង បែកធ្លាយ ពាល់តែ អគ្គមហេសីយាងរត់ចេញពីកំង ហើយជាប់អន្ទាក់ ដែលកុមារ គាំងពីរបានដាក់ ។ កុមារគាំងពីរ បានជាប់អគ្គមហេសីចង ហើយនាំយក ទៅថ្វាយព្រះរាជា ។

នៅពេលនោះ, ព្រះមហាក្សត្រទ្រង់ទតឃើញច្បាស់ថា អគ្គម-ហេសីរបស់ព្រះអង្គ ពិតជ្រាកដហើយ ថែមទាំងព្រះអង្គទតឃើញកំដែង កំង របស់ព្រះអង្គបែកធ្លាយដូច្នោះ, ព្រះអង្គមានព្រះរាជហឫទ័យ ចង់បាន មាន់នោះ យ៉ាងក្រៃលែង ។ ព្រះអង្គប្រទានព្រះរាជអាណាចក្រ អគ្គម-ហេសី ទឹងតួកស្រីស្មុំគាំងអស់ ទៅកុមារបង ។ កុមារប្អូនបានទទួល ហានៈជាទុបភជ ។

ចំណែកព្រះមហាក្សត្រ ទ្រង់យាងចេញ ពីក្នុងព្រះបរមរាជកំង ហើយទ្រង់បីមាន់ទ្នាក់នោះ ទៅជាមួយផង ។ ព្រះអង្គហាងធ្វើដំណើរ តាមរបៀបអ្នកទាក់មាន់ព្រៃ ។ ការធ្វើដំណើរយ៉ាងយូរនេះ បណ្តាល ឲ្យព្រះអង្គឃាងកាត់ព្រលប្លូលព្រៃ ចេញពីក្នុងព្រៃកាត់ព្រល លុះត្រា តែព្រះអង្គអស់អាហារសោយ ។

បន្ទាប់ពីនោះមក ព្រះរាជា ទ្រង់ខ្សឹកព្រះកាយពល យ៉ាងក្រៃលែង ទ្រង់ឈប់រៀបចំដាក់អន្ទាក់ ចោះស្នឹងចង់មាន់, រួចទ្រង់យាងតួនចាំ មើលលទ្ធផល ។ ម្តងនេះ មាន់មិនរើរសោះ ក៏ចេះតែប៉ប៉ុកដំ ។ តពី នោះបន្តិចមក ស្តេចដំរើរមកជិតមាន់ ហើយយកភ្នុកទាំងពីរមកត្រួចមាន់

ពាលតែក្តុកនោះមុតកប់ចូលទៅក្នុងដី ១បមាដូចជាគេចង់កប់មាន់ទៅក្នុងដីៗ បន្ទាប់មក ស្តេចដំរីក៏ត្រឡប់ចូលរកខ្នែងនិញ ។

លុះខតរយើញដូច្នោះហើយ ព្រះរាជាដែលជាម្ចាស់មាន់ មានព្រះបន្ទូល ដោយសោកស្តាយឥតឧបមាថា "ឃើអាដំរីកំណាច ! វាហ៊ានមកត្រួចសម្លាប់មាន់អញ ដែលអញទិញថ្លៃដល់ទៅនតរមួយពាំនមូល ! រួចស្តេចយាងទៅកន្លែងជាក់អន្ទាក់ ឃានខតរយើញមាន់នោះ នៅរស់ត្រមាំងខតរយើញក្តុកពីរ ធ្លាក់នៅអមសង្កាងមាន់ផង ។ ព្រះមហាក្សត្រ មានព្រះហឫទ័យសប្បាយរីករាយ ហើយព្រះអង្គទ្រង់សារអន្ទាក់ ចំមាន់ ហើយអូសក្តុកដំរី យាងមកគងំក្រោមដើមល្វា ។

នៅទីនោះ, ព្រះអង្គទ្រង់ចោះស្នឹងចងមាន់ ហើយទ្រង់ជាក់ក្តុកពាំងពីរ តងលើគ្នា ។

បន្ទាប់មក ព្រះអង្គទ្រង់ផ្តុំ សណ្តូកព្រះកាយ លក់ស្តប់ស្តល់ ដោយទ្រង់អស់ព្រះកាយពលយ៉ាងខ្លាំង នឹងអត់ព្រះស្មោយ៧ថ្ងៃរួចមកផង ។

កាលណោះ មានស្រីទេពអប្សរពីរនាក់ ចេញពីក្នុងក្តុកមក យើញព្រះមហាក្សត្រ ផ្តុំស្តប់ស្តល់ដូច្នោះ ដោយអត់ព្រះស្មោយ ជាយូរណាស់មកហើយ កំតាក់តែងធ្វើព្រះស្មោយស្រេច រៀបចំខ្ទុកជាក់ជិតព្រះអង្គ ហើយចូលទៅពួនក្នុងក្តុកវិញ ។

(នៅមានត)

កាំណាត់ដឹងប្រវត្តិការណ៍

ដំណើរឧស្សាហការសមាវដ្ឋអាមេរិកា

នៃព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត-តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត ក្រុងក្នុងពេញ.

រៀបរៀងដោយ ជា-ទង់

សាស្ត្រាចារ្យទទួលការងារខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

(តមក)

ចានឮថា គ្រូស្រី-អ្នកគ្រូ ច្រើនមានឧស្សាហ៍ទន់ភ្លន់ ចេះថ្នាក់ថ្នមបង្គោស អង្អែលលួងលោមក្មេង ជាងគ្រូប្រុស-លោកគ្រូ ចានជាគេច្រើន ឲ្យគ្រូស្ត្រីបង្រៀនៅថ្នាក់តូច ។ ក្នុងពេលដែលក្មេងមានអាយុតិច ព្រោះហេតុដូច្នេះ ចានជាយើញគ្រូសុទ្ធតែជាគេស្ត្រី ។

បន្ទាប់ពីសាលាបឋមសិក្សាទៅ គឺសាលាមធ្យមសិក្សា ដែលហៅតាមភាសាគេថា High School ។ ស្ថានភាពហាយស្គូល ក៏ដូចជាស្ថានភាពសាលាបឋមសិក្សាដែរ គឺគេសង់អាគារធំតែមួយ ហើយចែកចេញទៅជាថ្នាក់រៀន ទីធំបន្តប់ សាលផ្សេង ។ ទៅទៀត ។ នៅហាយស្គូល មានរបៀបថ្នាក់ទីឆ្នាំសិក្សា បន្តបន្ទាប់ពីសាលាបឋមសិក្សាមក គឺថា កុមារ កុមារី កូនប្រុសស្រីអាមេរិកាន់ចាំងឡាយ កាលណាចានសិក្សា ក្នុងសាលាបឋមសិក្សាគ្រប់ ៦ ឆ្នាំហើយ អាចឡើងថ្នាក់ទៅរៀននៅថ្នាក់ខាងលើ ក្នុងហាយស្គូលចានដោយស្ម័យប្រវត្តិ មិនចាំបាច់

ប្រឡងឡើងថ្នាក់ខេ ឡើងតាមឆ្នាំសិក្សា តែគេប្រឡងល្បងរៀងពីឆ្នាំឆមាស ។ ក្នុងហាយស្គូលនោះ មានថ្នាក់រៀតដូច្នេះគឺ

ថ្នាក់ឆ្នាំទី ៧ Seventh grade តាមរបៀបបារាំងថា Classe de 6ème

ថ្នាក់ឆ្នាំទី ៨ Eighth grade " Classe de 5.

ថ្នាក់ឆ្នាំទី ៩ Nineth grade " Classe de 4-

ថ្នាក់ឆ្នាំទី ១០ Tenth grade " Classe de 3-

ថ្នាក់ឆ្នាំទី ១១ Tivelfth grade " Classe de 2-

ថ្នាក់ឆ្នាំទី ១២ Eleventh grade " Classe de 1er

គេចែកឆ្នាំសិក្សានៅហាយស្គូលជា ២ គឺ ៣ ឆ្នាំដំបូង ពីថ្នាក់ឆ្នាំទី ៧ ដល់ទី ៩ ហៅថា Junior High; ពីឆ្នាំទី ១០ ដល់ទី ១២ ហៅថា Senior High ។

នៅក្នុងហាយស្គូល, សម្ភារៈសំរាប់សិក្សា មិនថ្លៃពីសាលាជាន់ក្រោមប៉ុន្មានទេ តែឃើញមាន :

តាប្អូជួបគ្នា ពណ៌ជួបគ្នា ពីទ្ធជុំវិញថ្នាក់,
តុសិស្សមានទំហំប្រែនជាង,
តុគ្រូបង្រៀនជួបគ្នា,
គ្រឿងប្រដាប់គ្រប់យ៉ាងរីកធំទៅតាមទំហំសិស្ស ។
គ្រូស្រីគ្រូប្រុសលាយចម្រុះគ្នា ។

រួមធ្មាំសិក្សាក្នុងសាលាបឋមសិក្សា ហៅថា Elmentary School ឬ Primary School និងក្នុងសាលាមធ្យមសិក្សា ហៅថា Secondary School ឬ High School គាំងពីរនេះ ចំនួន១២ ឆ្នាំ ក្នុងកំឡុងនេះ កូនប្រុសបានឡើង ជាកូនកម្លោះ, កូនស្រីបានឡើង ជាកូនក្រមុំ ទើបនិយាយតាមអាយុវិញ មានអាយុ១៨ឆ្នាំ មួយខ្នងៗហើយ ។ ប៉ុន្តែ បានដឹងថា ចំណេះវិជ្ជាដែលកូនគេបានរៀន ក្នុងវ័យ:ស្មើ ១២ ឆ្នាំ កន្លងទៅហើយ នោះមិនទាន់គ្រប់គ្រាន់នឹងប្រើការកើតនៅឡើយទេ ត្រូវតែរៀនតទៅទៀត ។ ត្រូវរៀននៅវិទ្យាល័យ ហៅតាមសំដីអង់គ្លេសថា College និងមហាវិទ្យាល័យហៅថា University ។

វិជ្ជាស្ថានសិក្សា ដែលមានអាគារធំៗ ជាច្រើន ហើយចែកផ្នែកវិជ្ជាដោយឡែកៗ ហៅថា College វិទ្យាល័យ, ឯវិជ្ជាស្ថាន ដែលធំហើយមានមុខវិជ្ជា ដែលបង្រៀនច្រើនផ្នែកជាងវិទ្យាល័យ, ជួនកាលមាន College ច្រើនរួមគ្នា ហៅថា University មហាវិទ្យាល័យ ឬហៅតាមភាសាបុរាណថា " សាលាឧត្តមាចារ្យ " ព្រោះ University ជាទីប្រជុំពុះនៃចំណេះវិជ្ជាជាន់ខ្ពស់បេ ដូចជាសាលាឧត្តមាចារ្យដែរ ។ នៅក្នុងមហាវិទ្យាល័យនីមួយៗ មានអាគារធំៗខ្ពស់ៗ ជាច្រើន, មហាវិទ្យាល័យខ្លះ មានអាគារដល់ទៅមួយរយ, ខ្លះមាន ៧០, ខ្លះ ៥០ ដែលគេចែកជាថ្នាក់រៀន តាមមុខវិជ្ជា, បណ្ណាល័យ ដាក់សម្រាប់សិក្សាស្រាវជ្រាវសម្រាប់និស្សិត, សាមគ្គីរ, មន្ទីរពេទ្យ, ទីពិសោធន៍ ការិយាល័យទីចាត់

ការមហាវិទ្យាល័យ ,ការិយាល័យ សាស្ត្រាចារ្យ, ប្រៃសន៍យដ្ឋាន, ភោជ-
នាគារ , ទីលានកីឡា, បណ្ណាគារ, ធនាគារ, អគារសំពាប់សន្និសីទ, គេ-
ហដ្ឋានសំណាក់អាស្រ័យ នៃនិស្សិតស្រី-ប្រុស ។ អគារជាច្រើនទាំងអស់
នោះ ប្រតិស្ថានទៅជុំគ្នាក៏មាន នៅឆ្ងាយដាច់ពីគ្នាក៏មាន លាតសន្ធឹង
យ៉ាងវែង ក្នុងមហាវិទ្យាល័យ គេហៅថា University Campus ។
មានមហាវិទ្យាល័យខ្លះទៀត មានហាងលក់ផ្លែ, មានហូតែល, មាន
ភោជនីយដ្ឋាន Restaurant មានទុសថស្ថាន មានហាងលក់ទោអាវ
សំលៀកបំពាក់ គ្រឿងម្ហូបអាហារគ្រឺសាច់ បន្លែឆ្អិនគ្រប់មុខ មាន
ពេងពុម្ពសំពាប់ចោះទស្សនាវដ្តី ការសែតនិងសៀវភៅសិក្សា ដូចជាមី
ក្រុងមួយយ៉ាងសមគួរ ។ ឯមហាវិទ្យាល័យទាំងឡាយ ដែលព្រះគេជ-
ព្រះគុណបានហ្នឹង ទើងខ្ញុំ បានឃើញជាមួយគ្នា មិនមែនសុទ្ធតែវិទ្យា-
ល័យធំ ។ សំបើម ។ ទាំងអស់ទេ មានខ្លះតូច ខ្លះធំ មានសិស្ស
ច្រើនក៏មាន តិចក៏មាន ។ មហាវិទ្យាល័យដែលតូច មានសិស្សយ៉ាង
តិចត្រឹមតែរាប់នាក់ខ្លះ ប្រាំពាន់នាក់ខ្លះ ឯមហាវិទ្យាល័យដែលធំៗ
ដូចជា Yale University, Harverd University, Columbia Univer-
sity, Universitz of Southem California មាននិស្សិតពី ១០ ពាន់
នាក់ ទៅ ២០ ពាន់នាក់ ។ មហាវិទ្យាល័យ ជាទីបញ្ចប់ចំណេះវិជ្ជា
ថ្នាក់ក្រោយបំផុត នៃសិក្ខាកាមកុលបុត្រ កុលធីតាទាំងឡាយ ។

នៅសហរដ្ឋអាមេរិក, សាលាបឋមសិក្សាក្តី សាលាមធ្យមសិក្សា
ក្តី សាលាឧត្តមសិក្សាក្តី ឬមហាវិទ្យាល័យក្តី ទាំងអស់ មិនសុទ្ធតែ

ជារបស់ពដការរដ្ឋ ឬពដការសហារដ្ឋទេ, ជារបស់ឯកជន Private ដោយ
ច្រើន ចាន់ដឹងថា ពដការរដ្ឋនីមួយក្នុងសហារដ្ឋ បានជួយចំនុកបំរុងខាង
ការសិក្សា ដោយសង់សាលាបឋមសិក្សា មធ្យមសិក្សា និងវិទ្យាល័យ
ជាច្រើនណាស់ដែរ តែនៅតែមិនល្មមគ្រាន់ដល់ចំនួនប្រជាជន ។ ដូច្នេះ
ដោយអធិបតេយ្យ, សិទ្ធិនឹងសេរីភាព ព្រមទាំងចំណេះវិជ្ជា ការចេះដឹង
របស់ខ្លួនដែលមានគ្រប់គ្រាន់ ហើយដើម្បីឲ្យការសិក្សាបានចំរើនច្រើន
ឡើង ដល់សិក្ខាកាមជាន់ក្រោយរបស់ខ្លួន, នៅក្នុងតំបន់ភូមិភូប ។ ដែល
ឆ្ងាយពីទីក្រុង អ្នកស្រុកជាឪពុកម្តាយកូនក្មេងទាំងឡាយ បានរួបរួមគ្នា
ជាសមាគម កសាងសាលារៀន ពុកជាប្រយោជន៍ដល់កូនចៅរបស់ខ្លួន ។

សាលាបែបនេះ ហៅថា សាលាឯកជន កើតឡើង ដោយប្រ-
ជាជន រួបរួមកំលាំងគ្នាបង្កើតឡើង មិនមានទាក់ទងនឹងពដការទេ ឯ
ពដការរដ្ឋ ក៏មិនបានឧបត្ថម្ភអ្វី សូម្បីបន្តិចបន្តួច ដល់សាលានោះដែរ ។
បានហ្នឹងសាលា នឹងអ្នកធ្វើការគ្រប់គ្រងសាលាទាំងប៉ុន្មាន គ្រូបង្រៀន
ទាំងអស់ សុទ្ធតែជារបស់សមាគម ថ្លៃឈ្នួលគ្រប់យ៉ាង សមាគមបេញ
ទាំងអស់ ។ សាលាសិក្សាទាំងឡាយ តាំងពីថ្នាក់ទាប ដល់ថ្នាក់ខ្ពស់
ច្រើនតែជារបស់ឯកជន គឺជារបស់សមាគមរបស់, church ធីង ។ ដូច្នេះ
សាលាឯកជន គឺមិនមែនជាសាលារបស់ពដការទេ ជារបស់ប្រជាជន
ដែលរួមគ្នា ជាសមាគម ។ សិស្សអ្នករៀនក្នុងសាលាឯកជន ត្រូវបេញ
ថ្លៃឈ្នួលសាលាទាំងអស់ ។ សាលាបឋមសិក្សានិងមធ្យមសិក្សា ច្រើន
តែជារបស់ពដការរដ្ឋ មិនសូវមានសាលាឈ្នួលទេ ឯមហាវិទ្យាល័យ

ឬ University ច្រើនតែរបស់ឯកជន មិនសូវមានរបស់ពាជការរដ្ឋទេ ។ ជាន់ក្នុងថា សូម្បី University របស់ពាជការរដ្ឋក៏ដោយ ទិសន្តិតប្រុសស្រីត្រូវតែចេញថ្លៃឈ្នួលដែរ គ្រាន់តែតិចជាង University ឯកជនប៉ុណ្ណោះ ថ្លៃឈ្នួលសាលា ទំនងថ្លៃឈ្នួលធ្លុះសំណាក់ ក្នុង ១ ឆ្នាំប្រហែល ២០០០ ដុល្លារ យ៉ាងច្រើនបំផុត ។ តម្លៃនេះ មិនមែនដូចគ្នា គ្រប់ទាំងអស់ទេ មានថោក មានថ្លៃ ដោយមហាវិទ្យាល័យផង ។ ។ ឯមហាវិទ្យាល័យទាំងឡាយ ដែលព្រះតេជព្រះគុណព្រះពោធិវង្ស ទំនងទ្រង់បានទៅទស្សនាសុទ្ធតែ ជារបស់ឯកជនទាំងអស់ រៀវលែងតែមហាវិទ្យាល័យខេមច៍មួយ ក្នុងរដ្ឋអូហៃយ៉ូ ។

អំពីការបង្ហាត់បង្រៀន, គ្រូបង្រៀន ទំងសាស្ត្រាចារ្យ.-

តាមដំណើរការណ៍ដែលបានសង្កេតឃើញ, របៀបបង្ហាត់បង្រៀនសិស្ស ឬ ទិសន្តិត ក្នុងសាលាទីមួយ ។ មានរបៀបផ្សេងគ្នាដូច្នេះ គេថាក់ទាប ។ ដែលមានកូនក្មេងតូច ។ ជាសិស្ស ដូចជា Nursery School Kindergarten First grade អ្នកគ្រូប្រចាំថ្នាក់ ទំនងនាងគ្រូដែលគេអប់រំ សុទ្ធសឹងតែជាអ្នកចេះថ្នាក់ថ្នម បបោសអង្អែល លួងលោមប្រលាមក្មេង ដោយពាក្យសំដី ទំនងដោយដៃជើង ឲ្យស្រឡាញ់សាលារៀន ស្រឡាញ់ការសិក្សា ។ ក្នុងថ្នាក់រៀន យើងសង្កេតឃើញមានច្រើនតែគ្រឿងលេងសំរាប់ក្មេង ។ មានតែសៀវភៅបន្តិចបន្តួច គ្រឿងជំរាបតំ ទំចំណី, ទឹកដោះគោ សំរាប់លួងក្មេង ។ ក្រៅពីនេះ យើញមាន់ទន្លូកតូច ។ កូនក្ងួយ កូនទ្វើយសំរាប់ក្មេងដេក ។ (មានត)

សន្និសីទនៃបណ្ដិតវិស្សាទ័អេក្លាត

ធ្វើនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ

លោក ភ័ឃ-ប៊ុត រៀមរៀង

កាលពីថ្ងៃសៅរ៍ ទី២១ខែកញ្ញា ១៩៥៧ ពេលម៉ោង ១៦ មានធ្វើសន្និសីទនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត (ក្រសួងធម្មការ) អំពីការសិក្សាព្រះពុទ្ធសាសនា ។

ពិតមែនតែមហាមេឃចុះអព្ជ័ បង្អោរខ្យល់ភ្លៀងធំ, អ្នកដែលអញ្ជើញមកសវនាខ្យល់សន្និសីទនេះ មានច្រើនកុះករ ទាំងបព្វជិតទាំងគ្រហស្ថជាង ១០០០នាក់ ។ បណ្ដាឥស្សរៈជនខាងបព្វជិត គេបានក្រឡេកឃើញសម្ដេចព្រះមហាសុមេធាធិបតី ជួន-ណាត ជោតញ្ញាណោ សង្ឃនាយកគណៈមហានិកាយ, ព្រះថេរានុត្តរមហាបណ្ឌិត អ៊ុន-សុវង្ស ជាតំណាងខាងសម្ដេចព្រះសង្ឃនាយក គណៈធម្មយុត្តិ, ព្រះគោដ៏វង្ស ហួត-តាត ចាងហ្វាងពុទ្ធិកវិទ្យាល័យ ព្រះសុរាម្រិត, ភជាគណៈហានុក្រម កិត្តិសាមណេរបិតនៅខាងឆ្វេង ។

ចំណែកឥស្សរៈជន ខាងគ្រហស្ថ មានពីរផ្នែក:

ផ្នែកទី១, ឥស្សរៈជនខាងខ្មែរ មានលោកស៊ុម-ភ័ នាយករដ្ឋមន្ត្រី, ប្រធានក្រុមប្រឹក្សាព្រះរាជអាណាចក្រ, លោកប៉ាល់-ជួន រដ្ឋមន្ត្រីក្រសួងមហាផ្ទៃទទឹងធម្មការ, លោក មាស-យ៉ង់ អនុរដ្ឋលេខាធិការក្រសួងធម្មការ, បុគ្គលិកក្រសួងធម្មការ ក្រុមពុទ្ធសាសនបណ្ឌិត្យ, បុគ្គលិកក្រសួងឯទៀតៗបិតនៅខាងជើង ។

ផ្នែកទី២, ឥស្សរៈជនជាតិអាមេរិក មានលោកស្រួមឯកអគ្គរាជទូតប្រចាំប្រទេសអាមេរិក ប្រចាំប្រទេសកម្ពុជា, លោកវូសីម៉ាន, នាយកក្រុមដំនួយសេដ្ឋកិច្ច អាមេរិក, លោកអូស្ការ៉ាសែរ នាយកមន្ទីរយោសនាការ អាមេរិក លោកអូវែរតុន ប្រធានមូលនិធិអាស៊ី ទីដ៏ឫកុគ្គលិកក្រុមស្ថានទូតអាមេរិក ។

ក្រោយដែលកៀវ ទាំងបញ្ជាជិតទីធ្លាគ្រហស្ថ ខ្មែរក្នុងទីដ៏អញ្ជើញជួបជុំ, ទើបលោកមាស-យ៉ង់អនុរដ្ឋលេខាធិការ ក្រសួងធម្មការ ចាន់ឡើងលើវេទិកា បង្ហាញនូវរូបលោតរីស្យាទ័ អេក្លាត ជាអ្នកវាគ្មិន អាមេរិកាំងយ៉ាងចំណាន រៀបរាប់អំពីជីវប្រវត្តិរបស់លោក ដោយសង្ខេប ។

លំដាប់តមក, លោករីស្យាទ័ អេក្លាត ថ្លែងនូវសុន្ទរកថាជាភាសាអង់គ្លេស លោកជា-ខន់សាស្ត្រាចារ្យពុទ្ធិកវិទ្យាល័យព្រះសុកម្រឹត ជាអ្នកប្រែជាភាសាខ្មែរ ដូចតទៅនេះ៖

សូមនមស្ការសម្តេចព្រះសង្ឃនាយក ទាំងពីរតណៈ សូមនមស្ការព្រះថេរានុត្តេរៈទាំងឡាយ សូមជំរាបឯកឧត្តម លោកអ្នកទាំងឡាយ ខ្ញុំខ្ញុំបានមកកាន់ប្រទេសកម្ពុជា ចានមកកាប់ប្រសព្វនឹងបញ្ជាជិតគ្រហស្ថ ជាអ្នកកាន់ព្រះពុទ្ធសាសនា, ពុកជាខ្ញុំមានតិចសំណាងពន់ពេក ។ ពេលនេះខ្ញុំព្រះករុណា ខ្ញុំបាទនឹងជំរាបអំពីការសិក្សាព្រះពុទ្ធសាសនា:

១- សារៈសំខាន់នៃការសិក្សាព្រះពុទ្ធសាសនាពេលបច្ចុប្បន្ននេះ

ពុទ្ធសាសនិកជនចានពុកព្រះពុទ្ធសាសនា ជាផ្លូវដ៏វិតដ៏វិបូណ៌ សម្រាប់

សព្វសត្វទំនឹងសង្គមជាំនឹងឡាយ ព្រោះព្រះពុទ្ធសាសនាជាប់ផ្តើមបង្រៀន បញ្ហាដែលជាមូលដ្ឋាន នៃជីវិតដែលមិនខៀងខាត់ ឲ្យពិចារណាការប្រែប្រួលនៃធម្មជាតិទំនឹងហេតុប្បច្ច័យនៃជីវិតអប់រំបញ្ញាដ៏ខ្ពង់ខ្ពស់របស់មនុស្ស ឲ្យដល់សន្តិវរបទ គឺព្រះនិព្វាន ដោយការចំរើនមេត្តាភាវនា ព្រោះអាស្រ័យសទ្ធាទំនឹងការប្រតិបត្តិបែបនោះ ព្រះពុទ្ធសាសនាទើបជាកំឡាំងមួយដែលជួយជំរុញទំនឹងទ្រទ្រង់វប្បធម៌ឲ្យបិតថេរ សម្រាប់ជនជាតិអាស៊ីក្នុងអតីតកាល ។

ពេលបច្ចុប្បន្ននេះ អ្នកកាន់ព្រះពុទ្ធសាសនាជាច្រើន កំពុងចំរៀនឲ្យបានយល់ខ្លួនគំរូដ៏ថ្មី ។ ជាលោកិយ ជារបស់អ្នកក្រុង ទំនឹងស្របតាមវិទ្យាសាស្ត្រនៃជីវិតទំនើប ដែលជាហេតុធ្វើឲ្យបុគ្គលម្នាក់ ។ ទំនឹងសង្គមមានសេចក្តីត្រូវការពោក្យប្រៀនប្រដៅ ខាងផ្លូវព្រះពុទ្ធសាសនា ជាគ្រឿងនាំផ្លូវ ។ ដើម្បីបំពេញមុខងារនេះ ព្រះសង្ឃទំនឹងឧបាសកដែលជាអ្នកដឹកនាំត្រូវសិក្សាធម៌តាមប្រពៃណី តែធម៌ក្នុងបច្ចុប្បន្ននេះ ត្រូវប្រកបដោយចំណេះដឹង ទំនឹងការពិសោធន៍គាន់សម័យ សម្រាប់ពុទ្ធសាសនិកជនដែលប្រៀបដូចជាមនុស្សគ្រាស់ដឹងខ្លួនធម៌ ក្នុងពិភពលោក ដែលប្រែប្រួលជានិច្ច ។ នេះហើយជាសារៈសំខាន់ពិសេស នៃការសិក្សាព្រះពុទ្ធសាសនាសម្រាប់បរិនាយកភាព នៃពុទ្ធសាសនិកជន ក្នុងសង្គមសម័យបច្ចុប្បន្ននេះ ទំនឹងជាខសន្ធនៈថ្មី នៃមុខងារក្នុងអនាគតកាល របស់ព្រះពុទ្ធសាសនាក្នុងអាស៊ី ទំនឹងក្នុងពិភពលោកជាំនស្រុង ។

ក្នុងការពិចារណាគោលបំណង ដែលជាមូលដ្ឋាន រឿងរ៉ាវទំនឹងវិធីសិក្សា

ខាងព្រះពុទ្ធសាសនា ដូចមានតទៅនេះ ៖

យើងនឹងសង្កេតឃើញថា ការរៀនតាមប្រពៃណីចាត់ថា ជាការសិក្សារយៈកាលសម័យបាន នឹងអាចកាប់បញ្ចូលក្នុងការសិក្សាហៅថាការសិក្សាបែបចំនើបក៏បានដែរ ព្រោះថាការសិក្សាសម័យបច្ចុប្បន្ន ក៏មានជាច្រើនតំណាតមកពីការសិក្សាក្នុងអតីតកាល ។ ហេតុនោះ ទត្តមគតិនៃធម៌ខាងផ្លូវព្រះពុទ្ធសាសនា រក្សាខុសបាន ដោយអាស្រ័យការសិក្សាជាតំណាតៗគ្នារៀងមក ។

២-គោលបំណង ជាមូលដ្ឋាននៃការសិក្សាព្រះពុទ្ធសាសនា

គោលបំណងដើម នៃការសិក្សាព្រះពុទ្ធសាសនា ក៏ដូចជាគោលបំណងចុងបង្អស់នៃធម៌ដែរ គឺជួយឲ្យមនុស្សត្រាស់ដឹង នូវធម៌នឹងឲ្យដល់នូវព្រះនិព្វាន ។ នេះគឺគោលបំណងនៃការសិក្សា ដែលពាក់ព័ន្ធនឹងបុគ្គល ព្រះសង្ឃទំនងសង្គមនូវទៅតាំងអស់ ។ ការសិក្សាឯទៀតៗ ត្រង់ឃ្លាំង ជួយឲ្យបានចំរើន ខាងផ្លូវបញ្ញានឹងអប់រំបុគ្គលិកលក្ខណៈឲ្យបានសមរម្យ យ៉ាំងណាមិញ ព្រះពុទ្ធសាសនា ក៏យ៉ាំងនោះដែរ គឺជួយមនុស្សត្រង់ប្រឹង ឲ្យឆាប់ដល់នូវសេរីភាព ដ៏ប្រសើរនៃជីវិត ។

គោលបំណងដើម នៃការសិក្សាព្រះពុទ្ធសាសនានេះ អាចពិនិត្យដោយគន្លងប្រពៃណី នឹងគន្លងសមតាមកាលសម័យ តាំង ២ យ៉ាំង ព្រោះសុទ្ធតែជាហេតុ នៃគំនិតការរៀនព្រះពុទ្ធសាសនា ។

គោលបំណងទីពីរ នៃការសិក្សាព្រះពុទ្ធសាសនា គឺការចេះ ការអធិប្បាយ នឹងការប្រៀបធៀបធម៌ ។ ការចេះធម៌ មានអត្ថន័យថា ការ

សិក្ខាធម៌ ដោយអាស្រ័យការបង្រៀន ទើបការណែនាំពីគ្រូចារ្យ អ្នក
មានគុណវុឌ្ឍិ, ការអធិប្បាយធម៌ មានអត្ថន័យថា ការបែកចែកលែកធម៌នោះ
ដល់អ្នកដទៃ ឬមួយហូតដល់ការបង្រៀនដោយវិធីរៀន ក្នុងការសិក្សា
ព្រះពុទ្ធសាសនា របស់បុគ្គលម្នាក់ៗផង ។ ការប្រៀបធៀបធម៌ជាន
សេចក្តីថា ការប្រៀបធៀប ជាបុគ្គលធំជាន្ត ហើយនឹងនាំយកការចេះដឹង
ធម៌នោះមកប្រតិបត្តិក្នុងខ្លួន ក្នុងការគាក់ទងនឹងអ្នកដទៃ ។ និយាយដោយ
សង្ខេប គោលបំណងទីពីរ នៃការសិក្សាព្រះពុទ្ធសាសនានេះ គឺត្រូវ
សិក្សាតាមបែបប្រពៃណី ទើបបែបទំនើបគាំងពីរយ៉ាង ព្រោះការសិក្សានេះ
គាបសម្រួចជាន់ពេញលេញ ដោយការពិសោធន៍ ដែលជាន់សន្សំទុក ។

គោលបំណងទីបីនៃការសិក្សាព្រះពុទ្ធសាសនាគឺ ការរក្សាទុកនឹងការ
យិតយោងព្រះសង្ឃ ព្រោះព្រះសង្ឃ ជាអ្នកទទួលមតិក ទើងជាគ្រូបង្រៀន
ធម៌ ។ ព្រះសង្ឃអាចរក្សាឲ្យជាន់តង់ទៅនឹងជាទីគោរព គ្មានអ្នកណា
ហ៊ានប៉ះពាល់ជាន់ ព្រោះអាស្រ័យការសិក្សាព្រះពុទ្ធសាសនា ។ ដើម្បី
ឲ្យព្រះសង្ឃជាន់ប្រជុំពេញទី ប្រជុំរឿយ ។ នឹងប្រតិបត្តិសង្ឃកិច្ច ដោយ
សេចក្តីសាមគ្គីគឺការព្រមព្រៀង ព្រះសង្ឃត្រូវតែឲ្យមានការសិក្សាដោយ
ត្រឹមត្រូវតាមវិន័យ ។ បើនាយកភាពនៃព្រះសង្ឃ ពេលបច្ចុប្បន្ននេះ
ក៏ដូចជាក្នុងអតីតកាលដែរ គឺត្រូវតែអប់រំឲ្យមានគុណវុឌ្ឍិដោយការសិក្សា
ព្រះពុទ្ធសាសនា បើគ្មានសិក្សាការសិក្សាហើយ ព្រះសង្ឃក៏មិនអាច
តាំងនៅជាន់តទៅទៀតឡើយ ។ មួយវិញទៀត បើនាយកភាពនៃឧបាសក
ក្នុងព្រះពុទ្ធសាសនា ក៏ដូចគ្នាដែរ គឺត្រូវតែចេះដឹងដោយប្រពៃ ដើម្បីជួយ

ទ្រទ្រង់ព្រះសង្ឃ ហើយអាចនាំយកធម៌មកប្រតិបត្តិ ដោះស្រាយបញ្ហាជីវិតសង្គមបាន ។

គោលបំណងទីបីនៃការសិក្សាព្រះពុទ្ធសាសនា គឺសិក្សាតាមបែបប្រពៃណីនិងបែបទំនើប ព្រោះជាគ្រឿងជាប់ទាក់ទង ដោយមុខងារក្នុងអតីតបច្ចុប្បន្ននិងអនាគតរបស់ព្រះសង្ឃនិងជាគ្រឿងចងក្លាប់ព្រះសង្ឃនិងគ្រហស្ថ ក្នុងគោលបំណងរួមគ្នា ។

គោលបំណងទីបួននៃការសិក្សាព្រះពុទ្ធសាសនា បានសំដែងឲ្យឃើញនូវភាពលាក់កាំបាំងនៃគោលបំណងជំពូកបង្អស់ គោលបំណងធម៌ទីនព្រះសង្ឃគឺជួយសង្គមទាំងអស់ឲ្យបាន ចំពោះលក្ខណៈសៅហាន់សេរីភាព ដំពេញទីដោយបញ្ហាដ៏ខ្ពង់ខ្ពស់ នឹងដោយអប្បមញ្ញាធម៌ ។ គោលបំណងនេះបានបង្ហាញឲ្យឃើញជាក់ ក្នុងសិល្បៈទីនវប្បធម៌ នៃព្រះពុទ្ធសាសនាតាមប្រពៃណី ហើយបង្ហាញឲ្យឃើញជាក់ នូវកិច្ចការនៃសន្តិសុខ របស់សង្គម ការសិក្សារបស់មហាជន ការណែនាំខាងសីលធម៌ នឹងការជាស់តឿនឲ្យកើតបញ្ញាជាកំពូលមួយ ដែលជួយដំរុញ នឹងទ្រទ្រង់វប្បធម៌ឲ្យបានថេរ សម្រាប់ជនជាតិអាស៊ីជាច្រើន ក្នុងអតីតកាល ។

ការពិនិត្យមើលគោលបំណងសង្គម ក្នុងការសិក្សាព្រះពុទ្ធសាសនាពេលបច្ចុប្បន្ននេះ អាចជួយធ្វើជាគំរូនៃមុខងារ តាមកាលសម័យ នៃព្រះពុទ្ធសាសនា ក្នុងពិភពលោក ។

(មានត)

ជីវប្រវត្តិសង្ខេបនៃឯកឧត្តម រាជក្រិស្ណាន
អនុប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌៀ

លោក ភ័យ.ប៊ុត រៀបរៀង

ប្រវត្តិសាស្ត្រ កម្រនឹងមានកន្លែងពួកទស្សនវិទូ នៃនានាប្រទេស ដែលបានបំពេញមុខការសំខាន់ខាងរដ្ឋកិច្ចល្អ ត្រូវតាំងខួលការៈយ៉ាងធ្ងន់សម្លឹងអស្ចារ្យថែមទៀត ក្នុងករណីពិសេសនេះ, មានតែឯកឧត្តម ស. រាជក្រិស្ណានេះទេ ដែលគេតាបបញ្ចូលនាម ទៅក្នុងក្រុមដែបនេះបាន ។ ឯកឧត្តម មិនត្រាន់តែខួលហានៈ ជាអនុប្រធានាធិបតីនៃសាធារណរដ្ឋ ដែលមានប្រជាពលរដ្ឋ ៣៦០ លាននាក់នោះទេ ថែមទាំងគេចុកឯកឧត្តមជាចិន្តបណ្ឌិតមួយរូប ចំពោះពិភពលោកទាំងមូល ។

ឯកឧត្តមសេរ៉ែបល្លី.រាជក្រិស្ណាន ប្រសូតនៅថ្ងៃទី ៥ កញ្ញា គ.ស. ១៨៨៨, នៅភូមិភាគខាងត្បូង នៃប្រទេសឥណ្ឌៀ ។ ឯកឧត្តម បានជាប់សញ្ញាប័ត្រ នៃមហាវិទ្យាល័យតាំងពីអាយុ ១៨ ឆ្នាំ ។

ឯកឧត្តម បានខួលដំណែងជាសាស្ត្រាចារ្យ ហើយបានបំពេញមុខងារនេះ តាំងពីឆ្នាំ ១៩០៩ រហូតដល់ឆ្នាំ ១៩១៧ ។ ពេលបឋម, ឯកឧត្តម បានបង្រៀនទស្សនវិជ្ជា នៅវិទ្យាល័យ ប្រធានាធិបតី ឯទីក្រុងកាល្រាស, (ប្រទេសឥណ្ឌៀ), រួចនៅមហាវិទ្យាល័យ ឯទីក្រុងមីសួរ (ប្រទេសឥណ្ឌៀ) ។

ក្នុងពេលនោះ, ឯកឧត្តម បានសរសេរសៀវភៅពីរ មានឈ្មោះជា

១- ទស្សនវិជ្ជានៃរ៉ាបិន្ទ្រណាត្តាគរ,

២- ការប្រតិបត្តិសាសនា ក្នុងទស្សនវិជ្ជាសម័យទំនើប ។

រវាងឆ្នាំ ១៨២១ ទីឆ្នាំ ១៨៣១, ឯកឧត្តមដែលបានឧទ្ទិសដំណែងជាទស្សនសាស្ត្រចារ្យ ចូលអញ្ជើញទៅបង្រៀន នៅមហាវិទ្យាល័យឯកឧត្តមព័ល្លកត្តា (ប្រទេសឥណ្ឌា) ។ ក្នុងពេលនោះ ឯកឧត្តមបានសរសេរសៀវភៅពីរក្បាត គឺ ទស្សនវិជ្ជាឥណ្ឌា ភាគ១-ភាគ២ ដែលបញ្ជាក់ឲ្យច្បាស់លាស់ នូវសភាពចិត្តានៃទស្សនវិជ្ជាឥណ្ឌា តាំងពី៣០០០ឆ្នាំ មុនគ.ស. ។

លទ្ធផលដ៏ប្រសើរនេះ ជាហេតុឲ្យចិត្តាទំនើប មានការច្រាស្រ័យទាក់ទងនឹងពួកទស្សនវិទូ ប្រទេសឥណ្ឌា ។ សៀវភៅនេះ បានចុះពុម្ពផ្សាយទៅក្នុងពិភពលោក, ហើយយើងនឹកសង្ឃឹមថា, មិនយូរប៉ុន្មាន, ទស្សនវិជ្ជាឥណ្ឌា នឹងអាចបញ្ចូលទៅ ក្នុងកម្មវិធីសិក្សាបាន ។

លំដាប់តមក, លោកបានតែងសៀវភៅសំខាន់ពីរក្បាត "ការពិចារណាអំពីឧត្តមគតិនៃជីវភាព" និង "សាសនាបូព៌ាប្រទេស, ចិត្តាមជ្ឈឹមប្រទេស" ។ សៀវភៅទីមួយ បានប្រមូលរួបរួមនូវសុន្ទរកថាដែលឯកឧត្តម បានធ្វើនៅមហាវិទ្យាល័យ ទីក្រុងឡុងជ្រ្ស នឹងទីក្រុងម៉ានសែស្ទែរ កាលពីឆ្នាំ ១៩២៩ ។ សៀវភៅទីពីរ ជាអត្ថបទស្តីអំពីសុន្ទរកថាដែលឯកឧត្តម បានធ្វើនៅមហាវិទ្យាល័យអុក្សហ្វរ ។ ឯកឧត្តម ជាជនជាតិឥណ្ឌាយ៉ាងឆ្នើមមួយរូប ដែលបានតែងតាំងមុនគេ ដំបូងបង្អស់ ជា

សាស្ត្រាចារ្យ នៅមហាវិទ្យាល័យ អុកស្វហ្វដ ។ សៀវភៅទាំងពីរនេះ ធ្វើឲ្យកិត្តិនាមឯកទត្តមល្បីល្បាញ នៅក្នុងមជ្ឈមប្រទេស ហើយញុំាងឲ្យមានការរាជាវដើម ក្នុងមជ្ឈដ្ឋាន នៃពួកទស្សនវិទូទាំងឡាយជាតិយោគាត ។

តាំងពីនោះមក, ឯកទត្តមក៏ត្រូវតែងតាំង ក្នុងសមាគមជាតិ, ក្នុងឋានៈជាសមាជិកគណៈកម្មាធិការ នៃសហការ ខាងបញ្ញា (១៩៣១) ។ ក្នុងឆ្នាំដដែលនោះ, ឯកទត្តម ត្រូវតែងតាំងជាអធិការបតីរង នៃមហាវិទ្យាល័យអង់ទ្រេ ។ ក្រោយមក, មិនយូរប៉ុន្មាន, ឯកទត្តម បានតែងតាំងជាសមាជិក នៃបណ្ឌិតសភាអង់គ្លេស ។ ក្នុងពេលនោះ ឯកទត្តម បានថ្លែងខ្លួវសុន្ទរកថាមួយ អំពីទស្សនវិស័យ នៃព្រះសម្មាសម្ពុទ្ធ ។

លំដាប់តមក, ឯកទត្តម ត្រូវតែងតាំងជាអធិការបតីរង នៃមហាវិទ្យាល័យហិណ្ឌូ នៅទីក្រុងបាណាក៏ស (ឥ.ស. ១៩៣៩), ប្រធានាធិបតីចិនបានអញ្ជើញឯកទត្តម ជាកៀវតិត្តិយស នៅធ្វើសន្និសីទ ។ អត្ថបទនៃសន្និសីទទាំងប៉ុន្មាន បានប្រមូលជាសៀវភៅមួយ មានឈ្មោះថា "ប្រទេសឥណ្ឌានិងប្រទេសចិន" ។

ក្រោយមហាសង្គ្រាម សាកលលោកទីពីរ, ឯកទត្តម បានបង្ហាញបោះពុម្ពផ្សាយ នូវសៀវភៅមួយទៀតនាម "សាសនានិងសង្គម" ។ នៅក្នុងសៀវភៅនេះ, ឯកទត្តមបានពណ៌នាអំពីរឿងកាម៉ាឡា ដែលឯកទត្តម បានថ្លែងនៅមហាវិទ្យាល័យ ក្រុងកំលកត្តានិងរឿង "កតវតីតាវណ្ណនា" ។ គឺនៅក្នុងសៀវភៅនេះឯង ដែលឯកទត្តម បានពាយុកុ

ជាមុនថា "មហាក្ខត្តន្ធី មុខជាថ្ងៃណាមួយទំនងបូជាដ៏វិត ដើម្បីទំនងឲ្យ
ដ៏វិតទៅប្រជាពស្ត្រ របស់លោកមិនខាន" ។

ក្នុងពេលមិនយូរប៉ុន្មាន, ឯកឧត្តមបានបោះពុម្ពផ្សាយនូវសៀវភៅ
មួយទៀតនាម "បូពាប្រទេស ទំនៀមដ្ឋានប្រទេស ទំនៀមដ្ឋាគត នៃប្រទេស
ទាំងនេះ" ។ សៀវភៅនេះប្លែកមនូវអត្ថបទនៃសន្និសីទ ដែលឯកឧត្តម
ធ្លើទៅមហាវិទ្យាល័យ ម៉ាក-គីល (ប្រទេសកាណាដា) ។

សៀវភៅដែលអ្នកទិពន្ធទាំងពីរ ជានសរសេរ បំពោះឯកឧត្តម
ពេញក្រិស្ណាន គឺសៀវភៅដំមួយ ដែលគេបានធ្វើអំណោយជាកិត្តិយសក្នុង
ពិធីបុណ្យខួបអាយុ ៦០ ឆ្នាំ នៃឯកឧត្តម ទំនងសៀវភៅ ដែលមាននាម
ថា "មាលីបទ នៃពួកទេវតាខ្ញុំ ដែលរស់នៅ" ។

មហាវិទ្យាល័យដែលបានប្រគល់ហានុត្តរសិក្ខាបទដូនឯកឧត្តមគឺ មហា-
វិទ្យាល័យអុកស្ហ្វត ១, កំមប្រិដ ១, ឡុងដ្រ ១, កូលុមប៊ីយ៉ា, ហ្វាវ ១,
ម៉ាកគីល ១, រ៉ូម ១, ប៊ុយអេណូសៃរ ១, សីឡង់ ១ ទំនងមហាវិទ្យាល័យ
ផ្សេង ។ ទៅប្រទេសផ្សេង ។

ឆ្នាំ ១៩៤៦, គេបានឃើញឯកឧត្តមកំពុងធ្វើសន្និសីទទៅសហរដ្ឋ
អាមេរិក ។ លំដាប់តមក, ឯកឧត្តម ត្រូវតែងតាំងជាប្រធាន នៃគណៈ
ប្រតិភូផ្សេង កាលប្រជុំសន្និសីទជាលើកដំបូង នៃអង្គការសហប្រជាជាតិ
នៃការសិក្សាវិទ្យាសាស្ត្រ ទំនងវប្បធម៌ ហើយឯកឧត្តម ត្រូវបញ្ជាលទៅ
ក្នុងគណៈកម្មាធិការនាយក នៃអង្គការនេះ ។

កាលពីឆ្នាំ ១៩៤៩, ឯកឧត្តម ត្រូវទទួលហានុត្តរសិក្ខា ជាឯកអគ្គ-

ពជទូតប្រទេសឥណ្ឌា ប្រចាំប្រទេសរុស្សី ។ នៅខែឧសភា ឆ្នាំ១៩៥២, ឯកឧត្តម ត្រូវជ្រើសតាំងជាអនុប្រធានាធិបតីនៃប្រទេសឥណ្ឌា ។ ចំពោះហានន្តរស័ក្តិនេះ ឯកឧត្តម ត្រូវទទួលដំណែងជាប្រធាន "ពជសភា", ជានាម នៃឧត្តមសភា ប្រទេសឥណ្ឌាថែមទៀត ។

ឯកឧត្តម មានជីវភាពជាសាមញ្ញជន, មិនបរិភោគសាច់, មិនអស្រ័យថាវ៉ី, ថ្នាំ, ស្រា ឬមេរ៉ាយ, ឯកឧត្តម ពេញចិត្តខាងអានសៀវភៅ "អានទឹងសរសេរជាសកម្មភាព ដែលឯកឧត្តម មានចិត្តសោមនស្សចង់បំពេញជាយ៉ាងវិត្រពេក" ។

គេលទិភាសទំនេរ, ឯកឧត្តម ពេញចិត្តលេងកំប្លែងកូនគោលដែលហៅថា "គ្រីកេត" ជាមួយទឹងចៅ ឬបុត្រ, ធីតា ។

ឯកឧត្តម ជាមនុស្សមានប្រាជ្ញា ហើយមានសម្រស់ទឹកចិត្ត អាចឲ្យអ្នកផងចូលចិត្តជាអនេក, ឯកឧត្តម ជាក់ត្តិនមួយប៉ុនប្រសប់ខាងវាគសិល្ប: អាចឲ្យអ្នកផងទាំងពួងព្រេញចិត្ត ចូលទៅសវនា ដោយចិត្តរីករាយ ។ មិនតែប៉ុណ្ណោះ, វាចាដែលឯកឧត្តមពោលទៅកាន់មហាជន មានពលភាព អាចញ៉ាំងចិត្តអ្នកស្តាប់ ឲ្យចង់ស្តាប់ហើយស្តាប់ទៀត, ព្រោះថាវាចាវិចេះក្បោះក្បាយ ហើយថែមទាំងមានលំអឱ្យមសារផងទៀត ។

គ្មានទស្សនវិទូណា ដែលមានជីវិតរស់ទៅសព្វថ្ងៃ អាចមកប្រៀបធៀបទឹងឯកឧត្តមបានក្នុងកិច្ចធ្វើឲ្យបូតាប្រទេស ទឹងមជ្ឈិមប្រទេស មានសភាពដ៏តស្ងួតទៅវិញទៅមក ។

កាលពីថ្ងៃច័ន្ទទី ៩ កញ្ញា ១៩៥៧, ឯកឧត្តមទស្សនសាស្ត្របណ្ឌិត

សារវិបល្លី ពាធក្រិស្ណាន ជាន់អញ្ជើញមកកាន់ស្បូនាប្រទេសកម្ពុជា ។ ក្នុង
ខុកាសនោះ មានពិធីខួលជាច្រើនរក ទៅមន្ទីរស្តីការនាយករដ្ឋមន្ត្រី ។
ឯកឧត្តមជាន់ថ្លៃនិងសុន្ទរកថាមួយយ៉ាងពិស្តារថា :

តាំងពីយើងមកដល់, យើងជាន់ខួលកិត្តិយសដ៏ខ្ពង់ខ្ពស់ត្រមពាំង
ការឧបត្ថម្ភដ៏ប្រសើរអំពីព្រះពាជវង្សានុវង្ស, ពាជរដ្ឋាភិបាលនិងប្រជាពស្ត្រ
នៃប្រទេសកម្ពុជា . . . . . .

ថា :

សម្តេចព្រះនរោត្តម សីហនុ ទ្រង់មានព្រះពាជបំណងជាខ្លាំង ចង់
ធ្វើប្រទេសព្រះអង្គ ឲ្យមានវឌ្ឍនភាពតទៅអនាគត ត្រមពាំងវចនា
ប្រទេសនេះ ឲ្យទៅជាប្រជាជាតិមួយ តាមសម័យនិនេះ ។ យើងជាន
ដឹងនូវព្រះពាជបំណងដូច្នេះ, ជាន់ជាយើងមានចិត្តសាទរ ដែលជាន់យើញ
ទ្រង់ស្តេចយាងទៅ ធ្វើព្រះពាជនិស្បូនាការ នៅប្រទេសយើង ។ ក៏ជាន
រៀបចំខួលព្រះអង្គ តាមព្រះពាជកិត្តិយសដ៏ខ្ពង់ខ្ពស់ . . . . . .

ថា :

យើងត្រូវយល់ថា យើងជាបងប្អូនសាច់ញាតិ នៅក្រោមសង្គម
តែមួយ, ហើយបើ មានោសញ្ចូតនានេះ ចម្រើនឡើងតាមលំដាប់, យើង
ត្រូវងាកទៅរកសេចក្តីថ្លៃថ្នូរខាងបញ្ញា ដែលសាសនាទាំងអស់ យកមកធ្វើ
ជាមូលដ្ឋាន ។ ព្រះពុទ្ធសាសនា ដែលលោកអ្នកពេញចិត្តជាពិសេស
ដោយព្រះសម្មាសម្ពុទ្ធ ទ្រង់ប្រទានទុកថា កូនដីរាគរបស់មនុស្ស មិន
មែនគ្រាន់តែបំពេញសកម្មភាពខាងសង្គមទេ ត្រូវបំពេញទៅតាមធម្មជាតិ

មួយបែបទៀត ដែលមានទំដួគាពផ្សេង គឺការបិតនៅស្ងប់ស្ងាត់តែម្នាក់ឯង ដែលជាបុព្វហេតុឲ្យកើត នូវស្នាដៃដ៏សំខាន់ខាងសិល្បៈ, វិទ្យាសាស្ត្រនិងការស្វែងរកយើញ នូវតែថ្មី ។ ថែមទៀត .....

ថា: បើអ្នកចង់ចាន់ប្រាជ្ញាឲ្យឆ្លាស់លាស់, ឬប្រមូលចិត្ត ឲ្យមូលតែមួយជាឯកគ្គតា អ្នកត្រូវតែតាំសោធមើល ក្នុងមួយជីវិត, ឲ្យបានតែម្តង គឺអ្នកត្រូវតែឃ្លាតចេញឲ្យឆ្ងាយពីលោកកន្ទុល ដើម្បីឲ្យអ្នកបិតនៅតែម្នាក់ឯង ។

ថា: បើយើងមានបំណងចង់រួបរួមពិភពលោក ឲ្យនៅតែមួយឯកឯង, យើងមិនអាចសម្រេច នូវលទ្ធផលទៅបាន ដោយប្រើនយោបាយនិងសេដ្ឋកិច្ចប៉ុណ្ណោះទេ យើងត្រូវតែរៀបចំចាត់ចែងវិធានា នូវប្រាជ្ញាពិភពលោកសិន ។ ពិភពលោកមានតែមួយ, ដូចជារូបយើងដែរ, ពិភពលោកស្វែងរកនូវប្រាជ្ញា, ដោយស្មារបញ្ចិតមួង ពិនិត្យមើលស្រមោលផ្សេង ដើម្បីនឹងរកនូវមនោធម៌ ឲ្យឆ្លាស់លាស់ ។ ដើម្បីនឹងឲ្យបានសម្រេចនូវទុត្តមគតិនេះ, យើងត្រូវតែធ្វើអំណាយ ចំពោះពិភពលោក នូវមនោធម៌តែមួយ, ប្រាជ្ញាតែមួយ, វិញ្ញាណតែមួយ មានសភាពទូលំទូលាយ ដូចបក្រក់ឡ ដូច្នេះ ។ តាមសេចក្តីពិនិត្យជាអាសាន, ឯកទុត្តមគឺជាមេដឹកនាំមានសភាពដ៏ខ្ពាំនឹងក្លាជាងគេ ចំពោះការបម្រាញ់ប្រាជ្ញា ដែលជាមូលដ្ឋាននៃទស្សនវិជ្ជាបក្រក់ឡ ដោយឯកទុត្តម បានបញ្ជាញនូវកស្តុតាង ដ៏ជាក់ស្តែងតំណាក្យសោលថា: "មនុស្សជាអ្នកសង្កេតការនៃមនុស្សធម៌" ។ មានលទ្ធិមនុស្សធម៌និយមបញ្ជាស្មើជាថ្មី នៅជើងមេឃ ។ តែលទ្ធិនេះប្រមូលរួបរួមនូវមនុស្សជាតិពាំងអស់ ។

X X X

ភិក្ខុ ប៉ាង.ខាត់ រៀបរៀង

(តមក)

-សាក្សាម៑, ទៅចំពោះមុខព្រះអគ្គិ; -សាក្សិក គុ. ដែលយកព្រះអគ្គិជាសាក្សី, ។ -សាក្សិកមយ៑ ឧ, គុ. ដែលយកព្រះអគ្គិជាសាក្សី, ដែលជាភក្តីភាពនៃស្វាមីភរិយា ។ -សារ នបុំ. ភ្លាំភ្លែក ។ -សារណិ បុំ. តាមព្រះមនុ ។ -សូត្រ នបុំ. ខ្សែដៃភ្លើង, ពួស្មៅជាពិធីសង្ក្រាប់ពាក់ឲ្យកុមារព្រាហ្មណ៍ ។ -ស្កោក បុំ. ដុំនៃភ្លើង ។ -ហុត គុ. ដែលបូជាដោយភ្លើង ។ -ហោត្រ បុំ. អ្នកយកអគ្គិជាប្រថ្នូដិត ។- ហោត្រ នបុំ. ការបូជាព្រះអគ្គិ, ព្រះអគ្គិ ។ -ហោត្រិន គុ. ដែលរះក្សាអគ្គិហោត្រ ។ -អគ្គីន្ធន (អគ្គិ+ឥន្ធន) បុំ. ភរិយាជិតព្រះអគ្គិ ។ អគ្គ្យាគារ (អគ្គិ+អាគារ) បុំ. ភោងនៃព្រះអគ្គិ ។ អគ្គ្យាធាន (អគ្គិ+អាធាន)នបុំ.ការយាបង្កើតនូវព្រះអគ្គិ,-អាធេយ ន្ធូបគ្គ ។ -អគ្គ្យាហិត (អគ្គិ+អាហិត) គុ. ដែលមានភ្លើងតាំងទុកហើយ ។ អគ្គិមន្ថ គុ. ដែលមានព្រះអគ្គិ ។

អគ្រ គុ. ខ្ពង់ខ្ពស់, ប្រសើរ ។ នបុំ. កំពូល, ចុង, ទីបំផុត, ចំណែកខាង ដើម,ខាងមុខ;។អគ្រេ ក្នុងខាងមុខ, ចំពោះមុខ; អគ្រមិ ខាងមុខ; អគ្រតស៑ ពីខាងមុខ; អគ្រតស៑ -ក្នុងពីមុខ។ -ករ បុំ. ម្រាមដៃ, រស្មីមួយ ។ -គ គុ. ដែលទៅមុខ, ដែលតាំ; បុំ. អ្នកតាំ ។ -គណ្យ គុ. ដែលគួរគប់ថាជាមេ ។- គាមិន៑ គុ. អ្នកតាំ។- ជ គុ. ដែលកើតមុន, នបុំ. កូនបង; ព្រាហ្មណ៍ ។ -ជន្ម៑ បុំ. ឆ្នូចអគ្រដ ។ - ណី ៣ ន. អ្នកតាំ, មេ; -ណ្យឆ្នូចអគ្រណី ។ ណីត ស្ត្រី. ភរិយាតាំបូជាមុន ។ -ទាក្ស គុ. អ្នកបូជាមុន ។- ទូត បុំ. ទូតមុន, ទូតធំ ។ -ន១ បុំ. ចុងនៃក្រចក ។

ភិក្ខុបាតិមោក្ខ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ១០ ខែតុលា ព.ស.២៥០០ គ.ស. ១៩៥៦





ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
–អប្បមាទធម៌ . .	លោកគ្រិញ-ភីញ អតីតអនុរដ្ឋលេខាធិការក្រសួងធម្មការ	រៀបរៀង ៨៧៩
–តើព្រះពុទ្ធសាសនាវិវត្តមកដល់ត្រឹមណា (តទប)	លោក ភ័យ-ប៊ុក	ប្រែរៀបរៀង . . . ៨៨៣
–សំវេគកថា	ស្រី-ភ្លូ	ក្រមដំបុត្រៃត្រៃបិដក រៀបរៀង ៨៩៣
ផ្នែកអក្សរសាស្ត្រ		
–សកម្មភាពនៃក្រុមដំបូងំទៀមទម្លាប់ខ្មែរ . . .	លោក ជាប-គីន	រៀបរៀង . . . ៩០០
–ភាសាខ្មែរ	លោក ភ័យ - ប៊ុក	ប្រែរៀបរៀង . . . ៩១០
–រឿងទេវន្តរបស់អម្រិតឥស្ត្រី ម៉ុក (តមក)	លោក ឡាក-ថែម តិនិត្យ	. . . . . ៩១៣
–រឿងសាមកុក (តមក)	ឧកញ៉ា ន្នុ-កន	ប្រែ រៀបរៀង . . . ៩២៥
–រឿងហ្សាតិត (តចប់)	លោក ភ័យ-ប៊ុក	ប្រែ រៀបរៀង . . ៩៣១
–អំពីបងប្អូនពីរនាក់នឹងមាន់ធ្លាក់ (តមក)	លោក ទៀង-ថៃ-ឈុន	ប្រែរៀបរៀង . . ៩៣៧
ផ្នែកកំណត់ទំនៀមប្រវត្តិការណ៍		
–ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះតេជគ្រូគុណព្រះពោធិវង្ស (តមក) . . .	លោក-ជាទន់	រៀបរៀង ៩៤៣
–ព្រះរាជដំណើរសម្តេចព្រះឧបយុវរាជ-ទៅកាន់កោះស៊ីលង្កាក្នុងពិធីបុណ្យពុទ្ធជយន្តី-	លោក ភ័យ-ប៊ុក	រៀបរៀង . . . ៩៤៩
–សន្និសីទនៃ បណ្ឌិត-វិស្សវ៍ អេក្លាត ធ្វើទៅ-ពុទ្ធិកវិស្សាល័យព្រះសុរាម្រឹត (តមក)	លោកភ័យប៊ុក	រៀបរៀង ៩៥៥
–វចនានុក្រមសង្ស្កឹត-ខ្មែរ (តមក)	ព្រះពហា ចាំងខាត	រៀបរៀង . . ៩៦០

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

-Appamadadharma par *M. TRINH-HOANH* 879
-Où en est le Bouddhisme (suite)? traduit par *M. RAY-BUC* . . . 883
-Samvegatha par *M. SREY-OU* 897

PARTIE LITTÉRAIRE:

-Activité de la Commission des Mœurs et
Coutumes par *M. CHAP-PIN* 900
-La langue khmère traduit par *M. RAY-BUC* 910
-Histoire de Devanda de *M. MOK*, (suite)
revue et corrigée par *M. NHOK-THEM* 917
-Histoire de Samkok (suite) traduit par *M. NOU-KAN* 925
-Histoire de Zadig (suite) traduit par *M. RAY-BUC* 931
-La légende de deux frères et du coq de combat (suite)
traduit par *M. TIANG-TAY-CHHUN* 937

NOTES ET CHRONIQUES :

-Voyage du Vénérable HUOT-TAT aux
U. S. A. (suite) par *M. CHEA-TONN* 943
-Voyage de Samdach Préah Uppayuvareach á Ceylan lors de
la fête du Buddha Jayanti par *M. RAY-BUC* 949
-Conférence du Dr. RICHARD A. GARD au Lycée
Buddhique Préah Suramarit par *M. RAY-BUC* . . . 955
-Dictionnaire Sanskrit-khmer (suite) par Vén. *PANG-KHATH* . . 960

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

អប្បមាឧធម៌

លោក ទ្រីញ-វ៉ាញ

អតីតរដ្ឋលេខាធិការក្រសួងធម្មការ

រៀបរៀង

ប្រកួតជាប់លេខ ជាន់ទទួលរង្វាន់

កុងត្រាសបុរណ្យ ព.ស. ២៥៤០

ជំនួន រតនត្តយសួ

សូមនមស្ការ បំភ្លោះព្រះធម្មត្រៃយ

(ដោយសេចក្តីគោរព)

ចន្លាប់តាំងនមស្ការនេះទៅ សូមលើកយក អប្បមាឧធម៌ "សេចក្តីមិនប្រមាទ" មកតាំងជាដើម្បីជាគ្រឿងជួយអប់រំដល់ជាតិកងតិចតួចលោក ដែលកំពុងមានសេចក្តីស្នេហា ចំពោះប្រយោជន៍ដ៏ល្អខ្ពង់ខ្ពស់ ធំធេងប្រយោជន៍ប្រទេសជាតិ មាតភូមិ រៀងពាស់រូបពាស់ជាតិ។

បពិត្រលោក-អ្នកស្រីគារប្រយោជន៍ទាំងឡាយ !

ហេតុដែលទាំងឱ្យលើកយក អប្បមាឧធម៌ មកតាំងជាលាតត្រដាងជូនក្នុងពុទ្ធសាសនាយុគាលគំរប់ ២.៥០០ ឆ្នាំ គឺងាកឆ្ពោះទៅរកពុទ្ធសាសនានេះ ដោយយល់ឃើញថា ធម៌នេះដាក់តួលធម៌ទាំងឡាយ ដែល

អាចញុំាងប្រយោជន៍ត្រង់យ៉ាងឲ្យសម្រេចបាន ។

អប្បមាទធម៌នេះ ចាប់តាំងពីគេលដែលព្រះអរហន្តសម្មាសម្ពុទ្ធ ទ្រង់ត្រាស់ដឹងឡើង ក្នុងលោកកាលណា ព្រះអង្គតែងទ្រង់សំដែងប្រាស ប្រទានសត្វសត្តនិកាយ ជាច្រើនលើកច្រើនគ្រា ដរាបដល់ទីគេលទៀប ទ្រង់ព្រះបរិនិព្វានទៀត ព្រះអង្គក៏ទ្រង់ឈ្វេងយល់ ដោយក្រែងសត្វក្នុងពិភពលោក ភ្លេចអប្បមាទធម៌នេះ ទ្រង់ត្រឡប់សំដែងផ្តាំផ្តែរដ៏ក្រៃលែង ជាបុងក្រោយបំផុត ដូចមានជាប់នៅសត្វថ្ងៃនេះថា:

ហន្ទ ទានិ ភិក្ខវេ អាមន្តយាមិ វោ យថាបិ សង្ខារា អប្បមាទេន សម្បាទេថ! ម្នាលភិក្ខុភាំងឡាយ តថាគតជាសត្តឿនអ្នកភាំងអស់គ្នា សង្ខារទាំងឡាយ មានការសូន្យជាធម្មតា អ្នកភាំងឡាយ ចូរញុំាងធ្វើប្រយោជន៍ឲ្យសម្រេច ដោយសេចក្តីមិនប្រមាទចុះ! ។

ក៏អប្បមាទធម៌នេះ ពិតជាធម៌ដែលព្រះសម្ពុទ្ធ ទ្រង់ពិចារណាជ្រើសរើសឃើញជាប់ព្រះអង្គឯងថា ក្រធម៌ណាអាចញុំាងប្រយោជន៍ត្រង់យ៉ាង ឲ្យសម្រេចក្នុងបច្ចុប្បន្នភាគខ្លះ ទីនប្រយោជន៍ក្នុងបរលោក ដូចជាអប្បមាទធម៌នេះគ្មាន ។ ព្រោះហេតុនោះហើយបានជា ព្រះសម្ពុទ្ធទ្រង់មានព្រះភ្នុដីកាផ្តាំទៀតថា ចូរសត្វក្នុងពិភពលោក កុំភ្លេចអប្បមាទធម៌នេះសោះឡើយ ។

ពាក្យថា: អប្បមាទធម៌នេះ ជាភាសាបាលី ប្រែចេញជាភាសាខ្មែរថា ការមិនប្រមាទ សេចក្តីមិនប្រហែសធ្វេស ។

សេចក្តីមិនប្រមាទនេះ ចែកជា ២ ផ្នែក:

១ - មិនប្រមាទក្នុងការលះ;

២- មិនប្រមាទក្នុងការចំរើន ។

សូមអធិប្បាយវិភាគន័យនៃសេចក្តី នៃការមិនប្រមាទទាំង ២ផ្នែក មួយម្តងដូចតទៅ ៖

១- មិនប្រមាទក្នុងការលះ ជានសេចក្តីថា: អំពើណា ។ ដែលជនដាតិប្រព្រឹត្តទៅហើយ នាំឱ្យខូចខាតផលប្រយោជន៍ផ្ទាល់ខ្លួន ទើបប្រយោជន៍សាធារណៈជន អំពើនោះ ។ ត្រូវតែលះបង់ចោល ដោយដាច់ខាត សូម្បីតែបន្តិចបន្តួច ក៏មិនត្រូវប្រថុយប្រព្រឹត្ត ឬប្រកបឡើយ ។ បើការណាជនដាតិមានសេចក្តីប្រមាទ ដោយនឹកស្មានថា អំពើតិចតួចមិនដាការប៉ះពាល់ទេ ហើយនោះតែងប្រព្រឹត្តតទៅទៀត ជនជាតិនោះឯង ឥតដាទឹងបានទទួលនូវផល ដាពុំគួរពុំខានឡើយ ។

២- មិនប្រមាទក្នុងការចំរើន ជានសេចក្តីថា : អំពើណា ។ ដែលជនដាតិប្រព្រឹត្តទៅហើយ នាំឱ្យកុមារកើតផលប្រយោជន៍ទើបសេចក្តីថ្កុំថ្កើងរុងរឿងដល់ខ្លួន ទើបសាធារណៈជន ទោះបីតិចឬច្រើនក៏ដោយ អំពើនោះ ។ ជនដាតិត្រូវតែចិញ្ចឹមយកមកបន្តសកម្មភាពទៀត ពុំត្រូវធុញទ្រាន់ខ្ជិលណាឡើយ ដោយមានគតិ ប្រកបដោយការប្រមាទ ហើយស្មានថា: អំពើតិចតួច ពុំដាយទើបសម្រេចអ្វីបានឡើយ ។ សូម្បីក្តីមទឹកដែលតែបើកមានចិញ្ចឹមរាល់ថ្ងៃ ក៏តែងពេញពោរពេញដោយដំណក់ទឹកភ្លៀង ដែលធ្លាក់តក់ ។ ចុះតើអាកាសមកពីណា ។

សេចក្តីប្រៀបធៀប នៃការមិនប្រមាទពាំនាំពីរផ្នែក មានកំពស់ស្មើគ្នា ។

បច្ចុប្បន្នសម័យ នៃពុទ្ធសករាជគំរប់ ២.៥០០ ព្រះវស្សានេះ ជនជាតិកន្លងពីកពាលោក ស្ទើរតែលប់ប្រទេស ចាន់បបួលគ្នារៀបចំធ្វើបុណ្យយ៉ាងទូលាំទូលាយ រំលឹកអាយុកាលតាក់តែងសាសនា ។ តាលបើដូច្នេះជនជាតិណាក៏ដោយ កន្លងពីកពាលោក គួរតែនាំគ្នាប្រព្រឹត្តសុចរិតយុត្តិធម៌ឲ្យកម្រិតម៉ាត់ គឺត្រូវស្រឡាញ់ប្រយោជន៍ផ្សាល់ខ្លួន ទើបប្រយោជន៍សង្គមជាតិ ប្រយោជន៍ជាតិមាតុភូមិសាសនា មហាក្សត្រខ្លួនព្រមទាំងជនជាតិដទៃផង មិនត្រូវបៀតបៀនញុះញង់បំផាន់ សង្កត់សង្កិនយកផលប្រយោជន៍ អំពីគ្នាទៅវិញទៅមកដោយសារតែទានសេចក្តីប្រមាទឡើយ ។ ប្រព្រឹត្តបែបនេះ ដើម្បីរក្សាការពារទុត្តមប្រយោជន៍ឲ្យបានស្ថាពរ ព្រមទាំងជួយពង្រីក ពង្រឹងសន្តិសុខ សន្តិភាព ឲ្យបានខ្ជាប់ខ្ជួនយូរអង្វែងតរៀងទៅ ។

អាសានកថា សូមផ្សាយសប្បុរសធម៌ គ្រប់សញ្ញាតិ សូមបានប្រកបដោយសេចក្តីសុខ-ចំរើន ព្រមទាំងតាំងនៅសិប់ ក្នុងព្រះពុទ្ធសាសនាអស់កាលជានិច្ច និរន្តរ៍ កុំបីឃ្លៀងឃ្លាតឡើយ ។

តើព្រះពុទ្ធសាសនាវិវត្តមកដល់ត្រឹមណា?

សន្និសីទលោក ។។. ពហុល ថ្លែងនៅវិទ្យាល័យ
ឯកទេសអាទិទេពនិយម Collège Idéologique
ឯក្រុងដាវីស កាលពីថ្ងៃទី ១០ ខែមិថុនា ១៩៨៦

លោក រ៉ាយ-ប៊ុក ប្រែពីភាសាបារាំង
មកជាភាសាខ្មែរ

(តចប់)

ចំពោះពុទ្ធមាមកជនម្នាក់ ពួកថេរវាទនិងពួកមហាយានថា ពួកពុទ្ធសាសនិកជនដូចគ្នាទាំងអស់ ពួកទាំងពីរខេត្តសុទ្ធតែជាអហង្ការ ខ្លួនក៏ចង់ព្រះបរមសម្មាសម្ពុទ្ធគឺចតុកកៈយសច្ច, អដ្ឋង្គិកមគ្គ, បដិច្ចសមុប្បាទ ។ល។ ការដែលពួកទាំងពីរមានទស្សនាផ្សេងពីគ្នា បឹតនៅទាំងពាហារហេតុនិងជំនឿប្រជាមានិតដែលមិនមែនជាសារៈសំខាន់ ។ បើគេបំបាត់លទ្ធិព្រះពុទ្ធសាសនាចេញ គេអាចយល់បានថា ការព្រមព្រៀងរបៀបពួកទាំងពីរជាការងាយ ។ នៅមហាវិទ្យាល័យព្រះសង្ឃ ទាំងលទ្ធិថេរវាទនាមថា វិទ្យាល័ត្តរបៀរវៀងឯក្រុងកូលម្ប (ប្រទេសស៊ីឡង់) មានលោកសង្ឃទាំងមហាយាន បានទទួលមកសិក្សារៀនសូត្រដែរ ។ លោកសង្ឃមហាយាននេះ មានបញ្ជីត ទីនិងគ្រូហាស្តគោរពដូចគ្នា ទីនិងលោកសង្ឃថេរវាទ ។

តុដ្ឋិកសមាគមពិភពលោក បានប្រមូលបញ្ចូលប្រទេសថេរវាទនិងប្រទេសមហាយាន ឲ្យបានចូលមកច្រាស្រ័យគ្នា ជាយ៉ាងជិតស្និទ្ធ ។ សមាជលើកទីពីរនៃអង្គការនេះ បានធ្វើនៅទីក្រុងតូក្យូប្រទេសជប៉ុន ពី គ.ស. ១៩៥២ សមាជលើកទីបី នៅទីក្រុងឡុណប្រទេសកូមា គ.ស. ១៩៥៤ ទីនិងសមាជលើកទី៤ បានប្រជុំគ្នាពីរខែវិច្ឆិកា ១៩៥៦ នៅទីក្រុងកត្តុ-

ម័ណ្ឌ (ប្រទេសនេប៉ាល់) ប្រទេសដែលព្រះដ៏មានព្រះភាគទ្រង់ប្រសូត ។
ខ្ញុំមានបំណងចង់ជម្រាបអំពីនេះថា ប្រជាជនកន្លែងពុទ្ធិកសមាគមមិត្តភក្តិ
លោកគឺលោកសាស្ត្រាចារ្យ មហៈលេសរៈនៅប្រទេសស៊ីឡង់ ។ ហើយ
លោកអ្នកមុខជា ខឹងមានចិត្តសោមនស្ស ជាយ៉ាងក្រៃលែងដោយបានឮ
ថា អនុប្រធានៃអង្គការពិភពលោកនោះ មកពីព្រំប្រទល់ប៉ាកីស្ថាន គឺនាង
កញ្ញាលុនស្បៃរ ប្រធានិកានៃសមាគមមិត្តពុទ្ធសាសនាព្រំប្រទល់ប៉ាកីស្ថាន ។

ក្នុងឆ្នាំនេះ, តាំងពីថ្ងៃពេញបូណ៌មីខែវិសាខ (ខសភ) ១៩៥៦
ទៅដល់ថ្ងៃពេញបូណ៌មី ខែពិសាខ (ខសភ) ១៩៥៧ គឺជាឆ្នាំសំខាន់
ណាស់ ក្នុងព្រះពុទ្ធសាសនាប្រវត្តិ ។ គឺឆ្នាំ ២៥០០ ក្រោយថ្ងៃដែលព្រះ
សម្មាសម្ពុទ្ធ ចូលបរិនិព្វាន ដែលគេសន្មតនាមថា ពិធីបុណ្យពុទ្ធជយន្តិ ។

មានជំនឿមួយ ចំពោះពុទ្ធសាសនិកជនទាំងឡាយនាក់ តាម
ប្រពៃណីបុរាណថា ឆ្នាំ ២.៥០០ នៃព.ស. ទាំងអស់គាន់តាលសម័យមួយ
ដែលធម៌បរិសុទ្ធរបស់ព្រះសម្មាសម្ពុទ្ធ ផ្សាយទូទៅក្នុងពិភពលោក ត្រូវតាំង
ជាប្រជាពលរដ្ឋនឹងគ្រាច់ទៅតាន់សុចរិតធម៌ហើយថា សុភមង្គល នឹង
សម្បូណ៌ភាពនឹងចម្រើនឡើង ក្នុងពិភពលោកនេះ ។

ពាក្យថា"ធម៌"ទាំងព្រះពុទ្ធ មិនមែនជាតណាមួយ ដែលគេបង្កើត
ឡើងនោះទេ, គឺជាពាក្យមានតម្លៃដូចជាសេចក្តីស្នេហា,
សេចក្តីមេត្តា, ការមិនបៀតបៀន ការសន្តោស តតិបណ្ឌិត ការយល់
ត្រូវ, សន្តិភាព, សុខចំរើន, ការជ្រាបចាក់ថែអត្តចរិតភាព, ការ
ស្អប់ខ្ពើមអវិជ្ជា ការបរិសុទ្ធិភាយក់ចាចិត្ត, ។ នេះជាតម្លៃសាកលហើយ

តម្លៃនេះ មិនបានតោលចំពោះតណៈណាសោះឡើយ ។ ការពុទ្ធសាស-
និកជនជឿជាក់ថា ឆ្នាំនេះគឺការសម័យ ដែលព្រះធម៌អាចផ្សាយទូទៅ
ក្នុងពិភពលោកគឺថា គតិដ៏ល្អ, គុណសម្បត្តិដ៏ប្រសើរ អាចផ្សាយទូទៅ
ក្នុងពិភពលោកបាន ។ កូមិការដែលកាន់ព្រះពុទ្ធសាសនា ដោយ
អចលនៈសទ្ធា ដ៏ខ្ជាប់ខ្ជួន, បានប្រុងប្រៀបរៀបចំនូវពិធីបុណ្យ ព.ស.
២៥០០ ។ គ.ស. ១៩៥០ ប្រទេសស៊ីឡង់ ហើយតាមលំដាប់មក
ប្រទេសកូមា មានការធ្វើពិធីបុណ្យធម្មសង្គាយនាព្រះត្រៃបិដក គឺការ
ធ្វើឆ្លាក់អក្ខរាបាលីដើម, ដើម្បីទំនឹងបោះពុម្ពជាសៀវភៅថ្មី ខាងពុទ្ធ-
សាសនាត្រមាំងសេចក្តីប្រជាការសាទំនើប ជាច្រើនការ ។ មាន
សមាគមចំនួនជាងមួយរយ បានរៀបចំអង្គការ ដើម្បីជួយគាំពារស៊ើលធម-
ទំនឹងប្បធម៌ប្រជាពស្ត្រខាងអស់ ។

ក្នុងឆ្នាំនេះ, មានពិធីបុណ្យធំ ។ ដែលគេបានធ្វើទៅប្រទេស ដែល
កាន់ព្រះពុទ្ធសាសនា ។ មានមនោសញ្ចេតនាខាងសាសនា មានសកាត
ឡាំងពនប្រមាណ បានផ្សាយទៅកាន់ប្រជាការពាំងឡាយ ។ មានការ
បោះពុម្ពសៀវភៅសារពត៌មាន ជាច្រើនសម្រាប់មហាជន ។ មាន
វិហារទំនឹងវិមានថ្មី ជាច្រើនបានស្ថាបនាឡើង សម្រាប់សកម្មភាពខាង
សាសនា ។ រដ្ឋភិបាលឥណ្ឌាបានធ្វើពិធីបុណ្យដ៏សំខាន់ក្នុងឆ្នាំនេះ
ដោយសាងមហាវិមានទៃអនុស្សាវរីយ៍ ទៅលើក្រួងញ្ជាវដែល្លី តាំង
ទូវស្តុបទំនពុទ្ធសាសនា ព្រមាំងបោះពុម្ពផ្សាយ អក្សរសាស្ត្រព្រះពុទ្ធ-
សាសនា ទំនឹងធ្វើភាពយន្តពុទ្ធសាសនា ។

ព្រះចាវដាវៃ - ឡាម៉ាទីនព្រះចាវម៉ាញ៉ិន ឡាម៉ានៃប្រទេសទីបេត ដោយសេចក្តីអញ្ជើញរដ្ឋាភិបាល ទៅប្រជុំ ក្នុងពិធីបុណ្យពុទ្ធជយន្តី ប្រទេសឥណ្ឌា កំពុងស្ថិតនៅទីក្រុងញូវ-ដែលហ្គី ។ ដោយសេចក្តីអញ្ជើញ នៃប្រទេសស៊ីឡង់ ពួកគណៈប្រតិភូចិន,ជប៉ុន កំពុងអញ្ជើញទៅកាន់ប្រទេសស៊ីឡង់ ។ ដោយខ្ញុំបានជំរាបមកហើយថា ការគមនាគមន៍រវាងប្រទេសថៃក៏ដូចជាប្រទេសមហាយាន មានសភាពកាន់តែជិតស្និទ្ធ ។ មានការប្រឹក្សាគ្នា ដើម្បីទីធើបើកវិញ្ញាស្ថានឯកឯកទៅប្រទេសជប៉ុន ទីធីប្រទេសចិន ដើម្បីទីធីសម្រួលការសិក្សា ខាងលទ្ធិថេរវាទ ។

ពីរខែមុន (វិច្ឆិកា ១៩៥៦) រដ្ឋាភិបាលឥណ្ឌាទីធីគន្លឹការសហប្រជាជាតិ នៃការអប់រំវិទ្យាសាស្ត្រទីធីវប្បធម៌ បានរួមប្រជុំ ដើម្បីទីធីធ្វើសន្និបាតព្រះពុទ្ធសាសនា នៅទីក្រុងញូវ ដែលហ្គី ដែលមានសុមេធបុរស នៃភូមិភាគបួនប្រទេស ទីធីបស្ចឹមប្រទេស បានទទួលសេចក្តីអញ្ជើញ ក្នុងពេលនោះ ។ សន្និសីទនេះ មានវត្តមាណដ៏ចង់ក្លាក់ពិភពលោកថា ព្រះពុទ្ធសាសនាអាចទ្បើសន្តិភាពទីធីញ៉ាំងចិត្តមនុស្សទ្បើមានសេចក្តីសន្តោសគ្នា ទៅវិញទៅមកបានយ៉ាងណាខ្លះ ?

ក្នុងសម័យឥឡូវនេះ នៅក្នុងប្រទេសនៃពិភពលោក ជាប្រទេសនិយមព្រះពុទ្ធសាសនា ឬមិននិយម តែងមានចិត្តសាទរឡើងជាថ្មី ចំពោះព្រះពុទ្ធសាសនា ទីធីវប្បធម៌នៃព្រះពុទ្ធសាសនា ។ អ្នកទាំងឡាយ បានសង្កេតឃើញស្រាប់ហើយ ក្នុងពេលថ្មីៗនេះ មានសារពិតមានជារច្រើនរយច្បាប់នៃប្រទេសទាំងឡាយ បានផ្សាយជា

ភាសាផ្សេង ។ ទូរសេចក្តីផ្សាយព្រះពុទ្ធសាសនា ។ ផលប្រយោជន៍សាកលនេះ កើតមានឡើង មិនមែនគ្មានវិចារណញ្ញាណនោះទេ ព្រះពុទ្ធសាសនាបានមកក្នុងសម័យបច្ចុប្បន្ន, ចំពោះពិភពលោក ទូរបេសកកម្មដ៏សំខាន់ ។

ឯចំណែកខាងទ្វីបអឺរុប កំដូចគ្នាពិធីបុណ្យ ព.ស. ២៤០០ ឬ ពិធីបុណ្យពុទ្ធជយន្តិ បានធ្វើនៅប្រទេសជាច្រើន ។ នៅទីនេះ ឯទីក្រុងប៉ារីស, ពិធីបុណ្យនេះ កំបានធ្វើពីខែឧសភាមុននេះ នៅគេហដ្ឋានមហាវិទ្យាល័យ ក្រោមអធិបតីភាពសមាគម មិត្តពុទ្ធសាសនា ។ មានគណៈប្រតិភូទាំងប្រទេស, ប្រជាជាតិទាំងឡាយ សាសនាទាំងឡាយ អគ្គកោសាទូត ទីតំណាងរាជធានីជាតិ បានចូលមកប្រជុំ ជាមួយផង ។ ខ្ញុំមានចិត្តសោមនស្ស ជាយ៉ាងក្រៃលែង ដោយបញ្ជាក់នៅទីនេះថា សមាគមពុទ្ធសាសនា នៅទីក្រុងប៉ារីសបានធ្វើផលប្រយោជន៍ជាច្រើន ដើម្បីផ្សាយនូវបេសកកម្មព្រះបរមសម្មាសម្ពុទ្ធ ចំពោះមហាជន ដោយហេតុនេះហើយបានជាថា សមាគមនេះ បានផ្សាយនូវមេត្រីភាព ទំនៀមទំលាប់ល្អៗ ទៅវិញទៅមក រវាងបូពាប្រទេស ទំនៀមប្រទេស ។

ព្រះពុទ្ធសាសនាតាំងនៅក្នុងមូលដ្ឋានពីរយ៉ាង: មេត្តាទំនៀតបណ្ឌិត មេត្តាចំពោះសត្វលោកទាំងអស់ ដោយមិនរើសមុខទំនៀតបណ្ឌិត; សម្រាប់ពិភពលោកបច្ចុប្បន្ននេះ ព្រះពុទ្ធសាសនាជាទំនៀតបូ

នៃសត្វ ជាឃាំងជ្រាលជ្រៅ ដែលបិតនៅ ក្នុងមនុស្សជាតិ ហើយ ចាន់ប្រគល់ចំពោះមនុស្សជាតិនេះ ខ្លួវការខ្លួលខុសត្រូវ គេញ៉ាំ លក្ខណៈចំពោះខ្លួន ទើនសេចក្តីថ្លៃថ្នូរបស់ខ្លួន ។ ព្រះពុទ្ធសាសនា ធ្វើ ឲ្យមនុស្សជាតិត្រួតត្រាខ្លួនដោយខ្លួនឯង ។

គោលការខ្លួលការខុសត្រូវ ចំពោះបុគ្គលនេះឯង ដែលព្រះ សម្មាសម្ពុទ្ធ ទ្រង់ចាន់ប្រគល់សេរីភាព ឲ្យសារីកព្រះអង្គ ។ ព្រះ អង្គទ្រង់ច្រកាន់ទុកខ ចំពោះសារីកថា មិនត្រូវយល់តាមគេដឹកនាំខ ព្រោះថា សាសនាពោលថា ឬ គ្រូចាន់អាចារ្យប្រដៅថា ត្រូវតែខ្លួល ប្រព្រឹត្តប្រតិបត្តិតាម ដោយហេតុថា ខ្លួនឯងស្គាល់ជាក់ច្បាស់នូវកុងនោះ។ ហើយចាន់ពីសោធម៌ស្គាល់ជាក់ច្បាស់ថា វត្តុនោះ មានសភាពពិតមែន ដោយខ្លួនឯងដែរមែនទែន ។ ព្រះអង្គទ្រង់យល់ជាក់ច្បាស់ថា បញ្ញាមនុស្ស មិនត្រូវចូលទៅជារណប នៃបញ្ញាដនដទៃ, ត្រូវតែគិតឲ្យយល់ច្បាស់ ដោយខ្លួនឯង ហើយការសម្រេចនូវសច្ចធម៌ មិនត្រូវមានបុគ្គលដទៃ ឬវិធានការ វិន័យដំខ្ទើរទាំងឡាយ ឬ លទ្ធិណាមកចង្ខិំឲ្យរៀ ដោយ ប្រើអំណាចហួសប្រមាណនោះទេ ។

សេរីភាពនៃចិត្តនឹងការសន្តោស ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់ខ្ចាន ហើយ មិនដែលមានក្នុងសាសនប្រវត្តិណាឡើយ ។

កាលមួយថ្ងៃ មានបុរសម្នាក់ជាអ្នកមានទ្រព្យសម្បត្តិ ព្រមទាំង ភរិយាដ៏មានប្រាជ្ញាស្ត្រី នាមថាឧបលី ដែលសាសារីតនៃខត្តុន្តនាផមុត្ត (ដែនមហាវិហារ) ចាន់បញ្ជូនាក់ថា បំណងចង់សុំធ្វើឧបាសកនៃព្រះ

សម្តេច ។ តែព្រះសម្តេចទ្រង់មានព្រះបន្ទូលទៅគាត់ទុកជាថា: ចូរអ្នក
ពិចារណាឲ្យម៉ត់ចត់សិន ក្នុងរឿងនេះ ហើយកុំប្រញាប់ប្រញាល់ពេក។

លុះទុកជាបានបញ្ជាក់ជាច្រើនដងទៀត, ព្រះដ៏មានព្រះភាគទ្រង់
យល់ព្រម ឲ្យទុកជាបួលមកធ្វើទុក្ខសុខបាន, ហើយទ្រង់ត្រាស់ថា កុំលះ
បង់ការគោរព នឹងតិចជួយឈឺផ្តាស ចំពោះគ្រូចាស់របស់ខ្លួន ដូចពី
កាលមុនមក ។

កាលពីសតវត្សរ៍ទី៣ មុន គ.ស. ព្រះបាទអធិរាជ, ព្រះអសោកនៃ
ប្រទេសឥណ្ឌា ព្រះអង្គបានកាន់ពុទ្ធសាសនា បានប្រើព្រះពលមនុស្ស-
ជាយ ដើម្បីនឹងផ្សាយព្រះពុទ្ធសាសនា ទៅក្នុងតំបន់លោកទាំងមូល
ដោយកាន់ព្រះពន្ធប្តូរយសន្តោស នឹងការយោគយល់គ្នាទៅវិញទៅមក
គោរពសាសនាជនៃទៀត ទៅក្នុងអធិប្រទេសរបស់ព្រះអង្គ ។ នៅ
លើព្រះពន្ធតម្រាស ដែលទ្រាក់ក្នុងសិលាព្រះអធិរាជ ទ្រង់បានប្រកាសថា:
"គេមិនត្រូវគោរពសាសនារបស់ខ្លួន ហើយប្រមាថមើលងាយសាសនា
អ្នកដទៃ ដោយយកសង្ឃា ចំពោះសាសនារបស់ខ្លួនទេ ; ធ្វើយ៉ាង
នេះឈ្មោះថា ធ្វើឲ្យអាប់ឧនដល់សាសនារបស់ខ្លួន ; ព្រោះ
ហេតុដូច្នេះ ការព្រមព្រៀងគ្នា ត្រូវតែលែលកឲ្យបានស្រួល ព្រោះថា:
អ្នកទាំងអស់ត្រូវស្តាប់ ឬ ត្រូវចង់ស្តាប់លទ្ធិរបស់ជនដទៃ" ។

ខ្ញុំចង់បន្ថែមថា: "ការប្រព្រឹត្តប្រតិបត្តិតាមព្រះពុទ្ធសាសនា ក្នុង
ការយោគយល់គ្នាទៅវិញទៅមក ដោយសមានចិត្ត ត្រូវតែយកមកអនុ-
វត្ត ក្នុងសម័យបច្ចុប្បន្ន មិនត្រឹមតែលទ្ធិសាសនាទេ ថែមទាំងលទ្ធិជាតិ

និយមនយោបាយ "សង្គមនិយមសេដ្ឋកិច្ច" ។

អ្នកជ្រាបស្រាប់ហើយថា តាំងតែពីបឋមសតវត្សទី ១៦ ពួកពុទ្ធសេស៍ បានមកតាំងនៅតាមខែត្រមាត់សមុទ្រ ប្រទេសស៊ីឡង់ អស់រយៈវេលាមួយសតវត្សរ៍ ។ ពួកពុទ្ធសេស៍ជាពួកអធិម្មត្តខាងសាសនាកាតូលិក ហើយក៏ធ្វើពុំណាកម្ម ដល់ពួកពុទ្ធមកជនប្រទេសស៊ីឡង់ ដើម្បីបង្ខិំពួកនេះ ឲ្យចូលទៅកាន់សាសនារបស់ខ្លួន; ពួកពុទ្ធសេស៍នេះ ទៅជាប្រព្រឹត្តបទខ្ញែកដ្ឋយ៉ាងកាចសាហាវ ។ លំដាប់តមក នៅកណ្តាលសតវត្សទី ១៧ ពួកជនជាតិហុលឡង់ ដែលកាន់សាសនាប្រូតេស្តង់ បានមកធ្វើសង្គ្រាមនឹងពួកពុទ្ធសេស៍មានជោគជ័យ កំមកបិតនៅតាមខែត្រមាត់សមុទ្រ ហើយក៏ធ្វើពុំណាកម្ម ចំពោះពួកជនជាតិពុទ្ធសេស៍ ដែលកាន់សាសនាកាតូលិក ។

ពួកពុទ្ធសេស៍ ក៏បានទៅគ្រាបបង្គំគាល់ព្រះមហាក្សត្រ ប្រទេសស៊ីឡង់ សូមឲ្យទ្រង់ជួយទំនុកបម្រុងផង ។ ព្រះមហាក្សត្រទ្រង់ជាអ្នកកាន់ព្រះពុទ្ធសាសនា ទ្រង់បានជ្រាបច្បាស់លាស់ អំពីពុំណាកម្ម ដែលពួកពុទ្ធសេស៍ បានធ្វើចំពោះពួកពុទ្ធសាសនិកជន នៅខែត្រមាត់សមុទ្រ តែទ្រង់មានបារមីធម៌ ខ្ពង់មហាសប្បុរិសធម៌ ទ្រង់ក្តៅចន្លូវរឿងក៏រំងាំនោះ ហើយក៏អត់ទ្មន់ទ្មរ់ទោសពាំងអស់ មានព្រះពាជឌ្ឋារថា: ចូរអ្នកអញ្ជើញមកចុះ សាងព្រះវិហារបស់អ្នក, ចូរអ្នកប្រព្រឹត្តប្រតិបត្តិ តាមសាសនារបស់អ្នក នៅក្នុងព្រះពាជអាណាចក្ររបស់ខ្ញុំ ដោយសន្តិសុខចុះ ។

កន្លងសម័យមួយវែងនេះ, នៅក្នុងវត្តពុទ្ធសាសនាប្រទេសស៊ីឡង់, មានពួកនិស្សិតក្រែជាង ទើមមហាម៉ាត់បិតនៅសិក្សារៀនសូត្រ ទើបបព្វជិតខាងពុទ្ធសាសនា ។ ខ្ញុំបានទឹកឃើញថា នៅវិទ្យាល័យវិទ្យាល័ង្កដែលខ្ញុំបានគោលមកហើយ, យើងមាននិស្សិតមួយ កាន់សាសនាគាតូលិក នៅតង់ក្នុងវត្តនោះ ពាល់ថ្ងៃអាទិត្យ ពេលព្រឹក ចៅអធិការវត្តបានស្រែកហៅយុវនោះ ហើយលោកញញឹម មានពុទ្ធដីកាថា: " លៅ (នេះគឺនាមយុវ) ឥឡូវនេះជាថ្ងៃអាទិត្យ អ្នកត្រូវទៅព្រះវិហារឬ ! " ។

ចំណែកឯជនជាតិស៊ីឡង់ កាន់សាសនាគាតូលិក ដែលរស់នៅក្នុងបរិវេណពុទ្ធសាសនាច្រើន មានចិត្តសន្ធោស ជាងពួកគាតូលិក នៃប្រទេសឯទៀត ។ ឧទាហរណ៍, ដូចជាគាលពួកគាតូលិក បានអញ្ជើញខ្ញុំម្ចាស់ មកធ្វើសន្ទិសីទ ។ ខ្ញុំមិនបានពិណានាព័ត្រពុទ្ធសាសនាទេ, ខ្ញុំពោលតែត្រឹស្តសាសនាដោយពន្យល់អំពីតារសិក្សាព្រះយេស៊ូគ្រិស្ត តាមតម្លាដែលខ្ញុំបានអានជាច្រើនផង ដោយសេចក្តីគោរព ។ មានពេលខ្លះ, មានលោកសង្ឃ ខាងត្រឹស្តសាសនា ត្រូវតែនិមន្តមកកាន់តែពិធីបុណ្យនៃពុទ្ធសាសនា ។

ការសន្ទោសនឹងសមានចិត្ត ប្រកបដោយសេចក្តីយោកយល់គ្នា ទៅវិញទៅមក ដែលមានមេត្តាសាកលនឹងតតិបណ្ឌិតជាយ៉ាងជ្រាលជ្រៅ ជាមូលដ្ឋាន ជាឧត្តមគតិមួយនៃប្បធម៌ នឹងអារ្យធម៌ព្រះពុទ្ធសាសនា តាំងតែបឋមសម័យរហូតមកដល់បច្ចុប្បន្នសម័យ ។ ព្រោះហេតុដូច្នេះពិតមែនតែព្រះពុទ្ធសាសនាផ្សាយទូទៅក្នុងទ្វីបអាស៊ីដោយសន្តិវិធី ហើយបាន

ប្រមូលសាវ័ក ក្នុងពេលឥឡូវនេះ ចានចំនួនជាង ៥០០ លាននាក់ គេមិនដែលដួចប្រទេះខ្លួនតែណាមួយ ខាងគារុណកម្មសាសនា ឬឈាមមួយដំណក់ធ្លាក់ដល់ដី ក្នុងនាមព្រះពុទ្ធសាសនា ចំពោះពុទ្ធប្រវត្តិ ដែលមានមកតាំងពី ២៥ សតវត្សរ៍ ។

ព្រះពុទ្ធសាសនា មានសភាពប្រកប ដោយវិចារណញ្ញាណនឹងលក្ខណៈទំនើប ចានត្រមត្រៀងខ្លួនរួមរួនភាពខាងសង្គម, សេដ្ឋកិច្ច, បញ្ញា, វិមុត្តិ ។ ព្រះបរមពុទ្ធាក់ទង់ដ៏បំខាន់ គឺថាវត្តពាំងអស់មិនខ្វៀងហើយមានសភាពប្រែប្រួលជាធម្មតា ។ ព្រោះហេតុដូច្នេះ, ការប្រែប្រួលខាងសង្គម, នយោបាយ,សេដ្ឋកិច្ច ឬវត្តិឯទៀត, ចំពោះព្រះពុទ្ធសាសនា ជាទម្លាប់ធម្មតា ។ សរុបទៅថា វិឌ្ឍនភាព គឺការប្រែប្រួល,ការចលនា ហើយមានសភាពមិនបិតថេរ ។ ចំណែកខាងចំណុចសេដ្ឋកិច្ចនយោបាយ ក៏ដូចគ្នា ព្រះពុទ្ធសាសនាជាសាសនា ប្រកបដោយសម័យបច្ចុប្បន្ន ។

គេចានយល់ព្រមអនុមតជាសាកលថា ដើម្បីនឹងឲ្យចម្រើនសុខុមច្ឆល ទឹងបិលធម៌នៃប្រជាពស្ត្រ, ដ៏វិភាគសេដ្ឋកិច្ចប្រជាពស្ត្រនេះ ត្រូវតែលើកតម្កើងជាអហំការ ។ តាំងពី ២៥ សតវត្សរ៍មកហើយ, ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះពន្ធនាន់ព្រះឱដ្ឋថា អ្នកកាន់តាបប្រទេសចានពិះសាធចង់បំបាតបទនក្រិដ្ឋ .ដោយឆ្លើងណាកម្ម ចំពោះអ្នកប្រព្រឹត្តបទនេះហើយជាកិច្ចមិនចានការ ព្រោះថា ដើម្បីបំបាត់នូវបទនក្រិដ្ឋ, ព្រមទាំងតម្កើងនូវសីលធម៌បុគ្គលនោះ, ត្រូវធ្វើស្ថានភាពខាងសម្ភារៈនៃបុគ្គល

នោះ ត្រូវបានបម្រើនតាមលំដាប់ ។

ពេលដែលព្រះសម្មាសម្ពុទ្ធទ្រង់ទេសនា ចំពោះគ្រហស្ថថា មានសុភមង្គល ៤ យ៉ាង គឺ ១. សន្តិភាពសេដ្ឋកិច្ច; ២. គ្មានបំណុល; ៣. សិទ្ធិប្រើប្រាស់ទូរទស្សន៍ចាយ ចំញឹមដ៏តែ បានដោយសេរី; ៤. បំពេញដ៏ភាពប្រកបដោយគុណធម៌ រឿរលែងទូរទាបអកុសលទាំងអស់ ។ យើងសូមរំលឹកនៅទីនេះថា បើតាមព្រះពុទ្ធសាសនា លំដូគោលទាំងពីរ សម្ភារៈទាំងប្រាជ្ញាជាការចាំបាច់ ដើម្បីឲ្យកើតសុភមង្គលដល់មនុស្សជាតិ ។ ចំណែកខាងបច្ចុដែត ក៏ដូចគ្នា, ដើម្បីទាំងធ្វើសមាធិកម្មដ្ឋានឲ្យបានគេញលេញ ប្រកបដោយសប្បាយត្រប់ប៉ាង ត្រូវតែមានទ្រព្យសម្បត្តិត្រប់គ្រាន់ ។ តើថាការគួរសរសើរថា ព្រះពុទ្ធសាសនាដែលជាសាសនា ប្រកបដោយមង្គលធម៌ ទាំងប្រាជ្ញាមិនបានកូចខ្ទួរសារៈសំខាន់នៃមូលដ្ឋានសេដ្ឋកិច្ច ។ មានមួយថ្ងៃ ព្រះអនាវញ្ញាណ ទ្រង់សំដែងថា ជាបអកុសលធំជាងគេ គឺការស្រេកឃ្លាន ហើយព្រះអង្គក៏ឈប់ចង្អុលមិនបានទេសនា, ពាល់តែមានមនុស្សម្នាក់អត់អាហារ បានអាហារបរិភោគ, ទើបព្រះអង្គទេសនាតទៅទៀត ។

នៅទីនេះ យើងត្រូវលើកយ៉ា បើតាមព្រះពុទ្ធសាសនា យសស័ក្តិជាមធ្យោបាយ ដើម្បីទៅកាន់វត្ថុបំណងមួយ ។ ទ្រព្យសម្បត្តិមិនមែនសម្រាប់ឲ្យយកមកគរទុកទេ គឺសម្រាប់ឲ្យប្រើប្រាស ។ ការប្រមូលទូរយសស័ក្តិដោយសេចក្តីលោភ ប្រកបដោយអត្តទត្ថភាព ក៏ព្រះអង្គមិនឲ្យធ្វើដែរ ការបែងចែកគោតទ្រព្យ ជាប្រយោជន៍ទាំងអស់គ្នា, ព្រះអង្គសរសើរ។

ខ្ញុំបានពោលមកហើយថា ព្រះពុទ្ធសាសនាជាកត្តាវង់ជាតំនៃទ្វីបអាស៊ី ហើយមានអានុភាពធំ ចំពោះទ្វីបនេះខាងកូមិភាគអគ្នេយ៍ ។ ព្រះពុទ្ធសាសនាជាជំនួយចំពោះដីភាពថ្មីនៃសង្គម, នយោបាយសេដ្ឋកិច្ច ដែលកាន់តែបញ្ចេញរូបភាពច្បាស់ច្រើយជាក់ស្តែងនៅទ្វីបនេះ ។

ក្រោយដែលប្រទេសចាំងឡាយ នៃកូមិភាគអគ្នេយ៍ទ្វីបអាស៊ី បានឯករាជ្យ ប្រទេសនេះច្រើនមានទំនាក់ទាក់ទងលទ្ធិសង្គមនិយម ដែលបម្រើនដុះដាលនៅកូមិភាគនេះ ។ លទ្ធិសង្គមនិយមនេះ មានសភាពដូចគ្នានឹងលទ្ធិសង្គមនិយម នៃប្រទេសស្កង់ឌីណាវ (ប្រទេសស៊ុយអែត នរវែស, ដាណាម៉ាកជាដើម) ។ លទ្ធិសង្គមនេះ ដែលនឹងបម្រើនរុងរឿងបាន នៅទីនេះ ដោយសារព្រះពុទ្ធសាសនា ។

ខ្ញុំអាចជូនដោយជាក់ស្តែង នូវឧទាហរណ៍មួយ:- លោកអ្នកប្រហែលជាបានជ្រាបស្រាប់ហើយ, នូវរដ្ឋាភិបាលសង្គម តាំងពីខែមេសា ១៩៤៥ ដែលមាននៅប្រទេសស៊ីរីលង្កា រដ្ឋាភិបាលអតីតៈជារដ្ឋាភិបាលអភិរក្ស នឹងមូលធននិយម ។ ក្នុងពេលបោះឆ្នោតជ្រើសរើសដំណាងរាស្ត្រ មានពួកកុំម្មុនីស្ត៍ជាច្រើនតាន់អង្គ បានចេញពីវត្តអារាមស្វាត់ដើម្បីមកប្រជុំ ជាសាធារណៈ ។ លោកមានតុទ្ធដីកាថា រដ្ឋាភិបាលអតីតៈជារដ្ឋាភិបាលប្រកបដោយបដិកម្ម ព្រមទាំងមូលធននិយម ហើយមិនអាចធ្វើប្រទេសឲ្យខ្សើនរៀងតាន់ភ្លាមភាពបានទេ ។ ព្រោះហេតុដូច្នេះ យើងត្រូវតែបោះបង់ចោលនូវរដ្ឋាភិបាលនេះ ហើយត្រូវជ្រើសរើសរករដ្ឋាភិបាលផ្សេងទៀត ទៅជារដ្ឋាភិបាលសង្គមនិយម ឬ បម្រើនជាតិ

ដែលនាំឲ្យបានផលដ៏ប្រសើរ ដល់ពួកប្រជាកសាំងឡាយ ។

រដ្ឋាភិបាលនោះ ក៏ភ្ញាក់ផ្អើលក្នុងបាតដ័យ ហើយគេបានជ្រើសតាំងនូវរដ្ឋាភិបាលសង្គមនិយមទីឯកម្រើនជាតិមួយ ដោយមតិភាគច្រើន ។ ប្រហែលជាមានវិចារណញ្ញាណអ្វីផ្សេងទៀត ចំពោះការប្រែប្រួលរដ្ឋាភិបាលនេះ, តែវិចារណញ្ញាណមានជាការគ្រៀបអត្ថបទសន្ធិសីទរបស់យើង ។

រដ្ឋាភិបាលអតីតៈ ជារដ្ឋាភិបាល មានឥទ្ធានុភាព ។ គ្មានអ្នកណាអាចដឹងបានថា រដ្ឋាភិបាលនេះខ្លួលបាតដ័យទេ ។ លោករដ្ឋមន្ត្រីទីមួយតែងថា គណៈប័ក្សខ្លួនប្រហែលជាបាន, យ៉ាងតិចត្រឹម ៧០ % ក្នុងចំណោមតំណាងរាស្ត្រទាំងអស់, ត្រឡប់ទៅជាបានតែ ៨ % ។ ក្នុងពេលសម័យជ្រើសតាំងនោះ គ្មានចលាចលវឹកវរអ្វីសោះឡើយ ។ គេបោះឆ្នោតដោយចិត្តស្ងប់ស្ងៀមជាយ៉ាងស្រួល ។ រដ្ឋាភិបាលមូលធននិយម មានវត្តានុភាពជាង ដែលគាន់តាប់ពាក្យរយៈមកហើយ ទៅជាលំ ។ ប្រទេសស៊ីឡង់បានបង្ហាញចំពោះនានាប្រទេស ត្រង់ទង្វើមួយជាយ៉ាងជាក់ស្តែង ។ យើងមិនត្រូវភ្លេចថា ប្រជាពលរដ្ឋនៃប្រទេសស៊ីឡង់, បុរសស្ត្រីបានឧទ្ទេសប្រើវិធីបោះឆ្នោតសាកល ក្នុងរយៈពេលមួយរយៈកាលមកហើយ ។

ខ្ញុំយល់ថា ការប្រែប្រួលនេះដែលធ្វើដោយសន្តិវិធី នៅប្រទេសស៊ីឡង់បានផលដ៏សំខាន់ ព្រោះថា វប្បធម៌ពុទ្ធសាសនា មានអានុភាពនៅក្នុងដីវភាពនៃប្រជាពលរដ្ឋនៅលើកោះនេះ អស់រយៈពេលជាងមួយពាន់ឆ្នាំមកហើយ ។

ព្រះសង្ឃខាងពុទ្ធសាសនា, នៅពេលបើកសម័យពាក់កណ្តាល, មានព្រះពុទ្ធដីកាថា ប្រទេសស៊ីឡង់ ត្រូវត្រឡប់ទៅកាន់សាធារណរដ្ឋសង្គមឯកភាពវិញ ហើយត្រូវតែចំណងសង្គមទាំងអស់ ត្រូវតែសម្រេចដោយប្រើមធ្យោបាយប្រកបដោយសន្តិវិធី ។

ខ្ញុំបានពោលមកហើយ អំពីប្រវត្តិសាស្ត្រនៃគោះគូបនេះ ដើម្បីបង្ហាញលោកអ្នក នូវអាកប្បកិរិយា នៃព្រះពុទ្ធសាសនា ចំពោះបញ្ហាសង្គម, សេដ្ឋកិច្ច, នយោបាយ ។

សេចក្តីសង្ខេបនេះ នឹងអាចបញ្ជាក់ឲ្យឃើញថា ព្រះពុទ្ធសាសនាបានបើកដោយសេរី ចំពោះទម្រង់ទាំងអស់នៃវឌ្ឍនភាពខាងចិត្ត, សីលធម៌ប្រជាសង្គមនឹងសេដ្ឋកិច្ច ហើយមានការណីយកិច្ច ដ៏សំខាន់បំផុតដែលត្រូវបំពេញក្នុងការសាងពិភពលោក នៅអនាគត ។ តែព្រះពុទ្ធសាសនា នឹងធ្វើយ៉ាងណាទៅ ?

តើត្រូវដាក់ចំពោះប្រជាពស្តូនូវនាមថា " ពុទ្ធសាសនិកជនឬ " ។ មិនមែនដូច្នោះទេ ។ នាមថា ពុទ្ធសាសនិកជន, គ្រិស្តសាសនិកជន, មហាមត្តសាសនិកជនឬហិណ្ឌូមិនមានតម្លៃទេ - ។ កិច្ចការដ៏ប្រសើរនេះ នឹងអាចធ្វើបាន ត្រូវបញ្ចូលទៅក្នុងអធ្យាស្រ័យមនុស្ស នូវសភាពពិតប្រាកដ ព្រមទាំងសេចក្តីចំរុះនៃការមេត្តាជាសាកល ប្រកបដោយសន្តិភាព, ចិត្តសន្តោសនឹងតតិបណ្ឌិតជាបរិយោសាន ។

ពុទ្ធភាសិតជាសារវន្ត

ក្នុងគម្ពីរធម្មបទដ្ឋកថា

ស្រី-អ៊ូ ក្រុមជំនុំព្រះត្រៃបិដក

រៀបរៀង

រឿងដើមនៃពុទ្ធភាសិត

ដំណាលអំពីស្ត្រីម្នាក់ឈ្មោះនាងបដាចារ នៅដឹកក្រុងសាវត្ថី ដែលត្រូវសេចក្តីទុក្ខជាខ្លាំងគ្រប់សង្កត់ គឺទុក្ខអំពីកូន ១ ត្រូវសត្វខ្វែងឆាបយក ទៅ, កូន ១ ត្រូវទឹកដីនន់កួចលិចស្លាប់ ក្នុងស្ទឹងអចិរវតី, ម៉ាតាបិតា ទីបងប្រុសរបស់នាង ត្រូវផ្លេះលើសង្កត់ស្លាប់អស់ ។ នាងបដាចារត្រូវសេចក្តីទុក្ខបែបនេះគ្រប់សង្កត់ ក៏រត់ទៅកាន់ស្មារតី ពេលមួយបានជួបព្រះបរមគ្រូ , ព្រះអង្គសំដែងតុច្ឆភាបិត ពន្យល់ឲ្យស្តាប់ , លុះចប់តុច្ឆភាសិតហើយ, នាងបដាចារ ក៏សម្រេចសេចក្តីទុក្ខសោក បានសម្រេចសោតាបត្តិផល មិនតែនាងបដាចារមួយប៉ុណ្ណោះទេ សូម្បីតួកជនដទៃជាច្រើន ដែលអង្គុយស្តាប់ជាមួយនឹងនោះ ក៏បានសម្រេចសោតាបត្តិផលដូចគ្នាដែរ ហេតុនេះហើយបានជា ខ្ញុំដកស្រង់តុច្ឆភាសិតនោះមកអធិប្បាយដូចតទៅ ៖

ន សន្តិ បុត្តា តាណាយ ន បិតា ន បិ ពន្ធវា
អន្តកេនាធិបន្នស្ស នត្ថិ ញាតីសុ តាណតា
ឯតមត្ថវសំ ញត្វា បណ្ឌិតោ សីលសំវុតោ

ឯញ្ជាឧភមនំ មក្តំ ទិប្បមេវ រំសោជយេ ។

ប្រែថា: បណ្ឌិតដឹងច្បាស់នូវអំណាចនៃហេតុនេះថា "កូនចាំងឡាយ មិនមាន ដើម្បីទីតឹង ឪតាក៏មិនមាន ដើម្បីទីតឹង ជនជាផៅពង្សចាំងឡាយ ក៏មិនមាន ដើម្បីទីតឹងបាន ជាវ ប៉ុន្តែលុះបើត្រូវសេចក្តីស្លាប់ត្រូវ សង្កត់ហើយ ក៏មិនមានទីតឹងចំពោះញាតិចាំងឡាយឡើយ" តម្រាំសង្រ្គម ស័ល ជម្រះផ្លូវសម្រាប់ផៅពាន់ព្រះនិព្វាន យ៉ាងឆាប់រួសពន់ ។

សេចក្តីអធិប្បាយ:

បុគ្គលគួរតិចារណានូវសេចក្តីសង្វេគឲ្យឃើញច្បាស់ថា ជនចាំងឡាយ ដែលកើតមកកន្លងលោកនេះ រកទីតឹងតំនាក់ឲ្យមាំមួននោះពុំមាន សុទ្ធតែជាអ្នកកំព្រាម្នាក់ឯង ទោះបីមានមាតាបិតា ស្វាមីភរិយា បុត្រធីតាញាតិសន្តាន ផៅពង្ស មិត្រសំឡាញ់ ទ្រព្យសម្បត្តិ ច្រើនគរគោក ក៏ដូចជាគ្មានព្រោះថា ជនចាំងឡាយមានមាតាបិតាជាដើមនោះ មិនអាចនឹងជួយការពារទប់ទល់នូវមរណសង្រ្គាម ដែលដំរង់ចំពោះរូបខ្លួនមួយៗនោះបានឡើយ។ បើមរណសង្រ្គាមដៅដំរង់មករូបបុគ្គលណាហើយ បុគ្គលនោះជាអ្នកកំព្រាឥតគ្នីគ្នាឡើយ បើបានជួបប្រទះនូវសេចក្តីទុក្ខ ដែលកើតអំពីអកុសលកម្ម ដែលខ្លួនធ្វើហើយ កន្លងពេលមុននោះ ក៏ត្រូវតែទទួលយកនូវសេចក្តីទុក្ខនោះភ្លាម ឬ បើជួបប្រទះនូវសេចក្តីសុខ ដែលជាលទ្ធផល នៃកុសលកម្ម ដែលខ្លួនបានកសាងស្អមកហើយ កន្លងពេលមុននោះ ក៏ត្រូវទទួលយកនូវសេចក្តីសុខនោះ ចំពោះខ្លួនមួយប៉ុណ្ណោះ មិនអាចចែកគ្នីគ្នាបានឡើយ ។

កាលបើបានពិចារណាឃើញច្បាស់ដូច្នេះហើយ កំនឹងយល់ច្បាស់ថា មនុស្សសត្វ បុរសស្ត្រីភាំងអស់ ទំនងរកគ្នាគ្មានពីនឹងពុំនាក់ឲ្យមាំមួននោះ ពុំមានឡើយ ឃើញតែគុណភាំងច្បាយ មានគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃទំនងមានសីលភាវនា ជាដើមនេះឯង ទើបជាទីពឹងជីវិសេស គាបជួយបង្កប្បគាំពារខំទុកបំរុង ក្នុងកាលដែលមរណៈសង្គ្រាម មកផ្តាច់ផ្តិលខ្លួរជីវិតន្ទ្រួយ របស់សត្វភាំងពួងនោះ ឲ្យបានសុខស្រួលរឿងពបជពបៀជល់លោកខាងមុខទៀតបាន ។

ដូច្នេះ តួរសន្ទូមសិល ជំរះសំអាតផ្លូវទៅកាន់ព្រះនិព្វាន ។

ឯផ្លូវសម្រាប់ទៅកាន់ព្រះនិព្វាននោះ មាន ៨ យ៉ាងគឺ

១- សេចក្តីយល់ត្រូវ,

២- សេចក្តីត្រិះរិះត្រូវ,

៣- ការពោលពាក្យត្រូវ,

៤- ធ្វើការងារត្រូវ,

៥- ការបិញ្ចឹមជីវិតត្រូវ,

៦- ការព្យាយាមត្រូវ,

៧- សេចក្តីរឭកត្រូវ,

៨- ការតាំងចិត្តខ្សឹងធឹងត្រូវ ។

ចប់សេចក្តីអធិប្បាយពុទ្ធភាសិតជាសារវន្តត្រឹមប៉ុណ្ណេះ ។

ផ្នែកអក្សរសាស្ត្រ

សកម្មភាពនៃក្រុមនិពន្ធទៀមធន្ធាប់ខ្មែរ

ដៅពុទ្ធសាសនបណ្ឌិត្យ

បរិយាយអំពី"ស្ត្រីភាព"

លោក ចាប ពិន រៀបរៀង

ពាក្យថា "ស្ត្រី" ដែលខ្មែរយើងភ្ជាប់ប្រើជាឈ្មោះមនុស្សស្រីនោះ ជាពាក្យសាមញ្ញប្រើក្នុងមកពី ស្ត្រី ជានាមស័ព្ទ ភាសាសំស្ក្រឹត ឆឺជាឈ្មោះភេទនៃមនុស្ស ១ ពួក ដែលខុសពីបុរស គឺខ្លួយ ។ ភាសាបាលីថា "ឥត្ថី" ប្រែតាមវចនានុក្រមខ្មែរថា "មនុស្សដែលបុរសគួរចង់ជាន, ដែលជាគូនឹងបុរស" ។ មនុស្សភេទនេះ បើហៅឲ្យចំតាមដើមកំណើតភាសា គឺត្រូវហៅថា "ស្ត្រី" ។

ពាក្យថា "ស្រី" មួយមាត់ទៀត ដែលខ្មែរយើងភ្ជាប់ប្រើរួមតាមដើមស័ព្ទជាដៃ ដូចជាស្រីសួស្តី, ព្រះស្រីសាក្យ, ពាដស័ព្ទថា ព្រះស្រីឥន្ទ (ស្វាចៀក) ព្រះស្រីបុណ្ណ (ស្វាបុក) ជាដើម នោះជានាមស័ព្ទ ភាសាសំស្ក្រឹត ។ ភាសាបាលីថា សិរិ ប្រែថា សួស្តី មង្គល ជាគ សេចក្តីសុខ សេចក្តីចម្រើន បុណ្យ កុសល ត្រូវនឹងសំណាង អំណាច តេជៈ ។

ខ្ញុំនេះ ខ្ញុំសូមលើកយកតែកេរ ទំនឹកគំណើរបស់ស្ត្រីមកអធិប្បាយ ដូចតទៅ :

ភេទរបស់ស្ត្រី : តាមធម្មជាតិ ជាកេរខ្សោយ សាច់ទន់ជ្រាយ កាយទន់ភ្លន់ ចិត្តទន់ធាប់ខឹង ធាប់ជា, ដូយពីកេរបុរសដែលជាកេរខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តរឹង ក្រៃចិត្ត ក្រជា ។

រឿងខ្សោយទឹងខ្លាំងនេះ មិនតែជាកេរមនុស្សជាស្ត្រីជាបុរសទេ សូម្បីតែកេរសត្វជាញីជាឈ្មោលក៏ដូចគ្នា ។

ការងាររបស់ស្ត្រី : ធម្មជាតិតាក់តែងស្ត្រីមក សម្រាប់ធ្វើជាមាតារបស់លោក សម្រាប់ចិញ្ចឹមបីបាច់ថែរក្សាគ្រឹះស្ថាន ទឹងគ្រួសសម្បត្តិ ។

តាំងពីដើមបឋមកប្បមក មនុស្សក្នុងលោកកាលតែប្រទេសគេនិយមទុកស្ត្រីឲ្យនៅតាមធម្មជាតិដើម គឺគេមិនឲ្យពួកស្ត្រីធ្វើការធ្ងន់ ជាការប្រើកម្លាំងខ្លាំង។ ដូចលើកជាក់ លើសែង កាប់គាស់ ជញ្ជក់ ប្លាំងកំងជល់ ជាដើមទេ, ការៈទាំងនេះ គេទុកជាការៈខាងពួកបុរស, ឯពួកស្ត្រីគេប្រើតែការស្រាលៗ ដូចស្ទូជណ្តាំ ដេរជ្រលាក់ ថែទាំកូនចៅជាដើម ដែលរួមយ៉ាងទូទីតបុរសៗជាអ្នកធ្វើការក្រៃ ស្ត្រីធ្វើការផ្លុះ ។

សម័យបុរាណ ប្រទេសខ្លះគេថ្នមពួកស្ត្រីដល់ទៅយកសំពត់ពុំដើងតាំងពីតូចៗ ដើម្បីមិនឲ្យដើរឆ្ងាយពីផ្ទះ ជាការទប់កេរស្ត្រីឲ្យនៅតាមធម្មជាតិ, ប៉ុន្តែឥឡូវ ប្រពៃណីនេះរលុបបាត់អស់ទៅហើយ ។

ប្រទេសយើង កំបណ្តោយពួកស្ត្រីឲ្យប្រព្រឹត្តទៅតាមធម្មជាតិ

ដើមដែរ, សម័យបុរាណអ្នកស្រុកមិនឲ្យពួកស្ត្រីរៀនអក្សរទេ, គេនិយាយបន្ទរចង្អាថា "មិនត្រូវឲ្យស្ត្រីរៀនអក្សរ ព្រោះរៀនចេះទៅនឹងសរសេរសំបុត្រទៅបុរសតាមអំពើចិត្ត" ។ ពាក្យបន្ទាបន្ទរនេះបានញុំាងស្ត្រីខ្មែរច្រើនតាំរយៈមិនឲ្យចេះអក្សរ, ប៉ុន្តែសម័យបច្ចុប្បន្ន ពាក្យបន្ទាបន្ទរនេះលុបរលាយបាត់ជិតអស់ទៅហើយ. គេត្រូវប្រាប់ថាប្រាប់គ្នាថា ត្រូវតែឲ្យស្ត្រីរៀនអក្សរគ្រប់គ្នាទៅវិញ ទើបប្រទេសជាតិបានសេចក្តីរុងរឿងចម្រើន ។

ពិតមែនតែធម្មជាតិតាក់តែងឲ្យស្ត្រីមានកេរខ្មាយ សាច់ទន់ជ្រាយតាយមិនរឹងប៉ឹង ចិត្តទន់ ប៉ុន្តែស្ត្រីអាចបង្ហាត់តាយរឹងបានតាមក្បួនអនា. ម័យអត្តពាសកម្មឲ្យរឹងប៉ឹង ឲ្យហ៊ានហ៊ុន, អប់រំចិត្តតាមក្បួនសិក្សាឲ្យមានប្រាជ្ញាវាងវៃប្រសប់លើសធម្មតាបាន មិនអន់ជាងបុរសប៉ុន្មានទេ ប្លែតែលមានគ្រោះបើជាងបុរសខ្លះដោយអនេ្តវាងផង បើប្រសិនជាគេព្យាយាមហ្វឹកហាត់ទឹងអប់រំម៉ឺងម៉ាត់មែនទែន ។

ការហ្វឹកហាត់អប់រំតាយចិត្តរបស់ស្ត្រីអាចឃើញលទ្ធផលជាក់ស្តែងដូចនិទានភាំងអតីតកាលទឹងបច្ចុប្បន្នកាលដែលនាំមកបញ្ជាក់តទៅនេះ :

សម័យមុនពុទ្ធកាលៈ មានស្ត្រីម្នាក់ឈ្មោះនាង "អ្នមរា" ជាមហេសីនៃព្រះមហាសថពោធិសត្វជាពជបណ្ឌិត នៃព្រះបាទវិទេហរាជ ។ ថ្ងៃមួយអាចារ្យភាំង៤នាក់ ដែលជាគូសត្រូវទឹងព្រះមហោសថបានលួចតែវណ៌ព្រះរាជទ្រព្យទៅលក់ឲ្យនាងអមរា, នាងបានទិញដោយកត់ភាំងៈឈ្មោះអ្នកលក់ ភាំងពេលទិញ, ហើយពួកអាចារ្យទូលព្រះមហាក្សត្រមួលបង្កាច់ថា ព្រះមហោសថលួច ។ ព្រះរាជាទ្រង់ព្រះរាជបញ្ជា

ឲ្យហៅព្រះមហាសថ។ ឃើញថាកែខ្ទេចពុំបាន ក៏ប្រាប់នាងអមកហើយ
គៀសខ្លួនសិនទៅ ។ ពេលនោះពួកអាចារ្យចង់បានឆ្នាងអមកជាតិយោ
ក៏ឲ្យដំណឹងថា ខឹងទៅជួបនាងក្នុងវេលាយប់ ទៅផ្ទះនាង។ឲ្យកម្មករជីក
រណ្តៅក្រោមផ្ទះដាក់លាមក ក្នុងរណ្តៅនោះក្រាលក្តារពីលើ ធ្វើគន្លឹះឲ្យ
ជាន់បន្តូចហើយក្រាលកម្រាលជូចអាសនៈធម្មតា ។ រីឯពួកអាចារ្យមក
ដល់ ដើរជាន់កម្រាលក៏ភ្លាត់ធ្លាក់ទៅក្នុងរណ្តៅនោះរណ្តំក្បាលគ្នា ។ នាង
អមកក៏ឲ្យចាប់អាចារ្យទាំង ៤ នាក់ ចងភ្ជាប់គ្នានាំទៅថ្វាយព្រះពុទ្ធ។
ព្រះអនិច្ចយថា កំហុសនេះធ្លាក់ទៅលើអាចារ្យទាំង ៤ ។ ព្រះមហាសថរួច
ខ្លួនដោយ ហេតុនាងអមកជាមហេសី ដែលជាស្ត្រីបានសិក្ខា មានប្រាជ្ញា
ច្រើនជួយដោះគុន ។

សម័យពុទ្ធកាល: មានស្ត្រីតម្កាត់ឈ្មោះនាងខុជ្ជុត្តរា ជាស្ត្រី
បម្រើពួកព្រះស្នំរបស់ព្រះបាទពន្ធុទត្តព្រះចៅក្រុងកោសម្ពី មានព្រះនាង
សាមាវតីជាដើម ដែលព្រះរាជាទ្រង់ហាមពួកព្រះស្នំមិនឲ្យចេញទៅស្តាប់
ព្រះធម៌ទេសនានៃព្រះសម្មាសម្ពុទ្ធឯក្រៅព្រះរាជវាំង ។ ព្រះស្នំទាំងនោះ
បានបាត់នាងខុជ្ជុត្តរាឲ្យទៅស្តាប់ ។ ហើយឲ្យទាំយកមកសំដែងប្រាប់ព្រះ
ស្នំ ។ នាងខុជ្ជុត្តរាបានស្តាប់បានសំដែងធម៌ ប៉ន្តែក៏បានទៅជាអ្នកប្រាជ្ញ
មួយរូបពូកែខាងសំដែងធម៌ បានលាភសក្ការៈច្រើន ។

មានន័យ១ទៀត ក្នុងសម័យពុទ្ធកាលដែរថា: មានស្ត្រីម្នាក់ឈ្មោះ
នាងកុណ្ឌលកេសី ជាកូននៃពាជគ្គហសេដ្ឋី នាងឲ្យសេដ្ឋីជាបិតាលោះបោរ
ម្នាក់ដែលត្រូវឃាតបណ្តើរទៅសម្លាប់ យកមកធ្វើប្តី ។ បោរមកនៅផ្ទះ

ស្តេចដ្ឋិហើយក៏និកថងំទៅនៅព្រៃវិញ ក៏លួងនាងឲ្យជូនវាទៅព្រៃ ដើម្បីលាបំណន់ក្បែរមាត់ជ្រោះនៅដើងភ្នំមួយ ក៏ឲ្យនាងស្លៀកពាក់ល្អ មានគ្រឿងមាសពេជ្រច្រើន ដើម្បីវាសម្លាប់យកគ្រឿងប្រដាប់លក់ស៊ីចាយ ។ លុះទៅដល់មាត់ជ្រោះ ចោរប្រុងសម្លាប់នាង។គិតថា "ប្រាជ្ញាដែលគេទំរៀនសូត្រមក គេមិនដែលប្រើជាអាហារទេ គេត្រូវតែប្រើដោះខ្លួនឲ្យផុតពីកំណែអាសន្ន" ។ លុះគិតហើយ នាងលួងចោរថា "អ្នកបង! ខ្ញុំជំនុតគុណណាស់ ដែលអ្នកបានមកធ្វើជាប្តីខ្ញុំនេះ មុនខ្ញុំនឹងខ្ញុំត្រាត់ចាកអ្នក ខ្ញុំសូមជូនជាគុណអ្នកសិន ហើយសឹមស្លាប់" ។ ថាហើយក៏សំពះទៅទិសទាំង ៤ ដើរប្រទក្សិណចោរ៣ជុំ ហើយប្រាន់ទម្លាក់ជ្រោះស្លាប់ទៅ ។

កាលដែលចោរធ្លាក់ជ្រោះ ពួកកុក្កុរតាដែលអាស្រ័យនៅព្រៃនោះ ក៏ស្រែកបន្ទំសាធុការព្រមគ្នាទាំងព្រៃថា :

ន សោ សព្វេសុ ឋានេសុ បុរិសោ ហោតិ បណ្ឌិតោ
ឥត្ថិបិ បណ្ឌិតា ហោតិ តត្ថ តត្ថ វិបក្ខណា ។

ប្រែថា: បុរសមិនមែនជាបណ្ឌិតគ្រប់ហេតុទាំងពួងទេ, ស្ត្រីក៏ជាបណ្ឌិតអាចតិចវាណាក្នុងហេតុនោះ។ដែរ ។

គឺថា: អ្នកប្រាជ្ញមិនមែនមានតែបុរសទេ, ស្ត្រីបើទំរៀនសូត្រចំណេះវិជ្ជាខាងឆ្ងាំលោកក្តី ខាងឆ្ងាំធម៌ក្តី ក៏បានជាអ្នកប្រាជ្ញដូចគ្នា ។

ប្រទេសកម្ពុជាសម័យនគរភ្នំ(ហ្វូណន) គ្រិស្តសតវត្សទី១:

ព្រះរាជ។ព្រះអង្គទ្រង់ចេញចាកប្រទេសតំណៀកខាងស្ងួន ចូល

មកកាន់ប្រទេសខ្មែរដំបូងបំផុត ។

ព្រះរាជាអង្គនេះខ្មែរហៅថា "ព្រះបាទកុមែរុ" តាមនាមវដ្ត ។ ព្រោះពាក្យថា កុមេរុ នេះហើយ បានជាក្លាយមកជាខ្មែរសព្វថ្ងៃនេះ ។

សៀមហៅថា"ព្រះបៅង"ប្រែជាខ្មែរថា"ព្រះអង្គមាស" ព្រោះព្រះអង្គមកប្រថាប់នៅជ្រោយគោះមាស (សុវណ្ណភូមិ);

ចិនហៅថា ព្រះបាទកៅណ្ឌិន្យ" តាមព្រះនាមដើមជាភាសាសំស្ក្រឹត ឬហៅម្យ៉ាងទៀតថា "ព្រះបាទបុំផនទៀង" ។

ព្រះរាជាអង្គនេះ បានធ្វើសង្គ្រាមទឹងព្រះរាជធីដី (ស្តេចស្រី) ទ្រង់ព្រះនាម"លៀវ៉ាយី" ដែលខ្មែរហៅថា"ព្រះនាងសក់ស្រអូប" ខ្លះហៅថា"ព្រះនាងនាគី" ព្រោះទ្រង់ព្រះសម្ពត្តពពាប់នាគ, តែតាមពិតព្រះនាងនេះមិនមែនជានាគទេ គឺព្រះរាជធីតានៃព្រះបាទអស្សវៃពាជ (ស្តេចចាមទី ៩) ដែលទ្រង់ព្រះចំរើនតែ មានតែព្រះរាជធីតានេះឡើងសោយរាជ្យតព្រះរាជវង្ស, ព្រះនាងនេះនៅលីវបានជាខ្មែរដាក់នាមហៅថា "ព្រះនាងនាគ"ព្រោះនាគប្រែថា ប្រសើរ ថាមវិសុទ្ធ គឺពុំមានបុរសប៉ះពាល់ ដូចកូនការបំបួស គេតែងហៅកុលបុត្រដែលគោរពរក្សាទឹងចួលបួសថា "នាគ"នោះឯង ។

កាលព្រះរាជធីតាលៀវយីចាញ់សង្គ្រាមហើយ ក៏សត្វព្រះរាជហ្លួងយកទ្រង់ព្រះរាជទានកុមេរុជាព្រះស្វាមី អតិសេកសោយរាជ្យនៅនគរភ្នំ

"ភ្នំ" ព្រះមហាក្សត្រអង្គនេះហើយជាដើមព្រះពាជវង្ស តំព្រះពាជបល្ល័ង្ក ទី ១ នៃប្រទេសកម្ពុជា ។ រឿងនេះសឲ្យឃើញថាប្រទេសខ្មែរដំបូងបំផុត មានស្ត្រីជាស្តេចគ្រប់គ្រង ។

* * *

សម័យអង្គរ (គ្រិស្តសតវត្សទី ១៣):

សិលាចារឹកនៅប្រាសាទអង្គរពោលថា "ព្រះនាងអគ្គមហេសីនៃព្រះបាទជ័យវរ្ម័នទី ៧ តូចកលើសលុប ឥតនរណាស្មើខាងវិទ្យាសាស្ត្រ ទឹងបរមត្ថសាស្ត្រ ព្រះពាក្យទ្រង់តាំងជាព្រះបរិនាយិកាចារ្យក្នុងព្រះអាគម ព្រះពុទ្ធសាសនាដ៏ល្បីល្បាញ ១ ព្រះនាងបានបង្រៀនពួកស្ត្រី" តំព្រះនាងនេះហើយ ដែលធ្វើឲ្យយើងដឹងដោយសិលាចារឹកយ៉ាងធំ ១ នៅប្រាសាទតាមានអាកាស ដែលព្រះនាងតែងដោយព្រះអង្គឯងថា "ព្រះនាងគង់នៅក្នុងទី ១ ឈ្មោះនរេន្ទ្រាស្រមជាទីសិក្សា ដែលពួកស្ត្រីពាជបរិពារមករៀនសូត្រ ព្រះនាងគំល្បីល្បាញក្នុងទីនោះ ដោយការគោរពរបស់បណ្តាសិស្សទាំងឡាយ ព្រះនាងជាអ្នកធ្វើឲ្យពួកស្ត្រីទាំងនោះបានសេចក្តីសុខ ទុបមាដូចជាទេវធីតាឈ្មោះសរស្វតីបែងភាគមក . . . ព្រះនាងបានផ្សាយសេចក្តីមេត្តាព្រះមហាក្សត្រ ចំពោះស្ត្រីណាដែលចូលចិត្តសិក្សាវិទ្យាសាស្ត្រ ទុបមាដូចជាទឹកចិត្តយ៉ាងប្រសើរដែលហូរចេញមកជាសេចក្តីចេះដឹង" ។

* * *

សម័យព្រះបរមរាជវាំងកោះស្លាកែត

(គ្រិស្តសករាជ ១៨៣៤ ដល់ ១៨៤១):

ប្រទេសកម្ពុជាមានស្ត្រីភាគ៨ព្រះរាជនី គឺព្រះអង្គ ម៉ី ក្សត្រី ព្រះ-រាជបុត្រីព្រះបាទ ចន្ទ័យរាជា (អង្គចន្ទ) ស្តេចឡើងសោយរាជ្យតំណាព្រះ-វរបិតាគង់នៅក្នុងព្រះបរមរាជវាំងកោះស្លាកែត (ត្រើយខាងជើព្រះបាទ) ក្នុងខេត្តកណ្តាលសព្វថ្ងៃនេះ ។ រជ្ជកាលនេះ ជារជ្ជកាលទី ៧៨ នៃព្រះរាជ-បល្ល័ង្កប្រទេសកម្ពុជា, មុនរជ្ជកាលព្រះករុណាបរមកោដ្ឋ (ព្រះអង្គឌួង) ដែលគង់នៅព្រះបរមរាជវាំងតុង្គឍ្គមានជ័យ ។

* * *

សម័យភ្នំពេញ (គ្រិស្តសករាជ ១៨៥៥):

ប្រទេសកម្ពុជាមានព្រះមហាក្សត្រ ២ ព្រះអង្គ គឺព្រះករុណាជា-អម្ចាស់ជីវិតលើត្បូង ព្រះបាទសម្តេចព្រះនរោត្តម-សុពម្រិត ជាព្រះរាជ-ស្វាមី នឹងសម្តេចព្រះមហាក្សត្រិយានី ស៊ីសុវត្ថិ-មុនីវង្ស-កុសុមៈនារី រ័តន៍សិរីវឌ្ឍនា ជាព្រះអគ្គមហេសី ទ្រង់ឡើងសោយរាជសម្បត្តិពីវៃ ទី ៣ ខែមីនា គ្រិស្តសករាជ ១៨៥៥ ជារជ្ជកាលទី ៨៤ នៃព្រះរាជបល្ល័ង្ក ប្រទេសកម្ពុជា តំណពីរជ្ជកាលទី ៨៣ នៃព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម-សីហនុ ជាព្រះរាជបុត្រដ៏ឆ្នើមនៃព្រះអង្គ ។

ស្រាវជ្រាវរឿងតាំងអតីតតាំងបច្ចុប្បន្ននេះមក ដើម្បីបញ្ជាក់ឲ្យ យើញថា: កេរស្តែដែលធម្មជាតិតាក់តែងមកជាកេរខ្ពើយ សាច់ជ្រាយ

កាយខន់ក្លំ ចិត្តមិនសូវរឹងប៉ឹងនោះ បើបណ្តាយខុសតាមធម្មជាតិក៏ខ្លាយតាមដើម ប៉ុន្តែបើគេបានអប់រំបន្ថែមនិស្ស័យដោយ ក្បួនអនាម័យក្បួនវិទ្យាសាស្ត្រ ទើបក្បួនសិក្សាយ៉ាងមុងមាត់ក៏ទៅជាមនុស្សខ្លាំង សាច់រឹង កាយរឹងប៉ឹង ចិត្តភូតែក្លាហាន មានប្រាជ្ញាជ្រាលជ្រៅស្មើនឹងបុរសដែរ ឬភូតែជាងបុរសខ្លះដោយអានុភាព ។ ក៏សឹងមាន ដូចនិទានដែលស្រង់មកតំណាលជាកស្តីតាងស្រាប់ ។

ព្រោះហេតុនេះ បានជាមនុស្សលោកសម័យបច្ចុប្បន្ន គេនិយមឲ្យស្ត្រីធ្វើពិធីហាត់ប្រាណ ដើម្បីឲ្យស្ត្រីមានសុខភាព ឲ្យរឹងប៉ឹង រហូតដល់អាចធ្វើជាគហាន ឬជាគេឲ្យគហានៈទៅប្រតិបត្តិការកន្លងទៅបាន, ឲ្យស្ត្រីរៀនអក្សរដើម្បីឲ្យមានប្រាជ្ញាជ្រៅជ្រះ រហូតដល់ធ្វើជាសាស្ត្រាចារ្យ ជាអ្នកកាន់ការគាន់មុះតំណែងធំ ៗ បាន, ឲ្យរៀនសិល្បៈរៀងគ្រប់បែបឲ្យបានជាសិល្បករ ហត្ថករ ទស្សហករ ណៃដ្ឋករ កសិករ កម្មករដ៏ជំនាញ ។ សម្រាប់ញុំាងសេដ្ឋកិច្ចរបស់ប្រទេស ឲ្យមានវិឌ្ឍនភាព ។ ល ។

ប្រទេសកម្ពុជាយើងសម័យបច្ចុប្បន្ននេះ ពរវរដ្ឋាភិបាលសង្គមកស្ត្រីនិយម មានសម្តេចព្រះបរមរាជ នរោត្តម-សីហនុ ព្រះបិតាឯកភាជ្ញាតិ ជាប្រជានទ្រង់បានស្តាបនាស្ត្រីខ្មែរជាតិ ជាអាទិ៍ តឹឲ្យស្ត្រីមានសិទ្ធិស្មើនឹងបុរស, អាចបោះឆ្នោតជ្រើសតាំងតំណាងរបស់ខ្លួន, អាចឈរឈ្មោះជាបេក្ខជនឹឲ្យគេបោះឆ្នោតជ្រើសតាំងខ្លួនជាតំណាងកស្ត្រីទៅគាន់រដ្ឋសភា, អាចធ្វើជារដ្ឋសភាបាន, ឲ្យស្ត្រីហាត់ប្រាណតាមអត្តពល-

កម្មវិធី ទៅមានពាក្យពេចន៍ប្លែកៗ មានសុភាព ឲ្យហាត់គាន់កាំភ្លើង, ដូចក្នុងវិធីនការព្រះសីហនុ ដែលតាំងស្ត្រីខ្មែរ ឲ្យជានាំក្បាហានដំណាលគ្នានឹងបុរស ដែលតាំងជាកងជីវពល គាន់កាំភ្លើងប្រតិបត្តិការសាមគ្គី មានជោគជ័យដកបដល់ដណ្តើមយកឯករាជ្យពេញទី ដូនមាតុប្រទេសបាន ពីថ្ងៃទី ៩ ខែតុលា គ. ស. ១៩៥៣ ។

ខ្ញុំមានសេចក្តីសង្ឃឹមថា អនាគតដ៏ខ្លីនៃប្រទេសកម្ពុជាយើង មុខតែបានភ្លឺត្រចះដោយសារស្ត្រីខ្មែរ ដែលនាំគ្នាសិក្សាអក្សរសាស្ត្រ សិល្បៈសាស្ត្រនឹងវិទ្យាសាស្ត្រត្រប់ថែបយ៉ាងតាមវិធីនការដែលសង្គមកស្ត្រីទាំងមានបន្តម្តងហើយដើម្បីធ្វើប្រទេសជាតិមាតុភូមិឲ្យបានសុខចម្រើនថ្កើងរុងរឿងតាន់សម័យដូចអារ្យប្រទេសនានានៅក្នុងសកលលោកជាច្រើនដទៃ ។

ចប់

ស្ត្រីជាតិសាសនាប្រទេសជាតិ
អាចជួយប្រុសជាតិសាសនាកម្មការ
ជួយជាតិសាសនាច្រើនក្បួនច្រើនប្រាប
យោធនដ៏សំណាងស្រីយោធប្រុស ។

លោកហ្សង់ស្វាស់ ម៉ារទីន៉ រៀបរៀង

លោកវ៉ាយ-ប៊ុក ប្រែមកជាភាសាខ្មែរ

ខ្ញុំមិនបានដឹងថា អ្នកណាជាបឋមដែលសរសេរថា ភាសាខ្មែរមកពីភាសាសំស្ក្រឹត ។ តែការភាន់ច្រឡំនេះ គឺតរឡើងដោយអ្នកនិពន្ធដែលមិនសូវមានវិជ្ជាខាងភាសាស្ក្រឹត ចេះតែចំឡងតាមគ្នាទៅរឿយៗមក ។ អត្ថបទនេះ សម្រាប់ពន្យល់បំភ្លឺអ្នកអាននៅចំណុចនេះ, ហើយមិនបានអះអាងថា ខ្លឹងតណាមានខ្ទង់ភាសាខ្មែរ ដោយសំដែងខ្លួលគួរតែលឲ្យពេញលក្ខណៈទេ ។

អ្នកដែលមិនបានខ្វល់ពីតិមានច្បាស់លាស់, ច្រើនភាន់ច្រឡំភាសាទីឯ អក្សរ ។ គឺ ចំពោះតែអក្សរខ្មែរ ដែលត្រូវពោលបានថា អក្សរនេះមកពីអក្សរឥណ្ឌៀ ។

តួអក្សរខ្មែរ គឺ គេខ្ចីតួអក្សរបស់ប្រទេសឥណ្ឌៀខាងត្បូង យកមកប្រើក្នុងសតវត្សរ៍ទី៦ ។ តួអក្សរខ្មែរដែលសម្រាប់ប្រើសព្វថ្ងៃមានពីរបែបគឺតួច្រឹងមានសភាពត្រេត ដែលសម្រាប់ប្រើជាសាម័ញគឺលិខិតសរសេរដៃឬចោះពុម្ព អត្ថបទរដ្ឋបាល សៀវភៅ ឬ សារពត៌មាន ។ តួ"មូល" គឺមានទម្រង់មូល ជាអក្សរសរសេរយឺត ហើយធ្ងិតធ្ងន់ថែមទៀត សម្រាប់ចំឡងអត្ថបទ ខាងសាសនាជាភាសាបាលី ។ តែគេច្រើនប្រើតួអក្សរធំដើម្បីយកទៅបរសេរចំណងដើងសៀវភៅ ពាក្យដែលគេតួសចំណាំតួងអត្ថបទជាអក្សរច្រឹង ឃើហោពាណិជ្ជកម្ម អក្សរជារឹតនៅក្នុងទ្វារគ្រឹះស្ថានជាសាធារណៈ ។

អក្សរបោះពុម្ព មិនមែនមានសភាពផ្សេង ពីអក្សរសរសេរដែរ ។

ឥឡូវនេះ គ្មានបុគ្គលណាមិនដឹងថា ភាសាសំស្ក្រឹតដែលជាភាសាអក្សរសាស្ត្រ សម្រាប់សិក្សារៀនសូត្រនោះប្រទេសឥណ្ឌៀ កើតឡើងដោយអំបូរភាសាឥណ្ឌូ-អើរ៉ូប៉ៀអែន, គឺថា ភាសាសំស្ក្រឹត មានប្រភពដូចគ្នានឹងភាសា សម្រាប់សិក្សា គឺភាសាក្រិកនឹងឡាតាំង ។ គឺជាត្រួយមួយពន្លកចេញពីដើមជាមួយគ្នា ដែលជាទីកើតនៃភាសាស្ងារ, សែរម៉ាន់ឯក នឹងថ្មាល់ឯក ។

អ្នកណាដែលបានសិក្សារៀនសូត្រខ្លះភាសាទាំងនេះ , បើទុកណាជាអ្នកនោះមិន មែនជាអ្នកស្ទាត់ជំនាញ ខាងវិជ្ជាភាសាសាស្ត្រ, តង់តែយល់ច្បាស់ថា សព្ទខ្មុសាស្ត្រ សូរសាស្ត្រ ទឹងវេយ្យាករណសាស្ត្រនៃភាសានោះ មានសភាពប្រហែល ។ គ្នា ដែលគេអាចសំគាល់បាន ។ មិនចាំបាច់ចេះភាសាឡែរច្រើនទេ ដើម្បីនឹងឲ្យយល់ថា ភាសាខ្មែរមានសភាពផ្សេងពីភាសាអើរ៉ូប៉ៀអែន ។

ភាសាខ្មែរដែលខុសគ្នាស្រឡះ ពីភាសាសំស្ក្រឹត, គឺភាសាឥណ្ឌូ-អើរ៉ូប៉ៀអែន, ជាភាសាដែលកើតឡើង ពីអំបូរភាសា ឥណ្ឌូប៉ុណ្ណោះដែលហៅថា ភាសាមនខ្មែរ ព្រោះថា ភាសាខ្មែរ នឹងភាសាមន ដែលគេនិយាយនៅប្រទេសកូមាខាងក្រោម ជាសាខាយ៉ាងសំខាន់នៃអំបូរភាសាឥណ្ឌូស៊ីណូ ។

ក្រៅពីភាសារៀតណាមដែលបំប្លែងមិនបាន បានជាឲ្យទៅជាភាសាចិនដោយភាគច្រើន, នៅឥណ្ឌូចិនមានភាសាសំខាន់ ៣ ក្រុម ឬពួកគឺ

-ភាសាថៃ(សៀម លាវ, គ្រាមភាសាថៃនៅប្រទេសភូមិភាគខាងលើ

-ឥណ្ឌូនេស៊ីយ៉ាង (ចាម, ជវ៉ា, ម៉ាដែ . . .) ។

-ភាសាមន-ខ្មែរ (ព័រ, ចូង, សាំរ៉ែ, ព្នង,,ស្តៀង, ភាគ . . .) ។

បើតាមពិនិត្យពួកភាសាទាំងអស់នេះ គេចមានសភាពដូចគ្នាជាច្រើនកន្លែង តាល់តែគេរួមពួកភាសាទាំងបី បញ្ចូលក្នុងអំបូរភាសាតែមួយហៅថា ភាសាអូស្ត្រូ-អាស៊ីអាទិក ។

ចម្បង, ភាសាខ្មែរដែលជាភាសាប្រជារស្ត្រ មានវាក្យន៍ស្តួចស្តើងក្រជាខ្លាំងបំផុត ត្រង់សព្ទ អរូបី (termes abstraits) ។ លុះដល់ជនជាតិខ្មែរបានទទួលសារវិទ្យាពីប្រទេសឥណ្ឌៀ ព្រមទាំងធ្វើស្ថាប័នសង្គម ទន់ឯសាសនាថ្មី,ជនទេនេះត្រូវខ្ចីពាក្យសំស្ក្រឹត យកមកប្រើប្រាស់ចំពោះពាក្យសព្ទរដ្ឋបាល, តុលាការ, ទន់អក្សរសាស្ត្រ ដើម្បីទន់យកពាក្យដែលបានមកពីបរទេស មកច្រៀបច្រើយដោយច្រើនជាខ្លួន ទន់ដរាបសម័យបច្ចុប្បន្ន ។ ហេតុនេះហើយបានជាគេតែងគេរៀនគេពោលថា ភាសាខ្មែរកើតមកពីភាសាសំស្ក្រឹត ; បើតាមពិត, ភាសាខ្មែរគ្រាន់តែខ្ចីសព្ទសំស្ក្រឹតយកមកប្រើប៉ុណ្ណោះ តែតមែនតែជនជាតិខ្មែរបានតម្កល់ទុកភាសាសំស្ក្រឹតជាភាសាវិញ្ញាជន, តែប៉ុន្តែ ភាសាសំស្ក្រឹតមិនដែលមានអានុភាពជាងភាសាអ្នកស្រុក ព្រោះថា តាមសិលាចារឹកបញ្ជាក់ថា តាំងពីបឋមសម័យភាសាខ្មែរ បានយកមកប្រើជាមួយនឹងភាសាសំស្ក្រឹត ។ ការដែលបញ្ជាក់ឲ្យឃើញនូវការប្រើប្រាស់ ដោយសេចក្តីសន្មតិ ឬ ដោយនិយមប្រជារស្ត្រ នូវភាសាសំស្ក្រឹតនេះ គឺថា អត្ថបទសំស្ក្រឹតទាំង

អស់ សុទ្ធតែសរសេរជាភាសាបាលី ។

ដល់ក្រោយមកទៀត, ក្នុងដើមសតវត្សរ៍ ១៩ ដោយព្រះពុទ្ធសាសនាហីនយាន ដែលមានអត្ថបទពិសិដ្ឋសរសេរជាភាសាបាលី ចូលមកដល់ទូទៅព្រហ្មញ្ញសាសនា ទើបពុទ្ធសាសនាមហាយាន, ភាសាខ្មែរ ក៏ចាប់យកពាក្យបាលីមកប្រើជាច្រើន ។ ការចម្រើនពាក្យនៃសព្ទានុក្រមខ្មែរ ដោយខ្ចីពាក្យបាលីយកមកប្រើ ចេះតែចម្រើនរាល់ ។ ថ្ងៃ, ជាលំដាប់តមក ។ តាំងពីប្រទេសកម្ពុជាចាប់ស្ថិតក្នុងសម័យអាណានិគមនិយមមក គេចាប់ផ្តើមឃើញការចលនានៃពាក្យខ្មែរ ឬការចម្រើននៃភាសាខ្មែរ ដោយហេតុថា អ្នកប្រែភាសាឬអ្នកនិពន្ធជាភាសាខ្មែរ ខ្វះអត្ថបទដែលត្រូវ, ដូច្នេះហើយ ឬអ្នកត្រូវការផ្តល់យោបល់តាមមាន តាមការសែតនិងវិទ្យុ ត្រូវប្រើពាក្យខ្លះជាការចាំបាច់ ។

ពត៌មានមួយ ត្រូវការតំណាល់ គឺនៅស័ព្ទ (ពាក្យថ្មី) ដែលចេះតែកើតឡើង ដោយគេញាប់ចិត្ត តែយកភាសាបាលី ជាមូលដ្ឋានច្រើនជាងភាសាសំស្ក្រឹត រឿងនេះ គឺមកពីជនជាតិខ្មែរសម័យបច្ចុប្បន្ន ស្គាល់ជាក់ច្បាស់នូវភាសាបាលី ជាងភាសាសំស្ក្រឹត ។ អ្នកអត្ថិម្ភាស់យត្តិវិទ្យាទ្រង់ទ្រាយ ស្តាបនានូវតែណាកម្មការមួយ សម្រាប់ប្រែច្បាប់ដ្ឋមន្ទីរថ្មី ដែលមានអត្ថបទដើមសរសេរជាភាសាបាលី ។ តណាកម្មការនោះ ច្រើនមានសមាជិក ជាសាស្ត្រាចារ្យសាលាបាលីជាន់ខ្ពស់ (ឥឡូវហៅថាសាលាតុន្តិកវិទ្យាល័យព្រះសុកម្រឹត) ឬ ជាពួកសុមេធពុទ្ធសាសនបណ្ឌិតជាសមាសភាព ។ មានរឿងមួយទៀត ដែលគេត្រូវតែតំណាល់, គឺថា ពាក្យចុះលើដែលបានព្រមព្រៀងយកមកប្រើ ដើម្បីបញ្ចូលទៅក្នុងវាក្យស័ព្ទ

ជាច្រើនភាសា ភាសាខ្មែរច្រើនមានសព្ទដូចគ្នា ទើបពាក្យដែលពួកសៀម បានយកមកប្រើហើយ ។ ដោយវាណាញ្ញាណគឺថា មានតិក្ខមគ្គខ្លះដែលមាន រឹង្ឋានទើបពួកសុមេធពុទ្ធសាសនបណ្ឌិតឬពាំនាំពីវាផ្នែក ដែលចះដឹងជ្រៅ ជ្រន្ធរវៃភាសាសៀម ហើយដោយមានបំណងយ៉ាងខ្លាំង, ចង់តម្រើកវប្បធម៌ របស់ខ្លួន ឲ្យកាន់តែចំរើនក្នុងកិច្ចស្វែងរកពត៌មាន អំពីវឌ្ឍនធម៌ ទើបវត្ថុ តំនល្បាយនៃជីវភាពទំនើប ពួកនេះមានវត្ថុនស្សនាវដ្តីទើបភាសែតសៀម ប៉ុណ្ណោះ ដែលគេទុកជាប្រភពនៃការស្វែងរកពត៌មានខ្លះ ។ តិក្ខសង្ឃ ដែលចេះភាសាថ្មីនិងបន្តិចបន្តួច ក៏រកបានដោយកម្រណាស់, ហើយតិក្ខ សង្ឃដែលមានសមត្ថភាពអានសៀវភៅ ជាភាសាថ្មីនិងបាន, ជាការកម្រ ណាស់ទៅទៀត ។ នៅប្រទេសកម្ពុជា, មិនមានទស្សនាវដ្តីទើនសារពត៌-មានផ្ទៃទេ (១), ចំណែកឯទីក្រុងថ្មីនិងកក មានសារពត៌មានទិនានុប្បវត្តិ, ទើនទស្សនាវដ្តីសង្គហៈទើនអនុមាស ជាពិសេសស្តីអំពីវិទ្យាសាស្ត្រ, វេជ្ជសាស្ត្រ, កសិកម្ម, អក្សរសាស្ត្រ, សាសនា, សេដ្ឋកិច្ច ទើនយោបាយ។ ពាក្យស័ព្ទបច្ចេកទេស, ប្រកបដោយច្រើនជាងជ្រាលជ្រៅ នៃទស្សនាវដ្តី ទាំងនោះ ច្រើនដកយកមកពីភាសាថ្មីលី ទើនភាសាសំស្ក្រឹត ។

ដោយមានការខ្ចីពាក្យយកមកប្រើ ចំពោះតែភាសាមួយដូចគ្នា ពិត មែនតែភាសាខ្មែរ ទើនភាសាសៀម មានអំបូរភាសាទុសគ្នាស្រឡះ ក៏ តែងតែមានបំណងទៅកាន់តួមជ្ឈន តើស្ថានៃភាសាដែលសម្រាប់ប្រើខាង

១- កំណត់នៃអ្នកប្រែ: លោកម៉ាំរ៉ូមីប្រហែលជាសរសេរអត្ថបទនេះក្នុងឆ្នាំ ១៩៦៥ ក្នុងពេលដែលប្រទេសកម្ពុជា មានទស្សនាវដ្តី ២ តំ ទស្សនាវដ្តីស្រុកខ្មែរ ១ ទស្សនាវដ្តីកម្ពុជ សុរិយា ១ ទើនសារពត៌មានតួតរវ័ត្ត ១ ផងដែរ ។

អក្សរសាស្ត្រ ទំនឹងវិទ្យាសាស្ត្រ ។

គោលការនេះ អាចធ្វើប្រជាពស្ត្រគាំងពីរនោះឯងបាន ដែលខ្លួនអារ្យធម៌ ពីប្រទេសឯណៅ ឲ្យមានមនោធម៌ នៃសមាគមន៍វប្បធម៌ប្រកបដោយពលភាពខ្លាំងខ្លៅ ។ ហើយបើគេយល់ថា ជនជាតិណាវ ដើម្បីទំនងធ្វើការសារបស់ខ្លួន ដែលមានសភាពប្រហែលគ្នា ទំនងការសៀម ឲ្យកាន់តែសម្បូរទាងពាក្យប្រើប្រាស់ សម័យបច្ចុប្បន្នបាន កំយកពាក្យនេះពីការសាចាលីដែរ ។ ការសាគាំងពីរ ដែលមានដើមតែមួយដូចគ្នា គឺការសាថៃបានចូលទៅជិតស្និទ្ធនឹងការសាខ្មែរ គាំងអក្សរសាស្ត្រទំនងបច្ចេកទេស ហើយគេអាចយើញថាជាការមានផលប្រយោជន៍ ការដែលស្រួលយាំងណាទៅចំពោះពាក្យសព្ទ ជំជ្រាលជ្រៅ ជាសម្ភហភាព ដែលអាចទំនងប្រើបាន ក្នុងកាលជាអនាគត ចំពោះការផ្សាស់ប្តូរវប្បធម៌ទំនងយោបាយរវាងប្រជាជាតិភាំងបី ដែលមានព្រំប្រទល់ជាប់គ្នា តាមភូមិសាស្ត្រ ។

ដោយហេតុថា ការសាខ្មែរមានពាក្យសព្ទអរូបីតិចណាស់ ទំនងពាក្យសម្ពន្ធ មានសភាពរឹងពន់ពេក, ការសាខ្មែរនេះ ក្នុងសម័យបច្ចុប្បន្នមិនអាចទំនងរបាទៀសម ទៅតាមតំនិតទំនើបបានឡើយ ។ តែយើងមិនអាចថា មិនបានការតែសោះនោះទេ ក្នុងពេលអនាគត ការសានេះអាចទំនងសម្រេច នូវលទ្ធផលដ៏ប្រសើរ គំមិនដឹងដែរ ។ ពាក្យសព្ទអរូបីទំនងបច្ចេកទេស កាន់តែចម្រើនពាស់ ។ ថ្ងៃ ដោយខ្លឹពាក្យសម្រាប់ប្រើប្រាស់ពីការសាសិក្សាប្រទេសឯណៅ, ហើយពាក្យសម្ពន្ធ អាចសម្រួលទៅបានដោយមានអ្នកទំនងពន្ធ មានប្រាជ្ញាចេះការសាខ្មែរទំនងបានពាក់ផង ។ ហេ

ដូច្នេះឯង ជាន់ជាការប្រតិបត្តិ នៃតិច្ចប្រែភាសាអើរ៉ូប៉ែអែន អាចនឹងធ្វើ
ទៅបានដោយងាយ តទៅជាអនាគត ។ តួនទាហរណ៍ដូចជាជន
ជាតិហ្វីណ្លា, ភាសាហ្វីណ្លាអូត្រីយែន (finno – ougrienne) ពីដើម
ជាស្មើនៃស៊ីវៃ្ស ជាន់សភាពុសគ្គា ទឹនស៊ីវៃ្ស ដែលជនជាតិហ្វីណ្លា
ជាន់ទិយមជាលំដាប់តមក តួនពេលដែលជនជាតិហ្វីណ្លា មកតាំនី
លំនៅ ។ តូមិភាគអើរ៉ូប៉ែអែន ។ បឋម, ជនជាតិហ្វីណ្លា, ដើម្បីនឹង
ពោលច្រាស្រ័យចំពោះស៊ីវៃ្សថ្មី ដែលគ្មានជាន់ទិយមតាន់យក, ត្រូវប្រើ
ភាសាស៊ុយអែដ្ឋ៉ា, ទ្រង់ក្នុងនេះជាន់ត្បាយមរបៀនភាសារបស់ខ្លួន ឲ្យ
ចម្រើនជាលំដាប់ តមកសម្រួលភាសានោះឯតិយតពីភាសាស៊ុយអែដ្ឋ៉ា, ។
ព្រោះហេតុនេះហើយជាន់ជាភាសាហ្វីណ្លា ដែលជាភាសាអាស៊ីភាគខិត
អាចនឹងយកទៅប្រើប្រាស់ជាន់ ចំពោះស៊ីវៃ្ស.អើរ៉ូប៉ែអែនទឹនតំនិតចំនើម
ជា យ៉ាងហ្មតចត់ ។ ចប់ ។

ភាសាលតាជាតិរលាយ
ប្រុសស្រីស្វាធ្យាយភាសាជាតិ
ត្បាយមរកុល ឲ្យសុទ្ធសាធ
កាំងាប្រមាធសង្ឃានយ៉ាម ។
។.ប.

រឿងទោង្គ

ពាក្យកាព្យ

លោកអង្គតក្យត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោកញ៉ុក.បែមពិនិត្យ

តមក

ក្រមុណីស្តាប់ តោធម្មឆ្លាប់ ទិម្មិតអាសនា សឹងមណីតែ្តភាស
ឆ្នុះឆ្លាសថ្លៃថ្លា តែវាកងសុវណ្ណា ភ្ញីផ្ទេកព្រោងព្រាយ ។ មានស្ទេតច្ចត្រ
ប្រាំពីរតែ្តតែ្ត សឹងផ្កាខាំងឡាយ តិចាក់ខាត់ខង ក្រាសក្រងឆ្នាត់ឆ្លាយ
តីដោះខ្លែខ្លាយ ទូវល្អងកេសរ ។ ខ្ទះដងទឹកស្រះ មកស្រង់ថ្វាយព្រះ
តោធម្មវរ ឲ្យទ្រង់ត្រប់ត្រៀង រុងរឿងសឹងស អាស្ចើញស្តេចមក
តងំលើធម្មាសន៍ ។ យងំយល់ត្រចះ ត្រចងំល្អល្អះ ភ្ញីផ្ទេកទិកាស
អុជខៀនធូបជង ព្រោតព្រោងតេញាសស ប្រក់តំឆ្នុះឆ្លាស់រុងរឿងស្មើ ។

ព្រះតង្សាពុទ្ធរៀ អ្នកតងំស្ងៀមនៅ លើអាសន៍សួស្តី ពុំបើក-
ព្រះសូរ មធ្យាថាអ្វី យក្សយល់នរបតី ស្តេចតងំស្ងៀមនៅ ។
យក្សគ្នើនខៀតថា ឥឡូវអាសនា គួរហើយម្តេចរៀ អង្គុយព្រងើយ
កន្តើយស្ងៀមនៅ មិនសំដែងរៀ រំពឹងដល់ណា ។

តោធិសត្វឆ្លើយ ថាយៃយក្ខអើយ បើទឹងទេសនា គួរមានបរិស័ទ
សុំអាពាធនា នោះទើបគួរថ្វា- ថ្លៃងព្រះធម៌ថ្លៃ ។ មួយរសោតឲ្យមាន

បុគ្គលកល្យាណ ស្តាប់ធម៌ប្រពៃ ប្រសើរជាងហ្វូង តុំគួរឲ្យយែនៃ
អង្គនុត្តរក្រៃ ប្រើអញស្មើខ្ញុំ ។ អញចេះសំដែង គួរតែប្រសើរ ទន-
សិរបង្គំ ក្រួញក្រាបឲ្យាប ស្តាប់តាមដែងធ្លុ អាចធនាស៊ុំ ខ្លួរសីលគាំងប្រាំ ។
អង្គអញសំដែង ធម៌ដល់ប្រសើរ ចូរខៅចង់ចាំ តួចតត់សំគាល់ រៀង-
ពាល់ចំណាំ ឲ្យបានចង់ចាំ ដោយអាថ៌គាថា ។ កុម្ភណ្ឌបួននាក់ ហេតុ-
ចង់ដឹងជាក់ ព្រះវេស្សន្តរ ក្រួញក្រាបបង្គំ បរមក្សត្រា ខ្លួលសីលមហា
បុរសវរញ្ញាណ ។

ទើបពោធិសត្វ ពន្លឹកតុខ្នែ បន្ទូលទៅថ្លាន ហៃអស់មហាយក្ស សីល
ប្រាំស្មាន ចូរអ្នកឲ្យនថា ចាំជាក់ប្រក្រតីៗបាណាតិបា-តាអទិន្នា កាមេសុ-
មិឆាចរិយា មុសាវាទ មជ្ជបិវ៉ី វេរមណា ។ ឃាណាតិបាត ឲ្យវៀរប្រមាទ
ជីវិតសត្តា អទិន្នាទាន វៀរមានលោភា លោភលួចទ្រព្យា នៃអស់-
មហាជន ។ កាមេសុមិច្ឆា កុំបរទារកា វៀរលួចប្រពន្ធ នៃអ្នកនានា
ឲ្យជាមានម-ន្ទិលទាស់ចូរនំ ដូចដល់អាត្មា ។ មុសាវាទ វេរមណី
វៀរពោក្យមុសា មជ្ជបិវ៉ី វៀរពីសុរា គឺលាមកជា ថ្នាំបំពុលអង្គ ។
ពន្លឹកសារពេជ្រ ឲ្យសីលប្រាំស្រេច ខៀនទើបត្រាស់ទ្រង់ បន្ទូលទៅថា
ហៃមហាយក្សយង់ ចូរប្រសើរប្រុង ស្មារតីពាល់គ្នា ។ ចូរចំណូចចង់ចាំ
ខ្លួរសីលគាំងប្រាំ នោះឯងឲ្យប្រា - កដកុំប្រមាទ ឲ្យឃ្លាតឃ្លៀងឃ្លា
សីលប្រាំនេះជា ឫសកែវពិភពមោ ។ សីលនោះជាខ្លឹម ឥតអ្វីប្រៀបផ្ទឹម
ជាយានសេដ្ឋា ប្រសើរភាំងបួន ហៅខ្លួនមុខ្លា ខ្លៅហេតុពាលោ
ភាត់ឫសកែវបង់ ។ ទំនឹងនាំខ្លួនទៅ ខលង់ទុក្ខនិត្យនៅ នរកលុះលង់

ព្រោះតាលជាមនុស្ស តាត់ប្តូរតែវេទនា សៀតសោះឲ្យអង្គុ តែធំរវើរវាយ
។ ចូរប្រែស្តួនឯង ស្តាប់អញបំដែន អធម្មធម្មា មិនមែនព្រះធម៌ ទើន
ធម៌ថ្លៃថ្លា អាចឲ្យ ស្តាប ឲ្យប្រែស្តួនស្តាប់ ។ មិនមែនធម៌ពិត នេះគឺពុច្ចរិត
តាំងបីពុំតាប់ ពុំគឺធម្មា ឥតសព្វមានសព្វ ភ្លាំងក្រឡាប់ ឲ្យវេ
វេទនា ។ ប្រែស្តួនតាំងអស់ តាលដើមជាមនុស្ស ព្រោះតែតក្សា ពុច្ចរិត.
តាំងបី នេះឥឡូវ យក្ខយង់មោហា ដូរជាតិតម្លៃ ។ កំឡាំងពុច្ចរិត
តាំងបីហៀនបិទ អកុសលខ្លួនហ៊ៅ គួរលាកគួរលះ ឲ្យដ្រះចេញទៅ
ពុច្ចរិតនោះហ៊ៅ មិនមែនធម្មា ។ តែធម៌ពេញពិត នោះគឺសុចរិត តាំងបី
ប្រកា ប្រកបប្រាកដ សន្តតហៅថា ព្រះធម៌ថ្លៃថ្លា ប្រសើរសេដ្ឋ ។

កុដ្ឋណ្ឌបួនខាក់ ស្តាប់ធម៌ដៀងជាក់ ខន់តាំងមនោ សោមនស្សាសល់
អង្គាល័យោ ក្រាបក្រាមថ្វាយ ពន្ធុកសាស្តា ។ ខ្ញុំលាបពិត្រ
អ្នកដ៏មានវិជ្ជ ជាតិជាអាចារ្យ ចូរអ្នកនិមាន ឲ្យបានពិស្តារ ពុច្ចរិតប៉ី
ប្រ - ការតើម្តេចហ៊ៅ ។

ពោធិសត្វឆ្លើយ ថាលៃយក្ខអើយ រឯលោកហ៊ៅ ថាពុច្ចរិត
ប៉ីតិតអញទៅ សំដែងចែងទៅ ឲ្យផ្សេងពីគ្នា ។ មួយគឺកាយំ
ពុច្ចរិតំ មួយគឺវាចា ពុច្ចរិតំ មួយគឺមនា ពុច្ចរិតា នេះហៅពុច្ចរិត(១) ។
ពុច្ចរិតប៉ីប្រ - ការនេះបែកជា ជាប់ប្រការពិត យក្ខសួរវើងខ្ញី រឺបីពុច្ចរិត
ជាជាប់ចរពិត ម្តេចខ្លះអាចារ្យ ។ ពោធិសត្វឆ្លើយ ថាលៃយក្ខអើយ
កាយពុច្ចរិតា បែបបទចាល់ ជាប៉ីប្រការ រឯវាចាពុច្ចរិតនោះ ។

---

(១) នេះជាសេចក្តីសំដែងអំពីពុច្ចរិត ៣ប្រការ គឺកាយពុច្ចរិត ១ វចីពុច្ចរិត១ មនោពុច្ចរិត១ ។

ជាជួនប្រែការ រីមានសា ខុច្ចរិតស្មោះ បែកបាតបែរជា បីប្រែការឆ្ពោះ បូករួមគំនិតអស់ ជាដប់ប្រែការ ។

យកទុស្តាប់ចូលចិត្ត សួរថាបពិត្រ ខុច្ចរិតដប់ប្រា- ការតើម្តេចខ្លះ សូមព្រះករុណា សំដែងពិស្តារ ឲ្យយើងចូលចិត្ត ។ កាលណោះតវ្ស-ពោធិ៍ ប្រទេសរដ្ឋតំរង ប្រុះប្រាជ្ញាល្អិត ហៃយក្ខទាំងឡាយ ឯកាយខុច្ច-រិត បែកជាបីចិត មានបាបបន្ទែ ។ មួយគឺចុរណា មួយគឺអទិន្នា មួយគឺកាមេ គំនិត ៣ ឯងគាប ក្នុកប្រាជ្ញប្រាប់ប្រែ ប្រមូលរួមផ្សែ ហៅកាយខុច្ចរិត ។ រីឯវចី ខុច្ចរិតបាលី បែងជាជួនពិត សោតសិងអប្រិយ មួយនិតិចិត្ត ស្តីពុំដែលពិត មានតែមុសា ។ មួយគឺញុះញង់ ឲ្យគេបែកបង់ សាច់សំព្នាញ់ក្នា រំនាសប្រាស់ក្រាត់ បែកបុត្រតវិយោ ប្រាស់ព្រោះវាចា ឯងគាបស្រដី ។ មួយពាក្យខ្ទេគោះ ពាក្យអសុរស តតរស់មេត្រី ពាក្យពោលរំនិងរូស ប្រទូស្តចងក្តី ពាលោស្រដី ច្រើនប្រឡាសលន់ ។ មួយពាក្យឈ្នានីស ជួរចង់ចរចស ស្រដីផ្តាញ់ផ្តន់ ផ្តាញ់ផ្តាលពុំគាប់ បង្អាប់បង្អន់ បំភាបំភាន់ បំផុតលាភគេ ។ ពាក្យបួនអប្រិយ នេះហៅវចី ខុច្ចរិត ជាពាក្យអបលក្ខណ៍ ហៃយក្ខរំឯ មនោមនេ ខុច្ចរិតា ។ មួយចិត្តសង្ឃឹត ចិត្តតាមតណ្ហា ខោសតបខោសា មួយចិត្តលោភពិត មួយចិត្តមិច្ឆា ទិដ្ឋិហៅថា មនោខុច្ចរិត ។

កុម្មណ្ឌបួននាក់ ចានស្តាប់ដៀងជាក់ ទូលថាបពិត្រ ខោះអ្នកដែលធ្វើ អំពើខុច្ចរិត ដោយកាយពុំនិត្យ ពុំណាយលាភលា ។ កម្មអ្នកដែលធ្វើ ដោយកាយនោះតើ ដូចម្តេចអាថ្យ ចូរអ្នកនិទាន ឲ្យចានពិស្តារ

ឲ្យយើងដឹងច្រើន កដកម្មដៀងជាក់ ។

ឥឡូវពុទ្ធដ្ឋិល ស្តេចបើកបន្ទូល ថាវៃអស់ឃ្ញុ ចរយោនវោ នរូនអ្នក
ណាឯងអបល់ក្ខណ៍ ធ្វើកម្មជាណា ។ ស្លាប់ទៅនរក លំបាកវេទនា
លុះមកកើតជា មនុស្សក្នុងលោកីយ អប្រិយមហិមា ប្រកបអង្គអា
ក្រក់ក្រៃពុំស្អាត ។ កំព្រាកំព្រយ ក្រងរក្រងយ ជាលំទៅព្យាធិ៍ តែង
ធ្វើឲ្យអ- ន្តរាយជន្មជាតិ ចួនគេតិយោដ ដោយគ្រឿងសស្ត្រា ។ ចួន
ស្លាប់ក្នុងពោះ ចួនប្រទះគ្រោះ សត្វខាំមរណា យក្ខអើយអ្នកធ្វើ អំពើ
បាបណា ពុំដែលមានអា - យុយឺនយូរនៅ ។ មានអ្វីតេញ្ចិត្ត កំពុង
ស្នេហ៍ស្និទ្ធ ប្រែប្រាសចោលទៅ តតគោះតតារ អសារអសៅ
ពុំដែលទឹងទៅ ស្លាប់ដល់ដាច ។ យក្ខអើយថាបើ អ្នកណាគេចធ្វើ
កម្មអទិន្នា ស្លាប់ទៅវេទនា នរកសោះ ។ លុះមកកើតជា មនុស្ស
ក្នុងលោកីយ៍ ។ មកជាអ្នកឲ្យត់ ហិនហោចទុគ៌ត កំព្រាអប្រិយ៍
ឥតញាតិជុំជិត ឥតមិត្រមេត្រី មានប៉ុន្មានក្តី ពុំបានដឹង-ឮ ។ សឹង
ប្រែប្រាត់ប្រាស ខ្ពាត់ខ្ពាយវិនាស អំពីខ្លួនទៅ ដោយវិនាសប្រាំ
តីកម្មខ្លួនឯង វិនាសមួយទៅ ទឹងក្តើងនេះហាន ។ វិនាសមួយចោរ
ជ្រមុចិត្តតាលោ លបលួចពុំក្បាច្ច ខ្លួចមួយប្រការ ទឹងមហាក្ស័ត្រមាន
មួយអន្តរាយ ទឹងព្រះគង្គា ។ មួយមិញ្ញាត់ខ្លាយ បង់បិទខ្លាច
ព្រាយ បង្កិនអាត្មា គោះរំរេកបាន ប៉ុន្មានក្តីណា វិនាសដោយប្រា-
ការគ្រោះអប្រិយ- ។ ឆ្លងយក្ខអើយឯ អកុសលកាម តែងតែថ្លូចថ្លុង
ឲ្យទៅនរក ខល់ខ្លួចលុះឆ្ងាំ លុះមកកើតកង លោកីយ៍នេះណា ។

ខុតុត្រូវយោ ខុតុរបូជា ។ ហេតុកម្មកើតជា ខ្មោរខ្មីយក្រាជក អាក្រក់មហិមា ឥត្ថីបុរិសា ស្មើរប្រុសស្មើរស្រី ។ អនិដ្ឋាថា ពោះបីប្រាថ្នា បន់ជានអ្វី ។ សឹងប្រែមិនបាន ដូចក្នានមេត្រី គួរលោក-កុំបី ធ្វើឲ្យមានហ្មង ។ ចាណាគិន្នា ការមេសុម៉ិញ្ច តាំងប៉ាន់ហោង ព្រះស្រីសម្ពុទ្ធ ជាម្ចាស់លោកផង សំដែងដួចចង ហៅកាយពុច្ឆតែ ។

យកស្តាប់ពោធិ ថ្លាត់ថ្លាយនេ្ត ពុលថាបពិត្រ រឿងយើងខ្ញុំ នេះសឹងចូលចិត្ត តែសូមអាណិត សំដែងវែក ។ អ្នកណាដែលធ្វើ ខ្លួកម្មអំពើ អំពីវាថា អ្នកនោះតើគ្រាំ ត្រូវកម្មវេទនា ម្តេចសូម មេត្តា សំដែងឲ្យបាន ។

សម្តេចតថាគតពោធិ ធីត្រាស់ថាគោ ម្នាលយក្ខគ្រប់ប្រាណ បើអ្នក ឯណា មោហាអាចហាន បំពោតបំពាន ស្រដីមុសា ។ ស្តាប់ទៅ រឿងពុក្ខ ទៅពួកនរក លុះមកកើតជា មនុស្សហីនពូតិត កំសត់កំត្រា មានមាត់អសារ អសោចិអប្រិយ៍ ។ សំឡេងស្អកស្អិត ពោះពោលពាក្យពិត ទឹងអ្នកណាក្តី គេស្អប់គេខ្ពើម គេឆ្អែមសំដី គេពុំមេត្រី ពុំជឿវាថា ។ រីពាក្យញុះញង់ ស្តីឲ្យគេបង់ បែកបុត្រគរិយា ស្តាប់-ទៅទៅត្រាំ រងកម្មវេទនា លុះមកកើតជា មនុស្សនេះជួរជាតិ ។ ហេតុកម្មតាមមក រូបរាងវិពាកពក ក្ងិនឆ្អែះដូចគ្នាត សៃយតិរច្ឆាន មិនមានស្ទឹងស្អាត សំឡេងគគ្រាត មាត់ស្អុយគគ្រុក ។ គគ្រិះគគ្រើម ខេត្តាមនុស្សខ្ពើម ប៉ដូចលាមក ហេតុកម្មបូពាណ មិញ្ជាមានតែទុក្ខ ពិតពុំសាន្តសុខ ជួបជុំញាតិទេ ។ រីពាក្យចិសុណ្ណ វាចជាវាចា ញុះញ

ញាំញែ ហេតុតែសំដី អំពីបុព្វេ ខ្ញុំនបំបែកគេ ក្រាត់កូនប្រពន្ធ ។ ផ្សុសក់ថា យក្ខអើយអ្នកណា នោលតាក្សខ្ញុំនិន បំភាន់បំភរ ច្រើនប្រឡាសលន់ បង្ហាប់បង្ខន់ ធ្លាស់ធ្វើយឈ្មានពាន ។ ទៅរនឹងវេទនាលុះមកកើតជា មនុស្សាសាមាន្យ រូបអក្រក់ខ្មុស ទឹងមនុស្សគ្រប់ប្រាណ ពាក្យនោលមិនមាន ជាចូលចិត្តគេ ។ តែស្តីកាលណាគេទឹងផ្តាសា គេដៀលដល់មែ តុបខកម្មត្រូវ អគ្គិឯងធ្វេសធ្វេធ្វើឲ្យគេ អាប់អន់ចិត្តា ។ ហៃយក្ខអើយថៅ នេះឯងហើយហៅផ្សុសក់ថា រំអែតើកម្ម សម្ផប្សាបា ជាខុវថា ពាក្យនោលខ្ញុំន ។ ដូចនាលោកយ៉ យេគប់អានអ្វី ថាពប់អានបុណ្យ សត្តាយឺនយស រថស់ជានធន់ ជាតិជាបំណាន់ បំណាច់នៅបាន ។ ឯងស្តីបង្ខន់បង្ហាប់ហើយប៉ន្តែយពន្យឺស្តាន ស្ងាប់ទៅនរក រនឹងកុំពុំស្រាន្ត បាវបរបង្ខាន បង្ខិបណាកគេ បើមកកើតជា មនុស្សឥតសក្តា រូបក៏ខ្សេ ខ្សន់ល្ងើល្ងង់ ឥតពន្លឺប្រាស្នេហ៍ ជាអ្នកកំសៃ កំសត់ទ្រព្យា ។ ឥតប្រាជ្ញឥតប្រាយ គោរនឹងនំយោយ ទៅទឹងអ្នកណា គេទឹងក្រែគ្រប់ប្រពន្ធ់ផ្តាសា ហេតុតៀរវេរ ដែលបង្ហាប់គេ ។ តាំងប្លួនប្រកាសនេះហោរក់ថា ខុចុះតែតែងតែ តាមភាន់ពុំសុខ ឲ្យខ្ញុំឥតស្ងៀ ព្រោះខ្ញុំនធ្វេសធ្វេ ធ្វើកម្មក់ថា ។ យក្សស្តាប់ចូលចិត្ត ទូលថាបពិត្រ បុរសថ្លៃថ្លា ប្រាជ្ញប្រដិយក្ស ចូរអ្នកមេត្តា សំដែងវេរ មនោខុចុះតែ ។ ចូរអ្នកប្រាជ្ញខេស្ន ព្រះធម៌វិសេស ឲ្យយើងចូលចិត្ត វេរៈវេរ មនោខុចុះតែ តើតៀរយ៉ាងដូច ដូចម្តេចអាចារ្យ ។

ពោធិសត្វឆ្លើយ ថាហៃយក្ខអើយ បើអ្នកឯណា ធ្វើនូវមនៈ
ទុច្ចរិតា(๑) មួយចិត្តលោភា មួយចិត្តព្យាបាទ ។ គេធ្វើអ្វីខ្លួន តិតពុំ
គង្គួន តែងតាមប្រមាទ នៃទឹងអ្នកនោះ លង់លុះដន្ទជាតិ តៀរជាប់
អង្គអាត្ម ដល់ទិព្វានខាយ ។

(ចប់ខ្សែព័រវែតប៉ុណ្ណេះ) ។

ដំណើរដំណាល ដំណតកាល តន្ទុកញ្ញាណញ្ញេយ្យ សំដែងធម្ម
សម្មាថ្វាថ្លៃ នៅក្នុងព្រឹក្សព្រៃ ខ្ញុំនាងយកក្ស ។ ហៅខ្សែប៉ាន តន្ស-
ពោធិញ្ញាណ សំដែងធម៌ថា យក្ខអើយទុច្ចរិត ដោយចិត្តនេះណា
នៅរនាសច្រា-កដពុំដែលខាន ។ រីចិត្តមិច្ចា- ទិដ្ឋិដូចជា ត្រវែស្តង
ត្រប់ច្រាណ ព្រះស្តែងសព្វថៃ្ង មមែស្មោះស្មាន ថាជាពុំមាន ពុំខ្មៀរ
វេត ។ ឃើញទុសជាត្រូវ ទឹងនាំខ្លួនវេរ វេរទុក្ខវេទនា គួរប្រែគួរ
ច្រាស គួរលះគួរលា ភាំងដប់ប្រការ សឹងពុំប្រែរៃ ។ នេះលោក
ហៅថា ពុំមែនធម្ម រីឯមិថ្វាថ្លៃ រិះសប្រាលប្រាំ ខ្លួនឆៅតរាត្រ
មនុស្សសត្វសព្វថៃ្ង សឹងសាន្តសុខា ។ គឺទុច្ចរិត ភាំងបីបទពិត
ជាដប់ប្រការ ឥតអ្វីប្រៀបត្រឹម ទឹងដ្ឋឹមទុបមា ព្រះស្តែងពាល់គ្នា
គួរវៀរទុច្ចរិត ។ កាន់សុចរិតា (ភាំងដប់ប្រការ) ប្រើច្រាស់ច្រុងចិត្ត
ដញ្ជាប់ដញ្ជឹង រំពឹងគន់គិត ជាពិពិធិត ពិនិត្យបូជា ។ រីរៈយោនោ
យានៈសេរជ្ជា វែងនាំច្រាណ ទៀងវេរដាក់ដល់ ត្រែយថ្នល់ទិព្វាន
លះលោកលែងខាន កំណើតនុជា ។

(មានត)

(๑) តំមនោទុច្ចរិត ។ (๒) ប្លាប់តើមថាត់ នេះដាឃ្លាថៃមក្មី ។

រឿងសាមកុក

ភាគទី ២៨

ចេញពីវិបុលកដសេនា ឆ្វី-ភីង ប្រែរៀបរៀង

(តទៅ)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃឆ្លាតបើបានអាន
ធឹងបេះទុយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ខណៈតាំងតែព្រះចៅហៀនតេ ស្តេចទៅប្រថាប់នៅក្រុងហ្គីគោបាន៨ ព្រះវស្សា លុះដល់ខែមាឃខាងខ្នើត ចូវថាត់ប្រើហ្គីខួនធីងហ្គុនថងឲ្យ លើកទាហានទៅនៅរក្សាស្រុកយីឡាំ ប្រយោជន៍ធីងកាំងទាំងតែងឡៅ ប៉ៅ កុំឲ្យទ្រុងទៅមកបាន , ឲ្យស៊ុនហុកធីងចាយិនទៅរក្សាស្រុកហ្គីគោ ឯខ្លួនចូវថាត់ប្រមូលពលទាហានបានច្រើន លើកចេញទៅ បំណងធីងកាយយកស្រុកអ៊ូនសៀវ ។ លុះទៅដល់មាត់ទន្លេហ្វាងហោកំឲ្យទ្រុងទៅតាំងបន្ទាយនៅចាំស្តាប់ដំណឹងអ៊ូនសៀវ ។

ឯអ៊ូនសៀវលុះចូលខ្នាំថ្មីក៏ស្រាកស្រាលដម្ងី ទើបចាត់ចែងសេនាទាហានធីងលើកទៅវាយយកទីក្រុងហ្គីគោ ។ សឹមផ្ទៅយកនិយាយហាមឃាត់ថាកាលត្រាមុនលោកកំប៉ុស់ការធីងចូលទៅដំបន់តួ តម្ពង់ នៅដំបន់ស៊ីង

គេឯម្ដង ខ្លួចខាតតាហានច្រើនណាស់ ឯតាហានដែលសល់នៅតាំងប៉ុន្មាន
ក៏ពុំពាន់ចាត់ហត់ខ្សោយនៅឡើយ សូមឲ្យលោកការពារបង្ហួនឲ្យតាកើនមាន
កំឡាំងសិនរួចសឹមគិតការតទៅទៀត ។

កាណ្ឌទី ២៩

តាំងពីអ្នស៊ុងសូមយកអាសាចេញទៅភាយវ័ត ហើយបាដាយនឹងបួន អូនស្បៃស្ងាប់
អ្នឧស៊ុងតាំងខ្លួនជាធំ បួនលើកទ័ពទៅភាយស្រុកកេងដាវ សឹមដោយឡើងយកទង់ជ័យ
ដោតឡើង ។

ខណៈនោះ មានអ្នកបំរើម្នាក់ជិះសេះមកដឹកបង្អួនស្បៃថា បួនលើក
កងទ័ពមកចុះបន្ទាយនៅវាស្រមោត់ខន្ធហ្វាន់ហោ តាមដំណឹងថាទឹងលើក
មកវាយឲ្យដល់ស្រុកគីដាវ ។ អ្នឧស្បៃឮហើយក៏និយាយទឹងសឹមដោយថា
យើងនឹងលើកកងទ័ពទៅវាយស្រុកហ្គីតោ អ្នកមកហាមយាត់មិនឲ្យលើក
ទៅ ឥឡូវបួនក៏លើកកងទ័ពមកហើយ អ្នកនឹងស្ងៀមទៅឲ្យកងទ័ពមក
ដល់ដើងកំពែងស្រុកឬគ្រានេះ យើងនឹងលើកកទ័ពទៅរំលោងបួនឲ្យចាញ
ឲ្យបាន ។ អ្នឧស៊ុងជាបុត្រនិយាយទឹងដូចបិតាថា វេលានេះបិតាមានជម្ងឺ
ឈឺមិនសប្បាយ ជម្ងឺគើរតែទឹងគ្រាន់បើ មិនទាន់ជាស្រួយ វែលទឹង
លើកទាងទ័ពទៅនោះ ពេលកំទឹងកំរើកប្លាំរឿងដ៏ថែមទៀត ប្លុចទឹង
សូមយកអាសាលើកតាហានទៅធ្វើការសង្គ្រាមទឹងបួន ។ អ្នឧស្បៃកំ
យល់ព្រមផង ហើយចាត់ដែនធ្វើសំបុត្រ ឲ្យទៅបង្គាប់ភ្លាមកងទ័ពស្រុក
ស្បៀងដាវ, ស្រុកអ៊ីវដាវ, ទឹងស្រុកប៉ែងដាវ ឲ្យមកបញ្ចូលគ្នាទឹកអ្នឧស៊ុង។

នោះតាំងពីគ្រាបានចេញច្បាំងសម្លាប់សូហ៊ិនស្លាប់ ក៏មានចិត្តកំរើកខ្លាំងណាស់ ។

គាលអ៊ួនសៀវឲ្យទៅបញ្ជូនកងទ័ពតាំងពីមុណ្ឌលនេះ អ៊ួនស៊ុងក៏មិនបានដឹងថា ខំលើកទាហានប្រហែល ៥ មឺនថ្ងៃ ស្រុតរួតទៅតាំងបម្លាយផ្ទាប់គ្នាទឹងបន្ទាយចូន ។ ឃើញដូច្នោះក៏ប្រើខៀវលៀវឲ្យលើកទាហានចេញទៅច្បាំងទឹងអ៊ួនស៊ុង ។ ក៏បរសេះកំណួចបួលប្រយុទ្ធគ្នាទឹងខៀវលៀវបាន ៣ ភ្លែង អ៊ួនស៊ុងគ្រាំទឹងកំច្បាំងខៀវលៀវមិនបានក៏ញាក់សេះរត់ ។ ខៀវលៀវបរសេះដេញចាក់តាប់សម្លាប់ទាហានអ៊ួនស៊ុងពីក្រោយស្លាប់ជាច្រើន អ៊ួនស៊ុងក៏នាំទាហានដែលសល់តាំងប៉ុន្មាន រត់ត្រឡប់ចូលទៅកងស្រុកតឺដាវិញ ។

ចំណែកអ៊ួនសៀវគាលដឹងថា អ៊ួនស៊ុងបែកទ័ពត្រលប់មក ក៏សុតរន្ធត់ចិត្ត ពេលនោះកំបាំងកំរើកឡើង ក្អួតជាក់សុទ្ធតែឈាមហូរចេញមកប្រហែលជា ១ ចាំង ខាងឡៅដឹងភរិយាឃើញដូច្នោះក៏ភ័យស្ងួតស្ងាតើ រៀបនាំពួកស្រីបំរើតាំងពួងគ្រាប់ត្រកងយកអ៊ួនសៀវចូលទៅដាក់ឯវិលូងក្នុង ហើយឲ្យហោសឹមដោយ ហាងតីចូលមកប្រឹក្សាដែលនឹងតាំងឲ្យអ៊ួនស៊ុងធ្វើជាចៅហ្វាយស្រុកតឺដាំនឹងខ្លួនឯង នោះទៅ ។

ខណៈនោះអ៊ួនសៀវក្អួសស្ងាតើឡើង ឃានឮហើយតែងយាយមិនរួចគ្រាន់តែយកម្រាមដៃចង្អុលត្រង់ដើមច្រមុះខ្លួនឯង ។ ខាងឡៅដឹងឃើញអ៊ួនសៀវយកម្រាមដៃចង្អុលដើមច្រមុះដូច្នោះ ក៏ចូលចិត្តថាឪអ៊ួនស៊ុងចៅហ្វាយស្រុកទើបកែងសួរអ៊ួន សៀវក៏តបថ្លាឡើងឲ្យមនុស្សទាំងអស់ទៅ

ទ័នោះឮជាបន្ទាល់ថា ស្រុកតែជីវានេះនឹងឲ្យអ្នកស៊ុនឬ? អ្នកសៀវទំយោយ
មិនរួចក៏ញាក់មុខលួមតែខ្សល់ដង្ហើមដកមកជុត តំស្រែកជោយសំឡេង
ខ្លាំង ហើយក៏ញាក់ដីតចរជាច់ខ្សល់ស្លាប់នោះទៅ ។

សឹមផ្សាយនឹងហង៍ត ឃើញអ្នកសៀវស្លាប់ហើយ ក៏នាំគ្នាតាក់តែង
ការសពតាមចំនៀម ។ ឧកញ៉ាឡាជក៏ឲ្យយកខ្មួនឆាំ៩នាក់ជាតរយោ
ចន្ទាច់ដែលអ្នកសៀវស្រឡាញ់នោះទៅសម្លាប់តាំងអស់ ហើយនៅតែ
ប្រចណ្ឌខ្លាចថាស្លាប់ទៅ ហើយទឹងទៅដួចគ្នាទឹងអ្នកសៀវ ។ ទឹងចង់មេ
ត្រីស្រឡាញ់ស្រីតាំងនោះទៀត ក៏ឲ្យយកជាវមកកាត់សក់កាត់ដើង ហើយ
ជក្រញុំ សាច់មុខឲ្យទៅជារបួសស្លាកស្នាម ប្រាប់ថាទឹងឲ្យអ្នកសៀវស្អប់
ខ្ពើមរអើម ហើយឲ្យយកសពស្រីតាំង ៥ នាក់នោះទៅចោល ។ អ្នក
ស៊ុនឃើញមាតាធ្លីដូច្នោះ ក៏គិតថាវម្តេក្រែងញាតិបងប្អូនរបស់ស្រីតាំង ៥
នោះ មានចិត្តព្យាបាទអាឃាតគំគួនដល់មាតាទឹងខ្លួន ទើបប្រើភាហានទៅ
ចាប់យកពួកញាតិសាលោហិត ស្រីតាំង៥នាក់នោះមកប្រហារជីវិតតាំង
អស់ ។ ឯសឹមផ្សាយនឹងហង៍ត ក៏រៀបចំតាក់តែងលើកអ្នកស៊ុនឲ្យឡើង
ខ្លួលស្តីពីដការជាទៅហ្វាយស្រុកតែជីវា ហើយធ្វើសំបុត្រចាត់ប្រៃ
ភាហានឲ្យកាន់យកទៅឲ្យដល់ អ្នកថាំ, អ្នកហ៊ីនឹងគោកន់ថា:"ឥឡូវអ្នក
សៀវជាបិតាយើងខ្លួលអនិច្ចកម្មទៅហើយ " ។

ឯអ្នកថាំលើកកងទ័ពមកដល់ដែនស្រុកតែជីវា ខ្លួលប្រទះអ្នកកាន់សំ
បុត្រដឹងហេតុសព្វគ្រប់ថាបិតាស្លាប់ហើយ ក៏ប្រឹក្សាទឹងគ្នា ស៊ុនបេងថា
ឥឡូវបិតាយើងអនិច្ចកម្មទៅហើយ :យើងនឹងគិតប្រការម្តេចក្តៅទៅធ្វើយថា

ខ្ញុំនលោកជាបុត្រច្បងហើយមិនបាននៅក្នុងស្រុក ខ្ញុំបានឃើញថាសឹម
ដោយនឹងមានតែនឹងឲ្យអ្នកស៊ុងធ្វើចៅហ្វាយស្រុកជំនួសបិតាលោក សូម
ឲ្យលោកប្រញាប់លើកចំតបូលទៅក្នុងស្រុក ហើយឲ្យនាម៉ឺនមុខមន្ត្រីប្រ-
ឹក្សាតាមទំលាប់ប្រពៃណីចេបតួរ ។ ស៊ុនបេងតបថា ដែលនឹងឲ្យអ្នក
ចាំបូលទៅដល់ក្នុងស្រុកនោះមិនបានទេ ព្រោះសឹមដោយនឹងមានតែជា
ដើមគំនិត ខ្លាចក្រែងធ្វើតលាក់ពុតប្រការម្តេច អន្តរាយនឹងមានដល់យើង ។
គួតៅធ្វើយថា ដែលអ្នកសង្ស័យដូច្នោះត្រូវហើយ គួឲ្យឈប់ចំតនៅទី
នេះចុះ តែខ្ញុំនខ្ញុំមាក់ងងឹតនឹងសូមអាសាបូលទៅក្នុងស្រុក ស្តាប់តាណែ
មើលល្អអាក្រក់ឲ្យច្បាស់ ហើយនឹងបានគិតការតទៅ ។ អ្នកចាំនឹងស៊ុន
បេងក៏យល់ឃើញត្រូវមែន គួតៅក៏លាអ្នកចាំបូលទៅជួបនឹងអ្នកស៊ុង ។ ក៏
សួគួតៅថា: អ្នកចាំបងឃើងមកដែរឬទេ ? គួតៅដំណាបថា អ្នកចាំឃើញ
សំបុត្រដែលឲ្យប្រញាប់លើកកងចំតមកនោះក៏ស្រួតលើកមកឈប់ចំតនៅ
ក្រៅស្រុក តែអ្នកចាំកើតបញ្ហាបន្ទោតនឹងមកមិនបានឥឡូវប្រើឲ្យខ្ញុំបានចូ-
លមកស្តាប់ដំណឹង ជានឹងលើកចំតទៅច្បាំងនឹងចូរណា អ្នកស៊ុង
ធ្វើយថា តាលបិតានៅមិនទាន់អញ្ជើញមកទេនោះ បានចាំពុកឲ្យយើងចូលពង
ការធ្វើចៅហ្វាយស្រុកតែជាវ ឲ្យអ្នកចាំនោះគង់នៅជាចៅហ្វាយស្រុកសៀង
ជាវ ឥឡូវចូរធ្វើលើកកងទ័ពមកតាំងនៅមាត់ទន្លេហ្វាវហោ ដូច្នេះចូរអ្នកទៅ
ប្រាប់អ្នកចាំឲ្យទៅធ្វើសង្គ្រាមតទល់នឹងចូរមុនចុះសឹមយើងសើបយើងលើក
កងចំតទៅជួយ ។ គួតៅតបថា អ្នកចាំគ្មានឹងខ្ញុំបានឲ្យមកដំណាប លោក
ថា កងកងចំតដែលលើកមកវាហានេះ ទឹងរកអ្នកឯណាឲ្យមានដម្រុះ

ប្រាជ្ញាធ្វើជាទីប្រឹក្សាការសឹកសង្គ្រាមគ្នានេះអ្នកចាំឲ្យថាសូមសឹមដោយ
ទឹងហង្គឺ ៗ ដៅជាមួយធង់ទឹងបានជួយគិតការគ្នា ។ អ្នកស៊ុងធ្វើយថា
ដែលយើងទឹងលើកទ័ពដាក់ងវហ្នឹងដៅវេលានេះ ក៏ដោយអាស្រ័យតែគំនិត
របស់សឹមដោយទឹងហង្គឺប៉ុណ្ណោះ បើអ្នកចាំឲ្យមកសុំយកដៅហើយ
យើងទឹងបានខានណាធ្វើទីប្រឹក្សា ។ គួរគេដំកបថា បើណាកមិនឲ្យ
ចាំងពីនាក់ ក៏សំតែសឹមដោយឬហង្គឺតែម្នាក់ណាមួយដៅផងក៏បាន ។
អ្នកស៊ុងមិនដឹងកល់ទុកឃ មិនហ៊ានខទឹងគាស់ ដោយបារម្ភចិត្តអ្នកចាំជា
បង ទើបសរសេរឈ្មោះសឹម ដោយទឹងហង្គឺចាំងពីនាក់ឲ្យចាប់ខ្លោត
បើចាប់ត្រូវលើឈ្មោះណាមុន ក៏ឲ្យអ្នកនោះដៅ ។ អ្នកស៊ុងសរសេរហើយ
ក៏ចាប់ត្រូវលើឈ្មោះហង្គឺ ទើបបង្គាប់ឲ្យហង្គឺដៅជាមួយទឹងគួរគេហើយ
អ្នកស៊ុងធ្វើសំបុត្រផ្ញើដៅដល់អ្នកចាំថា យើងប្រើហង្គឺមកជាទីប្រឹក្សា
ឲ្យអ្នកចាំលើកជាកងមុខចូលដៅធ្វើសង្គ្រាមទឹងបន្ទូ យើងទឹងលើកកង
ហ្នឹងដៅជួយ ។ គួរគេទឹងហង្គឺខលសំបុត្រហើយក៏លាអ្នកស៊ុងចេញ
ដៅដល់កងទ័ពអ្នកចាំ ។ ហង្គឺឃើញអ្នកចាំមិនមែនឈឺដូចពាក្យ
គួរគេនិយាយ ក៏តតួកកងចិត្តមិនសប្បាយ គួរគេក៏ជូនសំបុត្រដៅឲ្យអ្នក
ចាំមើល ។

(មានត)

លោក រ៉ាយ-ប៊ុក រៀបរៀង

(តទៅ)

វគ្គទី ៦ រដ្ឋមន្ត្រី

ចំណែកលោកហ្សង់ដឺតបឹតខៅកន្លងតំណែងខាងការដ្ឋមន្ត្រីនេះមិនបានយូរប៉ុន្មាន ក៏មានភ្លេចបង្គាប់ត្រូវទៅបង្គាប់លោកពីតំណែងនេះ ហើយត្រូវហួតដាវចេញខ្លួនឯងកម្ម បំបរបង់ចេញពីនគរខៅ ។

លោកហ្សង់ដឺតក៏រត់ចេញពីពដាមិថាប៉ះខ្លួន ធ្វើតំណើរខៅតាន់ប្រទេសគេស្ប៉ា ។

រឿងនារីដែលគេវាយជាដំណាំ

ពេលឃប់លោកហ្សង់ដឺតក៏រត់ចេញពីទីក្រុងថាប៉ះខ្លួន ; លោកក្រឡេកមើលតាមលើមេឃមានផ្កាយក្រតើជាដើម, ហើយលោកត្រាច់ខៅតាមផ្កាយនោះខៅ ។

លោកបានតិចាណាខ្លួនតាមភាពិនោះ ដែលគេចុតជាដុំស្មើធំខៅលើមេឃ បើតាមភ្នែកក្រឡេកខៅជាវត្តុចមួយកន្លង ភាគ ។ ចំណែកឯផែនដីដែលជាវត្តុចណាស់ស្មើរមើលតុំ ឃើញ, បើតាមចក្ខុរបស់យើង ខៅជាវត្តុធំសម្បើមអស្ចារ្យណាស់ខៅវិញ ។

លោកបានគិតអំពីមនុស្សក្នុងស្ថានភាពសម័យបច្ចុប្បន្ន ពួកជាណាត

សត្វស្ថិតនៅលើដុំតក់មួយហើយខាំដណ្តើមស៊ីគ្នាទៅ-វិញមក ហើយរូបពិតនោះក៏បញ្ចេញអារម្មណ៍កង់មានៅក្នុងវិញ្ញាណរបស់លោក ធ្វើឲ្យនៅសល់នូវសេចក្តីព្រួយលំបាកខាំងនោះ ដោយបង្ហាញសភាពខេត្តខ្វិមសារនៃរូបលោកនឹងទីក្រុងជាប៊ីឡាន ។

ចិត្តរបស់លោកកំពុងតែឡើងទៅកាន់លោកធាតុ ហើយលោកក៏បានតិចារណាចំពោះការរៀបចំចម្ងាយក្តីច្បាប់ កង់ចក្រភព ។ ប៉ុន្តែ, ដល់ចិត្តលោកវិលត្រឡប់មកកាន់ខ្លួនលោកវិញ លោកក៏បានគិតអំពីជោគវាសនារបស់លោកៗក៏បានយើញចំពោះធម្មជាតិទាំងមូល តែលោកហ្សាឌិតបិតនៅកង់ស្ថានភាពដ៏លំបាកប៉ុណ្ណោះ ។

កង់ពេលដែលលោកកំពុងតិចារណានូវខសរនវិញ្ញាជំប្រសើរនឹងខ្លួនវាខ្លួលំបាកជាអនេកប្រការ លោកក៏បានធ្វើដំណើរទៅកាន់ប្រទេសអេស៊ីប្ត ។ កង់ពេលនោះ ឥសាដែលមានចិត្តស្មោះស្ម័គ្រនឹងលោកបានទៅដល់កូមិមួយដ៏តក្រំប្រទល់ កំពុងស្វែងរកទីស្នាក់អាស្រ័យដែរ ។

ដល់លោកហ្សាឌិតអញ្ជើញទៅដល់កូមិនោះ លោកក៏ឆ្លៀតឱកាសអញ្ជើញទៅលេងកំសាន្តឯខ្ពង់ដែលបិតនៅជុងកូមិ ។ កង់ពេលនោះ លោកបានក្រឡេកឥច្ចល់ធំៗ ឃើញនារីម្នាក់យំខ្លួញស្រែកអំពាវនាវឲ្យមេយនឹងនាងគង្គីនក្រុងរណីជួយនាង ហើយមានបុរសម្នាក់កាចសាហាវដើរតាមពីក្រោយ ។ បុរសនោះកំពុងតែដញនាងទាន់ នាងកំពុងតុបក្បាលជង្គង់អង្វរបុរស ដោយពោលពាក្យគ្រប់យ៉ាង ។ បុរសនោះមិនតែបន្ទោសនាង ដោយពាក្យគ្រោះថ្នាក់ផ្សេងៗនោះទេថែមទាំង

ក៏យកដំបូងជាក់នាងទៀត ។ លោកក៏ចាប់ពិនិត្យមើលភាពរៈដ៏ឃោរឃៅ
នៃបុរសជាជនជាតិអេស៊ីប្ត ទើបភាពប្លែកពិរោធរបស់នាង ដោយគោល
ពាក្យអង្វរទៅកាន់បុរស ក៏យល់ថាបុរសជាអ្នកច្រណែន ហើយនារី
នោះជាអ្នកស្មត់ស្មោម ។ តែដល់លោកពិនិត្យចំពោះស្ត្រីនោះដែលមាន
រូបឆោមលោមតណ្ហាស្រស់ប្រិមប្រិយ, លោកក៏មានចិត្តអាណិតអាសូរ
ដល់នាង ហើយមានចិត្តស្អប់បុរសជាជនជាតិអេស៊ីប្តនោះទៅវិញ ។

នាងក៏ស្រែកឲ្យលោកហ្សូឌិតជួយនាង ដោយគោលពាក្យថា:
"សុំអ្នកជួយស្រោចស្រង់ខ្ញុំ ចូរអ្នកមាញខ្ញុំ ឲ្យផុតពីកណ្តាប់ដៃពីពុដ៏ខ
បុរសកាចកំពេលបួនជ្រុង សុំលោកជួយជីវិតខ្ញុំផង" ។

ដោយឮបម្រែកដូច្នេះ លោកហ្សូឌិតក៏រត់ទៅឈរនៅស្ទឹមរកេង
នាងទើបបុរសនោះ ។ លោកមានចេះភាសាអេស៊ីប្តខ្លះដែរលោកក៏ពោល
ជាភាសានោះថា: "បើអ្នកមានចិត្តសប្បុរសខ្លះ ខ្ញុំសូមចិត្តអ្នក ឲ្យគោរព
ចំពោះ លំអរទើបតូលភាពនៃស្ត្រីនេះ ។ តើអ្នកឯងមិនធើឲ្យខូចនូវ
លំអរដ៏ថ្លៃថ្លានៃធម្មជាតិដែលបិតនោជិតដើមដែលមានតែចិត្តកជាគ្រឿង
ការពារ ។

បុរសនោះទើបប្រឡោតស្រែកទៅកាន់លោកហ្សូឌិតថា: "ឯង
ស្រឡាញ់ស្ត្រីនេះដែរហើយអញត្រូវតែសងសឹកចំពោះឯងនេះវិញ" ។

បុរសនោះពោលដូច្នេះ ក៏ចោះបង់ចោលនាង ដែលគាត់ចាប់ចា ញ
សក់ហើយក៏ស្ទុះទៅកាន់លំពែង ដើម្បីទើលតមកចាក់លោកហ្សូឌិត។
មានស្មាតែវៃ ក៏ចាន់តេចផុតហើយស្ទុះទៅចាប់លំពែងត្រង់ពាក់

កណ្តាលដងអ្នកទាំងពីរនាក់ ក៏ប្រព័ន្ធភ្លាលំពែងនោះទៅក្បែរទៅមក លំពែងនោះក៏ជាក់ខ្លួចខ្លីអស់ ។ បុរសនោះហូតដាវរបស់ខ្លួន លោកហ្សាឯតក៏ហូតដាវដែរ ហើយក៏ស្ទុះទៅតាប់គ្នាទៅវិញ-ទៅមក ។ ជនសញ្ជាតិអេស៊ីប្តូបានតាប់លោកហ្សាឯតមួយរយដង តែលោកចេះតែការពារបាន ។ ស្ត្រីនោះអង្គុយលើស្មៅ ក៏រៀបចំមួកខ្លួនឲ្យបានស្រួលបួលត្រឡែកមកអ្នកទាំងពីរកំពុងតុនដាវ ។

ជនសញ្ជាតិអេស៊ីប្តូមានកាយដ៏មាំមួនជាងលោកហ្សាឯត តែលោកហ្សាឯតវៀងវៃប៉ិនប្រសប់ជាងគេ ក៏បានធ្វើឲ្យសត្រូវខ្លាក់អាវុធពីដៃបួលទៅចាប់កៀកគ្នាឆ្កែលៀតសល់ឱ្យសត្រូវនោះដួល ហើយក៏ក្រវែដាវយកមកដាក់ចំលើដើមទ្រូង តែលោកខុកដំរីតសត្រូវនោះ ឲ្យរស់ទៅ ។

ក្នុងពេលដែលលោកហ្សាឯត មានចិត្តសន្តោសត្រាប្រណី ជនសញ្ជាតិអេស៊ីប្តូដោយចិត្តខឹងហួសប្រមាណ ក៏យកដាវស្ទុះមកចាក់លោកហ្សាឯតតែលោកគេចខុត ក៏យកដាវចាក់ចំដើមទ្រូងសត្រូវដួលស្លាប់ក្នុងពេលនោះទៅ ។

លោកហ្សាឯតឯតបួលទៅដឹកមារីហើយនោះ គោលដៅយកជាស្រេចនិយាយថា: "បុរសនោះបានបង្ខិតខ្ញុំឲ្យខ្ញុំសម្លាប់គាត់" ។ ខ្ញុំក៏បានសងសឹកជូនខាងហើយ ខាងបានប្តូចព័ត៌ក្តាប់ដៃបុរសដែលមានចិត្តឃោរឃៅដ៏ម្ល៉ង់បំផុតដែលខ្ញុំមិនដែលឃើញសោះ ។ តើឲ្យខ្ញុំធ្វើអ្វីទៀតចំពោះខាង....។

-ខាងនោះក៏តបទៅលោកហ្សាឯតវិញថា: "អញ្ជើចង់ឲ្យឯងស្លាប់ ឯងត្រូវតែស្លាប់ ព្រោះឯងបានតំឃាដសង្សារបស់អញ។ អញ្ជើចង់តែហែក

លេះដូនឯងស៊ីគាំងសៅ ..." ។

លោកហ្សាឌិតក៏តបទៅវិញថា: "នាងឯងមានបុរសសង្សារប្លែកពីបុរសគាំងឡាយ ។ សង្សារនេះវាយដំប្រាំជាក់នាងឯងឥតមានត្រាប្រណីហើយ....." ។

នាងនោះក៏តបទៅលោកហ្សាឌិតតទៅទៀតថា: "អញាចង់ឲ្យគាត់វាយអញទៀត អញត្រូវតែគេវាយដូច្នេះឯង ព្រោះអញធ្វើអំពើមិនគួរគប្បី នាំឲ្យគាត់ច្រណែនចំពោះខ្លួនអញ ។ ល្អហើយគាត់វាយអញ។ ចង់ឲ្យឯងស្ងាប់ជួសគាត់ ឲ្យគាត់សៅមកវាយអញទៀត" ។

លោកហ្សាឌិតទឹកឆើឆឹងធ្ងល់ហើយមានចិត្តខឹងពន់ប្រមាណ ក៏ឆ្លើយតបទៅនាងវិញថា: "នែនាង, នាងឯង. ពិតមែនតែមានប្តូរឆើតធាយនាងឯងគួរតែអញវាយខើបសម ព្រោះនាងឯងប្លែកពីស្ត្រីធម្មតា តែអញមិនធ្វើទេ ក៏ស្អប់ដៃអញ...." ។

លំដាប់តមក លោកហ្សាឌិតក៏ដើរចេញតម្រង់ទៅភូមិនោះទៅ ។ ក្រោយដែលលោកចេញពីទីនោះបន្តិច ស្រាប់តែឮសូរដើងសេះបួនផ្សាយមកពីចម្ងាយជាប់ខ្លាំងឡាន ។ មានអ្នកជិះសេះម្នាក់ស្រែកឃើញនាងនោះក៏ឆោលពាក្យថា: "នាងនេះឯង" ហើយមានអ្នកជិះសេះទាំងពីរនាក៏ចាប់នាងព្រមនាក់លើខ្នងសេះបាត់ទៅ នាងនៅតែស្រែកឲ្យលោកហ្សាឌិតជួយ ដោយក៏ចាផ្តែមស្អែមថា: "ឧអ្នកមហាសប្បុរសអើយសូមលោកអ្នកអាណិតអាសូរដល់រូបនាងខ្ញុំចុះ នាងខ្ញុំសុទ្ធចិត្តបម្រើលោករហូតដល់ផុតដីតែឥន្ទ្រិយ....។

លោកហ្សាឌិត ក៏ឆោលតបទៅនាងវិញថា: នាងឯងឲ្យអ្នកណា

យកចុះ ឯខ្ញុំសេនីថាញ៉ាំបាយនាងឯងទៀតហើយ ។

លំដាប់តមក, លោកហ្សាឌិត; ក្រោយដែលបានធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗក៏លែងត្រឡប់មកកាន់ប្រទេសអេសិប្ត ដដែលវិញ ។ នៅទីនេះលោកបានយកបុរសម្នាយនាម "សេតុក" ជាមិត្ត ។

លោកសេតុក ត្រូវមានកិច្ចធ្វើពាណិជ្ជកម្ម ហើយត្រូវធ្វើដំណើរទៅកាន់កោះសេរេនីឌីប, តែលោកទើបនឹងរៀបរាប់ហាមឌ្គលការជាបឋមមិនអាចនឹងឃ្លាតចេញពីការិយាបថរបស់លោក ដែលជាទីគាប់ចិត្តបាន ។ លោកសុំឲ្យលោកហ្សាឌិត អញ្ជើញទៅកាន់គាប់មុខជំនួញនោះផ្ទួសលោកសិន ។

លោកហ្សាឌិតក៏ចាំនព្រមត្រៀង ទៅតំណើរទៅកាន់កោះសេរេនីឌីប ជំនួសលោកសេតុក ដែលទើបនឹងមានការិយាថ្មី ។ លុះលោកហ្សាឌិតអញ្ជើញទៅដល់ទីនោះ លោកទៅជាអាជ្ញាកណ្តាល សម្រេចការរវាងឥស្សរជនាយពាណិជ ជាកល្យាណមិត្តពួកបណ្ឌិត ហើយជាទីប្រឹក្សាពួកណា ដែលត្រូវការយោបល់អំពីលោក ។ កិត្តិសព្ទនៃលោកហ្សាឌិតក៏ផ្សាយទៅដល់ព្រះបរមពជកំងព្រះមហាក្សត្រីយ៍នៃកោះសេរេនីឌីប ទ្រង់មានព្រះពជចំណង់ចង់ឃើញលោកហ្សាឌិតនោះណាស់ ។ លុះលោកហ្សាឌិតចូលទៅក្រាបបង្គំគាល់ព្រះអង្គ ។ ទ្រង់ក៏មានព្រះពជឆ្ពោះសួរសេចក្តីប្រការ ទ្រង់យល់ជាក់ច្បាស់ថាលោកហ្សាឌិតជាអ្នកមានប្រាជ្ញាពិតមែន; មានព្រះពជហ្ឫទ័យទុកចិត្តចំពោះគតិបណ្ឌិតដែលលោកហ្សាឌិតបានក្រាបបង្គំទូលហើយទ្រង់យកលោកនេះធ្វើជាមិត្រយស់ព្រះអង្គនោះទៅ ។

(មានត)

អំពីបងប្អូនពីរនាក់

អ្វី

និង

មាន់ឈ្មោកក់

(ឥឡូវ)

លោកទៀង-តែឈុន ប្រែរៀបរៀង

លុះព្រះមហាកស្សត្រ ដែលមិនទ្រន់ជ្រាបថា មានស្រីខេពអប្សរតើវ
នាក់នេះ តួខនៅកន្លែងកេ ស្រាប់តែតើនឡើង ហើយឧតរយើញព្រះ
ស្នេយ ដែលចំនងជាមានឧជារស ហ៊ានឆ្ងាញ់ក្រៃលែងនេះ ក៏លាន់ព្រះ
ឧស្ឋថា "អញអត់អហារ ៧ ថ្ងៃហើយ ឥឡូវនេះ អញយើញ
អហារយ៉ាងអស្ចារ្យនេះ ! អ្នកណាធ្វើអហារនេះ ពុកឲ្យអញ ឬអាទិ-
ខេពនិម្មិតមក ឬ បុរសណាធ្វើអហារនេះ លាយទឹងថ្នាំពុល ដោយ
មានគោលបំណង ទីងសម្លាប់អញ បើពុកជាយ៉ាងណាក៏ដោយ អញត្រូវ
តែស្លាប់ ដោយអញខ្លាចមកពីអត់អហារ ឬ ដោយថ្នាំពុល អញត្រូវ
តែស៊ីអហារនេះសោ មើល ហើយបើគានបីយ៉ាងណា ក៏អញឃ្លាងរួចអំពី
សេចក្តីឃ្លាងម្តងមិនដែរ" ! ទ្រង់ប្រថុយសោយព្រះស្នេយ អស្ចារ្យនេះ
ដែលមានឧជារស គួឲ្យចាប់ចិត្ត ។ លុះសោយរួចហើយ ទ្រង់មានព្រះ
ទ័យធូរស្បើយ ប្រកបដោយសុខុមាលភាព យ៉ាងប៉ិបូណ៌ រួចពីនោះ
មកទៀត ទ្រង់យកភួកដំរីមកលាក់ពុត ហើយទ្រង់យកអង្ខាក់ទឹងមាន
យាងធ្វើដំណើរទៅមុខទៀត ទ្រង់យាងមិនឆ្ពោះទៅកន្លែងណាទេ នៅតែ
កន្លងព្រៃអស់ចំនួន ៧ ថ្ងៃ ៧ យប់ សោយតែផ្លែឈើ ហើយទ្រង់ពុំដែល

ចានព្រះស្វាយណា ក្រៅពីនេះមកសោយសោះ ។ នៅទីបំផុតទ្រង់អស់ព្រះកាយពល ហើយទ្រង់ឃ្លានព្រះស្វាយ យ៉ាងក្រៃលែង ។ ទ្រង់ត្រិះរិះដូចតទៅនេះថា "ខ្ញុំអញ ម្តេចក៏វេទនាដល់ថ្នាក់នេះ! ព្រោះតែអញ មានបំណងចង់ប្រសើរឆ្លើងជាងស្តេចទៅទៀត ទើបអញប្លន់នារយកមាន់នេះ, ឥឡូវ អញត្រូវឲ្យវេទនា តែម្នុងអញទៅវិញ"! រួចពីការត្រិះរិះនេះមក, ទ្រង់ចុះស្នងចងមាន់ ហើយរៀបចំដាក់អង្ករជាស្រេច ទើបទ្រង់យាងទៅតួនលបចាំមើលលទ្ធផល ដូចលើកមុនទៀត។

មាន់ខនះស្វាបរដាវ ៣ ដង ហើយចេះតែប៉ប៉ុកដដែ ។ បន្តិចមកស្តេចរមាសមកដល់ ឃើញហើយក៏ស្ទុះអស់ទំហឹងតម្រង់ទៅរកមាន់ ។ ស្រាប់តែកុយក៏ដាច់ពីថ្ងាស ធ្លាក់នៅដីតមាន់ ហើយក៏ត្រឡប់វិលចូលទៅព្រៃវិញ ។

នៅក្នុងកុយរមាស មានស្ត្រីទេពអប្សរម្នាក់ លាក់ចំពួនខ្លួន ។ ចំណែកឯមាន់កកាយដី ត្រូវពីលើកុយរមាសនោះហើយ ក៏ក្រាបប៉ប៉ុកដដែរទៀត។

ព្រះមហាក្សត្រកាលបើឥតឃើញស្តេចរមាស ស្ទុះអស់ទំហឹង ហាក់ដូចជាទៅចាំមាន់សម្លាប់ដូច្នោះ ក៏ទ្រង់ស្រែកថា "ឃើអើ! សត្វមាសនេះ មកពីណា ស្ទុះសំរុកមៅហែកមាន់អញស៊ុ" បន្ទាប់មក ទ្រង់រត់យ៉ាងលឿនតម្រង់ទៅកន្លែងដែលទ្រង់ចងមាន់ ហើយទ្រង់សព្វព្រះរាជហឫទ័យដោយឥតឃើញមាន់ កំពុងតែក្រាបប៉ប៉ុកដដែ ។ ទ្រង់ជកស្នឹងស្រាយមាន់ ពីចំណងយកមកបីនឹងព្រះហស្ត ។ នៅពេលនោះ ទ្រង់ឥតឃើញកុយរមាសធ្លាក់នៅទីនោះ ហើយទ្រង់រើសយកមក, ប៉ុន្តែទ្រង់មិនបាន

ជ្រាបថា មានស្ត្រីទេពអប្សរម្នាក់ នៅក្នុងកុយរមាសនោះទេ ។

ព្រះមហាសត្វ ទ្រង់យាងត្រឡប់មកដើមល្វា ហើយដោយព្រះអង្គទ្រង់អស់ព្រះកាយតបទ្ងាំងពេក, ទ្រង់ក៏ផ្ទំលក់ស្កប់ស្កល់នៅទីនោះ ។

ស្ត្រីទេពអប្សរ ដែលនៅក្នុងកុយរមាស មើលឃើញថា ព្រះមហាសត្វ ទ្រង់ផ្ទំលក់ស្កប់ស្កល់ហើយអត់ព្រះស្វាយ ក៏ចេញមករៀបចំព្រះស្វាយទុកជាក់ជិតព្រះអង្គ រួចចូលទៅភួនក្នុងកុយរមាសវិញ ។

លុះព្រះពាជាទ្រង់តើនឡើង ទតឃើញព្រះស្វាយអស្ចារ្យនេះស្ថិតនៅជិត ទ្រង់គិតថា "អើ! អញបានអាហារដ៏មានឱជារសនេះស៊ីម្ត ងទៀតហើយ! ប៉ុន្តែ អ្នកណាអាចដឹងបានថា អាហារនេះគ្មានលាយថ្នាំពុល? ល្អើយចុះ បើអ្នកណាច្រាច្នាចងដំបូលអញ ។ ត្រូវតែស្លាប់ទៅចុះ" លុះទ្រង់គិតយ៉ាងដូច្នោះហើយ, ទ្រង់បានសោយព្រះស្វាយនោះជារស្រេច ទើបទ្រង់មានព្រះហឫទ័យដូរសើយប្រកបដោយសុខុមាលភាពយ៉ាងបរិបូណ៌ ។

បន្ទាប់មក, ព្រះអង្គទ្រង់យាងធ្វើដំណើរតទៅទៀត, កាត់ព្រលឹងព្រៃចេញពីព្រៃកាត់ព្រល ។ មានមួយថ្ងៃនោះ, ព្រះពាជាទ្រង់សព្វព្រះពហុហឫទ័យ ឈប់នៅត្រង់កន្លែងមួយ, ទ្រង់ប្លោះស្នឹង ចងមាន់ នឹងរៀបចំជាក់អង្ករដូចលើកមុន ។ ទៀត ។ រួចស្រេច, ទ្រង់យាងទៅភួនលបចាំមើលលទ្ធផលនៅក្រោមដើមល្វា ។

ព្រះពាជាទ្រង់គ្មានទតឃើញលទ្ធផលអ្វីទាំងអស់ ដោយទ្រង់អស់ព្រះកាយតទ្ងាំងពេក, ទ្រង់ក៏ផ្ទំលក់នៅទីនោះ ។

រីឯមាន់នេះ មានលក្ខណៈដែលជាហេតុ មិនឲ្យគាត់បានមាន់ញី ដូចមានដែរ ។

បន្តិចមក, មាន់ទាំងនោះស្ងាបរងាវ ៣ ដង ។ ស្រាប់តែមានប្រាសាទមាស, ប្រាសាទប្រាក់, ផ្ទះគ្រប់បែប, ហាន់លក់ទំនិញគ្រប់យ៉ាង ផ្សារយ៉ាងល្អៗផុះឡើង ក្រចាំងក្រចែង មានពណ៌ក្រហមច្រាលឡើងហាក់ដូចជាមានអគ្គិភ័យ នៅលើមាន់ដែលនៅក្នុងមួយ ហើយមានកំណែងតិចតួចផ្សេងៗ ។

នៅពេលនោះ, ព្រះមហាសត្វត្រេតើនឡើង ស្រាប់តែឃើញអគ្គិភ័យរស់រវើកនេះ មានពន្លឺក្រហមត្រាងត្រាត ពាសពេញមហាមហ ។

ព្រះរាជាទ្រង់លាន់ព្រះឧស្ឋថា "ឃ្មាតអើ ! អ្នកណាដុតព្រៃ ? មាន់អញមុខតែនេះស្ងាប់ហើយម្ដងនេះ, អញនិញថ្ងៃស្មើនឹងរមួយភាំងមួល" ក្រោយមក, ព្រះអង្គទ្រង់យាងរត់សំដៅទៅរកមាន់គ្រប់កន្ទុង ហើយទ្រង់មានព្រះចិត្តាស្តាយមាន់នោះយ៉ាងក្រៃលែង ។

នៅពេលដដែលនេះ, ទ្រង់ទតឃើញប្រាសាទមាស, ប្រាសាទប្រាក់ដែលផុះស្មើភ្លឺក្រហមច្រាលឡើង ប្រជាជនគ្នាទៅគ្នាមកដោយអំណាចតេជៈទឹងតួងយ៉ាងល្អ ។ បំផុត ។ លុះទ្រង់រកឃើញមាន់នៅរស់ ហើយទ្រង់យាងតាមរកូវិថី ដែលមានផ្លូវល្អ ។ ទឹងហាន់លក់ទំនិញគ្រប់ហ្នឹង ហាក់ដូចជាព្រះអង្គ យាងទៅដល់នគរហន្ទសួតិ ។

គ្រានោះ ព្រះរាជាទ្រង់ត្រាបបង្ហាស់ថា របស់ទាំងនេះ ជាតែអស្ចារ្យ

ណាស់ ហើយទ្រង់ត្រិះរិះ ក្នុងព្រះចិត្តថា "យើអើ! បុរីទិព្វនេះ មិនមែនស្នាដៃរបស់មនុស្សធម្មតាទេ! តើពិតជាមានអញ្ចឹង មានលក្ខណៈត្រូវទៀងទាត់ បានប្រាសាទមាស,ប្រាសាទប្រាក់នេះ ដែលមានតន្ទឺត្រចះត្រចង់ ប្រកបដោយភាពស្អាតស្អំ" ។

បន្ទាប់មក, ទ្រង់យាងត្រឡប់ ទៅយកភ្នុកដំរីទាំងពីរ នឹងកុយរមាសហើយទ្រង់ឡើងមកគង់ក្នុងប្រាសាទទិព្វនេះ ជាមួយនឹងមាន ។

ឯស្រីទេពអប្សរ ដែលនៅក្នុងភ្នុកដំរី នឹងកុយរមាស បានចេញមកបង្ហាញខ្លួន ឲ្យព្រះមហាក្សត្រយើញ, ស្ត្រីទេពអប្សរទាំងបីនេះ មានរូបឆោមល្អ ។ ប្រកបដោយពណ៌ត្រចះត្រចង់យ៉ាងអស្ចារ្យ ។ បមាដូចជាស្ត្រីហានសួគ៌ ។ ព្រះមហាក្សត្រ កាលទតឃើញហើយ ក៏មានព្រះទ័យប្រតិព័ទ្ធស្នេហាចំពោះទេវកញ្ញាទាំងបីនេះ ព្រមទាំងសំដែងការក្តីផង ។

ព្រះពេជ្រទ្រង់តាំងស្ត្រីទេពអប្សរ ដែលនៅក្នុងភ្នុកស្តាំ, ជាមហេសីស្តាំ, តាំងស្ត្រីទេពអប្សរ ដែលនៅក្នុងភ្នុកឆ្វេង, ជាមហេសីឆ្វេង ។ ចំណែកស្ត្រីទេពអប្សរដែលនៅក្នុងកុយរមាស, ទ្រង់តាំងជាមហេសីកណ្តាល ។ រួចពីនោះមក, ព្រះអង្គទ្រង់សន្ទនាមនតរជា "បុរី-បុស្សា" ដែលជាក្រុងមានកើតឈ្មោះអស្ចារ្យ ក្នុងសាកលលោក ។

អ្នកជំនួញគ្រប់ប្រទេស បានទាំងទំនិញនឹងគ្រឿងបរិភោគ គ្រប់ថែបគ្រប់យ៉ាង ចូលមកក្នុងនគរបុរី-បុស្សានេះ ដែលស្គាល់តែសេចក្តី

សម្បូណ៌ សប្បាយនឹងសេចក្តីសុខស្ងាត់ក្សេមក្សាន្ត ។

ព្រះមហាក្សត្រទ្រង់ចាញ់មនុស្សលើកតម្កើងមានឫទ្ធិដ៏ខ្លាំងជាងអ្នកមានបណ្តាសក្តិធំតូច តាមសម័យនោះ នៅក្នុងព្រះពុទ្ធសាសនាចក្រ ។

ព្រះអង្គទ្រង់សោយពុទ្ធសម្បត្តិ នៅនគរនោះបាន ១០០ ឆ្នាំ ទើបព្រះអង្គ ទ្រង់ទីវង្គត ។ ឯមហេសីគឺនីបព្រះអង្គ ក៏ស្រាប់តែបាត់នៅពេលអាវជ្រៃ, ពីព្រោះវិមាននោះជាវត្ថុកើតឡើងដោយទិព្វិត ។

រឿងត្រៃដ៏នេះ សន្មតថា ចប់តែត្រឹមប៉ុណ្ណេះ ។

រឿងត្រៃដ៏ប្រយោជន៍	យើងដឹងវង្សពួជ
ទំនៀមធម្មាប់	ប្រវត្តិសាស្ត្រជាតិ
ប្រពៃណីតាប់	សង្គមស្រុកស្រាប់
ក្រមច្បាប់សាសនា ។	

ប. ប.

ដំណើរទស្សនាកសិកម្មរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះសោភ័ណ្ឌ ហួត_ភាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងតាកែវ

រៀបរៀងដោយ ជា.ទង់

សាស្ត្រាចារ្យទួលការងារខាងការបង្រៀនមធ្យមសិក្សា នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

(តទៅ)

អ្នកគ្រូដែលបង្ហាត់ មានឪពុកឈ្មោះ ឆ្នូ ចន្ទ្ឌ ដូច្នេះក្មេង ឈាស់ មានតុ-
កោសល្យសម្បាបបំណិ, គេបង្ហាត់ក្មេង ឲ្យលេង បង្ហាត់ដើរ.លេង.អត្តយ
ឲ្យច្រៀង ឲ្យពំ ឲ្យតែ ឲ្យដំយោយ ... គេបង្ហាត់ឲ្យកូនក្មេងៗ អាយុ
៤.៥.៦ ឆ្នាំ ហាត់ច្រៀងបទគោតេងដ៏ជាតិរបស់គេ ។ គេបង្ហាត់បង្រៀន
ភាសាល់ ធ្វើឲ្យក្មេងចូលចិត្ត ឲ្យស្រឡាញ់ដ៏ជាតិរបស់គេ ឲ្យស្រឡាញ់
សាលារៀន ឲ្យស្រឡាញ់ការរៀនសូត្រ ។ ដោយគាបង្កឹកបង្ហាត់បង្រៀន
ជាវេបទ តាំងពីតូចក្រចន្ទាយ៉ាងនេះ ហ៊ាន កូនប្រុសស្រីអាមេរិកាំងអាយុ
៧.៨ ឆ្នាំ នាំគ្នាដើរត្រសង ។ ដើរបណ្តើរច្រៀងគ្នាបណ្តើរ៧
សាលារៀន ដោយឥតនរណាបង្ខំអ្វីសោះឡើយ, គឺ៧សាលារៀន
ដោយសប្បាយ, មានត្រឹងសប្បាយនៅឯសាលា ។ នៅតំបន់ដែល
ឆ្ងាយៗ ពីសាលារៀន មានឡានធំៗហៅថា School bus ទៅដឹក
ជញ្ជូនកូនអ្នកស្រុកទៅ-មកសាលារៀន ។ ដូច្នេះ កូនក្មេងអ្នកស្រុកដែល

ខៅឆ្ងាយពីសាលា មិនមានលំបាកនឹងខៅសាលារៀនឡើយ ។

ខៅថ្នាក់ខ្ពស់ ។ កូនក្មេងធំ ។ អាយុ ៨.៩ ឆ្នាំឡើងទៅ, ការរៀនសូត្រ កំចេះតែចំរើនឡើង គ្រូអ្នកបង្រៀនក៏មានការប្រឹតប្រែបច្រើនជាងថ្នាក់ក្រោម ។ ។

គ្រូបង្រៀនប្រុសស្រី, សាស្ត្រាចារ្យ ទំនងសិស្ស ឬ និស្សិត មានការជិតជិត ទំនុកគ្នាណាស់, មិនមានប្រកាន់មានះ ចំពោះគ្នាទំនុកគ្នាខេ មានការគួរសម ចំពោះគ្នាទៅវិញទៅមក, មិនមានប្រើភាសាគំហកកំហែងគំរោះគំរាមទ្រគោះបោះបោករកគ្នាខេ ។ ច្បាប់តំាងឡាយណា ដែលគ្រូត្រូវប្រតិបត្តិចំពោះសិស្ស គេប្រតិបត្តិតាមច្បាប់នោះ ពុំហ៊ានឲ្យស្លៀងឡើយ ។

ចំណែកការសិក្សាខៅវិទ្យាល័យ ឬ មហាវិទ្យាល័យ មានរបៀបផ្សេងគ្នាជួចខ្លះនឹងពណ៌នាតទៅខេះ ៖

ខ្ញុំបានរំលឹកមកពីមុនខ្ញុំរៀបរាប់ហើយថា និស្សិតខៅមហាវិទ្យាល័យសុទ្ធសឹងធំ ។ អាយុ ១៧-១៨ ឆ្នាំទៅហើយ ហើយការរៀនសូត្រក្នុងមហាវិទ្យាល័យគេរៀបចំមហាវិទ្យាល័យពេជការដ្ឋ ឬ មហាវិទ្យាល័យឯកជនក៏ដោយ ក៏ត្រូវចេញថ្លៃឈ្នួលសាលា ទំនងថ្លៃផ្ទះសំណាក់អាស្រ័យ ។ ដូច្នេះ, ដោយហេតុនេះហើយ និស្សិតប្រុសស្រី តប្បីចេះរកប្រាក់ ។ ប្រាក់បានមក ដោយមធ្យោបាយណា គេត្រូវរកដោយមធ្យោបាយមែប នោះគេធ្វើគួលីស៊ុំឈួល ធ្វើការខៅហាងលក់ដូរផ្សេង ។ ហាងលក់ដូរថ្នាំ ហាងលក់ថ្នាំ ហាងលក់សៀវភៅ លក់កាសែត ឬ ខៅគោដនីយដ្ឋាន ធ្វើអ្វីក៏ដោយ ឲ្យតែបានប្រាក់ទំនងរៀនសូត្រ ផ្សេងៗទំនងប្រាក់

ដែលឪពុកម្តាយ ជួយចំនុកបំរុងផង អាចញ៉ាំងការសិក្សាឲ្យប្រព្រឹត្តទៅ
បាន ។ បានឮថា អ្នកស៊ីឈ្នួលធ្វើការជួរផង ។ តែងបានរ៉ាន់ឬថ្លៃឈ្នួល
យ៉ាងតិចមួយដុល្លារក្នុង១ម៉ោង ហើយបើធ្វើការខុសពេលម៉ោងថ្លៃឈ្នួល
ត្រូវខ្ពស់ឡើង មួយជាពីរឬជាពីរកន្លះ ក្នុងមួយម៉ោង ។ ហេតុនេះ និស្សិត
ប្រុសស្រីនៅមហាវិទ្យាល័យ តែងរៀបពេលធ្វើការ ក្រៅពីពេលរៀន គេ
រៀនផង ធ្វើការផង ។ ធ្វើការរៀងរាល់ថ្ងៃ បានលុយគាន់តែច្រើន,
ច្រើនជាងចំនួនច្រាក់ ដែលត្រូវបង់ឲ្យថ្លៃសាលា ឬផ្ទះសំណាក់។ តែទិញ
អ្វីដែលត្រូវការជាការចំបាច់ ទិញអ្វី? ទិញគ្មាន ! គ្មានជាជំនិះចាំបាច់
បំផុតនៅស.រ.អា, និស្សិតច្រើនគ្នា មានគ្មានផ្ទាល់ខ្លួន សំភារៈសម្រួលការ
រៀនសូត្រ មិនមែនជាជំនិះសំភារៈបង្ហូតគេ ឲ្យគេដឹងថាខ្លួនមានគ្មានដំនិះ
ទេ ឯគ្មានទៀតសោត ក៏ងាយទិញប្រើគ្រាសណាស់, គេមានលក់គ្មាន
ចាស់ ដែលគេប្រើ ២-៣-ឆ្នាំហើយ ទឹងគ្មានថ្មី តម្លៃមានតាំងពី ពី៥-ប៊ី.៤
រយដុល្លារ ឡើងទៅ ឯគ្មានថ្មី តម្លៃមានតាំង ពី១៧០០ដុល្លារ ទៅដល់៦
ពាន់ដុល្លារ ។

នៅមហាវិទ្យាល័យខ្លះ ,គេតម្រូវនិស្សិតប្រុសស្រី ធ្វើការយ៉ាងតិច
ដប់ម៉ោងក្នុង ១ សប្តាហ៍ ដើម្បីហាត់ហ្វឹក ឲ្យថ្នឹកនូវបំ ណះ ដែលបានរៀន
រួចហើយ,មានតិច្ចការគ្រប់ជំពូក ដែលគេលៃឲ្យនិស្សិត ស្រីប្រុសបាន ធ្វើ
គ្រប់គ្នា ។ មហាវិទ្យាល័យដែលគេតម្រូវឲ្យនិស្សិត ធ្វើការយ៉ាងដូច្នោះគេ
មិនយកថ្លៃឈ្នួលសាលាទេ ព្រោះគេឲ្យនិស្សិតធ្វើការឲ្យគេរាល់ថ្ងៃហើយ
ដូចជាធ្វើការនៅសណ្ឋាគារ,លក់ដូរ,គ្មាញ,ធ្វើគ្រឿងឈើ តុ ខ្ទះ។ល។

យ៉ាងដូចជា មហាវិទ្យាល័យបេរៀ ខែនរដ្ឋកេតឃី Berea KentucKy ជាដើម ប៉ុន្តែ គេយកថ្លៃឈ្នួលផ្ទះសំណាក់អស្រ័យ ។ ចំណែកខាងផ្ទះសំណាក់អស្រ័យនិស្សិត ចែកជា២យ៉ាងក៏មានដា ឲយ៉ាងគឺមានតឹមហាវិទ្យាល័យខ្លះ មានផ្ទះសំណាក់ សំរាប់និស្សិតប្រុស សំរាប់និស្សិតស្រី សំរាប់និស្សិតដែលមានប្តីប្រពន្ធ ។ ឯផ្ទះសិស្សសំណាក់អាស្រ័យនៅ ហៅថា Dormitory (F. Dortoir) ។

ទំសំណាក់អាស្រ័យនៃនិស្សិតគាំងឡាយ យើងសង្កេតឃើញក្នុង ១ បន្ទប់ៗ មានគ្រែពីរ ទំនិតុសរសេរពីរ សម្រាប់និស្សិតពីរនាក់ ក្រៅពីនេះ មានកន្លែងទទួលភ្ញៀវ ឬ កន្លែងអង្គុយលេង ដែលមានទូរស័ព្ទមួយទំនិទស្សនាវដ្តី កាសែត ទំនិសៀវភៅជាច្រើន, មានបន្ទប់ទឹកជាយថាឡែតគ្នា, នៅមហាវិទ្យាល័យខ្លះ មានបរិបូរដ្ឋាន (ដើងក្រាន) សំរាប់ចំអិនម្ហូបអាហារ តាមសេចក្តីត្រូវការនៃនិស្សិត ។ ជាសុភកាពនៃនិស្សិតគាំងឡាយ ដែលនៅរៀនក្នុងមហាវិទ្យាល័យមួយ ។ យើងឃើញថាមរិបូរគួរជាទីជ្រះថ្លា ក្នុងការរៀនសូត្រក្រៃពេក ។ កូនអាមេរិកាំងគាំងឡាយតែងបន្តការសិក្សារបស់ខ្លួន នៅមហាវិទ្យាល័យនានា ដូចខ្ញុំបានពណ៌នាដោយសង្ខេបមកនេះ ។ នៅមហាវិទ្យាល័យ មានរយៈពេលសិក្សា ៤ ឆ្នាំ យ៉ាងតិចគឺរៀន៤ឆ្នាំដំបូង ឃានសញ្ញាប័ត្រមួយហៅថា ឌីប្លូម៉ា, រៀន២ ឆ្នាំទៀតបានហាន:ជាមាស៊ស៊ើរ Maste Degree រៀន៤ឬ៥ឆ្នាំតទៅទៀតបានហាន:ជាដុកទ័រ ដែលជាហាន:ខ្ពស់បំផុតក្នុងមហាវិទ្យាល័យ ។ នេះជាការសិក្សាទំនឹរបៀបសិក្សាដោយសង្ខេបទាំងបរិបូរដ្ឋ ។

អំពីបណ្ណាល័យ ទីកន្លែងដ៏សំខាន់ដែលសិស្សនិស្សិតក្រុមគម្ពីរដើរតាងតែសាវនៃ ដើម្បីស្វែងរកចំណេះដឹងតាមអាន ហៅថា បណ្ណាល័យ (Library) ។ នៅសហរដ្ឋ មានបណ្ណាល័យជាច្រើនអនេកអនន្តណាស់ត្រង់សាលារៀន គេហៅថាសាលាបឋមសិក្សា តួចតាចយ៉ាងណាក្តី ធំក្តី សាលាមធ្យមសិក្សាក្តី មហាវិទ្យាល័យក្តី មានបណ្ណាល័យធំៗ សម្រាប់តុមារកុមារីសិស្សប្អូនិស្សិត ។ នៅមហាទីក្រុងនានាសុទ្ធតែមានបណ្ណាល័យ ។ ទីក្រុងតាំងឡាយ ស្រុក ឃុំ ភូមិតូចតាច ក៏មានបណ្ណាល័យដែរ ។ បណ្ណាល័យ ជាទីបណ្តុះពូជជាវៃឆ្លៀវឆ្លាចំណេះវិជ្ជាចំណែកមួយក្នុងបណ្តាគ្រឹះស្ថានសិក្សាតាំងឡាយ ។ បណ្ណាល័យប្រើនណាស់ ដែលព្រះគេជព្រះគុណព្រះគោធិវង្សទើងខ្ញុំបានឃើញក្នុងដំណើរទស្សនានេះ ។ ក្នុងបណ្ណាល័យមួយដូចមួយឃើញមានសៀវភៅសៀវភៅលាន ដែលគេដំតល់ទុកយ៉ាងមានរបៀបត្រឹមត្រូវ ក្នុងគាគារធំៗច្រើនជាន់, មានបន្ទប់អានធំល្វឹងល្វើយប្រដាប់ដោយតុកៅអី ភ្លឺដោយពន្លឺអគ្គិសនីព្រោនព្រាតគួរជ្រះថ្លា ។ ក្នុងបន្ទប់អាន គេឥតមានសួរសំដីអ្វីទាំងអ្វីរំខានអ្នកអាននោះឡើយ ។ បណ្ណារក្សច្រើនតែជាគេទស្រីជាអ្នកផ្គត់ផ្គង់រកសៀវភៅដល់អ្នកអានពាក់ព័ន្ធនាក់ក្នុង ១ ថ្ងៃ ។ ។

ឯសារមន្ទីរ គឺមានច្រើនពាន់ប្រមាណណាស់ ហើយមានអ្នកដំណើរទស្សនារៀងរាល់ថ្ងៃ ។ ខ្ញុំពុំអាចនឹងអធិប្បាយឲ្យសព្វគ្រប់អំពីសារមន្ទីរបានឡើយ ព្រោះនៅក្នុងសារមន្ទីរមួយ មានបុកណាតែ សារតែច្រើនពេកណាស់ តែខ្ញុំអាចបំព្រួញដោយខ្លីថា បណ្តាគ្រឹះស្ថានសិក្សា

ទាំងឡាយ សារមន្ទីរជាទីមានសារប្រយោជន៍សំខាន់ចំណែកមួយ ។ សារមន្ទីរជាកន្លែងបង្រៀនប្រវត្តិសាស្ត្រដល់អ្នកប្រវត្តិសាស្ត្រទាំងឡាយ ។ នៅក្នុងសារមន្ទីរនីមួយ ។, គេដាក់រូបចម្លាក់, ក្បាច់ក្បូរ, បុពណ៌ភាវគ្នា ដែលចង្អុលឲ្យឃើញនូវវប្បធម៌សម័យបុពណ៌នៃប្រទេសនីមួយ ។ អារ្យធម៌, វឌ្ឍនធម៌, វិប្បធម៌ សម័យបុពណ៌និងសម័យបច្ចុប្បន្ន នៃប្រទេសទាំងឡាយ គេអាចឃើញច្បាស់នៅសារមន្ទីរ ។ ដើម្បីឲ្យបច្ចាជនបានរៀនដូចគ្នាគារគ្រប់ផ្នែកសិក្សា ដូចជាខាងគ្រឿងចក្រ, គ្រឿងហត្ថកម្ម, លក្ខិសាសនាជាដើម គេបានបង្កើតឲ្យមានសារមន្ទីរជាច្រើន ។ សិល្ប: សម័យបុពណ៌ និងវិចិត្រសិល្ប: សម័យថ្មី, គេរៀបតាក់តែងមានរបៀបរៀបរយល្អ សម្រាប់សាធារណជនមើល ។

អំពីប្រជាជន.- សហរដ្ឋអាមេរិក ជាប្រទេសធំលំដាប់ណាស់ ព្រោះប្រទេសនេះ បានរួមរដ្ឋតាំង ៤៨ រួមចូលគ្នាតែមួយ ហៅថា សហរដ្ឋអាមេរិក តាមភាសាអង់គ្លេសថា United States of America (F. Etats Unis d'Amérique) ។ ភូមិភាគដែលបិតនៅក្នុងទ្វីបអាមេរិកខាងជើង ហៅថា North America ឬ ទ្វីបអាមេរិកដែលស្ថិតនៅខាងត្បូង ហៅថា South America ឬ អាមេរិកកណ្តាល ហៅថា Central America នេះមិនចាត់ចូលក្នុងសហរដ្ឋ ដែលមានរដ្ឋ ៤៨ រួមចូលគ្នានោះទេ ។

(មានត)

ព្រះរាជដំណើរសម្តេចព្រះឧបយុវរាជ
ទៅកាន់កោះសីរីលង្កាក្នុងពិធីបុណ្យពុទ្ធជយន្តី ។

សោភ័ណ-ឫក រៀបរៀង

កាលពីប្លែអង្គារ ទី១២ កុម្ភៈ ១៩៥៧ ម៉ោង ៧ ទឹង ១៥ នាទី, សម្តេចព្រះឧបយុវកដនកេតុមស័ហនុ ទ្រង់យាងចេញព្រះពជដំណើរដោយអាកាសយានពិសេស ក្រុមអាកាសយានខេមរភូមិន្ទ ឆ្ពោះទៅកាន់កោះសីរីលង្កា ។ ព្រះពជដំណើរនេះ គឺធ្វើដោយសេចក្តីអញ្ជើញជាផ្លូវការនៃរដ្ឋាភិបាលកុលម្ប៊ូ សូមទ្រង់យាងទៅជាព្រះពជកិត្តិយស ក្នុងពិធីបុណ្យពុទ្ធជយន្តិនៅប្រទេសសីរីលង្កា ។

បាននេះស្តេចយាង ទឹងអញ្ជើញទៅជាមួយទឹងសម្តេចតី ព្រះអគ្គម្ចាស់ក្សត្រី នរោត្តម-សូរ្យរៀងស៊ុ, ព្រះពជបុត្រី សហជីវិនីសាន-យុនវដ្ឋមន្ត្រីទីមួយទឹងលោកស្រី សហជីវិនីសឹង-សាន, សមញ្ញាណ, ហ៊ូ-ហុង ទឹងនាយគាហានពីរនាក់ ។

លុះដល់ម៉ោង ១១ ទឹង ៣០ នាទី សម្តេចទ្រង់បានយាងទៅដល់ទីក្រុងឆ្គីន (ប្រទេសកូមា) ហើយទ្រង់បានឈប់សម្រាកព្រះកាយពលខៅទីនោះ ។

ក្នុងពេលដែលទ្រង់យាងចុះពីព្រះទីនាំងអាកាសយានពិសេស, មានមន្ត្រីធំៗនៃក្រសួងការពារប្រទេស មានឯកអគ្គរាជទូតប្រទេសកម្ពុជាប្រចាំប្រទេសប៉ូលូញទឹងប្រទេសយូគូស្លាវីទឹងប្រតិភូនៃអគ្គរាជទូតសីរីលង្កាជាដើម បានអញ្ជើញទៅកាន់ស្ថានទីអាកាសយាន ដើម្បីសំដែង

តារាភាព ចំពោះព្រះអង្គជាព្រះពុទ្ធជិនវរស ។

ក្នុងពេលនោះ រដ្ឋាភិបាលប្រទេសភូមា គឺបានរៀបចំពិធីបុណ្យ
លៀងព្រះសោម នៅអាកាសយានដ្ឋាននោះ ។ លុះទ្រង់សោយព្រះ
ស្ងោយរួច ព្រមទាំងព្រះពុទ្ធបរិស័ទ ទ្រង់ក៏ចាប់ផ្តើមយាងឡើងព្រះទីនាំង
អាកាសយានពីសេសឆ្ពោះទៅកាន់ទីក្រុងព្រលគ្គ (ប្រទេសឥណ្ឌា) ។

ក្នុងពេលដែលទ្រង់យាងជុះតិព្រះទីនាំងអាកាសយាន, មានអ្នក
ដំណាងរដ្ឋាភិបាលចំនួន ប្រធានមហាពោធិសមាគមព្រលគ្គា និងការ
ជាន់ខ្ពស់នៃស្ថានឯកអគ្គរាជទូតប្រទេសភូមាប្រចាំប្រទេសឥណ្ឌាបានមកញ៉ែញ
ទៅសំដែងសេចក្តីគោរពចំពោះព្រះអង្គ ។

លំដាប់តមក មានពិធីទទួលទានព្រះសាសនា ដែលមហាពោធិ-
សមាគមទីក្រុងព្រលគ្គា បានចាត់ចែងឆ្លើចំពោះសម្តេច និងលោកជំទប់
ទីមួយ សាន-យុន ។

ក្រោយដែលមានពិធីបុណ្យតាមប្រពៃណីព្រះពុទ្ធសាសនា សម្តេច
ក៏បានយាងទៅតម្កើងលើរាជិកាកិត្តិយស ព្រមទាំងលោក សាន-យុន
និងព្រះពុទ្ធបរិស័ទ ។ ពេលនោះ មានភិក្ខុខ្មែរជាច្រើន ចាប់ផ្តើមសូត្រថា
សរសើរព្រះកិត្តិនាមសម្តេចព្រះទេបយុវាជ ដែលតិតតាលោកទទួលស្គាល់
ចំពោះសកម្មភាពព្រះអង្គខាងព្រះពុទ្ធសាសនានិងសន្តិភាពលោក ។

លំដាប់តមក សម្តេចទ្រង់ថ្លែងទុរិព្រះពុទ្ធសង្ឃថាមួយ ខ្លួលអំណរ
គុណយ៉ាងក្រៃ ចំពោះពួកពុទ្ធមាមកជន ទាំងគ្រហស្ថទាំងបព្វជិត
ដែលអញ្ជើញមកប្រជុំក្នុងទីនោះ, ព្រមទាំងបញ្ជាក់នូវការប្រាស្រ័យដ៏

ដ៏តស្ដួចតាឆនៈយោធាយ សម្បៈទើសាសនា រវាងប្រទេសកម្ពុជានឹង ប្រទេសឥណ្ឌា ហើយទ្រង់ប្រទានពរសំពះសាធុការ, សូមឲ្យ ប្រទេសឥណ្ឌា ប្រែប្រួលដោយសន្តិភាពនឹងសម្បូណ៌ភាព សមតាម បំណងតរៀ ។

ក្នុងឧកាសនៃពិធីបុណ្យនោះ សម្តេចបានធ្វើព្រះរាជអំណោយចំពោះ ប្រជាទមបាវោធិសមាគម នូវព្រះពុទ្ធរូបប្រាក់មួយអង្គ នឹងបច្ច័យ ១០០ រៀល ។ ចំណែកឯមហាវោធិសមាគម ក៏បានថ្វាយចំពោះព្រះអង្គនូវ ព្រះពុទ្ធរូបធ្វើពីទ្រឹមច័ន្ទន៍មួយអង្គ ។

សម្តេចព្រះបយុវរាជ, ព្រះអង្គម្ចាស់ក្សត្រី សូរ្យាវឿងស៊ី វង្សមន្ត្រី ទីមួយសាន-ឃុន នឹងលោកស្រីជាកើតិ្តយសនៃនាយករដ្ឋម័ន្ត្រីសៅ ទីក្រុងកាលកត្តា ។

ថ្ងៃពុធទី ១៣ កុម្ភៈ

ម៉ោង ៧ សម្តេចទ្រង់យាងចេញពីទីក្រុងកាលកត្តា ដោយព្រះរាជ-ទីនាំងអាកាសយានតិសេស បន្តព្រះរាជដំណើរទៅដល់ទីក្រុងម៉ាទ្រាស៍ (ប្រទេសឥណ្ឌា) ពេលថ្ងៃត្រង់ត្រូវនាំងព្រះរាជបរិវារ ។ រដ្ឋាភិបាល នៃទីក្រុងម៉ាទ្រាស៍ ក៏បានរៀបចំទទួលស្វាគមន៍ចំពោះសម្តេច ព្រះបយុវរាជ ទើនាហ៊ុនដែលធ្វើដំណើរជាមួយនឹងព្រះអង្គ ។

ម៉ោង ១៤, សម្តេចទ្រង់បន្តព្រះរាជដំណើរ ត្រឡប់ទៅកាន់ទីក្រុង គុលម្ប៊ូ ដែលទ្រង់យាងទៅដល់ពេលម៉ោង ១៧ ។

វង្សមន្ត្រីបីរូប បានអញ្ជើញទៅសំដែងការគោរពចំពោះសម្តេចនៅ

ចំណតអាកាសយាន ជាព្រះពុទ្ធសិត្តិយស ។

កន្លងពេលដែលសម្តេចយាងចុះពីព្រះទីនាំងអាកាសយាន មានតំណើរ
ឆ្ងាញ់ម្តែមួយពាក់ ថ្វាយជាព្រះពុទ្ធសិត្តិយស ។ លំដាប់តមកលោកស្រី
ប័ន្ធារនៈ អ៊ីរ៉ែ (Bandaranaike) ភរិយារដ្ឋមន្ត្រីទីមួយនៃប្រទេសស៊ីលង្កា
(ដោយស្លាប់មានពេគាពាធ) ទំនិញប្រធានព្រឹទ្ធសភាបានអញ្ជើញទៅ
ទទួលសម្តេច កន្លងពេលដែលសម្តេចយាងចុះ ពីព្រះទីនាំងអាកាសយាន ។
បុត្រលោកនាយករដ្ឋមន្ត្រីនាំពីរនាក់ បានយកកន្ទងបុប្ផាមកថ្វាយសម្តេច
ទំនងព្រះអគ្គម្ចាស់ក្សត្រីសុរ្យាវឿនស៊ី ។

លំដាប់តមក, ក្រុមនាយឥហានឈរគោរពសម្តេច ហើយ
សម្តេចទ្រង់យាងត្រួតពល, រួចព្រះសង្ឃបានចំរើនពុទ្ធជ័យមង្គលថ្វាយ ។
កន្លងពេលនោះ ពួកមន្ត្រីធំតូចនាំងអស់នឹកឥហាន បានអញ្ជើញមក
ទទួលសម្តេច ព្រមទាំងប្រជាជនប្រុសស្រីគឹកកងរំពង ពេញចំណត
អាកាសយាន; ពួកការទូតនានាប្រទេស ក៏បានអញ្ជើញមកគោរព
សម្តេច ហើយបរិយាកាសកន្លងពេលនោះ មានសភាពរីករាយផ្សព្វផ្សាយ
ពេញទីក្រុង ប្រកបដោយទិដ្ឋភាពស្រស់ស្រាយសប្បាយ ជាអនេក.
ប្បការ ។

រួចសម្តេចទ្រង់បានចុះព្រះហត្ថលេខាលើ " សៀវភៅមុវ័ណ្ណ "
ហើយទ្រង់ថ្លែងព្រះពុទ្ធសុន្ទរកថាដូចតទៅនេះ ៖

ព្រះពុទ្ធាគិចាលខ្ញុំបានទទួលយល់ព្រមដោយសេចក្តីសោមនស្ស
ជាយ៉ាងក្រៃពេកចំពោះការអញ្ជើញដោយស្មោះស្ម័គ្រ នៃរដ្ឋាគិបាលប្រទេ

សសរីលង្កា ហើយបានចាត់ព្រះពជគណៈប្រតិភូមួយ ដើម្បីសៅរួមប្រជុំ
កុដ្ឋពិធីបុណ្យពុទ្ធជយន្តិនេះ ។

កុដ្ឋព្រះបរមមាម នៃព្រះករុណាជាអម្ចាស់ដ៏វិសេសលើសត្វទ្រង, ព្រះនាម
នៃពជរដ្ឋាភិបាល ទឹងប្រជាជាតិខ្មែរ, ខ្ញុំមានកិត្តិយសក្នុងឋានៈ ជាប្រធាន
គណៈប្រតិភូ ដែលមានទត្តមបុគ្គលិកប្រទេស ជាសាមាជិក ថ្វែងនូវសេចក្តីសោមនស្សរីករាយ យ៉ាងក្រៃលែង ។ ដោយខ្ញុំបានមកកាន់ប្រទេស
របស់អ្នក ដែលជាប្រទេសមានការប្រកាន់យកខាងរឿងពីព្រះពុទ្ធសាសនា
ជាអនេកប្បការ ហើយជាប្រភពនៃព្រះពុទ្ធសាសនា មានសភាពដូចគ្នា
ទឹងប្រទេសកម្ពុជា ខ្ញុំមានបំណងជាបឋមចង់ទាំងសេចក្តីគោរពដោយចិត្តភក្តី
ទឹងភាតរភាព នៃពួកពុទ្ធសាសនិកជនខាងឯបព្វជិតជាង ៨០,០០០ រូប ទឹង
ត្រហ្ម ៤ ម៉ឺនខាត់ មកដូនចំពោះពួកទេវាសកទេវាសិកាប្រទេស
សិរីលង្កា ។

លំដាប់តមក, ខ្ញុំមានបំណងបញ្ជាក់ត្រង់លក្ខណៈដ៏ជិតស្និទ្ធ
ជាយ៉ាងជ្រាលជ្រៅនៃការគេមនាគមន៍ ដែលមានដែនការណ៍ទាំងអស់
ខាងសាសនា, សិល្បៈការពុធមិ, ទំនៀមទម្លាប់ ធ្វើឲ្យប្រទេសទាំង
ពីរជួបមុខគ្នា តាំងពីច្រើនសតវត្សរ៍មកហើយ ។

មិនតែប៉ុណ្ណោះ ដោយមានជំនឿក្នុងព្រះពុទ្ធសាសនាដូចគ្នា ប្រ
ទេសសិរីលង្កាទឹងប្រទេសកម្ពុជា ក៏បានទទួលអនុមតិនូវនៃយោបាយ
អព្យាក្រឹតភាពទឹងសហការប្រកបដោយសន្តិភាព ចំពោះប្រជាជាតិ
ទាំងអស់ ដែលគោរពឯកភាពទឹងអធិបតីភាព របស់ប្រទេសយើង ។

នេះយោងជាយថានេះ បានស្ថាបនាខ្លួនចំណែងជាថ្មីមួយវេនប្រទេសទាំងពីរទៅវិញទៅមក, ដែលមានចិត្តជាប់ស្និតទៅនឹងព្យាប់ស៊ីលធម៌ សេចក្តីត្រមត្រៀងវេនជាតិ នឹងសន្តិភាពពិភពលោក ។

គណៈប្រតិភូរបស់យើង មានចិត្តសោមនស្សជាមុន ដោយបានមកកាន់ទីនេះ ជាហេតុឲ្យលើកកិត្តិយសចំពោះពិធីបុណ្យពុទ្ធជយន្តីនៅទីនេះ ហើយមានបំណងជាយ៉ាងខ្លាំងក្លា ចង់ឲ្យគណៈប្រតិភូប្រទេសសីរីលង្កា, អញ្ជើញទៅកាន់ពិធីបុណ្យដូចគ្នា ដែលប្រទេសកម្ពុជានឹងធ្វើក្នុងនៃទសភាគ៍មុខនេះ ដើម្បីនឹងតម្កើនខ្សែពិធីបុណ្យនេះ ឲ្យកាន់តែទទួលរីករឿងថែមទៀត ។

ខ្ញុំគ្រឿងជាក់ថា ការដែលយើងបិតនៅប្រទេសអ្នក នឹងនាំឲ្យយើងមានចំណេះថ្មី ដែលជាហេតុធ្វើឲ្យសមភាពវេនប្រទេសយើងទាំងពីរឲ្យកាន់តែមានពលភាពឡើង នឹងបញ្ជូរស្មី ចូលមកបិតនៅកងទ្រព្យរបស់យើង ឲ្យកាន់តែភ្លឺស្វាងរុងរឿងឡើង ហើយនឹងស្ថាបនាខ្សែចិត្តយល់ជាក់ច្បាស់ដ៏ប្រសើរ រវាងប្រជារាស្ត្រ ជាបងប្អូនរួមសាច់ឈាមទាំងពីរ ជាគំរប្យកាពតទៅអនាគត ។

(មានត)

សន្និសិទនៃបណ្ឌិតវិស្សព៌អេក្លាត

ធ្វើនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ

លោក ញ៉ុយ.ប៊ុត រៀមរៀង

(តមក)

៣:- វិជ្ជាដែលជាមូលដ្ឋាននៃការសិក្សាព្រះពុទ្ធសាសនា

តាមសេចក្តីពិតក្នុងការសិក្សាថា បើគោលបំណងបានគិតត្រឹមត្រូវ ហើយ ជាន់ថ្នែងខុសហើយ បានយល់ច្បាស់ហើយថាជាគោលបំណងដែលហត្រូវបំពេញឲ្យសម្រេច ហេតុនោះរឿងរ៉ាវប្រវត្តិដែលត្រូវសិក្សាត្រូវលែលកឲ្យសមតាមគោលបំណងនោះ ព្រោះថាការពិចារណាតទៅមុខនូវគោលបំណងដើម នៃការសិក្សាព្រះពុទ្ធសាសនាជាន់ចង្អុលយ៉ាងច្បាស់លាស់ដល់វិជ្ជា ដែលគួរសិក្សាទើបត្រឹមត្រូវ គឺធម៌ ការចេះដឹងអំពីសង្គមមនុស្សទើបវត្តដែលនៅជុំវិញ ។

ការរៀនធម៌បែបចាស់គឺ ការគាន់ទើបខ្ចប់ចូលនូវគ្គណាមួយ ឬគាំងអស់នៃព្រះសូត្រ ព្រះវិន័យទើបព្រះអភិធម្មក្នុងគម្ពីរមួយ ឬច្រើនដោយភាសា ភូមា ខ្មែរ លាវសេរីលង្កា ឬថៃ ដែលប្រែពីធម៌នោះមកក្នុងក្បួនតម្រា ទើបមេរៀន ឬមួយវិញទៀត ដែលគេហៅថា ពាក្យអត្ថាធិប្បាយ។ ការរៀនដោយវិធីគាន់ទើបខ្ចប់នោះ ទើបប្រើសម្រាប់សិក្សាធម៌ ដែលមានក្នុងភាសាបំស្រ្តិត ទីបេត៏ ចិន ជប៉ុន ទើបភាសាឯទៀតផង ។ ការសិក្សាធម៌បែបចំនេះ គឺរួមការសិក្សាបែបចាស់

ទំនឹងការអធិប្បាយអត្ថន័យតាមការសាបច្ចុប្បន្នឲ្យបានសេចក្តីចប់សាស់ ទំនឹងរក្សាតម្លៃរបស់ការសាឲ្យបានគង់ជួចដើម ។

តាមការពិត ការសិក្សាអត្ថបទទំនឹងគម្ពីរទំនើបនៃជនជាតិអាស៊ីទំនឹងបច្ចុប្បន្នកាយបានជួយរក្សាធម៌ទំនឹងអត្ថាធិប្បាយនៃធម៌នោះ ។ ព្រោះជាការបំពេញគោលបំណងក្នុងការសិក្សាព្រះពុទ្ធសាសនាឲ្យបានពេញបរិបូណ៌ ។

ការសិក្សាព្រះពុទ្ធសាសនាតាមការពិតនោះ រមែងខាន់ការលាខាន់សម័យជាទិច្ចតាំងខាងផ្លូវទ្រឹស្តីទំនឹងផ្លូវប្រតិបត្តិ ត្រូវអាស្រ័យលើការស្រាវជ្រាវដ៏មានប្រយោជន៍ ទំនឹងធ្វើឲ្យបានស្រួល ដោយមិនបាច់គិតដល់យុគណា ឬ សម័យណាទេ ។

ការចេះដឹងអំពីរឿងសង្គមមនុស្សទំនឹងតែ ដែលខៅជុំវិញជាការមួយដ៏សំខាន់បំផុតក្នុងការរៀនព្រះពុទ្ធសាសនា ។ ព្រោះថាគម្ពីរទំនឹងការពិ. ភោធន៍ខាងផ្លូវព្រះពុទ្ធសាសនា ធ្លាប់មកឡើងដោយការពិភាក្សាអង្គុយរមនុស្ស ឲ្យឃើញថា ជា ពុទ្ធំ អនិច្ចំ ទំនឹង អនត្តា ។ ព្រះពុទ្ធសាសនាបង្រៀនឲ្យស្គាល់ ឲ្យចេះរឿងជាក់ ។ ក្នុងរឿងនេះការសិក្សាឯទៀតគ្រាន់តែជាព្រះពុទ្ធ-សាសនា ក៏ខៅគ្រាន់រឿងដែលភាក់ទងនឹងគម្ពីរព្រះពុទ្ធសាសនា ហេតុនោះទើបគ្មានការជំទាស់គ្នាខៅវិញខៅមកពេលការរៀនព្រះពុទ្ធសាសនា ទំនឹងចំណេះវិជ្ជាដទៃទៀត ក្នុងការសិក្សាព្រះពុទ្ធសាសនា ។ បើពិចារណាតាមប្រវត្តិសាស្ត្រ ក្នុងធម៌មានទីអាងជាច្រើន ដែលភាក់ទងដល់លក្ខខ័ណ្ឌបញ្ហា ទំនឹងសេចក្តីត្រូវការរបស់សង្គម បានព្រះពុទ្ធសាសនាជាគ្រឿងនាំផ្លូវឲ្យសមកាលទំនឹងសម័យនៃការបង្រៀនដូសិក្សាអត្ថបទ ។

ព្រះសម្ពុទ្ធជាម្ចាស់ ចានត្រាស់ដឹងជាតិតប្រាកដនូវតែដែលនៅជុំវិញ
ពីកាយនឹងសង្គម ហើយទ្រង់ប្រទានពាក្យប្រៀនប្រដៅរបស់ព្រះអង្គឲ្យ
ចាក់ឱនទឹងរៀនតាំងនោះផង ។ តាមសេចក្តីពិត លក្ខណៈនៃទុក្ខ អនិច្ច
ទឹងអនត្តា តែងកើត មានដល់សង្គមទូទៅ ដូចជាកើតមានដល់បុគ្គលពាល់រូប
ឥតចន្លោះដូច្នោះដែរ ។

ការពិចារណាឲ្យឃើញច្បាស់ ទឹងអធិប្បាយឲ្យចានឃើញទូទៅសម្ព-
ន្ធសច្ចនឹងកម្ម ត្រូវអាស្រ័យការចេះដឹងវត្ថុនៅជុំវិញខ្លួនដែលបុគ្គលម្នាក់ ។
អាចសង្កេតឃើញច្បាស់លាស់មួយវិញទៀត ការប្រតិបត្តិតាមផ្លូវអដ្ឋង្គិក
មគ្គនឹងការបំពេញចារមី១០ ដែលចានចំរើនហើយ អាចនាំឲ្យចានដល់ដំរៃ
ដ៏ប្រសើរសម្រាប់បុគ្គលនឹងសង្គម ។

ការចេះដឹងដែលគួរពឹងផ្អែកចាន គឺការចុំនប្រសប់ដែលសន្សំទុក
របស់បុគ្គលម្នាក់ៗនឹងការស្គាត់ដំនាញក្នុងគ្នានៃសង្គម ។ ហេតុនោះការចេះ
ដឹងនេះរមែងចានលក្ខណមកពីការប្រតិបត្តិភាពពីដើមមក ទឹងជាចំណេះ
វិជ្ជាខាន់សម័យជានិច្ច ។ ក្នុងអតីតកាលក៏ដូចជាក្នុងពេលបច្ចុប្បន្ន
ដែរ ការសិក្សាព្រះពុទ្ធសាសនា ត្រូវរៀនឲ្យស្គាត់ដំនាញក្នុងការសិក្ស
ភាសាស្ត្រ ប្រវត្តិសាស្ត្រការប្រែប្រួលនៃសង្គម ការស្គាល់តម្លៃនឹង
សកម្មភាពនៃសេដ្ឋកិច្ច គោលបំណងនឹងវិធីសិក្ខុត្តមគតិមនុស្សជាតិចំ
ពោះច្បាប់ទឹងសេចក្តីយុត្តិធម៌ ការបណ្តុះបណ្តាលបុគ្គលិកលក្ខណៈឲ្យចាន
ពេញលី គោលបំណងស៊ីវិល សង្គមកិច្ចត្តមគតិខាងសង្គមវិជ្ជា ការប្រតិ
ប្រតិបត្តិការស្រាវជ្រាវខាងផ្លូវវប្បធម៌ ចរិយាសាស្ត្រ ជីវភាពក្នុងសម័យ

វិទ្យាសាស្ត្របណ្ដាលឱ្យទទឹងពិភពលោក សម្រាប់រក្សាខុសខ្លួរក្តីមតិកដ៏ថ្លៃថ្លារនៃគំនិតទឹងស្គាច់នរបស់មនុស្ស ។

ទំយាយដោយខ្លី វិធ្លាដែលជាមូលដ្ឋានៃការសិក្សាព្រះពុទ្ធសាសនាត្រូវឱ្យមានវិធ្លាដែលគួរសិក្សា ត្រូវដំពូកដើម្បីឱ្យបានសម្រេចតាមគោលបំណងនៃសង្គម ។

៤.. របៀបជាមូលដ្ឋានៃការសិក្សាខាងព្រះពុទ្ធសាសនា

ការរៀនសូត្រទឹងវិធីបង្រៀនខាងការសិក្សា ព្រះពុទ្ធសាសនានោះតែងត្រូវការជាធម្មតា ខ្លួរបៀបខ្លះដែលជាមូលដ្ឋានចំពោះគោលបំណងទឹងកម្មវត្ថុ ។ នៅទំនេរកើដូចគ្នា ទឹងទីដៃដែរ: ការរៀនសូត្រទឹងការបង្រៀនការសិក្សាទឹងការអប់រំ ត្រូវអាស្រ័យគ្នាទៅវិញទៅមក ទើបបានសម្រេច ។ ការសិក្សាខាងព្រះពុទ្ធសាសនា ធ្វើឱ្យនិស្សិតទឹងត្រូវបង្រៀនបញ្ចូលមកគ្នាខ្លួរតុបំណងទឹងការពិសោធន៍តែមួយ ។

វិធីរៀនខាងព្រះពុទ្ធសាសនាតាមទំនៀមទំលាប់ មានការស្ដាប់គ្រូបង្រៀន ការរកខុសរកត្រូវទឹងការដង្ហឹងគិតដោយខ្លួនឯង ក្រឹងថ្ងៃដោយមាត់ឬដោយការសរសេរ ការសាកសួរ ទឹងការសាកល្បង ការទន្ទេញចាំមាត់ទឹងការប្រតិបត្តិអំពីមុខវិធ្លាដែលបានរៀនមកហើយ ។ របៀបបែបនេះនៅតែមានប្រើប្រាស់ក្នុងសម័យសិក្សាបច្ចុប្បន្ន ទោះបីវិធីសូត្រទឹងវិធីអធិប្បាយខុសគ្នាយ៉ាងណាក៏ដោយ ។

ការប្រតិបត្តិជាមូលដ្ឋានក្នុងការសិក្សាព្រះពុទ្ធសាសនា តាមប្រពៃណីគ្មានអ្វីជាជាងវិធីរៀន ដែលសំដែងក្នុងអរិយសច្ច ៤ ខេ ដំបូង

បង្អស់ ការសង្កេតនឹងការរួបរួមរឿងរ៉ាវដែលទាក់ទងខាងជីវិតដ៏មិនទៀង ទាត់,ទីពីរ វិធីរកឧស្សាហ៍នឹងការស្វែងរកហេតុផល ។ សម្រួយសច្ចៈ ពីរ ក្បួនទៃទ្រឹស្តីដែលអាចអនុវត្តទៅតាមស្ថានការណ៍ ឬ ការរំលត់ សម្មាដ្ឋានៃទុក្ខ "ទិពេធសច្ច" នឹងពីរបួន ការធ្វើឲ្យច្រាកដឡើង នូវទ្រឹស្តី ឬការត្រួតពិនិត្យសម្មាដ្ឋានៃនិពេធសច្ច ដោយប្រតិបត្តិតាម "មគ្គសច្ច" ។ វិធីរៀនតាមប្រពៃណីក្នុងព្រះពុទ្ធសាសនា គោងប្រកប ដោយការស្រាវជ្រាវក្នុងវិន័យសាស្ត្រ ខាងសង្គមកិច្ចនឹងខាងរូបកាយ ។

វិធីបង្រៀនខាងព្រះពុទ្ធសាសនាតាមទំនៀមទំលាប់មានន័យយ៉ាងច្រាប់ ដល់ក្លួកអ្នកសិក្សា ការធ្វើអត្ថាធិប្បាយដោយសរសេរដោយលក្ខណ៍ អក្សរ ការធ្វើសាកច្ឆា នឹងការណែនាំឲ្យស្រាវជ្រាវ ហើយនឹងការ បង្ហាញពហាវណ៌នៃវត្តុដែលប្រទ្រឿង ។ តរុកោសល្យបែបនេះគោះបីក្នុង រង្វង់ស្ថានការអប់រំដែលមិនទាក់ទងខាងព្រះពុទ្ធសាសនាក៏ដោយ ត្រូវយក មកប្រើក្នុងសម័យបច្ចុប្បន្ន ។

ហេតុនេះ វិធីជាមូលដ្ឋានៃការសិក្សាខាងព្រះពុទ្ធសាសនា ទើប ជាការសិក្សាតាមប្រពៃណីនឹងសម័យថ្មី ដោយមានបញ្ចាក់ក្នុងការប្រតិបត្តិ ដែលបានតាំងឡើង នឹងធ្វើឲ្យបានរុងរឿងឡើងដោយការប្រើប្រាស់នឹង ដោយផ្លូវបែងចែកខុសទំនើប។ ពិធានការដែលបានលទ្ធផលល្អនឹងការស្រួល ក្នុងការរៀនមើលបង្រៀនខាងព្រះពុទ្ធសាសនា តែងបានប្រយោជន៍ទំនឹងគួរ ច្រាប់ជាទិច្ច ទីបំផុតសាតថ្មីក្នុងការសិក្សារមែងប្រែប្រួលទៅតាមវត្តុ ដែលទៅជុំវិញ សង្គមតែមួយដងក្នុងសម័យនៃប្រវត្តិសាស្ត្រ ។ (មានត)

(តមពី)

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

-នាសិកា ស្ត្រី. ចុងនៃច្រមុះ។ -នវូបណា នបុ. ការិយាសម្រេចមុន។-ឋ គុ ដែលឆ្ងាយមុន ។- ឋាណ បុ. ចុងនៃដៃ, ដៃស្តាំ ។- ឋាន បុ. ចុងនៃផើង; ច្រាមដឹង។ -បូជា ស្ត្រី. ពួជាដំប្រសើរ ។-បេយ្យ នបុ. ការិយាឆាំងមុន ។ -ប្រតាយ៉ិន គុ.អ្នកប្រគល់ឲ្យមុន ។-ប្រតិណ្ឌ គុ. ដែលមានកំពូលបែកបាក់។-ភាគ បុ.ភាគដ៏ខ្ពង់ខ្ពស់,កំពូល ។ -ភុជ គុ. ដែលស៊ីមុន បុ. ព្រះអាទិត្យ ។ -ភូ គុ. ជាមេ,ជាប្រធាន។-ភូមិ ស្ត្រី.ជាន់ខាងលើ, សេចក្តីប្រាថ្នាជាន់ខ្ពស់ ។- ភោជិន គុ.អ្នកបរិភោគវត្ថុដ៏ប្រសើរ។ ភោជ្ជ គុ.ដ៏ចអគ្រភោជិន។មហិមិ ស្ត្រី. អត្តមហេសី ។ -មាឍ្យ នបុ.ប្តិត,ដួងដំណឹង។-យាត ក.ន. អ្នកដើរខាងមុខ ។- យាន, នបុ. ដំបាំនទៅមុខដើម្បីតស៊ូសត្រូវ, អត្រយាន។-យាយិ៍ គុ.អ្នកដើរមុខ; អ្នកនាំ ។ - រយោជិន គុ. ដែលមានយោធា,មេទាហាន ,ទ័ពស្រួច,ដើងឯក ។ វីរ ។. វីរបុរសដ៏ប្រសើរ ។ -ឝ្រិ១ គុ.ដែលមានអណ្តាតភ្លើងស្រួច ។ - សំ១ា ស្ត្រី.សំឡេងដើម,ជាន់ទីមួយ ដើមខ្សែ។ -សំឝ្យា ស្ត្រី. កាលទាងដើមនៃសត្វវៃលោ,អរុណ ។ -សន្ធានី ស្ត្រី បញ្ជីព្រះយមរាជ ។- សរ គុ.ដែលប្រព្រឹត្តទៅក្នុងទាងមុខ; -សរតា ស្ត្រី. ភាវនៃ..... ប្រព្រឹត្តទៅក្នុងទាងមុខ ។ -សុច ស្ត្រី. ចុងនៃឆ្នូល ។ - ហ គុ. ដែលជាមេ។ - ហស្ត បុ. ច្រាមនៃដៃ,ប្រមោយ។ - ហាយ ណ បុ. ទាងដើមនៃឆ្នាំ, តាមទៃនៃហិណ្ឌូ (ត្រូវនឹងប្រហែលថ្ងៃទី ១២ ខែធ្នូ) ។ - ហារ បុ. ការព្រះរាជទាននដ៏ដល់ព្រាហ្មណ៍,ដីឬភ្នំដែលទ្រង់ប្រទាន ។ អគ្រាក្សិ (អគ្រ+អក្ស) នបុ. ការិយាប្រឡោកមើល,ចុងនៃភ្នែក ។ អគ្រាង្គ (អគ្រ+អង្គ) បុ. ន្ធបអគ្រភាគ ។ អគ្រាន្ត (អគ្រ+អន្ត) បុ.ចុងនៃរស្មី។-

(មានត)

តន្ត្រីសន្ទនា

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ១១ ខែវិច្ឆិកា ព.ស. ២៥០០ គ.ស. ១៩៥៧



ភ្នំពេញសន្ទេយ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	បញ្ជីរឿង	ទំព័រ
	–ពុទ្ធប៊ិតុបវិនិច្ឆាទ ព្រះមហា ធូ-សុទ្ធ រៀបរៀង	៩៦៣
	–ពុទ្ធគុណ លោក ប៊ូ–ប៊ូ រៀបរៀង	៩៧៤
	–សេចក្តីពិចារណានៃពុទ្ធសាសនិកជនម្នាក់ . . . លោក ភ័យ–ប៊ុក រៀបរៀង . . .	៩៨០
ផ្នែកអក្សរសាស្ត្រ		
	–សុភាសិតណាវ លោក ភ័យ–ប៊ុក ជំរះស្រង់រៀបរៀង	៩៨៣
	–រឿងទេវន្ទេះបស់អម្រឹតក្សត្រី ម៉ុក (តមក) លោក ញ៉ុក-ថែម ពិនិត្យ	៩៨៧
	–រឿងសាមពុក (តមក) ឧកញ៉ា ធូ-កន ប្រែ រៀបរៀង	១០០៧
	–រឿងហ្សាឆិត (តមក) .លោក ភ័យ-ប៊ុក ប្រែ រៀបរៀង	១០១៨
ផ្នែកកំណត់ធម៌ប្រវត្តិការណ៍		
	–ដំណើរទស្សនាការសហរដ្ឋអាមេរិកនៃព្រះតេជព្រះគុណព្រះគោធិវង្ស (តមក) លោក ជា-ទង់ រៀបរៀង	១០២៣
	–ព្រះកាងដំណើរសម្តេចព្រះឧបយុវរាជ.ឥតាន់កោះ សិរីលង្កា ក្នុងឥតិធបុណ្យ ពុទ្ធជយន្តី (តមក) លោក ភ័យ-ប៊ុក រៀបរៀង. .	១០៤៩
	–សន្ធិសីទនៃ បណ្ឌិត-វិស្យាទ័ (អេស្លាត) ធ្វើនៅ-ពុទ្ធិកវិទ្យាល័យព្រះសុគម្រឹត (តមក) លោក ភ័យ-ប៊ុករៀបរៀង	១០៣៦
	–ចែតានុក្រមសំស្ក្រឹត-ខ្មែរ (តមក) ព្រះមហា ចាំងខាត់ រៀបរៀង	១០៤៤
	–សេចក្តីផ្តួចដំណឹងអំពីទស្សនាវដ្តី កម្ពុជសុរិយោដ្ឋាំ ១៩៥៨	

ម្ហូយឆ្នាំមាន ១២ សៀវភៅ ដំរៀបជាវ ២៣០រ៉ៀល

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIÈRES

PARTIE RELIGIEUSE:

-Bouddhaparinibbana par Vén. *THOU-SOTH* 963
-Bouddhaguna par *M. BOU-PO* 975
-Réflexion d'un bouddhiste par *M. RAY-BUC* 980

PARTIE LITTÉRAIRE:

-Recueil de proverbes laotiens par *M. RAY-BUC* 983
-Histoire de Devanda de *M. MOK* (suite)
revue et corrigée par *M. NHOK-THEM* 987
-Histoire de Samkok (suite) traduit par *M. NOU-KAN* 1007
-Histoire de Zadig (suite et fin) traduit par *M. RAY-BUC* . . . 1018

NOTES ET CHRONIQUES :

-Voyage du Vénérable HUOT-TAT aux
U. S. A. (suite) par *M. CHEA-TON* 1023
-Voyage de Samdach Préah Upayuvareach à Ceylan lors de la fête du Buddha Jayanti (suite et fin) par *M. RAY-BUC* . . 1029
-Conférence du Dr. RICHARD A. GARD au Lycée Buddhique Preah Suramarit (suite et fin) par *M. RAY-BUC* . . 1036
-Dictionnaire khmèr-Sanskrit- (suite) par Vén. *PANG-KHAT* . . . 1044
-Avis de la Revue Kambujasuriya 1958.

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

ពុទ្ធបិតុបវ៉ាំងញ្ញាន

បរិច្ឆេទទី ២៦ នៃពុទ្ធប្រវត្តិ

ព្រះមហា ធ្លុះ-សុន្ទ សាស្ត្រាចារ្យនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រឹត ទេសនា

នៅថ្ងៃសុក្រ ១៣ ខែឧសភា ២៥៦ ១៩៥៧

ក្នុងឱកាសបុណ្យ ព.ស. ២៥០០

ឥមោ ភគវន្ត ភគវន្តោ អរហន្តោ សម្មាសម្ពុទ្ធស្ស ។

សូមនមស្ការ បិទោះព្រះភគវន្តមុនីអរហន្តសម្មាសម្ពុទ្ធអង្គនោះ ព្រមទាំង ព្រះធម៌នឹងព្រះអរិយសង្ឃ ដោយសេចក្តីគោរព ។

ពេលនេះ ជាពេលត្រៃមាសទី ៥ នៃឆ្នាំបុណ្យ ព.ស. ២៥០០, ដែលកើតឡើងយ៉ាងឧឡារិកអស្ចារ្យ ដោយកម្លាំងសទ្ធា ឧត្តមសេចក្តីត្រេកត្រអាយ៉ាងមានមុត នៃពុទ្ធបរិស័ទគ្រប់ភាន: ។

ខ្ញុំព្រះករុណា អាត្មាភាពសូមដែន " ដំណើរណែនាំបង្ហាញនៃពុទ្ធបិតា " ត្រង់បរិច្ឆេទទី ២៦ នៃពុទ្ធប្រវត្តិ ដូចតទៅនេះ :

ដំណើរបង្ហាញនៃពុទ្ធបិតា

ព្រះពុទ្ធបិតា គឺព្រះបាទសុទ្ធោទនសក្យរាជ ព្រះចៅក្រុងកបិលព័ស្តុ ក្នុងប្រទេសឥណ្ឌា ដែលសព្វថ្ងៃមានឈ្មោះថា " នេប៉ាលរដ្ឋ " មានព្រះនាងមហាមាយាទេវី ជាព្រះពោធអគ្គមហេសី ។ ព្រះអង្គជាធម្មិក.

មហាភាគ ទ្រង់គ្រប់គ្រងប្រជាពលរដ្ឋប្រកបដោយទសពិធធម៌គាំង ១០ ប្រការគ្មានឃ្លៀងឃ្លាត ។ ទាន់ក្រោយមក, ទ្រង់មានព្រះរាជបុត្រមួយព្រះអង្គ ទ្រង់ព្រះនាមថា "សិទ្ធត្ថ" ។ កាលព្រះរាជទេវីបានព្រះជន្មាយុ ១៦ ព្រះវស្សារហើយ ទ្រង់អភិសេកឲ្យគ្រងរាជសម្បត្តិដ៏ធូរសព្រះអង្គ ។

លុះកន្លងមកខាងក្នុំ, ក្រោយពេលដែលព្រះរាជបុត្រលះបង់រាជសម្បត្តិ ចេញទ្រង់ព្រះផ្នួសហើយ; ការគ្រប់គ្រងក្រុងកបិលព័ស្តុ ក៏បានធ្លាក់មកលើព្រះអង្គម្ចាស់ទៀត ។

តាំងពីព្រះរាជបុត្រទ្រង់ចេញព្រះផ្នួសមក ទ្រង់តុំដែលបានដំណឹងអ្វីពីតក្រោកដល់ព្រះអង្គសោះ, លុះកន្លងមក ៧ ខ្នាំ ទើបបានជ្រាបដំណឹងពិតថា "ព្រះរាជបុត្របានត្រាស់ដឹងជាព្រះសព្វញ្ញាតុទ្ធកន្លងលោកហើយ, សព្វថ្ងៃ ទ្រង់ប្រថាប់នៅវត្តវេឡុវ័ន ក្រុងរាជគ្រឹះ" ។ ដំណឹងនេះធ្វើឲ្យទ្រង់តែកយល់ជាអនេក ប្រាថ្នាចាត់ព្រះរាជទូតឲ្យទៅទទួលព្រះសាស្តាជាច្រើនលើកដងរហូតដល់បានសម្រេចដូចព្រះបំណង ។ ក្នុងទីបាសាដែលព្រះសាស្តាស្តេចយាងទៅសំដែងធម៌ប្រោសព្រះបិតា ព្រមទាំងព្រះញាតិទាំងឡាយក្នុងព្រះរាជធានីកបិលព័ស្តុ, ថ្ងៃមួយ ព្រះពុទ្ធបិតាបានសម្រេចលោកុត្តរកិរិយាសម័យ ថ្វាយអាសនៈសាមគ្គីធម៌ ដោយពុទ្ធបិតាសំគាល់ថា "ទុតិយំ ទស្សនំ" ដូច្នេះជាដើម; តមក បានសម្រេចបាតិមោក្ខសីល ដោយពុទ្ធបិតាសំគាល់ថា "ធម្មញ្ចរេ សុចរិតំ" ដូច្នេះដែរដើម ។

ថ្ងៃក្រោយមកទៀត ទ្រង់បានសម្រេចដល់ថ្នាក់អនាគាមិផល ដោយទ្រង់ព្រះសណ្តាប់នូវធម្មបាលជាតក ។ តពីនេះទៅ ទ្រង់តុំតាំងបានសម្រេច

ទូវគុណធម៌អ្វីដទៃទៀតទៅទៀប ។ រហូតដល់ដកកាតបូលមកដល់ ធ្វើ
ព្រះសពាង្គកាយរបស់ទ្រង់ ឲ្យដល់ទូវការទ្រុះទ្រោមទុព្វលភាពថមថយ
ចុះទៅជាលំដាប់ ។

កាលនោះ ព្រះសម្ពុទ្ធភាស់ ចានគ្រាស់ដឹងឡើងក្នុងលោកអស់
រយៈកាល ៥ ព្រះវស្សាហើយ, ក្រោយដែលព្រះអង្គស្តេចយាងទៅកាន់
ញាតិសមាគម ក្រុងកបិលព័ស្តុជាលើកដំបូង; ដើម្បីសំដែងធម៌ប្រោស
ញាតិទាំងឡាយ មានព្រះពុទ្ធបិតាជាដើម, ព្រះអង្គព្រមទាំងតំកុសង្ឃ
ជាបរិវារ ស្តេចយាងនិមន្តទៅកាន់វេឡុវនារាម ក្រុងរាជគ្រឹះវិញ ។ លុះ
ដល់វស្សាទី ៥ ទើបទ្រង់យាងចេញព័ក្រុងរាជគ្រឹះ ទៅកាន់កូដាគារសាលា
នាព្រៃមហាវ័ន ជិតក្រុងវេសាលី ដើម្បីអនុគ្រោះដល់វេនេយ្យសត្វ ក្នុង
ទីនោះ ។

គ្រានោះ ព្រះចាតុម្បរិសុទ្ធោទនមហារាជ ជាពុទ្ធបិតា ស្តេចទ្រង់
ប្រឈួនជាខ្លាំង ដោយព្រះពោគជរា ។ ព្រះពោគនេះ ចានចាក់ដោត
ចូលក្នុងព្រះអង្គ ធ្វើឲ្យទ្រង់ខ្លួលវេទនា ដល់ទូវការឈឺចាប់យ៉ាង
ខ្លាំង ។ សក្យរាជវង្សាឡាយ ចានខ្នះខ្នែងស្វែងរកគ្រូពេទ្យនឹងឱសថ មក
ព្យាបាលរម្ងាប់ព្រះពោគនោះណាស់ដែរ ប៉ុន្តែ តុំចានលទ្ធផលសោះ ។
ព្រះពោគាពាធ នៅតែបន្តសកម្មភាព ឈឺចាប់ចាក់ដោត ក្នុងព្រះអង្គចំរើន
ខ្លាំងឡើងជាលំដាប់ ។ គេលនោះ ដោយកម្លាំងទុក្ខវេទនាគ្របសង្កត់ខ្លាំង
ពេក បណ្តាលឲ្យទ្រង់ត្អូបំរះទៀលប្រែចុះប្រែឡើង លើសិរីសយនា
ទ្រង់នឹកឃើញដល់ព្រះសារីបុត្តដោយព្រះតម្រិះថា " ពោគាពាធដែលចាក់

ដោត ក្នុងសាច់ខ្លួនកាយអាត្មាអញក្នុងគ្រានេះ មានតុខ្លួនលំបាកក្រៃណាស់ ពុំអាចស្វែងរកទុសថតិសេសណាមួយ មកជួយបន្សាបឲ្យស្ងប់រម្ងាប់បានទេ, បើប្រសិនជាបានព្រះសាស្តា មកស្ងាបព្រះសិរសា, ព្រះអានន្ទត្ថេរ ទ្រង់ព្រះខន្ធដ៏មានអាយុ មកស្ងាបអង្អែលព្រះជាសុកា ឥន្ទ្រដ៏ធំទាំងសង្ខាន ព្រះកហុលជាព្រះពន្ធុតា មកស្ងាបអង្អែលព្រះបិដ្ឋ នៃអាត្មាអញឥឡូវនេះ សង្ឃឹមថា ទុក្ខវេទនា ទីធំកោតពាងទាំងអស់នេះ ទីធំបានជាសះស្បើយពុំខាន ។

គ្រានោះ, ព្រះសម្ពុទ្ធដ៏ឆ្ងាប់ ទ្រង់គង់នៅឱ្យជាប់ស្រួយាល ព្រះកេតុមតិ ដែលព្រះអង្គកំពុតមែន, ប៉ុន្តែ ហាក់ដូចជាទ្រង់ប្រថាប់នៅ ក្បែរតែយ៉ាងនោះទ្រង់ដែរ, ព្រោះព្រះអង្គមានព្រះញាណតិះសេសជាសព្វ. វិញ្ញុបុគ្គល ទ្រង់ជ្រាបច្បាស់ឥតវើសឆាត់ នូវភ្លើតភ្លើការណ៍ទ្រង់យ៉ាងដែលកើតមានឡើងក្នុងលោក ។ តាស្មឹ បន បច្ចូសសមយេ ដូនជាក្នុងបច្ចូសសម័យថ្ងៃនោះ, ព្រះអង្គទ្រង់ប្រមើលមើលនូវខបនិសស្សយនៃសត្វលោក ដែលគួរត្រាស់ដឹង ទីធំមិនគួរត្រាស់ដឹង គឺទ្រង់ឆ្លុះនូវសេចក្តីដឹងសព្វរបស់ព្រះអង្គ ដើម្បីតិះតិស្យមើលនូវជនាគម្មរបស់រៀនយ៉ាសត្វក្នុងសាគលលោកទាំងមូល ឲ្យដឹងថា តើសត្វចំពួកណាខ្លះ ដែលមានបុព្វបទិសស្សយជាសមា គួឲ្យព្រះអង្គយាងទៅទាក់ទង ប្រោសប្រទីក្នុងវេលាព្រឹកនេះ ។ ខណៈនោះ ព្រះអង្គទ្រង់ជ្រាបច្បាស់ដោយព្រះចេតោបរិយាញាណថា " ព្រះពុទ្ធបិតាទ្រង់ប្រឈួនជាខ្លាំង ហើយទ្រង់នឹកជាខ្លាំងដល់ព្រះអង្គ ត្រមង់តែព្រះសង្ឃជាសាវ័ក " ទើបទ្រង់ព្រះតម្រិះថា " ព្រះ

ពុទ្ធបិតាទ្រង់ប្រឈួនក្នុងគ្រានេះ ហាខមួនឡាំងណាស់ គួរតែឯងទៅ
គាន់សំណាក់ព្រះអង្គ ក្នុងកាលឥឡូវនេះ ដោយពិត" ។ លុះទ្រង់ព្រះ
តម្រិះដូច្នេះហើយ ទើបត្រាស់ហៅព្រះអានន្ទមកហើយ ទ្រង់ត្រាស់
ថា "អានន្ទ! ឥឡូវនេះ ព្រះពុទ្ធបិតាស្តេចទ្រង់ប្រឈួនជាខមួនណាស់,
ចូរអ្នកចេញទៅឲ្យដំណឹងដល់ព្រះសង្ឃ ឲ្យបានដឹងគ្រប់គ្នា ហើយប្រាប់
ទៀតថា "យើងនឹងទៅគាន់សំណាក់ព្រះអង្គក្នុងកាលឥឡូវនេះ" ។
ព្រះអានន្ទ, ក្រោយដែលថ្លាបង្គំលាព្រះពុទ្ធដីកាហើយ, ក៏បានផ្សាយ
ដំណឹងនោះដល់ភិក្ខុសង្ឃគាំងពួង តាមព្រះពុទ្ធតម្រាស់ ។

នៅពេលដែលព្រះសង្ឃគាំង ៩០០ អង្គ មកជួបអស់ហើយ ទើប
ព្រះសាស្តាទ្រង់នាំព្រះសង្ឃគាំងនោះហោះឆ្ពោះទៅតាមអាកាសវេហាស៍
ដែលមានល្បឿនដូចផ្គរបន្ទោរ ខ្លោះទៅគាន់ក្រឡឹកបិលតំស្តុកដប្បុរី ចុះ
នៅនាព្រះឈានទៃព្រះពជនិវេសន៍ ។ ដល់ហើយទ្រង់នាំព្រះសង្ឃចូល
ទៅគាន់ព្រះពជមន្ទីរ ខតយើញព្រះពជា ទ្រង់ប្រឈួនមានព្រះកាយ
ពុតូលកាត ដុំស្តុកស្តឹងលើព្រះសេយ្យា ក្នុងកណ្តាលចំណោមព្រះញាតិ
គាំងពួយ ដែលកំពុងខ្វល់ខ្វាយបំរើ ទីឆ្ងាចាលព្រះពេតនេះ
ដោយសេចក្តីក្រៀមក្រំ; ទើបព្រះសាស្តាទ្រង់ប្រថាប់ ជិតព្រះពុទ្ធបិតា
ហើយតាំងទិត្យមើលអាការពេតនោះ ក៏បានជ្រាបដោយសព្វគ្រប់ ប៉ុន្តែ
ទ្រង់សាកសួរព្រះអង្គថែមទៀត ដើម្បីបន្ទរសេចក្តីតាងតឹងព្រះហឫទ័យអំពី
ពុទ្ធវេទនាថា "បពិត្រមហាពជ! ព្រះពេតាតាងកន្លងព្រះអង្គល្មមអត់ធន់
បានដែរឬទេ? ព្រះពុទ្ធបិតាទ្រង់តបថា "ព្រះពេតាតាងកន្លងសញ្ញត្តិកាយ

របស់ខ្ញុំព្រះអង្គ ក្នុងពេលនេះឆ្ងន់ណាស់ ពុំអាចនឹងអត់ធន់បានទេ" ។
ក្រៃណោះ ព្រះសាស្តាទ្រង់សណ្តែកព្រះហត្ថាធ្វើសច្ចាចំដ្ឋានថា "តថា-
គតតាំងពីបានចំណូលខ្លួនវត្ថុពួកព្យាករណ៍ក្នុងសំណាក់ព្រះពុទ្ធទីបង្គរមក បាន
កសាងអភិនីហារបំពេញសមត្តឹស បារមី អស់បួនអសង្ខ្យៃ នឹងមួយ
សែនកប្ប ដើម្បីប្រយោជន៍ពីរយ៉ាង :

មយ៉ាង ប្រយោជន៍នៃការត្រាស់ដឹងរបស់តថាគត ។

មយ៉ាងទៀត ប្រយោជន៍គឺការពង្រីក ផ្សព្វផ្សាយសេចក្តីសុខស្ងប់
ដល់សត្វលោកខ្លះៗ ដោយធម្មទេសនា, ឥឡូវនេះ តថាគតនៅមានកិច្ច
ត្រូវបំពេញតែប្រយោជន៍ ខាងព្រះនេះទៀតទេ ហើយយកព្រះហស្តស្តាំ
ស្ទាបអង្អែលយ៉ាងឋេរ លើព្រះសិរសានៃព្រះពុទ្ធ ដោយព្រះហឫទ័យ
ប្រកបដោយសេចក្តីករុណាយ៉ាងធំទូលាយ ។ ខណៈនោះ ព្រះពោគ-
ភាព ក្នុងព្រះសិរីអង្គានោះឯងក៏អស់ទៅ ។ តមក ព្រះអានន្ទត្ថេរ ក្រោយ
ដែលបានឮសម្តីព្រះសាស្តា ក៏ធ្វើសច្ចាធិដ្ឋានទឹកដល់គុណធម៌ ដែល
ខ្លួនបានបំពេញមក អស់កាលដ៏យូរអង្វែងហើយ, ក៏យកព្រះហស្តស្ទាបព្រះ
ឆាសុកាខាងស្តាំ ។ ការឈឺចាប់ត្រង់កន្លែងនោះ ក៏រំងាស់ចាត់អស់ទៅ
មួយរំពេច ។ បន្ទាប់មក ព្រះអានន្ទដ៏មានអាយុ ក្រាបបង្គំព្រះសាស្តា
ហើយធ្វើសច្ចាធិដ្ឋានថា " ខ្ញុំព្រះអង្គតាំងពីបានខំប្រឹងមកក្នុងសម្តីមក បាន
ខ្លួលប្រតិបត្តិគ្រប់ប្រការ របស់ព្រះសាស្តា ដោយឥតក្តុងក្រវែលប្រហែស
ឡើយ, នេះជាសេចក្តីពិតរបស់ខ្ញុំព្រះអង្គ" ហើយលើកព្រះហស្តស្តាំស្ទាប
អង្អែលព្រះឆាសុកាខាងឆ្វេង ។ ព្រះពោគាភាពត្រង់កន្លែងនោះ ក៏រំងាស

ចាត់អស់ភៅ ។ តពីនោះមក ព្រះកហុលបានថ្វាយបង្គំព្រះសាស្តាហើយធ្វើសច្ចាធិដ្ឋានថា "តាលតីអតីតជាតិ ខ្ញុំព្រះអង្គបានកើតជាកុមារឈ្មោះជាលី ព្រះមហាមុនីទ្រង់ឧត្តមព្រះទ័យ ទើបព្រះរាជទានខ្ញុំព្រះអង្គឲ្យទៅសួរមរណភាពក្រកំម្លាស់ឈ្មោះ ជូជកព្រាហ្មណ៍ តាលនោះ ខ្ញុំព្រះអង្គក៏ពុំបានតាក់តែងចិត្តអ្វីនឹងព្រះអង្គទេ, បេះតែទំនុកអត់សង្កត់ចិត្ត ក្នុងការខ្ចូលរឹងឆ្កួត ទើបខណ្ឌកម្មគ្រប់យ៉ាង នៅពេលដែលព្រាហ្មណ៍ចេញទៅ ដើម្បីជាកម្ចាំងក្នុងការជួយបំពេញបារមីរបស់ព្រះអង្គ ឲ្យបានពេញលេញ នេះជាសេចក្តីពិត ក្នុងអតីតកាលរបស់ខ្ញុំព្រះអង្គ" ហើយសូមអង្វរព្រះបិដ្ឋព្រះអយ្យកោ ដោយព្រះហស្តរាងស្តាំ។ ការចាក់ដោតបុកសៀត ត្រង់កន្ទែងនោះ គំរាបសូន្យអស់ភៅ ។

គ្រានោះ ព្រះសិរីសុភោទនមហាពជ បានជាសះស្បើយចាកព្រះពេគាពាធ ទ្រង់មានចិត្តសោមនស្សរីករាយ ទើបសុទ្ធតាតជាអនេកប្បការ ទ្រង់ក្រោកចាកសិរីសយនា ធ្វើអញ្ជលីកម្មថ្វាយបង្គំព្រះសាស្តា ព្រមទាំងព្រះសង្ឃជាសាវ័ក ។ ប៉ុន្តែ ព្រះពុទ្ធទ្រង់ត្រាបថា " សុទ្ធតាតរបស់ព្រះពុទ្ធបិតា បិតនៅក្នុងអនិច្ចតាធម៌ មិនបានតាំងនៅបិតរយៈកាលប៉ុន្មានឡើយ គឺទ្រង់គង់នៅតែ ៧ ថ្ងៃទៀតទេ ទើបបរិនិព្វានហើយ ឥឡូវនេះ ទ្រង់ពុំទាន់បានសម្រេចលោកុត្តរធម៌ជាន់ខ្ពស់ គឺព្រះអរហត្តផលនៅឡើយ" ទើបព្រះអង្គទ្រង់សំដែងធម៌ ដែលទាក់ទងដោយព្រះត្រៃលក្ខណ៍ តម្រូវតាមបុព្វបទិស្ស្រយពាសនានៃព្រះពុទ្ធ ដោយព្រះពុទ្ធដីកាជាដើមថា " បពិត្រព្រះមហាពជ! នាមរូបំ អនិច្ចំ នាមរូបមនិច្ចន្តិ

តែងវិប្រែប្រួលឬវិបរិតជាធម្មតា នាមរូបំ ខុក្ខំ នាមរូបជាទុក្ខ" តឺតែងជួបប្រទះនឹងសេចក្តីលំបាកវេទនា ដែលកើតពីការប្រែប្រួលនៃសង្ខារជាធម្មតា នាមរូបំ អនត្តា " នាមរូបនេះស្មោះសូន្យ គ្មានខ្លឹមសារ គ្មានឥស្សរភាព គ្មានអំណាចអាចយោគ កុំឲ្យប្រែប្រួលដូច្នោះបាន" ។ បន្ទាប់មកទ្រង់សំដែង សាមុក្កំសិកធម្មទេសនា តឺអរិយសច្ច ៤ មានទុក្ខសច្ចជាដើម ដែលអាចទាញមនោសញ្ចេតនា នៃព្រះពុទ្ធបិតាឲ្យយល់ច្បាស់ថា "លោកទាំងមូលជាទុក្ខ, ការកកើតឡើងនៃលោក ការប្រែប្រួលនៃលោក, ការប្រុះនាំបែកធ្លាយទៅនៃលោក គឺជាទុក្ខ , មូលហេតុនៃគំនរទុក្ខទាំងនោះ គឺតណ្ហា, តាលបើរលាស់ចាលនូវតណ្ហាចេញបាន សេចក្តីទុក្ខត្រូវយ៉ាងដិ ទឹងរលាយបាត់ទៅដែរ, ទុបាយ ឬ មាគ៌ាសម្រាប់បញ្ចូនចិត្តទៅកាន់រំលត់ទុក្ខ តឺមគ្គមានអង្គ ៨ មានសម្មាទិដ្ឋិជាដើម" ។ ទីបំផុតនៃធម្មទេសនា ព្រះពុទ្ធបានសម្រេចលោកុត្តរធម៌ជាន់លើ តឺព្រះអរហត្តផលជាតួសេចក្តីបរិសុទ្ធិ ទឹងសេចក្តីសុខសូប្បុកងឹសន្តាន ដែលអាចជំរុះចោលនូវសំយោជនកិលេស ទឹងត្រឿងសៅហ្មងត្រូវយ៉ាងជាសមុច្ឆេទប្បហាន។

លុះដល់ថ្ងៃទី ៧ ទ្រង់ត្រាបថា " ជីវាវសានៃអាយុសង្ខារ របស់ព្រះអង្គចូលមកដល់ហើយ" ទើបគ្រាបទូលព្រះសាស្តាថា "អាយុសង្ខារនៃខ្ញុំព្រះអង្គនេះតិចណាស់ ខ្ញុំព្រះអង្គសូមថ្វាយបង្គំលា ទឹងបរិនិព្វានក្នុងថ្ងៃនេះហើយ, ទោសកំហុសណា ដែលកើតពីសេចក្តីភ្លាំងភ្លាត់ ដោយកាយ វាចា ចិត្ត សូមទ្រង់អត់ឱនទោសនោះ ដល់ខ្ញុំព្រះអង្គ ។ គ្រានោះ សក្យរាជទាំងឡាយដែលមកប្រជុំគ្នាក្នុងទីនោះ កាលបើទ្រង់ព្រះសណ្តាប់

ការខួលសាទៃព្រះពុទ្ធចិតាដូច្នោះ ហើយ តំសំដែងបរិវេនាការខ្សឹកខ្សួល
តាខ្លោះអាល័យ ស្តាយព្រះអង្គ ដោយប្រការផ្សេងៗ ។ ព្រះបាទសិរី-
សុវត្ថិទមហាភជ, ក្រោយដែលបានថ្វាយបង្គំលាព្រះសាស្តារួចហើយ,
ទ្រង់ចំរើតព្រះកាយិន្ទ្រិយចុះលើព្រះសេយ្យាផុតខ្សល់អស្សាសប្បស្សាសៈ
រំលត់ខន្ធជាអច្ចន្តខិពេធ គឺបរិនិព្វានជាអវសានៃអាយុសង្ខារក្នុងគ្រានោះ
ឯង, ក្នុងព្រះជន្មាយុជាតំរប់ ៨៧ ឆ្នាំតត់ ហាក់ដូចជាប្រទីប ដែលរលត់
ទៅដោយអស់ប្រេងនិងប្រឆេះដូច្នោះ ។ សក្យជនទាំងឡាយក្នុងព្រះពុទ-
ធានីទាំងមូល បានសំដែងសេចក្តីសោកស្តាយខ្ជិះខ្សឹកខ្សួលគ្រប់ៗគ្នា ។
ព្រះសាស្តាទ្រង់សំដែងធម៌ប្រោសធំទូលសេរ តំសេចក្តីសោកសៅ នៃសក្យ-
ជនទាំងឡាយនោះហើយ ទ្រង់បង្គាប់ព្រះមហាកស្សបត្ថេរឲ្យពិនិត្យមើល
ទីបូជាព្រះបរមសព ។ ព្រះមហាកស្សបត្ថេរ ក្រោយដែលបានខួលព្រះពុទ្ធដីកាហើយ, បានចេញទៅតំបារណាមើលភូមិឋានដ៏សមគួរដល់
ការធ្វើឈាបនកិច្ចជាមួយសក្យជនទាំងឡាយ ។ លុះកំណត់យកឈា-
បនដ្ឋានមួយកន្លែងបានហើយ ទើបហៅជាងជំនាញ ។ ជារច្រើនរួប
ដែលថ្នឹកក្នុងវិជ្ជាហត្ថកម្ម ឲ្យចាត់ចែងធ្វើព្រះមេរុកូដាគារ ប្រដាប់ដោយ
កំពូល ៥០០ ពិចិត្រដោយក្បាច់ក្បូរបទា ខន្ធមាលាកម្ម លតាកម្ម
ដោយឈើក្រអូបឆ្ងុង ។ យ៉ាងនាំសម័យ តាក់តែងធ្វើជាចិតកធាន
(ដើងថ្កា) ដើម្បីទំនឹងដំកល់ព្រះបរមសព ។ (ក្នុងតម្ពីរប្រាប់ថា);
ក្នុងកាលនោះ ខេត្តភាំងឡាយក្នុងលោកជាតុភាំងមួយហ្នឹង មាន
សក្តិខ្លាំងជាងជាប្រធាន ប៉ានចូលមកជួយឧបត្ថម្ភយ៉ាងម៉ឺងម៉ាត់ក្នុងរឿងនេះ

ដកចេញលុះបានសម្រេចជាព្រះមេរុមានលំអយ៉ាងត្រកាល ហាក់ដូចជាខេត
ខ្ចីមុត ដ៏សមគួរដល់ព្រះបរមសពនៃព្រះពុទ្ធបិតា ។ លុះសម្រេចហើយ
ទើបព្រះមហាកស្សបត្ថេរ ចូលទៅក្រាបបង្គំទូលព្រះសាស្តា ឲ្យទ្រង់
ជ្រាប ។ ព្រះសម្ពុទ្ធជាម្ចាស់, ដើម្បីសំដែងកតញ្ញូតាព ជាកិត្តិយសចំពោះ
ព្រះបរមសព ទ្រង់លើកព្រះសរីរសោនៃព្រះបិតាដោយព្រះហស្ត រួចទ្រង់
ស្រោចស្រពដោយព្រះសុគន្ធវារី, ព្រះឆអនុនាបតិកំដួយប្រោះព្រំដោយ
ទឹកក្រអូប, ទើបព្រះបរមសម្ពុទ្ធទ្រង់ត្រាស់ថា " ម្នាលសារីបុត្ត!
បុគ្គលណាមួយ ប្រាថ្នាពោធិញ្ញាណ ចូរសំដែងកតញ្ញូតាធម៌ជាដើម
ចំពោះមាតាបិតា ឲ្យដូចតថាគតធ្វើក្នុងត្រានោះចុះ ឱកាសមិនបាន
មាន ព្រោះថា សេចក្តីកតញ្ញូនេះ ជាប្រធានៃកុសលទាំងពួង " លុះ
ត្រាស់ដូច្នេះហើយ ទ្រង់លើកព្រះបរមសព ដាក់ក្នុងព្រះមណ្ឌលភ្លើងហើយ
លើកព្រះមណ្ឌលដោយព្រះអង្គឯង នាំទៅដាក់លើជើងថ្ម ដើម្បីធ្វើ
ឈាបនកិច្ចថ្វាយព្រះភ្លើង ។ គ្រានោះ ពួកព្រះញាតិ ក្នុងនគរទាំង ៦
មាននគរកបិលព័ស្តុ នឹងនគរទេវទហៈជាដើម ដែលជាប់មានបិត្តស្វាមីភក្តិ
យ៉ាងជ្រាលជ្រៅ បានមកដួចដុំគ្រឿបគ្រា ដើម្បីធ្វើការប្រទក្សិណ សំដែង
គារវកិច្ច សុំខមាទោសចំពោះព្រះបរមសព តាមតន្ទុងប្រពៃណីគ្រប់ៗ
គ្នា ។ ពេលនោះ សក្កទេវរាជបានទាំយកកែវមណីជោតិ ដើម្បីថ្វាយព្រះ
ភ្លើង, ប៉ុន្តែ ព្រះសម្ពុទ្ធទ្រង់ឃាត់ថា "បពិត្រមហាពល! កិច្ចថ្វាយព្រះភ្លើង
ក្នុងត្រានេះ ជាការៈរបស់តថាគតៈ, ទើបទ្រង់ទូលយកកែវមណីជោតិ

ព័ត្រះឥន្ទ្រាធិពជ មកបូជាដោយត្រាអង្គឯង ។ អណ្តាតភ្លើងកំផុះជាល
ចេញពីជួងកែវពិសេសនោះ នេះព្រះបរមសាត ព្រមទាំងដើងថ្កុរព្រោន
ត្រាតពណ្តាយ ។ តមក ទើបះខ្លាទាំងឡាយ មានសក្តខ្លែវកជជាដើម
ព្រមទាំងសត្សដនទាំងឡាយ នាំគ្នាក្រាយព្រះភ្លើងតាមក្រោយ ។ លុះ
សម្រេចឈាបនកិច្ចហើយ ព្រះពុទ្ធទ្រង់បង្គាប់ ឲ្យសាធីព្រះចេតិយ
អញ្ជើញព្រះបរមធាតុព្រះពុទ្ធបិតា ទៅបញ្ចុះទុកជាទីសក្ការបូជាតទៅ ។

ការសំដែងមកអំពីដំណើរបរិនិព្វាន នៃព្រះពុទ្ធបិតា ក៏ល្មម
សមគួរដល់កាលវេលា ទីឆបញ្ចប់ត្រឹមប៉ុណ្ណោះឯង ។

ដោយអំណាចនៃធម្មទាននេះ, សូមឲ្យពុទ្ធសាសនារុងរឿងចំរើន
ទីឆង្រូវផ្សាយទៅក្នុងសាកលលោក !

សូមឲ្យព្រះគុណជាម្ចាស់ជីតែទាំងឥតព្រះអង្គ ទីឆសម្តេចព្រះទេព.
យុវរាជ ឋានប្រកបដោយសុខសួស្តីសិរីរុងរឿងគ្រប់កាល កុងសិរីរាជសម្បត្តិ សម
តាមព្រះពរជំណាង !

សូមអស់លោក អ្នកជាពុទ្ធសាសនិកត្រង់ឋាន: ដែលអញ្ជើញមក
ពីទីជិតឆ្ងាយ ឋានសម្រេចនូវឥដ្ឋមនុញ្ញផលវិបុលសុខ សមតាមចេតនា
បំណងរៀង ។ ខ្លួន កុំបីឃ្លាត ! ជាពិសេស, សូមប្រជានិករកុងសាកល-
លោកទាំងមូល ពាក់ព័ន្ធតាមផ្លូវសន្តិភាព ចាប់តាំងពីពេលនេះតទៅ !

សធា ឥជ្ឈតុ សពុទ្ធោ សម្មាសម្ពុទ្ធទេសិតោ
ឧសេដ្ឋោ សព្វលោកស្ស ធម្មមត្តំ វិសុទ្ធិយា ។
សូមព្រះបទ្ធម្ម ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងទុកមក ជាធម៌

បង្ហាញនូវមាគ៌ាដ៏ត្រឹមត្រូវ ទៅរកសេចក្តីបរិសុទ្ធិ ដល់សត្វលោកពាំនអស់រូន រឿងចំរើនឡើងសព្វ ។ កាលទៅហោង !

ចប់ ។

ឯវំ អយំ ធម្មទេសនា សង្ខេបេន សមត្តា

ព្រះធម្មទេសនាក្នុងរឿង "ពុទ្ធបិតុបរិនិព្វានវេទ" សន្មតជាចប់ដោយសង្ខេប ដូច្នេះ ។

សេចក្តីរំលឹក

ព្រះបាទសុរិន្ទាទនមហាពជ
ព្រើបព្រះនាំអណាចត្រង់រង្គ
សុះព្រះនាំសណ្តាប់ធម៌ទេសនា
នៃព្រះសាស្តាអង្គដ៏ឧត្តម ។
ព្រះនាំបានសម្រេចអរហត្តផល
លះបង់កង្វល់ក្នុងភពបី
ហានប្រាំពីរថ្ងៃ និព្វានទៅ
ភស័ខែសីហប្រាំពីរកើ ។

ស្រី - ភ្ជុំ

ឃុនបណ្ណាទុក្ខ ប៊ូ-ប៊ូ រៀបរៀង

ក្នុងគម្ពីរ មានសេចក្តីថា គុណរបស់ព្រះសម្មាសម្ពុទ្ធច្រើនណាស់ កប់មិនអស់ទេ ដូចមានបទគាថាថា :

ពុទ្ធោបិ ពុទ្ធស្ស ភណេយ្យ វណ្ណំ
កប្បម្បិ ចេ អញ្ញមភាសមានោ
ខីយេថ កប្បោ ចិរទីឃមន្តរេ
វណ្ណោ ន ខីយេថ តថាគតស្ស ។

សូម្បីព្រះពុទ្ធទ្រង់សំដែងតែអំពីគុណនៃព្រះពុទ្ធផងគ្នា មិនសំដែងពីរឿងអ្វីដទៃសោះ រហូតអស់មួយកប្ប កប្បដ៏យឺនយូរវែងឆ្ងាយ ក៏ទីបំផុតអស់ទៅទេ ក្នុងចន្លោះនោះ ឯគុណនៃព្រះពុទ្ធមិនអស់ទៅផងឡើយ ។

សមាសុរិសេបិ ចេ ទោសោ
សិសេ សិសេ សតំ មុខា
មុខេ មុខេ សតំ ជិវ្ហា
ជិវ្ហាកប្បេ មហិទ្ធិកោ
ន សក្កោតិ ច វណ្ណេតុំ
ឯសេ្សសំ សត្តុនោ គុណំ ។

ប្រសិនបើ មានបុរសម្នាក់ មានក្បាលមួយពាន់, ក្នុងក្បាលមួយមានមាត់មួយរយ, ក្នុងមាត់មួយ មានអណ្តាតមួយរយ, បុរសនោះគាយុវែងចំនួនមួយកប្ប មានឫទ្ធិច្រើន ក៏មិនអាចនឹងរៀបរាប់គុណ នៃព្រះសាស្តាឲ្យអស់រលីង គ្មានសេសសល់ឡើយ ។

ប៉ុន្តែ គុណនៃព្រះពុទ្ធ គេរៀបរាប់ដល់ម្ភៃកំណាត់ ដោយ តង់លោក-
សង្គ្រោះចូលក្នុងគោលធំបំផុតតែ ៣ យ៉ាង គឺ

១- វិសុទ្ធិគុណ,

២- បញ្ញាគុណ,

៣-ករុណាគុណ ។

អធិប្បាយ: (១)

សូម្បីព្រះនាមទាំង៩ គាំងពី អរហំ ជល់ ភគវា ក៏សង្គ្រោះចូល
ក្នុងពុទ្ធគុណ ដែលជាគោលធំបំផុតទាំង៣ នោះដែរ គឺ អរហំ ជាគ្រឿង
ប្រកាសព្រះវិសុទ្ធិគុណ ។ សម្មាសម្ពុទ្ធោ ១ វិជ្ជាចរណសម្បន្នោ ១
សុគតោ ១ លោកវិទូ ១ ទាំង ៤ នេះ ជាគ្រឿងប្រកាសព្រះ បញ្ញាគុណ ។
អនុត្តរោ បុរិសទម្មសារថិ ១ សត្ថា ទេវមនុស្សានំ ១ ពុទ្ធោ ១ ភគវា ១
ទាំង ៤ នេះ ជាគ្រឿងប្រកាសព្រះករុណាគុណ ។ ព្រះនាមទាំង៩
មានបទថ្លាលើ ក្នុងនវហរគុណ នឹងសេចក្តីប្រែដូចតទៅនេះ ៖

១- អារកត្តា តាលេសេមហិ សព្ពសនេមហិ សោ មុនិ
សព្ពបូជារហត្តា ច តិនិតោ អរហំ តតិ ។

ព្រះមុនីអង្គនោះ លោកហៅព្រះអង្គថា « អរហំ » ព្រោះព្រះអង្គ
ឆ្ងាយចាកតាលេស ព្រមទាំងឥសនា ១ ព្រោះព្រះអង្គគួរទទួលសក្ការបូជា
របស់មហាជនទូទៅ ១ ។

២- សម្មា សាមញ្ច សច្ចានិ ពុទ្ធោ ច អញ្ញាតោធនោ

---

១) ឃ្លាប់ពុទ្ធគុណចរិយាយ របស់ពុទ្ធសាសនបណ្ឌិតលេខ ២.៨ ទំព័រ១៤៧ ។

តេនេស សម្មាសម្ពុទ្ធោ សព្ពញ្ញូស្មីតិ ចក្កុមា ។

ព្រះអង្គត្រាស់ដឹងអរិយសច្ចទាំង៤ប្រការ ដោយប្រពៃចំពោះព្រះអង្គ១ ទ្រង់ដឹកនាំអ្នកដទៃឲ្យត្រាស់ដឹងតាម១ ព្រោះហេតុនោះ ព្រះអង្គមានចក្ខុកើតឡើងដោយពិសេស ទើបទ្រង់ព្រះនាមថា " សម្មាសម្ពុទ្ធោ " ។

៣- វិជ្ជាហិ ចរណេនាបេស សម្បន្នេវ សមាគតោ

វិជ្ជាចរណសម្បន្នោ ឧត្តមោ តេនមាទុសេ ។

ព្រះអង្គប្រកបដោយវិជ្ជា៣ ខ្ទឹងចរណៈ ១៥ ដោយប្រពៃ ទើបទ្រង់ព្រះនាមថា " វិជ្ជាចរណសម្បន្នោ " ព្រះអង្គខ្ពស់ក្នុងពួកទេវតា និងមនុស្ស ។

៤- សព្ពត្ថេសម្ពហានេន គតោ សោ សុគតោ មុនិ

សម្មា ភាយេន ចាចាយ មនសា សុគតោ គតោ ។

ព្រះមុនីអង្គនោះស្តេចទៅ ដោយការលះបង់កិលេសទាំងពួង (មួយទៀត) ឈ្មោះថា ទ្រង់យានទៅប្រពៃ ដោយកាយ, វាចា ចិត្ត ទើបទ្រង់ព្រះនាមថា" សុគតោ " ទ្រង់យានទៅប្រពៃ ។

៥- លោកំ វិទូតតោ សព្ពំ ញាណេនាញ្ញាសិ សព្ពថា

តាថោ លោកសុ សម្មាវ តេន លោកវិទូ ជិនោ ។

ព្រះជិនៈអង្គនោះជាឥតិធវេទស់លោក ទ្រង់ជ្រាបលោកទាំងអស់យ៉ាងជាក់ប្បាស់ត្រប់ប្រការ ដោយព្រះញាណដ៏ប្រពៃ ហេតុនោះ ទើបទ្រង់ព្រះនាមថា"លោកវិទូ " ព្រះអង្គទ្រង់ជ្រាបលោកជាក់ប្បាស់ ។

៦- សារថោ នរទម្មានំ អតុលប្បាយ វិម្មុត្តិយំ

តតោ អនុត្តរោ នាថោ បុរិសទម្មសារថិ ។

ព្រះអង្គទ្រង់ដឹកនាំអ្នកដែលគួរទូន្មានបាន ឲ្យធ្វើដំណើរទៅកាន់វិមុត្តិដ៏មិនកម្រើក ព្រោះហេតុនោះ ព្រះអង្គជាលោកនាថ ទើបទ្រង់ព្រះនាមថា "អនុត្តរោ បុរិសទម្មសារថិ" ព្រះអង្គជាសារថីទូន្មានបុរស ពុំមានអ្នកណាប្រៀបធ្ងន់ស្មើបាន ។

៧-លោកាយេហិ ច អត្ថេហិ អថោ លោកុត្តរេហិ ច

សត្ថា ទេវមនុស្សានំ សាសិតា ទេវមានុសេ ។

ព្រះអង្គទ្រង់ប្រៀនប្រដៅទេវតានឹងមនុស្ស ដោយលោកិយប្រយោជន៍ នឹងលោកុត្តរប្រយោជន៍ ទើបទ្រង់ព្រះនាមថា "សត្ថា ទេវមនុស្សានំ" ព្រះអង្គជាសាស្តារបស់ទេវតានឹងមនុស្សទាំងឡាយ ។

៨-សម្ពុទ្ធោតិ ច សច្ឆានំ ភគ្គសច្ចោ បពុទ្ធោតិ

សព្ពញ្ញោ កុណវិកាសេ - មច្ឆត្តោ ពុទ្ធោ ឯវ្តមោ ។

ព្រះអង្គត្រាស់ដឹងសច្ចៈទាំងឡាយផង ទ្រង់តើនពាក់កិលេសនិទ្រាផង ព្រះអង្គ រីកពេញដោយព្រះគុណគ្រប់យ៉ាង ទើបទ្រង់ព្រះនាមថា "ពុទ្ធោ" ព្រះអង្គត្រាស់ដឹង ខ្ចាត់ខ្ចាយជាងនរជនទាំងឡាយ ។

៩- ភាគ្យេន ភគជម្មេហិ សមង្គិ ចាតុលោ មុនិ

ភរុតាវាយុត្តោ ច វិសុទ្ធោ ភគវា ឥតិ ។

ព្រះអង្គប្រកបព្រមដោយជោគជ័យ នឹងភគធម៌ ៦ ប្រការ គ្មានអ្នកណាប្រៀបស្មើបាន ទើបទ្រង់ជាទីគោរពរបស់ត្រូវាអាចារ្យផង លោកថ្លាយព្រះនាមថា "ភគវា" ព្រះមានព្រះភាគ ។ (ច្បាប់សូត្រមន្ត) ។

ព្រះនាមទាំង ๙ នេះ ជាព្រះគុណនៃមិត្តភាព ព្រោះជាប់មកតាមហេតុគឺគុណវិសេស មានអរហំជាដើម ដែលមានក្នុង ๑ ខ្នងសន្តានរបស់ព្រះពុទ្ធអង្គ ឥតអ្នកណាថ្វាយឡើយ ស្រាប់តែលេចឡើងខ្លួនឯងឡើង ឯង ។ តែម្តង ជាមួយនឹងសព្វញ្ញុតញ្ញាណ ដែលព្រះអង្គមានក្សេត្រលើព្រះមហាភោធិព្រឹក្ស ។ ព្រះពុទ្ធគ្រប់ព្រះមគ្គខ្ទង់មានព្រះគុណនៃមិត្តភាពទាំង ๙ នេះ ដូច ។ គ្នា ឥតប្លែកពីគ្នាឡើយ ។

ប៉ុន្តែ ក្នុងតម្រាវដំណោះ លោកញ្ញាក អនុត្តរោ ជាព្រះនាម ๑ ពុទ្ធសម្មុសាវចិ ជាព្រះនាម ๑ រួមជា ๑๐ ព្រះនាម មានបទគាថា ថា:

យស្ស ឧសក្ខក អ-សំ-រិ-សុ-លោ អ បុ ស-ត្ថុ-ក
វចសា បតុណា ត្វត្តោ មនសា សោ សុខំ លភតិ ។

អក្ខរៈទាំង ๑๐ តួ គឺ អ សំ រិ សុ លោ អ បុ ស ត្ថុ ក ក្តី សេចក្តីអធិប្បាយ (នៃអក្ខរៈទាំង ๑๐ តួនោះ) ក្តី គឺបុគ្គលឯណាមួយ ពោះជាគ្រហឹក្តី ជាបព្វជិតក្តី បានធ្វើឱ្យចាំស្តាត់ដោយវាចាចិត្តហើយ គ្រហស្ថនឹងបព្វជិតទាំងនោះ ខឿនតែបានមួយសេចក្តីសុខ ។

ឯអក្ខរៈទាំង ๑๐ តួនោះ ជាអាទិសង្ខ្លឹត គឺ អ - អរហំ ។
សំ - សម្មាសម្ពុទ្ធោ ។ រិ - វិជ្ជាចរណសម្បន្នោ ។ សុ - សុគតោ ។
លោ - លោកវិទូ ។ អ - អនុត្តរោ ។ បុ - បុរិសទម្មសារថិ ។
ស - សត្ថា ទេវមនុស្សានំ ។ ពុ - ពុទ្ធោ ។ ក - ភគវា ។

ព្រះពុទ្ធគុណសង្ខេបប៉ុណ្ណេះ ។

លោក រ៉ាយ-ប៊ុក រៀបរៀង

១ - អំពីរឿងបែបសេព

មានគាលយថៃមួយ ខ្ញុំបានទៅបែបសេពមិត្រម្នាក់ ។ កន្លងពេលវែងណាស់ធ្លាប់តែជួបគ្នាតាមវិថីក្រុង ឃើញទំនាក់ទាក់ពីប្រការនី

ក) បុត្រ, ធីតា, ញាតិសាលោហិត ខ្លះស្លាប់ពាក់ស, ខ្លះគោរក្សាល ឃាំដើរតាក្រោយក្តារខ្មៅដែលតម្កល់សត, សោកសង្រេងអាឡោះអាល័យសព ដោយពាក្យទំនួញ, ជំរុញសព្វគ្រប់ប្រការ ។ កន្លងមកផ្សាំនេះ ជាវត្ថុកូ, ហោក, ជាទី បន្ទុកជង្គង់ ជាទីខ្ជិលធុំគ, គ្មានសង្ឃឹម ។ សូម្បីតែឆន្ទៈក្រៃលែងណា ដែលត្រូវក្នុងសំដែងថា ប្រុំអង្គុំ, ប្រជុំ ឧត្តុំ, ប្រុំ អង្គា, ក៏គ្មានមនុស្សយើញរេ កន្លងពេលនោះក្រោមនុស្សទាំងនោះ ត្រូវក្នុមតគ្រប់សង្កត់ស្ទើរតែជាតិញាណស្លុយឈឹង ។ ពុកមានអាត្មាភាពដ៏ធំធាត់ពត, មិនអាចធ្វើឱ្យអ្នកទាំងនេះតិចារណាធម៌ជាន ។ តិតៈដៅស្រមៃឯកត់ដូចយើញតក្តុសព, ដំណើរសួរសុំដំណាដើម, ដាស់ឆាត់ប្រាន្តោះ ។, បន្តិចយើញប្រាន្តោះទៀត តែមិនយើញកោះ, កំតាំងតែឡើតប្តូបអូសតាត់ស្ងាត់ ។ ប៉ើចិត្តជ្រមុជទៅក្នុងសាតនៃកូនៗទៅហើយ, ឯាមួយតិតពីធម៌ ដែលជាទីឯាយរំលត់ទុក្ខនោះជាន ព្រោះហេតុដូច្នេះ ជាទីគ្រូឯាគាល្បួងឱ្យគ្នាប្រាដៅថា "ធម៌នេះត្រូវតិតទុកជាមុន, ត្រូវពិចារណាខ្លះសេចក្តីស្លាប់នេះជាមុនថា: អញមុខជានឹងស្លាប់ថ្ងៃណាមួយមិនខាន, ការស្លាប់ឆៀង ការស្លាប់ជាទម្ងិតក្រាកដ ការស្លាប់គ្មានអ្នកណាចៀសរួច ជាដើម" ។ លុះពិចារណា

ជាមុន, តិតគូរមុន, ទម្លាប់ចិត្តឱ្យត្រេះរិះហេតុផលជាមុន, ទើបស្តាប់ធម៌ស្តាប់នោះឮស្តាប់ល្អ ដល់សេចក្តីស្តាប់មកដល់ មិនស្តាប់តក់ស្តុតទីដ៏សេចក្តីស្តាប់ពេក ។ បើយើញថាតាមាតា ឬ ស្វាមី ភរិយា បុត្រ ធីតា ខ្ជួលមរណភាព, មិនស្តាប់ជាសោកស្តាយពន់ពេក ដោយគិតថា "សេចក្តីស្តាប់មានតិតប្រាកដ, គ្រាន់តែមួយស្តាប់មុន, មួយស្តាប់ក្រោយ" ឬ គិតថា:"កាលគេមកកើត ក៏គេមិនបានមកសួរអញ កាលគេស្តាប់ទៅវិញ, ក៏គេមិនប្រាប់ឲ្យអញ, តើអញសោកស្តាយធ្វើអ្វី?" ។ កាលបើបុគ្គលបានតិចារណាន្តវៈសេចក្តីស្តាប់រឿយ ។, ការតិចារណានោះទើបជាមរណានុស្សតិកម្មដ្ឋាន; អ្នកណាបានតិចារណាមរណានុស្សតិកម្មដ្ឋាន, អ្នកនោះឈ្មោះថាមិនប្រមាទ ជាហេតុនាំឱ្យកើតសេចក្តីសង្វេគ, ត្រេះថ្នាក់ក្នុងការកុសល ឈ្មោះថា ញុំាងចិត្តឱ្យតាំងនៅក្នុងកុសលធម៌ ធ្វើចិត្តឱ្យច្រាសចាកនីវរណធម៌ ទីដ៏ឋានសុះកង់ឈានណាមួយមិនមាន ព្រោះមានពុទ្ធភាសិត កង់តម្លឹងធម្មបទត្រង់ចិត្តវគ្គថា:

ទុន្និគ្គហស្ស លហុនោ យត្ថ កាមនិបាតិនោ
ចិត្តស្ស ឧមជោ សាធុ ចិត្តំ ទន្តំ សុខាវហំ ។

ប្រែថា: ការខ្ជួនចិត្តដែលគេសង្កត់សង្កិនបានដោយក្រធម្មជាតវហ៊ុសមានប្រក្រតីធ្លាក់ចុះទៅតាមប្រាថ្នា កង់អារម្មណ៍ណាមួយ ជាគុណឱ្យសំរេចប្រយោជន៍ ព្រោះចិត្តដែលគេខ្ជួនហើយ រមែងនាំមកនូវសេចក្តីសុខ ។

១- អ្នកដែលហៃសព

ភរិយាអ្នកដែលហៃសព មិនមានសភាពខុសគ្នាពីបុត្រ, ធីតា, ញាតិ

សាសោហិតសពនោះទេ ព្រោះថា ត្រូវបែរភ្នែកញញើតអាកប្បកិរិយា ជាអ្នកឧស្សាហ៍ក្នុងជាមួយនឹងបុត្រ, ធីតា, ញាតិសាសោហិតនោះដែរ តែត្រូវធ្វើចិត្តមុខស្រស្លឹត,ស្រងាំត់ ធ្វើដំណើរស្ងប់ស្ងៀម ;អាកប្បកិរិយាសមរម្យទៅតាមអារម្មណ៍កាល ចិត្តទំនេរលើកដល់មរណានុស្សតិកម្មដ្ឋាន ឬអសុភកម្មដ្ឋាន ឬកាយគតាសតិកម្មដ្ឋាន ដើម្បីទីដាច់ខាតចិត្តឱ្យសង្វេគ, ឱ្យត្រេកអរក្នុងការកុសល ។ ត្រូវគិតថា ការស្លាប់, ជាធម៌ទៀង, ខ្ញុំនឹងស្លាប់ ខ្ញុំនឹងចៀសចាំនូវសេចក្តីស្លាប់មិនបានត្រូវតែស្លាប់. សត្វណាកើតហើយ សត្វនោះតែងតែស្លាប់ មានសេចក្តីស្លាប់ជាបរិយោសាន ទុសគ្នាតែមួយស្លាប់មុន មួយស្លាប់ក្រោយ ដូចមានព្រះពុទ្ធភាសិតក្នុងធម្មបទ ទុកនិយាយថា:

អចិរំ វតយំ កាយោ បថវិំ អធិសេស្សតិ

ឆុទ្ធោ អបេតវិញ្ញាណោ និរត្ថំវ កលិង្គរំ ។

ប្រែថា កាយនេះមិនយូរប៉ុន្មាន តែមានវិញ្ញាណទៅប្រាសហើយ ត្រូវចោះបង់ចោល ដំណេកសង្កត់លើផែនដី ដូចបំណាំងឈើរកប្រយោជន៍គ្មានដូច្នោះ ។

បើបានពិចារណា យ៉ាងនេះជាច្រើនដង ក្នុងពេលដែលរើរហាសត្ថមុខជានឹងកើតសេចក្តីសង្វេគពុំខាន ។

ក្នុងពេលដែលរើរហាសត្ថ ពុំគួរប្រើវិតមុនស្រស់ស្រាយ ធ្វើអាកប្បកិរិយារីករាយសើចខ្ចាំង។ ដ្បិយោងដូចតគ្គាញ្ញឹមញញែមសើចក្អាកក្អាងដែលជា,ហេតុមិនសមរម្យដល់ការរើរហាសត្ថខ្លាំយ ។ (មានត)

សុភាសិតលាវ

លោក រ៉ាយ-ប៊ុក ដកស្រង់ហើយរៀបរៀង

១- កាលណាគេពូ ត្រូវតែគេមើលថែម, កាលណាគេឃើញ គេត្រូវតែយកចិត្តមកត្រង់រឹះខ្លៃត ។

២- ត្រូវចឿតែត្រចៀកមួយ ទុកត្រចៀកមួយទៀតសម្រាប់ត្រង់រឹះ ។

៣- ត្រីមួយត្រក, ស្អុយតែមួយ ស្អុយទាំងអស់,

៤- ការសេពគប់នឹងពួកល្អ ចំហាយល្អតែងដឹតជាមជាប់ពណ៌មក ។ ការសេពគប់នឹងពួកអាក្រក់, ចំហាយអាក្រក់តែងដឹតជាមទូវត្រឿងស្អុយជាប់មកជាមួយ ។

៥- ចិត្តល្អប្រសើរជាងរូបល្អ ។

៦- ការចេះធ្វើមិនដល់ការពិះសាធន៍ ។

៧- បើគេធ្វើកិច្ចការអ្វី ។ ត្រូវគ្រោយាមធ្វើដោយចិត្តមុឺងម៉ាត់ ទោះបីមានគូសង្ឃឹមចាត់ឆ្នើងនឹងមួយពាន់ដងក៏ដោយ,មិនត្រូវធ្វើតាមឡើយ ។

៨- ចូរយើងអត់ទ្រាំតុយកក់, បើយើងខឹងបរិភោគអន្ទង់ ។

៩- សត្វដើងបួនតង្កើមានក្តាត់, អ្នកប្រាជ្ញចេះស្ងាត់តង្កើមានខុស ។

១០- ត្រូវឆ្នៃការតំខាន់លើខ្ទេសិន សឹមឲ្យធ្លាក់ទៅខាងក្រោមខ្ទេជាក្រោយ ។

១១- ម្ហូបអាហារពេញថាសប្រាក់ មិនស្មើចំណេះវិជ្ជាពេញពោះ ។

១៦- ប្រាក់ដប់ស្លឹងបិតនៅត្រើយម្ខាង, អំពីមុខយើង កុំយើងប្រញាប់ប្រញាល់ពេក ប្រាក់តែពីរស្លឹងរត់ចូលក្នុងដៃយើង,ត្រូវប្រញាប់យកគ្នាម ។

១៣- អាយោបក់ទៅទិសខាងណា,គេត្រូវទៅទិសខាងនោះ ។

១៤- ខ្លះមានចិត្តស្លាហាននៅភូមិ ទៅដាក់ឆ្កែព្រៃ ។

១៥- បង់ដីធំដំរី ដោយមើលកន្ទុយ, បង់ដីនាងកញ្ញាដោយមើលមាតា ។

១៦- ឆ្កែស្មាមមនុស្សបិតនៅខាងក្នុង, ឆ្កែទ្វាបិតនៅខាងក្រៅ ។

១៧ ខ្លួនខន្ធាយ, បង់គ្របព្រះចន្ទ ។

១៨- ទឹកបបាក់ជ្រៅចេះតែតាបៅ, ទឹកស្ងប់ដុះចេះតែក្ងស់ឡើង ។

១៩- អ្នកមានចេះតែមាន, អ្នកក្រ ចេះតែក្រ ។

២០- សំឡេងអ្នកក្រគ្មានអ្នកណាឮ ។

២១- អង្កត់ទសមួយកំណាត់ មិនអាចធ្លីក្លើងឲ្យឆេះបានឡើយ ។

២២- បើគ្មានប្រជាពស្ត្រ កេត្រានៃព្រះអង្គម្ចាស់ មិនអាចត្រាច់ៅមុខបាន ។

២៣- ខ្លួនជាអន្ធង់, បង់សុំឈាមគ្នាម ។

២៤- ខ្យល់ក្បុះសង្ឃឹម មិនភ្ញាំដាងខ្យល់មាត់ ។

២៥- អ្នកណាបរិភោគអាហារក្តៅ ខឹងឃើញគោះខ្លួនចេញចំហាមក្តៅមិនខាន ។

២៦- ក្រមុំចាស់ចូលចិត្តស្មៅខ្ចី ។

២៧- បើគាលណាម្ហូបក្តៅ ត្រូវតែខ្លួលទាន, បើគាលណាស្រែងែ ត្រូវតែកំ ។

២៨- ដើងហត្ថុយកទៅបំពេចំពុសបក្សា ។

២៩- ចំនួនក្រោកយើង ទឹងបានដល់ជាងមួយរយរៀល ដោយហេតុយើងស្រឡាញ់ ហើយសន្សំពុកតាំងពីមួយរៀលឡើងទៅ ។

៣០- អត់ធន់ថ្នាំបួនដង ទឹងព្យាយាមថ្នាំបួនដង ទឹងបានថ្នាក់ណែនមាស ។

៣១- តាអោរជាហេតុឲ្យកើតភោគទ្រព្យ ។

៣២- បើយើងរស់នៅជាមួយពួកឆ្នាត, យើងនៅជាឆ្នាត ។ បើយើងរស់នៅជាមួយពួកក្អែក, យើងនឹងនៅជាក្អែក ។

៣៣- មាត់ដប់ដែលគោល មិនស្មើទឹងយើញដោយក្អែកខ្លួនឯង ។ ក្អែកដប់ដែលយើញ មិនស្មើទឹងតែដែលតាន់ជាប់នៅដៃ ។

៣៤- ស្ថានសួគ៌នៅក្នុងដើមទ្រូង, ស្ថាននរកនៅក្នុងបេះដូង ។

៣៥- ស្អាងប្រាសាទនៅលើអាកាស ។

៣៦- ឃកជាវគាប់ចិត ។

៣៧- បើគាលណាក្រមើដល់គ្នា,ក៏ខ្ចិចស្មៅ ។

៣៨- ជាក់ចិតមួយដំណាក់ ។ ទៅតងពាងធំ ។

៣៩- ដបចិតទេ ឆ្នុសពួរឡាយ ។

៤០- មានល្អគ្រោះកេម, រួបគោមល្អគ្រោះតែង ។

៤១- ចិញ្ចឹមពស់ដើម្បីឲ្យក់ចិតយើង ។

៤៦ - បើគេផ្ទាស់ប្តូរទឹកនៃទន្លេ, គេតែងមានទឹកនៃទន្លេ បើគេចោះបង់ចោលគេហដ្ឋាន, គេនឹងជាប់ទាសរគេហដ្ឋាន ។

៤៥- អ្នកណាលោភហួស,សំណាងរត់ឆ្ងាយ ។

៤៤- មាសធ្លាក់លើដី មិនស្រែអាប់ពណ៌សម្បុរទេ ។

៤៣- ខុសវាស, ត្រឹមមក ។

៤២ - ទឹកឡើងត្រីស៊ីស្រែមាច ទឹកហោចស្រែមាចស៊ីត្រី ។

៤១- ទឹកក្រជាក់ត្រីភក្តម, ទឹកត្តៅ ត្រីទៅអស់ ។

៤០ - ផ្ទះឈើមិនដែលជ្រុះឆ្ងាយពីតល់ ។

៣៩- កូនក្មេងមិនស្គាល់ជំរាឆ, ត្រីមិនស្គាល់ទ្រូ ។

៣០ - សរសៃដូចមាន់តកាយដី ។

៣១ - ទៅភូមិដែលគ្មានមាន់រងាវ ។

៣២- ឈើទ្រូងដូចគេនេះ, ឈើចិត្តដូចនេះជាញ់ ។

៣៣ - ដុំខ្ទុះដោយដឹងត្រចៀកក្រមៃ ។

៣៤- ជាក់ដំបុកនៅលើដៃស្លា ។

៣៥- បើកាលណាមនុស្សល់, គេមិនដើរកន្ទុងខ្ទុះទេ, បើកាលណាដើមឈើរលំ, គេកន្ទុងជាន ។

៣៦ មាត់រាល់ញាប់ដាំមិនឲ្យខុសចិត្ត, ដើងរហ័សនាំឲ្យរលំដើមឈើ ។

ភាសាភាស្យ

លោក អម្ចឹតក្សត្រី ម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក ថៃម ពិនិត្យ

(ទម៉ៅ)

តាំងជួនទុម្ពណ្ណ នុនអង្គកតិវ្ជ ទូលទៅរៀតថា បពិត្រអ្នកមានវិញ្ញាណថ្លៃថ្លា សូមអ្នកមេត្តា សំដែងសុចរិត ។ ដែលអ្នកថ្លែងថា មានជម្រកការ ពែកបែរបេទបិទ ដូចម្តេចរៀងជាក់ សូមអ្នកអាណិត សំដែងឲ្យពិត ឲ្យពិស្តារទៅ ។ ពោធិសោតណា ប្រាថ្នាដរែ តិក្ខណាប្រាសប្រសើ ស្តេចមើកព្រះស្ងួរ មធ្យក្រឹត្ត សំដែងដោយខ្លួ បទបាទគាថា។

យេចតវំ សុចរិតំ សុសេរិត្តា ចរិត្តាន ទេសិតា រិធំសិត្តា អតុបលៈ ។ ជទបន្ទែថា បើអ្នកឯណា បរិស្ស័យ មែនមានវិញ្ញាណប្រសើរប្រាណប្រាសប្រែ ទុច្ចរិតេ អំពីទុច្ចរិត ។ ទេសិតា តាំងជម្រកការ រៀរតុំឲ្យដិត ដល់អង្គមិតល់ ឆេតដល់សុចរិត ទោះមកជាំនិចិត្ត នៃអង្គអាត្ម ។ យេចតវំ សុចរិតំ ជ្ញូអ័ឃនណា ប្រាសប្រែប្រព្រឹត្តខ្លួសុចរិតា តាំងជម្រកការ ហៅត្រូវដរមេ ។ តំរៀបាណា រៀអនិច្ច

មួយវៀរគាមេ វៀរតាំងចិត្តបរ ប្រាកដឯងឯង ហៅសុចរិត សុចរិត-
ដោយកាយ ។ វៀរពាក្យកុហក វៀរពាក្យអាក្រក់ ពុំគួរនិយាយ
វៀរពាក្យញុះញង់ ឲ្យបង់ព្រាត់ព្រាយ ញាតិសាច់តាំងឡាយ នៃអ្នក
ជាតែ ។ មួយវៀរឲ្យគោះ ពាក្យមក្សុះក្សេះ ឥតសព្វសម័យ ប្រុងប្រយ័ត្ន
រឹងរូសពេកក្រៃ បង្កើនបង្កៃ លាភនៃអ្នកឆ្លង ។ ពុំបេះបង្អួត បង្អាប់-
ផ្តាញ់ស្តាន់ អាចឲ្យមានហ៊ាន តាំងប្តូរ៣ណា អាចរួសោកកង
ក្រមដោយគន្លង ហៅពាក្យសុចរិត ។ មួយវៀរលោភ វៀរព្យាបាទ
មួយវៀរចាកចិត្ត មិច្ឆាទិដ្ឋិ អប្រិយពេកក្តិត នេះហៅប្រព្រឹត្ត ដោយ-
ព្រះធម្ម ។ អាថិភាំងចិត្តបរ អ្នកប្រាថ្នាសុខគ្រប់ ប្រាកដហៅថា សុចរិត-
មនោ វៀរវៀរ សត្តំទេក្ខា ឧបេក្ខាសត្តិ ។ អ្នកណាប្រព្រឹត្ត នូវធម៌
សុចរិត តាំងជាប់ប្រក្រតី អ្នកនោះនឹងខុច សោយសុខសិរី ក្សេមក្សាន្ត
ក្នុងត្រៃ-ពិធៈសម្បត្តិ ។

បតុយក្តា អតិវន្តា ថ្លាយជាចរិយ៍ ទើបខ្ញុំលះជណ្តើង ទៅរឹងខ្លៀតថ្នាត់ បពិត្រមហាក្សត្រ ប្តូរសម្រេចស្តេរ ។ អ្នកដែលប្រព្រឹត្ត តាន់
ធម៌សុចរិត តាំងជាប់នោះតើ ជាទម្ពុជាន្តរស ដោយតស់អំពើ
អំពីខ្លួនឆ្លើ នោះដូចម្តេចខ្លះ ។

តទ្ធុតពន្យោធិ សត្វសេដ្ឋា ខ័ន្ធកប៉ុណ្ណាស្រាស់ លោកនាថា
បញ្ញាជ្រៅជ្រះ ប្រឹមប្រើយបើកព្រះ សូរសំដែងថា ។ អ្នកណាប្រព្រឹត្ត
តាន់ធម៌សុចរិត តាំងជាប់ប្រការ រកពស់លាភខ វិញ្ញាណធម្មារ
វៀរទុច្ចរិតា តាំងជាប់នោះឯង ។ អ្នកនោះប្រសើរ នោះយោបើ អ្នក

នោះកើតក្នុង បត្តុទ្ទិបស្មោះ ប្រទេសប្រឡង់ នៅឰដ៏ស.ដ៏ព្រះសោត.
សុខសាន្ត ។ ពុំដែលចួបបួល ចួបចាប់ត្រកួល អប្បីឥតសន្តាន ឥត
សៅឥតសព្ទ ឥតទ្រព្យធនធាន ពុំដែលខឹងមាន ទុក្ខទោមនស្ស ។
ពុំដែលព្រាត់ច្រាស ព្រាត់ព្រាយនាស លែងញាតិកា កើតតែត្រកួល
អម្បាវថ្ងៃថ្ងា ប្រកបឯកត្តិតា សម្បត្តិធនធាន ។ មានរូបល្អក្រៃ លែង
មនុស្សដទៃ កម្រធ្មឹមបាន មានពាំនស្រះស្រី នៅព្រៃខ្យាន សម្រាប់
បិទបាន គាន់ដោយសុចរិត ។ សម្បត្តិចរួល តែវាកងិមិតមួល ពុំបានរិះគិត
អ្នកនេះវិសាល ត្រកាលគេកក្តិត បរិបូណ៌ឯងឥត ថ្លៃងថ្លឹងឧបមា ។ កើត
ជាចក្រពត្តិ ធិកជមហាក្សត្រ នោះទៅហាខណា ខេត់មនុស្សី ខ្ជិតាំង
ខេត្តា ខ្ជូវអស់មនុស្សម្នា សោតសិង្ហ ញ ។ ស្នេហាខុកចិត្ត ដូច
ញាតិដូចមិត្រ ឥតមានមនោម្នេញ នោះទ្រព្យធនធាន ឥតមានមោះញ
ហេតុអ្នកនោះមិញ គាន់ធម៌សុចរិត ។ ហើយមានតេជះ តេុជោតបះ
នោះបញ្ចាមិត្រ ទេសទិសចាត់បញ្ជ ខ្លាចខ្លួបពាំតែ ពុះចាលចាញ់បិទ បុណ្យ
ជាវមីមាន ។ ជាសុខសល់ខ្លាត លុះលែងឆ្នែងជាតិ ជាបរិយោសាន
អ្វីឯរូបស្មោះ អ្នកនោះនៅជាន ខៀងសៅនិព្វាន បរមសុខក្តិត ។ ចូរ
អស់ព្រះស្តែង ប្រុងប្រែះលែង កុំគាន់ខុចរិត គាន់សុចរិតជា ធម្ម
នេញពិត ឲ្យជាន់សម្រិទ្ធិ៍ សម្រេចច្រាជ្ញ ។ អស់អង្គព្រះស្តែង នេះ
ហៅរំឭក អំពីមគ្គា ត្រូវគិតសែងស្ទាក់ រកអ្នកឯណា មានញាណច្រា.
ជ្ញា បង្ហាញទិសទី ។ ទៅគាន់បរលោក ចៀសចាកទុក្ខសោក បង់បុញ្ញ.

ឥន្ទ្រិយ ប្រែប្រាសលះលោភ ចៀសចាកអំពី អំតើអវិ - ជ្ជាជាតិដក ។ ព្រះធម៌នេះគាប់ ប្រសើរជាច្បាប់ ខត្តមថ្លៃថ្លា ក្រៃអ្នកណាមាន វិញ្ញាណ. តែងជារ វេសធម៌តាថា វិសេសសេដ្ឋ ។ ចូរអស់ក្រុងយក្ខ ចងចាំដៀង ជាក់ ខុកលើសិរសី ធម៌នេះប្រសើរ ស្មោះស្មើជវីអម្រឹតជារធី ដល់បរ. លោកច្បាស់ ។ ធម៌នេះព្រះពុទ្ធ ប្រតៃបរិសុទ្ធ ព្រះអង្គបានត្រាស់ ទេសន៍ ខ្ញុំខ្ញានជន អរហន្តក្រៃក្រាស់ ជ្រួតជ្រាបជ្រៅជ្រះ ល្អិតល្អក្រៃក្រៃ ។

ពន្ធកសារពេជ្ជ សំដែងធម៌ស្រេច ទើបគុំនគពត្រៃ ទេវិន្ទ្រព្រហ្ម ទេវព្រឹក្សវៃក្រ សឹងអរឲ្យជ័យ សត្វសាធុការ ។ គ្រប់ក្រាក់ក្តីមាស ជ្វាក់ មកពេញតាស ដោយដង់ជាសជា រញ្ជួយព្រឹក្សវៃក្រ ពន្ធឹកអស្ចារ្យ ហេតុ ដោយសម្ភារ ប្រុសរដ្ឋថ្លៃ ។

ភុម្ពណ្ណបួនឃល់ ហេតុអស្ចារ្យសល់ សឹងអរឲ្យជ័យ សត្វស្រែក អឺងកង រំពងព្រះវៃក្រ សរសើរបុណ្យនៃ ពោធិសត្តា ។ លុតលើកព្រះ ជាខ ព្រះបរមនរនាថ ជាក់លើសិរសា ក្រួញក្រាបបង្គំ ប្រណម្យខ្លួលថា យើងខ្ញុំនេះជា ខ្ញុំព្រះអង្គហោង ។ ព្រះអង្គសព្វញ្ញូ យើងខុកជាគ្រូ ជា ម្ចាស់យើងផង ចំរើបុំរុង ព្រះអង្គឥតហ្មង សិរសោភ័ព្រង ខត្តួលអាសា ។ ពោះមានសត្រូវ បៀតព្រះដល់ទៅ ប្រមាថតាធា យើងយកខ្លួនប័ះ តាង ព្រះពជា កុំឲ្យអាណា ទៅបៀតព្រះអង្គ ។

កាលណោះពោធិ-សត្តថ្លៃវៃរើ សេសសារពេជ្ជពង្ស ពន្ធកពុទ្ធក្រ វែលក្តណ៌វែរ -ឆ្ងាស័ក្តិសំម -ង្គិលកបច្រាជ្ញា ។ ព្រះកក្តស្រស់ស្រួល បើក ព្រះបន្ទូល មធួរថ្លៃឯថា យកក្តអើយអញអរ អំណរមហិមា អរនឹងវាចា

ព្រះស្តេងស្រដី ។ ដ្បិតអញកំព្រា ព្រាត់ប្រាសភាព មកនៅបូរី ហេមពាន្ធសោះសូន្យ ខន់ប្អូនមួយស្រី សត្វថ្លៃតែបី- នាក់ខន់អស្សត្រ ។ បើចៅពាល់គ្នា អាណិតមេត្តា អង្គអញាស្មោះសរ ចូរចៅនាំផល ខ្លួនផលាករ ទៅឲ្យអញាប-រិភោគកំសត្វថ្លៃ ។ យកទូលធ្វើយធ្វាស បពិត្រអម្ចាស់ កុំព្រួយព្រះឱយ ជានាយើងខ្ញុំ ខន់នាំផលស័យ ខ្លួនផលព្រឹក្សព្រៃ ទៅថ្វាយព្រះអង្គ ។ ជាតិជាគោជន៍កសុ ប្រសិទ្ធិរស ខ្លួនព្រះណាមស្រង់ ថ្វាយក្សត្រប្រសើរ បំរើព្រះអង្គ លុះយើងខ្ញុំបង់ ជីវិតកល់គ្នា ។ នោធីសត្វធ្វើយ ថាហៃយក្ខអើយ អញអរចិត្តបា មោះព្រះសុរិយន់ ខន់តាបសន្ធយា អង្គអញាសូមលា អស់ព្រះស្តេងទៅ ។ កុម្ភណ្ឌថ្វាយការ អញ្ជើញាស្តេចចរ ពន្យុគ្គខ្ញុំចៅ ឡើងគង់សោះហោះ ផ្លេកផ្លោះសំដៅ ដល់ទីលំនៅ ប្រាសាទសុវណ្ណា ។

ស្តេចដល់ស្រេចស្រាប់ ឲ្យផ្លែក្រចាប់ ផ្លែបទុមា តញ្ចាប់ស្ទឹកស្រះ ដល់ព្រះប្អូនក្សា នាងនន់នាង ខ្លួលយកទៅ ។ រីឯតយ៉ារីឯតិត រីឯគន់ រីឯតិត ទ្វាបត្រះចមចៅ ក្រើតក្រែស្រស់ស្រោយ ទិយាយមកទៅ ឥតឯ ហ្នឹងសៅ មោរមន្ទិលា ។ ធ្វើវត្តប្រណិប័ត្ត បរម្រើមហាក្សត្រ ដូចសត្វទាំក ស្តេចប្រាប់ក៏ស្តាន ខ្លួនាងយក្សា ទាំងប្អូនបានជា បរិភោគព្រះអង្គ ។ កាលរះគ្រាយភោជ លែមកមន្ទីរ មណ្ឌលតួរគង់ សន្ធឹកដួចដួន ទាំងប្អូនយក្ខយង់ ស្តីបាយើងជង់ តិតប៉ាមែកគ្នា ។ ពីរនាក់ចូរចៅ ក្នែងជាមនុស្សទៅ ចំរើកជា ការក្រែងសត្រូវ កះខ្លាបំណាច ក្រែងព្រះអង្គអា – ពាធភ័យខ្លាច ។ គ្រោនថ្មមក្សា តបគុណាក្សត្រា ដ្បិតស្តេចស្តេងមាន ព្រះ

តេជព្រះគុណ ដ្ឋន់ពន់ប្រមាណ មួយរោតអស់គាណ រកផ្លែឈើផង ។
ថ្វាយសត្វវិលា ប្រណិប័ត្តក្សត្រា កុំឲ្យមានហ្មង យើងគាំងពីរនាក់ នៅ
រក្សាគ្រង ស្រះស្រើនឹងដង ទឹកតំត្បាងថ្លា ។ កាប់ផ្លែឈូកដក ក្រតុឈូកយក
ក្រចាប់ផលា ខៀងនៅថ្វាយថ្វត់ មហាក្សត្រសត្វគ្រា សត្វខំនខាំ កុំឲ្យ
ខាតខាន ។ ថារស្រេចយកទូពីរ ប្រែប្រាណតន្ត្រីយ៍ ជាមនុស្សស្មោះស្មាន
ហៀរហោះទៅដល់ មណ្ឌលក្សត្រក្បាន ខន្ធបប្រញាប្រាណ បត់ជាខ
បង្គំ ។ ទើបទូលទៅថា បពិត្រព្រះមហា-ភដរយើងខ្ញុំ ជាយក្សនៅស្រះ ខ្ញុំ
ព្រះអង្គអ-ម្ចាស់ថ្លៃខ្ពស់ ឥស្សរសិរសា ។ កៀសប្រាណមកនៅ ចំរើ
បមទៅ រីឯរូហា ឲ្យនៅតំក្តី ស្រះស្រើរឥតថ្លា ដងព្រះគង្គា បេះផ្លែ
បទុម ។ ដកយកត្រឡុះ បេះក្រចាប់នៅ មកថ្វាយតង្គអ-ម្ចាស់ថ្លៃលើស
លើ រីពីរយើងខ្ញុំ នៅអាយជាទំ-រំពេលវិលា ។ មួយទឹងទៅរក ផ្លែ
ឈើផងមក ថ្វាយមហាក្សត្រជា សត្វថ្លៃគ្រាន់សោយ កុំឲ្យព្រះជា-រម្ភរិះ-
អស់អា-ហារហើយព្រួយប្រាណ ។ ពោធិសត្វឆ្លើយ ថាហៃយក្សអើយ
គត្តាអរិត្តកាណ ដឹងគុណអង្គអញ្ជ នោះមិញ្ជាស្មោះស្មាន មកនៅគ្រាន់
បាន ជាគ្នាសោះស្មាត់ ។ តាំងពីនោះទៅ យក្សតាំងពីរនោ គោរពធ្វើ
វត្ត គ្រប់គោលវិលា ជាអ្នកប្រយ័ត្ន មិនឲ្យមហាក្សត្រ មានហ្មងព្រះង័យ
ពោធិ៍ថ្លៃដ៏ថ្លាខ គង់នៅសុខសាន្ត អម្ចាស់ជីវិត្ត ស្តេចទឹងអស្សតរ ភ្ញុចរ
ទៅព្រៃ រីឯរុះឈើនៃ យក្សយកមកថ្វាយ ។

រីកាលណោះណា ក្សត្រីចន្ទ្រា ពិតពុំសប្បាយ ដ្ឋលក្នុងចិត្ត

ព្រោះដូច្នេះឃ្លាតឡាយ ពុំបានយល់តាយ យល់តក្រែកស្តា ។ ក្សត្រី ទ្រង់តិត ថាទ្រព្រះមេត្រ ព្រះមេសេស្ដហា សមព្រះអង្គនឹង ខន្ធឹង ប្អូនក្លា ចិខបាត់លង់ជា ចិថ្ងៃទៀងហើយ ។ ពុំឃើញប្អូនទៅ សម ព្រះចមទៅ ជាខ្លុតពុំសៀ្ច គួរឱ្យអាណិត ព្រះមេត្រគ្រាណាត្រើយ សម សោកឥតល្ហើយ ឥតល្ហែព្រះទ័យ ។ ធ្វើម្ដេចញ៉ាំងបាន ព្រះរៀមក្សត្រ ក្សាន្ត ស្ដេចចេញទៅព្រៃ ខ្ចប្អូនទឹងបាន ទៅថ្ងាន ក្សត្រៃថ្ងៃ រួមក្សត្រមូលមៃ ត្រីក្សត្រនោមទាយ ។ ខែនេះ ហេមន្ត ពុំតីវស្សន្ត រដូវផ្ទៃស្ងាយ គួរអញទឹង ធ្វើ អំតើនថ្ងាយ ឱ្យក្សត្រពណ្ណាយ ស្ដេចចេញទៅព្រៃ ។ ព្រះរៀមបវរ ស្ដេចជ្រាបជាក្រ ហើយព្រះដៃម្ចាស់ ទឹងប្រើយក្លាទៅ ទៅទាំងក្សត្រៃថ្ងៃ ព្រោះព្រះមានមៃ ត្រីទ្រង់ក្សុណា ។ ស្រេចនន់ន្ទោ នៃព្រះពង្សពោធិ ទើបទូលទៅថា បពិត្រទេសាលំ ឱ្យលះសប្តីថា ចានឆ្នៃអង្គា អំពីហេម ពាន្ត ។ ហាក់ខ្ញុំគោក្តា តានសេតិសា ក្រែក្រំប្រមាណ សូមព្រះហារវង្ស ស្ដេចទ្រង់ក្រោសប្រាណ ទៅរកឱ្យបាន បិទខ្ញុំម្ចាស់ចង់ ។

សម្ដេចនន់ន្ទ នរបតិន្ទ្រ អរិយ៍ពុទ្ធពង្ស ស្តាប់ព្រះប្អូនទូល ខន្ធូលហើយទ្រង់ គ្រាស់ទៅតាន់តង្គ អមុខសក្សត្រក្សាន្ត ។ ប្អូនអើយហេមន្ត ពុំតីវស្សន្ត រដូវក្រែងគ្មាន បងគិតបងឈ្លើន បងក្រែងពុំបាន តែព្រះហេម. ពាន្ត ដើមប្រើនក្រាស់ក្រៃ ។ តែបងពុំបាន ឆានាថាបាន ឱ្យប្អូនមាសមៃ ដ្បិតនៃពុំត្រូវ រដូវឡើយនៃ កុំប្អូនថ្នើមថ្ងៃ អាក់អន់ចិត្ត ។ បងទឹង ទៅរក ឱ្យប្អូនតក្នុក ក្រែងបុណ្យប្អូនក្លា ប្រាកដមិនបាន ដូចគ្មានប្រាថ្នា ត្រាស់ស្រេចប្រើថា ហៃយក្នុងវាំងនេ្ច ។ ដ្បិតប្អូនឆោមនាយ ចិត្តបងស៊ី

ស្វាយ ចូរអ្នកប្រាស់ប្រៃ ត្រាច់ទៅបច្ចឹមៈ ទំរតំយេ ទំសទ្ធំណោ
អន្តេយ៍បូតា ។ អញ្ជាទៅរកពី ប្តូរាទំសទ័ ឆ្ងាំសាណទ្ធក រៀងពាប
ក្រឡាប់ ពាយព្យបច្ចឹមា យកូតរ៉ាក្រាបណា ផ្លែកន្ទោះហោះទៅ ។ កាល
ក្រោយក្រុងយក្ស សម្តេចហរិវៈ ផ្លែផ្តាំប្អូនទៅ លំលាលះលោក ចេញ
ពាកលំនៅ បន្ទុលហោរហៅ សិទ្ធពអស្សយាន ។ ច្រាយច្រាប់អស្សតង្ស
អំតំចំណង់ ព្រះប្អូនកល្យាណ សេះសាតក្រួញក្រាប ទ្ធូបអគ្គីច្រុំណា
ទន្ធឲ្យស្តេចឈាន ឡើងគង់បរិបូណ៌ ហោះដោយអាកាស រស្មីទ្ធុះឆ្ងាស
ប្រៃសើរឥតគូ. ហេតុដោយជវនៃ សេះតន់តុំយូរ នានាំព្រះភ្ញូ-ធដេល់
ហេមពាន្ត ។ ស្តេចរកសត្វជ្រោះ សត្វច្រកលង់លុះ ថ្ងៃត្រង់តុំបាន
ស្តែងស្តេចចូលឈប់ នៅអូបមួយមាន នៅត្រឹកក្បាសាន្ត ទ្រនំផលបុប្ផា ។
នាងាងមាត់អូរ ដួយមានទឹកហូរ អំរិបត្ថាតា ស្តេចចុះស្រប់ស្រង់
លាងអង្គអស្សពាហ៍ ស្រេចមកតុំនា ក្នុងដាតិមួយដំ ។ សេះរកស៊ីស្មៅ
ដុំកំចមៅ ថ្ងៃត្រង់ទៅឯកុ-ម្ភាណ្ឌពីរកសត្វ ទំសត្រប់ដំតុំ យន់ឃល់
ឡើងលំ. ហែអង្គាគាត្ត ។ ហោះទៅបួងបួន ផងគ្នាជាបួន ឲ្យដួយរកគ្នា
សឹងរកតុំបាន ដួចក្តាន្ទ្រាថ្នា ពីព្រោងសុំយោ លុះល្ងាចត្រជាក់ ។

នៃនាងបន្ទា កាលក្រោយយក្ស ទំនត្រទ្រង់លក្សណ៍ ចរចេញទៅ
ព្រៃ ក្សត្រីព្រឺសតង្គ ទៅតាន់សំណាត់ អរ័យកុមារ ។ ឯរបួលកង់ស្តេរ
ក្តីការត្រេតអរ ថ្នាត់ដួមដាយោ ដួតតួតមេត្រី ដោយក្តីស្នេហា បម្លួលស្មារថា

ហៃហ្អូនប្រឹមប្រើយ ។ មានមោះហ្អូនតួ ហេតុម្តេចកំបាត់ លង់ដល់ថ្ងៃថ្ងៃ
ព្រួងបងតែងតឹង ខន្ធឹងប្អូនស្រី ព្រះរៀមចក្រី ទៅគាន់យក្សា ។ ញ៉ាំទ
ព្រះបង់បាន ត្រឡប់លែងថ្លាន ច្រាសខសុវណ្ណា ថ្នូយក្សពិយាជ ដន្ធជាតិ
មរណា ឬបានយកូជា បរិពារទៀតតន់ ។ ក្សត្រ័ចន្លា លុតលើកហត្ថា
ទុនអភិវន្ទ ទូលថាបពិត្រ មហាក្សត្រសោតណ ព្រះរៀមរំខ្ចិត-ទ្វឹកលើស
លោកផង ។ ប្រើព្រះជេស្ឋជ័យ ឲ្យទៅក្សិណក្សយ ច្រើនគ្រាច្រើនជង
ថាជានឹងបាន ដូចក្នានបំណង ប្រែបានសត្វផង មកជាបរិពារ ។
ប្រើទៅគាន់យក្ខ ជ្រួជាតិអបល័ក្សណ៍ ចិត្តចោរមោហា ស្មានម្តងនឹងក្សយ
ដូចក្តីច្រាំថ្នា ប្រែបានយកក្សជា បរិពារពុំក្សយ ។ ឥឡូវយកយក្ខ មកទៅ
តីរនាក់ បម្រើសត្វថ្ងៃ ព្រះបាទកូធរ ពុំបរទៅព្រៃ ព្រោះយក្ខនោះនៃ រក
ផ្លែឈើថ្វាយ ។ ខ្ញុំនឹកព្រះរៀម ដ.ខុក្ខក្រែងគ្រៀម ក្រែងក្រុងក្នុងកាយ ខ្ញុំក្លួត
ព្រះអង្គ ឋាបង់ឥស្សាយ ចូរក្សត្រតណ្ហាយ បរបេញ្ញាទៅរក ។ ទៅតាំង
យកមួតីរលះលែងមន្ទីរ ទើបខ្ញុំបានមក យល់ព្រះកត្រ្តថ្ងៃ ស្មាមីតទ្វក សៀយ
អស់ខុក្ខសោក ពីអង្គឥន្ទ្រីយ៍ ។ បពិត្រក្សត្រថ្ងៃ យើងនេះសមក្សយ
ច្រាកដតាំងខ្ញុ រំនេកតាល់កិច្ច ដូចម្តេចកូមី ឲ្យរស់ដីវ៉ែ ខិត្យនៅសុខ
សាទរ ។ កុមារធ្វើយថ្លាន ប្អូនអើយបងមាន ភ្លាយខ្ពស់ស្មាងស្មាត
ពីព្រះបិតា ក្សត្រានខោថ តែងនឹងពិយោជ ជីវតមនុស្សម្នា ។ យើង
រៀបខុកក្នង បន្ទប់តែងស្រង់ បើមហាក្សត្រ ដល់ហើយព្រះវង្ស តង់ស្រង់
កាលណា ចូរនាងធ្វើជា ត្រៃមេមសំដី ។ ឲ្យព្រួដល់ផាក់ បងនឹងកន្ត្រាក់

ខម្លាក់ចក្រី ត្រូវនឹងលំតែង យន្តស្តែងសម្បី ក្បាលក្បាយកុំស្រី តន់តិតតយ៉ា ។ ពីតងរ្យែងតិត ត្រមត្រះតំនិត ស្រេចហើយយកភ្លារ មកវៀបពុកក្នុង ខ័ស្រែងក្បត្រា សិតនៃត្រាន ណា នាំទៅតង់ស្តារ ។ ស្រេចនាង ណាទៅ តប់ចាំព្រះទៅ ស័ហបញ្ជារន្ត រ៉ែពោធិសត្វ បុរសត្តតន់ ស្តេចនុះក្រាមម. ណ្ហាសម្ងប់ត្រីក្បា ។

សូរ្យសាយណ្ហា ខោរខន់តាបខោ ខៀតខើបត្រះមហា បុរសតើន ត្រែង ស្រប់ស្រែងតង្គា ម្បើដតង់អស្សភាហ៍ ហៀវហោរត្រែតត្រាំប់ ។ ដោយជតង់ត្រីក្បា យោនយានសាខា លតាលូតលេច លំខោនខតិខន់ ណ្ហាសណ្ងន់ស្រែសស្រែច អាសូរត្រែរស្តេច រកផ្សារម្ហា ។ ខតយល់ដើមស្វាយ មួយចែមកត្រសាយ មែនមានផលា មួយជាប់ខាខែង អង្ក្រែងធ្លើជា សម្បុតពាសតារ ដិតដុំពិ.ក្រៅ ។ ហេតុបុណ្យមានក្តែក មួយខំនៅមែក បូលហើយដូច.ខ្យ ចឹតសម្បុតនោះ ស្តេចឆ្ពោះខតទៅ ឃល់ជាក់ចមាច់ ចន្ទលថាបង ។ ចង់តែយមើលក្តែក នោះនឹងចឹតហែក សម្បុតអង្ក្រែង ហេតុនេះប្អូនយល់ ប្អូលន្ទល់តន្ទង ម៉ើឆ្ពោះបូរបង នាំប្អូនចូលទៅ ។ ក្រែងអង្ក្រែងខ្ញុំ ជាប់ខ្នែស្វាយខុំ ខាំខន់ខនោះខ្យ សេះស្តាប់ខន្តោរ ក្បត្រាចមាច់ ហ៊ានហោះសំរោង ចរបូលទៅដិត ។ ក្តែកយល់ចមាច់ តិតតយ៉ាហ៊ារទៅ ព្រោះជាខ្រែងខ្លែ ហែកសម្បុតអ.ង្ក្រែង ខ្រែងពិនិត្យ យល់ខ្នែស្វាយតិត អត់តខមា ។ បេះជាខតាលណោះ ខ្រែងត្រឡប់ឆ្ពោះ .ខៅតាន់តាត ដល់ស្រែចស្តេចខ្រែង ឲ្យអង្គអនុជា អនុវ

វង្ស ខ្ញុំលុកនៅ ។ អញ្ជើញព្រះអង្គ ឲ្យចូលស្រង់ កេះកយ
ចៅរៅ ធ្វើស្មោះស្មានត្រង់ ខឹងអង្គចមចៅ ស្តេចចូលទៅ ខឹងស្រង់
គង្គា ។ ស្តេចយល់ក្តាក់ឫក ក្តារនេះចំឡែក ចង្ហុលសួរថា ហៃប្អូនឥន្ទ្រា
បានមកពីណា នាងគ្រាបវង្ស ទូលស្នងព្រះអង្គ ។ ក្តារនេះស្អែង
ស្អុត នៅក្នុងប្រាសាទ ក្សត្រាធ្វើសង្រ្គង់ សម្រាប់ខុកជា ក្រឡាណាំ
ស្រង់ ខ្ញុំថ្វាយព្រះអង្គ ដម្រះកាយា ។ ព្រះស្រីសារពេជ្ជ តង់ចរបូណា
ស្រេច ក្សត្រីណានាងធ្វើជា ត្រហែមបន្ទី អភ័យកុមារ ឆ្នៀងជាក់ជា
បន្ទីក្សត្រី ទាញខ្សែកន្ត្រាក់ កន្ទុះយន្តដ្ឋាក់ ព្រះបាទចក្រី ទេព
ដែលក្សត្រ ក្សត្រាធិបតី ផាត់ឈ្មោះតែងឲ្យ ពុំត្រូវព្រះអង្គ ។ ព្រះអង្គខឹង
ពេត ខឹងចិត្តក្រៃក្រោធ លើលាឡើងគង់ យកឫកលុបលាង សារភាង្គ
ព្រះអង្គ ព្រះស្តេត្រគ្រាស់ទ្រង់ មានមន្ត្រីថា ។

តុអញឥតគ្គង ឥតទោសអ្វីផង ខឹងអ្នកឯណា មោះមកហ៊ានធ្វើ
អំពើមាយា ឲ្យអញមរណា តើញុំងទោសអ្វី ។ នាងយល់ក្សត្រីថ្ងៃ
ពុំបានក្សត្រីណាស្រួយ សែងព្រះភូមី ញ៉ាំអង្គខ្ទេត សូន់ស្តុតស្មារតី
រត់រៃពីផ្ទៃខ្ញុំ ចូលក្នុងប្រាសាទ ។ សំដីតួនព័ន្ធ ញ៉ាំជជួបកូនសត្វ ខ្លាច
ក្សួយដន្ធជាតិ ក្សត្រីណាយក្សត្រីដេល អគ្គមហេសីនាថ ក្រែញក្រាបក្រាមថ្វា-
យាទៅបង្គំលថា ។ បតិព្រតក្សត្រក្សាន្ត ខរណៈអាចហ៊ាន ប្រមាទ
ក្សត្រា យើងខ្ញុំសូមកេ ចារយកបង្ហ- មិត្រមកថ្វាយមហា- ក្សត្រ
ថ្លៃឲ្យបាន ។ ស្រេចម្នាក់ហោះស្រែក- ដីទៅជោយតេជ ដល់ឋាត
ជាលហ៊ាន ម្នាក់ហោះអាកាស រៀហាស៍ហៅហ៊ាន តុយល់លែក្តាន

ព្រះដ៏តម្កើងព្រះនាមថ្កើង ។ ចរចូលកុដិឋាន យធ៌យលំខ្សែពាន យកួយដំ
ឃោរឃៅ កែវដ៏ជាស្រមោច តូចៗខៀវៗ ពាសាមខ្សែៗ លុះចូលកុដិ
ស្ងាត់ ។ យកួពីរយលំដាក់ ប្រែប្រួលណាជាយកួ ប្រែបន់ខែរ ត្រែវត្រាច
ឆារដាក់ ចែកបាត់ល្អិតស្តែរ ប្រឹងប្រាន់ប្រួតប្រៃ. ខន់ខែរពេញសៅ ។
ដល់ចាំយយកួដូល តន្ត្រីពុទ្ធឆ្លើស បតិត្រែបមាប់ ខេរ៉ាន់ឯងជា
ខោហាយោរយៅ ពួនតំណិតិត្យខេរ៉ា ឆាកន្លងស្តេចសេស ។ សើច្រាន្តច្រាំ-
សាខ ប្រែសើរស្តាងល្អាត សុទ្ធសាតទុំប្លោម ខ្ញុំស្ទុំពាយាដ ដន្ទុដាតនៅសេ
លះលែងប្រែណាស្រែស ប្រាកដតែម្តង់ ។ ពោធិសត្តា ហេតុព្រះអង្គដា
តន្ទុកសត្តញ្ញូ ឥសូពោធដ ឯងឆាចដាត្រូ ត្រែរអង្គឥសូ ឃាត់ខៅយកួថា ។
ក្បាលដែងទុំប្លោម ឆាសូត្តាខៅ កុំប្រែមណោ ឆកល្អមហ៌ហ៊ីយតិត កន
ជិត្តដែងថា ទុំភ្លាំបុកត់ ខេរ៉ាន់ដីឋាតុំ ។ ពាមកួបន្ទុំ ខ្ញុំ ខោរឮមកសួន
ឯមទុំប្យាយោ ...ាំ ស្តាយអើយស្តាយ ពីនាយយើតរ៉ាតុំ ដេរ៉ាមកួមាប់ខៅ
ខោរយៃលំដាំ ។ អ្នកខេរ៉ាហៅកួ ប្រែសើរមហាតាប់ ម៉ិនឲ្យមណា
ស្តេចស្តាប់ប្រែប្រឹម ញាតាំមធ្វើយថា ខៃហាប្រែយក្សា ស្តាប់តញ្ជាធ្វើយ
រឹង ។ ឆម្តងអ្នកប្រាជ្ញ ប្រាជ្ញប្រុងឆាចតាតុំដែលទំង ខោរខុស
ប៉ុន្មាន ជាក្បាលកំពង់ អាចតាត់កំហឹង កំហុកខោរបាន ។ ដូចព្រះ
តាយដាត់ ថ្នាក់តុំតួត ខៀមខេញ្ជាសេងខាន រ៉ែនខោរសោ ខោរហោសា-
ហាន្យ ម៉ោរ្យបំពាន ឈ្នះចិត្តខ្ញុំ ។ ខោរណាតុំលោ ឆ្នកប្រាជ្ញដ្ឋាន
ប្រាំ អាសូរកុំបី ឲ្យឋង់ដន្ទុដាតិ ជូរអ្នកប្រណី ខោរភាំងខ្ញុំ ដាតិ

ជាប្រធាន ។ បើមានឮប៉ាសឹក មកមិនភ្លឹកភ្លឺក ខើបឃើញខុរហាន បើ
គាន់អំណត់ អាចអត់នោះបាន ឃើញកាលត្រាមាន សេចក្តីក្រាជា ។
បើឃើញប្រាជ្ញប្រាយ ឃើញកាលដោះស្រាយ អស់អាថប្រស្នា កម្រ
ក្រក្រើ ឃើញក្តីមេត្តា យដ៏យល់កាលត្រា មានចៅសប្រោសប្រាណ ។
បើឃើញដឹងគុណ អ្នកមានគុណគួន ឃើញកាលគេមាន គោសគាង
គោសស្មើ ថាបើមិនមាន ប្លេះហើយនឹងបាន ឃើញកាលឯណា ។

យកតួតីរច្រញប្រាណ ខ្លួនខ្ញុំខ្ញាន ខើបមហាសុត្រា ប្រៃព្រះកត្តែថ្ងៃ
ថាហៃកុមារ គោនុខាហ មាតាបិតរោ ។ គោនុនាមម្នក ចូរថ្ងែនដៀងដាក់
ដោយសច្ចាគោ តិដ្ឋតិន្តីរ នានីនាគោ ឃក្តីយក្ខោ ខេរិនួខេក ។
មនុស្សាមនុស្សោ តិន្តឯគោ ហេតុម្តេចបានជា អ្នកនៅហិនហោច
ត្រមោចតំត្រា ឥតញាតិកា ដៅជនពារគង្ស ។ ចូរចៅសំដែង
ដំណើរចៅឯង ដោយពាក្យពិតត្រង់ អញពុំឃកទោស សន្តោសឲ្យគង់
ជីវិតអញចង់ ដំនឹងដើមអតីតា ។

កុមារក្រុញក្រាប សិរសោស្រុកាប ស្រះពោនកក្តោ សញ្ជឹងសញ្ជប់
ថ្កប់ព្រះសិរសោ លើកត្រះហត្ថា ញាប់ញ័រមន្តិ ។ ខើបខូលចៅថា
បពិត្រព្រះមហា-បុរសខ្ញុំ រួចរស់ជីវិត ត្រោះជ្រកអង្គអ-ម្ចាស់ជ្រោសខ្ញុំសុំ
ជាខ្ញុំបាទ ។ ខូលស្រែចសុះសេពូ ដំណើរត្រាន់ត្រប់ ដួចជ្រាប់ធីតា
ពីសត្វឥន្ទ្រីយ៍ ឈ្មោះសត្តិមោហា មកផ្ទាញនគរ សូមស់ស្តាត់សូន្យឈឹង ។

ពោធីប្រសើរ ជ្រាបត្រប់ដំណើរ បន្ទូលសួរថែង ចៅអើយតំទិត ចៅ
តិតំពឹង ធ្វើកល់កម្មហ៊ឹង ពិយាជអញចៅ ។ ញ៉ាំងអញមានគ្តង់ មាន

ទោសអ្វីផង ខៃខន់ខ្លួនចៅ ប្តូរចៅតិតធ្យាន បងំបានប្អូនវិញ អង្គអញប្តូរចៅ បានរួមគ្នាហើយ ។

កុមារទូលថា បពិត្រព្រះមហា-ក្សត្រាត្រាណ ត្រើយ អញខ្ញុំជួរជាតិ ខន់ណាស់អ្វីឡើយ តិតដូច្នោះហើយ តាមតែមេត្តា ។ ក្រែងនាងមានតតិ លុះក្តួរទ្រង់ វែរ ដល់មហាក្សត្រា ក្រែងក្រោះពុំប្រោស អត់ទោសកុណា ហេតុនោះបានជា ខ្ញុំតិតពិឃាត ។ ឲ្យព្រះអង្គទៅ កាន់ស្វាខ្លាទៀ ខន់ឃក្សាសេ តិតឲ្យក្សត្រថ្លៃ ក្សិណក្សយជន្មជាតិ ឃល់ក្សត្រ ខនាថ ពុំក្សយជន្ម ។ បានជាឆ្លើយន្ត ខន់ផ្តាច់ជីពជន្ម ព្រះបាទក្សត្រា អញខ្ញុំខ្ចុចខុស ជាមនុស្សពាល តុំចរត្រមហា ក្សត្រាក្រាណ ។

ស្តេចបើកទង្ការ ហៃពាជកុមារ រំឯប្អូនស្រី អង្គអញឲ្យបា ឃកជា មហេសី តែអញស្រដី ប្រដៅចៅសិន ។ ចៅឯងរៀបចិត្ត ទោសខុច្ចរិត ខន់ទាំអង្គឥ-ន្ទ្រីយ៍ត្រួតអាចឲ្យ សេពសោយចក្ខុន ឥន្ទ្រិយ៍ក្រៃ រួចជាយ ។ ហេតុដោយអំពើ អំពីដើមរៀ អធម្មកម្មកាយ បំបែកបំបាក់ កំចាត់កំចាយ កំចោកបងំពាយ បងំពាត់អ្នកធង ។ បំបងំបំបាត់ ជីវិតសព្វសត្វ ហេតុវែរវង បងំឃ្លាបងំឃ្លាត អស់ញាតិឯងឯង ត្រាត់ត្រាស់ ប្អូនបង មាតាបិតា ។ ចូរប្រែប្រុងចិត្ត កាន់ដោយសុចរិត ធម៌ព្រះពុទ្ធា រក្សាសីលត្រាំ បងចាំជាក់ជា ពាំនាក់អាត្មា ទៅជាខន់ភ្លាន ។ ស្រេចព្រះបណ្តាំ ខ្លួសីលខាំងត្រាំ តាមធម៌ប្រពណី កុមារបន្តិ ប្រណម្យស្មាខាន សីលខាំងត្រាំបាន ក្លួចកត់ចាំនៅ ។

ពោធិសោភ័ណ ស្តេចទ្រង់ចំអន់ នៃព្រះប្អូនភៅ គ្រាស់ទ្រង់ព្រះស្រែល បន្ទូលហ៊ាហៅ ថាមៃប្អូនភៅ ពាលពេញស្នេហា ។ បងអ្នកចុកស្ងួន ស្មើចិត្តស្មើខ្លួន ស្មើអង្គរៀមក៏ ស្មានប្អូនសូនត្រង់ ពីកងទុក មិនដឹងឡើយជា ប្អូនត្រង់តែក្រៅ ។ ថ្ងៃនេះទើបដឹង ជាប្អូនព្រលឹង ចៃដន្យបេះជ្រះជ្រៅ កន្ទៀបលាក់កាយ មកអាយប្អូនភៅ បងនឹងឲ្យហៅ មួលស្វាមីមេ ។ បើបងមាសវិញ បងធ្លើះច្នេះមិញ បងពុំរត់ទេ បងនៅប្រែប្រឹងតាំងទឹងតែ តាំងតភាល់តែ ក្បាលក្បែរជង្គា ។ ស្តែងស្តេចបន្ទូលត្រេកទ្រង់ព្រះស្រែល ទឹងអង្គអនុជា មធ្យស្ថាកស្ថាយ ពោះពាយចរចា ហេតុព្រះទ័យជា ពន្ធុកពន្ធពង្ស ។

នាងភ្ញាស្តេចថ្ងៃឆ្ន ទុនភៀងអង្គឯង ពុំអាចជំអង់ ជំអឹងតាជ្ញាក្សត្រាវង្ស ចិន្តាពុំបង់ យល់ព្រះកត្តា ។ យានភៅតាំងភាល់ ទុនអង្គតង់តាល់ បង្គិកជា ពុំភៅខៀបនៃ អភ័យកុមារ ស្តេចស្រែលត្រាស់ថា មៃប្អូនឱមឱយ ។ កុំធ្វើមិនត្រឹម ទៅមកឲ្យទឹម ជិតមកភៅអាយ បងនឹងឲ្យដំរី ប្រពៃពណ្ណាយ ឲ្យសុខសប្បាយមួលមួយជង្គា ។ នាងទិតសន្សឹម ចូលភៅទុំម ទុំងអង្គកុមារ ព័ពេញប្រពៃ លើកមកអភិវាទ ក្រាបខៀបជាតា ព្រះពង្សពោធិ ។ ស្តេចទ្រង់ញាញឹម ប៉ៃប្រៃប៉ាំម ទើបត្រេកក្បាំ ចំរើនព្រះពរ បវរប៉ុន្មាន អនុជតាំងខ្លី ខ្នួលព្រះពរ ។ ពីថ្ងៃនោះភៅ ប៉ាអង្គនិត្យនៅ ជាសុខស្មោះសរ តាំងពីរពង្សក្សត្រ ប្រណិប័ត្តកូនរ ស្មោះស្មើព្រះវរមាតាបិតា ។

លង់លុះរោត្រី ព្រះពង្សរោធី ចូលទីសេយ្យា សេយ្យាសន៍ ឯកអង្គ នៅក្នុងច្រាង្គច្រា-សាទសង់ឥតា ប្រុសើរសក្តិសម ។ ក្នុងនឹកមានា ខ្សឹកខ្សួលទុក ទុះក្រៀមក្រំ នុះនុព្រះមេ តាំងតែកូនតំ-ព្រាព្រាត់ចាកចំ បែងចាត់មុខមក ។ សមព្រះមេមាន តែខ្លួនឥតស្រាន្ត ឥតស្រាកវិយោគ សង្រេងសង្រែក កន្ទេងរែក កូនចាត់សំស្មោក ដល់ក្សីយដ្ឋា ។ នុះនុព្រះគុណ ប្រុសើរមេហាជន់ ឥតឯបមា អ្នកនៅផ្ទៃវត្ត ប្រណាំបត្តុយក្សា ញាំងត្រូវចិត្តវ ឬមួយពុំត្រូវ ។ ឬយកូយកជា អាហារគោក្តា ឬព្រះមេនៅ ជាសុខសប្បាយ លោះលាយពុំស្ងួត គន់គិតកូនស្ងួត យកូយដ៏មេត្តា ។ នេះហេតុហៅ ភៀវ ពុំទិក្សាំទៀវ នៃអង្គអាត្មា អំពីបុព្វជាតិ បន់ឃ្លាតបន់ឃ្លា ឲ្យយើងព្រាត់គ្នា ពុំបានមួយមួល ។ ពីដើមអញគ្មាន សេនាគ-ហាន ត្រកាលត្រកូល ឥឡូវអញបាន ទាហានមិត្តមួល គិតគួរលើកបួល ទៅកាន់ទន្លា ។ សម្ងាប់នន្ទី យកូយដ៏ខ្ចី នោះឯងឲ្យមរណ៍ រួចហើយសិមអញ យកពង្សសោយបរិ-បូណ៌បានពស្ត្រប្រ-ជាជនជួបជុំ ។ ស្តេចរែងសូរ្យ សែងសាយបរិបូណ៌- មិមិញបួនចំ ពោះពីបពារពី- លាវិសេសស- ម្តេចដឹងដោយដំ- ណើរនៃយោគ យោម ។ ចរចូលស្រប់ស្រង់ ជម្រះអស់ពង្គ ពិតឥព្រហ្មោម ប្រជាប់អង្គ៌ស្ងួត្រ មុជវត្តអាពាម ហូរក្សន្ទាម សូរឆកឆក ។ ទើបព្រះកូមិ ត្រាស់គាន់ពាដ៏ ថាចូរបងចរ ទៅទិសឯលិច ហៅស្តេចពាន រហ័ស

ទៅទត្តរ ហៅស្តេចខ្វាឃ្មុំ ។ ឲ្យបរមូលពល បរិវារគ្រប់ចំ ឲ្យដួច
ឲ្យដុំ ឲ្យចូលមកកាន់ ហេមន្តវដ្តមេឃ យើងនឹងដំនុំ រិះគិតពាធគារ ។
សេះគ្រាបណាទៅ ត្រាណាត្រាប់ហារហៅ ស្តេចស្វាស្តេចខ្វា សឹងអារ
ស្រែះស្រែល ខ្លួលអាថ្ម បបួលយោធា ដោយខ្នុនរួសពន់ ។ គាល
ក្រោយពាជី ទៅទើបពោធី ត្រាស់ប្រើកុម្ភណ្ឌ តាំងពីនោះនោះ ឲ្យ
ហោះទៅកាន់ តាំងពីកុម្ភណ្ឌ ចូលមកបង្គំ ។ រីឯស្តេចស្វា ន្ទវិអគ្គ
ស្តេចខ្វា បបួលពលថ្មុំ ស្រែចស្រោចស្រើបស្រួល ចរចូលបង្គំ ។
ព្រះបាទព្រះបរមេ គោធីសម្ភារ ។ ក្នើនព្រះកេរ្តិ៍ស្តែង ដួចព្រះចន្ទ្រ
ចែង រស្មីពិស្តារ តន់ទៅកណ្តាល ពលរាលបរិវារ ដួចដង់តាក(១)
ចរចោមព្រះបន្ទូ ។ អនុជភាតិពីរ ទុទគន្ធីព្រះសិរ-សាសួស្តីអតិទ្ធ
ស្តេចបើកទត្តរ ពិស្តារវែងសព្វន់ ទ្រង់ត្រាស់ទៅកាន់ ជំនុំយោធា ។

អង្គអញ្ជបីបំ- ណាន៥ធីទាតាំ នៃអ្នកយាត្រា ទៅពាកណ៌សី ចូរ-
វដ្ឋ ត្រាសត្រាប់យក្ស ឈ្មោះនន្ទីយក្ខ ។ គឺនិតកំណាច កំណើត
កៀចគាច ចិត្តចោរអបល័ក្ខណ៍ ទ្រុស្តទ្រើសតិយោធ ព្រះបាទទ្រង់
លក្ខណ៍ ព្រះនាមនៃអ្នក គាសិកមហាសុត្រ ។

គាលណោះព្រះបាទ ចេញទៅដ្រួតពល ព្រះត្រីក្សត្រៃស្ងាត់
ត្រមអស់សេនា យោធាពលតន្ត្រី ភ្លេងភ្លៃភ្លែបភ្លាត់ តស់អង្រឹតត្រៃ ។
យក្ខយង់ភ្លាយក្នែង ភ្លាយភ្លាប់អង្គឯង ជារជ្រើសមាសមៃ ស្តេចយល់
គួរគាប់ ចូលចាប់ព្រះទ័យ ទៅនឹងនឹមនាមទ័យ ឆាយដេញអម្រឹតា ។

---

(១) ដង់: ពាក្យសៀម ប្រែថា ផ្កាយ ។ តាក: ពាក្យថាលី ឬ សំស្ក្រឹត ប្រែថា ផ្កាយដែរ ។

ព្រោកព្រាត់ច្រាសពស ដល់ថ្ងៃមណ្ឌល នៃខន្ធិយក្ស ប្រែចាប់
ពិរោធ ព្រះបាទបិតា ក្សត្រិយ៍ជន្មា ជាចំណីយក្ខ ។ រួចរៀប
ស៊ីសេះ ។- មានតម្រិះ តម្រូវចិត្តជាក់ បញ្ជាកបរញ្ជាត បំពោតថាអ្នក
យកខ្ញុំជាកត្តិ ដែត្តែតមួយថ្ងៃ ។ ប៉ែអ្នកចូលចិត្ត តាមខ្ញុំតន់តិត អ្នក
បានដែត្តែតថ្ងៃ ស៊ីសឹងអាហារ ពិសាឲ្យញ៉ែក្រៃ អ្នកដែត្តែតបាល់ក្សីយ ដ
រិតមរណា ។ ក្នែងជាពមថៅ ឲ្យើងតវ៉ាខ្ញុំ៧ គ្រប់គ្រងសីមា គ្រប់
មុខមន្ត្រី គ្រងស្រែស្រុងផ្ការ គ្រងនាងរមែលា ជាពជរទេពី ។ ហេតុ
ដំណើរនេះ យក្ខតាមពាក្យសេះ ។- រួចដំរី អង្គអសុរកាយ ក្នែងក្លាយ
តន្ត្រីយ៍ ដូចព្រះវរបិ- តារដ្ឋពជា ។ គ្រប់គ្រងបូរី គ្រងមុខមន្ត្រី
គ្រងស្នំស្នងហា ជាសុខឥតហ្មង គ្រប់គ្រងមាតា អង្គអញ្ជេនះជា ទេពី
ស្នេហ៍ស្និទ្ធ ។ ហើយយក្ខទ្រង់ត្រុះ ឲ្យជាក់ក្តីសេះ ច្រាំពីរវែងពិត
ហេតុបុណ្យពុំក្សយ យក្សកំយគ្រោះដ្បិត សេះដើងតំនិត ក្រែងច្រាប់
អ្នកផង ។ ហេតុតែបុណ្យផល អង្គអញ្ជេយល់ ឲ្យវែកច្រាប់
ប្រែង អំពីអំពើ ដំណើរខំនង ដំណាលដើមខង អញឃ្លាតដើងជាក់ ។
សេះឲ្យអញ្ជេ បញ្ជាតយក្ខខ្លៅ សុំសេះពីយក្ខ កាលដើមព្រះបាទ
ខរនាថទ្រង់សំក្តី ព្រះតំយស្មោះស្មគ្រ ថាឲ្យតស្សយាន ។ នេះតេច
ព្រះអង្គ បន្ទូលពុំគង់ ពាក្យសត្យប្រតិញ្ញាណ ប្រែយកអស្សតន្ត្រ
ជាក់ទ្រង់ពុំបាន ច្រោសព្រះពជាន ដូចពាក្យប្តេជ្ញា ។ យក្ខស្មាន
ពាក្យពិត ពាក្យពោលសុចរិត យក្ខឲ្យអស្សពាហ៍ ខាំរត់ចេញឆាត
លះលោកនគរ ទាំងព្រះមាតា ពុំដឹងសេចក្តី ។ មកច្រាំវែងស្ងាន់

យកតាមមកខាន់ យកគាត់សំរេច ស៊ីប្តូមិនដឹង អញទំនិងប្អូនស្រី ប្តូរ
តែឃ្លាតខ្លី ចូលកន្លែងថ្មៃ ។ ខេញ្ចាំងបំពេ ចាំងតាយអញដឹត
យកយង់ចង្រៃ រកពុំឃល់ខ្លួល រំលែកត្រូងក្រៃ អញយល់សេះក្ស័យ
អញសូន្យស្មារតី ។ ព្រះឥន្ទ្រមកប្រស់ អង្គអញប្តូរសេ ឲ្យអញប្អូន
ស្រី ដើរកត្រអាល ចានក្សាលពដសីហ៍ ស្រេចឥន្ទ្រធិបតី ភ្លាប
ទំនិងអស្សពាហ៍ ។ ពាដីប្តូរសេ ជីតែស្មានស្មោះ ចេះហោះរំហាស
នាំអញមកគាន់ ហេមខ្លួនគត អង្គអញតិតថា ទំនិលើកពំពៅ ។
តំយោជនៃនខ្លួ. យកួយង់ខ្លួនិន យកស្រុកនិគ្យមៅ ព្រះស្តេចទំនិងតែ
តំនិតម្តេចហៅ ព្រើសព្រមតាមៅ ឬពុំហៅទេ ។

តាំងប្អូនយក្ស ស្តេចស្ងាស្តេចខ្វា ខ្លួតាំងតលរហ៍ ឮព្រះនន្ទាវ
ថ្ងៃថ្ងាសឹងតែ លើកហត្ថឆ្លង់ឯ មណ្ឌលសំរេច ។ ខ្លួលថាបពិត្រ
ព្រះភ្លុខខ្លែនិខ្លែ ជាមុជលោក ប្រសើរឆ្នុះទ្វាស សិល្បសាស្ត្រសត្យ
ច្រើជប្រុសពិស្តារ ធីការថ្លើនិថ្លាន ។ យើងខ្ញុំសឹងតាម ទៅធ្វើសង្គ្រាម
ស្នងគុណក្សត្រក្សាខ្ពួ រែនខ្លីយកួ សិខ្លីស័ក្តិហៅហាន យើងខ្ញុំគ្រប់
ច្រើណ ជានាគាសា ។ មិនឱ្យត្រួយព្រះ អង្គគាចពារពេះ យុទ្ធ-
យកួមោហា សាមាន្យសេរើ ពុំរស្ទើសក្តា ទំនិគាប់ខ្លួនគា- ខុគាត
ខុពស ។ បើដល់ត្រែក្រូង សូមព្រះអង្គគង់ ជាសុខក្សេមស្តុល
យើងយុទ្ធយកយកួ អបល់កួណ៌កំហល់ មិនឱ្យដឹតដល់ មកព្រះអង្គា ។
ស្តែងស្តេចជំនុំ ពលពាលមកជុំ ព្រមព្រះអង្គា អង់អួតស្រុះស្រួល
ខ្លួលគាសា ស្តេចក្តុំយោធា អំលុងបីវ៉ែថ្ម ។ ស្រេចវែចប្រាក់មាស

តែវាកន្ទុះធ្លាស សំពត់អាវវែស្បៃ សំពាយ ។ រៀបពាយច្រើនក្រៃ ពាជ
ទ្រព្យព្រះថ្លៃ ព្រះមហាក្សត្រា ។ យកទៅទំនង់ឲ្យ ទានមនុស្សផង
ដោយ ដែនជាធ៌មាតិ ទំនុកនៅអាយ ខួចខាយអាសា ឥតក្តៅឥត
ការ ឥតគេកក្តី ។ ស្តេចឲ្យព្រាទាក់ សំពាយមួយម្នាក់ ត្រប់ខ្លួន
សេនី ហើយឲ្យអភ័យ ព្រះថ្លៃចក្រី រួសពនឃ្មាតខ្លី តង់ស្តេចពាន ។
ចេញជាស្រុចស្រេច នាទាំស្តេងស្តេច ទើបព្រះកូនរ ឲ្យអង្គុចន្លា
អនុជបវរ លើលាចេញចរ តង់ស្តេចខ្វាឃ្មុំ ។ ចរចេញតាន់តាប់
ណាស់ណាន់បន្ទាប់ ខ្មៀតទើបព្រះបរម តោធិសត្តា ថ្លៃថ្លាទត្តម ស្តេច
តង់សេះសម ក្រោយក្រុងយោធា ។ កុម្ភណ្ឌទាំងបួន សឹងមុតសឹង
មួន សឹងមាំសឹងមារ សឹងមានដរយោ តាលោក្យវក្យា តាងតាន់ក្រពា
ដែកដោយដៃដំរ ។ តារតាល់ឯក្រោយ បែកបែរខាងម្ខាយ ហៃ
ក្សត្រប្រុសើរ ទោរដេកទោរដាក់ តំណាក់តំណើរ យកកូនតំណែងធ្លើ
ពេងកដពន្ធា ។

(មានត)

ទាញ៉ាវិបុលភាដសេនា ជ្វ.ភាន ប្រែរៀបរៀង

(តមក)

រឿងសាមកុកទុកជាយុទ្ធសាស្ត្រ
អ្នកវាងវៃធ្លាស បើបានអាន
ធំងបេះទុបាយកលបំណាន
ទាំងមានសន្តានស្នេហាជាតិ ។

ឯអ្នកចាំខ្លួលហើយក៏មើលដឹងសេចក្តីសព្វគ្រប់ ក៏ប្រឡោតទឹងខ្ញាំនណាស់ តិតនឹងឲ្យសម្លាប់ហាងតែចេញ ។ តួតៅក៏ចូលទៅរៀបនឹងអ្នកចាំថា គ្រានេះកងទ័ពលើកធ្ងន់ដែន ដែលចូលមកជិតណាស់ហើយ ហាងតែក៏នៅក្នុងកណ្តាប់ដៃយើង ដែលលោកនឹងបន្ទឹសម្លាប់ចេញនោះមិនគួរទេ សូមឲ្យលោកបង្អង់ឈប់សិនចុះ ត្រូវធ្វើជាមិនដឹងជល់តំនិតអ្នកសុង យើងសព្វាហ៍នៃតិត ធ្វើការសង្គ្រាមច្បាំងទឹងចូរឲ្យសំរេចសិន រួចសឹមតិតបាយយកស្រុកតីដី ឲ្យបានដោយងាយ អ្នកចាំក៏យល់ឃើញត្រូវដូនទើបលើកកងទ័ពទៅដំបន់លីយ៉ែន ។

ចូរឲ្យបានដឹងដំណឹងដូច្នោះ ក៏លើកកងទ័ពធ្ងន់ទៅតាំងបន្ទាយជាប់គ្នានឹងបន្ទាយអ្នកចាំ ។ ក៏ចាត់តាំងដៀវ ឲ្យឃុំនាំតាហានលើកចេញទៅច្បាំងនឹងចូរ ។ ក៏នាំតាហានទៅចាប់រសេះ ពីមុខបន្ទាយ ហើយឲ្យស៊ីហ្គីលើក

តាហានចេញតយុទ្ធនឹងអាំងដៀវបាន ៥ ភ្លេង ស៊ីហនយកខ្លួនចាក់ត្រូវអាំង
ដៀវធ្លាក់ពីលើសេះស្លាប់ ។

ចូឌូយើញគ្មានចំណាប់ គឺបញ្ជូលចូលប្រកាប់តាហានអួនចាំស្លាប់
អស់ជាច្រើន លុះតេលដឹងដល់ ចូឌូក៏នាំតាហានចូលបន្ទាយ អួនចាំក៏ឲ្យ
តាហានឡើងកាន់សើនជាមាំអួន ហើយឆ្លើសំបុត្រឲ្យបំរើសេះទៅរួមកង
ទ័ពអួនសុនលើកមកជួយ ។

អួនសុនឃើញសំបុត្រដូច្នេះ គឺប្រកាន់ឥសីមរៀងយថា ត្រូវតែ
កេណ្ឌតាហាន ៥ ពាន់លើកទៅជួយអួនចាំ ។ បំរើសេះចូឌូដឹង ក៏នាំសេចក្តី
នោះទៅជំរាបចូឌូថា ឥឡូវ អួនសុន ឲ្យតាហានលើកមកជួយអួនចាំ ។
ចូឌូដឹងដូច្នោះក៏បាត់ប្រើលីខឿន, ឆ័កជិន ឲ្យលើកតាហានទៅស្កាត់ផ្លូវ
តាហានអួនសុន ។ លីខឿន ឆ័កជិន ក៏លើកតាហានស្រួតទៅនៅចាំ
កណ្តាលផ្លូវ សម្លាប់តាហានគាំង ៥ ពាន់នោះស្លាប់អស់ ឥតសេស
សល់ឡើយ ។

អួនចាំដឹងថាអួនសុនឲ្យតាហាន ៥ ពាន់មកជួយ ហើយតាហាន
ចូឌូលើកទៅស្កាត់ផ្លូវសម្លាប់អស់ដូច្នោះ ក៏ខឹងណាស់ថា អួនសុនមិន
លើកមកជួយដោយខ្លួនឯង ដូចពាក្យទិឃាយ ក៏ឆេវហង៉តជាពាក្យគ្រោះ
អសុរកេះផ្សែង។ ។ ហង៉តតិថា លោកកុំអាលប្រកាន់សិន ខ្ញុំបាទ
នឹងឲ្យមានសំបុត្រទៅដល់អួនសុនវិញ ឲ្យលើកកងទ័ពចេញមកខ្លួនឯង
ឲ្យបាន ហើយហង៉តក៏ឆ្លើសំបុត្រសេចក្តីថា ឲ្យអួនសុនលើកកងទ័ពទៅ

ជួយ លុះធ្វើសំបុត្រហើយក៏ជូនទៅអ្នកចាំ។ក៏ប្រើបំរើសេះទៅដល់អ្នកសុង។

ឯអ្នកសុង ឃើញសំបុត្រហើយ ទើបប្រឹក្សាទីឆ្លាមផ្ទាល់ថា ដែលហាងគីនឹងឲ្យយើងលើកទ័ពទៅជួយអ្នកចាំនោះ អ្នកនឹងយល់ឃើញប្រការម្តេច? ឆ្លាមផ្ទាល់ឆ្លើយថា ការដែលលោកបានធ្វើជាចៅហ្វាយស្រុកនេះ គួរតែក៏មានសតិបញ្ញា គន់ដឹងដល់គំនិតយើង ប្រសិនជាគួរតែតគ្នានឹងអ្នកចាំ ធ្វើកលទាយទកសុំហាងគី ទៅជួយតតាសង្គ្រាមហើយនឹងលើកត្រឡប់មកវាយយកស្រុកគីវិញ ឥឡូវដែលអ្នកចាំឲ្យហាងគីមានសំបុត្រមកសុំកងទ័ពយើងទៅជួយនោះ លោកកុំគាលលើកទៅឡើយ ព្រោះអ្នកចាំមិនគាបគន់លំនិតគិត ទឹងចិត្តដែលចូលធ្វើបានទេ ត្រូវតែយើងទៅស្រឡាមឲ្យអ្នកចាំចាញ់ចូលទៅចុះ ទុបមាជួបយើងខ្ញុំដែលចូលឲ្យសម្លាប់អ្នកចាំចេញ ។ អ្នកសុងយល់ឃើញត្រូវឆន្ទៈ ក៏ធ្វើសំបុត្រតបទៅវិញថា ដែលទឹងឲ្យយើងលើកកងទ័ពទៅជួយនោះ មិនកើតទេ ព្រោះចូលកន្ទុងដែនចូលមកកន្ទុងស្រុកយើង ហើយ ត្រូវតែយើងរៃគិតការពារ រក្សាស្រុកខុកឲ្យមាំអ្នកបាន ។ បំរើកើតទួលសំបុត្រ ហើយស្រួតទៅឲ្យអ្នកចាំ។ ឃើញសំបុត្រហើយក៏ទឹងណាស់ ទើបចាត់ឲ្យចាប់យកខ្លួនហាងគី ទៅប្រហារជីវិត ហើយប្រឹក្សាទីគួរនោះ សុំនៈបនថា យើងគិតចូលទៅធ្វើពុតការជាមួយទឹងចូលវិញ ស្រួលជាង ប្រយោជន៍បានៈសេចក្តីសុខតទៅ ។ គួរតែទឹងសុំនៈបនទៅស្រួម មិនភាន់ធ្វើយតបថាម្តេច ។

ឯបំរើសេះ លុះឮដំណឹងដូច្នោះហើយ ក៏នាំសេចក្តីនោះទៅប្រាប់អ្នកសុង តាមពាក្យអ្នកចាំប្រឹក្សា ។ អ្នកសុងក៏ពិគ្រោះប្រឹក្សាទីឆ្លាមផ្ទាល់ថា

ប្រសិនបើ យើងមិនលើកទៅដួងអួនចាំហើយ អួនចាំគង់ទៅទៀតមិន
ចូលមិនខានឡើយថា ស្រុកយើងគ្មានមនុស្សឯណាយ ។ សឹមដោយយល់
ឃើញត្រូវដូច្នេះ អួនសុង្គីចាត់ប្រើសឹមដោយទឹងសោហ៊ុំ ជាឧកញ៉ាហាន
ឲ្យទៅរក្សាស្រុក ចាត់ប្រើលីកង ទឹងលីសៀម បងប្អូនឲ្យលើកទាហាន ៣
ម៉ឺនទៅជាទ័ពស្រួច អួនសុង្គីជាទ័ពហួង ប្រចាំជួនលើកចេញទៅ លុះទៅ
ដល់ដីតបន្តាយអួនចាំ កំណប់ទ័ពខាំស្ទាប់ការពារដល់អួនចាំឆ្លើសកងទ័ពចូល ។

ឯអួនហ៊ុំទឹងកោកងនឹងដំណឹងហើយ ក៏ប្រមូលទាហានជាកងទ័ព
លើកមកតាំងបន្តាយ ជាលំដាប់តគ្នាតបន្តាយអួនសុង្គីទៅ ។ ពេលនោះ
មានអ្នកបំរើសេរម្នាក់ ចូលទៅក្រាបអួនចាំថា អួនសុង្គី, អួនហ៊ុំ ទឹងកោកង
លើកទ័ពមកដួយ ។ អួនចាំក៏មានកំណរណាស់ មិនឆ្ងាយរៃគិតទឹងចូល
ទៅទាំងពួនឡើយ បើយឲ្យតាំងបន្តាយត្រួតមើលកងទ័ពទាំង ៣
កង រើម្បីទឹងដូសត្រាំង តទឹងពួនឡើងម្តេចនុះ ។

ឯណានោះ អួនសុង្គី, អួនហ៊ុំទឹងកោកងក៏លើកទាហានចេញតច្បាំង
ទឹងកងទ័ពចូល បាញ់កងទ័ពពួនត្រប់ត្រា គំរប់ ១៧.១៨ ថ្ងៃ ទាហាន
ក៏ត្រូវតាវុង តិចរស្ទាប់តស៊ូជាច្រើនណាស់ ។ លុះគ្រាដល់ថ្ងៃ ១ ចូលឆ្នាំ
ឃើញកងទ័ពអួនចាំ តំរៀបចែកកងទ័ពជា ៤ ក្រុម, លើកទៅ
ឯយទំលាយត្រមង់ទ្វារទាំង ៤ ទិស ត្រប់បន្តាយ ទាហានទាំង ៣ ស្រុកក៏
ប្រយុទ្ធតតាវស្ទាប់ខ្លះ ចាក់ទ័ពរត់ខ្ចាត់ខ្ចាយទៅផ្សេង ។ ខ្លះ ចាប់បានខ្លះ ។
អួនចាំ, អួនសុង្គី, អួនហ៊ុំ ទឹងកោកងឃើញថា ទឹងគ្រាំតទល់ពុំបាន

តំរាលបន្ទាយនាំគាហានគាំងឡាយ ដែលសល់នោះ វេរគត់ចេញទៅ
ចូរឆ្លុំលើកពលសេនាគាហានដេញតាមទៅ ។

ឯអ្នកចាំទឹងអ្នកសុងនោះ កំរត់ចូលទៅក្នុងស្រុកតគីជាវិញ ហើយឲ្យ
គាហានឡើងរក្សាសើនបន្ទាយជាមាំមួនតែអ្នកហ៊ីទឹងកោកន់លើកគាហាន
ទៅតាំងបន្ទាយប្លាំងតទឹងចូរឆ្ងាងក្រៅស្រុក ចូរឆ្លុំឲ្យតាំងបន្ទាយជាប់គ្នា
ហើយលើកទៅក់យបន្ទាយអ្នកហ៊ី, កោកន់ជាច្រើនគ្រា មិនបែក។ គុយកែ
ជំរាបចូរឆ្លុំថា វេលានោះ អ្នកសៀវស្ងាប់ទៅហើយ គាហានដែលយើង
ចាប់បាននោះ ក៏និយាយថា បុត្រអ្នកសៀវ ៣ នាក់ ជះណ្តើមគ្នាបង់ចូលទឹង
អ្នកសុងជាប្អូន តាំងខ្លួនជាចៅហ្វាយខែត្រតគីជាវ គ្រានេះ ខ្លួនមានបឹក
សង្គ្រាមបានជាព្រមគ្នាលើកទ័ពមកប្លាំងជួយគ្នារក្សាស្រុក ប្រសិនបើអស់
សឹកសង្គ្រាមហើយ អ្នកទាំង ៣ នាក់ ក៏ទឹងតាំងជះណ្តើមគ្នាកើតជាជំពាំង
ស្បើងពុំខាន ហេតុនេះ សូមឲ្យលោកលះបង់ ស្រុកតគីជាវទុកមួយអន្លើសិន
ចុះ ត្រូវលើកគងទ័ពទៅក់យយកស្រុកកេងជាវ ទឹងអាណាខែត្រទិសខាង
ត្បូង កំចាត់ឡៅប៉ៅវេញសិន ឯបុត្រអ្នកសៀវ ៣ នាក់នេះ បើយើញ
យើងលើកគងទ័ពចេញទៅហើយ គង់ទឹងបណ្តាលជាជំពាំង ជះណ្តើម
យកស្រុកគ្នាទៅវិញទៅមក កាលណាបើ កំឡាំងខាងណាអន់ថយចុះ
ហើយ សឹមយើងលើក មកព្រួតក់យយកស្រុកតគីជាវបាន ប្រាំងក៏ងាយ
ណាស់ ។ ចូរឆ្លុយល់ត្រូវផង ទើបប្រជុំគ្នាលើកគងទ័ពត្រឡប់ទៅបន្ទាយ
ល្ប៉ីយ៉ុង ហើយចាត់ឲ្យគាសៀតត្រតគាហាន ទៅកំងទ័ពក្នុងដំបន់នោះ
ចាត់ឲ្យចោហងលើកគាហានទៅកំងទ័ព ទៅមាត់ទន្លេហង់ហោ ឯខ្លួនចូរឆ្លុ

កំលើកទ័ពចុះទៅខាងឆ្ងាយអាណាខែត្រខិសខាងត្បូង ។ ចំណែកឯអ្នកហ៊ីនឌីគោកន្ធ ឃើញបច្ចាលើកទ័ពត្រឡប់ទៅហើយ ក៏មានចិត្តអរណាស់ នាំគ្នាលើកទ័ព ត្រឡប់ទៅស្រុករៀងខ្លួន ។

ខណៈនោះ អ្នកចាំដែលទៅក្នុងស្រុកគីជីវ ក៏លបប្រឹក្សាគ្នាគួរតៅសុំទេវធីថា ខ្លួនយើងជាបុត្រចុងអ្នកសុងជាបុត្រតៅ ហើយគេតតីតរំយោគុចផង នាំគ្នាយកក៏ទៅក្នុងសេចក្តី ខ្លាំងគេជាងយើងនាំគ្នាអស់ ដែលមកដណ្តើមធ្វើធំ ក្នុងស្រុកគីជីវនេះ យើងមិនយល់ព្រមផងទេ អ្នកទាំងពីរនឹងយល់យើញប្រការម្តេច ? គួតារ៉ូយថា លោកចូរប្រុងប្រៀបសេនាទាហានចេញទៅនៅត្រស្រុកចុះ ហើយឲ្យទាហានក្លួនបង្កប់សងខាងឆ្ងាយទុកឲ្យត្រឹម រួចឲ្យបួលរាប្រាប់អ្នកសុង ខ្ញុំនឹងមានយថា ខ្លួនលោកនឹងរៀបលើកទ្រុប៉ាលទៅខែត្រកៀរហើយ សូមអញ្ជើញអ្នកសុង ខ្ញុំនឹងមានយ ទៅស៊ុំលៀងជាសេចក្តីមេត្រីតប់អាន បើតាលណាអ្នកសុងខ្ញុំនឹងមានយ ទៅដល់កន្លែងនោះហើយ ឲ្យទាហានដែលក្លួនបង្កប់នោះចេញឲ្យត្រឹមគ្នាមកចាប់អ្នកសុង ខ្ញុំនឹងមានយសម្លាប់ចេញ ស្រុកគីជីវក៏ខ្ញុំនឹងបានដល់លោក ។ អ្នកចាំយល់យើញដូច្នេះ ក៏នាំទាហានចេញមកពីផ្លែងក្រៅស្រុក ហើយរៀបចំទុកតាមវិធីទុក ដែលគិតធ្វើនោះតាមពាក្យគួរតៅពន្យល់ ។ ខណ្ឌលអង្គស៊ីវប្រឹក្សាអ្នកចាំ មកពីស្រុកសៀងណីវចូលមកដល់ អ្នកចាំក៏សួរសុខទុក្ខដោយសេចក្តីក្រែកអរ ហើយក៏ពណ៌នារឿងដែលគិតធ្វើអន្តរាយអ្នកសុងនោះ ឲ្យគង្គស៊ីវស្តាប់ ។ អង្គស៊ីវធ្វើឧ ថាធម្មតាបងប្អូនទំនឹងគ្នានោះ លោកឧបមាបីដូចដើងដៃខាងស្តាំខាងឆ្វេង ហេតុ

ម្តេច លោកមកតិតស្រាល? គាត់ដែរដើរបស់ខ្លួនចោលដូច្នេះ មិនគួរសោះ
គាល់បើលោកធ្វើប្រទូស្តកយគាត់បង់ប្អូនចេញដូច្នេះ ខ្ញុំបាទក៏មិនមាន
សេចក្តីសប្បាយទេ ដែលលោកនឹងយកអ្នកដទៃ មកធ្វើជាបង់ប្អូនវិញនោះ
តើនឹងមានចិត្តឈឺឆ្អាលប្រាកដនឹងលោក ឬ? លោកមិនគួរនឹងស្តាប់ពាក្យ
មនុស្សទាំញុះញង់សោះ ព្រោះមនុស្សគេស់នោះ សុទ្ធតែតិតខ្ជិ នឹងយល់
បំណាច់មាត់តែ ១ ស្រេចកនោះ មកជាទីសង្ឃឹមវែងឆ្ងាយពុំបាន ។
អ្នងចាំបានស្តាប់ហើយ ក៏ខឹងខ្លាំងណាស់ បណ្តេញអង្គស៊ុវ ឲ្យដើរចេញ
ពីទីនោះ ហើយបំរើចូលទៅអញ្ជើញអ្នងសុង នឹងសឹមដោយមកបរិភោគ
អាហារតាមពាក្យគួរតែ ។ អ្នកបំរើក៏ចូលទៅជំរាបអញ្ជើញអ្នងសុង នឹងសឹម
ដោយតាមបង្គាប់ថា អ្នងចាំឲ្យអញ្ជើញលោកទៅស៊ីលៀង ។ អ្នងសុង
ក៏ប្រឹក្សានឹងសឹមដោយថា ដែលអ្នងចាំឲ្យអ្នកមកហៅយើងចេញទៅ
បរិភោគអាហារនោះ តើអ្នកយល់ឃើញប្រការម្តេច? សឹមដោយធ្វើយថា
ដែលអ្នងចាំឲ្យមកហៅយើងទៅនោះ ខ្ញុំបាទយល់ថា ជាគំនិតរបស់គួរតែ
ធ្វើតស់ៗជាយទេ បើយើងនឹងចេញទៅវេលានេះ មុខជាកើតអន្តរាយជា
ប្រាកដ តែបើយើងនឹងបង្អង់ទៅសៀមវិញ អ្នងចាំនឹងគួរតែមុខជាមានគំនិត
គិតថែមទៀតឯង សូមឲ្យលោកលើកទ័ពចេញទៅចាប់អ្នងចាំនឹងគួរតែ
សម្លាប់ចេញវេលានេះ ទើបស្រុកយើងអស់ចំរូងចំពសតទៅ ។ អ្នងសុង
យល់ឃើញត្រូវ ក៏ប្រមូលទាហានបាន ៩ ម៉ឺន ចេញទៅក្រៅស្រុក ។
ឯចំណែកអ្នងចាំ ឃើញអ្នងសុងលើកទ័ពចេញមកជាក្បួនតឹជ័យ

សង្ក្រាមដូច្នោះ យល់ថាអ្នកសុងដឹងដល់ទុក្ខយនៃខ្លួន អ្នកចាំកំពាក់ក្រោះ
ឡើងរេះ កាន់ខ្លួនទាំងហានចេញទៅ ហើយស្រែកហៅអ្នកសុងថា ឯង
ជាមនុស្សអកតញ្ញូឲ្យសណាស់ ហ៊ានយកថ្នាំពិសបន្ទុំឲ្យបិតាបង់កោត
ទាល់អនិច្ចកម្ម ហើយតាំងខ្លួនឡើងធ្វើជាធំ សម្រេចពាជការក្នុងនៃត្រតីដូ
ម្តេចក៏ឡើង ស្តាប់ចង្កាប់ឯងជាអ្នកទឹកដោះនៅមាត់ដូច្នេះ ជាគួរហើយឬ ?

អ្នកសុងឮហើយខឹងណាស់ បរេះដេញទាហានទៀបចូលតយុទ្ធនឹង
អ្នកបាំជាតទឹក អ្នកចាំគ្រាំកំឡាំងនឹងអ្នកសុង មិនជាន់កិបរេះទាំងហាន
ចាំនឹងតួនរត់ទៅ អ្នកសុងក៏ដេញតាប់សម្លាប់ទាហានអ្នកចាំស្លាប់អស់ជា
ច្រើន លុះនឹងតាមអ្នកចាំទៅទៀតឃើញថា មិនទាន់ហើយក៏លើកទ័ព
ត្រឡប់ចូលមកស្រុកវិញ ។ អ្នកចាំដឹងថាអ្នកសុងលើកទ័ពទៅវិញ ក៏ឈប់
ទ័ពទៅទីភ្នាក់ ហើយតិតនឹងលើកទ័ពទៅសងសឹកអ្នកសុង ទើបឲ្យ
ធ្វើមេផកលើកទាហានជាកងមុខ (ទ័ពស្រួច) ខ្លួនឯងនោះជាកងហួង
(ទ័ពធំ) ធ្វើត្រឡប់ទៅនឹងចាប់យកខ្លួនអ្នកសុង ។

អ្នកសុងដឹងសេចក្តីដូច្នោះ ក៏ប្រមូលទាហានលើកមកច្បាំងនឹងអ្នក
ចាំវិញ ធ្វើមេផកកិបរេះចេញទៅមុខទាហាន ហើយស្រែកហៅអ្នក
សុងជាពាក្យរេវរ្រេគោះផ្សេង។ អ្នកសុងឮដូច្នោះ ក៏ខឹងណាស់ប
រេះចេញទៅប្រយុទ្ធគ្នានឹងធ្វើមេផក លឺកងវ៉ែកហាមឃាត់អ្នកសុង
ថា ដែលលោកនឹងចេញទៅតទឹងនឹងធ្វើមេផកនោះមិនគួរទេ ពុកឲ្យខ្ញុំបា
ទំាងស្មរយកអាសា ចេញទៅដោយខ្លួនឯង ហើយលឺកងបរេះចេញទៅ

ប្រយុទ្ធគ្នាទីធ្លាមេផកបាន ៩ ក្បួន លីកធ្វើយកខ្លួនចាត់ត្រូវនឿមេផក ធ្លាក់ពីលើសេះស្លាប់ អួនចាំយើញខាហានខ្លួនឯឡដីតែដូច្នោះ ក៏បរសេះ ទាំខាហានវាត់ទៅចូលស្រុកពេងឆ្នួនគួនជាស្រុកចំណុះ ក៏តាំងឲ្យសេនា ខាហានឡើងត្រួតត្រាក្សាសើនបន្ទាយជាមាំមួន ។

ចំណែកអួនសុនក៏លើកខាហានដេញតាមទៅយើញដូច្នោះ ហើយ តាំងឲ្យពាយកងទ័ពឡោមព័ទ្ធជុំវិញស្រុកនោះ គ្រប់គយចាំង ៣ ទិស ។ គួតៅក៏និយាយទីធ្វើអួនថាំថា ដែលយើងទីធ្វើតាំងទ័ពនៅក្នុងស្រុកពេងឆ្នួន គួននេះតទៅមិនបានទេ ព្រោះស្រុកនេះមិនសូវមានស្បៀងអាហារបរិបូណ៌ ចាំងខាហានអួនសុន កំភ្លៀវក្លាមានចិត្តកំរើក សូមឲ្យលោកមានសំបុត្រ ទៅដល់ចូធួ សុំចុះចូល ឲ្យចូធួលើកទ័ពមកវាយយកស្រុកតីដីវ៉ា ការ ណាបើចូធួលើកមក អួនសុនក៏ទីធ្វើលើកទ័ពទៅតទល់ទីធ្វើចូធួខាងណោះ សឹមយើងលើកចេញទៅវាយខ្ទប់ពីក្រោយ មុខជាអួនសុនទីធ្វើថ្លស់ការ ជាប្រាកដ ឯចូធួដែលលើកទ័ពមកនោះ ជាផ្លូវឆ្ងាយជាច់ស្រយាលមិនមាន ស្បៀងអាហារ បើសិនណាជាយើងទីធ្វើរះគិត ត្រឡប់ធ្វើសង្គ្រាមទីធ្វើចូធួ ក៏ទីធ្វើមានជ័យជំនះ ដោយងាយ ដែលខ្ញុំបានជំរាបនេះយើញថា បានការ ចាំងសងខាង ។ អួនចាំយល់យើញត្រូវ ទើបប្រឹក្សាថា អ្នកបានយើញ នរណាមានគំនិតគិតគ្រាន់បើ ទីធ្វើប្រើឲ្យកាន់សំបុត្រទៅឲ្យចូធួ ។ គួតៅ ទើបថា ស៊ីនក៏ជាទៅហ្វាយស្រុកពេងឆ្នួនគួន ជាមនុស្សមានស្មារតី ប្រាជ្ញា ហើយត្រូវជាប្អូនស៊ីនបេងផង សូមលោកចាត់ប្រើឲ្យកាន់សំ បុត្រទៅចុះ មុខជាបេះនិយាយឲ្យចូធួលើកទ័ពមកបាន ។

អ្នខ្ញុំធ្វើសំបុត្រ សេចក្តីថា ខ្ញុំបានអ្នខ្ញុំសុំចំណុះចុះបួលតំនាប់មកមហាឧបរាជ សូមឲ្យមហាឧបរាជ លើកកងទ័ពមកជួយកំចាត់អ្នខ្ញុំសុង ដែលប្រព្រឹត្តទុច្ចរិតចេញ ខ្ញុំបានទឹងរ៉ាយរ៉ាងទ័ពសន្ធប់ខ្ចប់ពីមុខ បើសម្រេចការហើយ ខ្ញុំបានតំសូមបួលធ្វើការស្មោះត្រង់ នឹងលោកតទៅ លុះតែងស្រេចហើយ តំប្រគល់ឲ្យស៊ុនត្រាន់ចេញទៅ ហើយផ្តាំថា អ្នកបួរ រិះគិតរកគំនិតនិយាយ ឲ្យបួលើកទ័ពមកជួយកុំឲ្យខាន រួចប្រគល់ថាហាន ៣ ពាន់ ឲ្យស៊ុនត្រាំទៅចំលាយទ័ពអ្នខ្ញុំសុង ដើម្បីនឹងចេញទៅឲ្យបាន។ ស៊ុនត្រាំទទួលសំបុត្រហើយ កំលាទៅនាំថាហានតាំង ៣ ពាន់ ការចំលាយចេញទៅជុតកងទ័ពអ្នខ្ញុំសុង ស៊ុនត្រាំក៏ចំបរសេះទៅរកបួធូ ខាងទិសឯក្បួនតែម្នាក់ឯង ។

ឯបួធូបានលើកទ័ពទៅដល់ស្រុកសេបើងតួន ដែនស្រុកកេងដ៏វែងប៉ៀវជិតរហើយក៏កែណ្ដាថាហានប្រគល់ឲ្យទៅពីលើគេចេញទៅតាំងបន្ទាំនឹងកងទ័ពបួធូ ។ ខណៈនោះ ទទួលស៊ុនត្រាទៅដល់កងទ័ពបួធូ ថាហានបួធូ ក៏នាំខ្លួនទៅជួបនឹងបួធូ។ ទទួលយកសំបុត្រពីស៊ុនត្រាមកមើលនឹងសេចក្តីហើយ ក៏ប្រឹក្សានឹងសេនាទាំងពួងថា អ្នខ្ញុំមានសំបុត្រមកអង្វរករ សូមចំណុះចុះបួលយើង តើអ្នកទាំងពួងនឹងយល់យើញប្រការម្តេច? ធ្វើយ៉ាងដំរាបថា គ្រានេះ យើញថា អ្នខ្ញុំនឹងបាត់ជ័យចាញ់អ្នខ្ញុំសុងហើយ ថ្វាន់ជាមានសំបុត្រមកសុំចំណុះចុះបួលលោក ប្រាថ្នានឹងឲ្យលោកលើកទ័ព ទៅជួយកំចាត់អ្នខ្ញុំសុងចេញ តែលោកកុំអាលធ្វើតុកចិត្តឲ្យ ។

លើយើងនឹងមាន់ថនធ្វើយថា ពីថ្ងៃមុន លោកលើកកងទ័ពមកច្រាំ
ទឹងកំចាត់ខ្មែរប៉ៃវ ដែលលោកទឹងត្រឡប់ទៅផ្ទៀកាន់យកសំដីខាងអ្នក
ចាំ ហើយទឹងលើកទ័ពត្រឡប់ទៅវិញនោះ មិនគួរសោះ ។ ស៊ុនហ៊ុវ
ធ្វើយថា ដែលអ្នកទាំង ៣ នាក់និយាយមកនោះ ខ្ញុំមិនយល់ត្រមផងទេ
ព្រោះដែនដីសព្វថ្ងៃនេះ កំពុងតែតេតចលាចល អាណាខែត្រទាំងពួងសុទ្ធ
តែប្រកាន់ មិនចង់ចុះចូលទៅខាងណា ដូចខ្មែរប៉ៃវដែលបានជាធំ
កងខែត្រកេងដីវនោះ មានស្រុកតូចជាចំណុះច្រើនដុចន់កីមែន តែថា
ខ្មែរប៉ៃវនោះ មានដម្រះច្រាំងតិចណាស់ មិនបានគិតទ្យអាណាខែត្រ
របស់ខ្លួន រែកធំលាយចេញទៅខ្មែត ឯអ្នកសៀរែកីខ្សែដីវែតទៅហើយ
តែទៅមានភូនចៅផៅសន្តានជាច្រើន ស្រុកចំណុះធំ ។ ក៏មានដល់ ៤
មណ្ឌល ស្រុកចំណុះតូច ។ ក៏ច្រើនដុចន់ ទាំងពលសេនាគាហានក៏
មានច្រើនពាប់រយម៉ឺនថ្មាយ បើភូនចៅផៅសន្តានអ្នកសៀវ ទៅជាប្រក្រតី
ទឹងគ្នា ក៏មិនមានអ្នកដណែទឹងទៅញ៉ាំញីបានឡើយ ឥឡូវ អ្នកចាំទឹងអ្នក
សុងតាស់ខែងគ្នា អ្នកចាំទ្យមកលន់តួគាស អង្វរលោកហើយ ទោះបី
ជាសេចក្តីកល់ទុកាយយ៉ាងណា ក៏ឃើញថាបានការខាងយើងហើយ សូម
ទ្យលោកលើកកងទ័ពទៅជួយអ្នកចាំចុះ ដើម្បីទឹងកំចាត់អ្នងសុនចេញ
រួចបីមយើងរែតិត កំចាត់អ្នកចាំខ្មែត ក៏សឹងបានដោយងាយ ។

(មានត)

រឿងមាឌដ៏ក

លោកវ៉ុលតែរនិពន្ធ

លោក រ៉ាយ-ប៊ុក រៀបរៀង

(តបប់)

តេមិនអាចណាត់បំបិទបំបាំង ខ្លួវសេចក្តីអនុគ្រោះនៃព្រះមហាក្សត្រចំពោះលោកហ្សូនិតបានឡើយ ។ ព្រោះថា បណ្តាមហាពជនៅទ្វីបអាស៊ី ព្រះចុងណាបុស្សន៍ ព្រះមហាក្សត្រ គោរសេរនីរ៉ប ជាព្រះមហាក្សត្រមានព្រះពជវិយោល្អជាងគេ បើគាលណាទ្រង់ធ្វើព្រះពជសន្ទនាការនឹងបុគ្គលណា ; បុគ្គលនោះ មិនលែងមានចិត្តភក្តីចំពោះព្រះអង្គឡើយ ។

ព្រះមហាក្សត្រអង្គនេះ ទ្រង់មានតែពួកសេវកាមាត្យ តែងតែចូលគាល់ហ្វាំ ដើម្បីសរសើរព្រះអង្គ ព្រមទាំងរិះកន្ទូរមធ្យោបាយគ្រប់យ៉ាងដើម្បីទំនុកបម្រុងព្រះអង្គ លួចព្រះពជខ្មាត្យ ។ ទ្រង់មានព្រះពជបដិគ្គាហកមួយ តែងតែប្រព្រឹត្តបទខុសច្បាប់តែនេះ។ ទ្រង់បានផ្លាស់ប្តូរព្រះពជបដិគ្គាហកជាមេឃ្មាំងព្រះពជខ្មាត្យនេះ ជាច្រើនលើកច្រើនសារតែទ្រង់មិនអាចប្រែតែខ្លួនម្ចាស់គាក្រក់ ដែលត្រូវបែងព្រះពជខ្មាត្យ ជាតិរវង្ស, ផ្នែកតិចជាងគេ ត្រូវបានទៅព្រះមហាក្សត្រ, ផ្នែកច្រើនជាងគេ ត្រូវបានទៅមេឃ្មាំងព្រះពជខ្មាត្យ ។ មានមួយថ្ងៃ; ព្រះចុងណាបុស្សន៍ ទ្រង់បានប្រឹក្សាជាមួយនឹងលោកហ្សូនិត អំពីរឿងនេះថា លោកដែលចេះដឹងខ្លួវវិជ្ជាគ្រប់ថែបគ្រប់យ៉ាង តើលោកអាចរិះកន្ទូរមធ្យោបាយអ្វីមួយ ដើម្បីទំនុកបម្រុងមេឃ្មាំងព្រះពជខ្មាត្យណាមួយ កុំឲ្យវាលួចព្រះពជខ្មាត្យបានឬទេ ។

លោកហ្សាឯតក៏ក្រាបបង្គំទូលព្រះមហាក្សត្រថា:

សូមទ្រង់ព្រះមេត្តាប្រោស ការនេះដោយណាស់, បុគ្គលណាដែលសុំធ្វើជាមេឃ្មាំងព្រះរាជទ្រព្យ, សូមព្រះអង្គទ្រង់ត្រាស់បង្គាប់ ឲ្យពិភាក្សាអស់គ្នា ។ អ្នកណាដែលនឹងពិស្រាលសមមេឃ្មាំងនេះ អ្នកនោះពិតជាបុរសសុចរិតពិតត្រង់; សូមទ្រង់ជ្រាបក្រាមបង្គំធួលព្រះបាទ ។ ព្រះមហាក្សត្រទ្រង់មានព្រះបន្ទូលតបទៅនឹងលោកហ្សាឯតថា : អ្នកឯងពោលពាក្យនេះ គឺពាក្យឡកចំអក, ហើយមនុស្សជាយដែលស្នងរកមេឃ្មាំងសុចរិតបែបនេះ ជាមនុស្សជាយ គួរឲ្យខ្ញុំអស់សំណើចពន់ពេក ។ លោកឃើញថា អ្នកណាដែលជាអ្នកដឹងនេះ, អ្នកនោះ ជាមេឃ្មាំងសុចរិតហើយប៉ុន្តែប្រសប់ជាងនេះ ។

លោកហ្សាឯតក៏ក្រាបបង្គំទូលតបព្រះមហាក្សត្រវិញថា "ទូលព្រះបង្គំជាខ្ញុំ មិនបានយល់ថា ជាមេឃ្មាំងប៉ុន្តែប្រសប់ជាងនេះទេ, ទូលព្រះបង្គំជាខ្ញុំគ្រាន់តែថាជាមេឃ្មាំងសុចរិតជាងនេះ" ។

លោកហ្សាឯត ក្រាបបង្គំទូលព្រះមហាក្សត្រណាបុស្សនឹ ដោយពាក្យប្រៀបធៀបជាអនេកបរិយាយ តាល់តែទ្រង់ជឿជាក់ថា លោកហ្សាឯតមានអាទុកាតអាថ៌កំបាំងអ្វីប្លែក ដែលជាសម្ភារៈសម្រាប់សំគាល់ពួកមេឃ្មាំង ។

លោកហ្សាឯត ក្រាបបង្គំទូលតបព្រះមហាក្សត្រវិញថា " ទូលព្រះបង្គំជាខ្ញុំ មិនចូលចិត្តភាន់មន្តអាគមប្លែកអ្វីប្លែកឥស្សរៈនោះទេមនុស្សមានឫទ្ធានុភាពនឹងសៀវភៅ ដែលមានការអាថ៌កំបាំង, ទូលព្រះបង្គំជាខ្ញុំស្គាល់ជា

ឃាំនវត្រលែង ។ បើព្រះអង្គទ្រង់ព្រះពរដាទុញ្ញាត ឲ្យខ្ញុំលព្រះបង្គំជាខ្ញុំ ពិសោធមើល ក្នុងរឿងនេះ, ព្រះអង្គទ្រង់ជ្រាបជាអស់មានថា តាវ អាថ៌កំបាំង ជាវត្ថុសាមញ្ញ ហើយមានសភាពងាយបំផុត ។

ព្រះបាទណាបុស្សធ៌ទ្រង់មានពាក្យប្រើនឲ្យលឿនឆ្លើយថា តាវអាថ៌កំ បាំងនោះជារបស់ងាយបំផុត, ទ្រង់ក៏មានព្រះពាក្យបន្ទូលតបទៅលោក ហ្សាំនិតវិញថា : "ចូរលោកធ្វើតាមចិត្តចុះ" ។

លោកហ្សាំនិត ក្រោយដែលបានទទួលព្រះបន្ទូលព្រះមកពន្លឿន តំបាត់ ក្នុងថ្ងៃនោះ ឲ្យធ្វើព្រះពាក្យចុងក្រោយ ក្នុងព្រះនាមព្រះមហាក្សត្រ ថា ឈ្មោះណាបង់ធ្វើជាមេឃ្មាំនព្រះពាក្យ នៃព្រះបាទណាបុស្សធ៌ ជាព្រះពាក្យបុត្រព្រះបាទណុស្សាណាប . ត្រូវស្នើកងកំភេរអាវ៉ែត្រ ស្រាល ។ចូលមកមើលថ្ងៃទីមួយ នៃព្រះចន្ទក្រតើ, ឯមហាប្រាសាទព្រះអង្គ។

ពួកម្នាក់ចំនួន ៦៤ នាក់ក៏ចូលទៅឯមហាប្រាសាទ តាមកំណត់ ពេល ។ គេបានចាត់ឲ្យពួក ភូមិមកគាន់ព្រះបន្ទប់នោះដែលជាកេងចាំ ។ តែព្រះពាក្យបន្ទប់នោះ មានទ្វារបិទជិត, ដើម្បីនឹងទៅតាមព្រះបន្ទប់នោះ ត្រូវ ដើរកាត់ទ្វារយ៉ាមួយធំធំជិត ។ មានអាជ្ញាសាលាម្នាក់ ខ្លួលការៈទាន់ បេក្ខជនចាំនឹងឡាយ ទៅកាន់យ៉ាំនោះ ហើយ គេចុកឲ្យទៅទីនោះមួយស្រ បក់ ទើបបញ្ជូនឲ្យទៅចូលព្រះពាក្យបន្ទប់ កេងកំជាអស់មាន ។

ព្រះមហាក្សត្រ ទ្រង់ជាមួយតំណាក្សាជាមួយលោកហ្សាំនិត, បានយក ព្រះពាក្យទ្រង់មកគាន់ចុក នៅយ៉ាំនោះជាច្រើន ។

កាលពួកបេក្ខជនចាំនឹងឡាយ មកដល់ព្រះពាក្យបន្ទប់កេងកំនោះហើយ

ព្រះមហាក្សត្រទ្រង់គ្រាសបង្គាប់ឲ្យភ្លក់នោះពំ ។ ពួកអ្នកពិតពិតធ្ងន់ដើនដៃ ហើយមិនសមរម្យផង, ពួកនេះមានក្បាលតូច, ត្រគាកធ្ងន់, ដៃជាប់ទៅនឹងឆ្អឹងជំនីរ . . . . . ។

លោកហ្សាឌ្ឌិត ពោលពាក្យឡើង ។ ថា ឱ៎ហ្ន៎! សុទ្ធតែពួកគាបោរពោលសាមន្យ ។

បណ្តាពួកអ្នកពិការនោះ មានអ្នកពិម្នាក់ ពិទៅតាមបង្គាក់ភ្លើងសម រម្យ ឈានដើរហ៊ាស ក្បាលងើយមើលទៅលើ, កំភួនដើងត្រង់ស្រួល, ដៃលាតសន្ធឹងសម, ជង្គង់ត្រង់ . . . . . ។

លោកហ្សាឌ្ឌិត ក៏ពោលថា "ឱ៎ហ្ន៎! មេឃ្លាំងសុចរិត, ។ ព្រះមហាក្សត្រទ្រង់តើនឡើង ស្តេចទៅនុបអ្នកដែលពិស្រាលសម រម្យនោះ, ហើយប្រកាសតែងតាំងអ្នកនោះ ជាមេឃ្លាំងព្រះពជ្រឲ្យ ។ ទ្រង់គ្រាសបង្គាប់ឲ្យគេធ្វើខណ្ឌកម្ម ចំពោះពួកអ្នកពិការ ៦៣ នាក់ ព្រោះពួកនេះ គាលអាជ្ញាសាលាខាមកគាន់យ៉ាងនោះ, ពាស្រក់ព្រះពជ្រឲ្យ ជាក់ហោប៉ៅគាវៅ ធ្ងន់ដើរស្ទើរមិនរួច ។ ព្រះបមកតទ្រង់ព្រះក្រោធ ខ្លាំងថា ចំពោះធម្មជាតិមនុស្ស, បណ្តាពួកពិការ ៦៤ នាក់, មានលោរពោលទុច្ចរិត ដល់ទៅ ៦៣ នាក់, ហើយព្រះអង្គទ្រង់បានសមន្តនាមយ៉ាងនោះថាជាយ៉ាងអកុសល ។

បើនៅប្រទេសយើង, គេយកអ្នកពិការ ៦៣ នាក់ទៅធ្វើខណ្ឌកម្មជាយ៉ាងទុក្ខិដ្ឋ (យកឈើស្រួចចាក់ពោះ ឲ្យឆ្កាយភោះវៀន); នៅប្រទេសឯទៀត គេអាចឲ្យតុលាការសម្រេចសងព្រះពជ្រឲ្យ ដែលលួចនោះ

ឲ្យបានចំនួនលើសបីដងទៀតទៀត , ហើយព្រះពាជទ្រព្យទាំងនោះមិនបាច់ចូលទៅកន្លែងព្រះឃ្លាំងទេ, គឺចូលទៅកន្លែងហោរច្បាំចាក្រម; នៅព្រះពាជអាណាចក្រឯទៀត, ពួកទាំង ៦៣ នាក់ពួតដៃគ្នាធ្វើពាក្យតវ៉ាទៅជាច្រើនខ្នុន, ហើយត្រូវអ្នកកំម្នាក់ដែលកំសាមមកជាងគេ ទៅជាមានទោសទៅវិញ ។

តែនៅគោះសើរើឥឡូវ, ពួកអ្នកកំទាំង ៦៣ នាក់ត្រូវពិន័យជាច្រើនក់បន្តិចបន្តួចគ្រាន់តែឲ្យបានកើន ចំនួនព្រះពាជទ្រព្យទៅកន្លែងព្រះឃ្លាំង ព្រោះព្រះចាខណាបុស្សដ៏ជាមហាសប្បុរស . . . . . ។

លំដាប់តទៅពីនេះ, មិនឃើញមានរឿងរ៉ាវអ្វីទៀត ។ ចំពោះលោកហ្សាដិតនេះ, ខ្ញុំបានស្រាវជ្រាវរកឯកសារសព្វគ្រប់ហើយគ្មាន, សូមបញ្ចប់រឿងលោកហ្សាដិតត្រឹមប៉ុណ្ណេះ ។

កំណាត់នីមួយៗអំពីសហរដ្ឋអាមេរិក

ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះពោធិវ័ន្ស ហួត_តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងកំពង់ចាម

រៀបរៀងដោយ ជា.ទង់

សាស្ត្រាចារ្យទទួលការងារបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

(ត)

សហរដ្ឋអាមេរិកមានទំហំដែនដីចំនួន ៩.៨៧៧.១២៨ ម៉ាយល៍ ៤ ជ្រុង (ការ៉ែ) ។ ប្រទេសនេះ មានព្រំប្រទល់ខាងជើងនឹងប្រទេសកាណាដា, ខាងត្បូងទល់នឹងប្រទេសមិកស៊ិកូ ខាងកើតទល់នឹងមហាសមុទ្រប៉ាស៊ីហ្វិក, ខាងលិចទល់នឹងមហាសមុទ្រអត្លង់ទិក ។ នៅមានភូមិភាគ ៤ ក្នុងនោះទៀត ដែលមិនបានរាប់បញ្ចូលជារដ្ឋនៅឡើយ គឺកោះហាវ៉ៃអ៊ី នឹងអឡាស្កា ។ សហរដ្ឋអាមេរិក សព្វថ្ងៃមានប្រជាជនគិតអស់ ប្រមាណជា ១៦០ ទៅ ១៦៥ លាននាក់ ។

របៀបគ្រប់គ្រងប្រទេស ខ្ញុំពុំអាចដឹងបានដោយសព្វគ្រប់ទេ តែបានដឹងខ្លះ ។ ថា សហរដ្ឋអាមេរិក មិនមានព្រះមហាក្សត្រទេ. មានតែប្រធានាធិបតី ដែលហៅតាមសំដីគេថា President ១ រូប ដែលប្រជាពលរដ្ឋជ្រើសតាំងតាមស្មគ្រចិត្ត រើសយកតែមួយរូប ចេញពីរូបតំណាងគណបក្សពីរគឺគណៈបក្សសាធារណរដ្ឋ និងគណៈបក្សប្រជា-

ធំជាងគេបង្អស់ ក្នុងរយៈពេល ៤ ឆ្នាំម្តង ជាអ្នកអភិបាលរដ្ឋាភិបាលសហរដ្ឋអាមេរិក ។ លោកប្រធានាធិបតី នៃសហរដ្ឋ មានអនុប្រធានាធិបតីមួយរូប ជាភូ-ឈ្មួយ ហើយទើបមានលេខាធិការ (Secretary) ជាច្រើនរូបទៀត ធ្វើការជាមួយគ្នា; លេខាធិការមួយ ។ មានអនុលេខាធិការ (Assistant Secretary) ច្រើនរូបទៀតជាភូឈ្មួយជួយសម្រួលកិច្ចការត្រង់ប៉ង់, ហៅរួមទាំងប្រធានាធិបតីទើបអនុប្រធានាធិបតី, លេខាធិការ, អនុលេ-ខាធិការទាំងអស់ ថា រដ្ឋាភិបាលសហរដ្ឋ (United States Governe-ment) មានទីសំណាក់ការនៅវ៉ាស៊ីនតុនឌីស៊ី ដែលគេស្គាល់ថាជារាជ-ធានីនៃសហរដ្ឋ ។

ក្នុងសហរដ្ឋអាមេរិក មានប្រជាជនច្រើនជាតិ ច្រើនសាសន៍ លាយចំរុះគ្នា ខ្លះមានសញ្ជាតិដើមជា រុស្សី, ចាក់ង, អល្លឺម៉ង់, ជប៉ុន, ចិន, អេស្ប៉ាញ៉ុល អ្រហ្វិក ។ ល ។ រួមចូលជាតិជាអា-មេរិកាន់ ។ ខ្លះមានជាតិដើម ជាអាមេរិកាន់ស្រេចស្រាប់តែម្តង ។ បានឮថា ជនជាតិទាំងឡាយណាក៏ដោយ ឲ្យតែកើតក្នុងសហរដ្ឋ ទើបទៅជាពលរដ្ឋ អាមេរិកាន់ ក្នុងពេលដែលខ្លួនមានអាយុ ១៨ឆ្នាំ ។ ហេតុដូច្នេះ ជនជាតិនេះ មានពណ៌សម្បុរ សាច់ ឈាម ខ្លួនកុម មុខ មាត់ ប្លែក ។ គ្នា អាចកំណត់ សំគាល់បានថា គាត់ច្រើនជាតិ ច្រើនសាសន៍មែន ។ ប៉ុន្តែ បើពួកជា-ច្រើនជាតិ ច្រើនសាសន៍យ៉ាងនេះក៏ដោយ គេហៅជនជាតិនេះថាជាតិអា-មេរិកាន់ មាន ២ យ៉ាង គឺអាមេរិកាន់ ស ទើបអាមេរិកាន់ខ្មៅ ដែលគេ ហៅ នីគ្រោ Negro ។

ប្រជាជនអាមេរិកាន់ភាគអស់ ពាក់ព្រុសពាក់ស្រី សុទ្ធសឹងតែជាប្រជាជាតិមានសិទ្ធិ, សេរីភាពទំនើបសមត្ថភាពបរិបូណ៌ មានចំណេះវិជ្ជា ការរៀបជីងគ្រប់គ្រាន់ អាចប្រើប្រាស់នូវសិទ្ធិនីងសេរីភាព ដែលខ្លួនមាន ឲ្យបានម៉ត់ចត់ត្រឹមត្រូវ តាមក្របខ័ណ្ឌ ដែលមានគ្រោងកក្នុងច្បាប់ផ្សេង ។ នីងក្នុងរដ្ឋធម្មនុញ្ញរបស់ជាតិគេ ។ គេគោរពប្រតិបត្តិច្បាប់ណាស់ ច្បាប់ហាមមិនឲ្យធ្វើអ្វី គេមិនហ៊ានធ្វើបំពានច្បាប់ឡើយ គេធ្វើតែអំពើណាដែលច្បាប់អនុញ្ញាតឲ្យធ្វើ ។

សហរដ្ឋអាមេរិក គាំងតែពីដណ្តើមយកឥស្សរភាព នីងអធិបតេយ្យបានមកនៅក្នុងកណ្តាប់ដៃខ្លួនវិលាណា ប្រជាពលរដ្ឋគាំងសាសន៍ មានយោបល់ស្របគ្នា សាមគ្គីរួមកំឡាំងគ្នាជាប់ ទំនាក់ទំនងរក្សាឯកភាពរបស់ខ្លួន មិនឲ្យឆ្ងាត់ចេញក្នុងកណ្តាប់ដៃបរទេស ឬនដោយងាយឡើយ គឺដោយសារតែសេចក្តីព្រមព្រៀងគ្នា ស្តាប់ចង្អាប់គ្នា មានធន្ទុះស្របគ្នា នេះឯងហើយបានជាគេអាចកសាងប្រទេសជាតិគេឲ្យបានចំរើនរុងរឿងជាអារ្យប្រទេសមួយ ក្នុងលោកនេះ ។

ក្នុងដំណើរទេស្សនាសហរដ្ឋចំនួន ៦ ខែកន្លះ យើងបានសង្កេតឃើញខ្លះ នូវខ្សែសំខាន់ ។ ដែលប្រជាជនអាមេរិកាន់ប្រតិបត្តិ ដើម្បីសេចក្តីចំរើនប្រទេសជាតិ - គឺ

១ ប្រជាជនអាមេរិកាន់ មានសេចក្តីស្អប់ខ្ពើមសេចក្តីថោកទាបនីងភាពល្ងង់ខ្លៅ មិនចង់ឲ្យប្រទេសជាតិរបស់ខ្លួន ធ្លាក់ចេញក្នុងកណ្តាប់ដៃបរទេសណាមួយឡើយ, មានស្មារតីដឹងខ្លួន មានសាមគ្គីព្រមព្រៀងគ្នា

គោរពប្រតិបត្តិច្បាប់របស់រដ្ឋ របស់សហរដ្ឋពុំមានលក្ខឿន ដែលហាមចំ-
ពោះច្បាប់សូម្បីតែតិចតួចក៏ស្មានថា; ការគោរពប្រតិបត្តិ តាមច្បាប់របស់រដ្ឋនេះ
ហើយជាការណែនាំតែមួយគត់ដែលសមរម្យបំផុតរបស់គេ ។

២ - មន្ត្រីអ្នកគាន់អំណាចនិងប្រតិបត្តិតាមឡាយ ជាអ្នកចេះប្រើ
អំណាចរឿងខ្លួន គឺជាមានសមត្ថភាពគ្រប់គ្រាន់ ក្នុងមុខក្រសួងរបស់ខ្លួន
គេមិនលើកលែងគោលគ្រាប្រណាំងទេ តែកាលណាធ្វើខុសច្បាប់ ។ ច្បាប់
តែងឡាយបិតនៅតាន់លើ នៃប្រជាជនតាំងអស់ គោះនាម៉ឺនមុខមន្ត្រី
គោះអស្ចារ្យផង ។ តាហារណ៍ថា "ក្នុងទីក្រុង ច្បាប់ពដការក្រុង អនុ-
ញ្ញាតឲ្យបររថយន្ត ៤៥ គីឡូម៉ែត្រ ក្នុង ១ ម៉ោង, បើជនណាមួយបរហួស
ពីកំរិតល្បឿននេះ ប៉ូលិសបញ្ជាំឲ្យតាមគ្នាម សឿងឡូននៅលើ
ចិញ្ចើមថ្នល់ភ្លែត ចេញសំបុត្រលក់តិន័យ ១ រំពេច ឲ្យពន់ពិត" ។
ប៉ូលិសក្រុង មានអំណាចខ្លាំងជាងគេបំផុត អាចផ្តន្ទាទោសបាន
តាមនាទីរបស់ខ្លួន ។ ប្រជាជនខ្លួនឯង ខ្លាចប៉ូលិសរាល់រូបគ្រប់គ្នា ។
គេមិនមែនខ្លាចជនអ្នកធ្វើជាប៉ូលិសទេ គឺគេខ្លាចច្បាប់របស់ប៉ូលិស ។
មានរឿងមួយខ្លី តែបានសេចក្តីវែងជា "មានកាលយប់មួយនោះ ស្ងាត់
ណាស់ហើយ, ម៉ោងប៉ុន្មានទៀបភ្លឺ ។ តែនៅក្បែលមាន
ឡានមើតមួយ ។ ស្រាប់តែ, នៅត្រង់ផ្លូវបែកជាបួន គេជាក់ភ្លើងមីតាំងពី
សំពាប់ផ្លូវ មនុស្សដែលបើកឡានខ្លួន ប្រទេតឮប្រសាសន៍ព្រះពោធិវត្ត
របស់យើង លោកតែមិនតឹមតែប្តូចនូវសំណាក់ទៅ យើញឡានមួយ
ឈប់ស្ងៀមកណ្តាលផ្លូវ លោកឮសំឡេងថាគេមិនបានទៅ ? ក្នុង

ពេលនោះ លោកបានឃើញបងប្អូនគ្នា នូវក្តីនក្រហមផ្តៅ ដែលជាសញ្ញា
ថាឈប់កុំទៅ លោកជំនឹងថា ១! គេគោរពច្បាប់ក្តីនក្រហមរបស់គេ,
លោកមានពុទ្ធដីកាថា លោកបន្តការចាំលបមើល តើមានអ្នកណាមួយ
ហ៊ានបន្ថោនបំពានច្បាប់ក្តីនក្រហមទេ បើយប់ស្ងាត់ដូច្នេះ? គ្មានសោះ!
ព្រឹកឡើង លោកមានពុទ្ធដីកាប្រាប់ទៀតថា ហឺ! ស្រុកនេះ គេគោរព
ច្បាប់សំពប់ដួងមែនហើយ! សូម្បីក្នុងទីស្ងាត់កំគេមិនហ៊ានបំពានច្បាប់គេ
ដែរ! លោកនើបមានពុទ្ធដីកាពីរឿងនេះប្រាប់ទៀត ទឹងអ្នកឯទៀតជាច្រើនៗ
ទិញនេះមិនជាពិពេះទេ ព្រោះមិនសូវកំសត់ តែមានប្រយោជន៍គួរឲ្យ
សរសើរដល់ជនជាតិគេ បំពោះការគោរពច្បាប់នេះ ។

អំពីជីវភាពនៃប្រជាជន_ ជីវភាពនៃជនជាតិអាមេរិកាំងនិយាយ
ឡាយ សឹងដូចជាជីវភាពនៃជនជាតិឯទៀតដែរ ប៉ុន្តែជនជាតិនេះសម្បូរ
ដោយគ្រឿងសម្ភារៈ សំពប់សំលៀងជីវភាពរបស់គេ ឲ្យប្រព្រឹត្តទៅដោយ
ស្រួលជាងជនឯទៀតខ្លះ (ដោយស្មាន) ។ គ្រឿងចក្រ គ្រឿងម៉ាស៊ីន
គ្រឿងអគ្គិសនី ដែលស្រុកគេមានភាំងប៉ុន្មាន បានធ្វើឲ្យជីវភាពរបស់
ជនជាតិគេ សម្រើកស្រស់ញញឹមប្រឹមប្រើយ ។ អ្នកស្រុកអាមេរិកាំងមាន
របៀបញុះជីវិតប្លែកគ្នាដូច្នេះ :

១- ធ្វើស្រែចំការៈ ដាំពោត, សណ្តែក, ស្រូវ, ថ្នាំ ទឹងបន្លែ
បង្គាផ្សេងៗ ដូចជា ម៉ែងជ្ញាំ, ត្រសក់, ឪឡឹក ទឹងផ្លែឈើឯទៀត
ជាច្រើន;

២- ធ្វើការពាណិជ្ជកម្មក្រសួងផ្សេងៗ,

៣- ធ្វើរបាយការណ៍ជូនកម្ម,

៤- ធ្វើការស៊ើបអង្កេតផ្សេងៗ (កម្មករ) ។

អ្នកធ្វើស្រែចំការ មានគ្រឿងម៉ាស៊ីនច្រើនកាស់ ជាពិសេសឆ្នាំ សំពាធ់ សំណើការរបរវេតខ្លះ មិនបានខ្វៃឱកាសពេកទេ ។

រីឯអ្នកធ្វើការពាណិជ្ជការវិញ ប្រហែលជាមិនបានក្នុងបន្ទាន់ អំពីអ្នកពាណិជ្ជការនៃប្រទេសឯទៀតឡើយ ។

ចំណែកខាងរបាយការណ៍ជូនកម្ម ទំនាក់ទំនងសង្គមកម្ម ជារបៀបបំផុត ក្នុងសហវត្ស ។ មានសមាគម, ក្រុមហ៊ុនសហការដ៏ធ្ងន់ធ្ងរ ។ ច្រើនណាស់មិនឈ្មោះនឹងរាប់ ទាំងក្រុមក្រាន់ទៀត ខ្ញុំគ្រាន់តែលើកឧទាហរណ៍ខ្លះៗ ដូចជាសមាគមអាកាសយាន, អាយស៊ីឆយាន, ឡានដឹក រត់ឈ្លួសដឹកទំនិញក្នុងដំណើរតែក្នុងមួយ, ទៅក្នុងមួយ សមាគមចំណូលក្នុងប្រទេស ក្រៅប្រទេស, សមាគមពាណិជ្ជកម្ម ធ្វើគ្រឿងចក្រនឹងម៉ាស៊ីនផ្សេងៗ ខាងផ្នែកម៉ាក្ស មានសមាគមផ្សេងៗ បង្កើតវិញ្ញាបនប័ត្រ មហាវិទ្យាល័យការពេញប្រទេស ។ល។ ខាងផ្នែកសង្គមកិច្ច មានសមាគមបង្កើតមន្ទីរព្យាបាលរោគ ជាច្រើនកន្លែង ។

(មានត)

ព្រះរាជដំណើរសម្តេចព្រះឧបយុវរាជ
ទៅកាន់កោះសិរីលង្កា ក្នុងពិធីបុណ្យពុទ្ធជយន្តី

លោក ភ័ក្ត្រ.ប៊ុត រៀមរៀង

(តមក)

ថ្ងៃព្រហស្បតិ៍ទី ១៤ កុម្ភៈ

ម៉ោង ៨ សម្តេចព្រះឧបយុវរាជនៃកត្តមសីហនុ ទ្រង់ចាប់ផ្តើមព្រះរាជដំណើរ ចេញពីទីក្រុងកុលម្ប៊ូ ព្រមទាំងរដ្ឋមន្ត្រីក្រសួងវប្បធម៌, មន្ត្រីក្រុមពិធីការនៃព្រះរាជដំណើរ ដើម្បីទៅកាន់ទីក្រុងគ័ល្ល ។ នៅតាមផ្លូវនៃព្រះរាជដំណើរ ឆ្លងកាត់ដែនដីវេណមហាវិហារ ចានរៀបចំទទួលសម្តេចជាឧឡារិក សម្តេចចានទ្រង់ធ្វើព្រះរាជអំណោយចំនួន ១០០០ រូបិយវត្ថុនៅវត្តនេះ, ព្រះគុណាធិការអម្ចាស់ជីវិតលើត្បូងប្រទេសកម្ពុជា ទ្រង់ចានសព្វព្រះរាជហឫទ័យ ព្រះរាជទានព្រះរាជអំណោយ សាងសាលាបុណ្យមួយខ្នងដែរ ។ លុះដាច់តមក នៅវត្តវេណមហាវិហារ ក៏ចានទទួលសម្តេចជាអធិកវរធម ទាំងត្រហស្ថ ទាំងបព្វជិត ពាក់ពាន់នាក់ ។ ក្នុងពេលនោះ សម្តេចទ្រង់ចានទទួលព្រះរាជកិត្តិយស ស្តេចយាងទៅបញ្ចុះបឋមសិលាឫស្សី នៅសាលាមួយថ្មី ហើយទ្រង់ចានព្រះរាជទានទ្វៀនព្រះអំណោយ ១០០០ រូបិយ ចំពោះវត្តវេណមហាវិហារ ។

លុះដល់ម៉ោង ១១ ទឹង ១៧ នាទី, សម្តេចចានយាងទៅដល់ទីក្រុងគ័ល្ល ។ លោកបេះហ្វាយក្រុងនិងលោករដ្ឋមន្ត្រី ក្រសួងសិក្សាធិការជាប្រតិភូនៃរដ្ឋាភិបាលស៊ីលង្កា នៅរង់ចំទទួលសម្តេចដោយសេចក្តីគោរព ។

លំដាប់តមក, មានការរៀបរាប់ពីការទូលអនុមោទនាដល់ការ ចំពោះ
សម្តេច នៅសណ្ឋាគារក្រុង ជាព្រះពុទ្ធសាសនូបត្ថម្ភក ។

ថ្ងៃរសៀល, សម្តេចទ្រង់យាងទៅបញ្ចុះបឋមសិលាចូលក្ស មន្ទីរ
សំណាក់ការនៃសមាគមយុវពុទ្ធសាសនិក ហើយទ្រង់ប្រទានព្រះពុទ្ធ
ទូរព្រះអំណោយ ១០០០ រូបិយវត្ថុ ចំពោះសមាគមនេះ ។

រួចប្រធានក្រុមប្រឹក្សាក្រុងឥន្ទ្រ នៃខែត្រទាំងពីរក្បាលប្រទេសសិរីលង្កា
បានថ្វាយសន្តិថាមួយ ទទួលសេចក្តីអំណរ ចំពោះសម្តេចព្រះទេយ្យវង្ស ។
ទ្រង់ប្រទានថ្លែងព្រះសន្តិថាតបទៅវិញថា:

"ព្រះធម្មនៃព្រះបរមសម្មុទ្ធជាម្ចាស់ ដែលព្រះអង្គទេសនាប្រៀប
ហើយដែលយើងប្រព្រឹត្តប្រតិបត្តិតាម ដើម្បីនឹងបំបាត់ បន្ថយនូវ
សេចក្តីទុក្ខលំបាកគ្រប់យ៉ាង នៃពិភពលោកនិងសម័យបច្ចុប្បន្ន . . ។

ថា:

"ព្រះពុទ្ធសាសនាបានធ្វើ ឲ្យស្ថានភាពនយោបាយកម្ពុជរដ្ឋ ឲ្យតាន់
តែមានទ្រឹង្គ្រាយជាក់ច្បាស់ឡើង . . . . . ។

ថា:

ស្ថានភាពនេះ គឺ អត្ថប្រតិភាព ពិតប្រាកដ រវាងភ្លុកទាំងពីរក្រុម
ដែលធ្វើឲ្យពិភពលោកបែកចាក់គ្នា គឺបិតនៅជាកណ្តាល អាចជួល
ទៅប្រាស្រ័យ ទំនាក់ទំនងពីរក្រុមបាន ដូចមានពាក្យ ។ ពោលយ៉ាង
ដូច្នេះ គឺខ្ញុំមិនមែនថាបិតនៅកណ្តាលទេ , ពោះគឺបង្កើតក្រុមមួយជាថ្មី
មានគំនិតអត្ថប្រស្រ័យ ផ្សះផ្សាទំនាក់ទំនងនោះឡើយ, ហើយ

ខ្ញុំគិតថា ប្រទេសសិរីលង្កា អាចនឹងមានយោបល់ដូចគ្នា នឹងប្រទេសកម្ពុជា ចំពោះបញ្ហានោះ . . . . . ។

- ថា "ខ្ញុំសូមបញ្ជាក់ថា ព្រះពុទ្ធសាសនា ជាទស្សនៈមួយដ៏ប្រសើរសម្រាប់តែនូវបញ្ហាសង្គម គឺនិយម នឹងនយោបាយ ឲ្យកាន់តែចំរើនឡើង បញ្ហាដែលទាក់ទងនឹងមនុស្សជាតិឲ្យ ឲ្យផ្តិតជាប់រហូតមកដល់សម័យបច្ចុប្បន្ន" ។

លំដាប់តមក, លោកសម-ញាណ អធិបតីពុទ្ធិកសមាគមកម្ពុជវដ្ត អនុប្រធាន ក្រុមប្រឹក្សាព្រះពុទ្ធសាសនាបច្រប្រទេសកម្ពុជា បានថ្លែងសុន្ទរកថាមួយដែរ ។

រួច, សម្តេចព្រមទាំងព្រះពុទ្ធបរិវារ ទ្រង់ស្តេចយាងទៅគោរពព្រះអដ្ឋិព្រះអរហន្តមោគ្គលិបុត្តតិស្សត្ថេរ ។ លុះដល់ម៉ោង ២១ សម្តេចទ្រង់យាងវិលត្រឡប់មកកាន់ទីក្រុងកុលម្ប៊ូវិញ ។

ថ្ងៃទី ១៥ កុម្ភៈ

សម្តេចទ្រង់បានស្តេចយាងទៅធ្វើព្រះពុទ្ធប្រាស្រ័យ ដោយមេត្រីភាព ចំពោះលោក ស៊ែរ-ហ្សូន-កូតឺរ៉ាំឡ អតីតរដ្ឋមន្ត្រីទីមួយ នៃប្រទេសសិរីលង្កាព្រមទាំងលោកសាន-យុន រដ្ឋមន្ត្រីទីមួយប្រទេសកម្ពុជា និងលោកសឺន-សាន ។

លំដាប់តមក ទ្រង់បានស្តេចយាងទៅកាន់គេហដ្ឋាន នៃលោកបន្ទូរនអ៊ីកេ រដ្ឋមន្ត្រីទីមួយសម័យបច្ចុប្បន្ន ។

ពេលរសៀល សម្តេចទ្រង់យាងទៅធ្វើព្រះពុទ្ធទស្សនាការ នៅ

មហាវិហារខុបខុត្តរមាយោនឹងសាលារៀនខាងខ្មែរនេះ ហើយព្រះតាន
ព្រះអំណោយ ១០០០ រូប៊ីយ ចំពោះវត្តនេះនឹង ៣០០ រូប៊ីយ
ចំពោះភិក្ខុខ្មែរមួយរូប ដែលជាសមណទិស្សិតនៅសាលានេះ ។

សំដាប់តមក, មានពិធីរៀបខួលសម្ពះដ៏ធ្លាក់. នៅសណ្ឋាគារ
ក្រុងកុលម្ប, ដោយក្រុមប្រឹក្សាក្រុង ជាអ្នកចាត់ចែង ។ ក្នុងពេល
នោះ សម្តេចព្រះឧត្តមមុនីសិរីសត្ថាមាន បញ្ជាក់ពីភាពនៃមិត្តភាព ជា
ច្រើន រវាងប្រជាជនស្លូវ៉ាគីពីរ ហើយព្រះអង្គក៏ថ្លែងនូវកិត្តិគុណ
ចំពោះប្រជាពលរដ្ឋ នៃទីក្រុងកុលម្ប ដែលបានរៀបចំខួលព្រះនាមគណៈ
ប្រតិភូខ្មែរ ដ៏ឧឡារកៃ ។

សម្តេចព្រះឧត្តមមុនីសិរីសត្ថាមាន: អាគារ ឬទីស្ថានៃសហភាពរៀត
ប្រទេសចិនប្រជាមានិត នៅអាន់ប្រទេសកម្ពុជា គឺរួមទៅដោយ
ជាប្រក្រតីភាព, ក្រោយដែលប្រទេសកម្ពុជា បានតាន់ឃាត់ឃាយ
អត្ថាក្រិត ។ ចំពោះនឹងមួយទាងនេះឯកិច្ច នឹងបានបញ្ចប់ទេ, ព្រះ
អង្គបានបញ្ជាក់ថា មានប្រជាជាតិប្រកបដោយមេត្រីភាព ដូចជាប្រទេស-
ជាកិន, សហព័ន្ធអាមេរិក, ប្រទេសចិនប្រជាមានិត, សហភាពសូ-
វៀត, ក៏ជួយប្រទេសកម្ពុជា ទាងវិស័យសេដ្ឋកិច្ច, ការពារជាតិ
និងសុខភាព ។

ព្រះអង្គបានបន្ថែមថា, "ក្រោយដែលបានទទួលឯករាជ្យ ចេញពីប្រទេស
កម្ពុជាពី គ.ស. ១៩៥៣, ប្រទេសទាំងពីរ ក៏ធ្លាប់ស្រស់ឆ្អាតភាព
ខ្លាំង ដោយមេត្រី, ហើយប្រទេសចាក់ដែនបានជួយប្រទេសកម្ពុជា ខ្លះតិចនិ

នាក់មួយ ដែលខំឆ្លើយក្នុងខ្នាំមុខ" ។ ទ្រង់ចាន់តោលតទៅទៀតថា:

"សហវដ្ឋគាមេកៈ ចានជួយខាងគ្រឿងសស្ត្រាវុធ, ប្រទេសចិនប្រជាមានតិត, ខាងកេងទុស្សហកម្ម, សហភាពសូវៀតខាងការស្ថាបនាខ្លួមម្ចាស់ចាស់លេត នៅពេជាន់ក្តុតេញ ។

ក្នុងពេលនោះ, តែតមែនតែមានក្លៀងបង្អោរមកខ្លាំង, ក៏ប្រជាពស្ត្រនៅខ័ក្រុង ចាំងបុរសចាំងស្ត្រី ស៊ូត្រាំឈរស្តាប់ព្រះសង្ឃថាសម្តេចតាល់តែចប់សព្វគ្រប់ ។

ថ្ងៃសៅរ៍ ទី ១៦ កុម្ភៈ

ម៉ោង ៧ ខាង ៣០ នាទី, សម្តេចទ្រង់យាងចេញពីខ័ក្រុងកុលម្ប៊ូ ទៅកាន់ខ័ក្រុងកន្ទី ។ នៅតាមរយៈផ្លូវនៃព្រះពេជតំណើរ, ទ្រង់ចានស្តេចយាងទៅធ្វើព្រះពេជទស្សនាការ នៅមហាវិទ្យាល័យកុលម្ប៊ូ ព្រមចាំងព្រះពេជបរិពារ ។

លុះសម្តេចយាងទៅដល់ខ័ក្រុងកន្ទី, ទ្រង់ចានគង់ឃព្រះស្ងោយនៅមហាសណ្ឋាគារ "គីឆប៉ាឡេយ៉ុង" ។ គេចានរៀបចំខ្លួលសម្តេចជាយ៉ាងខ្ពស់កៃ ដោយមានក្បួនដង្ហែដ៏រុងរឿងចាំ, ព្រះសង្ឃជាច្រើនមកហែទ្រង់ទៅកាន់មហាវិហារចង្កួមកែវ ។ ព្រះចង្កួមកែវនេះ ចានដំកល់នៅក្នុងព្រះកោដ្ឋ ដែលរចនាដោយសុវណ្ណដ៏វិចិត្រ លោកលៅអធិការ ក៏ចានថ្វាយខ្លួចង្កួមកែវព្រះសម្ងាសម្តុខ្លួមកសម្តេច ដោយព្រះទ័យសោមនស្ស ជាយ៉ាងក្រៃលែង ។ សម្តេចទ្រង់ចានធ្វើព្រះអំណោយខ្លួព្រះពុទ្ធរូបធ្វើពី

មាស ២ អង្គ, ពោធិព្រឹក្សមាស ១ ដើម, ច្រាក់ ១ ដើម, ចំណែកមួយវាំង
ទឹងច្រាក់ ១០០០ រូបិយ ។

លុះដល់ម៉ោង ១៩ ទឹង ៣០ នាទី, មានពិធីទទួលសម្តេច ឯសាលា
ក្រុងកន្ទី ជាយ៉ាង១ឡារិក ។ ក្នុងពេលនោះ, សម្តេចព្រះបានថ្វែងនូវ
ព្រះសង្ឃថាមួយ ជាគាសាអង់គ្លេសព្រះពន្ធរសព្ទសាធុការពៅលោកពៅ
ហ្វាយក្រុង ហើយព្រះអង្គបានបញ្ជាក់អំពីព្រះរាជតំណើរព្រះបាទសម្តេចព្រះ
ស៊ីសុវត្ថិ មកកាន់ទីក្រុងនេះ ព័ត៌មានសរសើរថា ទីក្រុង
នេះបីតពៅជាមជ្ឈដ្ឋានដ៏ត្រចះត្រចង់ សម្រាប់ផ្សព្វផ្សាយនូវពន្លឺព្រះធម៌ ពៅ
គ្រប់ទិសានុទិស ឲ្យបានភ្លឺស្វាងរុងរឿង ។

លុះដាច់តមក, សម្តេចព្រះអង្គយាងពៅធ្វើព្រះរាជទស្សនាការនៅតំបន់
ចោលមហាវិហារ ទឹងប៉ុស្តិ៍ល្វមហាវិហារ ដែលមានពិធីរៀបចំទទួល
ព្រះអង្គជាយ៉ាងសំបើមអស្ចារ្យ តាមរបៀបពិធីសាវបុរាណ នៃប្រទេស
សិរីលង្កា ។ លុះដល់ប៉ុស្តិ៍វិមហាវិហារ ពួកមហាជនទាំងប្រុសទាំង
ស្ត្រីគឺនាំគ្នាសុះទាំងអស់គ្នា ពាក់ម្ទឹងនាក់ ដើម្បីចង់ឃើញសម្តេច ។ តែ
ដោយក្រុមនគរបាលឃាត់ការពារ មិនឲ្យចូលមកបាន, ក៏អាក់ខានលែង
បានចូលពៅជិតព្រះអង្គ ។

ប្លែអាទិត្យទី ១ពិភក្តា:

ពេលព្រឹក, សម្តេចព្រះទេបយុវរាជ ទ្រង់ស្តេចយាងពៅដាំព្រឹក្ស-
ជាតិមួយដើម ពៅសណ្ឋាគារ " គីដ៏ប៉ាវីយ៉ុង " រួចទ្រង់បានធ្វើព្រះពន.

ទស្សនាគារ ចំពោះមហាវិហារបីតន្លៃនៃ មានអស្ចារ្យជាដើម ដែលពីអតីតកាលមានព្រះក្សត្រចងក, ធ្លាប់តែស្អាយមាត់ខ្លះ, ឥឡូវនេះ ទើបនឹងមានគម្ពីរសរសេរជាលាយលក្ខណ៍អក្សរជាដម្លឹង ។ ក្នុងពេលខោះ, សម្តេចទ្រង់ស្តេចយាងទតព័ត៌មានសមាគមសិល្ប: នឹងពិពិធកណ្ឌស្ថានទីក្រុងកន្ទឺ ។

ពេលរសៀល ជល់ទ្រង់ស្តេចយាងវិលត្រឡប់ មកគាន់ទីក្រុងកុលម្ប៊ូវិញ, ទ្រង់ថ្នាន់ដាំព្រឹក្សជាតិមួយដើមទៀត នៅខាងមាត់ទន្លេ: ។

ម៉ោង ១៩ លោកវរដ្ឋមន្ត្រីទី ១ ប្រទេសសិរីលង្កា ថ្នាន់រៀបចំខួលជាខាងឯកសម្តេច នឹងព្រះពរជាដរាប ។

ថ្ងៃចន្ទទី ១៨ កុម្ភ:

សម្តេចទ្រង់ស្តេចសម្រាកព្រះកាយតាល ព្រមទាំងព្រះពរជាដរាបទ្រង់ស្តេចយាងចេញពីទីក្រុងកុលម្ប៊ូ ដោយព្រះទីនាំងអាកាសយានពិសេស នៅថ្ងៃអង្គារទី ១៨ កុម្ភ: ត្រលប់មកកាន់ពដ្ឋានទីក្នុងវិញ ។

សម្តេចទ្រង់យាងមកដល់ស្ថានីយ៍អាកាសយាន ពោធិចិនតុង នៅថ្ងៃពុធទី ២០ កុម្ភ: ១៩៥៧ ម៉ោង ១៨ ម៉ីង ០៥ នាទី ។

សន្និសីទនៃបណ្ឌិតវិសាទ៍អេក្លាត
ធ្វើនៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងភ្នំពេញ
លោក រ៉ាយ-ប៊ុក រៀបរៀង

(ត)

៥. ការទាក់ទងគ្នាទៅវិញទៅមកនៃការសិក្សាខាងព្រះពុទ្ធសាសនានឹងការសិក្សាឯទៀត ៗ ក្នុងការអប់រំខាងព្រះពុទ្ធសាសនា ។

ការទាក់ទងគ្នាទៅវិញទៅមក ខាងការសិក្សាព្រះពុទ្ធសាសនា នឹងការសិក្សាឯទៀត ដែលមិនមែនជាព្រះពុទ្ធសាសនា គួរនិយាយរៀង ជាវិធីដ៏សំខាន់នៃការរៀន នឹងការបង្រៀន ខាងការសិក្សាអំពីព្រះពុទ្ធសាសនា សមគួរយកមកគិតថាណា ជាតិសេសនៅទីនេះផង ។ ដូចបានថ្លែងពីមុនមក ហើយ មុខវិជ្ជាទាំងអស់ប្លែកនៃការចេះដឹង ដែលចាត់ទុកជាមានប្រយោជន៍ ដើម្បីសិក្សាធម៌ នឹងសង្គមមនុស្សជាតិទំនើបតុ ដែលមានន័យដ៏ពិត បង្កើតឲ្យមានសម្មតិដ្ឋានដ៏ត្រឹមត្រូវ សម្រាប់ការសង្កេតពិនិត្យខាងព្រះពុទ្ធសាសនា ។ ទោះបីយ៉ាងណាក៏ដោយ បញ្ហាតែងតែកើតឡើងជាញឹកញាយថា វិធីសិក្សាមិនមែនជាព្រះពុទ្ធសាសនា អាចទំនាក់ទងជាមួយនឹងការសិក្សា ខាងព្រះពុទ្ធសាសនាយ៉ាងណាៗ តើការបៀបនៃការសិក្សា មិនមែនជាព្រះពុទ្ធសាសនានោះ អាចបំពេញសេចក្តីត្រូវការដល់

ការសិក្សាខាងផ្លូវសាសនាយ៉ាងណា ទំនៀមទំលាប់នៃការសិក្សាមិនមែនដូច
ព្រះពុទ្ធសាសនានោះ គាប់ជួយបន្ថែមចំណេះវិជ្ជា ឲ្យបានយល់ខាងផ្លូវព្រះ
ពុទ្ធសាសនាយ៉ាងណា ក្នុងអតីតកាល គោលបំណងជាមូលដ្ឋានទឹងតំនិត
រួមនៃការសិក្សា ខាងផ្លូវសាសនាបានបំភ្លឺការប្រើការសិក្សាផ្សេងៗ ទឹងការ
ប៉ុនប្រសប់ ឬវិជ្ជាបច្ចេកទេស សម្រាប់បណ្តុះបណ្តាលការសិក្សាខាងផ្លូវ
ព្រះពុទ្ធសាសនា ដែលមានទៅក្នុងប្រពៃណីនៃវិជ្ជាសមោធាន ដើម្បីធ្វើទឹង
ការសំដែងសួនៗ នៃធម៌ ។ ទោះបីយ៉ាងណាក៏ដោយ ក្នុងសម័យបច្ចុ-
ប្បន្ននេះ ការពិសាំញុំ ការជាក់ឲ្យមានការពាក់ព័ន្ធ ទឹងការឲ្យការនាំគេ
ជាគ្រហស្ថ ដែលមានចំនួនការនាំតែច្រើនឡើង ក្នុងដីវិការពិនិត្យទៅលើ
ផែនដីខ្លួនៗនោះ ត្រូវការចំណេះវិជ្ជាដ៏ពិតប្រាកដជាមូលដ្ឋាន សម្រាប់
អំពើដ៏ឈ្លាសវៃហើយត្រមភាំងមុខវិជ្ជា មិនមែនជាព្រះពុទ្ធសាសនា ក៏ត្រូវ
ជាក់បញ្ចូលទៅក្នុងវិជ្ជាបង្រៀន ខាងផ្លូវព្រះពុទ្ធសាសនាផង ។ មុខវិជ្ជា
បែបនេះ តែងមានឡើងដោយអន្តរាត្តិ៍ លើដីវិការពិនិត្យប្រើនជាងការ
សិក្សាធម៌ ហើយវៀរលែងតែមានការពាក់ព័ន្ធ ដោយត្រឹមត្រូវជាមួយទឹង
គោលបំណង ជាមូលដ្ឋានខាងការសិក្សាព្រះពុទ្ធសាសនា មុខវិជ្ជាទាំងនេះ
អាចសន្មតបានថាជា ស្ថានភាពមិនសមគួរយកមកបង្រៀន ខាងការសិក្សា
ព្រះពុទ្ធសាសនា ។ ដូច្នេះអ្នកដឹកនាំព្រះសង្ឃខ្លះនៅទីបញ្ជាស៊ី ភាគអនុគ្រោះ
បានបញ្ចេញសំឡេងទិនទៀន ដល់ការសិក្សាខាងផ្លូវព្រះពុទ្ធសាសនាបែប
ទំនើប ហើយបានជាប់តឿនថា មិនគួរសិក្សាទេ គ្រាន់តែគួរពិនិត្យសង្កេត
មើលប៉ុណ្ណោះ ពួកនេះមានសេចក្តីបារម្ភ ខ្លាចក្រែងការសិក្សាខាងផ្លូវព្រះ

ពុទ្ធសាសនា ទប់ការសិក្សាគ្មានដាច់ព្រះពុទ្ធសាសនាមិនឈ្នះ ហើយធម្មត្រូវបង្ហើរសេចក្តីពិតត្រូវរំលាយបង់ទៅ ដោយហេតុដូច្នេះ ព្រះសង្ឃកំពុងទៅជាគាន់តែទ្រគ្រហស្ថវិញ ហើយនាំឲ្យមានការសោកស្តាយទៅបន្តិចម្តង ។ ការយល់ឃើញបែបនេះហៅថា "ប្រពៃណីនិយមលើសលុបហួសប្រមាណ" គួរឲ្យប្រុងប្រយ័ត្នហ៊ានខ្លាំង ជាពិសេសដោយការរកហេតុផល ឲ្យច្បាស់ជាក់ច្បាស់ ។ ការយល់ឃើញខុសពីបែបនេះ ដែលហៅថា "និយមសម័យថ្មីហួសគេក" នោះពុំបានតិចឡើយ ជាសំណាស់ ដោយគ្រាន់តែគិតឃើញថា ការអប់រំខាងក្នុងព្រះពុទ្ធសាសនាត្រូវតែធ្ងើ ឲ្យទំនើបឲ្យខាងតែបានដើម្បីឲ្យទៅមានជីវិតបន្តទៅ តាមពិតភាពលោកក្នុងសម័យបច្ចុប្បន្ននេះបាន ។ ដូច្នេះ ការណីនេះអាចបណ្តុះបណ្តាលការខ្វែងរំលាយ នៃពួកអ្នកនិយមការអប់រំ ដែលគិតថា ពុំមែនជាក្បួនចាំបាច់នៃទស្សនវិជ្ជា ខាងការអប់រំដ៏សមគួរ សម្រាប់វិជ្ជាស្ថានៃព្រះពុទ្ធសាសនាឡើយ ។

ប្រសិនបើសព្វថ្ងៃនេះ បានពិនិត្យពិចារណា ឲ្យត្រឹមត្រូវនូវស្ថានការណ៍ នៃពុទ្ធិកសិក្សាគង់នឹងបានឃើញថា ការដោះស្រាយនៃស្ថានការណ៍នោះ មិនមែនពឹងផ្អែកទៅលើក្រុម "អ្នកប្រកាន់ប្រពៃណី ហួសប្រមាណ" ឬទៅលើក្រុម "អ្នកប្រកាន់តាមសម័យថ្មី ហួសប្រមាណ" ទេ ប៉ុន្តែ ត្រូវស្វែងរកការចេះដឹងដ៏ជ្រាលជ្រៅ នូវគោលបំណងដើម មុខវិជ្ជា ហើយនឹងនូវវិធីនៃពុទ្ធិកសិក្សា ។

បើតាមគំនិតអស់ ដែលជាប់ពាក់ព័ន្ធយល់ថា គោលបំណងដើមនៃ

ការសិក្សាព្រះពុទ្ធសាសនា ការសិក្សាធម៌របស់ព្រះសង្ឃ ទើបរបស់សង្គម
ត្រូវការសេចក្តីពេញចិត្ត ក្នុងការសិក្សាព្រះពុទ្ធសាសនាផ្សេង ៗ គ្នា ដើម្បី
បំពេញការកិច្ចរបស់ខ្លួន តម្រូវចូលចិត្តថា ការសិក្សាឲ្យបានយល់នូវមុខ
វិជ្ជាដូច្នោះ ត្រូវអាស្រ័យលើផែនសិក្សា ដែលបានលទ្ធផលល្អទើបសេចក្តី
ស្រួលក្នុងការសិក្សា ហើយត្រូវយល់ថា របៀបសិក្សាតាមប្រពៃណីនិយម
ទើបការនិយមបែបបទសិក្សាតាមសម័យថ្មី គ្រាន់តែជាសម័យចាត់ទុកគ្នា ក្នុង
សេចក្តីចំរើនខែការសិក្សា ខាងផ្លូវព្រះពុទ្ធសាសនាប៉ុណ្ណោះ បើដូច្នោះ
រឿងភាំងអស់នេះ ត្រូវតែដោះស្រាយឲ្យស្រួលបួល ដោយការបញ្ចូល
វិជ្ជាសិក្សាមិនមែនជាព្រះពុទ្ធសាសនា ចូលក្នុងវិជ្ជាសិក្សា ខាងផ្លូវព្រះពុទ្ធ-
សាសនា ក្នុងបទរៀនសម្រាប់តុក្កវិក្ខាល័យ ឬជាតវិជ្ជាខាងព្រះពុទ្ធ-
សាសនាដែលជ្រើសរើសត្រឹមត្រូវ ហើយឲ្យជាបទរៀនក្នុងវិក្ខាល័យ
ដែលមិនមែនជាពុទ្ធិកៈ ។

វិជ្ជាខាងផ្លូវលោកនិងខាងផ្លូវសាសនា ដែលគេចូលហ្គាល់ថា
ជាប់ទាក់ទងគ្នាទៅវិញទៅមកនោះគឺ វិជ្ជាខាងភាសា ខាងប្រវត្តិសាស្ត្រ
ខាងសង្គមសាស្ត្រ អាទិទេពសាស្ត្រ ខាងសាសនា ខាងទស្សនវិជ្ជា
ខាងសិល្បសាស្ត្រ វិទ្យាសាស្ត្រ ខាងរូបនិយម វិជ្ជាខាងសាមគ្គីនិងនិ-
ខាងបណ្ណាល័យ ។ ការបញ្ចូលមុខវិជ្ជាទាំងអស់នេះទៅក្នុងសិក្សា
ក្នុងតុក្កវិក្ខាល័យ អាចនឹងជ្រើសរើសតាមផ្នែកវិជ្ជាភាសាសាស្ត្រ ដូចតទៅនេះ ខ ១ ការពិចារណា ពីបញ្ហាភាសានៃពុទ្ធិកសិក្សា ។ ខ ២ ការបោះ
ជំនឹង ខាងបណ្ណាល័យ ស្តីពីវិជ្ជាភាសា ។ ខ ៣ ការយល់ន័យនឹងតំហិ

របស់ផ្លែកាសា ។ ទី ๔ ការបង្កើន នូវនិន្នៃផ្លែកាសា ។ ទី ๕ ការប្រើប្រាស់ផ្លែកាសា ដើម្បីរៀនបំណងផ្លែ នូវនិន្នៃសាសនា ដូចជាប្រើផ្លែកាសា ដើម្បីពន្យល់នឹងបកប្រែអក្សរសាស្ត្រ នូវនិន្នៃសាសនាដូចជាប្រើផ្លែ នូវនិន្នៃកាសា ដើម្បីដឹងនូវការខាក់ខន រវាងពុទ្ធិកវិន្ញាណនឹងអពុទ្ធិកវិន្ញាណ ។ ប្រសិនបើ ការខាក់ខននៃពុទ្ធិកសិក្សា នឹងអពុទ្ធិកសិក្សាធ្លើឡើងបាន តម្រូវដែនៃការសិក្សានៅពុទ្ធិកវិទ្យាល័យ នឹងពុទ្ធិកមហាវិទ្យាល័យនឹងអាចត្រូវប៉ះគ្នា ជាចង្កាមវិន្ញាណមួយ ដែលមានឧស្សាហវិន្ញាណជាគ្រឹមុខ ហើយបញ្ជាក្រៃណីនិយម ប្រតាំងនឹងសម័យនិយម មិនអាចនឹងកំណកការចំរើន នៃពុទ្ធិកសិក្សាក្នុងលោកបានឡើយ ។

๖- សេចក្តីសន្និដ្ឋាន

ការពិចារណាចំពោះពុទ្ធិកសិក្សា អាចសន្និដ្ឋានយ៉ាងខ្លីដូចតទៅនេះ គោលបំណងដ៏តឹ ព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ នឹងសង្គមមនុស្ស អាចយើញ អាចថ្លែងបាន អាចយល់ នឹងអាចសម្រេចបាន សម្រាប់មនុស្សគ្រប់រូប មុខវិន្ញាដ៏សំខាន់តឹងមិនឹងការស្គាល់ នូវសង្គមមនុស្ស នឹងមជ្ឈដ្ឋានជុំវិញសង្គមមនុស្សនោះ ត្រូវតែឲ្យមានការខាក់ខន នឹងគោលបំណងខាងលើនោះ ។ រាល់សិក្សានឹងរបៀបបង្រៀន ទោះបីតាមប្រពៃណីក៏ដោយ តាមសម័យក៏ដោយ ត្រូវតែតម្រូវតាមមុខវិន្ញា ហើយនឹងត្រូវតែបំពេញ តាមគោលបំណងឲ្យបានសម្រេច ។ ការខាក់ខនរវាងផ្លែទាំងអស់ នៅក្នុងបរិវេនខាងផ្លូវព្រះពុទ្ធសាសនា អាចធ្លើឲ្យចំរើនឡើង

ជាន អាចធ្វើឲ្យយល់ ដោយជាក់ច្បាស់នូវរឿងនោះ ទើបអាចនាំឲ្យសម្រេច គោលបំណងទាំងអស់ បានដោយងាយ ។

ដូច្នេះ តុលាការសិក្សាក្នុងសម័យបច្ចុប្បន្ននេះ អាចនឹងជួយរៀបចំបុគ្គលត្រប់ប្រប ព្រះសង្ឃនឹងសង្គមមនុស្ស ឲ្យបានប្រកបដោយជីវភាពរុងរឿងសៅអនាគតកាល ។

សន្និសីទនេះ បានបញ្ចប់សៅវេលាម៉ោង ១៦,៤០ នាទី ។

លុះដាច់តមក, សម្តេចសង្ឃនាយកគណៈមហានិកាយ បានថ្លែងខ្លឹមសង្ខេបជាមួយ ពីណានាថា:

"ការសិក្សាក្នុងព្រះពុទ្ធសាសនានេះ, តំណុះសង្ឃ បានទទួលសៅទេសនាត្រប់វត្តអាម នៃព្រះពុទ្ធអាណាចក្រទាំងមូល, តែដែលគួរឲ្យសរសើរលោកវិស្សាទ័នេះ ត្រោះលោកពិតជាអ្នកកាន់តួន ដែលមានកិត្តិនាមល្បីល្បាញ ក្នុងសកលលោក ហើយជាអ្នកប៉ុនប្រសប់ ខាងពន្យល់បំភ្លឺការសិក្សា ក្នុងព្រះពុទ្ធសាសនា ដោយបញ្ជាក់ត្រង់ប្រយោជន៍ នៃការសិក្សានេះ សៅអនាគតទើមធ្យោបាយផ្សេង ។ ដែលធ្វើឲ្យការសិក្សាបម្រើនតាមលំដាប់ ព្រមទាំងការសិក្សាព្រះពុទ្ធសាសនា សៅខាងប្រទេសថៃមទៀត ដោយរសេចក្តីពិស្តារ ។

ដើម្បីត្រឹត្តិ

បណ្ឌិត វិស្សុទ្ធ អេ.ភ្នំពេញ ១០០៦ ២-ធ្នូ

ស្នងឈ្មោះ-ម៉ាំងិ

សេតាក្លាយ៉ា.គុ

ប្លុកប៊ុង

លោកតេតាសេ ភីនក្លាវ៉ែ ប្រទេសតាណាដា ថេ.សេ.នៅថ្ងៃទី ២៩ ខែធ្នូសតាឆ្នាំ ១៩១៤ ជាតំណាងរំកិល ធ្វើអាពាហ៍ពិពាហ៍មង្គល ក្នុងឆ្នាំ. ១៩៤២ មានបុត្រ ២ ជាមួយនឹងការបញ្ចប់ការសិក្សាជាន់អក្សរសាស្ត្រ B.A. អំពីមហា-វិទ្យាល័យ ក៏សុីតុនក្លូ ... ក្នុងដំបូងក្នុងនាមជាសិស្ស នៃមហាវិទ្យា-ល័យហាវ៉ែក្នុងឆ្នាំ ១៩៤៦-៤៧ ជាមួយនឹងការបញ្ចប់ត្រមហាបណ្ឌិតM.A. ក្នុងឆ្នាំ ១៩៤០ ដាប្លុកលីនៃមហាវិទ្យាល័យ ហ្គ្រីនកេហ្ស ហ៊ូល្លឺរ មហាវិទ្យាល័យ តេន្ទ្រីលពីណៀ ក្នុងឆ្នាំ ១៩៤៦-៤៧ ជាមួយនឹងការបញ្ចប់ត្រមហា-បណ្ឌិតខាងទស្សនវិជ្ជា Ph.d. ពីវិទ្យាល័យ ក្នុងឆ្នាំ ១៩៥១ ជា សាស្ត្រាចារ្យ ជំនាញខាងវិទ្យាសាស្ត្រនយោបាយ នៅមហាវិទ្យាល័យ ហាវ៉ែ ឆ្នាំ ១៩៤៦-៤៧ ជាអ្នកសំដែងអំពីការសិក្សាសាជីវកម្ម A.S.T.P. នៅមហាវិទ្យាល័យ តេន្ទ្រីលពីណៀ ឆ្នាំ ១៩៤៩-៥០ ជាអ្នកសំដែងតិចតួច នៅក្នុងបូជាប្រទេស នៅមហាវិទ្យាល័យ ហ្សន ហប.តិន ជាកន្លែងបង្រៀនការសាអន្តរជាតិជាន់ខ្ពស់ "ក្រុងវ៉ាស៊ីង.តុន ដេ.សេ." ក្រោយឆ្នាំ ១៩៥២ ជាបាឋហ្វាងក្រុមដែនការណ៏មួលនិធិអាស៊ី សាន់ហ្វ្រាន់ស៊ីស្កូ ក្នុងឆ្នាំ ១៩៥៤-៥៦ ជាទីប្រឹក្សាពិសេស ក្នុងឆ្នាំ. ១៩៥៦ ។ ជាសាស្ត្រាចារ្យ ... នៅមហា. វិទ្យាល័យសូតាន ... មហាវិទ្យាល័យ ... ទីនេះមហាវិទ្យាល័យ ... ស្តី

ក្បូតូ ក្នុងឆ្នាំ១៩៥៣-១៩៥៤ ជាអ្នកធ្វើដំណើរទៅសំដែងសុន្ទរកថានៅ
គ្រប់ប្រទេស ដែលខ្លួនទៅទស្សនា ក្នុងឆ្នាំ ១៩៥៧ ចានទទួលគ្រឿង
ឥស្សរិយយស ចម្លងឈុ ពីពុទ្ធសាសនិក ជប៉ុន នៅហ្គីឡាដេលហ្វៀ
ឆ្នាំ១៩៤៦ គ្រឿងឥស្សរិយយសឈឺងកន.ឈុ នៅឡសអែនជែលេស
ឆ្នាំ១៩៥០ គ្រឿងឥស្សរិយយស ថេរវាទ ពីពុទ្ធសាសនិកថៃ នៅក្រុង
ចាងកកឆ្នាំ ១៩៥៦ ។ គ្រឿងឥស្សរិយយស ថេរវាទ ពុទ្ធសាសនិកកូមា
នៅក្រុង រង្គូនឆ្នាំ១៩៥៦ USMC ឆ្នាំ ១៩៤១-១៩៤៥ ជាវរសេនីយ៍ទោ
"សមាជិក"ជាសមាជិកសមាគមអាមេរិកាំងខាងបូព៌ាជាសមាជិកការសិក្សា
ទ្វីបអាស៊ី ជាសមាជិកសមាគម· សៀម ជាសមាជិកសមាគម ជប៉ុន
សម្រាប់ការសិក្សា វណ្ណៀ នឹងព្រះពុទ្ធសាសនា "វិជ្ជាដែលបានសិក្សា"
ប្រវត្តិសាស្ត្រនៃបាមគ្គ វិជ្ជាខាងព្រះពុទ្ធសាសនា ប្រវត្តិសាស្ត្រនៃគំនិត
ខាងនយោបាយអាស៊ី ប្រវត្តិសាស្ត្រពុទ្ធសាសនាមជ្ឈិមកៈ "រឿងដែល
បានសរសេរ" ឥទ្ធិពលព្រះពុទ្ធសាសនា លើគំនិតខាងនយោបាយ
នឹងស្ថាប័ន វណ្ណៀ នឹង ជប៉ុន ។ត្តមគតិ ខាងផ្លូវនយោបាយនៃព្រះពុទ្ធ·
សាសនា:ជីវប្រវត្តិនឹងសេចក្តីសង្ខេប ។ត្តមគតិ ខាងផ្លូវនយោបាយនៃព្រះ
ពុទ្ធសាសនាការសិក្សា អំពីព្រះពុទ្ធសាសនាក្នុងសង្គម ។

ព្រះមហា ប៉ាង.ខាត់ រៀបរៀង

អគ្រាណីក (អគ្រ+អណីក) នបុ. រណសីរ,សមរភូមិ ។ **អគ្រាណីក្យ** នបុ. ចំពស្រួច ។ **អគ្រេទិធិមូ** ស្ត្រី. ប្តីនស្ត្រីដែលការមុនបងស្ត្រី ។ **អគ្រេ-ទិធិបុ** បុ. ទីពុកដែលរៀបចំការកូនស្រីប្តីនមុនកូនស្ត្រីបង ។

អគ្រែ-ភូ គុ. ដែលកើតមុន, ដែលមានមុនគេ ។

អគ្រែស្ត (អ+ក្រស្ត) គុ. ដែលមិនទាន់លេប ។

អគ្រាមីណ គុ. ដែលមិនមែនជាគ្រាមជន ដែលមានចោរភាព, ដែលភាក់ខាក់ ។

អគ្រាមីណ្យ នបុ. ភាពមិនមែនជាគ្រាមជន, ចោរភាព ។

អគ្រាហ្យ គុ. ដែលបុគ្គលកាន់យកមិនបាន, ដែលបុគ្គលមិនគប្បីស្គាល់ ។

អគ្រិម គុ. ជាឯក, ដែលនៅមុនគេ ។

អគ្រ្យ គុ. ជាមេ,ប្រសើរ,ចាស់;ពិសេស ។ **-គមន** បុ. នាមនាមស ។

អឃ ក្រ. ប្រព្រឹត្តទៅខាងទុស ។

អឃ គុ. លាមក, ដែលមិនបរិសុទ្ធ, ដោកខាបជាងវាឡោះខ្លួន; ។នបុ. សេចក្តីមិនបរិសុទ្ធ, សភាពមិនបរិសុទ្ធ,ទោស, ទុក្ខ ។ **-កូត** គុ. ដែលធ្វើឲ្យលាមក, អ្នកធ្វើឲ្យលាមក ។ **-ឃ្នុ-នាគក** គុ. អ្នកបំបាត់នូវទោសឬសេចក្តីទុក្ខ ។ **-ឃ្នស ឃ្ន-នាគ្ន** បុ. នាមប្រវិញ្ញ ។ **-មតំណ** គុ. "លាងបាប" ឈ្មោះបទសូត្រក្នុងគម្ពីរវេទ (ពួកព្រាហ្មណ៍ប្រើសូត្រនេះរាល់ថ្ងៃ) ។ **-វិឃាតកត្ថ** ភ.ន. អ្នកធ្វើនូវការយកចាត់បង់នូវបាប ។ **-វិនាគិន**

អំពីទស្សនាវដ្តី កម្ពុជសុរិយា ផ្សាយចេញអំពីពុទ្ធ-សាសនបណ្ឌិត្យ

ទស្សនាដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៧ ដែលអស់លោក-អ្នក ចានចុះឈ្មោះជាវមកនោះទើចបត់ត្រឹមខែលេខ ១២ ខាងមុខនេះហើយ ។ យើងសូមថ្លែងអំណរគុណយ៉ាងក្រៃលែង ចំពោះអស់លោក អ្នកដែលចានចុះឈ្មោះជាវចាំងនោះ ហើយយើងសង្ឃឹមថា អស់លោក-អ្នកនឹងចុះឈ្មោះជាវទស្សនាវដ្តី ដែលយើងកំពុងរៀបរៀង ទើចប្រមូលផ្សុំរឿងរ៉ាវនឹងថ្លោះពុទ្ធ ក្នុងឆ្នាំ ១៩៥៨ តទៅទៀត ។ កិច្ចដែលអស់លោក អ្នកចានចុះឈ្មោះជាវច្រើនឡើង ។ នេះ ឈ្មោះថា ចានជួយបំពេញការណ៍យកិច្ច ចំពោះប្រទេសជាតិ ផ្នែកខាងសាសនានឹងអក្សរសាស្ត្រ ។

តាមការណ៍ពិត ទស្សនាវដ្តី កម្ពុជសុរិយានេះ ជាទស្សនាវដ្តីផ្លូវការ ផ្សាយចេញនូវរឿងរ៉ាវផ្នែកសាសនា ទើងអក្សរសាស្ត្រ ទុកជូចជាប្រទីប សម្រាប់បំភ្លឺប្រជាជនរួមជាតិ ឲ្យមានបញ្ញាចក្ខុ មើលឃើញច្បាស់នូវ សេចក្តីវិនាស ទើងសេចក្តីចំរើន ក្នុងផ្លូវលោក ទើងផ្លូវធម៌ ព្រមទាំងពង្រីក អក្សរសាស្ត្រជាតិ ឲ្យរីកធំទូលាយតាមសម័យ ជាកុំយ្បីគាត ។

រឿងរ៉ាវសម្រាប់ចុះ ក្នុងទស្សនាវដ្តី កម្ពុជសុរិយា ឆ្នាំ ១៩៥៨ ជូបមានរាយមាតិកា តទៅនេះ ៖

ផ្នែកសាសនា

១. ដំណឹងផ្សេង ៗ ខាងព្រះពុទ្ធសាសនា;

២. ធម្មទេសនា ដែលមានអត្ថរសប្លែក ៗ;

៣. សីលធម៌របស់ព្រះពុទ្ធសាសនា;

៤. ការជ្រើសរើសប្រៀបព្រះសូត្រ ដែលមានសេចក្តីត្រូវជឿ ទំនងជាធ្លុះប្រតិបត្តិ ។

ផ្នែកអក្សរសាស្ត្រ

១. គោលចារឹកខាងផ្នែកអក្សរសាស្ត្រខ្មែរ ព្រមទាំងការពន្យល់ជាស់ ៗ ឬទំនើប;

២. ឯកសារ (រឿងព័ត៌សំខាន់ ៗ ដូចសិលាចារឹកជាដើម);

៣. រឿងសាមកុក នៅតែបោះពុម្ពតទៅទៀត ត្រាតែចប់;

៤. សុភាសិតផ្សេង ៗ របស់ជាតិយើង ទំនងនានាជាតិ;

៥. រឿងព្រេងខ្មែរ ឬ រឿងព្រេងរបស់នានាជាតិ,

៦. រឿងទំនៀមទម្លាប់ខ្មែរ របស់គណៈកម្មការទំនៀមទម្លាប់ខ្មែរ។ល។

ហេតុនេះ អស់លោក-អ្នកដែលមានបំណងទំនងជាវ ទស្សនាវដ្តី កម្ពុជសុរិយា ប្រចាំឆ្នាំ១៩៥៨ សូមប្រញាប់ផ្ញើនាមទុំនីលំនៅ ឲ្យមានក្នុងខែ ធ្នូ ឆ្នាំ ១៩៥៧ ទៅអគ្គលេខាធិការនៃពុទ្ធសាសនបណ្ឌិត្យកម្ពុជា (Monsieur le Secrétaire Général de l'Institut Bouddhique Phnôm-Penh ព្រមទាំងដំឡៃជាវប្រចាំឆ្នាំបំនួន ២៣០រៀលផង ។

ពុទ្ធសាសនបណ្ឌិត្យ

ភ័ទ្ទបច្ចេកទេសយោ

ទស្សនាវដ្តី ផ្សាយដំណឹងខាងសាសនា និងអក្សរសាស្ត្រ



ឆ្នាំទី ២៩ លេខ ១២ ខែ ធ្នូ ព.ស. ២៥០០ គ.ស. ១៩៥៧

ក-ក-ស៤ ១ ត-ល-ម៤



ទស្សនាវដ្តី ផ្សាយជំណឹងខាងសាសនា និងអក្សរសាស្ត្រ

បោះពុម្ពផ្សាយអំពីពុទ្ធសាសនបណ្ឌិត្យ

ផ្នែកសាសនា	មញ្ជើរឿង	ទំព័រ
-និទានសុភាសិត	ព្រះមហា ម៉ៅ-ខាន់ រៀបរៀង	១០៤៧
-សោភាធិប្បាយ	លោក ប៊ូ-ប៊ូ រៀបរៀង	១០៦១
-សេចក្តីពិចារណាពីពុទ្ធសាសនិកជនម្នាក់ (តទក)	លោក វ៉ាយ-ប៊ុក រៀបរៀង	១០៦៥
ផ្នែកអក្សរសាស្ត្រ		
-រឿងអ្នកឥង្គាលរៀមស្ងួតត្រង់និងព្រះរាជធីតា	លោក ផេង-ត្រីវ ប្រែរៀបរៀង	១០៦៩
-រឿងទេវន្ទរបស់អម្រិតក្សត្រី ម៉ុក (តមក)	លោក ញ៉ុក-ថែម ពិនិត្យ	១០៧៩
-រឿងសោមកុក (តមក)	ឯកញ៉ា ន្ធ-កន ប្រែ រៀបរៀង	១០៨៤
-រឿងចៅយាយភ្លាំង	លោក ទៀង-តៃឈូន ប្រែរៀបរៀង	១០៨៨
-រឿងព្រេងនិងរឿងបុរាណនៃប្រទេសជប៉ុន	លោក ហ្ស៊ែលបឺយ៉ាងអាឡាយ រៀបរៀង លោក វ៉ាយ-ប៊ុក ប្រែ រៀបរៀង	១១០០
ផ្នែកកំណត់ទីប្រវត្តិការណ៍		
-ដំណើរទស្សនាការសហាវដ្ឋអាមេរិកនៃព្រះគេជីព្រះគុណព្រះពោធិវង្ស (តមក)	លោក ជា-ទង់ រៀបរៀង	១១០៧
-ពិធីបុណ្យបញ្ចុះអដ្ឋិធាតុបុគ្គការ	នៃលោក សាម-ម្ហាមុត នៅវត្តស្វាយមាស លោក សាម-ម្ហាមុត រៀបរៀង	១១១៤
-ពិធីបុណ្យឆ្លងព្រះសពសម្តេចព្រះឧទ្ទលិវិត	ទ្តមប្រិក្សាវត្តលង្កា លោក វ៉ាយ-ប៊ុក រៀបរៀង	១១២០
-វិចនានុក្រមសំស្ក្រឹត-ខ្មែរ (តមក)	ព្រះមហា ប៉ាងទាត់ រៀបរៀង	១១៣៣

មួយឆ្នាំមាន ១២ លេខរៀងៗ ជំរៃដោយ ៤.០០

KAMBUJASURIYA

Revue religieuse et littéraire éditée par
l'Institut Bouddhique

TABLE DES MATIERES

PARTIE RELIGIEUSE:

-Nidanasubhasita par Vén. *MAU-KHANN* 1047
-Lokadhippaya par *M.BOU-FO*. 1061
-Réflexion d'un Bouddhiste par *M.RAY-BUC* 1065

PARTIE LITTERAIRE:

-Le berger fidèle de la princesse traduit par *M. PHENG-CHRIV* . . 1069
-Histoire de Devanda de *M. MOK* (suite)
revue et corrigée par *M. NHOK-THEM* 1079
-Histoire de Samkok (suite) traduit par *M. NOU-KAN* 1084
-Légende de "Sieur **Croûte** de Riz" (suite) traduit
par *M. TIANG-TAY-CHHUN* 1088
-Conte et légende du Japon (traduction) par *M.RAY-BUC* . . . 1100

NOTES ET CHRONIQUES :

-Voyage du Vén. Huot-Tat aux U.S.A (suite) par *M.CHEA-TON* . 1107
-Fête d'ensevelissement des cendres au
Monastère de Svay-Méas par *M.SAM-LAMOUTH* 1114
-Obsèque National de Son Eminence *LOUIS-EM* Grand Consiller
de l'ordre Mahanikay par *M.RAY-BUC*. 1120
-Dictionnaire khmèr-Sanskrit- (suite) par Vén. *PANG-KHAT* . . . 1133

Prix d'abonnement annuel (comprenant 12 numéros): 230$00

ផ្នែកសាសនា

ជីវិតរបស់

ពិសោធរកមនុស្សល្អ

ព្រះមហា ម៉ៅ.ខាន់ (ឥន្ទវរិយោ)

ប្រមាំនុំព្រះត្រៃបិដកនៅពុទ្ធសាសនបណ្ឌិត្យ

រៀបរៀង

មនុស្សល្អ មិនមែនសំដៅយកត្រឹមតែមានរូបល្អ មានទ្រព្យ ច្រើន កើតក្នុងត្រកូលស្តុកស្តម្ភ មានយស មានអំណាចប៉ុណ្ណោះទេ គឺសំដៅយក មានអធ្យាស្រ័យល្អ មានសីលធម៌ខ្ពស់ក្នុងខ្លួន ។ ព្រោះមនុស្សរូបល្អ តែបើខ្វះអធ្យាស្រ័យល្អហើយ ក៏ប្រហែលគ្នាទឹងផ្កាឈើ ដែលមានតែពណ៌ខ្មៅស្រាយល្អ តែមិនមានក្លិនក្រអូប ។ តែបើមានពាំងរូបល្អ ទាំងអធ្យាស្រ័យល្អផង នោះតែងតែប្រសើរដូចផ្កាឈើ ដែលមានពាំងពណ៌ល្អ ពាំងក្លិនក្រអូប ។

មនុស្សមានអធ្យាស្រ័យល្អ ជាប្រភពនៃសេចក្តីសុខក្សេមក្សាន្ត ដូចអន្ទង់ទឹកដ៏ត្រជាក់ត្រជុំ ។ ព្រោះហេតុនោះ មនុស្សល្អ ទើបជាទីនិយមត្រេកអរ ជាទីស្រឡាញ់ពាក្យអាន ជាទីជ្រះថ្លា ទឹងជាទីគោរពបូជានៃជនទូ ទៅ ។

ការពិសោធន៍រកមនុស្សល្អ កំពុងដល់ការល្បងពិនិត្យមើលដំណើរប្រព្រឹត្តិ គឺពិនិត្យមើលកិរិយា អាការៈ កិច្ចការដែលធ្វើ ទើនស្តាប់តាក្យដែលនិយាយស្តី . . . ។

ថើរឃើញថាល្អ ថាត្រឹមត្រូវ មិនអាក្រក់ មិនគ្រំគ្រងឯ ក៏អាចស្គាល់ឃុនថាជាមនុស្សល្អ ព្រោះការប្រព្រឹត្តិល្អ ប្រត្រឹត្តិត្រូវ ជាស្នាមហូរចេញពីអធ្យាស្រ័យល្អ ផ្ទុយគ្នានឹងការប្រព្រឹត្តិអាក្រក់ ខុសគ្នឯ ដែលជាស្នាមសម្រាប់សំគាល់មនុស្សអ្នកមានអធ្យាស្រ័យអាក្រក់ ។

ប៉ុន្តែ ដំណើរប្រព្រឹត្តិ តាំងល្អ តាំងអាក្រក់នោះ មានប្រភេទនឹងជាន់ថ្នាក់ខុស ។ គ្នា ច្រើនបែប ច្រើនស្ថានណាស់ ដូច្នេះ, ការពិសោធន៍ក៏ត្រូវមានច្រើនបែបច្រើនស្ថានដែរ ។

និយាយតទៅនេះ សំដែងតួយ៉ាងនៃការពិសោធន៍មួយបែប ដើម្បីរកមនុស្សល្អ មានសីលធម៌ខ្ពស់ក្នុងខ្លួន ។

ពាក្យណាស៊ី ជារាជធានីនៃដែនកាស៊ី ជ្រោកដាមក្នុងរឿងព្រឹត្តិការណ៍ផ្សេង ។ តាំងតាំងពីបុរាណសម័យរៀងមក ឥឡូវនេះហៅក្លាយថា បេណារ៉ែស ទៅក្នុងអាណាខែត្រនៃប្រទេសឥណ្ឌា ។

មុនពុទ្ធកាលឡើងទៅ ជាយូរអង្វែង ក្រុងពាក្យណាស៊ី ធ្លាប់មានមហាក្សត្រសោយរាជសម្បត្តិជាមហិស្សរៈ ទ្រង់ព្រះនាមព្រហ្មទត្ត ហើយព្រះនាមនេះ ប្រហែលជាព្រះនាម នៃរាជវង្សមួយ ដែលមានមហាក្សត្រព្រះនាមដូច ។ គ្នានេះជាច្រើនអង្គ ត្រង់កន្សែត ។ មក ។

អ្នកនគរពោធិសាត់ ចាំងស្ងួត ព្រាហ្មណ៍ ទីឆ្ងាយហាមតែធំ ។ តែងបញ្ជូនបុត្រឲ្យទៅឯក្រុងតក្កសិលា ជាពុទ្ធានីនៃដែនគន្ធារៈ ដើម្បីឲ្យជ្រើសរើសមុខវិជ្ជាសិក្សា តាមសេចក្តីត្រូវការ ។

ព្រោះក្រុងតក្កសិលា ជាប្រភពនៃសិល្បសាស្ត្រទីឆ្ងាយធម្មតាផ្សេងៗ ហើយមិនមែនតែអ្នកនគរពោធិសាត់ទេ សូម្បីតែអ្នកនគរដទៃ ។ ទៀតក៏ច្រើនចូលទៅរួមសំណាក់សិក្សា នៅក្រុងតក្កសិលាដែរ ទាំងដឹងបានតទៅទៀតថា តក្កសិលា ជាក្រុងអត្ថក្រិតមួយ ក្នុងសម័យព្រឹទ្ធនាយនោះ ។

ក្រោយដែលបានសម្រេចការចេះដឹង តាមការគួរហើយ ទិស្សតដែលមកពីបរទេសចាំងឡាយ ក៏លាអាចារ្យវិលទៅកាន់មាតុភូមិ របស់ខ្លួនវិញ, ខ្លះជារដ្ឋបាលខេ (មកុដពន្ធកុមារ) ក៏បានខួលពន្ធសម្បត្តិគ្រប់គ្រងប្រទេសតព្រះវង្ស ខ្លះក៏បានជាពន្ធមហាមាត្យ ខ្លះជាកូនព្រាហ្មណ៍ ក៏បានជាពន្ធបុរោហិតតទៅ ។ ក្រៅពីបានខួលមុខតំណែងពន្ធការ ដូចពោលហើយ ខ្លះក៏តាំងគ្រឹះស្ថានសិក្សាផ្ទាល់ខ្លួន សម្រាប់ឃុំដែនដែលមិនចាប់ទៅសិក្សា ឯនគរតក្កសិលា អាចនៅសិក្សាក្នុងស្រុកកំណើតរបស់ខ្លួនក៏បានដោយបង់ថ្លៃឈ្នួលប្រចាំខែ.ខ្នាំ ដូនអាចារ្យ ឬខ្លះណា ដែលមានភូមិលំនៅនៅឆ្ងាយ ក៏យកខ្លួនទៅនៅបម្រើអាចារ្យផ្ទាល់តែម្តង, របៀបចាំងពីរយ៉ាងនេះ មិនខុសគ្នាពីការទៅសិក្សាឯនគរតក្កសិលាទេ ។

ចំនងនេះហើយ បានជានៅក្នុងសម័យពន្ធវង្សព្រាហ្មខត្តនោះ មានគ្រឹះស្ថានសិក្សាឯកជន តាំងនៅកន្លែងចំថ្នល់ខ្លះ ក្នុងសង្កាត់នានានៃទីក្រុងពោធិសាត់ តែមិនសូវសម្បើមដូចជានៅឯនគរតក្កសិលាទេ ។

តីនេះនៅស្ពាំ ឡាយតាត្រែរពាដាំង មានត្រែះស្ពានមួយខ្នង ធ្វើពីឈើប្រក់
ស្បឹង មានសភាពគ្រាំគ្រា ខំនង់ជាសង់មកប្រើនាំហើយ បីតនៅយ៉ាង
ប្រើរៀងតងតូម មានដើមចេក ដូង ស្លា ដើមខ្នុរ យ៉ាងច្រុបច្រុល ខំង
មានពេងត្រែតណាងទឹក ពីខាងក្រោយ ហើយមានក្រុងតាត់ផ្លែង ។ ទៀត
ត្បូងជាបេងពុំរួញយ៉ាងត្រសុំត្រសាយ ។ ក្បោះទៅខាងនេះខំងខាងស្ពាំ
អមប្រកម្ល់ ដែលចូលទៅពីខាងមុខ មានពេងស្ទឹកយ៉ាងវែងពីរខ្នង ដែរ
មុខរកគ្នា ម្ខាងជាអាសយដ្ឋាន (តំនែ្ងសម្រាប់ដេកនៅ) ម្ខាងទៀត
ជាតំនែ្ងសិក្សា មានទំព្លាសម្រាប់ហាត់ប្រាណ ខំងសួនបន្លែសម្រាប់
សម្រាកទប់រំភាយចិត្ត នេះជាបន្តោះ ។ បន្ទះក្តារខុំងពីលើមាត់ប្រកបូល
ក្រោមភ្នាង់ភ្លាវជាតិការៈនៃក្តួងតាតីព័ណ៌ខៀវខ្ចី បង្ហាញមុខគ្នោះទៅរកថៃ
ក្រុង ឃើញតួអក្សរថ្មោសៗ ចារកថា "ត្រែះស្ពានអាចារ្យខំសាធុមោក្ខ" ។

សាស្ត្រាចារ្យ ជាចាង់ហ្វាងនៃត្រែះស្ពាននេះ កន្លងំណាស់ប្រហែល
ជាមានវ័យជាង៩ពាក់កណ្តាលកន្លះហើយ លំនាំជាអ្នកទេសាភិខំណ្ឌាស
ភៃ តាងជាអ្នកមានអធ្យាស្រ័យអត់ធន មានសន្តានសប្បុរសប្រកបដោយ
មេត្តាករុណា ច្រើនជួយប្រយោជន៍ខំង់សេចក្តីសុខ ចំរើនដល់សិស្សពិត ។ ដូច
ជាកូនបង្កើតរបស់ខ្លួន ចរិយារបស់គាត់ថ្លៃថ្នូរឥតខ្ចោះ គាត់មិនដែលប្រព្រឹត្ត
អាក្រក់មុខ ជាដើមថា លេងស្រី ផឹកស្រា លេងល្បែងស៊ីសង ឬអំពើមោះ
ហ្មងអ្វីម្តង ឡើយ ព្រោះគាត់ប្រកាន់ថា មុខងារប្រៀបដូច
ខ្លួនឯងទើបបានបទសំខាន់ ហើយគាត់យល់ច្បាស់ថា ខ្លួនគាត់ដែលរស់ជាគ្រូ

អាចារ្យគេ គឺពុកជាមេពុទ្ធ ជាគំរូជាតួយ៉ាងសម្រាប់ឲ្យសិស្សខំឯកាយ
យកតម្រាប់តាម ។

ត្រង់នេះ គួរនឹកដល់ជំពូន្មានរបស់ព្រះសម្ពុទ្ធបរមគ្រូថា ធ្វើជាគ្រូ
ចាត្បាយគេ ត្រូវប្រកបដោយគុណសម្បត្តិ៨

១- ធ្វើខ្លួនឲ្យជាទីស្រឡាញ់ របស់សិស្ស,

២- ធ្វើខ្លួនឲ្យជួនចិត្ត គួរជាទីគោរពបូជារបស់សិស្ស,

៣- ត្រូវតម្រង់ខ្លួនឲ្យចំរើនឲ្លូជាធំសិស្សជាខ្លួច,

៤- ត្រូវទុកសិស្សហាប្រដៅខ្លួនសិស្ស មិនបណ្តោយឲ្យទុសខុច,

៥- ត្រូវអត់ខ្មេនពាក្យសំដី,

៦- ត្រូវនិយាយពាក្យជ្រាប មានហេតុផល មានប្រយោជន៍,

៧- មិនត្រូវដឹកនាំសិស្ស ឲ្យប្រកបការមិនគួរផ្សេង ។ ។

ទៅកន្លែងរៀនគារ នៃអាចារ្យខាងលើនេះ មានទិសត្រៃទៅសំណាក់
សិក្សាជាច្រើនឆ្នាំក់ ហើយច្រើនតែជាអ្នកនៅសិក្សា ដោយរបៀបខាង
ក្រោយ គឺទៅបម្រើអាចារ្យតំនួសថ្ងៃឈួស ។ សិស្សទាំងនោះ បាន
សិក្សាមកជាច្រើនឆ្នាំរហើយ ម្នាក់ៗ សុទ្ធតែមានចំណេះវិជ្ជាល្មមប្រើការ
បាន ទៅតែជាធំកន្លះទៀតទេ គេនឹងបញ្ចប់ជីវិតាពសិស្ស ចេញទៅ
តាំងជីវិតាពថ្មី តាមសេចក្តីចេះដឹង ខ្នាំងសេចក្តីអត់អាចរបស់គេតទៅ ។

ដំណើរនេះ នាំឲ្យអាចារ្យទិសាបាមោក្ខ រំពឹងគិតចង់ផ្តុកផ្តាក់ត្រង
សំណាងនៃកូនស្រីរបស់គាត់ ព្រោះនាងជាកូនតែមួយគត់ មានវ័យគ្រប់
ការក្នុងឆ្នាំនេះហើយ គាត់ចង់រៀបចំឲ្យស្រេច ព្រោះឃើញថា សង្ខារ

ជាសភាពមិនខឿនខាត់ តែងប្រែប្រួលទៅដោយឆាប់រហ័ស មិនអាចកំ-
ណត់បាន, ខ្លួនគាត់សោតក៏ចូលក្នុងវ័យជរាហើយ ត្រែងជួនឥតពីគាត់
ទៅ ត្រែងសំណាងកូនស្រីគាត់ទំនឹងមិនជឹងជាយ៉ាំងណា, គាត់ដឹងច្បាស់
ថា ការរៀបចំខុកជាក់កូនទៅ ឲ្យមានត្រែងសំណាងសមគួរ ជាបន្ទុក
របស់មាតាបិតា ដែលបានបង្កើតមក បើមានផ្លូវ មានឱកាសហើយ មិន
ត្រូវបណ្តោយឲ្យកូនៗរបស់ខ្លួនប្រព្រឹត្តទៅតាមយថាកម្មទេ . . . ។
ដោយត្រង់គាត់យល់ឃើញថា សិស្សគាំងអម្បាលនេះ សុទ្ធតែបានសម្រេច
សិល្បសាស្ត្រជាន់ខ្ពស់ គេបម្រុងទុនប្រឡងចេញ ក្នុងពេលខាងមុខឆាប់ៗ
នេះ អនាគតរបស់គេ ទំនងមិនអូនថយឡើយ, ងាយណាស់...ព្រោះ
គេក៏សុទ្ធតែជាសិស្សរបស់គាត់ស្រាប់ ។

ជាធម្មតាទេ អ្នកដែលមានកូនស្រី គេតែងតែតវ៉ែនឆ្ងាយដល់ឪឡាសនា
នៃកូនស្រីរបស់គេ មុនទីណរៀបចំមង្គលការ ឲ្យដល់កុលបុត្រណាម្នាក់
គេត្រូវជ្រើស ឲ្យតែអ្នកដែលបានហាត់រៀន មានចំណេះវិជ្ជា មានយស
ស័ក្តិ ឬមានទ្រព្យសម្បត្តិ ព្រោះគេសង្ឃឹមថា បើបានទៅជាគូគ្រែងនៃកុល-
បុត្រដូច្នេះ កូនស្រីគេនឹងមានភ័ព្វសំណាង បានសេចក្តីសុខសុភមង្គល
ទៅថ្ងៃក្រោយ ។ គេមិនសុខចិត្តឲ្យទៅកុលបុត្រណា ដែលឥតបាន
រៀនសូត្រ ឥតមានចំណេះវិជ្ជាអ្វី ក្នុងខ្លួនសោះមានទេ ព្រោះបុរសប្រភេទ
នេះ កម្រនឹងចិញ្ចឹមរក្សាកូនស្រីគេ ឲ្យបានសុខសួស្តី ប្រើនតែនាំឪឡាសនា
កូនស្រីគេឲ្យធ្លាក់ដុនជាប ំបាកគាកយ៉ាក ។

គំនិតនេះត្រូវហើយ, ប៉ុន្តែបើប្រៀនទៅលើបុរសអ្នកបះនោះ ជាមនុស្សខ្វះចរិយាសម្បត្តិ តើមនុស្សពាលឥតពូជ ខូចគាប ប្រព្រឹត្តតែអនាចារ អច្ចាយមុខស៊ីផឹកចាយវាយ ឥតបើគិតវិញ តើវាសនាកូនស្រីនោះ វាទីនឹងទៅជាយ៉ាងណា? ត្រង់នេះ បើចាញ្ចួយ៉ាងនារីអត់ភូមកពណិនាជនោះ ទីនឹងឃើញរឿងច្រើន គួរឲ្យសង្វេគសូតចិត្ត ។

ព្រោះហេតុនោះ គេត្រូវពិចិត្យ អង្កេតមើលពូជវង្សជនទៀត តាមពាក្យបូពណ៌ថា " ធ្វើស្រែឲ្យមើលស្មៅ ពុកជាគ់កូនចៅ ឲ្យមើលផៅសន្តាន" ។

ប៉ុណ្ណោះ ក៏នៅមិនទាន់អស់ហើយទៀត, ព្រោះតែមនុស្សខ្វះការស្រ័យការបះដឹង ទីនឹងបានខ្វះការអប់រំស្អ ពីគ្រូចា អាចគ្មានទិស្សយ ពីអាក្រក់ ទៅល្អក៏មានច្រើន ។ សូម្បីមនុស្សល្អ តែខ្វះការអប់រំ ឬអាស្រ័យការសេពគប់ពុំសូវជាខាងគ្រោយ ក្លាយទៅមនុស្សអាក្រក់ក៏មានច្រើនដែរ ។ ដូច្នេះ, សំខាន់គេត្រូវពិចារណា មើលចរិយាវេស់សាមីខ្លួនជាស់តែម្តង... ។

ព្រោះហេតុនោះ អាចារ្យទិសាបាមោក្ខ គិតតទៅទៀតថា តើគួរទីនឹងលើកកូនស្រីទៅ ឲ្យជស់ជិស្សប្រុសណា ?

គាត់មិនមែនមិនដឹងទេ, សិស្សទាំងអប់ ពតមែនតែពីដេមជាមនុស្សចិលខូច មានកិរិយាមារយាទអាក្រក់ខ្លះ ប៉ុន្តែ ដោយសារបានមកនៅសិក្សាទីនឹងគាត់ ជាយូរខ្នាំ ក្រៅពីបានបង្ហាត់បង្រៀនវិជ្ជាការឲ្យបះបំ គាត់ថានាំងអប់រំប្រៀនប្រដៅ ឲ្យទៅជាមនុស្សល្អរៀបរយសឹងតែប្រហែលៗគ្នាអ ទៅហើយ ។

ត្រង់នេះ បញ្ជាក់ឲ្យឃើញថា គាថាប្រៀបជាមេកូនោះ មិនមែនជាគ្រាន់តែបង្រៀនសិស្សតែត្រឹមចំណេះវិជ្ជាមួយចំណែកទេ គឺបង្រៀនទាំងផ្នែកចរិយាផង ដែលទាំងឲ្យសិស្សបានទទួលទាំងវិជ្ជាសម្បត្តិ ទាំងចរិយាសម្បត្តិ ដើម្បីតម្រូវទីផ្នត់គំនិតថា:

ត្បូងតេជ្រលេចតណ្ហិល្អទុតាស គាស្រាយមានមាសជាគ្រឿងទ្រូ
សិល្បៀសខ្លឹងវិជ្ជាដូច្នេះលំអ ឆាស្រាយគ្រឿងទ្រូតីបរបោ (១) ។

យ៉ាងនេះគឺមែនហើយ, ប៉ុន្តែអាចារ្យទំនាក់ទំនងទៅនឹងសិស្សណា ដែលមានសេចក្តីល្អដោយធម្មជាតិ (ល្អតាមធម្មស្រាយ) គាល់ពិសោធទៅឃើញ គាត់ទីនឹងរៀបចំបុត្រ ឲ្យរៀងតាមត្រូវនៃអ្នកនោះតទៅ ។

ក្រោយដែលបានជញ្ជាំងលំនិតគស់ពេលជាច្រើន អាចារ្យទំនាក់ទំនងអ្នក កំសម្រេចយកយោបល់មួយ ដើម្បីជាតំណពិសោធ ។

១៥ ថ្ងៃក្នុងនោះ, នៅពេលព្រលឹមមួយ.ស្ទះតាំងតំលាន់ឮខ្ទើង ជាសញ្ញាហៅសិស្សមកប្រជុំពិសេស ។

សិស្សទាំងអស់ដែលធ្លាប់តែគោរពបទបញ្ជានៃអាចារ្យ គាល់ឮស្ទះតាំងហើយ ទោះបីខ្លះណាកំពុងមានធុរៈតិច្ចកាអ្វីប្លែកម្រងនឹងទៅណា...គឺអាត់ខានសិនដែរ ម្តីម្នាក់មកវៀចចំខ្លួនច្រាណ ប្រញាប់ប្រញាល់ចូលទៅកាន់ទីប្រជុំ ។ មុននឹងអង្គុយចុះ តាមទីកន្លែងរៀងខ្លួន, សិស្សទីមួយ។ សុទ្ធតែលំនោមកាយបន្តិច។ ជាគំនួសដែងសេចក្តីគោរព ចំពោះអាចារ្យ។

(១- កំណាព្យរបស់អ្នកស:សេរ ។

ក្រោមពន្លឺភ្លើងដ៏ចិញ្ចាច សភាពស្ងប់ស្ងៀម, ព្រោះលោកបានថា ដួច
ជុំគ្នា ហើយសិស្សទាំងអស់ កំពុងប្រុងស្តាប់ការណែនាំពីគាថ្យ ។

"កូនសំណព្វទាំងអស់គ្នា, ល្អហើយ! ការដែលពួកអ្នកបានគ្រាំនៅ
សិក្ខាទីនេះ ដរាបដល់បានសម្រេចសិល្បសាស្ត្រនេះ ពេលសិក្ខា
បានចប់ទៅហើយ បានជាយើងហៅពួកអ្នកមកប្រជុំ ក្នុងឱកាសនេះ "
សំឡេងគាថ្យទៅកាន់សិស្ស ។

" គួរឱ្យសរសើរ ដោយតាំងពីមកដល់ ពួកអ្នកមិនដែលបង្អង
ដំណោះ បង្កើតរឿងហេតុអ្វីនាំឱ្យសៅហ្មង ទុស្សាន ឬលេងឆ្កួ រវាងមិត្ត
អ្នក, រវាងយើង, រវាងគ្រូសារយើង ហួតដល់អ្នកជិតខាងយើង, ពួកអ្នក
បេះធ្វើខ្លួនឱ្យងាយស្តីប្រដៅ បេះបង្កើសាមគ្គី បេះស្រឡាញ់ពប់កេគ្នា បេះ
រក្សាគ្នា ស្គាល់ទុក្ខធុរៈគ្នា ខំធ្វើបេះជួយយកការគ្នា រីស័យដូចបងប្អូន
បង្កើត ,, ។

យើងពេញចិត្តណាស់! យើងត្រេកអរណាស់ ដោយពួកអ្នក, ក្រៅ
ពីខំយកចិត្តទុកដាក់សិក្ខា កំហាត់ធ្វើយច្រើន ខំជម្រើយើង ជួយប្រកប
កិច្ចការយើង បេះប្រកាន់ថាជាសង្គមមួយ សំបាច់មួយរួមរស់ជាមួយគ្នា
ដោយសេចក្តីសុខសាន្ត បេះជួយរក្សា ជួយរក ជួយជួសជុល ហួតដំណាក
ដំណបង់ មិនធ្វេស មិនបណ្តោយ មិនប្រថាំ មិនមើលចំណាំគ្នា.." ។

"តុ! ពេលនាងមុខយ៉ាងនេះ ឪពេលដែលពួកអ្នកត្រូវឃ្លាតពី
សំណាក់យើងទៅ, ដើម្បីជាតស្តូតាង ជាអនុស្សាវរីយ៍ នៃការសរសើរ.
នៃចិត្តត្រេកអរបេះយើង, ក្រៅពីសិល្បវិទ្យាដែលយើងបានបង្ហាត់បង្រៀន

មកនេះ, ក្រៅពីសព្វសាធុការពារដែលយើងគាំងចិត្តប្រសិទ្ធឡើង ដើម្បីសេចក្តីសុខសួស្តីដល់ពួកអ្នកតវ៉ា, ពួកអ្នកក៏ចាន់ដឹងយើញនឹងភ្នែកស្រាប់ហើយយើងគ្មានអម្រស់អម្រម្ងាំសេស ចែកដាច់ពួកអ្នកឲ្យចាន់ត្រប់គ្នាខ្លះ។

" ប៉ុន្តែ...យើងមានកូនស្រីមួយ ជាថ្លើមប្រមាត់របស់យើង ដែលល្អអាក្រក់យ៉ាងណា ពួកអ្នកក៏ធ្លាប់ស្គាល់ចាប់អានស្រាប់ហើយ យើងបំណងនឹងឲ្យនាងដល់ពួកអ្នក ព្រោះយើងមានសេចក្តីស្នេហា ហើយសង្ឃឹមពុកចិត្តលើពួកអ្នក ដូចកូនបង្កើត... ។ តែថា ពួកអ្នកក៏សុទ្ធតែជាទីស្រឡាញ់របស់យើង ដូចៗគ្នា យើងនឹងលើកឲ្យចំពោះប្អូម្នាក់ៗ មិនចាន់ហើយនឹងឲ្យគាំងអស់គ្នាក៏មិនកើត ព្រោះកូនស្រីយើងតែមួយ,.." ។

" ដូច្នេះ បើសិស្សណាម្នាក់ មិនចំពោះប្អូ អាចចេញទៅរកបរស់មានតម្លៃ ដូចគ្រឿងមាសប្រាក់សំពត់អាវ ប្តូរតម្លៃ ។ ជាសម្បត្តិទ្រព្យរបស់ញាតិសន្តាន-ឯកជនរបស់ខ្លួន ដែលគ្មានគេដឹងឃើញសោះ យកមកប្រគល់ឲ្យយើង ចាន់ចំនួនច្រើនជាងគេ កូនស្រីនេះ យើងនឹងប្រគល់ឲ្យដល់អ្នកនោះ ដើម្បីជាតួគ្រងតទៅ " ។

គ្រាន់តែចប់ពាក្យអាចារ្យក្លាម សិស្សគាំងអស់គ្នា ក៏មានទឹកមុខពេញពោរ ដោយសេចក្តីក្រេវក្រេសស្រស់ស្រាយ ថ្លៃកតីធម្មតា ។ ព្រោះគេចាន់ខ្វល់ពាក្យសរសើរ មួយអន្លើដោយសេចក្តីស្រឡាញ់ពុកចិត្តយ៉ាងអស់អញ្ញាពីអាចារ្យ សូម្បីអ្នកខ្លះមានសេចក្តីរង្គើស សង្ស័យនឹងខ្លួនឯងក្រែងមានការប្រព្រឹត្តិខ្លាំងលើសលស់ បន្តិចបន្តួចពីពេលមុន ។ មក ក៏រលាយបាត់សូន្យពីសន្តានចិត្ត ក្នុងរំណៈនោះឯង ។

តែចំណុចដែលនាំឲ្យគេសប្បាយចិត្តជាចំផុតនោះ ត្រង់ដែលថា "ឲ្យកូនស្រីជាតួស្រែករ" ព្រោះគេសុទ្ធតែធ្លាប់សំគាល់ឃើញទឹងក្អែកជាយូរមកហើយថា ៖

ក្រៅពីមានរូបឆោមអតខាស់ក្អែក, នាងជាស្រីមានបញ្ញាវៃឆ្លាត ចេះការងារមេផ្ទះ គ្មានសល់ចន្ទោះ តឹងរ៉ឹងម្ហូបចំណីយ៉ាងឆ្ងាញ់ពិសា, ចេះគ្រាញ្ញវៃ; ចេះគាត់ ដេរ ថ្មាំ ជុល ចេះរៀបចំផ្ទះសំបែង ឲ្យបុះរបៀប។ មិនតែប៉ុណ្ណោះ នាងចេះអក្សរលេខទឹងវិជ្ជាការផ្សេង ។ ទៀត ដែលធ្លៀតសិក្សាពីបិតានាង ជាមួយទឹងទិសត្រៃពាង ឡាយ ។ នាងចរិយាសោត នាងជាព្រហ្មចារិនី គ្រប់ល័ក្ខណ៍ មានកិរិយាបុគ្គាទឹងខ្លួន មិនមានមាយាឡែះឡោះ, នាងមានការពេញចិត្តចំពោះពួកបិស្សុ ដែលនៅអាស្រ័យក្នុងផ្ទះនាង ដូចជាបងប្អូនប្រុសរបស់នាងដែរ នាងមិនដែលសំដែងការប្រមាថមើលងាយ ឬប្រព្រឹត្តអសុពេះខ្មោះខ្វះ មិនគួរសមឡើយ, ទឹកមុខនាងញញឹមប្រឹមប្រិយ, សំដីនាងពីពេះឆ្អែមស្លែមជានិច្ច ។ ពួកក្រៅ សឹងស្ងើចសរសើរនាងពាល់មាត់ថា នាងមិនចេះអីមអៀម ឬឆ្មើងឆ្មៃទេ ប៉ុនប្រសប់ ក្នុងការជ្រាស្រ័យចាក់ទងពាក់ព័ន្ធ, ស្រែការនាង គម្រមានតាំណាដូច ។ នាងជាសិរីនៃវង្សត្រកូល ដូចផ្កាជាលំអនៃទីសួន ..... ។

ពិតមែនតែធ្លាប់សំគាល់ឃើញដូច្នេះ ប៉ុន្តែពីមុន ។ មក សិស្សទាំងឡាយ គ្រាន់តែគោតសរសើរក្នុងចិត្តត្រង់ៗ គេទុកនាងដូចជាប្អូនស្រីបង្កើតរបស់គេ ព្រោះគេគោរពគាចារ្យ ដូចជាឪពុក ។ ម្ដងនេះ ទឹក

ចិត្តគេបានប្រែពណ៌ប្លែកពីខាងដើមស្រេចឆ្ងល់ ម្នាក់ៗ សុទ្ធតែប្តេជ្ញាចិត្តថា ខ្លឹមផ្តាច់អធ្យាស្រ័យគាបសង្កត់ ខ្នួលយកនាងជាគូវាសនាវ ឱ្យខានតែបាន តទៅក្លែចតែងដល់ពាក្យថា "ទៅលួចព្រួតត" ជាមិនក្រសោះតែម្តង ។

ស្អែកឡើង តាំងពីព្រឹកដរាបល្ងាច, ពីព្រលប់ដល់អធ្រាត្រ អាចារ្យ ទិសាបាមោក្ខ រវល់តែខ្នួលត្រឿងមាស ប្រដាក់, សំពត់ភាវ ខ្លឹងរបស់ ផ្សេងៗ ពីពួកសិស្ស យកមកវៀបទុកជាគំនរដោយឡែកៗ តែគ្នា ហើយ ទៅលើចំណែកខ្លួយ ។ មានបំនងស្មាគជាសញ្ញា ដើម្បីកុំឱ្យច្រឡំគ្នា ។

ការណ៍សម្គាល់ដូចនេះ ប្រសិនបើ អាចារ្យទិសាបាមោក្ខ ជាអ្នកមាន អធ្យាស្រ័យអាក្រក់ ល្មោភខ្លឹងទ្រព្យសម្បត្តិ សាងសេចក្តីសុខរបស់ខ្លួន លើសេចក្តីទុក្ខសោករបស់អ្នកដទៃ· ម្ល៉េះសមខ្លឹងទាំងឱ្យមានបានយ៉ាងសន្ធឹក ពៃនេះផ្ទួយទៅវិញ ព្រោះលោកជាម្នាក់មានឧត្តមគតិប្រកបដោយការចេះ ដឹង ជាអ្នករក្សាតម្លៃសេចក្តីល្អទុក ដូចអំបិលរក្សាសាច់ប្រៃ ជាអ្នកមាន អធ្យាស្រ័យត្រជាក់ ដួងចិត្តមិនតែមួយចំណែក ។

តាមបណ្តាយមហាវិថី ដែលសុខ្លឹងគាត់ទ្រុងភាពណាស៊ី ពីខាង ស្តាំទៅខាងជើង តាមខាងក្រោយព្រះពជនវិសេទ រហូតដល់ជាយក្រុង, ឆ្ងាកទៅខាងឆ្វេងដៃ ឃើញគេហស្ថានឈើមួយខ្នង យ៉ាងធំខ្ពស់ ហើយ ពាសពាស់ មានផ្ទះក្បឿងច្រើនខ្នងទៀត អមសងខាងជាបរិវារ, បន្តោះពី ផ្ទះមួយ ទៅផ្ទះមួយទៀត មានសួនត្រួយ៉ាងស្រស់ប៉ែប្រៃ មានក្តូជាតិជា របងព័ទ្ធជុំវិញ រួមជាភូមិមួយយ៉ាងស្អាតស្អំ ។

តាំងពីព្រលប់រហូតដល់យប់ជ្រៅ, ខ្មៅគេហស្ថានធំនោះ ឃើញភ្លើងភ្លឺ ឃើញមនុស្សអ្នកអរ ឮសូរសំឡេងនិយាយសើច ។ ចៃដន្យសម្បុរថ្លៃពីសព្វមួយជង ។ នៅកណ្តាលមនុស្សប្រុស.ស្រីក្មេងចាស់ជាច្រើននាក់នោះ ឃើញប្រុសកម្លោះម្នាក់ រូបពងស្អាតជាត សម្បុរពណ៌យ៉ាងសមរម្យ កាពជាអ្នកចេះដឹងយ៉ាងជ្រៅជ្រះ ដូចជាកំពុងពណ៌នាដំណើរសុទ្ធតែ ទំនងរឿងរឿនសូត្រ ត្រង់បម្រុងមនុស្សទាំងនោះ តែទឹកមុខគេ ហាក់ដូចជាមានជាប់ចិត្តទំនឹងអាម្មណ៍អ្វីមួយ ដោយឡែកផ្សេង ។

បុរសនេះ គឺជាកូនព្រាហ្មណ៍ម្ចាស់គ្រួសារនេះ ដែលបិតាបានបញ្ជូនឲ្យទៅសិក្សា ក្នុងសំណាក់អាចារ្យខ្ញុំសាជាមោក្ខតាំងពីក្មេង ។ មនុស្សទាំងអស់នោះ គឺជាមាតាបិតាទំនងបងប្អូនរបស់គេ បានមកជួបជុំសម្តែងសេចក្តីអបអរសាទរ ព្រោះដឹងថា គេបានសម្រេចសិល្បវិជ្ជាចេញពីសាលាមកថ្មី ។..... ។

អ្នកទាំងអស់ គិតតែពីនាំគ្នាសប្បាយចិត្ត ឥតខ្វល់ណាមួយទឹកសង្ស័យថា កូនខ្មៅនៃគ្រួសារនេះ មានគំនិតអាថ៌កំបាំងអ្វីមួយ ដែលបាត់ថាជាអ្នកស្អាតទឹងសេចក្តីស្រឡាញ់ពុកចិត្តរបស់ខ្លួនឡើយ ។ មានតែវាម្តង ពីរដងហើយ បងប្អូនដែលមកពីផ្លូវឆ្ងាយ ដោយស្ទើរតែលទឹងដោយការលើកអាល័យ មិនទាន់គស់ចិត្ត ឥរិយាត្រឡប់ទៅផ្ទះវិញទេ ទាល់ថាគ្នាច្រើនហើយ សុទ្ធតែបងប្អូនបង្កើត គ្មានជាមិត្តក្រៃឥតព្តាយអ្វី ក៏នាំគ្នាដោះការ ខំហូ ខ្មៀត ខ្សែក ខ្សែក្រវាត់ទ្រាក់ ទឹងសំពត់អាវស្អុ ។ ជាក់ក្តងឥតតុខ្លះ ពួរខ្លៅដញ្ជាំងខ្លះ ខ្មៅសសៅខ្លះ ខ្លះជាក់កូនសោខ្លះ សោហិច សោខ្ចូ

នៅក្នុងហោប៉ៅអាវដែលព្យួរនោះ ។ រួចពាល់ហើយលត់ភ្លើង នាំគ្នាចូលនិទ្រាវៀងខ្លួន ។

ការជួបជុំនៃក្រុមញាតិ ជាហេតុនាំឱ្យសុខក្សេមក្សាន្តចិត្ត ។ ផ្ទុយទៅវិញ មាណពជាប្អូនពៅនៃត្រកូល ឥតមានសេចក្តីក្សាន្តចិត្តបន្តិចបន្តួចទេ ចិត្តគេមមៃចាំឱ្យតែមានឱកាស ឃើញផ្លូវភ្លោះ ត្រូវនឹងបំណងគេតែម្តង កន្ទុយភ្នែកគេចេះតែលបតន់ំតៃ កំណត់ចំណាំទីកន្លែងនៃទ្រព្យរបស់ទាំងនោះ គិតថា ដល់ពេលនិទ្រាស្ងាត់ គេនឹងលបលួចរបស់សំខាន់ៗយកទៅលាក់នៅកន្លែងណាមួយ ដែលផុតនរណាសង្ស័យ ហើយស្មែកឡើង នឹងបណ្តោះនាំយកទៅជូនចាស្យ . . . ។ ឃើញផ្លូវហើយដេកញញឹមតែម្នាក់ឯង ។

ខ្ញុំតាមមានកំលាំងណាស់ហ្ន៎ ! អាចនាញទឹកចិត្តមនុស្សដែលមានវិជ្ជាគេញ៉ាងខ្លួន មានទិស្ស័យជាពោធិសត្វឱ្យនឹងតែអាប់អួរ . . . ។ គួរប្រយ័ត្នគួរជឿនាន់ . . . ទូវាគេសារបស់តាម . . . ។

. ដោយយប់យូរ យន់ភ្នំងងឹតពេក ហើយដោយអត់ងងុយពីយប់មុនមកខ្លះផង គេក៏ច្រាសខ្លួនលក់មួយស្របក់ៗ ក្នុងខណៈកំពុងលក់នោះ ជំនោរឡើងកណ្តាលភក្ត្រ នៃចុងគិម្ហរដូវ បក់ចូលតាមច្រកបង្អួចដែលបើកចំហរនឹងតាមចន្លោះនោងផ្ទះ មកបោកសង្កែលកាយនៃមាណពកម្លោះ ឱ្យរហើយត្រជាក់ បំបាត់កំដៅស្អុះស្អាប់ ដួចនុសបទិព្វ ជ្រាបចូលទៅក្នុងសាច់ឆ្អឹងកាយ បន្ទុបពិសពេគឱ្យជាសះស្បើយ . . . ។ (មានត)

លោកាធិប្បាយ

(សោឡសបញ្ហា)

លោក ប៊ូ-ប៊ូ រៀបរៀង

អ្វីឈ្មោះថា លោក ?

ខន្ធ ក៏ឈ្មោះថាលោក ។ អាយតនៈ ក៏ឈ្មោះថាលោក ។ ធាតុក៏ឈ្មោះថា លោក ។

ខន្ធទាំង ៥ គឺ រូប , វេទនា , សញ្ញា , សង្ខារ , វិញ្ញាណ,- ឈ្មោះថា ខន្ធលោក ប្រែថា លោកគឺខន្ធ ។ អាយតនៈ ១២ ខាងក្នុង ៦ គឺ ចក្ខុ , សោត , ឃាន , ជិវ្ហា , កាយ , មនៈ, ខាងក្រៅ ៦ គឺ រូប , សំឡេង , ក្លិន , រស , របស់ដែលគប្បីពាល់ត្រូវដោយកាយ , ធម៌ដែលគប្បីដឹងច្បាស់ដោយចិត្ត នេះឈ្មោះថា អាយតនៈលោក ប្រែថា លោក គឺអាយតនៈ ។ ធាតុ ១៨ គឺធាតុមួយៗ មានប៉ុ ។ គឺ ចក្ខុធាតុ , រូបធាតុ , ចក្ខុវិញ្ញាណធាតុ ៣ នេះចាត់-ជាពួក ១ ។ សោតធាតុ , សទ្ទធាតុ , សោតវិញ្ញាណធាតុ ៣ នេះចាត់ជាពួក ១ ។ ឃានធាតុ , គន្ធធាតុ , ឃានវិញ្ញាណធាតុ ៣ នេះចាត់ជាពួក ១ ។ ជិវ្ហាធាតុ , រសធាតុ , ជិវ្ហាវិញ្ញាណធាតុ ៣ នេះចាត់ជាពួក ១ ។ កាយធាតុ , ផោដ្ឋព្វធាតុ , កាយវិញ្ញាណធាតុ ៣ នេះចាត់ជាពួក ១ ។ មនោធាតុ , ធម្មធាតុ , មនោវិញ្ញាណធាតុ ៣ នេះចាត់ជាពួក ១ បី ៦ ដង រួមជា ១៨ ឈ្មោះថា ធាតុលោក ប្រែថា លោក. គឺ ធាតុ ។ លោកគឺខន្ធ , អាយតនៈ; ធម៌ធាតុនេះ មានសភាវៈដែល .

ប្តូរគ្នាសព្វគ្រប់ដើមដំណើរ, ជារបស់មិនទៀង, ជាទុក្ខ, មិនមែនខ្លួនក្រាណាទេ។ ពាក្យថា "លោក" នេះជាភាសាបាឡី បានន័យថា សភាវៈធម្មជាតដែលកើនកើត, តែងវិនាសរៀយ។ ឬដែលបាត់។ ឃើញ។ តីដែលកើតមានហើយបាត់។ ហើយកើតមានឡើងវិញ តាមកាល ។

បើចង្អុលទៅឃើញរូបកាយរបស់លោក សំដៅយក ដី, ទឹក, ភ្លើង, ខ្យល់, អាកាស, មនុស្ស, សត្វ ទូទៅគឺឯអស់។ ហានមនុស្ស, ហានសួគ៌, ហានព្រហ្ម, ហាននរក, ហានប្រេត ។ល។ ជារូបកាយរបស់លោក ។

ប្រជាជនជាតិខ្មែរយកពាក្យ "លោក" មកសន្មតជាភាសានិយាយគ្នាដោយគោរព សម្រាប់និយាយដំនួសឈ្មោះមនុស្សថ្នាក់ខ្ពស់ជាងខ្លួនឬថ្នាក់ស្មើនឹងខ្លួន ដែលត្រូវនិយាយទៅគេ ដូចជានិយាយថា "លោកអញ្ជើញទៅណា? លោកបៅហ្វាយ, លោកគ្រូ, លោកនាយ, លោកវត្តុក, លោកតា, លោកយាយ, លោកមា, លោកកូយ..." ។ សូម្បីគេទុកឪសក៏ហៅ (លោក) ដែរ ដូចជានិយាយថាខ្ញុំមិនឲ្យលោកឆាន់ ។

កាលបើយើងបានស្គាល់រូបកាយលោកច្បាស់លាស់ហើយ យើងត្រូវស្គាល់ធម៌របស់លោកទៀត ដែលតាមភាសាបាលីខាងពុទ្ធសាសនាហៅថា "លោកធម៌" ប្រែថា "ធម៌សម្រាប់លោក" គឺការ, សណ្ឋាប់ធ្នាប់ ឬធម្មតា របស់សត្វលោក។ ក្នុងច្បាប់ពុទ្ធសាសនាថា លោកធម៌មាន ៨ យ៉ាង គឺ ๑-លាភៈ ការបាន, ๒- អលាភៈ ការខានបាន ឬការខាតបង់, ๓- យសៈ ការមានយសស័ក្តិ, ๔- អយសៈ ការមិនមានយសស័ក្តិ ឬការថ្នាក់យសស័ក្តិ, ๕-និន្ទា ការតិះដៀល, ๖-

បសំសា ការសរសើរ, ៧- សុខៈ ការជាន់សុខ, ៨- ទុក្ខៈការជាន់ទុក្ខ ។

បើលោកធម៌ ៨ ប្រការនេះណាមួយ កើតមានឡើងដល់ខ្លួនយើងហើយ, យើងត្រូវពិចារណា ឲ្យឃើញថាជារបស់មិនទៀង, ជាទុក្ខ, មានសេចក្តីប្រែប្រួលជាធម្មតា គឺថា បើយើងជាន់សុខហើយ, ប្រែជាជាន់ទុក្ខវិញ ក៏មាន ។ យើងត្រូវដឹងតាមការពិត របស់ធម្មតាលោកកុំឲ្យលោកធម៌ណាមួយគ្រប់សង្កត់ចិត្តរបស់យើងបានគឺយើងកុំត្រេកត្រអាលនឹងអារម្មណ៍ដែលជាទីពេញចិត្ត, កុំទោមនស្សនឹងអារម្មណ៍ដែលមិនពេញចិត្តឡើយ ។

អ្នកណាមិនបានគិតពិចារណាឲ្យដឹងថា លោកធម៌ជារបស់មិមទៀងទាត់តែងប្រែប្រួល ។ អ្នកនោះនឹងបានសេចក្តីក្សោភអន្ទះអន្ទែងជាតិឬទ្រព្យសម្បត្តិជាមិនខាន ។ សូមគ្នាតែយូរនឹងធាប់ប៉ុណ្ណោះដូចមានអតីតនិទានតទៅនេះ ៖

សម័យថ្ងៃមួយ ព្រះជាទេវរាជបាដទ្រង់យាងទៅក្រសាលទឹកបានមានសត្វបង្កួយមួយ ចុះពីដើមតរមក ធ្វើក្បាលងក់ងាក ។ ងក់ងើក ។ ព្រះរាជាទ្រង់ត្រាស់សួរថា បង្កួយនេះវាធ្វើអ្វី ? ព្រះមហោសថកុមារក្រាបបង្គំទូលថា សត្វបង្កួយនេះវាគោរពព្រះអង្គ ។ ព្រះរាជាមានព្រះរាជហឫទ័យត្រេកអរ បង្គាប់តាមាត្យឲ្យទិញសាច់ ឲ្យបង្កួយនោះស៊ីតែពីរថ្ងៃ ។ ដល់ថ្ងៃទីបី តាមាត្យរកទិញសាច់មិនបាន កំយកមាសមួយកែវដំឡៃស្មើនឹងសាច់ ទៅបំពាក់នៅកបង្កួយ ។ ឯបង្កួយនោះ លុះបានមាសពាក់ហើយ ក៏គិតឃើញថា អញក៏មានមាសពាក់ ស្តេចក៏មានមាសពាក់ដូចគ្នាដែរ ចាំគោរពស្តេចធ្វើអ្វី ។ សម័យក្រោយមក លុះស្តេចយាងដល់ទីនោះ បង្កួយកើតអស្ចារ្យមានប្រការខ្លួន ធ្វើបុកក្រអឺតក្រទម ។ ព្រះ

មហាក្សត្រែនឹកឆ្ងល់ ទើបទ្រង់គ្រាស់សួរព្រះមហាសថកុមារ ។ គាត់ក្រាបទូលថា សូមទ្រង់ព្រះមេត្តាប្រោស ជាមើលឆាយព្រះអង្គ ព្រោះអាមាត្យបានបំពាក់មាសឲ្យរាប់ពន្លិចប៉ុណ្ណោះ ។ ព្រះរាជាទ្រង់ឮលំនឹងសត្វបង្គួយនោះ ទ្រង់បង្គាប់ឲ្យអាមាត្យបណ្តេញបង្គួយតែវិនាទីនោះទៅ ។ ឯបង្គួយក៏ដល់នូវសេចក្តីវិនាស ខូចខាតលាភ ព្រោះតែដំឡើងអស្ចារ្យនេះ ប៉ុណ្ណោះឯង ។

រឿងនេះមានក្នុងមហាសថជាតក ។

រឿងសត្វបង្គួយខូចខាតមាស ព្រោះតែលោភធម៌ត្រូបសង្កត់យ៉ាងណា ធម្មតាមនុស្សដែលបណ្តោយ ឲ្យលោភធម៌ត្រូបសង្កត់ចិត្ត ក៏យ៉ាងនោះដែរ ។

ហេតុនេះ កូនសិស្សដែលលោកគ្រូស្រឡាញ់រាប់អានហើយនិយាយសរសើរ ។ នាម៉ឺនមុខមន្ត្រីត្រាប់ដំណែង ដែលព្រះបរមក្សត្រាធិរាជទ្រង់ប្រោសប្រាណលើកដំកល់ដំកើងឡើងជាធំ ។ សេនាពាហនដែលលោកមេទ័ពប្តូរមកជ័ស្រឡាញ់រាប់អានសរសើរ ។ ជនទាំងឡាយមានកូនសិស្សជាដើមនេះ ត្រូវតិចារណាឲ្យឃើញថា ការសរសើរជាលោភធម៌ ហើយកុំឡើងជារបណ្តោយចិត្តឲ្យត្រេកអរហួសប្រមាណ ឬក៏រាយក្នុងក្រអឺតក្រទម ហាក់ដូចជាមានយសស័ក្តិស្មើនឹងលោកដែរ បើខប់ចិត្តបានយ៉ាងនេះ ទើបគ្មានសេចក្តីវិនាស មានតែសេចក្តីសុខចំរើនរឿងទៅ មកពីមិនបណ្តោយឲ្យលោភធម៌ចូលត្រូបសង្កត់សន្ធានជ្មាន ។

អធិប្បាយអំពី លោភ ទីឆ លោភធម៌ សង្ខេបតែប៉ុណ្ណេះ

សេចក្តីពិចារណាដែលពុទ្ធសាសនិកជនម្នាក់

(តទៅ)

លោកវ៉ាយ-ប៊ុតរៀបរៀង

អ្វីដែលហៅថាសាសនា?

ក) សាសនាប្រែថាដូចម្តេច? សាសនា ប្រែថា ពាក្យបណ្តាំ, ពាក្យផ្តាំផ្ញើ, ពាក្យប្រៀនប្រដៅ, លទ្ធិ ។

ខ) ហេតុដែលកើតសាសនាមកពីអ្វី? មនុស្សទាំងអស់ក្នុងលោកមានបំណងចង់បានសុភមង្គលគ្រប់ៗគ្នា, តែមនុស្សនេះ បានប្រព្រឹត្តបុណ្យ, បាប, កុសល, អកុសល លាយចំរុះគ្នា, បានជាផលបុណ្យ, ផលបាប ឲ្យផលតាមលំដាប់, ផ្ទាស់វេនគ្នា ។ មនុស្សណាបានខ្ជួលផលបុណ្យ មនុស្សនោះក៏មានចិត្តសោមនស្ស, តែកាយ ត្រេកត្រអាលសប្បាយ ប្រៀបដូចជាបុដ្ឋា ដែលត្រូវទឹកសន្សើមមក តែផ្សាយក្លិនក្រអូបឈ្ងុយឈ្ងប់ឡើង ឬ ដូចជាកង្កែបខៃត្តែត្រូវភ្លៀងធំដូច្នោះ ។ មនុស្សណាបានខ្ជួលផលបាប មនុស្សនោះក៏មានចិត្តទោមនស្ស, ខ្កុំក្តៅទោស, ភ័យ, លំបាក, ខ្សឹកខ្សួល, អួលអាល់ក្នុងព្រួយត្រប់យ៉ាង ដូចមានពុទ្ធតាសិតសំដែងនៅក្នុងធម្មបទ, ខុទ្ទកនិកាយ, សុត្តន្តក្នុងវគ្គ ថា:

ចរញ្ចេ នាលភេ សេដ្ឋំ សហាយំ សទិសំ ធ្រុវំ
អភិភុយ្យ សព្វានិ ភយានិ តេន អត្តមនោ
ចរេ ឯកោ ទឡ្ហំ កយិរា នត្ថិ ពាលេ សហាយតា
ឯកចរិយំ ទឡ្ហំ កយិរា នត្ថិ បាបេ សហាយតា

មនុស្សពាលភាំងល្ងង់ អ្នកមិនមានបញ្ញា ប្រព្រឹត្តធ្វើកម្មណាមកដែលជាវេរស់មានផលក្តៅក្រហាយ ដោយខ្លួនឯង ដូចជាសត្វមិនមែនមិត្ត ។

នៅក្នុងធម្មបទដ្ឋកថាទីកាយ, កសកវត្ថុជាខ្លោងថា:

ន តំ ភជ្ជ កតំ សាធុ យំ ត្វា អនុតបតិ
យស្ស អស្សុមុខោ ភេរំ វិចារេ បដិសេវតិ ។

មនុស្សធ្វើកម្មណាហើយ រមែងតាមក្តៅក្រហាយ មានមុខរងាកដោយទឹកភ្នែក ស្រែកយំសោយឆ្លៀវបស់កម្មណា កម្មដែលគេធ្វើហើយនោះ។ មិនល្អទេ ។

មនុស្សណាដែលជាខ្លួលវង្វេងក្នុងលំបាកគ្រប់យ៉ាង ក្នុងជាតិជាបច្ចុប្បន្ននេះ មនុស្សនោះគិតថា: "ទុក្ខលំបាកនេះមកពីណា? ហេតុអ្វីក៏ឥឡូវខ្ញុំត្រូវសោកខ្លាំងម្ល៉េះ?" សេចក្តីទុក្ខនោះ ទៅជាស់សតិរបស់បុគ្គលនោះភ្លាត់លើកញ្ឆាយ, ឃ្លេចទៅ។ មានជិតមួយចង្កាដឹង, ចង់ឃើញឲ្យច្បាស់លាស់ ក៏ទៅសាកសួរបណ្ឌិត, អ្នកប្រាជ្ញ អំពីហេតុដែលខ្លួនកើតទុក្ខ ។ លោកជាបណ្ឌិតក៏ពន្យល់បំភ្លឺមនុស្ស ដែលវង្វេងក្នុងនោះអំពីជាបដែលខ្លួនប្រព្រឹត្តពីជាតិមុនមក ឲ្យដល់ក្នុងសម័យនេះ ដោយអាងដល់ពុទ្ធភាសិត ក្នុងធម្មបទដ្ឋកថាទីកាយ ជាបវគ្គវណ្ណនា, សេយ្យសកត្ថេរវត្ថុថា:

ជាបញ្ច បុរិសេ កយិរា ន នំ កយិរា បុនប្បុនំ
ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ ជាបស្ស ឧច្ចយោ ។

បើបុរសធ្វើជាប កុំគប្បីធ្វើជាបនោះញយ។ កុំដើរសេចក្តីពួលជាប កង់ជាបនោះ ព្រោះការសន្សំនូវជាប នាំឲ្យកើតទុក្ខ ។

លុះកើតទុក្ខ, សេចក្តីត្រេកត្រអាយមកជុតកេលពាល ក្នុងសន្តានចិត្ត, ទើបបុគ្គលនោះ លែងប្រព្រឹត្តធ្វើបាបអកុសល ព្រោះតែគាល់ណាខ្លួនដឹង ដោយខ្លួនឯងថា បាបជាអំពើអាក្រក់ គួរកុំប្រព្រឹត្តកំលះបាបនោះ ប្រែទៅប្រព្រឹត្ត អំពើល្អគឺបុណ្យនោះឯងមានទាន, សីល, ភាវនាជាដើម ។

សាសនានេះជាប្រទីបសម្រាប់អុជបំភ្លឺផ្លូវ ឲ្យអ្នកដាំដំឡាយដើរ, គឺផ្លូវខុស, ផ្លូវត្រូវ, ផ្លូវអាក្រក់, ផ្លូវល្អ, បាប, បុណ្យ, គុណ ទោស ត្រង់យ៉ាង ។ បុគ្គលណាមិនភាន់ដឹងនូវបាប បុណ្យ, គុណទោស, ហើយប្រព្រឹត្តធ្វើតែបាបអកុសល, បុគ្គលនោះហៅថា ពាលអ្នកទុច្ចរិត, អសប្បុរស, បុគ្គលណាស្គាល់ជាក់ច្បាស់នូវបាប បុណ្យ, គុណទោស ហើយប្រព្រឹត្តធ្វើតែបុណ្យកុសល រៀរចាកបាបអកុសល បុគ្គលនោះហៅថា បណ្ឌិត, អ្នកសុចរិត, សប្បុរស ។

ព្រោះហេតុដូច្នេះ, ហេតុដែលកើតសាសនាគឺមកពី :

១- មនុស្សភាំងអស់ប្រាថ្នានូវសុភមង្គល ;

២- មនុស្សភាំងអស់ តែងសោយនូវទុក្ខលំបាកគ្រប់យ៉ាង;

៣- មនុស្សភាគច្រើន តែងប្រកបដោយអវិជ្ជា, តណ្ហា, ពាតិក្កិលេស, ក្រាស់ខាងអកុសល គឺលោភៈ, ទោសៈ, មោហៈ ;

៤- មនុស្សភាគច្រើន មិនដឹងផ្លូវខុស ផ្លូវត្រូវ, ផ្លូវល្អ ផ្លូវអាក្រក់;

៥- មនុស្សភាគច្រើន តែងមានទុជ្ឈាន, ប្រកាន់លទ្ធិ, ក្រុម, បក្ស, ពួក, គណៈ, និកាយ ជាដើម ។

១- មនុស្សភាំងអស់ប្រាថ្នាខ្លួវសុគមង្គល? អ្វីជាសុគមង្គល? សុគ-
មង្គលគឺមង្គលល្អ គឺសេចក្តីសុខកាយ, សប្បាយចិត្ត ។

មែនពិត, សាសនានៃអ្នកប្រាជ្ញ ជាសាសនាដែលរាបាមនុស្សឲ្យ
ផុតចាកទុក្ខភាំងពួង ឲ្យរួចផុតពីកណ្តាប់ដៃនៃតណ្ហា, ឲ្យធុតចាប់ចំពៀម
ខ្ទាប់ប្រពៃណី, ឲ្យរួចស្រឡះពីជាតិ, ប្រទេស, ពីគ្រឿងវិលវិល ដែលនាំ
សត្វឲ្យស្វាប់, កើត ។ ស្លាប់, វង់ទុក្ខវេទនាជាអនេកប្បការ ក្នុងភពវដ្ត-
សង្សារគ្មានចំបុតគ្មាន សាសនានៃអ្នកប្រាជ្ញ គឺព្រះពុទ្ធសាសនាដែលប្រ-
តិបត្តិទៅហើយបានបញ្ឈប់ខ្លួវគ្រឿងវិលភាំងឲ្យ, រួចផុតចាកវត្ថុជា
គ្រឿងបញ្ឆោតសត្វ ឲ្យវិលទៅវិលមក មិនចេះចប់; ស្ថានណាដែលឈប់
វិល, ស្ថាននោះឈ្មោះថា មិនប្រព្រឹត្តប្រតិបត្តិតាមច្បាប់អស់ចំពៀម
ខ្ទាប់ប្រពៃណី, អស់ជាតិ, អស់តណ្ហា, អស់កិលេស, អស់អវិជ្ជា ។
មនុស្សណាដែលដឹងខ្លួន ដោយខ្លួនឯង, ប្រព្រឹត្តប្រតិបត្តិទៅតាន់ធម៌
ដែលឈប់វិលកើតវិលស្លាប់ មនុស្សនោះឈ្មោះថា ដល់ស្ថានដែលឈប់
វិល គឺព្រះនិព្វានោះឯង ។

២- មនុស្សតែងចូលខ្លួវទុក្ខគ្រប់យ៉ាង, តើទុក្ខនោះមកពីអ្វី?

ទុក្ខនេះ, ព្រះសម្មាសម្ពុទ្ធទ្រង់ត្រាស់ទេសនា ប្រាសបញ្ចាត្តិយកតុ
មានព្រះអញ្ញាតកោណ្ឌញ្ញជាប្រធាន ឧដ្ឋាតពួកព្រហ្មចាំង ១៨ កោដិ ឮដំ
ព្រៃឥសិបតនមិគទាយវន ទៀបក្រុងពារាណសី អំពីចតុរារិយសច្ច គឺ:

(មានត)

ប្រវត្តិសាស្ត្រនិទានព្រះរាជធីតា
លោក ផើង.ស្រ៊ី នៅក្រសួងឃោសនាការជាតិ

ប្រែចាកសៀវភៅ ក្រុងព័រឡេសងំធំ ធី រោមានី
(Contes et Légendes de Roumante,)

ឮដំណាលណោះ មានព្រះចៅពាជាធិរាជមួយព្រះអង្គ ទ្រង់ទូរមហិ.
ច័ន្ទិ ទីឯមានព្រះកិត្តិនាម ឃាំងលីល្បាញសព្វទិសទី ។ ព្រះអង្គមានព្រះ
រាជធីតាមួយព្រះអង្គ មានរូបឆោមលោមពណ៌ល្អក្រៃណាស្អ ជាងផ្កា
ទៅទៀត ។ លុះព្រះនាងបានដល់សោឡសកាលហើយ ពួកកំឡោះៗ
ចូលមកទាំងហ្វូង អំពីចំណែកនៃទិសផ្សេងៗ ក្នុងពិភពលោក ដើម្បី
ដណ្តឹងព្រះនាង ។

ប៉ុន្តែ បើមាណពណាមួយ គឺសេចក្តីស្នេហាបានទាំមកដល់ទីនោះ
ហើយ ចង់ចូលទិយាយការណ៍ទឹងព្រះចៅ។ ទ្រង់មានព្រះរាជឌ្ឌារថា :

ម្នាលមាណព តើឯងបានឃើញដើមខៀម នៅក្នុងព្រះរាជឧទ្យាន
ហើយឬ ?

អ្នកកំឡោះនោះក្រាបបង្គំលទូល ឆ្លើយតបព្រះរាជឌ្ឌារថា :

ទូលព្រះបង្គំបានឃើញហើយ ។ ដើមខៀមដែលគេក្រឡេកឃើញ
ភ្លាម ធ្វើគេឲ្យពេញដោយសេចក្តីត្រេកត្រអាល ។ ដើមខៀមនោះ ជុំនា
ក់ណាស្រះរាជឧទ្យាន មានទំហំដើមយ៉ាងធំ ស៊ើរទឹងប៉ុនធុងស្រាដាក់ស្រា
ទំពាំងបាយជូរ ហើយមានបុងយ៉ាងខ្ពស់ស៊ើរដល់មេឃ ។

ម្នាលមាណព ចូរចាំស្តាប់ដើមរឿងនេះ នៅទាន់ពុទ្ធសាសនាយើងនេះ ។ អ្នកណាៗហើយចង់បានកូនយើង សុទ្រាតែអ្នកនោះអាចឡើងទៅយកវិទ្យាគុណបានមក ទើបយើងឲ្យ ។

គ្រានាងតែអ្នកកំណើរ ចាប់ឆ្គើមតឹងឡើង ព្រះចៅស្រែកប្រាប់ថា:

ម្នាលមាណព គ្រានាងឡើងដូច្នោះឯងទេ មែនឬមិនមែន ? ប៉ុន្តែដើម្បីបំពេញកិច្ចឲ្យត្រឹមត្រូវមិនខាន តាមបំណងរបស់យើង ត្រូវឡើងកាន់តែស្រាមួយទៀត ។ ឯងឃើញឬ ទេ ? ហ៎! ឃុនទៅ ។ ចូរកុំឲ្យកំពុបមួយដំណក់ចេញ ក្នុងពេលដែលតំពុនឡើង ការនេះស្រេចលើខ្លួនតាំងអស់បើឯងធ្វើឲ្យកំពុប អ្នកឯងនឹងមានក្បាលជាប់ជាមិនខាន ។ ឯងស្តាប់ជ្បានហើយ ? ។

- បពិត្រព្រះគុណាវុធិសេម ខ្ញុំព្រះបង្គំជាខ្ញុំស្តាប់ជ្បានហើយ ។

ហើយបុត្រនៃព្រះអង្គម្ចាស់ ឬព្រះរាជា កាន់តែវាយដៃហើយប្រកាសឡើងទៅ ។ ប៉ុន្តែ ឡើងមិនជ្បានត់បើតាម តែវាធ្លាក់ ហើយស្រាហូរចុះមកច្រួច . . . ច្រួច . . . ច្រួច . . . ។

ឃើញដូច្នោះព្រះចៅស្រែកថា:

ម្នាលអាចោរចង្រៃ ចូរចុះមក ចុះឲ្យឆាប់! ហើយតែមួយស្របក់តួកតីយាជក៏តាត់ក្បាលទៅ ។

ម្នាលសំឡាញ់តាំងឡាយ មាណាពរូបល្អ។ ស្តាប់កប់រយ ពាន់នាក់ ដោយសារតែមាតុគ្រាមម្នាក់ ដែលមានរូបសម្បត្តិដូច្នេះ ។

គួរឲ្យអាណិតណាស់ កាលណាគេឃើញនៅទីព្រះលានខែដើមខៀវ នៅបងដែលមានដងតក្បាលអ្នកហាវហាន គ្រប់បង្គើល ។

អ្នកទាំងប៉ុន្មានដែលប្រាថ្នាមកដណ្តឹងព្រះកដធីតា ជានដល់ខ្លួវមរណភាពសឹងតែស្លូតខ្លួន ។ ព្រះកដធីតាកំសត់ កាលព្រះនាងទ្រង់ទតឃើញព្រះកាយ កាន់តែមានរើយចំរើនទៅមុខណាស់ហើយ កំទ្រង់តស់តែរ្យព្រះបើមាបញ្ជារហើយទ្រង់ច្រៀន ស្រងូតស្រងាត់តែមួយព្រះអង្គឯង

ម្ល៉ោះហើយ សេចក្តីទុក្ខព្រួយយ៉ាងធំ ក្នុងព្រះហរមកដកំងនៃព្រះហៅផ្សាយទៅកាន់ទីជិតឆ្ងាយនានា រហូតដល់ប្រកល្បាកដងក្នុ ស្រុកស្រែកៀនកោះ ។ ក្មេង ដក កំឡោះ ក្រមុំ អ្នកកំសត់ អ្នកមាន អ្នកធំតូចតង្អាលចៀម តែងនាំគ្នានិយាយពីរឿងនោះ ឥតឈប់ឈរ ។ ចូរតិតមើល តែកាលណានិយាយអំពីរឿងហេតុ ក្នុងព្រះហរមកដកំងនៃព្រះហៅ កូមិណាក៏មានសេចក្តីរំតើបទាំងអស់ ។

ចូរមើលចុះ អ្នកនោះក៏និយាយ អ្នកនេះក៏និយាយ ដំណឹងនោះឮរហូតដល់កន្លែងចិញ្ចឹមចៀម ដែលជារបស់អ្នកតង្វាលបងប្អូនពីរនាក់ ។

បងប្អូនពីរនាក់ និយាយប្រាប់គ្នាទៅវិញទៅមកតីរឿងនោះដែរ ។ ស្រាប់តែថ្ងៃមួយ បងបានប្អូននិយាយប្រាប់ថា:

-នែ អ្នកបង ខ្ញុំដូចជាបងរំខាសំណាងលមើលនឹងគេដែរ ។

-ឯងនិយាយខ្លួ? ត្រឡប់ជាបើគេស្លូតតែមានវិន្ធិជាងឯង តង់ស្ងួនមិនរួចអំពីសេចក្តីស្លាប់ ខ្លាំបើឯង តើឯងធ្លាប់ដូចម្តេច ខ្លួនបានសម្រេច? ។

-ស្រេចតែល្បែងមើល ។ ខ្ញុំសូមលាទៅហើយ ។ នែអ្នកបង ចូរ

មើលចៀមឱ្យខ្ញុំផង: បើខ្ញុំទៅមានដំរែត ខ្ញុំនឹងយកតែបងវិញ បើខ្ញុំស្លាប់ បងឯងយកគាំងអស់ចុះ ។

ហើយមិនយូរប៉ុន្មានបងប្អូនគាំងតាំរាំបែកគ្នា ។ បងទៅទំព្រឹងនិយាយ ភាញប្អូនទៀត គឺនិយាយបន្ទាប និយាយដោយទន់ និយាយដោយសំដីផ្អែម . . . . ។

-ប្រាកដមែន តែខ្សល់ក្តួចទៅហើយ មិនងាយយកមកវិញទេ ។ ប្អូនដំបូងប្អូនទៅសួរហេតុកម្តាយ រួចគេចូលទៅដល់ព្រះបរមកដកាំង យ៉ាងប្រញាប់ ។

-បពិត្រ ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះបង្គំជាខ្ញុំចង់ឡើងដើមទៀបល្បងមើលដែរ ដើម្បីសេចក្តីស្នេហាចំពោះព្រះពជនីតាព្រះអង្គ ។

ព្រះពជាទ្រង់យថា:

-បើឯងចង់ ចូរឡើងទៅ ប៉ុន្តែ ឯងបានឃើញបង្គាលរបងគាំងនោះឬទៅ?

-ខ្ញុំព្រះបង្គំជាខ្ញុំបានឃើញហើយ ។

ពេលដែលគេកំពុងប្រុងប្រៀបរៀបចំនឹងឡើង គឺមានសេចក្តីអស្ចារ្យមួយ ព្រះពជនីតាលបហៅអ្នកគង្វាលមកជិត ប្រគានស្បៀតសក់មួយឱ្យ ហើយប្រាប់រៀបៗ ថា:

[redacted] ចូរជាក់ឬស្បៀតសក់នេះក្នុងកែវស្រា នឹងស្លុតជាប់ មិនអាចហៀរហូរបានឡើយ ហើយចេះតែអញ្ជើញឡើងទៅចុះ ប្រពៃហើយ ។

ហេតុអ្វី ក៏ព្រះអង្គម្ចាស់ក្សត្រីធ្វើដូច្នេះ ចុះចំណែកខាងអ្នកដទៃជាច្រើន ខ្លះមានប្រុសជាង ខ្លះមានទ្វីជាង ម្តេចឡើយព្រះនាងមិនឲ្យស្មៀតសក់? ខ្ញុំចង់ដឹងរឿងនេះ ។ ប្រហែលអ្នកគង្វាលចិត្តស្លូតត្រង់នេះជាទីពេញព្រះហរទ័យ នៃព្រះនាងជាពិតប្រាកដមែន ? ។

ហើយអ្នកកំឡោះចេះតែមឿនខ្ពស់ទៅ ខ្ពស់ទៅជាជាងប ។ មនុស្សនៅឯក្រោមមើលឃើញគេឡើងផ្តាត់ផ្តាប់ ដូចជាកំប្រុក ។ តុ! មើលទៅមេឃ ដូចជានៅឆ្ងាយពេក . . . ។

ខ្សាច់បក់មកត្រូវមុខ ធ្វើឲ្យគេស្រែកខឹកភ្នែកមកដីតក់ . . . តក់ . . តក់ . . . . តក់ . . . . ។

ព្រះចៅស្រែកថា:

-ហៅវាចុះមកវិញ ហើយឲ្យគេយកទៅគាត់ក្បាល ! ឯងពាល់គ្នាមិនឃើញស្រាហូរភ្លាក់មកដីទេឬ?

ព្រះអង្គម្ចាស់ក្សត្រីទូលតបព្រះពាដតុង្ហារថា:

-បពិត្រព្រះវរបិតា គឺជាខឹកភ្នែក មិនគឺស្រាទេ ។ សូមទ្រង់ព្រះមេត្តាប្រោសលើកទៅមើល ព្រះអង្គនឹងទ្រង់ជ្រាប ។

ព្រះចៅទ្រង់ខ្ចាល់ លិទ្ធលមើល ទើបទ្រង់យល់តាម ។ ចំណែកអ្នកគង្វាល ចេះតែឡើងឥតបង្អង់ ។ មិនយូរប៉ុន្មាន អ្នកនៅខាងក្រោមទើលភ្ញុំ ឃ័ញ ។ លុះទីបំផុតគេក៏ដល់មែកឈើបាំងភ្លាម ហើយគេស្ងួតាមមែកធំជាងគេ ។

នៅខាងបុងមែកនោះ គេឃើញរូមរបស់យាយចាស់ម្នាក់ ។ យាយ
នោះចាស់ពេក ព្រោះគាត់មានអាយុតិរេយឆ្នាំហើយ ។ គឺយាយព្រះ
សុក្រ ។ អ្នកតផ្លាសយើងសួរថា:

-បពិត្រលោកយាយព្រះសុក្រ សូមលោកយាយអាណិតចៅ
សូមច្រាប់ចៅ តើចៅត្រូវនៅតាមមែកណា ដើម្បីឲ្យបានដល់បុងទៀត ។

-នែអាចៅ ចូរឯងឈប់តាំបន្តិច យាយគំពុងថ្វាយបង្គំព្រះ ។
អ្នកតផ្លាសឈប់តាំ ។ លុះយាយព្រះសុក្រសូត្រធម៌ហើយ គាត់
ច្រាប់ថា:

-នែចៅឯងនៅខាងសើបន្តិចទៀត ទំនងបានឃើញបងរបស់យាយ
ឈ្មោះយាយព្រះសៅរ ។ គាត់បងយាយមួយថ្ងៃ ហើយគាត់ទំនងច្រាប់
ដំណឹងដល់ឯង ។

ចំណែកអ្នកតផ្លាសយើង ក៏ឡើងនៅទៀត ។
យាយព្រះសៅរ គំពុងសូត្រធម៌ដែរ ហើយគាត់ច្រាប់ថា;

-នែចៅ តាំយាយច្រាប់ ។ ប៉ុន្តែ ក្នុងពេលឈប់សៀមនេះ ចូរចៅ
យកគូនសោតាំនេះទៅ ទៅអាចចូលមើលបានត្រប់បន្ទប់តាំងអស់ រឿ
តែបន្ទប់កណ្តាល ។

-បាទលោកយាយ ។

ប៉ុន្តែដល់នៅតែឯង អ្នកតផ្លាសយើងយកគូនសោទៅ តាក់ចេក
បន្ទប់ដែលយាយព្រះសៅរហាម ។ នៅនោះតើគាត់យើញអ្វី ព្រះអង្គ
អើយ? មានយក្សមួយផាប់ច្រកក់ចើខ្យ ។

យក្សអង្វរថា:

-បពិត្រអ្នកកំឡោះ សូមអ្នកអាណិតខ្ញុំ សូមទៀតខ្ញុំមួយកែវ ។ ខ្ញុំសូមជូនពរដល់អ្នកម្ចាស់ ។

អ្នកគង្វាលយកទឹកទៀមួយកែវ ស្រាប់តែប្រព័ន្ធមួយខែឡើងជាប់ម៉ាត់អស្ចារ្យពេក ។

-សូមមួយកែវទៀត អ្នកកំឡោះ ខ្ញុំមិនជូនពរដល់អ្នកម្ចាស់ទៀត ។

អ្នកគង្វាលទ្រើតាម ប្រព័ន្ធទីពីរជាប់ទៀត ។ តទៅ នៅតែប្រព័ន្ធមួយខែឡើងទេ ដែលចង់យក្ស ។

-សូមមួយកែវទៀត បន្តិចបន្តួចទៀត អ្នកកំឡោះ ខ្ញុំនឹងជូនពរទីបីដល់អ្នក ។

គ្រាន់តែដឹកទឹក ក្នុងកែវទីបីហើយភ្លាម ប្រព័ន្ធទីបី ក៏ជាប់ដែរ ហើយយក្សរួចខ្លួន ស្ទុះទៅដក់យកកូនក្រមុំ របស់យាយព្រះសៅរ៉ា ខ្ញុំក្លែបប្រាប់អ្នកថា យាយព្រះសៅរ៉ាមានកូនក្រមុំមួយ យក្សដក់យកនាងក្រមុំជាប់ក្រោមដៃ ដូចជាគេកាន់ភ្នែដ៏ស្រាលមួយ រួចហោះសំដៅទន្លេរបស់ក់ ដែលនៅឆ្ងាយ ។

អញ! ធ្វើដូចម្តេច អាហាក ម្ចាស់នេះ? សេចក្តីទុក្ខនឹងកើតមានដល់អ្នកប្រហែស កំសត់ហើយ! យាយព្រះសៅរ៉ានេះដូចក្តៅឆ្អឹង តេញដោយកំហឹង ស្ទុះមកប្រាន់អ្នកគង្វាលយើង ខ្លាំងមកដ៏ ។

ប៉ុន្តែ ដីនៅឆ្ងាយពេក ។ ហើយមុនដែលអ្នកកំឡោះ ទឹងទ្លាក់ដល់ដី យាយព្រះសៅរ៉ាដើងខ្លួនថា គាត់កាន់ស៊ីល មានចិត្តមេត្តាកើតឡើងភ្លាម

បញ្ជូនស្ងាបមួយជាងគ្រាយ ទៅឱ្យអ្នកកំឡោះ ដើម្បីឱ្យធ្លាក់ដល់ដី សន្សឹមៗដូចជាស្ងាបដែលហើរ ដោយខ្យល់ ។

ម្យ៉ាងទៀត ព្រះជាម្ចាស់ ក៏មិនលះបង់គេចាលដែរ ហើយព្រះអង្គធ្វើឱ្យធ្លាក់ត្រូវចំពីខាងមុខនៃប្រាសាទយក្សចោរនោះ ។ យក្សស្ទុះមកមួយរំពេច ដើម្បីទំងចង់សម្លាប់ហោល . . . ។ អ្នកគង្វាលនិយាយថា:

-បពិត្រ ស្តេចយក្ស តើលោកបាននិយាយឬទេថា ទឹងអត់ទោសឱ្យខ្ញុំម្ដង ? តើបែបយ៉ាងដូច្នេះឬ ដែលលោកកាន់ពាក្យសច្ចៈ ? ។

-ប្រាកដមែនហើយ ។ បើដូច្នេះ អញអត់ទោសឱ្យដល់ឯង ។ ប៉ុន្តែ ចូរកុំត្រឡប់មកទីនេះទៀត ។

អ្នកគង្វាលចិត្តស្ងួតត្រង់ ធ្វើជាដើរចេញទៅឆ្ងាយ ប៉ុន្តែ លុះព្រឹកឡើងកាលណា យក្សទៅលេងព្រៃជាន់ គេមកលួចយកនាងក្រមុំជាកូនយាយព្រះសៅរ ហើយនាំគ្នាវត់ . . . . ។

ប៉ុន្តែ គ្រានោះ សេះរបស់ស្តេចយក្ស គិតតែស្រែកកញ្ជ្រៀវហៅយក្ស ។

-ឃើ! ឃើ សេះយក្ស សេះសិង្ហ តើឯងគ្មានបានផឹក បានស៊ីទេឬ?

-មិនអីទេ ខ្ញុំបានផឹក បានស៊ីហើយ ប៉ុន្តែ ប្រពន្ធរបស់លោកវត់ជាន់ទៅហើយ អ្នកគង្វាលចៀមលួចយកទៅ ។

-ចុះតើអញ មានពេលទំនេរឈប់ផឹក ឈប់ស៊ីសឹងបានឬទេ? ។

-បានឥតមានពាស់ទេ ទៅហ្ន៎ាយ អញ្ជើញពីហាត់មចិត្តចុះ ។

ចំណែកយក្ស តាំងធឹកស៊ី រួចក៏ផែលឡើងលើសេះ ដេញតាមអ្នកវត់ ។ ប៉ុន្តែ វេលាដែលតាមទាន់ចាប់សក់ជាប់ យក្សគិតនឹងលំអិតឲ្យទៅជាធួល អ្នកគង្វាលរំលឹកឡើងថា:

-បពិត្រ ស្តេចយក្ស លោកបានឱយយថា ឱដអត់ទោសដល់ខ្ញុំជាតំរប់តីដេង ។ សូមលោកកាន់ពាក្យសត្យ ។

-ពិតមែន ។ ណ្ហើយអញអត់ទោសឲ្យឯងម្តងទៀត ។ ប៉ុន្តែកុំឲ្យអញចាប់បានទៀត ? ។

មិនយូរប៉ុន្មាន វត់ទៀត ដេញតាមទៀត អត់ទោសជាតំរប់បីដង ។

កូនយាយព្រះសៅរយំគ្នូញគ្នែរថា:

-បើដូច្នេះ ធ្លើដូចម្តេចទៅ បពិត្រលោកហាវិហាន ? មើលទៅខ្ញុំចេញមិនរួច ពីទីនេះឡើយ មែនឬទេ ? ។

-យើងវត់ទៀត ហើយលើកក្រោយ ប្រហែលបានសម្រេច ។

-មែនហើយ យើងត្រូវវត់ទៀត ប៉ុន្តែ ប្រយ័ត្នកុំឲ្យដួចលើកមុន។ ។

ចូរស្តាប់ខ្ញុំ: ខ្ញុំបានឮគេនិយាយថា: នៅឯអូរក្បែរមាត់សមុទ្រ មានយក្ខិនីមួយ គួរខ្លាចហើយគាចក្រៃលែងគាជ ។ ប៉ុន្តែ យក្ខិនីនោះមានមេសេះមួយ ។ បើអ្នកណាហើយស៊ីឈ្នួលក្បាមេសេះឲ្យបានបីខ្នាំ នោះគាត់នឹងឲ្យកូនសេះមួយជារង្វាន់ ឯកូនសេះនោះ ហ៊ាសដូចអណ្តាតភ្លើង ហើយលឿនដូចជាផ្គរបន្ទោ ។ សេះរបស់យក្ស តាមវាមិនទាន់ឡើយ ។

-បើដូច្នោះ បពិត្រអ្នកគង្វាលចិត្តស្លូតត្រង់ តើអ្នកនឹងទៅក្បាមេសេះឱ្យយក្ខិនីសឹងឬ? មិនយូរប៉ុន្មានទេ ឆ្នាំរបស់យាយយក្ខិនីតែបីយប់ទេ។

ចំណែក អ្នកតស្វាលយើង ក៏ទៅរកយក្ខិនី តាមការប្រាប់ក្រមុំកូន យាយព្រះសៅរ ។

-លោកម៉ែ ទៀតសួស្តី ។

-អរគុណច្រើន អ្នកកំឡោះ តែអ្នកមកនេះ តើមានការណ៍អ្វី ? ។

-បពិត្រលោកម៉ែ ខ្ញុំមកនេះ ដើម្បីរកស៊ីឈ្នួល ។ តើលោកម៉ែចង់ជួនខ្ញុំឬទេ ?

យាយយក្ខិនីតំណាងឆ្លើយថា:

-ចុះមានការអ្វី ប៉ុន្តែ សេចក្តីតណ្ហាតក្ខ័នេះ ឥតមានឡើយ តែអ្នកឯងធ្វើឧសចំណង មុនជាក្បាលអ្នកឯង គេយកទៅដោតទំនប់ឆ្កាលរថនហើយ ។ ចូរក្រឡេកមើលដុំវិញខ្លួនចុះ . . . ។

រថស់ដែលអ្នកតស្វាលយើញ ធ្វើឲ្យគេតេញទៅដោយសេចក្តីស្ងប់ស្ងែន ដូចជាដើមទៀប នៃព្រះចេរពជាធំពជដែរ ក្រោលមេសេះតំខ្ចុំវិញ ដោយបង្គាល ដោតសុទ្ធតែក្បាលមនុស្ស ។ នៅសល់បង្គាលមួយតែឯងទំនេរ ចេះតែងាកចុះងាកឡើង ស្រែកគាថា "ក្បាលមួយមក ក្បាល . . . ក្បាល . . . ។

បពិត្រលោកម៉ែ សូមគុណព្រះជាម្ចាស់ជួយ ខ្ញុំសូមបូលស៊ីឈ្នួលទំនង លោកម៉ែចុះ ។

យាយយក្ខិនីព្រមឲ្យ ហើយប្រាប់គេឲ្យទៅស៊ីចាយ ។ តាលវុដែលគេកំពុងមករកោត តាត់ទៅឯក្រោលដាំយមេសេះ ហើយប្រាប់ថា:

(មានត)

ពាក្យពាត្យ

លោក អ្នកឧត្តមក្សត្រីម៉ុក រៀបរៀង

ក្នុងរាជ្យព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម

លោក ញ៉ុក_ថែម ពិនិត្យ

(តមក)

តំណែងតំណេក សម្រេចសម្រេក សម្រាំងអាហារ ដំៗស្រស់ៗ មានរស់ពីសា សម្រាប់គោគ្គា សម្រស់ពួកតល ។ ទង្គិចង្គើល សម្រឹមសម្រួល ដោយផលាផល ស្តេចលើកយោធា សេនាថ្លើងថ្កល់ សន្ធឹកស័ព្ទសល់ ដោយសូរសម្រែក ។ ស្តេចលើកយោធា ចេញចរយោគ្រា ដោយដងផ្លោរជ្រែក តិរីបតិត ឆ្លងបត់ផ្លូវបែក លង្វែងលង្វែក ពេកពន់ពានេចរ ។ គជសង្ឃឹគជសីហ៍ គជសារហត្ថី រមាសកេសរ ពាជសីហា ត្បូរគ្រែប្រើសប្រ - កៀងគូកុះករ បណ្តើរដោយគ្នា ។ គោគ្រែ-គោក្របី សេះសំភារគាមុំ គិះលេខរលៀងកា លិលាលេងលោត ទុដ្ឋខោតជុំពា សត្វសោតសឹងជា មិត្តមកដង្ហែ ។ ឮផ្គរហៀនកេះរៃ យាសយំដោយភ្លៃ រួសត្វសង្ខ្លែ ភ្ញេងភ្ញាត់ភ្លែងភ្លុំ ប្រគំដោយដែរ ជ្រួចជ្រែងដង្ហែ ព្រះបាទកូរនាថ ។ ឋណ្ណាលអស្ចារ្យ ខេតខាំងស្ងួតាំ ថ្ងាយសាធុសាធន៍ បែរបាចមាលាំ ក័ង្ការព្រាយព្រាត ចម្រើនជន្មជាត ឥយាយុកា ។

ស្តេចលើកទ័ពទៅ ទាល់ទៀបលំនៅ អស់ទាំងមនុស្សម្នា ស្តេចឲ្យក្ត
ប្ញន ប្រែខ្លួនជាតិជា រួបពងមនុស្សា សុទ្ធសាតវិស័យ ។ ស្តេចឲ្យត្រួត
ត្រា ខ្លាឃ្មុំខ្លួវស្វា គ្រប់តួទីវៃ ចើមនុស្សឯណា ក្លៀវក្លាជាញាដ៏យ
ចេញចរតៃដ កុំឲ្យសម្លាប់ឱចោមជាប់ឲ្យបាន ហើយបួរអស់ការណ
ទំយាយច្រាយច្រាប់ ដំណើរអញឯង ឲ្យសែងឲ្យស្តាប់ កុំប៉ិឲ្យហ្ងាប់
អាសូរចិត្តស្ត្រ ។

កាលណោះមនុស្សនៅ ទិតមត្រាមក្រៅ យល់តាលៈពន្លឺតាស
សឹងស្វាសឹងខ្លា ត្រៀបត្រាដេរដាស យល់ស្ងំក្រុងកាស ដូចព្រះចន្ទ្រា ។
តង់លើអាជានេយ្យ ថ្កើងអង្គុយសម្លៀ ក្សាលជាសំហា យន្តាក្លិងក្លុងក្ង
អភិរម្យរចនា បើកបាំងក្សត្រា អប្សអន់សុរ្យសែង ។មនុស្សម្នាផងយល់
កើតគោលាហល់ រន្ធត់ស្ងប់ស្ងែង រួតរត់ជ្រកជ្រុះ ចោលផ្ទះសម្បែង
ប្រែច្រាសលះលែង ប្រតន្ធកូនចៅ ។

ស្តេចយល់អ្នកស្រុក តើតកល្ងីយុគ ឲ្យយកមួយទៅ ច្រាយច្រាប់ពត្ថ
មាន ស្ងំត្រួកក្សាន្តចមចៅ ទឹងលើកទ័ពទៅ ពិយាជយក្សា ។ អស់មនុស្ស
ផងដឹង ដំណើរដំណឹង ជាម្ចាស់អាត្មា ស្រុះស្រួលត្រួកត្រង់ ជួញដង្ស
អភិរាទ ប្រស្មោះឆ្ពោះមហា. បុរសថ្កើងថ្កាន ។ រួសរកចំណី ពិសាតិ-
សី ពិសាសឹងមាន ត្រីសាច់ស្រស់ៗ កោដន៍កស្តុត្រប់ច្រាណ នាំច្រាយ
ក្សត្រក្សាន្ត ឥសូរសរសោ ។ សូរសព្ទតិមាន សឹងយំរសោកសោក ខ្លួញ
ល់ខ្លុតា ស្តេចតែងច្រោសច្រាណ ប្រតាន់ពស្ត្រា ទាសច្រាក់សុវណ្ណា
រៀនៗជាគាន ។ សាច់ស្រស់ត្រីស្រស់ ច្រោសប្រគាន់ទស់ ខ្លាឃ្មុំ

ត្រប់ច្រាណ ឯអស់រុក្ខា ផលាបើកបាន ច្រោសព្រះរាជទាន ពួកពលទាន ។ ស្តេចស្តេចបានសោយ ខ្ទូក្រយាស្ងោយ រៀងៗពនេចរ អស់ពលយោធា សេនាទីការ សោតសឹងបានបរិ- ភោគបរិជង្ហាយ ។ ពុំព្រមតម្រែះ ចំពាកបេះ សឹងស៊ីសប្បាយ ស្តេចទាំយោធា សេនាទិគាយ ច្រាំពីរខែថ្ងៃ ជាល់ពាកណាស៍ ។ យក្ខប្រែកាឡា សុវណ្ណពន្ធា រិពេចន៍ រន្ធី តិចាយតិចរ្យ បុស្សជោត្រី ទិលត្នោស្មើ ពព្រោងពព្រាយ នាជួមមានជយ័ ថ្កើងរំខ្ចៃក្រៃ លើសលោកសម្ងួយ ចិដូចពន្ធា ឥន្ទ្រាសួគ៌នាយ ត្រសៀកព្រះពាយ ត្រសាយត្រសាក់ ។ ស្តេចគង់សង្រ្គាន ព្រះអង្គ ស្ងប់ត្រក្សាន្ត ខ័ន្ធទឹកភ្នឹកយក្ខ ច្រាច់ពលបរិស័ខ សម្ងាត់ដេកជាក់ ក្រែងមនុស្សផ្តើលក្បាក់ កើតកោលាហល ស្តេចក្តុចពោរ រិះពាជសារ ព្រះសូរច្ចើនថ្កល់ ទីនឲ្យទៅថ្វែង សំដែងដើមដល់ ឲ្យយក្ខដឹងកល់ ជាយើងលើកទ័ព ។ ព្រះតុខ្ជល ស្តេចបើកបន្ទូល ព្រះសូរសោរសំតូ ព្រះថ្វែងសាកសម ជំនុំស្តេចស្តាប់ ព្រះប្រើច្រាយច្រាប់ ពីព្រះថាព្រះ ។ ជាម្ចាជាតិជន ព្រះនាមខេរាំង ព្រះទ្រង់តបៈ ព្រះប្រើលើកទ័ព ត្រឡប់រូតរះ ព្រះមកចំដ៏ប៉ះ យុទ្ធនឹងប្រស្តេង ។ ព្រះដូចម្ចាស្តូទ្រង់ខ្ញើ តបៈខ្លះខែង ព្រះមកផ្តាច់ដន្ធ ខែនន្ទិយក្ខឯង ឲ្យស្បើខ្ញើ ស្តេចខ្លួចាំដ៏ខំសា ។ ស្តេចប្រើមាណព យក្ខម្នាក់ទទអ . ភ្លាំវន្ធុសុតលា ចរចូលទៅជាល់ គំនាល់យក្ខា មុខមន្ត្រីត្រា រៀបរៀងនិត្យ៍ទា ។

មាណពយក្ខយល់ សេនារេហ៍ពល ច្រើនកៃក្រៃស្រាស ក្រៅអស់ភាំងស្រើស្មុំ ជិតដុំគាល់ហ្វៅ រួបរាងស្តួញស្តៅ សៀមសាបានបទ ។ ខ្លុះ

កាន់ឋុមា បេះបកប្បជ្ជា ស្រគាំស្រគត់ នាងខ្លះកាន់ផ្ទីត សែសិតតាយ
តាត់ ល្មមស្មែមុខមាត់ ញញឹមដិតស្ងា ។ ខ្លះដាក់តក្រែងធំ បំព្រំ
បំព្រង ភាំងសង្គាំមា សៀតផ្កាភាំងខង តម្រង់សុវណ្ណា ពាក់ពន្ធអង្សា
កយរត្នៈធ្ងៃ ។ ខ្លះលេងខ្លះសើច សំណេះសំណើច សំណាលមេត្រី
ទៅមកគាន់គ្នា ចរចាប្រឹមប្រិយ តក្កាតក្តី ត្រចះត្រចង់ ។ ស្រ
ឡឹស្រឡះ អង្គកាងជ្រួតជ្រះ អង្គុយរហាំ ប៉ប្រឹមប៉ប្រៃ ល្មមស្មែ
អស់អង្គ ផ្សាផ្សាស្រីកូន ចែងចេះស្អាងកាយ ។ មាណពយកទុយល់ ខន្ធីយក្ស
ថ្លើងថ្លល់ តន់តិតពីនាយ អានេះរុងរឿង ថ្កុំថ្កើងពណ្ណកយ ក់ទឹងអន្ត.
កយ ថ្ងៃនេះឯងហើយ ។ មាណពតគាត ឡើងលើប្រាសាទ ទីរកូកយក្ខ.
ឡើយ ចរចូលទៅជិត ឈរបិតត្រើយ ខន្ធីយក្ខយល់ហើយ ស្រដីទៅ
ថា ។ មឹងនេះមកពី តំបន់ទិសទី ប្រទេសឋានណា លេះមឹងពុំខ្លាច
អំណាចបេស្ដា អង្គអញដឹងថា ឥសូរអស់កស្ត្រ ។

មាណពឆ្លើយថា អង្គអញអាជ្ញា ព្រះឋាតុកាស ព្រះនាមទេវន្ធ
សោតំណអតិកាស ទេពទាំងសុទ្ធាក់ស ត្រមព្រះនិមន្ត ។ អង្គអញជា
សិស្ស ព្រះឋាតអង្គឥសូរពាលណ ខេមន្ធយោធា សេនាអនន្ត ទឹងមក
ឆ្ពាំងដន្ទ មារមឹងសត្រូវ ។ ព្រះឆ្លាំមកថា ព្រះអង្គដូចជា ព្រះមេត្យ
ព្រះទឹងឆ្លាញ់ឆ្លែង ប្រសែ្ដងឥរ្យាវ ឱ្យដាក់ស្ដេងខ្លាវ ព្រះឋាវម៉ីតា ។ ប្រ
សែ្ដងបើខ្លាច ត្រែពាងអំណាច ព្រះមហាសុត្រា ប្រសែ្ដងអតិភព ព្រះឋាត
ពាជា ព្រះអង្គមេត្តា ប្រសែ្ដងនេះទេ ។ ថាបើប្រសែ្ដង អួតវិទ្ធីខែង រិះរឹងប្ដឹង
ថ្កែវ ពុំគ្រាបអតិភព ព្រះឋាតនោះទេ ចូរវៀបពលរេហ៍ ចរចេញទៅឆ្ងាំង ។

សិនខ្ញុំយក ស្មែនស្តាប់ឮដាក់ ក្រែវក្រែងញ៉ែងាំង ហាយ
ពុះពោរ ហេតុមោហ៍មកជាំង បើកបន្ទូលខ្ញាំង តម្រាមបន្តុះ ។

មាណពយកុស្តាប់ ខន្ធិយកុថាប់ គោសពៃដូច្នោះ ក្រែវក្រែងជាល
ជាម តម្រាមតម្រោះ តំហិតខ្រគោះ ពាក្យពះពាក្យថា ។ អង្គអញខ្លាច
ថ្លី ប្រស្នែងតិរ្ថិយ ចិត្តចោរមោហា អាចចាប់កាសិក ធម្មិកជា ស៊ីជា
អាហារ តំនិតតាលពន់ ។ កែងជាមហាក្សត្រ មកសោយសម្បត្តិ
សម្បូរមហាជន ខ្លាំមុខមន្ត្រី សេនីអនុគ្គ យកជាកោជន តាមចិត្តចិន្តា ។
មឹងខ្ញុំវៃសូវណ៌ា អញជាកុម្ភណ្ឌ សឹងខ្ញុំដួចគ្នា អញនឹងកត់ក្បាល មឹង
កាលនេះណា យកទៅថ្វាយ មហា ក្សត្រជាម្ចាស់អញ ។

ខន្ធិយកុស្តាប់ ពាក្យពោលតុំគាប់ ពុំគួរនឹងខ្លាញ់ ចិនឧនឹងសំដី អង្រ៊ិ-
យនោះមិញ ញាប់ញ័រម្ខោម្ខេញ ខ្នះខ្នែងគ្រឿង ។ មាណពកុម្ភណ្ឌ
គេចតាវុំទាន់ ដល់ដួលឆ្អែកគ្រឿង រីឯដៃលឯង ពុំនឹងទៅឡើង ប្រែ
ជ្រាណាប់ឮឿង កើតជារបួសមារ ។ ខ្នះទៅខន្ធិយកុ ត្រង់ត្រូវថ្ងាស់ឆ្អាក់
ពីរត្នុសង្ហារ ឆ្អាក់ដល់កន្ទុល ជាំនឹងលដួលឆ្ងារ របួសនោះប្រែជា យកុយន់
ឃើសឃ្លង ។ សុះដល់ដៃហាន យកដំបងបាន ហោរើលវែងគ្គន ឯ
នាងមែលា ស្រឡាំស្ទុងង សឹងស្រែកយំកង ពាំងកស្តែមន្ត្រី ។ រួតរត់
ដៃកគ្នា ជាក់ឆ្វាយភាំងភ្ញារ កំពែងជ្រលី ខ្នះដួលផ្ងាប់ផ្ងារ ជាន់គ្នាប្រុសស្រី
តិតបាត់ស្មារតី មឹនដឹងនរណា ។

(មានត)

រឿងសាមកុកកុក

កំណែទី ២៩

ឧកញ៉ាវិបុលរាជសេនា ស៊ូ-ភីន ប្រែរៀបរៀង

(តមក)

> រឿងសាមកុកកុកជាយុទ្ធសាស្ត្រ
> អ្នកវាងវៃឆ្លាស បើបានអាន
> ធំងបេះទុយកលបំណាន
> ទាំងមានសន្តានស្នេហាជាតិ។

ចូរឆ្លើយបានឮស៊ុនហ៊ីវនិយាយដូច្នោះ កំប្លែងចិត្តផង ទើបឲ្យហៅខ្លួនស៊ុនតឹមមកបរិភោគគោជនាហារ ហើយចូរឆ្លួសសួរស៊ុនតឹមថា ដែលអ្នកចាំឲ្យសំបុត្រមកដល់យើងនេះ ដោយសុពត្ថភាព ឬ កំជាកល់ទុកយ៉ាងម៉េច ? ស៊ុនតឹមតបថា ដែលលោកសួរនេះ ខ្ញុំបាទនឹងជំរាបមិនកើត ត្រង់ៗរៀបនឹងត្រង់នោះ លោកជាមហាឧបរាជស្រាប់ ចូរលោកត្រិះរិះពិចារណាមើលទៅចុះ កំតង់ជ្រាបបានហើយ ដូចអ្នកសៀវនោះ បានធ្វើសឹកសង្គ្រាមតទឹងលោក កំបរាជ័យចាញ់លោកច្រើនគ្រាហើយ ព្រោះអ្នកសៀវមិនជឿស្តាប់ពីប្រឹក្សា ត្រឡប់យកគោសអ្នកដែលរំលឹកត្រូវនោះ ដល់ប្រហារជីវិតកំមាន ជាក់ឆ្កួតហួតដកងារ ពីរាជការកំមានពីប្រឹក្សាទឹងសេនាទាហានទាំងពួង កំមានតែសេចក្តីខន់ថយស្មារតីច្រាស្ងាត់ ទឹងកំឡាំងធ្វើការជាដរាប ពាល់តែខ្លួនអ្នកសៀវនោះ ពេមនស្សចុះពាសដល់ខ្លួវសេចក្តីស្តាប់ឥឡូវ អ្នកណា

ទឹងអួនសុន ឈ្មោះភាស់គ្នាជាល្អេីមដូចេ្នាះ បណ្តាមនុស្សទាំងពួង ក៏ជានដឹង
ព្រមព្រៀងថា សែអួនទឹងសាបសូន្យតាំងថ្ងៃនេះទៅហេីយ ជានជាបណ្តាល
ឲ្យមានរឿងដូច្នេះ សូមឲ្យលោកលេីកចំពាទៅកាយយកស្រុកតាជីវិតចុះ
អួនសុន ក៏តង់ទឹងតឡូលជាក្រោយ លេីកចំពាបណ្តាយមកបង្ហាញទឹងលោក
អួនចាំកំលេីកព្រួតគ្នាមកតាមាទ ជាអាងខ្លាងនៅតណ្តាលទេ សែអួនគ្រោ
នេះ ឧបទាដូចជាស្ទឹកឈេីសួត ត្រូវតែជំរុះធ្លាក់ចុះ តង់ខេសកាលតាមន្តដូរ
ខ្លួនលោកដូចគ្នេីនដែរ ដែលត្រូវឲ្យលស់បត់មក រមែងនេះបានកណ្តាត
ទៅលេីស្ទឹកឈេីសួត ក៏ទឹងកំខេច ដោយអំណាចអគ្គីនេះជាធួលីអស់ទៅ
ដែលលោកទឹងតាំងព្យាយកស្រុកគេងជាខាងណេះ មិនជាប្រយោជន៍
បានឡេីយ ព្រោះខ្លៅប៉ៅ បានទំនុកបំរុងអាណាប្រជាពស្តេ បាន
សេចក្តីសុខមកយូរហេីយ ឯអាណាខែត្រខាងទិសឧត្តរនោះសោត ក៏
ខ្លាំងពូកែ ជាងអាណាខែត្រទាំងពួងឯទៀត ។ ជាប្រាន បេីលោកប្រាប់
ប្រាមតាណាខែត្រខាងទិសឧត្តរ ពេលវាបានហេីយ គាគាំងពួងក៏ទឹងជា
កម្មសិទ្ធិរបស់លោកទាំងអស់ ខ្ញុំបានដំណាទាំងនេះ ចូរលោកត្រិះរិះពិចារ-
ណាមេីលតាមតារត្រូវចុះ ។

ជូតូបានស្តាប់សព្វគ្រប់ប្រការហេីយ ក៏មានអំណរណាស់ ទេីប
ក្រែងសរសេីរស្ងេីនតិចថា បេីពីដេីម យេីងបានប្រទះទឹងអ្នក ជាទីប្រឹក្សា
ការល្អ។ ប្រហែលក៏ទឹងតិតឲ្យបានសម្រេច សមតាមសេចក្តីប្រាថ្នាដោយ
ងាយស្រួល ដូចបានត្រួយលំបាកឡេីយ ហេីយចូរធ្វេីតាលេីកតង់ទឹង
ត្រឡប់ទៅកាយយកស្រុកតាជីវិត ។ ខ្លៅពីយេីញថា ចូរធ្វេីលេីកត្រឡប់

ទៅវិញហើយ គឺគិតត្រែងថា ចូរឲ្យនឹងប្រើកលៗជាយមិនលើកទ័ពដេញតាម ទើបនាំគ្នាហានទាំងពួង ត្រឡប់ចូលទៅស្រុកគេងដើរវិញ ។

អ្នងស៊ុងដឹងដំណឹងថា ចូរួលើកទ័ពត្រឡប់ទួនខ្នងហោមកវិញ ទឹងវាយយកស្រុកគីវ៉ា កំពាត់ប្រើលីកងទឹងលីសៀងឲ្យលើកទ័ពទៅទាំងកំងខាងក្រោយ ហើយអ្នងស៊ុងក៏លើកទ័ពត្រឡប់មក រក្សាស្រុកវិញ ។

អ្នងចាំយើញដូច្នោះ ក៏លើកទ័ពចេញពីស្រុកគេងដួនតួន ស្រុតតាមទៅ ចម្ងាយប្រហែល ៦០០ សិន (១៦គី) ឃើញលីកង លីសៀង លើកទ័ពមកកំងខ្នងវិញ អ្នងចាំក៏បរសេះចេញទៅ ហើយស្រែកឲ្យលីកង លីសៀងថា បិតាយើងបិញ្ញើមកក្បាអ្នកឯង ឲ្យបានសេចក្តីសុខ មកដល់ហួរហើយ ឥឡូវបិតាយើងអនិច្ចកម្មទៅ អ្នងស៊ុងចិត្តទៀតាំងខ្លួនជាធំ ឲ្យខុសប្រពៃណី អ្នកឯងទាំង ២ នាក់ នៅកងស្រុកជាមួយគ្នាបណ្តាយឲ្យខ្ជិលខុស មិនមានយល់រាស់ត្រង់ណា ថែមមកគិតប្រហារដើរតែយើងជាច្បងទៀត អ្នកឯងមិនគិតដល់បិតាយើងផង ដែលមានគុណលើខ្លួនសោះ គួរហើយ ឬ ជានៅចូលនឹងអ្នងស៊ុងមនុស្សអសប្បុរសមិនស្គាល់ត្រូលរៀមច្បង ហើយប៉ងនឹងបំផ្លាញយើងដូច្នេះ ជាគួរឬ មិនគួរ ? ។

លីកង លីសៀង ជានឮអ្នងចាំរំលើកសព្វគ្រប់ហើយ ក៏សតស្ងប់កងចិត្តឥតចេញស្រដីថាអ្វីសោះ លោតចុះពីរលើសេះតាំង ២ នាក់ ទម្លាក់អាវុធផុតពីដៃ ហើយក៏រត់ចូលទៅលុតដង្គង់គំនាប់អ្នងចាំហើយថា ដែលខ្ញុំជាទាន់ធ្លើលើស្នេខុសដូច្នេះ ព្រោះតំនិតនឹងចិត្តនៅស្រាល ខ្ញុំជាទេសូមឲ្យលោកកុំ

តាលប្រកាន់ទោសសិនចុះ ។ អ្នឧថាំតបថា ដែលអ្នកមកលុះអំណាចសុំទោសយើងដូច្នេះ កំយើញថាគួរណាស់ហើយ អ្នកអើយ ឥឡូវនេះ យើងនឹងបបួលគ្នាទៅតំនាប់ចូន្ទ ហើយអ្នឧថាំក៏នាំលីកឆ លីសៀនទឹងសេនាគាហានចាំងពួង លើកឆស្រុកតីដីវ ទៅដល់កងទ័ពចូន្ទ ហើយកំចូលទៅតំនាប់ ។

ចំណែកចូន្ទបានយើញអ្នឧថាំចូលទៅ ក៏ខ្លួចអំណរសោទរ ហើយសួរអ្នឧថាំថា ខ្ញុនអ្នកចូលមកសុំចំណុះចុះចូលយើង ។ ក៏ពេញចិត្តហើយបើបានសម្រេចការសង្គ្រាមវៀលណា យើងនឹងលើកបុត្រីរបស់យើងឲ្យធ្វើជាភរិយាអ្នក ឯលីកឆ លីសៀងនោះ យើងនឹងចិញ្ចឹមឲ្យដល់ឡាត ។ អ្នឧថាំបានស្តាប់ដូច្នោះហើយ ក៏មានចិត្តត្រេកអរណាស់ ទើបធ្វើយថា សូមឲ្យលោកប្រញាប់លើកកងទ័ព ទៅកាយយកស្រុកតីដីវចុះ ។ ចូន្ទទើបកែងតបថា “ យើងមកធ្វើការសង្គ្រាមគ្រានេះ ក៏ច្រើនវែណាស់ហើយ កងទ័ពប្រចាំ សម្រាប់ជញ្ជូនស្បៀងអាហារនោះសោត ក៏មានសេចក្តីលំបាកណាស់ ក្រោះផ្លូវឆ្ងាយជាច់ស្រយាលពេក យើងចង់ឲ្យដឹកវ្រែតពីខេត្តគីស៊ុយ រហូតទៅដល់ខេត្តប៉ែកតុក ឲ្យខូកល្មមដើរចូលចេញនាំស្បៀងអាហារបាន ទើបនឹងធ្វើការបានស្រួល ឯខ្ញុនអ្នកឯងចុះលើកកងទ័ពទៅតាំងបន្ទាយ នៅក្នុងស្រុកពេងជួនគួនសិនចុះ យើងយកតែលីកឆលីសៀង ខុកប្រើការជាមួយនឹងយើង” ចូន្ទក៏តាំងលីកឆនឹងលីសៀងឲ្យធ្វើជានាយភាហាន ហើយលើកកងទ័ពទៅតាំងនៅជំបន់លីយ៉ឹង ទើបកែណាមនុស្ស ឲ្យដឹកវ្រែតពីខេត្តគីស៊ុយ រហូតទៅខេត្តប៉ែកតុក ។ (មានត)

ទៅចាយក្តាំង

លោក ទៀង_តែ_ឈុង

ក្រមការដើមខ្សែលេខ ១

ប្រៀបរឿង

ក្នុងសម័យពីព្រេងនាយ, មានប្តីប្រពន្ធមួយគ្រួ នៅភូមិព្រះពជ-អាណាចក្រ "ខេតបុរី" (Deb-Puri) មានកូនប្រុសមួយអាយុប៉ែនាំ ។ ឈ្មោះ ខ្ទឹមឆ្កឹយ អនិច្ចកម្មទៅ កុមារនេះនៅជាមួយដីដូន ។

កាលបេជដូនឲ្យចាយខ្ទន់ស្មៅ, កុមារនេះយំ មិនព្រមស៊ី ចង់សុំតែចាយក្តាំងប៉ុណ្ណោះ ។ ហេតុដូច្នេះ ទើបដីដូនឲ្យឈ្មោះថា "ទៅចាយក្តាំង" ។

ដីដូនទំនៅក្រលំចាក តោកយ៉ាកវេទនា ណាស់ បើចានបរិភោគព្រឹកខ្លះល្ងាច, បើចានល្ងាចខ្លះព្រឹក ។ លុះទៅចាយក្តាំងនេះចានអាយុ ៧ ឆ្នាំវាជាអ្នកមានប្រាជ្ញាវៀងវៃ ខំជួយធ្វើការដីដូន ដើម្បីចិញ្ចឹមជីវិត ។

មានកាលសម័យថ្ងៃមួយ កាលទៅចាយក្តាំងចានអាយុ ១៦ឆ្នាំ, សាច់ញាតិទំនឹមក្រចានបបួលថា "នែទៅចាយក្តាំង, ឯងទៅចាប់ត្រីជាមួយទំនើរយើងឬទេ"?

ទៅចាយក្តាំងឆ្លើយថា "ខ្ញុំទៅដែរ! ប៉ុន្តែ មិត្តអញ្ជើញទៅមុនចុះ សិនខ្ញុំទៅតាមក្រោយ" ។

ញាតិមិត្តទាំងគ្នាទៅមុន ហើយចាប់ចានត្រីជាច្រើន ។ ចំណែក

ចៅជាយក្តាំងដើរទៅតាមគ្រោយ លុះដើរដល់មាត់ត្រាំង ឃើញដើមកំឯមួយដើម កំឡើនទៅដេកលើមែកកំឯនោះ ឥតមានតិតគួរបាប់ត្រីសោះ ។

លុះភាប់ត្រីគ្រប់គ្រាន់ហើយ ញាតិមិត្រទាំងគ្នាត្រឡប់វិលមកផ្ទះវិញ រឿង ។ ចប់ ។

ចៅជាយកុំងនោះតែដេកសន្ធឹងលើមែកកំឯតែម្នាក់ឯង ។ នៅពេលនោះក៏ស្តេះដួលដល់អាសនាព្រះឥន្ទ្រាធិរាជ ។ ព្រះឥន្ទ្រប្រទេលមើលមកក្នុងមនុស្សលោក ឃើញចៅជាយក្តាំងហើយតិចណាស់ "ឧ! ចៅជាយក្តាំងនេះ មានបុណ្យអស្ចារ្យណាស់ ។

បន្តាបមក, ព្រះឥន្ទ្របញ្ជូលចិត្តត្រេះប៉ើ ឲ្យហោលទៅហោះមកស្បែមាត់ត្រាំង ។

កាលបើឃើញត្រីនោះហែលជាពួក តម្រង់មកដូច្នេះ, ចៅជាយក្តាំងចុះពីដើមកំឯ អង្គុយទៅមាត់ទឹក ហើយតាំងចាលមេដែក ដើម្បីទំងាប់ត្រីនោះ ។ ត្រីទាំងឯកស្រែងលង់ផ្សោះ ។ ចៅជាយក្តាំងបានចាប់ត្រីទាំងអស់ ដោតត្រណោតយកមកផ្ទះវិញ ។

កាលណោះ សេដ្ឋីម្នាក់មានគ្នាមួយ ប្រកបរាល់យប់មារយោនល្អ ជាហេតុឲ្យសេដ្ឋីស្រឡាញ់គ្នានោះណាស់ ។ មានមួយថ្ងៃនោះ ខ្ញុំកំដរម្នាក់ទ្វើមបង្គុកផ្ទះសេដ្ឋីជាចៅហ្វាយ ឡាំសំឡាញ់បានលួចតាហារនោះស៊ីមុន ។ សេដ្ឋីខឹងយ៉ាងខ្លាំង ហើយបង្គាប់ឲ្យខ្ញុំកំដរភ្ជាប់ឡាយកទៅប្រាសចោល ។ លុះដើរដល់តាក់តស្តែ លុះខ្ញុំកំដរនោះដួងខឹង ចាប់ជាយក្តាំង ដែលស្តាយត្រីសែបី វិលមកតាត្រាំង ។

ចៅជាយក្តាំងសួរទាសៈទាំងពីរនោះថា "អ្នកយកគ្នាទៅណា"? ។ ទាសៈទាំងពីរឆ្លើយថា យើងយកគ្នាទៅច្រាសចោល" ។

ឮដូច្នោះហើយ, ចៅជាយក្តាំងនិយាយតបទៅថា "ខ្ញុំសុំប្តូរត្រីរ៉ស់ពីរនឹងគ្នាអ្នក" ។

ឮសេចក្តីស្នើនេះ, ទាសៈទាំងពីរនាក់គិតគ្នាថា "យើងបំរុងយកគ្នាទៅច្រាសចោល, ឥឡូវតែមានរនេះមកសុំប្តូរនឹងត្រីរ៉ស់ពីរ, កាលណាបានត្រីយើងយកទៅស្ងូស៊ី" លុះគិតគ្នាហើយ គឺប្រគល់គ្នាឲ្យទៅចៅជាយក្តាំង។

ចៅជាយក្តាំងឲ្យត្រីពីរទៅទាសៈ ហើយស្ពាយត្រីមួយ ដែលទៅសល់នឹងចំគ្នាដើរមកផ្ទះ ។ ទាសៈក៏ត្រឡប់ទៅផ្ទះវិញ ដោយសប្បាយរីករាយណាស់ ។

លុះទៅដល់ផ្ទះ ចៅជាយក្តាំងយកត្រី ដែលខ្លួនចាប់បានប្រគល់ឲ្យទៅជីដូនស្ងូស៊ី ។

ដល់ពេលយប់ អ្នកស្រុកដេកស្ងាត់អស់ហើយ គ្នាចេញលួចតាំឆ្នាំងជាយ នឹងត្រីតាំងមកឲ្យចៅហ្វាយ ។ ចេះដើរលួចដូច្នេះ កាលតែយប់គ្មានខាន ជាហេតុមិនឲ្យចៅជាយក្តាំងខ្វះអាហារបរិភោគ តាំងពីថ្ងៃដែលបានគ្នាគោះមក ។

ស្អែកឡើង ញាតិមិត្តបានបបួលចៅជាយក្តាំងម្តងទៀតថា "នែចៅជាយក្តាំង ឯងទៅចាប់ត្រីជាមួយនឹងយើងឬទេ"? ចៅជាយក្តាំងឆ្លើយថា "ខ្ញុំទៅវិញ" ។

ពួកញាតិមិត្តនាំគ្នាទៅ ។ ចៅជាយក្តាំងទៅតាមក្រោយ ។

អ្នកទៅមុនគាំងប៉ុន្មាន ចាប់បានត្រីត្រប់គ្រាន់ រួចហើយត្រឡប់មកផ្ទះវិញ
ទៅ ។ ចំណែកចៅជាយក្តាំងដើរ ទៅដល់មាត់ត្រពាំង ហើយក៏ឡើងទៅ
ដេកលើមែកគាំងដូចពីលើកមុន ។

ម្តងនេះទៀត, ព្រះឥន្ទ្រមកបញ្ឆោតចិត្តត្រីសំបៅ ឲ្យហែលមកកៀរ
មាត់ត្រពាំង ។ លុះឃើញត្រីហែលមក ចៅជាយក្តាំងចុះពីលើដើមគាំង
ហើយចោលមេដែកទៅចំត្រីនោះ ។ ត្រីគាំងបាស្រឡាំងកាំង ផ្ងារគោះឡើង
លើ ចៅជាយក្តាំងយកវល្លិទៅដោតត្រីគាំងបីនោះ ហើយយកមកផ្ទះ ។

កាលណោះ មានសេដ្ឋីម្នាក់ទៀត មានឆ្កែមួយ ។ ខ្ញុំកំដរសេដ្ឋីនោះ
ហាលជាយ ដើម្បីបុកធ្វើម្ហូប ។ ឆ្កែមកនាមលើជាយនោះ ។ ឃើញ
ដូច្នោះហើយ, សេដ្ឋីបង្គាប់ទាស: ឲ្យចាប់ឆ្កែទៅច្រាសចោល ។ ដើរ
ដល់ពាក់កណ្តាលផ្លូវ, ទាស:នោះ ជួបនឹងចៅជាយក្តាំង ដែលត្រឡប់ពី
ត្រពាំង ដោយមានត្រីសំបៅបីមកផង ។

ចៅជាយក្តាំងសួរទៅទាស:នោះថា អ្នកយកឆ្កែទៅណា ? ទាស:
ឆ្លើយថា យើងយកឆ្កែទៅច្រាសចោល ។

ភ្លាហើយ, ចៅជាយក្តាំងនិយាយថា បើអ្នកយកឆ្កែទៅច្រាស
ចោល អ្នកឲ្យមកខ្ញុំ ។ ឲ្យត្រីសំបៅពីរ ។

ទាស:ព្រមឲ្យឆ្កែទៅចៅជាយក្តាំង ។ ឲ្យត្រីសំបៅពីរទៅទាស: ។ ប្តូរ
ឆ្កែនឹងត្រីរួចហើយ ចៅជាយក្តាំងទៅសល់តែត្រីសំបៅមួយ ដើរទៅផ្ទះហើយ
នាំឆ្កែទៅផង ។ ទាស:ក៏ត្រឡប់ទៅផ្ទះវិញដែរ ។

លុះទៅដល់ផ្ទះកាលណា ចៅជាយក្តាំងឲ្យត្រីទៅដាំជូន ធ្វើម្ហូបថវៃកោត

ពេលយប់ ទៅនឹងដំណូនដែកចាំងអស់គ្នា ។ ស្អែកឡើង អ្នកចាំងពីរតែត
តែនិតខំធ្វើការចាំញឹមដដែរ តាមធម្មតា ដូចអ្នកឯចាំងពួង ។

ពីទ្បូរ យើងអធិប្បាយអំពីព្រះករុណា "ភូជិង្គ" (Bhûvajung,)
ស្តេចនាគដែលសោយភជសម្បត្តិ នៅក្នុងព្រះភជអាណាចក្រ "ផាតាល"
(Pâtâla) ។

មានកាលមួយថ្ងៃ នាគចាំងអស់ ដែលជាព្រះរាជាយាបស់ព្រះថ្មោគុដង្ក
ចាប់តាំងពីអគ្គមហេសីទី ១ ទៅមហេសីឯទៀត គ្រប់ថ្នាក់ មានព្រះចិន្តាចង់
យាងឡើងទៅក្រសាលក្នុងព្រៃ នាឋានមនុស្សលោក ។ ព្រះរាជាចាំង
នោះបានទាំគ្នាទៅគាល់ព្រះថ្មោគុដង្ក ដែលជាព្រះស្វាមី ដើម្បីក្រាប
បង្គំលា ។ ព្រះពុទ្ធជាំបានយល់ព្រម បើកឲ្យព្រះរាជាចាំងនោះ ចេញ
ទៅក្រសាលតាមព្រះចិត្ត ។ កាលណោះ នាគចាំងឡាងបានហោះ
ចេញទៅជាមួយនឹងបរិពារ ហើយបានទៅដល់ព្រៃ ដែលបឹតនៅជិតនគរ
ខេមបុរី ជាកន្លែងដែលទៅចាយក្តាំង នៅជាមួយនឹងជំដូន ។

ក្នុងចំណោមនៃព្រះរាជាចាំងនោះ មានមហេសីមួយព្រះអង្គព្រះ
នាមនាងទៅនាគ ដែលមានព្រះទេវដិតដល់ពេលប្រសូតស៊ុត ។ ទោះ
បីយ៉ាងណា ព្រះនាងនៅតែក្រសាលជាមួយនឹងគេទៅ ។ ព្រះនាងមាន
ព្រះចិត្តស្រឡាញ់កែកឈូ ហើយយាងទៅបេះផ្កានឹងផ្លែឈើបានយ៉ាងច្រើន
នៅក្នុងព្រៃនោះ ដែលព្រះនាងទុកដូចជាសួនមួយ ។

ខណៈពេលនោះ ព្រះនាងចាប់ឈឺព្រះទេវយ៉ាងខ្លាំងនឹងប្រសូតស៊ុត
ព្រះនាងគ្រាំពុំបាន ក៏យាងវែកចន្លែងស្ងាត់ក្នុងព្រៃ ឆ្ងាយពីនាគឯទៀត ។

ព្រះនាងរំជោសដ៏ច្រេច ទើបប្រសូតស៊ុត ហើយព្រះនាងយាងត្រឡប់មកទីកន្លែងវិញ ។

ស៊ុតនោះ មានចំនួនពីរយ៉ាងធំ ដោយហេតុមិនឲ្យព្រះនាងយកទៅបាន ក៏ចាលទៅកន្លែងប្រសូតនោះ ។ ក្នុងរឿងនេះ ព្រះនាងមិនមានព្រះបន្ទូលឲ្យព្រះជាយាគាំងឡាយជ្រាបទេ ហើយព្រះនាងយាងបេះផ្កាឥន្ធវែ្លឈើជាមួយនឹងគេទៀត ធ្វើហាក់ដូចជាគ្មានការអ្វីសោះ ។

លុះដល់ល្ងាច ពេលថ្ងៃលិច នាគីគាំងអស់នាំគ្នាហោះត្រឡប់ទៅនគរបាតាលវិញ ។

ពីមួយ យើងលើកយឿងញាតិមិត្ត ធំងអ្នកជិតខាងនៃចៅបាយក្តាំង មកអរិប្បាយវិញ ។

ពួកគាំងនេះ បានបបួលចៅបាយក្តាំងថា: នែចៅបាយក្តាំង! ព្រឹកស្អែកយើងទាំងគ្នាទៅរកចាប់អណ្តើក ធ្វើការហាមចរិកោតជាមួយនឹងខ្លែងយើង ។ ឯងទៅជាមួយខ្លះយើង ឬ ទេ ដ្បិតឯងទើបនឹងបានខ្លែងថ្មី ត្រូវលួងដាងខ្លែងយើង ។ ចៅបាយក្តាំងឆ្លើយថា ខ្ញុំទៅដែរ ។ ខ្ញុំចង់តាំសោនខ្លែលទើលព្រោះតាំងតាំខ្ញុំបានមក ខ្ញុំមិនទាន់បានទាំទៅចាប់អណ្តើកម្តងសោះ ។

ព្រឹកឡើងពេលថ្ងៃរះ ចៅបាយក្តាំងប្រាប់យាយឲ្យធ្វើបាយបរិភោគដ៏ដូនឆាំបាយមួយថ្នាំងពេញ ។ ចៅបាយក្តាំងដួសបាយទន់ ឲ្យខ្លែស៊ីស្រួចបួល ចំណែកខ្លួនឯងស៊ីបាយក្តាំង ។

លុះស៊ីរួចស្រេចហើយ ចៅបាយក្តាំងនិយាយទៅខ្លែថា មកណេះបងខ្លែ យើងទៅកន្លែងព្រៃ ចាប់អណ្តើកធ្វើម្ហូប ។

បន្ទាប់មក ចៅជាយក្តាំងនាំគ្នាចេញទៅ តែដើរតេចចេញតាំញាតិមិត្រទាំងអស់គ្នា ហើយចូលទៅកន្លែងព្រៃតែម្នាក់ឯង ។ អ្នកទៅជាមួយទាំងប៉ុន្មាន ចាប់ផ្តើមរត់ណែកគ្រប់ៗគ្នា ហើយត្រឡប់មកផ្ទះវិញ ។

ចៅជាយក្តាំងដើរតាមក្រោយក្តែហើយគិតថា បើអញជួបប្រទះអណ្តើកតាមផ្លូវ, ទើបអញចាប់ បើអញមិនឃើញអណ្តើកទេ, អញចាំស្តាប់ក្តែព្រុស ទើបអញដើរទៅមើល ។ លុះគិតដូច្នោះហើយ ស្រាប់តែក្តែស្ទុះសំរុកទៅក្នុងព្រៃភ្លាម, បានឃើញស៊ុតនាគីហើយ ក៏ព្រុសបដង់ព្រមទាំងបញ្ចេញសំរែកយ៉ាងខ្លាំងផង ។ ឮក្តែព្រុស, ចៅជាយក្តាំងមានចិត្តសប្បាយក៏កកយ, ទះដៃរត់តម្រង់ទៅរកក្តែ ហើយគិតថា ក្តែអញពិតជាជួបប្រទះនឹងអណ្តើក ទើបក៏ព្រុសដូច្នោះ លុះរត់ដល់ទីនោះ ចៅជាយក្តាំងបានឃើញស៊ុតនាគីពីរយ៉ាងធំ ហើយស្រែកថា អើ! អញបានស៊ុតអណ្តើកយកទៅស្ងោស៊ី ហើយរឿងស៊ុតនោះវេចស្តាយយកទៅផ្ទះ ។ ពេលនោះមិនដឹងជាថា ស៊ុតនាគីទេ ស្មានថា ស៊ុតអណ្តើក ទើបគិតកង់ចិត្តថា យកស៊ុតនោះស្ងោស៊ីឱ្យសប្បាយ ។

ព្រឹកស្អែក ចៅជាយក្តាំងនិយាយទំនឹងដីដូនថា យាយទៅខ្ចីឆ្នាំងខ្លះតូចអ្នកជិតខាងយើងមួយ យកមកស្ងោស៊ុតអណ្តើកស៊ីម្តង ។

ដីដូនទៅខ្ចីបានឆ្នាំងខ្លះតូចមួយ យកមកឱ្យចៅជាយក្តាំង ។ កាលដើរក្រោយបីមុំ យ៉ាងត្រឹមត្រូវហើយយកឆ្នាំងខ្លះទៅដាក់លើដើរក្រោននោះ ។ ចៅជាយក្តាំងដងឹកជាក់ឆ្នាំងខ្លះយ៉ាងតេញ ហើយទម្លាក់ស៊ុតនាគីទាំងពីរទៅក្នុងឆ្នាំងខ្លះ ។ នៅចំពុត ចៅជាយក្តាំងបង្កាត់ភ្លើងដើរក្រោន ឱ្យឆេះ

ខ្លឹង ។

"តាលបើឃើញដូច្នេះ អ្នកដឹតខាងមកបន្ត ។ គ្នា ហើយនិយាយទៅកាន់ចៅប្អាយក្តាំងថា នែចៅប្អាយក្តាំង! ឯងស្មោសុីតនោះទៅកុងភូមិយើងមិនល្អទេ ។ តាំងពីយើងដឹងក្តីមក, យើងមិនដែលឃើញសុីតឯណាធំដូចសុីតនេះ! បើឯងចង់ស្មោសុីតនោះសុី, ឯងទៅស្មោក្រៅភូមិទៅយពីផ្ទះយើងវិញទៅគ្នា! ។

ចៅប្អាយក្តាំង ឮ ហើយខឹងខ្លាំង ក៏ឆ្លើយថា "តំណាចនេះតឺអ្វី, គ្រាន់តែស្មោសុីតអណ្តើកសុីមិនបានដែរ? ។

បន្ទាប់មក ចៅប្អាយក្តាំងស្រង់យកសុីតចាំងពីរ ពីកុងឆ្នាំងខ្លះ ហើយខ្ចប់ចូលចាក់ទឹកចោល ហើយយកឆ្នាំងខ្លះពាក់លើស្មា, ហៅឆ្កែដើរទៅ ហើយយកកន្ត្រែងទៅផង ។

លុះដើរទៅដល់ព្រៃស្មាត់, ចៅប្អាយក្តាំងកល់ដើងក្រានបីមុំ ដើម្បីដាំឆ្នាំងខ្លះ ។ កំបុតណ្តើរឆ្កែទៅដងទឹកអណ្តើងយកមកចាក់កុងឆ្នាំងខ្លះ ។ រួចដាក់សុីតចាំងពីរទៅកុងខ្លះ ហើយដុតភ្លើងដើងក្រាន។ ក្រោយដែលចៅប្អាយក្តាំងបានរៀបចំស្មោសុីតនោះ ទើបហៅឆ្កែដើរត្រឡប់មកផ្ទះវិញ ។

ចៅប្អាយក្តាំងដើរបណ្តើរគិតបណ្តើរថា: "តាលបើសុីតឆ្ងន, អញវិលមកសុីវិញ" ។

ខ្ញុំនោះដាក់ពេលត្រង់ថ្ងៃ ដែលនាគត្រូវញាស់ចេញពីសុីត ។ លុះភ្លើងឡើងកំដៅហើយ ទឹកកុងឆ្នាំងខ្លះមានចំហាយ; នាគចាំងពីរបើរះចាល់តែបែកសុីត ។ ឆ្នាំងខ្លះដោយត្រូវកូនខាងក្នុងយ៉ាងខ្លាំងក៏ផ្ទាប់ខ្ទាក់

ឥតដើនក្រានទៅដ៏, ជាហេតុបណ្តាលឲ្យក្ងើរលេងអស់ ។ កូនខាត
ពីរធ្លាក់ទៅនៅក្រោមឆ្នាំនខ្លះ ហាក់ដូចជាមានអ្នកណាម្នាក់យកឆ្នាំនខ្លះ
នោះទៅគ្រប់ពីលើ ។

បន្តិចមក ចៅជាយក្តាំនគិតថា "ស៊ុតអណ្តើកអញ, ប្រហែល
ឆ្អិនហើយ ?" កំប្រញាប់ប្រញាល់ទៅមើលស៊ុតកន្ទុំឆ្នាំនខ្លះ, ឃើញឆ្នាំន
ផ្ទាប់ធ្លាក់មកដី ហើយបញ្ចេញសំរែកថា "អ្នកណាមានចិត្តអនិច្ចហ៊ាន
មកយកស៊ុតអណ្តើកអញ ហើយផ្ទាប់ឆ្នាំនខ្លះដូច្នេះ" ? ។

ចៅជាយក្តាំនដើរទៅជិត ហើយលើកឆ្នាំនខ្លះឡើង ពេលនោះ,
កំឃើញកូនខាតពីរ មានក្អែកធំប៉ុនស៊ុតមាន់ ។ ចៅជាយក្តាំនភ្ញាក់ព្រួយ
ញាក់យ៉ាងខ្លាំង ដោយមិនដឹងជាកូនខាត, ស្មានថាសត្វធម្មតា, ក៏តំ
ទៅរកដំបងយកមកវាយសម្លាប់ ។ លុះយារត្រចង់លើឆ្នាំនខ្លះ, ស្រាប់តែ
កូនខាតស្រែកថា ឧបង កុំវាយយើងធ្វើអ្វី ! ចូរបងអាណិតយើងចុះ,
កុំសម្លាប់យើង ! យើងមិនមែនសត្វធម្មតាទេ យើងជាត្រកូលនៃព្រះ
ចាខកូដង្គ ។ ព្រះមាតាយើង ព្រះនាមព្រះនាងតៅនាគី គង់នៅព្រះពន-
អាណាចក្រចាតាល ។ ព្រះមាតាប្រសូតយើងមក ចោលស៊ុតនៅក្នុង
ព្រៃមួយយ៉ាងស្ងាត់ ។ បងរើសស៊ុតនោះមកបំរុងទឹងស្មោស្មី ។ ឥឡូវ
យើងកើតមកចាន់រស់, យើងសូមអង្វរកបង ឲ្យអាណិតយើងផង ។
ចូរបងមេត្តាយើង ។ ទឹងដឹងគុណជាមិនខាន ។ សូមឲ្យបងយកយើង
ទៅលាក់កន្លែងស្ងាត់នៅក្នុងព្រៃ ដែលគេពុំសូវទៅមក ហើយចិញ្ចឹម
យើងផង ព្រមទាំងថែរក្សាជីវិតយើង ឲ្យបានគង់ទ្រង់ លុះត្រាតែកាល

ណាយើងមានសមត្ថភាព ទើបត្រឡប់ទៅកន្លែងយើងវិញប្រាកដ ។ ដូច្នេះ យើងដែលត្រូវជាប្អូនអ្នកមិនក្តៅចេ មុខជាតបស្នងសងគុណបងជាមិនខាន ។ បើពុកជាបងប្រាថ្នាបងបានអ្វី ក៏ប្អូនបំពេញចិត្តបងគ្រប់តែបាន ។

នេះជាពាក្យ ដែលកូនខាតទាំងពីរមួយញី, មួយឈ្មោល និយាយទៅកាន់ទៅឪពុកក្តាំង ។ លុះឮហើយ ទៅឪពុកក្តាំង មានចិត្តមេត្តាករុណាដល់កូនខាតនោះ ហើយក៏យកទៅលាក់ក្នុងព្រៃស្ងាត់ ។

កូនខាតនិយាយទៅកាន់ទៅឪពុកក្តាំងទៀតថា : ឧបង, បងរបងអាណិតយើង, ឲ្យឪពុកយើងស៊ីមួយថ្ងៃមួយក្តាប់ផង រហូតដល់ ១៥ ថ្ងៃ យើងនឹងធំមានកំឡាំងដើរបុិន ។ យើងខ្ញុំជាប្អូនអ្នក កាលណាទៅដល់ខាត, យើងនឹងឲ្យរង្វាន់អ្នកជាប្រាកដ ។

ដោយបានឮកូនខាតអង្វរករដូច្នោះ ទៅឪពុកក្តាំងមានចិត្តអាណិតអាសូរ ហាក់ដូចជាប្អូនខ្លួនបង្កើត ដែលចេញពីទេវមោតាជាមួយគ្នា ។

នៅវេលាពេលព្រឹក, ទៅឪពុកក្តាំងយកឪពុកមួយក្តាប់ទៅឲ្យកូនខាតតែរៀងរាល់ថ្ងៃ ។ លុះបានមួយអាទិត្យ, កូនខាតកំពុងឡើង ពេញបង្គៀតកន្ទេង ដែលដាប់នៅ, កូនខាតនោះនិយាយទៅទៅឪពុកក្តាំងថា: ឧបង ! យើងខ្ញុំនៅកន្ទេងនេះបង្គៀតណាស់ ។ សូមបងរកកន្ទេងដទៃទៀត ឲ្យយើងខ្ញុំនៅវិញ ។ ទៅឪពុកក្តាំងបានយកកូនខាតទាំងពីរមកពាក់លើស្មាយកទៅឪពុកកន្ទេងផ្សេង ហើយត្រឡប់មកផ្ទះវិញ ។

លុះកន្ទេងទៅបាន ១៥ ថ្ងៃ, ខាតបងនិយាយទៅខាតប្អូនថា: ប្អូនសំណាញ់, ឥឡូវ យើងទាំងពីរធំហើយ, មានកំឡាំងមាំមួន, យើងគួរ

តែតិះសាធហោះមើល ។ កាលគិតគ្នាដូច្នោះ នាគទាំងពីរសំដែងសេចក្តីគ្នាហាន ហោះទៅឯអាកាសយ៉ាងលឿន ហើយចុះមកនៅកន្លែងដដែលវិញ ។

មានថ្ងៃមួយ ពៅថ្មាយក្តាំងយកថ្មាយទៅឲ្យកូននាគ។ និយាយថា: ឧបជ! សេចក្តីល្អដែលឧបជបានធ្វើចំពោះយើងខ្ញុំ ជាបន្ទុកមួយហើងធ្ងន់ ដោយឧបជបានជំរុញមនទីរចង្រៃជីតាយើងខ្ញុំ ឲ្យបានធំមាំមួន ។ តវ្យវ យើងខ្ញុំសូមណាឧបជ[illegible]នាគនោគហើយ ។ ប៉ុន្តែ យើងខ្ញុំចង់ឲ្យឧបជទៅជាមួយនឹងយើងខ្ញុំ ។ កាលបើឧបជចង់ត្រឡប់មកស្រុកវិញតាមចិត្តឧបជចុះ ។ ពៅថ្មាយក្តាំងក្មេងតបថា: ប្អូនសំឡាញ់ទាំងពីរ! បើប្អូនចង់នាំឧបជទៅ, សុំប្អូនឲ្យចំពាក់ឧបជមួយ ព្រមសំពត់ស្តួច ដើម្បីឧបជស្លៀក, បើបានដូច្នោះ, ឧបជសុខចិត្តនៅជាមួយប្អូន ។ នាគទាំងពីរឆ្លើយថា: ឧបជទៅជាមួយនឹងយើងខ្ញុំសិន! យើងខ្ញុំនឹងការ: ទីឯសម្លៀកបំពាក់ឧបជ ។

ប្អូនសំឡាញ់! ប្អូនចង់ឲ្យខ្ញុំទៅជាមួយ ធ្វើម្តេចបាន, បើចេះហោះទៅអាកាសតែប្អូនទាំងពីរ, ចំណែកខ្ញុំមិនចេះហោះសោះ, ធ្វើដូចម្តេចខ្ញុំឆ្លងព្រៃធំៗ ឆ្ងាយ! ។

-ឧបជ! ឲ្យតែឧបជព្រមទៅជាមួយនឹងយើងខ្ញុំចុះ, បើឧបជមិនចេះហោះ, ឧបជឧបត្ថម្ភយើងខ្ញុំបាននហើយ ។

ពៅថ្មាយក្តាំងក្រមុំតាមនាគទាំងពីរទៅនគរព្រះបរមេស្វរជាតា ។ ប៉ុន្តែមុននឹងទៅ, ពៅថ្មាយក្តាំងទៅនិយាយប្រាប់ដីដូចថា: លោកយាយសំឡាញ់! ខ្ញុំសូមឲ្យលោកយាយដាំថ្មាយធ្វើទៅតាក ឲ្យខ្ញុំបរិភោគតាមផ្លូវ ។

ជាដូនសួរថា: ចៅ! ហេតុម្តេចបានជាចៅប្រាប់យាយឲ្យធ្វើចៅតាក? ឯងគិតចៅណា? ។ ចៅឆ្លើយថា: ខ្ញុំធ្វើដំណើរចៅប្រទេសធ្វាយ ។ លុះជាដូនដឹងបំណងចៅប្រាជ្ញហើយ, ក៏ដាំបាយធ្វើចៅតាក សម្រាប់ធ្វើដំណើរ ហើយខ្ចប់ស្បៀងអាហារនោះស្រេច ។

ចៅបាយក្តាំងផ្តាំទងជាដូនថា: លោកយាយជាទីស្នេហា! លោកយាយចិញ្ចឹមខ្ញែនឯងឲ្យខ្ញុំជនកុំខាន ។

បន្ទាប់មក, ចៅបាយក្តាំងយកកញ្ចប់ស្បៀងអាហារនោះស្ពាយហើយចុះពីរខ្ទមដើរចៅយ៉ាងឆ្ងាយ ។ លុះដើរដល់កន្លែងនាគក្តាំងពីរ, ក៏ស្រាយកញ្ចប់ ចែកបាយគ្នាស៊ី រួចខ្ចប់បាយនោះចៅវិញ ។ នាគនិយាយចៅគាន់ចៅបាយក្តាំងថា: បង! ចូរបងគោងកយើងខ្ញុំ ឲ្យជាប់មែនទែន ។ បើខុកជាបងឃើញអ្វី ។ ដែលគួរឲ្យបងរំលឹក ក៏កុំមើលឲ្យសោះ ខ្លាចឆ្ងាក់ ។ បងកុំក្រេបមណ្តាំយើងខ្ញុំ ។

នាគបន្ទាបកន្ទុយឲ្យចៅបាយក្តាំងគោងក ហើយហោះចៅអាកាស ។ គឺជាចម្ងាយឆ្ងាយដែលត្រាំដើរបីថ្ងៃ, ប៉ុន្តែ នាគហោះតែបីថ្ងៃ ។

បន្ទាប់មក, នាគបានឮឃើញបឹងមួយ ហើយហោះចុះមក ។ នាគបានដល់កន្លែង ដែលជាត្រាំដែនខែត្រពាណារសីទ្ធ ។

នៅទីនោះ, នាគនិយាយទៅចៅបាយក្តាំងត្រមាំងបង្ហុលបង្ហាញដើមឈើមួយថា: បង! ចូរបងពួន កន្ទុយដើមឈើនោះចុះ ។ យើងខ្ញុំខ្លាចក្រែងមានខ្មាន់ទៅទីនេះ មកដល់ដោយដួនឃើញបងចាប់ហែកស៊ី ។ ហេតុនេះ បានជាយើងខ្ញុំឲ្យបងពួន កន្ទុយដើមឈើនោះសិន ។ (មានត)

Contes et Légande
du Japon
par Félicien Challaye

រឿងព្រេងនឹងរឿងបុរាណនៃប្រទេសជប៉ុន

លោក ហ្វេលី ស៊ីយ៉ាង សម្បាយ រៀបរៀង

លោក ង៉ិយ--ប៊ុក ប្រែរៀបរៀង

១_រឿងព្រេងសាសនាស៊ិនតូស៊ូ

ការស្ថាបនាពិភពលោក

មានមេឃមានពណ៌ខៀវធំល្វឹងល្វើយ មានពពកសអណ្តែតត្រៃ-សែតពាសពេញ ។

គឺនៅទីនោះឯង ដែលពួកអនុអាទិទេពរស់នៅ ។

អនុអាទិទេព មានសភាពដូចគ្នាទាំងមនុស្ស ; តែមានអានុភាពធំជាង, ខ្លាំងជាង, ស្រាលជាង, ល្អជាង ។ ពួកអនុអាទិទេពត្រាច់ទៅដូចជាបក្សាហើរ ។ ដើងពួកនេះ មិនចាំបាច់ចុះមកជាន់ប្រថពីទេ ។ តែកាលរឿងព្រាំនេះ កើតមានជាបឋម, នៅលើមហាសមុទ្រមានតែប្រទេសអណ្តែត ; ផែនដី, ផែនដីពិតប្រាកដដែលមនុស្សជាតិរស់នៅ, មិនទាន់មាននៅឡើយ ។

នៅកណ្តាលមហាមេឃ មានកំលង់ទឹមលង្វាច គ្មានព្រំដែនទេពណ៌ស សដូចទឹកដោះ (គេហៅថាដើងក្តាយ តាំងពីនោះមក) ។

គឺនៅលើដើងក្តាយនោះឯង កាលសម័យថ្ងៃមួយ មានការប្រជុំពួកអនុអាទិទេព ដែលមានវិស្សាចាស់ជាងគេ ។

គឺត្រូវសម្រេចនូវកិច្ចការដ៏ឧត្តម: គឺត្រូវស្ថាបនានូវពិភពលោក ។

ការសម្រេចនេះប្លែកអស្ចារ្យ; ព្រោះហេតុអ្វីក៏ចានជា ឲ្យមានពិភពលោក ព្រមទាំងជីវិតសត្វ ឧទ្ធវត្តុងទៀត ? ព្រោះហេតុអ្វី ចានជាអនុគាមិ-ទេព មិនគេញចិត្តឲ្យមានត្រឹមតែសភាពបរិសុទ្ធ ដែនាមធម៌ប៉ុណ្ណោះ ? តើធ្វើបែបនេះប្រហែលជា ដើម្បីនឹងចង់ចំចាត់នូវលោក ពួកនេះដែលមានបំណងចង់ចានសត្វឧទ្ធវត្តុងទៀត ដើម្បីនឹងធ្វើសេចក្តីស្នេហា ប្រកបដោយសុខ្រឹតភាព ឲ្យកើត ឲ្យមានឡើង? ឬដោយការអផ្សុក ឧទ្ធវត្តុជីវភាពរបស់ខ្លួនដែលមានសភាពដដែល ។ ដូច ។ គ្នា មិនប្រែប្រួល ពួកអនុគាមិទេព មានប្រាថ្នាចង់តំណាន្តព្រះ ។ យ ចំពោះការទស្សនាមនុស្សជាតិ ដែលប្រព្រឹត្តទៅតាមវិស័យសត្វ ។ ខ្លួន នៅលើផែនដី ។

ពួកអនុគាមិទេព ចានណាត់ប្រជុំគ្នា នៅលើដើងភ្នំយមួយ ដើម្បីនឹងស្ថាបនានូវពិភពលោក ។

ពួកអនុគាមិទេពភាំងប៉ុន្មាន ក៏ចានប្រគល់កិច្ចការទាំងនេះមកទេវតាទាំងពីរប្រភេទ ទេវតាដំឡង់ម្នាក់ នាមអ៊ីដសាណាគី ឧទ្ធនាងទេវធីតាម្នាក់ នាមនាងអ៊ីដសាណាមី ។

ពួកវិចិត្រករ ឧទ្ធជាងឆ្នាក់ជប៉ុន ចានគួរឆ្នាក់រូបទេវតាទាំងពីរ ។ អ៊ីដសាណាគី មានសភាពជាបុគ្គលដំឡង់ ភ្នាំងមានសក់វែង មានពុកចង្កាវែងដូចសាសតេញមុខ: ស្លៀកពាក់សំពត់ពណ៌ស្រអែប ។ នាងទេវធីតាអ៊ីដសាណាមី មានសភាពដូចជានារីដប៉ុន្មានស្អាតល្អ មានក្បែកធំ

មានសក់វែងល្អក់លើស្មា: ប្រជានរទៀតតាស្រោបសុទ្ធតែសំពត់មានពណ៌ស . . . ។

ពួកអនុគាមិនទេពឯទៀត ស្រែកទៅគាន់អ្នកទាំងពីរនោះថា: "ចូរអ្នកស្រឡាញ់គ្នាទៅ, ចូរអ្នកធ្វើសមវិសំគ្នាទៅវិញទៅមក ។ ចូរអ្នកបង្កើត ចំរើនពិភពលោក ។ យើងសូមឆានាជាមុនថា អ្នកទាំងបានប្រសូតបុត្រ មានសភាពស្អាតល្អ មិនខាន" ។

អ៊ីដសាណាគី ទាំងនាងអ៊ីដសាណាមី បានព្រមទទួលទទួរបៃសកកម្មនេះ ដែលពួកអនុគាមិនទេពទាំងប៉ុន្មាន បានប្រគល់មក ដោយកិត្តិយស ។ អ្នកទាំងពីរក៏គ្រាប់ដើរសប្បាយ ។

អ៊ីដសាណាគី បានកាន់លំពែងទាសមួយ មានដាំត្បូងជាច្រើន, ខេវតាទាំងពីរ បានទៅដល់ស្ពានមួយ ប្រកបដោយអច្ឆរិយតរៈ, ធំសម្បើម ដូចជាមានសភាពមូលជារង្វង់ពាក់កណ្តាល ចោះទៅកន្លែមហាមេឃ ។ ខាងក្រោមស្ពាននោះ មានពណ៌ស្វាយ; ខាងលើមានពណ៌ខៀវស្រអាប, រួចខៀវក្តី, ខៀវខ្ចី, ក្រឿងខៀវ, លឿងក្រហម ដែលមានលំនាំស្អាតស្រស់, បើគេដើរសួរតាមស្ពាននោះ ពីមួយទៅមួយ មិនអាចឮសូរអ្វីឡើយ ។ នៅខាងលើស្ពាន មានពណ៌ក្រហម ដូចអាចម៍ល័ក្ក ។ ស្ពាននោះ មានសភាពសម្បើមអស្ចារ្យ ហើយមានទ្រង់ទ្រាយឥន្ទធនូ ។

អ្នកទាំងពីរឈប់នៅខាងលើស្ពាន មានសភាពដាច់ផ្តាច់មូល ពាក់កណ្តាលខាងក្រោមមានសម្បុរធំ, មានការចលនាជាទំនាន់, ទឹងសភាពខៀវ

ផ្លែមេឃដែលមានរលកតូច ។ សដូចជ្រាក់ កំពើកចុះឡើង ។

អ័ដសាណាគី ចាននយកលំពែងចាក់ចូលទៅ ក្នុងរលកប្រែត្រីចុះឡើងទៅមកជាច្រើនពោលថា: "កូរ៉ូ, កូរ៉ូ" ។

ស្រាប់តែមានចាជិហារឬទីមួយ កើតឡើង: គឺដល់អ័ដសាណាគី ដកលំពែងចេញមក, គេឃើញមានផ្កាក់ពពុះ ដែលអណ្តែតមកប្រជុំមួយគ្រាស, ប្រមូលមូលជាប់គ្នាទៅជាមានសភាពរឹងកើតទៅជាដី ។ គឺដីដំបូងដែលកើតមានឡើង ក្រោមមហាមេឃ; ដីតូច, ដីនោះតូចណាស់, ផែនដីមួយតូចណាស់ មានទឹកជុំវិញ គេហៅថាកោះអូណូគូរ៉ូ ។ ប្រៀបដូចជាប្រពឹកសមុទ្រ ហើរចុះមកទំលើថ្ម, អ័ដសាណាគី ខឹងនាងអ័ដសាណាមី នាំគ្នាចុះទាំងពីរនាក់ មកកាន់កោះតូចនោះ ។ ឧ! គួរសប្បាយណាស់; ដោយអ្នកទាំងពីរបានចុះមកកាន់ផែនដី ជាបឋមមុនគេ! ។

នាងទេវតាបានក្រេចន្ទវរសជាតិ នៃតាមតណ្ហានោះ ។ នាងក្មេងស្ទាន់សួតិ ដែលនាងចេញពីនោះមក ។ នាងក្មេងតូចទាំងអស់ ដែលនៅក្រៅពីបច្ចុប្បន្នកាល ។ នាងពោលថា យើងមិនអាចធ្វើចំយោយើងឲ្យទៅនឹងដួចតាលពីព្រឹកមុញ ។ ក្អែកនាងមានរស្មី ក្រឡេកទៅកាន់ក្អែក, សក់, មាត់, ដៃ, ជើង, រូបកាយទាំងអស់នៃអ្នកជាស្វាមីដែលមានលំអគួរបេតនា ។

នាងទេវធីតាពោលទៅកាន់ស្វាមីថា: "តើយើងនឹងតបរៀបការអាពាហ៍ពិពាហ៍ឬ?" ។

ទេវតាទាំងប្រុសស្រី ទាំងព័រនាត់ ទំសំឡក់គ្នាទៅវិញទៅមកដូច ទើបនឹងយើញគ្នាជាដំបូង ។ មាត់ញញឹមរេីបទៅកម៉ាត់ញញឹម ។ ទៅកន្លែកភាំពីនោក់ គេបានយើញសភាពទន្លូនដូចគ្នា ។

អ័ដសាណាគ៏ ទិន្នន័យអ័ដសាណាម៏ បានព្រមយកគ្នាជាប្តីប្រពន្ធ ហើយអ្នកភាំងព័រ រង់ចាំមើលកូនស្អាតល្អ ដែលទេវតាបានផ្សាយដំណឹងជាមុន ។

ទ ! គួរឲ្យអាណាចអធ័ម្មតន់តេក, កូនដែលកើតដំបូង ជាសត្វប្លែកពីធម្មតា គឺសត្វឈ្លើងមួយរំ ។ អ្នកភាំងព័រ មិនបង់រក្សាទុកន្លូវតែសត្វថែបនេះ ហើយក៏ដាក់កូនងាំឈ្លើងនោះ ទៅលើទូកដែលធ្លាប់តេីមដែត្រឹងបង់ប្រទាក់គ្នា ហើយក៏បណ្តែតពេងតាយ ទៅតាមទឹកនោះទៅ ។

កូនដែលកើតមកថ្មីទៀត គួរអួបដិត្តតន់តេក ម្តងនេះ គឺដូចជាគោះមានតភុស, ថែបតាតដូចជាសត្វមេដុស (Méduse) (១) មានសភាពតាក្រក់តន់តេក ។ អ្នកភាំងព័រមិនត្រមទួលស្គាល់ថាជាកូនរបស់ខ្លួន ។

១– មេដុស : មេដុសមានបងប្អូនស្រី ប៉ែនាក់គឺ: នាងមេដុស ១, នាងអេរីយាល់ ១, នាងសេន ១ ។ នាងទាំងប៉ែនាក់ប្រវែមរឿងទុក្ខាគឺអ្នកណាដែលមើលនាង, អ្នកនេះ នឹងក្លាយកេីជាថ្ម ។ រឿងទុក្ខាគនោះ ប្រែនមានចំពោះនាងមេដុស ។ ពីដើម, នាងមេដុសមានរូបឆោមរលាមពណ៌ស្រស់ប្រែមប្រិយ, តែដោយក្រវែបណ្តាសាព្រះនាងមិណែវ, សក់នាងក្លាយទៅជាពស់អាក្រក់តន់តេកណាស់ ។ ឯក្រោះចេះថា: ចនាងមេដុសនោះ ជំពាប្រវែមានរូបអាក្រក់ណាស់ ។

ដោយមានចិត្តព្រួយលំបាកជាខ្លាំង, ទេវតាទាំងពីរបូកក៏បានទៅសួរអនុគាមិទេពឯទៀត, ឲ្យពន្យល់អំពីហេតុផ្លែកអស្ចារ្យនេះ ។ ទេវតាទាំងពីរ បានសួរទៅអនុគាមិទេព ដែលចាស់ៗគ្រាជាន់គេ, ដែលជាលោកប៊ុនប្រសប់ស្គាល់ នូវអាថកំបាំងនៃជីវគោត, អនុគាមិទេពដែលជាអ្នកធ្លាប់ក្សាទុកនូវរឿងការ នៃសីលធម៌ តាំងពីសម័យបូកណា "ព្រោះហេតុដូចម្តេច, បានជាយើងមិនបានបុត្រក្អែ ដែលពួកអនុគាមិទេពបានសន្យាតាំងពីមុនមក ?" ។

ពួកអនុគាមិទេពទាំងនោះកំតបទៅវិញថា : "តើត្រូវបុរសស្ទួនជាមុនទៅកស្ត្រីជាកំណែ នេះជាធម្មនីយមហាមេឃ ... ។ នេះមិនដូច្នោះ, នាងអ័ដសាណាម៏ បានពោលពាក្យជាតំបូងមុនគេបង្អស់; តើនាងនេះឯង បានពោលពាក្យលួងលោម អ័ដសាណាគ៏ ឲ្យកន្ធជាកំណែ ... ព្រោះហេតុដូច្នេះ, បានជាអ្នកឯងមិនមានកូនល្អ តាមពាក្យសន្យា"។

បុរសអ័ដសាណាគ៏ ទើបនាងអ័ដសាណាម៏ ក៏មិនអាចតបទៅពួកអាទិទេពឯទៀយ ។ អ្នកទាំងពីរនាក់ក៏ខ្មាសចំពោះការបរទ្ធាសនៃពួកអនុគាមិទេព, ក៏ចាកចេញមកយ៉ាងមេឃ មកគាន់តែរបស់ខ្លួន ។

នាងអ័ដសាណាម៏ មិនអាចហ៊ានក្រឡេកមើល អ័ដសាណាគ៏ ឬពោលពាក្យមកកាន់បុរសសោះម្យ៉ាយ ។ នាងគ្រាន់តែទៅ, ក្សាលទុន, អាត់បិទ ។ តែបុរស អ័ដសាណាគ៏ មានសាទរចិត្ត ដោយឃើញដើរតាមស្ត្រីដែលមានរូបកាយល្អដាក់ខ្លួន, បុរសនេះ បានគន់មើលសក់, ក្បែរ, ចមូរមាត់, ដៃ, សព្វសាព័ងកាយទាំងអស់ ល្អឥតគណនា ។

បុរសនោះគិស្សរទៅនាងថា: "តើនាងយល់ព្រមថា យើងទាំងពីរ
នាក់ជាប្តីប្រពន្ធ ឬ?" ។

នាងគិញញឹមស្រស់, យល់ព្រម ។

ទេវតាទាំងពីរនាក់ក៏ចាកប្រព្រឹត្ត, ប្រតិបត្តិតាមបណ្តាំនៃពួកអនុអាទិទេពទាំងឡាយ: គឺបុរសចាន់តោលតាក្យជាបឋម ។ ការប្រតិបត្តិតាមពួកអនុអាទិទេព ។ ទីដ៏ឱ្យរង្វាន់ ។

ឥឡូវនេះ, ទេវតាទាំងពីរនាក់ក៏ចាន់បុត្រជារបស់; តើបុត្រនោះយ៉ាងណាទៅ! បុត្រនោះស្អាតស!

ព្រោះថាបុត្រនៃទេវតានោះ គឺកោះដប៉ុនេះឯង!

អើកោះដប៉ុន ដែលមានដី, ថ្ម, ភ្នំ, ខន្ធ, ដើមស្រល់, ដើមសឺរីស. តលវដ្ត, សត្វតិរច្ឆាន, ទីដ៏បុរសទាំងឡាយ នេះជាកូននៃនាងអ័ដសាណាមីទីដ៏បុរសអ័ដសាណាគី ។

× ×

ដំណើរទស្សនាការសហរដ្ឋអាមេរិក

នៃព្រះតេជព្រះគុណ ព្រះពោធិវង្ស ហួត_តាត

ចាងហ្វាងពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត ក្រុងកំពង់ញ

រៀបរៀងដោយ ជា.ទង់

សាស្ត្រាចារ្យទទួលការងារខាងការបង្រៀនអង់គ្លេស នៅពុទ្ធិកវិទ្យាល័យព្រះសុរាម្រិត

(តមក)

និយាយដោយសរុបទៀតទៅ ហើយដោយត្រង់ផង ជនជាតិអាមេរិកាំង ជាប្រជាជាតិ ជួយសង្គ្រោះយ៉ាងគ្មានឈប់ឈរ អ្នកមានជួយសង្គ្រោះអ្នកក្រ, អាមេរិកាំងចេះ ជួយអាមេរិកាំងល្ងង់, អាមេរិកាំងពេទ្យ ជួយសង្គ្រោះអ្នកជម្ងឺ ។ ឧទាហរណ៍ដូចជា ភ្លើងអគ្គិសនីនឹងទឹកម៉ាស៊ូនជាដើម ។ នៅស្រុកអាមេរិកគាំងមួល មើលចុះត្រង់ផ្ទះ គេសុទ្ធតែប្រើភ្លើងអគ្គិសនី នេះឯង មានម៉ាស៊ូនទឹក មានតេឡេហ្វូន មិនថាអ្នកក្រ អ្នកមាននៅក្នុងក្រុងឬស្រែចំការ ក្រៃគុំឡើយ ។ នៅក្នុងផ្ទះមួយ ។ ដែលយើងបាននៅឃើញ យើងសង្កេតឃើញមាន :

បន្ទប់ទទួលភ្ញៀវ ហៅថា Living room សឹងដាក់មានតុ កៅអី វែងខ្លី មានវិទ្យុទូរទស្សន៍ ហៅថា Television; មានវិទ្យុ, មានទូរស័ព្ទ ហើយក្នុងផ្ទះភ្លឺ ដោយពន្លឺអគ្គិសនី; បន្ទប់ដេក ពីរបួបី សឹងដាក់

មានពួកខ្មែរសស្គុះ; បន្ទប់ទឹកដែលមានគាង សំពាប់ដួតលាងដំរះកាយ; បន្ទប់បរិភោគ ដែលមានតុ តែមិនពុំបានតុ មានដើងគ្រានសម័យថ្មី ប្រើដោយកំលាំងអគ្គិសនី ឬ ឡល់ Gas សឹងមានគ្រឿងប្រើប្រាស់គ្រប់មុខ។ មានម៉ាស៊ីនលាងចាន ដុំឆ ម៉ាស៊ីនជោសសំពាមកំរេចធូលីក្នុងផ្ទះ; មានទូទឹកកកសំពាប់ដាក់គ្រឿងបរិភោគច្រើនបែប, ហើយនោះក្រោមផ្ទះ (ថ្នាក់ក្រោម bassement,) មានម៉ាស៊ីនជោកគក់លាងខោអាវ ម៉ាស៊ីនហាលខោអាវឲ្យទាប់ស្អួត ។ នៅផ្ទះខ្លះទៀតមានបណ្ណាល័យ តិដំកល់សៀវភៅសម្រួនល្អាប់នានា សំពាប់អាន, មានផ្ទះឡាន ។ គ្រែសាឡើមួយ ។ ច្រើនមានឡានយ៉ាងតិចមួយដែរ ។ ឡានឬថ្មេយន្ត ជាជំនិះចាំបាច់បំផុត, គេមិនអាចរកឃើញបានដោយគ្មានឡានឡើយ ។ សព្វថ្ងៃនេះមានជន ៧០ ភាគរយ ដែលមានឡានប្រើប្រាស់ ។ សម្បត្តិកន្លងទាំងអស់នេះហើយ ដែលញ៉ាំងជីវភាពរបស់គេឲ្យមានស្ទើរឯងរឿង ព្រោះគេចេះជួយជាតិគេ អាមេរិកាំងមានច្រើនច្រប់ច្រែន រួបរួមចូលជាមួយអាមេរិកាំងជាង (វិស្ស) បង្កើតជាសមាគមធ្វើផ្ទះ យ៉ាងមានរបៀបត្រឹមត្រូវ មានគ្រឿងប្រើប្រាស់សព្វគ្រប់ លក់ឲ្យអាមេរិកាំងក្រ យកថ្ងៃបន្តិចម្តងៗ ពាល់ខែ ។ ឡានមួយថ្លៃគួរនាថា ២០០០ ដុល្លារ គេយកតែ ៦ ដុល្លារ ១ អាទិត្យ ឬ ២៤ ដុល្លារ ១ខែ ។ ជួនកាលមួយឆ្នាំ ឡានមិនទាន់ជុនជាប់មក ជារបស់ខ្លួននៅឡើយទេ នៅជំពាក់ម្ចាស់ហាងខ្លះទៀត ។ ថ្លៃផ្ទះក៏ដូចគ្នា ជំនួនជាង៩ភាគក្នុងលាយប្រជាជនដែលមាន គឺថាក្នុងចំនួនប្រជាជន ១៦០ លាននាក់, ប្រជាជន

១០០ លាន មានឡានដឹកគ្រប់គ្នា ។ សព្វថ្ងៃទីក្រុងអាមេរិកាំង ដែលធំ ។ ស្ទើរតែរកកន្លែងចតឡាន មិនបានទេ គេធ្វើកន្លែងចតឡានជាច្រើនជាន់ ឡើងទៀត គ្រាន់តែកន្លែងចតឡាន មានដល់ទៅ ១១ ឬ ១២ ជាន់ ។ នៅក្នុងបរិវេណមហាវិទ្យាល័យ ដែលហៅថា University Campus នីមួយ ។ គេរាត់តកន្លែងយ៉ាងវែងធំទូលាយ ចម្ងាយប្រមាណ ១.៥០០ ម៉ែត្រជួនជ្រុង សម្រាប់ពួកនិស្សិតចតឡាន ។ ដោយប្រទេសនេះថា ប្រកួតនៃរថយន្តយ៉ាងនេះ ការរៀបចំផ្លូវគមនាគមន៍ ក៏ត្រូវធ្វើឲ្យបានស្រួលងាយ ទំនងធ្វើដំណើរទៅគ្រប់ទីកន្លែង ។ គេសាងផ្លូវថ្នល់ច្រើនបែបច្រើនយ៉ាងដូចខ្លះ :

១- គេសាងផ្លូវថ្នល់ធំ ។ ដែលអាចបើកឡានបួនទៅ បួនមកបានដោយកំរិតល្បឿន ៦០ ម៉ាយល៍ក្នុង ១ ម៉ោង ជាច្រើនក្នុងប្រទេសសំបាប់សំរួលដំណើរ តាមរថយន្តឬ ឡាន ។ ផ្លូវថ្នល់នេះ គេហៅថ្លាក់ខ្លះ ប៉ែកខាងកើត គេហៅថា Turnpike (ធ័រន ផៃខ៍), ប៉ែកខាងលិចគេហៅថា Freeway ដោយសំដៅសេចក្តីដូចគ្នាថា "ផ្លូវទំនេរ ឬ ផ្លូវដែលគ្មានអ្វីនាំឲ្យខ្ទេចខ្ទីឆ្ងាយ នាំឲ្យរំខានបើកឡាន មិនបានស្រួល" ។

២- គេសាងផ្លូវថ្នល់ធំម្យ៉ាងទៀត អាចបើកជារថយន្តពីរទៅ ពីរមក ដោយកំរិតល្បឿនពី ៤៥ ទៅ ៥៥ ម៉ាយល៍ក្នុង ១ ម៉ោង ជាច្រើនផ្លូវនេះ គេហៅថា U.S.Highway ប្រែថា "ផ្លូវជាតិសហរដ្ឋ ;

៣- គេសាងផ្លូវថ្នល់ធំ ចុះឡានមួយទៅ មួយមកផងទៀត ក្នុង

រដ្ឋទីមួយ ។ ផ្លូវនេះគេហៅថា State Highway "ផ្លូវជាតិរបស់រដ្ឋ" ។

ផ្លូវគាំង ៣ ផ្នែកខាងលើនេះ គេធ្វើខាក់ខនខ្លាត់ខ្លែងគ្នា ពីរដ្ឋមួយទៅរដ្ឋមួយ ។ ត្រង់តំខ្លែងណាដែលចរាចរឆ្លងកាត ដោយរថយន្ត ត្រូវបើកបរកាត់ចុះឡើង គេធ្វើស្ពានខ្លាត់ខ្លែងគរលើគ្នា ៣-៤ ជាន់ ចំមាខ្លែងស្ពាននេះ ហៅថា ស្ពានគោក (ដោយសន្មត់) ដើម្បីឲ្យស្រួលធ្វើដំណើរ ។ បើមានទឹសខាក់ទឹងខ្ទេតូច - ខ្ទេធំ ដែលសម្រួច ឬ ធកសម្រួច, គេធ្វើស្ពានឆ្លងទឹកយ៉ាងធំ ។ វែង ។ ប្រវែង ៨ ម៉ាយល៍, ៩-៦.៧ ម៉ាយល៍ ជាច្រើនខ្លែង, បើផ្លូវគាំងនោះទឹសទឹងតំបន់ ។ គេខំលាយកំ ធ្វើផ្លូវកែងរួងកំនោះទៅខ្លែង ។ ម៉ាងតែប៉ុណ្ណោះទេ គេធ្វើផ្លូវថ្នល់យ៉ាងស្អាត ។ គេលកុងត័ក្តចុះឡើង ។ ទៅលើកំពូលកំផងខ្លែង ។ ផ្លូវគាំងអស់ដែលគោលមកនេះ គឺជាផ្លូវគមនាគមន៍ តាមរថយន្ត ឬ ឡានក្នុងប្រទេស ។ រីឯផ្លូវចរាចរក្នុងទីក្រុងវិញ គេបានធ្វើឲ្យមានរបៀបរបបល្អណាស់ ។ មានផ្លូវបែកជាបី ទឹងផ្លូវបែកជាបួន, មានផ្លូវមួយដែលគេហៅថា One way ។ មានភ្លើងត្រាហ្វិក (Traffic light) ជាច្បាប់ចរាចរ ក្នុងទីក្រុង ទឹង ខែត្រ ស្រុកស្រែ ។ ភ្លើងមានបីពណ៌ គឺពណ៌ក្រហម ពណ៌លឿង ពណ៌ខៀវ មានន័យផ្សេងគ្នាយ៉ាងនេះ :

ភ្លើងក្រហម មានន័យថា ឈប់ (សំរាប់រថយន្ត, ឡាន, រទេះភ្លើងក្នុងក្រុង)

កុំដើរ (សំរាប់ជនអ្នកដើរ) ។

ភ្លើងលឿង " បង្អង់ ឬ ថា ប្រយ័ត្ន (ព្រោះភ្លើងខៀវកំពុងផ្ទាស់ទៅជាក្រហម)

ភ្លើងខៀវ " ទៅ ឬ ដើរឆ្ពោះចុះ

មានផ្លូវខ្លះ គេដាក់សញ្ញាក្រាប់ថា ឈប់ Stop, ថា កុំបត់ទៅខាងឆ្វេង No left turn, ថា កុំបត់ទៅខាងណាក៏ដោយ No turn, មានសញ្ញាផ្សេង ។ ច្រើនថែមណាស់ ដែលគេបានរៀបចំ ឲ្យបានស្រួលសំរាប់អ្នកបើកបររថយន្តគាំងឡាយ តាមប្រទេសរបស់គេ ។

ក្រៅពីផ្លូវគមនាគមន៍តាមរថយន្ត ធឹងតាមឡាន ដូចខ្ញុំបានជំរាបមក ដោយសង្ខេបនេះ មានផ្លូវគមនាគមន៍តាមរនេះភ្លើង ជារច្រើនទៀត ហើយដែលមានសមាគម ខាងរនេះភ្លើង ស្គាល់ឈ្មោះមិនអស់ទេ បើកបរចេញពីទីក្រុង ទៅទីក្រុងពាល់មៅង ។

នៅលើអាកាសវេហាស៍ នាឡើយ, អាកាសយាន ច្រើនឈ្មោះរបស់សមាគមផ្សេង ។ ហោះចុះឡើង ដឹកជញ្ជូនអ្នកដំណើរ តាមខ្នងមួយទៅតាមខ្នងមួយទៀត ច្រើនពាសពេញ ។ នៅចំណតអាកាសយានទៃទីក្រុងធំ ។ ដូចជា វ៉ាស៊ីនតុន Washington, ញូយ៉ក New York, ឈីកាហ្គោ Chicago, បស-តុន Baston, Los Angeles ឡូសអាន់ជើលិស, ន្យូអ័រលីន New Orleans San Francisco ជាដើម, អាកាសយានចេញបន្តគ្នា ចូលចុះចតបន្តគ្នា ពាល់ ៥ នាទី ។ អ្នកស្រុក, មុនទឹងធ្វើដំណើរទៅណា មកណាម្តង ។ តាមតុលាសរសៀមតាលរបស់គេ គេ

តែងសួរគ្នាថា ទៅដោយអ្វី ? ដោយរថយន្ត, ដោយរទេះភ្លើង, ដោយអាកាសយាន, ឬ ដោយទ្បាន ? ព្រោះមានន័យផ្សេងគ្នាយ៉ាងនេះ, គឺថាបើធ្វើដំណើរ ដោយរថយន្តផ្ទាល់ខ្លួន ត្រូវបើកបរផ្ទាល់ប្លុកគ្នា, បើកមួយរយៈ ឬ ពីរយៈមាំយល៍ម្នាក់ស្រួលម្យ៉ាងដែរ តែហត់ខ្លាំងបន្តិច ។ បើធ្វើដំណើរដោយរទេះភ្លើង ក៏ស្រួល ព្រោះអាចដើរលេងមើលឃើញស្រុកទេសភូមិឋាន ស្រែចំការអ្នកស្រុកផង អាចដើរចុះឡើង ឬ ឈរលេងលើរទេះភ្លើងបាន មានកន្លែងដេកក៏ស្រួល ហើយលឿនជាងទ្បានច្រើន តែខាសថ្លៃម្ហូបអាហារបន្តិច ហើយរទេះភ្លើងច្រើនតែបរកាត់ព្រៃភ្នំក្រុងផងចូលទៅដល់ខ័ណ្ឌធំ ។ ទីប្រជុំជនច្រើន ។ តែបរចូលក្នុងដីបើកគ្រាមដងទៅវិញ ។ បើធ្វើដំណើរតាមកប៉ាល់ហោះ ខាងរហ័ស ហើយថោកជាងធ្វើដំណើរតាមរទេះភ្លើងផង តែខាសមើលអ័ម៉ូនយើញក្រៅតពក ។ ទៅក្នុងឈ្នួល ក៏លឿនណាស់ដែរ តែខាសអង្គុយ ១ កន្លែងយូរ ។ ពេក ។ នេះជាការប្រៀបធៀបគ្នា មុនធ្វើដំណើរម្តង ។ នៃជនជាតិអាមេរិកាំង ។ ប្រជារដ្ឋគេបានស្រួល ហើយគេចង់ឲ្យរឹងរឹតតែស្រួលថែមឡើងទៀត ។

មានគ្រឿងម៉ាស៊ូនជាច្រើនទៀត ដែលសំរាប់សំរួលដល់ភាពប្រជាជនដូចជា ម៉ាស៊ីនច្បាប់ខោអាវ, ម៉ាស៊ូនសំង្ហតខោអាវ, ម៉ាស៊ូនលក់ជាវ ម៉ាស៊ូនលក់តែកក្រូច ទូទាទូទ្បា. ការក្រៅ តែដោះគ្រា, ម៉ាស៊ូនលក់តែមធ្វើសំបុត្រ, ម៉ាស៊ូនប្រឿង ដែលលុះណា តែជាក់លុយទើបប្រឿង ១ ជាស ឬ ២ ជាស ស្ងួយប្រវត្តិ, ទៀ ដែលលុះណាតែជាក់

លុយទើបមួលបើកស្តាប់បាន, ត្រូវដែលលុះណាតែជាក់លុយទើបចូលទៅបាន, ម៉ាស៊ីនបួកសេះ ៦សេះ នៅតាសតេញសហវដ្ត យើងសង្កេតឃើញម៉ាស៊ីនតូចនេះ ។ ក្រៅពីនេះ មានខ្សែសព្វសាធារណៈគ្រប់កន្លែង ដែលបើកមិនជាក់លុយ និយាយទៅមកមិនបាន ។ ក្នុងទីក្រុង នៅសង្កាត់លត់ដូរ ដែលហៅថា Dovoutovon ក៏ជាការក្រុងធ្វើបង្គោលបញ្ជរគ្រប់ទីកន្លែង សំរាប់ទ្រែតរថយន្ត តែមិនជាក់លុយក៏បតមិនបានសោះឡើយ ។ គ្រឿងម៉ាស៊ីនតូចអស់នេះ សំរាប់ជួយសំរួលសេចក្តីហត់ឲ្យ នៃប្រជាជន, ធ្វើឲ្យប្រជាជនមានការរស់នៅធូរស្រាល ហើយងាយផង ។ នៅហាងកាត់សក់, ជាងកាត់សក់មានកន្ត្រៃ ប្រើដោយកំលាំងអគ្គិសនី ក្រៅតែពីបើមិនពុត ដល់ការជើងសក់ស្រេច, ក្នុង ១៥ នាទីយ៉ាងយូរបំផុត ហើយកញ្ឆាលមួយថ្ងៃ ១ ដុល្លារ ៥០ សេនវង្វាន់ (ធីប tip) ២៥ សេនទៀត ត្រូវជា ១ដុល្លារ ៧៥ សេន។ ពួកកម្មករធ្វើការនៅកោងចក្រ, ពេលសួរហាកម្ម ទំងទីកន្លែងផ្សេង ។ ធ្វើការក្នុង ១ ថ្ងៃ ៨ ម៉ោង ហើយក្នុង ១ ម៉ោងបាន ១ ដុល្លារ ឬជាង ១ ដុល្លារបន្តិចបន្តួច ឯកត្រីក្រសំបាកណាស់ តែស៊ីឈ្នួលកូនតំណាលតូច។ ដោយដៃក្នុង ១ ថ្ងៃ គឺបាន៧ ទៅ ៨ ដុល្លារដែរ ។ ដោយពួកជនជាតិគាមេរិកាំង មានមុខរបរងាយ ។ ស្រុលរកលុយយ៉ាងនេះ ព្រោះមានគ្រឿងឧបករណ៍ចំបូងណា ឥតខ្លះខាតដូច្នេះ មុខជាទីងមានលុយច្រើនលើស ពីចំនួនដែលត្រូវចំណាយ ។

(មានត)

ពិធីបុណ្យបញ្ចុះអដ្ឋិធាតុបុព្វការី នៃលោក សាម-ឡាមុត

នៅវត្តស្វាយមាស ឃុំប្រទះឡាង ស្រុកភ្នំពេញ (កណ្តាល)

លោក សាម ឡាមុត រៀបរៀង

តាំងបុណ្យចាប់ផ្តើមតាំងពីថ្ងៃទី ៧ កញ្ញា ១៩៥៧ ម៉ោង ៨ ល្ងាច ដល់ ១ ភ្លឺឡើង ។

ឯកឧត្តមក្នុងពិធីបុណ្យនេះ លោក ង៉ែម-ប៊ុក លោក ខៀវ-ម៉ី លោក អ៊ុក-ធន់ ក្នុងនាមនៃសមាគមមិត្តភក្តិវិទ្យាល័យ លោក សម-ម៉ន ក្រសួងយោធាការ ទីឯកត្តេជតួជាច្រើន ។ លោក សម-ម៉ន តាងនាម លោក សាម-ឡាមុត ទីឯត្រូវការឯកឧត្តមថា ១ ដូចយើងទីឯ ចុះឆ្លាយៗទៅខាងក្រោម ម៉ោង ៧ ល្ងាច ក្រសួងយោធាការ ឯកឧត្តមបញ្ជាឱ្យ ។

ម៉ោង ៧ កន្លះល្ងាច ព្រះសង្ឃសូត្រសត្តបរិត្តកណាកិធម្ម ។

ម៉ោង ៨ យប់ព្រះតេជព្រះគុណព្រះនាម ឆុត លៀតអភិការវត្តខាងត្បូង (ភ្នំកណ្តាក់) សំដែងធម៌ទេសនា ព្រះធម្មគារព ។

ម៉ោង ៩ យប់ព្រះឃ្លាំងភ្លឺ សាសនវង្ស រស់-កែវ វត្តតាកូវង្ស៊ី សំដែងធម៌ទេសនា បឋមត្រាស់ ។

ម៉ោង ១១ ព្រះសង្ឃតីរអង្គ សូត្រតុឱ្យគតិសោក ។

ម៉ោង ១២ យប់ បញ្ចុះអដ្ឋិធាតុ ស្មឹកគោដំព្រីក្ស ព្រះបដិមាករ ដំ ១៣ ក្នុងដំណែលព្រះសម្មាសម្ពុទ្ធ បដិច្ចសមុប្បាទធម៌ ។ល។

ក្នុងពេលដែលបញ្ចុះ មានព្រះសង្ឃសូត្រដរង្គោ សព្វបុរត្តិមាយ ។ល។

ព្រឹកឡើងថ្ងៃ ១៤ កើត ខែ ឆ្នាំ ជវីស ម៉ោង ៧ ព្រឹក ប្រគេនយាគូ ដល់ព្រះសង្ឃ ម៉ោង ១១ ប្រគេនភត្តាហារ ដល់ព្រះសង្ឃដែលនិមន្តមកពីក្នុងក្រុងនិងក្រៅក្រុង មានព្រះតេជព្រះគុណ សាសនមុនី មាស-កង ព្រះញាណគោសល ញាណ-ឈឹន ព្រះវិន័យធរ ឯក-ញឹម ព្រះតេជព្រះគុណ អនុគណ អឹង-ឡាំ ចៅអធិការ វត្តជម្ពូវែន ព្រះតេជព្រះគុណ ជួង-ង៉ែន ចៅអធិការវត្តស្វែង ព្រះតេជព្រះគុណ ង៉ុយ ចៅអធិការវត្តតាំងរនាម និងព្រះសង្ឃគាំងអស់ ក្នុងវត្តស្វាយមាស ម៉ោង ៤រសៀល សំដែងធម៌ទេសនាសង្គីយនា មានធម្មកថិក ២ អង្គ គឺ ព្រះញាណគោសល ញាណ-ឈឹន និងព្រះវិន័យធរ ឯក-ញឹម ចោទនេ្ទយ ។

បុណ្យនេះបានចប់សព្វគ្រប់នៅម៉ោង ៤ រសៀល ។

សូន្យរកថា

សូមនមស្ការចំពោះព្រះរតនត្រ័យ

ដោយគោរព !

សូមថ្វាយបង្គំចំពោះព្រះចេកន្ទុត្តរៈគ្រប់ព្រះអង្គ ដោយគោរព !

សូមជំរាបដល់អស់លោក-អ្នកតុ្ចបរិស័ទ សប្បុរសប្រុស ស្រីទាំងឡាយ

សូមមានជ្រាប សូមជ្រាប ។

ឥឡូវនៃថ្ងៃនេះ ជាខុទ្ទកឫក្សដ៏ប្រសើរ ជាមង្គលដ៏ប្រសើរដល់យើងខ្ញុំទាំងអស់គ្នា ដោយមកពីមនោសញ្ចេតនា នៃយើងខ្ញុំទាំងអស់គ្នា មានចិត្តប្រកបដោយកតញ្ញូចំពោះទេយ្យការគុណបុគ្គលបុរស របស់យើងខ្ញុំទាំងឡាយ

មានត្រូវបង្ហាញដោយការ មាតាបិតា បុត្រ ភរិយា ជាដើម ដែលខ្ញុំសូម
អនិច្ចធម្ម អនិច្ចកម្ម ទៅកាន់បរលោកនាយ អស់កាលជាយូរហើយ តែ
យើងខ្ញុំទាំងអស់គ្នា ពុំបានមានឱកាសទំនឹងតបស្នងសងគុណ ដល់បុព្វបុរស
ទាំងនោះ ទើបតែក្នុងថ្ងៃនេះយើងខ្ញុំទាំងអស់គ្នាបានត្រមត្រៀងបរិច្ចាគ
ទ្រព្យធ្វើបុណ្យជាទានវិត ដើម្បីឧទ្ទិសកាតដល់ដ៏ទុកដ្ឋម ដែលទើបតើតមាន
ទៀងក្នុងពេលនេះ ប្រគេនដល់ចំពោះទៅវិញ ណាក្នុងបុព្វបុរសទាំងឡាយ
ដូចមាននាមតទៅនេះ គឺ លោកគ្រូសូត្រ អ៊ុក-ញ្ហួង លោកឧបាសក
សូ-សាម ឧបាសិកាអ៊ូ-ទឹម សម្តេចព្រះឥសីកន្ត្រៃ រស់-ម៉ាំង ឧបាសក សំ
ឧបាសិកា សុត មេស្រុក អ៊ិច-សាលី នាង ខន់-សឿន នាងឡាមុត
សូនេ បាល។ បុញ្ញកម្ម ដែលបានកសាង ក្នុងពេលនេះគឺ ១- សៀវ-
ភៅធម៌ សម្រាប់សូត្រពុទ្ធាភិសេក ដែលត្រូវនិន្នាការ ឯក ញឹម ទីធ-
ឡាត់សាសនវង្ស រស់.តែវ ត្តពិតពួរង្វី បានរៀបរៀង តាមព្រះថេរដីកា
សម្តេចព្រះសង្ឃនាយក គណៈមហានិកាយ ទីធ:សៀវភៅនៃប្រយោគ
ធម្មបទ ដែលលោកស៊ីវ:ហុង (កុមារតទ្យ) បានចូលជាធម្មទាន ។

២ - ព្រះរាជតិយដែលបានស្តាបនា អំពីឥដ្ឋទីនស៊ីម៉ង់ត៍ នៅលើ
ខឿនព្រះវិហារ ។

៣ - ព្រះពុទ្ធរូបប្រាក់ ទម្ងន់មួយណែន ដែលម្តាយធំនាម សូ.អ៊ីង
បែកពុកជាស្ត្រីមគ៌ត តាំងពីកាលដែលៈលោកនៅ, លុះលោកអនិច្ចកម្ម
ទៅ ខ្ញុំយល់ឃើញថា គួរយកប្រាក់ណែនទោះ កសាងជាព្រះពុទ្ធរូបពុក
ជាអនុស្សាវរីយ៍ សម្រាប់នមស្ការបូជាផ្ទាល់ខ្លួនខ្ញុំផង នៃពួកពុទ្ធបរិស័ទ

ទាំងឡាយផង ដើម្បីជាទីបង្អែមក្នុងបុណ្យ ជាឱកាសដែលលោក ទេបាសិកា សូ អ័ង ផង ។

៤- ស្វឹកព្រះពោធិព្រឹក្ស ២ សន្ទឹក មួយសន្ទឹកដែលលោក ប៉ុយ ប៊ុក ប្រធានសមាគមមិត្តភក្តិវិញ្ញាល័យ នាំយកមកឲ្យ គាលលោក អញ្ជើញទៅសន្និបាត នៅប្រទេសឥណ្ឌា ក្នុងពេលបុណ្យពុទ្ធជយន្តី ព.ស.២៥០០ វស្សា ។ មួយសន្ទឹកទៀត គណៈប្រតិភូវេជ្ជបណ្ឌិត (ក៏លី. ស៊ីណា) អគ្គលេខាធិការជាតំណាងសមាគមមហាពោធិ ប្រទេសឥណ្ឌា ដែលអញ្ជើញមកសន្និបាត នៅប្រទេសកម្ពុជា ក្នុងពិធីបុណ្យពាត់កណ្តាលព្រះពុទ្ធសាសនា គាលពីថ្ងៃ ១៤ កើតខែពិសាខ មកទល់នឹងថ្ងៃ ៥ រោច ខែពិសាខ ព.ស. ២៥០០ វស្សា បានចែកមកឲ្យខ្ញុំព្រះករុណា ខ្ញុំ ជាទៅលើសណ្ឋាគារ ថៃសាន ដែលគណៈកម្មាធិការភ្ញៀវសមាគម ប្រទេសកម្ពុជា បានអញ្ជើញវេជ្ជបណ្ឌិត (ក៏លីស៊ីណា) នេះ ទីឯគណៈ ប្រតិភូចិនពីអង្គព្រះនាម (ជ័ម្ពុន) ជាប្រធានអធិការវត្ត ចេអាង ក្រុងសាំង ហាយ មួយអង្គទៀត ព្រះនាម (យ៉ី ហ្សួន) នៅវត្តភ្នាងដីប៉ែកាំង មក លៀងតោជនាហារ ជាមិត្តភាព នៅថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ១៩៥៧ នៅពេលម៉ោង ១០ ទៅទល់នឹងម៉ោង ១៣ កន្លះ ។

៥- ដើ ១៣ កន្ទៃនជាបូជនីយស្ថានក្តីដ៏ណែលព្រះសម្មាសម្ពុទ្ធទៅ ក្នុងប្រទេសឥណ្ឌា ដែលព្រះថេរៈ ព្រះនាម ង្ហ្វិន-ង្ហន អាចារ្យបង្រៀន កម្មដ្ឋាន នៅវត្តស្ថានខ្ពែ (ខួលតឹង) យកមកចែកជូនដល់ពុទ្ធបរិស័ទ ពុកជាទីគោរពតៈ ។

៦- គ្រឿងអង្ហរក្សារមានព្រៃត្រចីរជាដើម ។

៧- ព្រះធម្មទេសនា-ធម្មគោរពទីមួយគ្រាស់ ដែលព្រះធម្មកថិក គឺព្រះបាឡាត់សាសនវង្ស រស់-កែវ បានតង់លើធម្មាសនៈនេះទីទេសនា ចែកជូនដល់ពួកពុទ្ធបរិស័ទ ក្នុងគ្រាឥឡូវនេះ ។

ប៉ុន្តែកិរិយាវត្តុតាំងឡាយ ដែលបានរៀបរាប់មកខាងលើតាំងប៉ុន្មានគឺជាទំនិត្តរូបមួយ សម្រាប់ឲ្យកើតបុណ្យ ហេតុនេះយើងខ្ញុំដែលជាតានាសាមីបានជាត់ចែងក្នុងពេលនេះ សូមឧទ្ទិសកាតផលដ៏ខ្ពង់ខ្ពស់នេះម្តងទៀត ដោយសុទ្ធចិត្ត ចំពោះទៅវិញ្ញាណក្ខន្ធ នៃបុព្វបុរសតាំងអស់ ដូចមានឈ្មោះខាងលើ សូមឲ្យលោកបានទទួលឯកន្តវាសដ្ឋមនុញ្ញផលជាទីគាប់ចិត្តនេះ បើប្រសិនណា ជាវិញ្ញាណក្ខន្ធបេតបុព្វបុរសណាមួយ មានគតិភ្លាំងភ្លាត់ថ្ងោះត្បាយ ទៅកើតក្នុងអបាយភូមិក្តី កំសូមឲ្យទេវញ្ញតព្រះនេត្រទិព្វព្រះស្រោតទិព្វ បានឃើញ បានស្តាប់ប្តេជ្ញាពាសី ដែលយើងខ្ញុំតាំងអស់គ្នា បានឧទ្ទិសប្រគេន ជូនទៅក្នុងពេលនេះ សូមឲ្យដំណឹងដល់បុព្វបុរសដែលភ្លាំងភ្លាត់តាំងនោះថា នៅទីនេះមានញាតិមិត្រសាច់សាលោហិតជាដើម បានឧទ្ទិសផលមកជូនហើយ សូមអនុមោទនាយកចំណែកបុណ្យ, បើបុព្វបុរសតាំងនោះ បានអនុមោទនាបួចហើយ សូមឲ្យបានរួចរំដោះពីកន្លែងតាំងពួង ហើយសូមឲ្យបានឡើងទៅកើតសុគតិភព គឺឲ្យបានជាទេវតានឹងមនុស្សជាដើម; ឬ មួយបើបុព្វបុរសតាំងអស់ ដូចមានឈ្មោះខាងលើ បានសុគតិភពស្រាប់ហើយ កំសូមឲ្យរំលឹកតែចំរើនសុខស្រួលឡើងជាតំណាក់កាលទៅទៀត ។

នៅទីបំផុតនៃសុន្ទរកថានេះ យើងខ្ញុំសូមទទួលភាគទក្ខិណានេះ ជូនដល់ឥន្ទ្រាយមយក្ស ទេវតាអ្នកគាំពារក្នុងទេវតា គាំងឡាយដែលបិតនៅលើដើមឈើតូចធំក្តី នៅក្នុងព្រះវិហារនេះក្តី នៅលើព្រះចេតិយក្តី ព្រះពោធិព្រឹក្ស នៅទាបក្រោមឡគាំងឡាយក្តី សូមទេវតាគាំងឡាយនោះ ទទួលយកផលានិសង្ស ដែលយើងខ្ញុំគាំងអស់គ្នាទទួលជូនទៅនេះ ។

មុនទំងបញ្ចប់សុន្ទរកថានេះ យើងខ្ញុំសូមឱ្យកុសលដែលកើតឡើងអំពីបុណ្យគាំងឡាយគ្រប់ប្រភេទ ដូចមានខាងលើនេះ ចូរមានដល់យើងខ្ញុំ ដែលជាទានសាមីព្រមគាំងពួកពុទ្ធបរិស័ទគាំងឡាយ ដែលគង្វេញមកពីកំពេញ ឬទៅទីនេះក្តី សូមឱ្យបានប្រកបដួបប្រទះតែនឹងសេចក្តីសុខចំរើនតរៀងទៅ តាមលំដាប់ភព ហើយសូមឱ្យបានដួប នឹងកុសលវិបុលសុខដ៏ធំឧឡារ កុំបីឃ្លាតឡើយទៅជាប្រការៈដទៃឡើយ ។

ចប់សុន្ទរកថា ។

ពិធីបុណ្យបូជាព្រះសពសម្តេចព្រះធម្មលិខិត

ល្វី-ឯម ឧត្តមប្រឹក្សាគណៈមហានិកាយ

គង់អធិការវត្តលង្កា ភ្នំពេញ

លោកវ៉ាយ-ប៊ុត រៀបរៀង

ថ្ងៃបុណ្យទី ១.

ថ្ងៃអង្គារ ១១ កើត ខែមិគសិរ ឆ្នាំរកានឆ្នូសក

ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៣ ខែធ្នូ គ.ស. ១៩៥៧

ថ្ងៃនេះ ជាថ្ងៃដែលពួកគ្រហស្ថ បព្វជិត ឧបាសក ឧបាសិកា បាន សំដែងគារវកតញ្ញូ ចំពោះសម្តេច ដូចធ្លាប់តែបានធ្វើជាយ៉ាងក្រៃលែង ។

មើ៉ងដប់ប្លន់, ព្រះស្ងួរយោគីបរាញ្ញាវស្ន ដ៏ត្រជាក់ស្រួចខ្លាំងមិនក្តៅពេក មិនត្រជាក់ពេក ថ្ងៃមួយមានពពកខ្មៅងងឹតដុំៗ ហាក់ដូចជាខ្លាំងបង្អុរភ្លៀង តែមិនបង្អុរភ្លៀងទេ ពួកពុទ្ធសាសនិកជន ចាំងបព្វជិតចាំង គ្រហស្ថ បានឈរជាជួរ នៅតាមផ្លូវចេញព្រះបរមសពមុន ខាងមុខវត្តលង្កា រង់ចាំដង្ហែព្រះសព នៅតាន់ឈូលព្រះមេរុ ខាងជើងព្រះបរមពាតាំង ។

មានក្រុមកូនព្រះពាជទ្រព្យ ក្រុមគាហានក្សាព្រះអង្គ ក្រុមកូនខ្ញុំ ថ្នាក់ នាម៉ឺនសព្វមុខមន្ត្រី បព្វជិតគ្រហស្ថបានដង្ហែព្រះសព ដោយរថយន្ត ដែលរចនាដោយរូបនាគ រំលេចដោយភ្លើងភ្លាត់ឡើងភ្លាត់ ជាយ៉ាងអឺកធឺក គឹកកងរំពង ប្រហែលជាង ១០.០០០ នាក់ ។

មុនទទឹងរំកិលព្រះសពយកមកតម្កល់ និមន្តសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយកគណៈមហានិកាយ ទទឹងសម្តេចព្រះសុធម្មាធិបតីសង្ឃនាយកគណៈធម្មយុត្ត ព្រមទាំងព្រះកិក្ខុសង្ឃ ៨០អង្គ ចំរើនសត្តបរិត្តរាណាកិធម្ម; និមន្តព្រះមហាវិមលធម្ម ខេត ជាព្រះអកិធម្ម តំណាងសម្តេចព្រះមហាសុមេធាធិបតីសង្ឃនាយក គណៈមហានិកាយ ។

ការរំកិលព្រះសព គឺធ្វើចំពោះមុខព្រះពជតំណាង ក្រុមឧត្តមប្រឹក្សានៃព្រះពជា ប្រធានសភាទាំងពីរ ទទឹងគណៈរដ្ឋមន្ត្រី ។

ម៉ោង ១៩ ទទឹង ៣០ នាទី ក្បួនដង្ហែក៏ចេញពីមុខវត្តលង្កា តាមវិថីព្រះចន្ទសីហនុ បត់តាមមហាវិថីព្រះចន្ទនពេត្តម ឆ្ពោះទៅខាងជើង ដល់មុខតំណាក់ព្រះអង្គសុភានុវង្ស ឈប់សម្រាក ១០ នាទី ដើម្បីនិមន្តព្រះសង្ឃវត្តបុទុមវតី ៨០ អង្គ ចំរើនសត្តបរិត្តរាណាកិធម្ម បន្តក្បួនហែបត់ត្រង់វិថីព្រះអង្គមឃវន ទៅខាងកើត ដល់ត្រង់ជ្រុងវត្តសាកវន តេជោ សម្រាកចំនួន ១០ នាទី ដើម្បីនិមន្តព្រះសង្ឃវត្តខោះ ៨០ អង្គ ចំរើនសត្តបរិត្តរាណាកិធម្ម ដល់ជ្រុងព្រះមេរុ ត្រង់ពេងភាពយន្តតារា សម្រាក ១០ នាទី ដើម្បីនិមន្តព្រះសង្ឃវត្តឧណ្ណាលោម ៨០ អង្គចំរើនសត្តបរិត្តរាណាកិធម្មមួយទៀត បត់ក្បួនហែតាមមហាវិថីសម្តេចសុធាវាសមកខាងត្បូង ចូលកាលព្រះមេរុតាមទ្វារខាងកើត ។

លុះក្បួនហែដល់ព្រះមេរុហើយ លើកព្រះគ្រោដ្ឋហែប្រទក្សិណព្រះមេរុ ៣ ដង រួចគឺយកទៅដំកល់លើបញ្ជាំបីជាន់កន្លែងព្រះមេរុ ។

ព្រះសង្ឃជាច្រើនពាន់អង្គ មានសម្តេចព្រះសង្ឃនាយកទាំងពីរ គណៈជាប្រមុខ គង់នៅព្រះពន្លាខាងជើង រង់ចាំធ្វើតាវៀកច្ចុ ។ខាងត្រហស្ន មានក្រុមព្រះពជវង្សពុទ្ធវង្ស ប្រធានសភាទាំងពីរ គណៈរដ្ឋមន្ត្រី មន្ត្រីធំ-តូច នៅលើវេទិកាកិត្តិយស រង់ចាំធ្វើតាវៀកច្ចុ ។ បន្ទាប់មក ឯកឧត្តម សាន-យ៉ុន ព្រះពជតំណាងបានអញ្ជើញមកដល់ ។ ក្រោយដែលទំនួញ កិត្តិសង្ឃ៨០ អង្គចំរើនសត្តបរិតរណាភិធម្ម ព្រះពជដំណាងនឹងនាម៉ឺន សត្តមុខមន្ត្រី (ពហានអសេខិក) សំដែងនូវតាវៀកចំពោះព្រះសព ។

ក្នុងពេលនោះ ព្រះអាទិត្យដ៏តេជអស្តង្គត ទិសានុទិសបាប់ក្រាលសំពត់ខ្មៅ ងងឹតល្មម់មកលើកលត្រមេរុ ព្រះមេរុកំបាំងភ្នែកវិស័យចំញាប ដេញកំចាត់ងងឹតអស់ទៅវិញ តាំង្រួចរន្ទាបពេញសំឡេងនូវភ្លុសូរសព្ទ ដូចគ្នារលាន់ ឬកាំភ្លើងធំ សំដែងនូវតុគាតភ្លៀលខ្លាត់ស្ទុះសំរេងលើនភាល័យ ជាតិច្ចតាវៀកព្រះសពសម្តេច ។

លំដាប់តមក គណៈកម្មការបុណ្យ បានទំមន្តព្រះសង្ឃ១ចំ អង្គចំរើនព្រះបរិត្ត សូត្រព្រះធម្ម រួចទំមន្តធម្មកថិកមួយអង្គទេសនា ។

ថ្ងៃបុណ្យទី ២-

ថ្ងៃពុធ ១២ កើតខែមិគសិរ ត្រូវនឹងថ្ងៃទី ៤ ខែធ្នូ

វេលាម៉ោង ១០ ព្រឹក ពលព្រះមេរុ មានការវៀរភត្តទំនប្រគេនសាដកចំពោះព្រះសង្ឃ ដែលចំរើនព្រះបរិត្តទំនសូត្រព្រះធម្មពីល្ងាច ដើម្បីទុទ្ទិសដល់ទិសង្ឃ ប្រគេនចំពោះវិញ្ញាណក្ខន្ធសម្តេចព្រះធម្មលិខិត ស្ងួ-ឯម ។

ចាប់ពីម៉ោង ១៨ តទៅ ពិធីបុណ្យបានប្រព្រឹត្តទៅដូចថ្ងៃទី១ ។

ថ្ងៃបុណ្យទី ៣-

ថ្ងៃព្រហស្បតិ៍ ១៣ កើត ខែមិគសិរ

ត្រូវនឹងថ្ងៃទី ៥ ខែធ្នូ

ថ្ងៃនេះជាថ្ងៃដែលត្រូវបូជាព្រះសពសម្តេច ព្រះធម្មលិខិតស្ងួ-ឯម ។ ជំបូង, មានការរៀបចំគ្រឿងបូជា តាំងពីម៉ោង ៦ ព្រឹក, មានក្រុមភ្នាក់-ងារ រំកិលព្រះកោដ្ឋចុះចាកបញ្ជា ទៅដំកល់នៅថែវខាងលិច ហើយមានការរៀបគ្រឿងជាន់ សម្រាប់បូជាព្រះសព ។ រួចហើយមានពិធីនិមន្តឡត មកដំកល់គ្រឿងជាន់ សម្រាប់បូជាសព ក្នុងព្រះមេរុវិញ ។ នៅពេលនោះ ពួកចារគូបានដុំសង្ឃ ហើយភ្លេងខ្លងខែក ក៏បានបញ្ចេញសូរសព្ទ ជាបទមណោសញ្ញា គួរឲ្យគរណាចអធម្មនន់ពេក ។

ពេលម៉ោង ១១ ទឹង ១៤ នាទី ក្រុមព្រះពជវង្សានុវង្សនឹងឥស្សរជនជាច្រើន បានស្តេចយាង អញ្ជើញមកតង់អង្គុយ នៅលើវេទិកាកិត្តិយស។ គេក្រឡេកទៅឃើញសម្តេចក្រុមព្រះ ស៊ីសុវត្ថិ-មុនីវ៉ង្ស សម្តេចព្រះពជកទិដ្ឋារស្ម៉ីសេតំណ , ក្រុមព្រះពជវង្សានុវង្ស, លោកឯកឃី-អ៊ុនប្រធានវដ្ឋសភា, លោក សម-ញ៉ាណ ប្រធានក្រុមប្រឹក្សាព្រះពជអាណាចក្រស្តីពី សមាជិកនៃសភាតំណាងរាស្ត្រ លោក ស៊ុម.ព័ នាយករដ្ឋមន្ត្រី សមាជិករដ្ឋាភិបាល ; ពួកការទូត , មន្ត្រីជាន់ខ្ពស់ ។

លំដាប់តមក, បានឮព្រះសង្ឃ ៨០ អង្គ ចំរើនសត្តបរិកាណ-កំឆត្ត ។

ដល់ម៉ោង ១៧, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង សម្តេចព្រះមហាក្សត្រីយានី ដោយមានឯកឧត្តម ឡេង វ៉ែត ខឹងឯកឧត្តម សាន.យុន សមាជិកឧត្តមក្រុមប្រឹក្សា អមព្រះអង្គ ជាទៀព្រះរាជដំណើរមកផង ស្តេចយាងមកដល់ ។

ក្រោយដែលទ្រង់គង់ប្រថាប់ លើព្រះសុវណ្ណាគោច្ចៈ ក្នុងព្រះពន្ធាគត្តិយសហើយ លោក មាស.យ៉ង់ អនុរដ្ឋលេខាធិការ នៅក្រសួងធម្មការ ជាន់ឡើងថ្វៃងសុន្ទរកថា ដូចយើងខ្ញុំបានជម្រាបជូនខាងក្រោយ ។

នៅគេលថ្វៃងសុន្ទរកថា យើងបានត្រឡែកមើញពួកពុទ្ធមាមកជន ទាំងបុរសស្ត្រីខ្លះ មានទឹកភ្នែកហូរចេញរហាម ខ្លះមានទឹកមុខស្រងូតស្រងាត់ រលេងរលោងទឹកភ្នែក, ខ្លះរកតល់ចន្លឹំ សំដែងសេចក្តីសោកស្តាយ ចំពោះព្រះសព ។

លុះចប់សុន្ទរកថាលោកមាស.យ៉ង់ហើយ ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង, សម្តេចព្រះមហាក្សត្រីយានីទ្រង់ស្តេចយាងយកផ្កាខ្ទឹមចន្ទន៍ទៅជាក់លើព្រះកោដ្ឋ នៃព្រះសពសម្តេច ។ ទើបសម្តេចក្រុមព្រះ មុនីវង្ស, សម្តេចព្រះពជកនិដ្ឋាវស្ថិសោភ័ណ, ក្រុមព្រះពជវន្ទ្យាទុវង្ស, ក្រុមឧត្តមប្រឹក្សាព្រះពជា, ប្រធាននៃសភាទាំងពីរ, នាយករដ្ឋមន្ត្រី និងសមាជិករដ្ឋាភិបាល, សមាជិកសភាទាំងពីរ សមាជិកអង្គុតូត, មន្ត្រីធំៗតូចៗ, បានយកផ្កាខ្ទឹមចន្ទន៍ ទៅបូជាព្រះសព ។ លំដាប់តមក, នៅម៉ោង១៧, នឹង៣៥,នាទី ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្តេចយាងទៅកាន់ព្រះមេរុ ដើម្បីប្រគេនភ្លើងចំពោះព្រះសព ។

ម៉ោង ១៧, នឹង ៤០នាទី ព្រះមហាក្សត្រ ទាំងព័ររព្រះអង្គ ស្តេច យាងត្រឡប់ ទៅកាន់ព្រះបរមរាជវាំងវិញ ។

បន្ទាប់មក, ព្រះសង្ឃដែលមានសម្តេចព្រះសង្ឃនាយក ទាំងព័រ គណៈជាប្រធាន តមក ។ ឧបាសក។ ឧបាសិកា, ក្រុមសិស្សានុសិស្ស ជាប់រៀបរាន ចាយកផ្កាទឹមចន្ទន៍ ទៅដាក់លើព្រះកោដ្ឋ, ។

លុះដល់ម៉ោង ២០, មានការទំមន្តព្រះសង្ឃ តំណាងសម្តេចព្រះ សុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្តនិកាយ ។

ម៉ោង២០នឹង៣០នាទី, មានការអុជកាំជ្រួចភ្លើងខៀន ភ្ញីចញ្ចាចពេញ ។ល។ព្រះមេរុ . . . ។

ថ្ងៃបុណ្យទី ៤-

ថ្ងៃសុក្រ ១៤កើតខែមិគសិរ ត្រូវនឹងថ្ងៃទី ៦ខែធ្នូ

ថ្ងៃនេះ មានពិធីរែសព្រះធាតុរបស់សម្តេច ។ មានពួកជាតូចាន ទៅសូត្រធម៌, រួចមានអាចារ្យមួយរូប ចាយកព្រះគន្ធារំលត់ព្រះអង្គារ ។ ក្រោយដែលព្រះសង្ឃ ៤ អង្គ សូត្រសត្តបរិកណាតិធម្ម ប្រៃព្រះរូប រែស ព្រះអង្គ, ត្រហស្ថ បព្វជិត មករែបតាមលំដាប់ដាខាងក្រោយ, មានការ ធ្វើពិធី "សាមហាប" មានត្រឿងចង្អាន់ ឧទ្ទិសកិត្តារផ្សេង។ ជាបីអម្រែក, មានបុរសស្លៀកសំពត់អម្រែករែរប្រទក្សិណព្រះមេរុបីដុំ។ ក្នុងពេលនោះ គេក្រឡេកទៅឃើញមានសម្តេចក្រុមព្រះ សុីសុវត្ថិ.មុនីរ៉ែត, ព្រះពោធិវង្ស ហួត.តាត ចាងហ្វាងតុទ្ធិតខ្លាលយ៉ព្រះសុពម្រឹត, ព្រះញាណាគោសល ញាណ-ឈឺន, ព្រះតុន្តវង្ស កៅ.សុីម, បព្វជិត, ត្រហស្ថ, ទ្រង់ស្តេច

ទំមន្ត, អញ្ជើញទៅកាន់ព្រះមេរុដែរ ។ លំដាប់តមក, មានការដង្ហែ
ព្រះអង្គារ ចុះទូកយកទៅបំផ្លេងកណ្តាលទន្លេចតុមុខ ។ រួចមុខក្រសួងបាន
រៀបបញ្ជា ហើយទំមន្តព្រះអដ្ឋទៅតំកល់លើបញ្ជាវិញ ។

ម៉ោង ១០, ទំមន្តព្រះសង្ឃ ៤៤ អង្គ ប្រគេនបង្ហាន់ទេយ្យទាន,

ម៉ោង ១៨, ទំមន្តព្រះសង្ឃវត្តលង្កាទាំងអស់ បំរើនសត្តប្បការណា-
ជម្ម ។ លំដាប់តមក ទំមន្តព្រះសង្ឃ ២០ អង្គ បំរើនព្រះបរិត្ត, ព្រះធម្ម-
កថិកមួយអង្គ សំដែងព្រះបឋមសម្ពោធិ រួចរៀបចំធ្វើពិធីអភិសេក
ព្រះភ្នំរូប ដោយមានព្រះសង្ឃ ២ អង្គ សូត្រតាមអភិសេក ។

ថ្ងៃបុណ្យទី ៥.

ថ្ងៃសៅរ៍ ១៥ កើត ខែមិគសិរ ត្រូវនឹងថ្ងៃទី ៣ ខែធ្នូ

ពេលម៉ោងដប្រឹកដប្តូរដុំបពូដិត ទំនឹគ្រហស្ថជាច្រើន, ហែព្រះអដ្ឋ
ដោយមានភ្លេងខ្ទរខ្ទារគ្រប់គ្រាំ ទំនឹក្បួនហែយ៉ាងវែង មកកាន់វត្តលង្កា ។

ពេលម៉ោង ៨, មានឥស្សរជនទាំងបពូដិត គ្រហស្ថជាច្រើន ជានទំមន្ត
ទំនឹអញ្ជើញមកកាន់វេតាកិត្តិយស ពីមុខព្រះវិហារ, ជិតក្រោង្គណ៍មួយធំ ។

ឯកទាំងបពូដិត មានសម្តេចព្រះមហាសុមេធាធិបតី សង្ឃនាយកគណៈ
មហានិកាយ, សម្តេចព្រះសុធម្មាធិបតី សង្ឃនាយកគណៈធម្មយុត្ត, ព្រះ
ពោធិវង្ស ហួត-តាត, ពជាគណៈ, ឋានានុក្រម, ព្រះភិក្ខុសង្ឃទាំងឡាយ,
ឯកទាំងឥស្សរជន ទាំងគ្រហស្ថ មានសហជីវិនឯក-ឃីអ៊ុនប្រធានវេជ្ជសភា
សហជីវិនសម-ញាណ ប្រធានក្រុមប្រឹក្សាព្រះពជអាណាចក្រស្តីទី,
សហជីវិន ស៊ុម-ភ័ នាយករដ្ឋមន្ត្រី, សមាជិកនៃសភាទាំងពីរ, សមាជិក

រដ្ឋាភិបាល, មន្ត្រីធំ-តូច ។ ប្រាសាទ ប្រាសាទ នាហាន អារេមនាងជាច្រើន។

ម៉ោង ៨ និង ១០ នាទី, សម្តេចក្រុមព្រះស៊ីសុវត្ថិមុនីយ៉ាងមកដល់លំដាប់តមក, ម៉ោង ៨.១៥, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ស្តេចយាងមកដល់ព្រះពន្ធាភិត្តិយស ដោយមានឯកឧត្តមសាន-យុនសមាជិកឧត្តម-ប្រឹក្សាអមព្រះអង្គ និងព្រះពជបរិពារ ដង្ហែព្រះអង្គ ជាព្រះពជភិត្តិយស ។

មានគាន់មន្តព្រះសង្ឃ ៨០ អង្គ ចំរើនសត្តបរិកណាភិធម្ម រួចស្រែច ទើបឧកញ៉ាមហាឧត្តមា-អ៊ីន ថ្វាយព្រះកោដ្ឋ ដែលតម្កល់ព្រះអដ្ឋិ សម្តេច ក្សត្រ-ឯម, ថ្វាយទៅព្រះករុណាជាអម្ចាស់ជីវិតលើត្បូង។ ទ្រង់ព្រះពជទានទៅសម្តេចក្រុមព្រះស៊ីសុវត្ថិ-មុនីវេត ។ ខ្លួលយកទៅបញ្ចុះដំកល់ក្នុងប្រាង្គណ៍ ។

ក្រោយដែលព្រះសង្ឃសូត្រដងន្ទោ, មានក្មេងពិណពាទ្យ បន្ទឹមវៃសរសៃល្អឺងល្អើយ គួរឲ្យអណោចអធម្មតន់ពេក ។

លំដាប់តមក, ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង ទ្រង់ស្តេចយាងលែងត្រឡប់ មកព្រះបរមរាជវាំងវិញ ។ ម៉ោង ១០, មានតិជាក់ជាត្រ ចំពោះតិក្ខសង្ឃ ៨០ អង្គ ក្នុងវត្តលង្កា ។

ម៉ោង ១៧ មានតិជ ទេសនាសង្គាយនា ក្នុងព្រះវិហារជាកិច្ចបង្ហើយ

បុណ្យព្រះសព ។

សុន្ទរកថា នៃសហជីវិន មាស_យ៉ង់ អគ្គរដ្ឋលេខាធិការ ក្រសួងធម្មការ ថ្លែងក្នុងពិធីបុណ្យប្រគល់ព្រះសពសម្តេចព្រះធម្ម-លិខិតល្វី_ឯម ទុតមប្រឹក្សាគណៈមហានិកាយ ទៅអធិការវត្ត លង្កា កាលពីថ្ងៃព្រហស្បតិ៍ទី ៥ ធ្នូ ១៩៥៧ ។

សូមព្រះតេជៈដ៏គង់លើស្នួង ;

សូមព្រះភគវាន្តគ្រាបបង្គំទូលព្រះគុណា ជាអម្ចាស់ដ៏វិសេស!

.. សម្តេចព្រះមហាសង្ឃត្រៃយាន៍!

.. សូមទ្រង់ជ្រាបក្រោមស្តេចធួលព្រះបាទ ។

ទូលព្រះបង្គំជាខ្ញុំ សូមព្រះភគវាន្តថ្លែង ខ្ញុំអំណរព្រះគុណ ចិត្តគុណ ដ៏ត្រាលជ្រៅ ចំពោះព្រះគុណាជាអម្ចាស់ដ៏វិសេសលើស្នួង សម្តេចព្រះមហា-សង្ឃត្រៃយាន៍ សម្តេចព្រះឧបយុវរាជ ដែលទ្រង់ព្រះមេត្តាជ្រោស ស្តេចបានយាងមកជាព្រះរាជាធិបតី ទីធ្លាព្រះរាជាធិវាសនី ក្នុងពិធីបូជាព្រះសព នៃសម្តេចព្រះធម្មលិខិត ព្រះនាម ល្វី ឯម ទុតមប្រឹក្សា គណៈមហានិកាយ ក្នុងវេលានេះ ។

បន្ទាប់ពីនេះ ទូលព្រះបង្គំជាខ្ញុំ សូមព្រះភគវាន្តព្រះបរមរាជវិ-រាស ថ្លែងជាឯកវចនៈបន្ទូលប្រគល់ព្រះសព នៃសម្តេចមានសេចក្តីដូចតទៅនេះ :-

សម្តេចព្រះធម្មលិខិត ល្វី.ឯម ប្រសូតនៅ ថ្ងៃច័ន្ទ ៥ កើត ខែពិសាខ ឆ្នាំកេរ៉ឹងសំរឹទ្ធិ ព.ស.២៤៦២ គ.ស.១៩១៩ នៅសង្កាត់លេខ ៣ ក្រុងភ្នំពេញ មាតានាម ច្រាក់ បិតានាម ម៉ាន់ ជាចាងហ្វាងព្រះឃ្លាំង នៅ

ព្រះបរមរាជាំង ក្នុងរជ្ជកាលព្រះករុណា ព្រះបាទសម្តេចព្រះនរោត្តម ព្រះសុវណ្ណគោដ ។

កាលកុមារ ល្វី-ឯម មានអាយុ ១០ ឆ្នាំ ឪពុកបាននាំទៅឲ្យរៀនព្រះត្រៃបិដក ក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជព្រះនាម ខៀង បានបួសជាសាមណេរនៅវត្តឡាយុ ១៥ ឆ្នាំ ហើយសិក្សាព្រះបរិយត្តិធម៌ បានចេះដឹង បានធ្វើជាគ្រូបង្រៀនកិក្ខុសាមណេរជាច្រើនរូប ។

ក្នុង គ.ស. ១៨០០ សាមណេរ ល្វី ឯម មានវស្សាយុ ២១ ឆ្នាំ បានទទួលសម្បទាជាកិក្ខុ ក្នុងសំណាក់សម្តេចព្រះមហាសង្ឃរាជ ជាព្រះឧបជ្ឈាយ៍ ព្រះភូវង្ស នន្ទ ទីឆព្រះមង្គលទេពាចារ្យ កុយ ជាឧបសម្បទាចារ្យ បានទាមទាវជើរឬក្លាញ ។

ក្នុង គ.ស. ១៨០៦ សម្តេចព្រះមហាសង្ឃរាជ បានចាត់កិក្ខុ ល្វី-ឯម ឲ្យទៅធ្វើជាចៅអធិការវត្តស៊ីធរ ស្រុកឧព្រាច់កណ្តាល ខែត្រកណ្តាល ។ កាលកិក្ខុ ល្វី-ឯម បានធ្វើជាចៅអធិការហើយ បានបំពេញគន្ថធុរៈ ទីឆវិបស្សនាធុរៈ ព្រមទាំងបានរៀបចំវត្តភ្នោះ ឲ្យរុងរឿងដោយទីសេនាសនៈ ទីឆដោយកិក្ខុសាមណេរសិក្សាធម៌ជាន់ច្រើន ។

ក្នុង គ.ស. ១៨១១ ព្រះករុណាព្រះបាទសម្តេចព្រះប៉ុស្សុវត្តីមុនីវង្ស កាលទ្រង់នៅជាព្រះអគ្គមហាសេនាធិបតីនៅឡើយ ទ្រង់ស្និទ្ធឆសម្តេចព្រះមហាសង្ឃរាជ សុំយកកិក្ខុ ល្វី-ឯម មកធ្វើជាចៅអធិការវត្តលង្កា ក្រុងភ្នំពេញវិញ ។ កាលបានធ្វើជាចៅអធិការវត្តលង្កា កិក្ខុ ល្វី-ឯម បានព្យាយាមស្ថាបនាវត្តនេះ ឲ្យបានជាវត្តធំដុំ មានកិក្ខុសាមណេរច្រើនជាល់

៧០០ ឡើងបួសដែលមកអំពីត្រប់ខែស ក្នុងព្រះពុទ្ធសាសនាចក្រកម្ពុជា អំពីកម្ពុជាក្រោម ទឹងអំពីប្រទេសលាវ មកនៅរៀនសូត្រធម៌វិន័យ ហើយទឹងបានស្ថាបនាគ្គលឡើង ឲ្យបានជាវត្តរុងរឿង ដោយចំណែនាសនៈមានព្រះវិហារសាលា ទឹងកុដិធំ ៗ ជាច្រើន មានផែនដីស្មៅ ផ្ទៃវាត់ខ្នែង កំពែងឥដ្ឋស្ទើរតែជុំវិញ ។

ព្រះករុណាជាម្ចាស់ដ៏តេលើក្បាលទ្រង់សព្វព្រះពុទ្ធហឫទ័យទឹងវីរិយសម្បត្តិរបស់កិក្ខុ ល្អ ឯម បានទ្រង់ព្រះមេត្តាប្រោស ប្រគេនសមណសក្តិ ដល់លោកតាំងឥដ្ឋាន់ថានា ដល់ថ្នាក់ឯក គឺ

គ.ស. ១៩០២ ជាព្រះគ្រូវិមលបញ្ញា,

គ.ស. ១៩១៤ ជាព្រះញាណបវរវិជ្ជា,

គ.ស. ១៩១៥ ជាសាស្ត្រាចារ្យសាលាជាលើជាន់ខ្ពស់,

គ.ស. ១៩២៩ ជាបាឋហ្វាងសាលាជាលើជាន់ខ្ពស់,

គ.ស. ១៩៣២ ជាអធិបតីក្រុវិនិច្ឆ័យព្រះត្រៃបិដក,

គ.ស. ១៩៣២ ជាព្រះសិរីសម្ពត្តវង្ស,

គ.ស. ១៩៤២ ជាព្រះធម្មលិខិត,

គ.ស. ១៩៤៩ ជាសម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា គណៈមហានិកាយ ។

សម្តេចព្រះធម្មលិខិត ឧត្តមប្រឹក្សា ល្អ ឯម ជាសាស្ត្រាចារ្យ ឧអង្គជំនាញខាងការប្រែតម្រាជាលើ បង្ហាត់សិស្សានុសិស្ស ហើយជាធម្មកថិក ឧអង្គឈ្មោះលៃ ខាងក្បាសុំដែងធម្មទ្ទានព្យួចរិស៍ ទឹងជាអ្នកនិពន្ធ ឧអ

ចុំនប្រុសប់ ខាងការរៀបរៀងធម៌វិន័យ ពុកជាសារប្រយោជន៍ ក្នុងព្រះពុទ្ធ-
សាសនា ដូចខានស្នាព្រះហស្ត ដែលសម្តេចបានរៀបរៀង ជាសៀវភៅ
ច្រើនព្រះគម្ពីរចំនួន ១៣ មុខ មានសៀវភៅឈ្មោះញាណកថាជាដើម ដែលពុទ្ធ-
សាសនបណ្ឌិត្យ បានចែកផ្សាយក្នុងឆ្នាំបុណ្យនេះ ជាតំណាង ។

សម្តេចព្រះធម្មលិខិត ខ្ពុមប្រឹក្សា ស៊ូ-ឯម បានសាងកុសលកិច្ចជា
ច្រើនប្រការ ក្នុងព្រះពុទ្ធសាសនា តែកូលព្រះបង្គំជាខ្ញុំ សូមព្រះរាជទាន
អភ័យទោស ដោយពុំបានរៀបរាប់សព្វគ្រប់ ក្នុងទីនេះ ។

ដោយហេតុសម្តេចព្រះធម្មលិខិត ខ្ពុមប្រឹក្សា ស៊ូ-ឯម ប្រកបដោយ
គុណសម្បត្តិច្រើន ដូចតាំងមកនេះហើយ ទើបមានទទួលគ្រឿង
ឥស្សរិយយស គឺ

គ.ស. ១៩១៧ មេដាយមុខិសារគណៈប្រទេសកម្ពុជា,

គ.ស. ១៩៣២ មេដាយអស្សវិន្ទប្រទេសកម្ពុជា,

គ.ស. ១៩៣៣ មេដាយសឹកសិរយើងដើរឡាវឡេស៊ីយុងជាណ្តើរ
ប្រទេសចិនកំពង់ ។

សូមទ្រង់ព្រះមេត្តាប្រោស!

សម្តេចព្រះធម្មលិខិត ខ្ពុមប្រឹក្សា ស៊ូ-ឯម ចាប់មានអាពាធតាំងដើម
ឆ្នាំ ១៩៥៦ ព្រះកុណ្ឌាជាអម្ចាស់ដ៏តែលើតួនតាំងពីព្រះអង្គ ទ្រង់ជាន
ចាត់តេទៅមកភ្ជាប់ជាល ដោយព្រះនុសង្គ្រោះពេទ្យជាប់ជានិច្ច ក្រុម
សិស្សានុសិស្ស ទីងពុទ្ធបរិស័ទ ជាទបង្កើតគណៈកម្មការ ១ សម្រាប់
ទទួលការព្យាបាលអាពាធនោះ ឥតឮសប្រហែស ប៉ុន្តែនោះប៉ុន្តែពេទ្យ

ឆំ ។ ប្រកបទុសចរិតសេស ។ យ៉ាងណា ក៏ពុំអាចសង្រេងបាន ។ ដកញ្ជូនធម៌ណៈដ៏កំណាច បានផ្តាច់ដួលព្រះជន្មាយុសង្ខារ នៃសម្តេចឱ្យអន្តិចធម្មៈទៅនៅថ្ងៃ ៩ កើត ខែពិសាខ ឆ្នាំរកា នព្វស័ក ព.ស. ២៥០០ ត្រូវនឹងថ្ងៃទី ៧ ខែឧសភា ព.ស ១៩៥៧ វេលាម៉ោង ៥ ទឹក ៤០ នាទីក្តី ក្នុងព្រះជន្មាយុ ៧៨ ឆ្នាំ វស្សា ៥៧ ។

ទុក្ខកដ៏ធំយោរយៅ ! ពុំគួរអ្នកមកកាត់យកជួនវិញ្ញាណ នៃសម្តេចទៅ ដោយឥតមេត្តាដល់តិចសោះ ធ្វើឱ្យពុទ្ធបរិស័ទ៍ទាំងអស់គ្នា ត្រមាំងសិស្សក្តុងសិស្ស ហាន១ខ្លួលសេចក្តីទុក្ខក្រៀមក្រំ ទើរសេចក្តីសោកស្តាយរកទីបំផុតគ្មាន ដូច្នេះឡើយ ។

ចរិយាសម្បត្តិដ៏ថ្លៃថ្លា ទឹង សារប្រយោជន៍ដ៏ឧត្តម សម្តេចបានបំពេញសព្វគ្រប់ហើយ សូមសម្តេចបានសម្រេចសម្បត្តិមនុស្ស សម្បត្តិសួគ៌ ទឹងសម្បត្តិព្រះនិព្វាន សមគួរតាមផលបុណ្យ ដែលសម្តេចបានខិតខំសន្សំទុកជាយូរមកនោះចុះ ។

ខ្ញុំព្រះករុណាខ្ញុំទាំងឡាយ បានជួនដំណើរសម្តេច ដល់ទីអាសន្ននេះសូមថ្វាយបង្គំលាសម្តេចហើយ ។

×

× +

ព្រះមហា ប៉ាង-ខាត់ រៀបរៀង

គុ. អ្នកកំចាត់ខ្លួចបាប ។ -គំស គុ. ដែលប្រាប់ខ្លួចបាប, ដែលលាងបាប ។ *អវោបយោគ* គុ (អឝ + ឧបយោគ) ដែលសម្អាប់បង់ខ្លួចបាប ។

អយ្យជិត គុ. ដែលមិនដាប់ខ្នា, ដែលមិនតគ្នា ។ -យជិត គុ. ដែលមិនតគ្នាខ្លះតគ្នាខ្លះ ។

អយ្យម៌ គុ. ដែលមិនក្តាំ. ត្រដាក់ ។ - ជាមន៑ បុ. "មានរស្មីត្រដាក់" ព្រះចន្ទ ។

អយោយុ នុ. កាច, យោរយៅ ។

អយោសកិ គុ. ដែលមានអាហារមិនមាន, ដែលមានស្បៀងមិនមាន ។

អរ្ជែណ គុ. ដែលឥតអាណិត · *អយ្ជណិន* គុ. ដែលឥតអាណិត។

អរោរ គុ. ដែលមិនយោរយៅ ។ -រោរវូប គុ. ដែលមានរូបមិនយោរយៅផងយោរយៅផង; បុ. ព្រះនិស្សរ ។ -បក្ខ្មស៑ គុ. ដែលមានក្បែរគួរភ្ញាច ។

អរ្ឃោត្ត ក.ន. អ្នកមិនអាំតក្ងិន ។

អរ្ឃេយ គុ. ដែលមិនគួរអាំតក្ងិន ។

អរ្ជុ ក្រ. រាប់, ត្រាទុក ។

អរ្ជុ បុ អង្គ, ត្រា, សំគាល់, គ្រឿងសំគាល់; ដោះ, ចរិត្តៈ; ដ៏រិត; ហ៊ាន; ឆ្លងដំនឹង; ជាកម្មសព្ទោន; ពួក, សួស្ស, លេខ; ការៈ ។ -ការ បុ. ដើងឯកដែលរើសតាំងសងខាង ដើម្បីយកឯកវត្ថា ។